# សម្មោហវិនោទនី

## អដ្ឋកថាព្រះអភិធម្មបិដក

## ទុតិយភាគ

## ៦

រចនាដោយព្រះពុទ្ធឃោសាចារ្យ

ផ្ដើមប្រែរៀបរៀងដោយខ្ញុំព្រះករុណាខ្ញុំបាទ សុជ្ឈ៍-សារៈម្សៀង

ព. ស. ២៥៥៧

# សម្មោហ

# វិនោទនី

# អដ្ឋកថា

# ព្រះអភិធម្ម

# បិដក

# ទុតិយភាគ

# ៦

ព. ស.

២៥៥៧

# សេចក្តីបញ្ជាក់

គម្ពីរ **អដ្ឋកថាព្រះអភិធម្ម** ជាពាក្យអធិប្បាយសេចក្តីក្នុងព្រះអភិ-ធម្មបិដក ចាត់ជាភាគធំៗ មាន ៣ ភាគ គឺ

**១.បឋមភាគ** ឈ្មោះ **អដ្ឋសាលិនី** អធិប្បាយគម្ពីរ ***ធម្មសង្គណី***

**២.ទុតិយភាគ** ឈ្មោះ **សម្មោហវិនោទនី** អធិប្បាយគម្ពីរ ***វិភង្គ***

**៣.តតិយភាគ** ឈ្មោះ **បរមត្ថទីបនី** អធិប្បាយគម្ពីរ ***បញ្ចបករណ៍***

តាំងពី ***ធាតុកថា*** រហូតដល់ចប់គម្ពីរ ***បដ្ឋាន*** ទាំងអស់ ។

បើចាត់ជាភាគតូចៗ មាន ១២ ភាគ ដោយបែងចែកចេញពីភាគធំៗ ទាំង ៣ ខាងលើនេះ ក្នុងមួយភាគៗ មាន ៤ លេខ ខុសគ្នាទៅនឹងការបោះពុម្ពមុនៗ ។ ឯសៀវភៅដែលលោកអ្នកកំពុងអាននេះ ជាគម្ពីរអដ្ឋ-កថា ***អភិធម្មបិដក ទុតិយភាគ ៦*** កើតឡើងដោយស្នាព្រះហស្ដនៃ ***ព្រះពុទ្ធឃោសាចារ្យ*** ជាជនជាតិឥណ្ឌា បានរចនានៅឯប្រទេសសិរីលង្កា ក្រោយការបរិនិព្វានរបស់ព្រះពុទ្ធជាង ៩០០ឆ្នាំ ។ ឯរូបខ្ញុំផ្ទាល់វិញគ្រាន់តែជាអ្នកផ្តើមប្រែសម្រួលរៀបរៀង ជាបណ្តោះអាសន្ន សម្រាប់អ្នកដែលត្រូវការសិក្សារៀនសូត្រតែប៉ុណ្ណោះ ព្រោះហេតុដូច្នេះ ខ្ញុំ***សូមបញ្ជាក់*** និងសូមទោសជាមុន ចំពោះអ្នកអាន និងអ្នកសិក្សាជាទីគោរពថា ខ្ញុំពុំមានសមត្ថភាពនៃការចេះដឹងគ្រប់គ្រាន់ ដូចសេចក្តីនៃធម៌ដែលមាននៅក្នុងសៀវភៅនេះទេ ថែមទាំងសមត្ថភាពនៃការប្រែសម្រួល និងរៀបរៀង

នេះទៀត មិនអាចគេចផុតពីការខុសឆ្គាំឆ្គងបានឡើយ ។ ការខុសឆ្គាំឆ្គងទាំងនុ៎ះ មានដោយអចេតនាខ្លះ ដោយការចេះមិនដល់ខ្លះ តែខ្ញុំយល់ឃើញថា **មានប្រសើរជាងគ្មាន** ព្រោះសៀវភៅដែលរៀននូវព្រះអភិធម្មបិដកបែបនេះ មិនទាន់ដែលមានគ្រប់គ្រាន់ក្នុងប្រទេសយើងទេ ដូច្នេះយើងក៏អាចឧទាហរណ៍បានថា ៖

* សម័យណា ដែលមានភាពអន្ធការ សូម្បីតែពន្លឺអំពិលអំពែក ក៏អាចភ្លឺបានដែរ ។

* សម័យណា គ្មានដើមឈើ គេក៏អាចយកដើមល្ហុង ធ្វើជាដើមឈើបានដែរ ។ ល ។ (ស្រីហិតោបទេស) ។

ព្រោះហេតុដូច្នេះ ខ្ញុំសូមផ្ញើនូវគម្ពីរនេះ ដល់លោកអ្នកសិក្សា និងវិញ្ញូជនទាំងឡាយ ជួយកែសម្រួល សម្រាប់សិក្សាតរៀងទៅ ។ ដើម្បីសម្រួលដល់ការបូកសរុបមតិកែតម្រូវ ក្នុងអត្ថបទនេះ សូមមេត្តាជ្រាបដូចតទៅ ៖

១-សូមសរសេរឈ្មោះ ទីកន្លែង និងថ្ងៃ ខែ ឆ្នាំ ដែលកែសម្រេចនៅលើក្រដាសដែលផ្ញើមក ។

២-ចុះលេខទំព័រ បន្ទាត់ ក្នុងតារាងលេខ ១ និងលេខ ២ ។ ចំពោះសេចក្តី ពាក្យ ឃ្លា ឬអក្ខរាវិរុទ្ធត្រង់ណា ដែលយល់ថា មិនទាន់ត្រឹមត្រូវ សូមសរសេរចុះក្នុងតារាងលេខ ៣ ។ ចំណែកពាក្យដែលយល់ថា គួរកែមកជាយ៉ាងណាវិញនោះ សូមសរសេរចុះក្នុងតារាងលេខ ៤ ។

៣-ប្រសិនបើ ការកែតម្រូវនោះ មានឯកសារបញ្ជាក់ សូមចុះឈ្មោះឯកសារនោះ ក្នុងតារាងលេខ ៥ ។

៤-នៅក្នុងតារាងលេខ ៦ សម្រាប់បញ្ជាក់បន្ថែម ចំពោះករណីពិសេសណា ដែលប្រាថ្នាចង់បញ្ជាក់បន្ថែម ។

៥-សូមផ្ញើកំណែមកខ្ញុំ ដោយការទាក់ទង តាមទូរសព្ទដែលមាននៅក្នុងសៀវភៅនេះស្រាប់ ។

* ប្រសិនបើ នៅក្នុងសៀវភៅនេះ មានការខុសទំព័រលេខរៀងអក្សរដាច់ ឬមើលមិនសូវច្បាស់ជាដើម នុ៎ះពុំមែនជាកំហុសនៃសំណៅដើមរបស់ខ្ញុំឡើយ ៕

ភ្នំពេញ, ថ្ងៃទី ១៨ ខែ ឧសភា ឆ្នាំ ២០១៣

ខ្ញុំព្រះករុណា ខ្ញុំបាទ **សុន្ទរ៍ សាមៀន**

សូមអរព្រះគុណ និងអរគុណ

# តារាងកែតម្រូវ "ឡ"

## នាមអ្នកជួយពិនិត្យផ្ទៀងផ្ទាត់កែសម្រួល

- *លោកធម្មបាល* **រិត សោរចន្ទ្រី** *(ខុទ្ទសាចារ្យសាលាបាលីនៅភ្នំពេញ )*
- *ភិក្ខុសាមណេរជាពហូសូតក្នុងវត្តធុតង្គ (ចំការដូង) មាន ១១ រូប*
- *ភិក្ខុសាមណេរជាពហូសូតក្នុងវត្តនិគ្រោធវ័ន (គល់ទទឹង) មាន ១០ រូប*

- *លោកខន្តិជាតិកោ* **ថៃ តិរម្យ**
- *ភិក្ខុ* **សាំ ចន្ធីរ**
- *ឧបាសក* **ស៊ីរេង វណ្ណា**
- *ឧបាសក* **ចុំវ សុខុម**
- *អ្នកគ្រូ* **ទី សុធី**
- *ឧបាសក* **ហាយ ចំរើន**
- *លោកធម្មរក្ខិតោ* **គង់ វន**
- *ឧបាសក* **សេម រឿយ**
- *ឧបាសិកា* **អ៊ឹង គីមរស់**
- *ឧបាសក* **រឿង ស៊ីសុគន្ធ**
- *ឧបាសិកា* **ចន្ធូ**
- *ឧបាសក* **ខៀវ ណារិន្ទ** ៕

## អ្នកមានឧបការៈក្នុងការរៀបរៀងធម្មទាននេះ

- *ធម្មាចារ្យមេត្តាបាលោ* **ទឹម សឿត**
- *ធម្មាចារ្យឱវាទរក្ខិតោ* **ហោគីមសាន្ត**
- *លោកគ្រូអគ្គបណ្ឌិត* **ប៊ុត សាវង្ស**
- *លោកបញ្ញាបទីបោ* **ព្រឿង ប៊ុនធឿន**
- *លោកខន្តិជាតិកោ* **ថៃ តិរម្យ**
- *លោកធម្មរក្ខិតោ* **គង់ វន**
- *ក្រុមទ្រទ្រង់ព្រះត្រៃបិដក មានលោក* **សួន ឱសថ** *ជាដើម*
- *ភិក្ខុសាមណេរ* **វត្តគីរីរម្យចាស់** *ជាដើម* - *លោក* **បាន សុផាន** *និងភរិយា*
- *លោក* ***រហេង សុវណ្ណារ៉ា*** - *ឧបាសក* ***ស្រេង ចាន់ណា*** *និងក្រុមគ្រួសារ*
- *ឧបាសក* ***ម៉ៅ ផុន*** *ហៅ* ***ពុយ*** *និងសហការី ។*

ខ្ញុំព្រះករុណា ខ្ញុំបាទ សូមអនុមោទនា ថ្លែងអំណរគុណយ៉ាងជ្រាលជ្រៅ ចំពោះសន្តានចិត្តដ៏ល្អរបស់គុណម្ចាស់ ញាតិញោមជាពុទ្ធបរិស័ទទាំងក្នុង និងក្រៅប្រទេស ដែលបានចំណាយពេលវេលាដ៏មានតម្លៃ ជួយពិនិត្យកែសម្រួល ព្រមទាំងចំណាយរូបិយវត្ថុជាដើម ដើម្បីជំរុញឲ្យអត្ថបទនៃគម្ពីរនេះ ចេញជារូបរាងឡើង ។

បន្ទាប់ពីទុតិយភាគ ៦ នេះទៅ ខ្ញុំនឹងដំណើរការបោះពុម្ពនូវទុតិយភាគ ៧ ជាបន្តទៀត ។

អាស្រ័យហេតុនេះ បើព្រះគុណម្ចាស់ ញាតិញោមត្រូវការចូលប្រាក់ដើម្បីថតចម្លងជាធម្មទាន ឬយកផ្ទាល់ខ្លួន ឬក៏យកទៅតម្កល់តាមវត្តនានា សូមមេត្តាទាក់ទងតាមរយៈទូរសព្ទដូចខាងក្រោមនេះ ៈ

០៩២ ៩០ ៨២ ៦៥

០៩៧ ២៣ ៣០ ២១៥

០១៦ ៨៦ ៥២ ៣៨

# ឧទ្ទិសកថា

*ខ្ញុំសូមផ្សាយនូវមហាកុសលធម្មទាននេះ ប្រគេន ថ្វាយ ជូន ចំពោះ សម្តេចព្រះសង្ឃរាជទាំងពីរគណៈ, ព្រះថេរានុត្ថេរៈគ្រប់រូប ទាំងក្នុង ទាំងក្រៅ ប្រទេស, **អតីតព្រះមហាក្សត្រ ព្រះមហាក្សត្រក្នុងបច្ចុប្បន្ន** រាជរដ្ឋាភិបាល ដែលមានសម្តេចតេជោ **ហ៊ុន សែន** ជាប្រមុខ និងមន្ត្រីរាជការគ្រប់ៗ ស្ថាប័ន, ព្រមទាំងពុទ្ធបរិស័ទទាំងក្នុងប្រទេស ទាំងក្រៅប្រទេស មានលោក គ្រូអគ្គបណ្ឌិត **ប៊ុត សាវង្ស** ជាដើម មួយអន្លើដោយសព្វសត្វទាំងអស់ សូម ទ្រង់ត្រេកអរ និងត្រេកអរ អនុមោទនា យកចំណែកបុណ្យធម្មទាននេះ គ្រប់ៗ រូប គ្រប់ៗ អង្គ គ្រប់ៗ គ្នា កុំបីខានឡើយ ។*

***ដោយអំណាចនៃមហាកុសលធម្មទាននេះ សូមឱ្យ ៖***

***-សត្វទាំងឡាយ កុំមានពៀរនឹងគ្នា មានតែសេចក្តីសុខ កុំមានទុក្ខ***

***-សត្វទាំងឡាយ កុំព្យាបាទគ្នា កុំមានការចង្អៀតចង្អល់នឹងគ្នា***

***-សត្វទាំងឡាយ មានអាយុវែង សម្រេចដោយសម្បត្តិទាំងឡាយ***

***-សត្វទាំងឡាយ រក្សានូវខ្លួន ឱ្យបានជាសុខតរៀងទៅ ៕***

................................................................................................................................................

តារាងកែតម្រូវ

អដ្ឋកថាទុតិយភាគ ៦

សម្រាប់បោះពុម្ពលើទី ៣

ថ្ងៃទី ....... ខែ ..... ឆ្នាំ ...

ឈ្មោះ .......................

អាសយដ្ឋាន .................

| ទំព័រ | បន្ទាត់ | ពាក្យខុស | ពាក្យត្រូវ | ឯកសារយោង | សេចក្ដីផ្សេងៗ |
|---|---|---|---|---|---|
| | | | | | |

~ញ្ញី~

# សម្មោហវិនោទនី

## អដ្ឋកថាព្រះអភិធម្មបិដក

## ទុតិយភាគ ៦

**មាតិកាចម៌** **ទំព័រ**

## ៦. អដ្ឋកថាបដិច្ចសមុប្បាទវិភង្គ

**ពណ៌នាអំពីសុត្តន្តភាជនិយ**


សម្តែងអំពីនិទ្ទេសវារៈ ..... .... ..... ..... .... .... .... .... .... .... .... ..... ១

សម្តែងអំពីការវិនិច្ឆ័យដោយសេចក្តីផ្សេងគ្នានៃទេសនា ..... ..... .... .... ៣

សម្តែងអំពីបដិច្ចសមុប្បាទយ៉ាងទី ១ .... .... ..... ..... ..... ..... ..... ..... ៤

សម្តែងអំពីបដិច្ចសមុប្បាទយ៉ាងទី ២ ..... .... ..... ..... ..... ..... ..... .... ៤

សម្តែងអំពីបដិច្ចសមុប្បាទយ៉ាងទី ៣ ..... ..... ..... ..... ..... ..... .... ... ៥

សម្តែងអំពីបដិច្ចសមុប្បាទយ៉ាងទី ៤ ..... ..... ..... ..... ..... ..... .... .... ៦

សម្តែងអំពីការវិនិច្ឆ័យដោយអត្ថ ..... ..... ..... .... .... .... .... .... .... ១២

សម្តែងអំពីការវិនិច្ឆ័យដោយលក្ខណៈជាដើម ..... ..... ..... .... .... .... ២០

សម្តែងអំពីការវិនិច្ឆ័យដោយមានតែម្យ៉ាងជាដើម ..... ..... ..... ...... ២៤

សម្តែងអំពីការវិនិច្ឆ័យដោយការកំណត់អង្គ .... .... .... .... .... ... ២៦

សម្តែងអំពីនិទ្ទេសនៃអវិជ្ជា .... .... .... .... ..... ..... ..... ..... ..... .... ២៧

**អវិជ្ជាមានលក្ខណៈ ២៥** ..... ...... ..... .... ..... ..... ..... ..... ..... ..... ៣០

សម្តែងអំពីសង្ខារនិទ្ទេស ..... ..... ..... ..... ..... ..... ..... .... .... .... ៣៦

សម្តែងអំពីបុញ្ញាភិសង្ខារ ..... ..... ..... ..... ..... ..... ..... .... .... .... ៣៨

**មាតិកាធម៌** **ទំព័រ**

សម្តែងអំពីអបុញ្ញាភិសង្ខារ .... .... .... .... .... .... .... .... .... ..... .... ៤០
សម្តែងអំពីអានេញ្ជាភិសង្ខារ .... .... .... .... .... ..... ..... ..... .... ..... ៤០
សម្តែងអំពីទ្វារនៃកម្ម .... .... .... .... .... .... .... .... .... .... .... ..... ៤២
សម្តែងអំពីសម្បយោគនៃអភិសង្ខារ ៣ ..... ..... ..... ..... .... ..... ... ៤៣
សម្តែងអំពីសង្ខារមានអវិជ្ជាជាបច្ច័យ តើដូចម្តេច ? ..... ..... ..... ..... ៤៤
សម្តែងអំពីអវិជ្ជាជាបច្ច័យដល់សង្ខារ តើដូចម្តេច ? ...... ..... ..... ..... ៤៧
សម្តែងអំពីអវិជ្ជាជាបច្ច័យដល់សង្ខារម្យ៉ាងទៀត ...... ...... ..... ...... ៥៤
សម្តែងអំពីនិទ្ទេសនៃសង្ខារជាបច្ច័យដល់វិញ្ញាណ ..... ..... .... ..... .... ៥៦
សម្តែងអំពីបវត្តិវិញ្ញាណ ២ យ៉ាង ...... .... .... .... .... .... ...... ..... .. ៦០

**វិញ្ញាណក្នុងបញ្ចវោការភពក្នុងបវត្តិកាល ១៣ ដួង**

សម្តែងអំពីចិត្តក្នុងបវត្តិកាល និងបដិសន្ធិកាលក្នុងភពបី ១៩ ដួង ..... ៦២
សម្តែងអំពីហេតុដែលតទារម្មណ៍មិនប្រព្រឹត្តទៅក្នុងរូបភូមិ និងអរូបភូមិ ៦៤
សម្តែងអំពីបដិសន្ធិ ២០ ប្រភេទ .... .... .... .... ..... .... .... ..... ៦៧
សម្តែងអំពីអារម្មណ៍របស់បដិសន្ធិ ៣ យ៉ាង .... .... .... ..... ..... ....... ៦៧
រឿងនាយគោបកសីវលី .... .... .... .... .... .... .... ..... ..... .... ...... ៦៨
រឿងការស្លាប់របស់អ្នកវង្វេង .... .... .... .... .... .... .... ...... .... .... ៦៨
វិនិច្ឆ័យរឿងស្លាប់ទាន់ហន់ ..... .... .... .... .... .... .... ..... .... .... .... ៦៩
បដិសន្ធិមានអារម្មណ៍អតីតៈ តពីចុតិមានអារម្មណ៍អតីតៈ ...... .... ... ៧១
បដិសន្ធិមានអារម្មណ៍បច្ចុប្បន្ន តពីចុតិមានអារម្មណ៍អតីតៈ ...... ...... ៧២
បដិសន្ធិមានអារម្មណ៍អតីតៈ និងបច្ចុប្បន្នក្នុងលំដាប់នៃចុតិ

# សម្រាហវិនោទនី


មានអារម្មណ៍ជាអតីតៈ ..... ..... ..... ..... ..... ..... ..... ..... ៧៣

បដិសន្ធិមានអារម្មណ៍អតីតៈ ឬនវត្តព្វៈ ក្នុងលំដាប់នៃចុតិ

មានអារម្មណ៍ជាអតីតៈ ..... ..... ..... ..... ..... ..... ..... ..... ..... ... ៧៤

បដិសន្ធិមានអារម្មណ៍បច្ចុប្បន្ន តពីចុតិមានអារម្មណ៍ជាអតីតៈ ..... ... ៧៥

បដិសន្ធិមានអារម្មណ៍ ៣ យ៉ាងណានីមួយ មានអារម្មណ៍

ដែលមិនគប្បីពោល .... .... ..... ..... ..... ..... ..... ..... ..... ..... ..... ៧៦

បដិសន្ធិមានអារម្មណ៍អតីតៈ និងបច្ចុប្បន្ន តពីចុតិមានអារម្មណ៍អតីតៈ ៧៧

សម្តែងអំពីចុតិវិញ្ញាណ និងបដិសន្ធិវិញ្ញាណ ..... ..... ..... ..... ..... .... ៨៤

សម្តែងអំពីបុញ្ញាភិសង្ខារជាបច្ច័យ ..... ..... ..... ..... ..... .... ..... ..... ៩០

សម្តែងអំពីអបុញ្ញាភិសង្ខារជាបច្ច័យ ...... ..... ..... ..... ..... ..... ..... ៩១

សម្តែងអំពីអនេញ្ជាភិសង្ខារជាបច្ច័យ .... .... .... .... ..... .... ..... ..... ៩២

សម្តែងអំពីកាយសង្ខារ ២០ ដួង ជាបច្ច័យ ..... ..... ..... ..... ..... ..... ៩២

សម្តែងអំពីចិត្តសង្ខារ ១៩ ដួង ជាបច្ច័យ ...... .... .... .... .... ..... ..... ៩២

សម្តែងអំពីសង្ខារជាបច្ច័យដល់វិញ្ញាណ ...... .... .... .... ..... ..... ..... ៩៣

សម្តែងអំពីនាមរូបនិទ្ទេស ...... ..... ..... ..... ..... ..... .... .... ..... .... ៩៦

សម្តែងអំពីការវិនិច្ឆ័យដោយប្រភេទនៃទេសនា ...... ..... ..... ..... .... ៩៦

សម្តែងអំពីការវិនិច្ឆ័យដោយសេចក្តីប្រព្រឹត្តទៅក្នុងភពជាដើម .... .... ៩៧

សម្តែងអំពីការវិនិច្ឆ័យដោយសង្គ្រោះ ...... .... .... ..... ..... .... ..... ១០២

សម្តែងអំពីការវិនិច្ឆ័យដោយបច្ច័យ ..... .... .... .... .... ..... .... .... ១០៣

សម្តែងអំពីសឡាយតននិទ្ទេស .... .... ..... .... ..... .... ..... .... ..... ១០៦

**មាតិកាធម៌** **ទំព័រ**

សម្តែងអំពីនាមជាបច្ច័យដល់អាយតនៈ ..... ..... ..... ..... ..... ..... ១០៧
សម្តែងអំពីរូបជាបច្ច័យដល់អាយតនៈ ...... ..... ..... ..... ..... .... ១១០
សម្តែងអំពីនាមរូបជាបច្ច័យដល់អាយតនៈ ...... ..... ..... ..... ..... ១១២
សម្តែងអំពីផស្សនិទ្ទេស ..... ..... ..... ..... .... .... .... ..... ..... .... ១១៣
សម្តែងអំពីសឡាយតនៈជាបច្ច័យដល់ផស្សៈ .... ..... ..... .... .... ១១៣
សម្តែងអំពីវេទនានិទ្ទេស ...... .... .... .... .... .... .... ..... ..... ..... ១១៧
សម្តែងអំពីតណ្ហានិទ្ទេស ...... .... .... .... .... .... .... .... .... ... .... ១១៨
សម្តែងអំពីតណ្ហា ១៨ យ៉ាង (ជាតណ្ហា ១០៨) ..... ..... ..... ..... ១១៩
សម្តែងអំពីសុខវេទនាដែលមានវិបាកជាបច្ច័យ ..... ..... ..... ..... ១២០
សម្តែងអំពីវេទនា ៣ ជាបច្ច័យ ...... .... .... .... .... .... .... ... .... ១២១
សម្តែងអំពីឧបាទាននិទ្ទេស ..... .... .... .... .... .... .... ... ... ... .... ១២២
សម្តែងអំពីការចែកដោយអត្ថ .... .... .... .... .... .... .... .... .. ១២៣
សម្តែងអំពីសេចក្តីសង្ខេប និងសេចក្តីពិស្តារនៃធម៌ ...... .... .... .... ១២៣
មតិរបស់អាចារ្យពួកខ្លះ ..... .... .... .... .... .... .... .... .... ..... .... ១២៤
សម្តែងអំពីលំដាប់ ៣ យ៉ាង ..... .... .... .... .... .... .... .... .... .... ១២៥
សម្តែងអំពីតណ្ហាជាបច្ច័យដល់ឧបាទាន ...... .... .... .... .... .... .... ១២៧
សម្តែងអំពីភវនិទ្ទេស ...... .... .... .... .... .... .... .... ... .. .... ..... ១២៨
សម្តែងអំពីនិទ្ទេសនៃជាតិ ..... ..... ..... ..... ..... ..... ..... ..... .... ១៣៨
អធិប្បាយភវចក្រ ១២ ..... ..... ..... ..... ..... ..... ..... ..... ..... ... ១៤០
អធិប្បាយកាល ៣ ..... ..... ..... ..... .... .... ..... ..... ..... ..... ១៤៦

# សម្មោហវិនោទនី

អធិប្បាយសន្ធិ ៣ ..... ..... ..... ..... ..... ..... ..... ..... ..... ..... .... ១៤៦
អធិប្បាយសង្គហៈ ៤ ..... ..... ..... ..... ..... ..... ..... ..... ..... ..... ១៤៧
អធិប្បាយអាការៈ ២០ ..... ..... ..... ..... ..... ..... ..... ..... ..... ១៤៧
គប្បីជ្រាបសេចក្តីជាសច្ចៈ និងជាដែនកើតមាន ..... ..... ..... ..... .... ១៤៤
គប្បីជ្រាបសេចក្តីជាភវចក្រដោយកិច្ច .... .... .... ..... ..... ..... .... ១៤៥
គប្បីជ្រាបសេចក្តីជាភវចក្រដោយការហាម ..... ..... ..... .... .... ១៤៦
គប្បីជ្រាបសេចក្តីជាភវចក្រដោយការឧបមា ..... ..... ..... ..... ..... ១៤៦
គប្បីជ្រាបសេចក្តីជាភវចក្រដោយប្រភេទនៃសេចក្តីជ្រាលជ្រៅ ..... ១៤៨
គប្បីជ្រាបសេចក្តីជាភវចក្រដោយប្រភេទរបស់ន័យ ..... ..... ..... ១៥២
ពណ៌នាអំពីអភិធម្មភាជនិយ ..... ..... ..... ..... ..... ..... ..... ..... ១៥៥
អធិប្បាយន័យរបស់មាតិកាមានអវិជ្ជាជាមូល ..... ..... ..... ...... ១៥៥
សម្តែងអំពីបច្ច័យចតុក្កៈ ..... ..... ..... ..... ..... ..... ..... ..... ..... ១៥៦
សម្តែងអំពីសេចក្តីផ្សេងគ្នាក្នុងវារៈទី ២ ..... ..... ..... ..... .... ..... ១៦៣
សម្តែងអំពីសេចក្តីផ្សេងគ្នាក្នុងវារៈទី ៣ ..... ..... ..... ..... ..... ..... ១៦៤
សម្តែងអំពីសេចក្តីផ្សេងគ្នាក្នុងវារៈទី ៤ ..... ..... ..... ..... ..... ..... ១៦៦
សម្តែងអំពីហេតុចតុក្កៈ ..... ..... ..... ..... ..... .... ..... ..... ..... ១៦៨
សម្តែងអំពីសម្បយុត្តចតុក្កៈ ..... ..... ..... ..... ..... ..... ..... ..... ១៧១
សម្តែងអំពីអញ្ញមញ្ញចតុក្កៈ ..... ..... ..... ..... ..... ..... ..... ..... ... ១៧២
អធិប្បាយន័យរបស់មាតិកាមានសង្ខារជាមូលជាដើម ..... ..... ..... ១៧៣
សម្តែងអំពីចតុក្កនិទ្ទេសទី ១ ..... ..... ..... ..... ..... ..... ..... ..... ១៧៣

**មាតិកាធម៌** **ទំព័រ**

អធិប្បាយអកុសលនៃចតុក្កនិទ្ទេសទី ១ ..... ..... ..... ..... ..... ..... ១៧៥

ចតុក្កនិទ្ទេសទី ២ ..... ..... ..... ..... ..... ..... ..... ..... ..... ១៧៧

ចតុក្កនិទ្ទេសទី ៣ ..... ..... ..... ..... ..... ..... ..... ..... ..... ..... ១៧៧

ចតុក្កនិទ្ទេសទី ៤ ..... ..... ..... ..... ..... ..... ..... ..... ..... ....... ១៧៨

អធិប្បាយកុសលនិទ្ទេស ..... ...... ...... ...... ..... ..... ..... ..... ...... ១៨០

អធិប្បាយអព្យាកតនិទ្ទេស ..... ..... ..... ...... ..... ..... ..... ..... ..... ....... ១៨១

អវិជ្ជាមូលកកុសលនិទ្ទេស .... .... .... ...... ..... ..... ..... ..... ..... ..... ..... ១៨៣

សម្តែងអំពីកុសលនិទ្ទេសម្យ៉ាងទៀត ..... ..... ..... .... ..... .... ១៨៣

អកុសលមូលវិបាកនិទ្ទេស ..... ..... ..... ...... ..... ..... ..... ..... .... ១៨៥

សម្តែងអំពីអកុសលវិបាកចិត្ត ៧ .... ..... ..... .... ..... ..... ..... ..... ១៨៥

## ៧. អដ្ឋកថាសតិប្បដ្ឋានវិភង្គ

ពណ៌នាអំពីសុត្តន្តភាជនិយ ..... ..... .... ...... .... ..... ...... ..... .... ១៨៩

សតិប្បដ្ឋានតាមន័យរបស់បករណ៍ ..... ..... ..... ..... ..... ..... ..... ១៩២

ន័យរបស់អដ្ឋកថា ..... ..... ..... ..... ..... ..... ..... ..... ..... ..... ១៩៣

កាយានុបស្សនានិទ្ទេស ឧទ្ទេសវារកថា ..... ..... ..... ..... ..... ..... ..... ...... ១៩៥

អធិប្បាយពាក្យថា **ឥធ ភិក្ខុ** .... ..... ..... ..... ..... ..... ..... ..... ១៩៥

អធិប្បាយពាក្យថា **អជ្ឈត្តំ កាយេ** ..... ..... ..... ..... ..... ..... ..... ១៩៦

អធិប្បាយពាក្យថា **កាយេ កាយានុបស្សី** ..... ...... ..... ...... ...... ១៩៧

អធិប្បាយពាក្យថា **វិហរតិ** ..... ..... ..... ..... ..... ..... ..... ..... ... ២០២

# សម្មោហវិនោទនី


អធិប្បាយពាក្យថា **ពហិទ្ធា កាយេ** ជាអាទិ៍ ..... ..... .... ..... .... ២០២

អធិប្បាយពាក្យថា **អាតាបី សម្បជានោ សតិមា** ..... ..... .... ... ២០៣

អធិប្បាយពាក្យថា **វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ** ..... .... ២០៤

ពណ៌នាអំពីអត្ថនៃវេទនានុបស្សនានិទ្ទេសជាដើម ..... ..... ..... .... ២០៦

និទ្ទេសវារកថា (ពណ៌នាអំពីកាយានុបស្សនា) ..... ..... ..... ..... .... ២០៩

កម្មដ្ឋានពោលដោយអំណាចនៃសមថៈឧគ្គហកោសល្យ ..... ..... .... ២១២

**វចសា** ប្រាប់ដោយវាចា ..... ..... ..... ..... ..... ..... ..... ..... ..... ២១៣

គប្បីស្វាធ្យាយដោយវាចា ..... ..... ..... ..... ..... ..... ..... ..... ២១៤

**វចសា** (វិធីស្វាធ្យាយដោយវាចា) ..... ..... ..... ..... ..... ..... ២១៥

**មនសា** (វិធីស្វាធ្យាយដោយចិត្ត) ..... ..... ..... ..... ..... ..... ២១៧

**វណ្ណតោទិ** (កំណត់ដោយពណ៌ជាដើម) ..... ..... ..... ..... ..... ២១៧

ខគួរជ្រាបមុននឹងប្រាប់ឧគ្គហកោសល្យ ..... ..... ...... ...... ..... ២១៨

មនសិការកោសល្ល ១០ ..... ..... ..... ...... ..... ..... ..... ..... ..... ២១៩

មនសិការដោយលំដាប់ ..... ..... ..... ..... ..... ..... ..... ..... ...... ២២០

មនសិការដោយមិនប្រញាប់ពេក ..... ..... ..... ..... ..... ..... ..... ២២០

មនសិការដោយមិនយឺតពេក ..... ..... ..... ..... ..... ..... ..... ..... ២២១

មនសិការដោយហាមឃាត់ការរវើរវាយ ..... ..... ..... ..... ..... ២២១

មនសិការដោយការឈានកន្លងបញ្ញត្តិ ..... ..... ..... ..... ..... ..... ២២១

មនសិការដោយការបណ្តោយតាមលំដាប់ ..... ..... ..... ..... ..... ២២២

ការឧបមា និងឧបមេយ្យ ..... ..... ..... ..... ..... ..... ..... ..... ២២៣

**មាតិកាធម៌** **ទំព័រ**

ដោយអប្បនា ..... ..... ..... ..... ..... ..... ..... ..... ..... ..... ២២៥
ដោយសុត្តន្ត ៣ ..... ..... ..... ..... ..... ..... ..... ..... ..... ..... ២២៥
អធិចិត្តសូត្រ ..... ..... ..... ..... ..... ..... ..... ..... ..... ..... ២២៥
សីតិភាវសូត្រ ..... ..... ..... ..... ..... ..... ..... ..... ..... ..... ២២៧
ពោជ្ឈង្គកោសល្លសូត្រ ..... ..... ..... ..... ..... ...... ..... ...... ២២៨

## អាការៈ ៣២ យ៉ាង

១. **កេសា** (សក់ទាំងឡាយ) ..... ..... ..... ..... ..... ..... ..... ២២៩
២. **លោមា** (រោមទាំងឡាយ) ..... ...... ...... ...... ..... ..... ២៣២
៣. **នខា** (ក្រចកទាំងឡាយ) ..... ..... ..... ..... ..... ..... .... ២៣៣
៤. **ទន្តា** (ធ្មេញទាំងឡាយ) ..... ..... ..... ..... ...... ..... ..... ២៣៤
៥. **តចោ** (ស្បែក) ..... ..... ..... ..... ..... ..... ..... ..... ..... ២៣៥
៦. **មំសំ** (សាច់) ..... ..... ..... ..... ..... ..... ..... ..... ..... ..... ... ២៣៧
៧. **នហារូ** (សរសៃទាំងឡាយ) ..... ..... ..... ..... ..... ..... ..... ២៣៨
៨. **អដ្ឋិ** (ឆ្អឹងទាំងឡាយ) ..... ..... ..... ..... ..... ..... ..... ..... ..... ២៤០
៩. **អដ្ឋិមិញ្ជំ** (ខួរក្នុងឆ្អឹង) ..... ..... ..... ..... ..... ..... ..... ..... .... ២៤៤
១០. **វក្កំ** (ទាច) ..... ..... ..... ..... ..... ..... ..... ..... ..... ..... .... ២៤៥
១១. **ហទយំ** (បេះដូង) ..... ..... ..... ..... ..... ..... .... ..... .... ២៤៦
១២. **យកនំ** (ថ្លើម) ..... ..... ..... ..... ..... ..... ..... ..... ..... ២៤៧
១៣. **កិលោមកំ** (វាវ) ..... ..... ..... ..... ..... ..... ..... ..... ២៤៧
១៤. **បិហកំ** (ក្រពះ) ..... ..... ..... ..... ...... ...... ..... ..... ២៤៨

# សម្មោហវិនោទនី


១៥. **បប្ផាសំ** (ស្ងួត) ..... ..... ..... ..... ..... ..... ..... ..... .. ២៤៨

១៦. **អន្តំ** (ពោះវៀនធំ) ..... ..... ..... ..... ..... ..... ..... ..... ..... ២៤៩

១៧. **អន្តគុណំ** (ពោះវៀនតូច) ..... ..... ..... ..... ..... ..... ..... .. ២៥០

១៨. **ឧទរិយំ** (អាហារថ្មី) ..... ..... ..... ..... ..... ..... ..... ..... ..... ២៥០

១៩. **ករីសំ** (អាហារចាស់) ...... ...... ..... ..... ..... ..... ..... ២៥៣

២០. **មត្ថលុង្គំ** (ខួរក្នុងក្បាល) ..... ..... ..... ..... ..... ..... ..... .... ២៥៤

២១. **បិត្តំ** (ទឹកប្រមាត់) ..... ..... ..... ..... ..... ..... ...... ..... ..... ២៥៤

២២. **សេម្ហំ** (ស្លេស្ម) .... ..... ..... ..... ..... ..... ..... ..... ..... ..... ២៥៥

២៣. **បុព្វោ** (ខ្ទុះ) ..... ..... ..... ..... ..... ..... ..... ..... ..... ..... .. ២៥៦

២៤. **លោហិតំ** (ឈាម) ..... ..... ..... ..... ..... ..... ..... ..... ..... ២៥៧

២៥. **សេទោ** (ញើស) ..... ..... ..... ..... ..... ..... ..... ..... ..... ២៥៨

២៦. **មេទោ** (ខ្លាញ់ខាប់) ..... ..... ..... ..... ..... ..... ..... ..... ..... ២៥៩

២៧. **អស្សុ** (ទឹកភ្នែក) ..... ..... ..... ..... ..... ..... ..... ..... ..... ២៦០

២៨. **វសា** (ខ្លាញ់រាវ) ..... ..... ..... ..... ..... ..... ..... ..... ..... .. ២៦១

២៩. **ខេឡោ** (ទឹកមាត់) ..... ..... ..... ..... ..... ..... ..... ..... ..... ២៦១

៣០. **សិង្ឃាណិកា** (ទឹកសំបោរ) ..... ..... ..... ..... ..... ..... ..... ២៦២

៣១. **លសិកា** (ទឹករំអិល) ..... ..... ..... ..... ..... ..... ..... ..... ២៦៣

៣២. **មុត្តំ** (ទឹកមូត្រ) ..... ..... ..... ..... ..... ..... ..... ..... ..... ... ២៦៤

កម្មដ្ឋានកថាសម្តែងដោយអំណាចនៃសាធារណី ...... ..... ..... ..... ២៦៩

ប្រាប់ការកំណត់ នឹងជាទោសដូចម្តេច ? ..... ..... ..... ..... ..... .... ២៧១

**មាតិកាធម៌** **ទំព័រ**

តើអាចារ្យគប្បីប្រាប់ដូចម្ដេច ? ..... ..... ..... ..... ..... ..... ..... ..... ២៧២
ការប្រាកដនៃកោដ្ឋាសៈ ..... ..... ..... ..... ..... ..... ..... ..... ..... ២៧៣
គប្បីជ្រាបសេចក្ដីឧបមាដូច្នេះ ..... ..... ..... ..... ..... ..... ..... ..... ២៨៤
សេចក្ដីនេះគប្បីជ្រាបការឧបមានោះឯង ឱ្យប្រព្រឹត្តទៅដោយសព្វគ្រប់យ៉ាងនេះថា ..... ..... ..... ..... ..... ..... ..... ..... ..... ..... ..... ..... ២៨៥
សម្ដែងអំពីនិមិត្តជាដើម ..... ..... ..... ..... ..... ..... ..... ..... ..... ២៩២
អដ្ឋកថាវេទនានុបស្សនានិទ្ទេស ..... ..... ..... ..... ..... ..... ..... ..... ..... ២៩៩
អដ្ឋកថាចិត្តានុបស្សនានិទ្ទេស ..... ..... ..... ..... ..... ..... ..... ..... ..... ៣០៨
អដ្ឋកថាធម្មានុបស្សនានិទ្ទេស ..... ..... ..... ..... ..... ..... ..... ..... ..... ..... ៣១០
អដ្ឋកថានីវរណបព្វៈ ..... ..... ..... ...... ..... ..... ..... ..... ..... ..... ..... ..... ៣១១
អដ្ឋកថាពោជ្ឈង្គបព្វៈ ..... ..... ..... ..... ..... ..... ..... ..... ..... ..... ៣២៣
សតិសម្ពោជ្ឈង្គ ..... ..... ..... ..... ..... ..... ..... ..... ..... ..... ..... ៣២៣
ធម្មវិចយសម្ពោជ្ឈង្គ ..... ..... ..... ..... ..... ..... ..... ..... ..... ៣២៤
វិរិយសម្ពោជ្ឈង្គ ..... ..... ..... ..... ..... ..... ..... ..... ..... ..... ..... ៣២៩
បីតិសម្ពោជ្ឈង្គ ..... ..... ..... ..... ..... ..... ..... ..... ..... ..... ..... ៣៣៦
បស្សទ្ធិសម្ពោជ្ឈង្គ ..... ..... ..... ..... ..... ..... ..... ..... ..... ..... ... ៣៣៩
សមាធិសម្ពោជ្ឈង្គ ... ..... ..... ..... ..... ..... ..... ..... ..... ..... ..... ៣៤១
ឧបេក្ខាសម្ពោជ្ឈង្គ ..... ..... ..... ..... ..... ..... ..... ..... ..... ៣៤៣
ពណ៌នាអំពីអភិធម្មភាជនិយ ..... ..... ..... ..... ..... ..... ..... ..... ៣៤៨
ពណ៌នាអំពីបញ្ហាបុច្ឆកៈ ..... ..... ..... ..... ..... ..... ..... ..... ៣៥០

# អក្សរសង្ខេប
## ដែលប្រើក្នុងអដ្ឋកថាខុទ្ទកនិកាយ ភាគ ៦ នេះ

| | | |
|---|---|---|
| អភិ. | = | អភិធម្មបិដក |
| អភិ. វិ. | = | អភិធម្មបិដក វិភង្គ |
| អំ. ចតុក្ក. | = | អង្គុត្តរនិកាយ ចតុក្កនិបាត |
| អំ. ឆក្ក. | = | អង្គុត្តរនិកាយ ឆក្កនិបាត |
| អំ. តិក. | = | អង្គុត្តរនិកាយ តិកនិបាត |
| អំ. ទសក. | = | អង្គុត្តរនិកាយ ទសកនិបាត |
| ខុ. ថេរ. | = | ខុទ្ទកនិកាយ ថេរគាថា |
| ខុ. ធ. | = | ខុទ្ទកនិកាយ ធម្មបទ |
| ខុ. បដិ. | = | ខុទ្ទកនិកាយ បដិសម្ភិទាមគ្គ |
| ខុ. មហា. | = | ខុទ្ទកនិកាយ មហានិទ្ទេស |
| ខុ. សុត្ត. | = | ខុទ្ទកនិកាយ សុត្តនិបាត |
| ទី. ម. | = | ទីឃនិកាយ មហាវគ្គ |
| ទី. មហា. | = | ទីឃនិកាយ មហាវគ្គ |
| ទី. សី. | = | ទីឃនិកាយ សីលក្ខន្ធវគ្គ |
| ម. ឧ. | = | មជ្ឈិមនិកាយ ឧបរិបណ្ណាសកៈ |
| ម. ម. | = | មជ្ឈិមនិកាយ មជ្ឈិមបណ្ណាសកៈ |

# អក្សរសង្ខេប

| | | |
|---|---|---|
| ម. មូ. | = | មជ្ឈិមនិកាយ មូលបណ្ណាសកៈ |
| វិនយ. | = | វិនយបិដក |
| វិសុទ្ធិ. | = | វិសុទ្ធិមគ្គ |
| សំ. ខ. | = | សំយុត្តនិកាយ ខន្ធវារវគ្គ |
| សំ. និ. | = | សំយុត្តនិកាយ និទានវគ្គ |
| សំ. សឡា. | = | សំយុត្តនិកាយ សឡាយតនវគ្គ |
| សំ. ស. | = | សំយុត្តនិកាយ សគាថវគ្គ |
| សំ. ម. | = | សំយុត្តនិកាយ មហាវារវគ្គ ។ |

# សម្មោហវិនោទនី

## អដ្ឋកថាព្រះអភិធម្មបិដក

### ឈ្មោះ វិភង្គប្បករណ៍

### ទុតិយភាគ ៦

ព. ស. ២៥៥៧

# សម្មោហវិនោទនី

# អដ្ឋកថាព្រះអភិធម្មបិដក

# ទុតិយភាគ ៦

### នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។

## ៦. អដ្ឋកថាបដិច្ចសមុប្បាទវិភង្គ [១]

### ពណ៌នាអំពីសុត្តន្តភាជនិយ

### សម្តែងអំពីនិទ្ទេសវារៈ

គប្បីជ្រាបវិនិច្ឆ័យក្នុងបដិច្ចសមុប្បាទវិភង្គ ដែលជាលំដាប់តអំពីឥន្ទ្រិយវិភង្គតទៅ ៖

ព្រះបាលីតន្តិ (បែបផែន) នេះឯង ដែលព្រះមានព្រះភាគជាម្ចាស់ទ្រង់តាំងទុកដោយន័យមានជាអាទិ៍ថា **"អវិជ្ជាបច្ចយា សង្ខារា** = សង្ខារកើតមានព្រោះអវិជ្ជាជាបច្ច័យ" , ដែលកុលបុត្រអ្នកនឹងធ្វើការសំវណ្ណនាសេចក្តីនៃព្រះបាលីនោះ គប្បីចូលទៅកាន់ទីប្រជុំពុទ្ធសាវ័កអ្នកជាវិភជ្ជវាទី គប្បីជាអ្នកមិនពោលបំផ្លើស (មួលបង្កាច់) ពាក្យអាចារ្យ មិនលំអៀងទៅកាន់លទ្ធិរបស់ខ្លួន ទាំងមិនកង្វល់លទ្ធិដទៃ មិនបដិសេធព្រះសូត្រ ស្របតាមព្រះវិន័យ ពិចារណាមើលមហាបទេស (ហើយ)

---

[១] ព្រះបាលីជា បច្ចយាការវិភង្គ ។

សម្តែងធម៌ (បដិច្ចសមុប្បាទ) រួបរួមអត្ថ មិនផ្លាស់ប្តូរអត្ថ នឹងសម្តែងបរិយាយ សូម្បីយ៉ាងដទៃ ទើបសមគួរធ្វើការសំវណ្ណនាសេចក្តីតាមព្រះបាលីចុះ ។

ម្យ៉ាងការសំវណ្ណនាសេចក្តីនៃបដិច្ចសមុប្បាទនេះ សូម្បីដោយប្រក្រតី ក៏ជារឿងដែលធ្វើបានដោយលំបាក; ដូចយ៉ាងដែលព្រះបុរាណាចារ្យទាំងឡាយពោលទុកថា ៖

**“សច្ចំ សត្តោ បដិសន្ធិ បច្ចយាការមេវ ច**
**ទុទ្ទសា ចតុរោ ធម្មា ទេសេតុញ្ច សុទុក្ករា**

ធម៌ ៤ យ៉ាង គឺ សច្ចៈ ១ សត្តប្បញ្ញត្តិ ១
បដិសន្ធិ ១ បច្ចយាការ ១ ជាធម៌ឃើញបានដោយ
លំបាក និងសម្តែងបានដោយសែនលំបាក” ។

ព្រោះហេតុដូច្នោះ ការសំវណ្ណនាសេចក្តីនៃបដិច្ចសមុប្បាទ ទើបធ្វើមិនបានដោយងាយ វៀរលែងតែលោកបានសម្រេចបរិយត្តិ និងអ្នកបានសម្រេចមគ្គផលទាំងឡាយហើយប៉ុណ្ណោះ ។

ខ្ញុំ (ព្រះពុទ្ធឃោសាចារ្យ) ពិចារណា ហើយប្រាថ្នានឹងពោលពណ៌នាបច្ចយាការក្នុងថ្ងៃនេះ (ឥឡូវនេះ) តែនៅមិនទាន់បានទីពឹងបង្អែក ដូចចុះកាន់សា-គរ; តែព្រោះព្រះសាសនា (បាលីបដិច្ចសមុប្បាទ) នេះ ប្រដាប់ដោយន័យនៃទេសនាផ្សេងៗ និងគន្លងប្រព័ន្ធនៃបុព្វាចារ្យ (អដ្ឋកថាបដិច្ចសមុប្បាទចាស់) ក៏នៅតែប្រព្រឹត្តទៅមិនដាច់ខ្សែ; ព្រោះហេតុដូច្នោះ ខ្ញុំនឹងអាស្រ័យខសេចក្តីទាំង ២ នោះ ផ្តើម

ការវណ្ណនាសេចក្តីនៃបដិច្ចសមុប្បាទនេះ សូមអ្នកទាំងឡាយ តាំងចិត្តស្តាប់ការសំវណ្ណនានេះចុះ ។

សេចក្តីនេះសមដូចពាក្យដែលលោកបុព្វាចារ្យពោលទុកថា ៖

**“អ្នកណាមួយតាំងចិត្តស្តាប់ការសំវណ្ណនានេះ គេក៏នឹងគប្បីបានគុណវិសេស បន្តទៅក្នុងភពខាងមុខ លុះបានគុណវិសេសតទៅក្នុងភពខាងមុខហើយ ក៏គប្បីដល់ទីដែលមិន ជួបមិនប្រទះនៃព្រះបាទមច្ចុរាជ”** ។

ម្យ៉ាង បណ្ឌិតគប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យមានជាអាទិ៍ថា **“អវិជ្ជាបច្ចយា សង្ខារា”** ចាប់ផ្តើមពីដើមទៅតែម្តងថា ៖

**ទេសនាភេទតោ អត្ថ លក្ខណេកវិធាទិតោ**

**អង្គានញ្ច វវត្ថានា វិញ្ញាតព្វោ វិនិច្ឆយោ**

គប្បីជ្រាបវិនិច្ឆ័យ ដោយសេចក្តីផ្សេងគ្នានៃ

ទេសនា ១ ដោយអត្ថ ១ ដោយលក្ខណៈជាដើម ១

ដោយជាធម៌មានតែម្យ៉ាងជាដើម ១ និងដោយការ

កំណត់អង្គទាំងឡាយ ១ ៕

## សម្តែងអំពីការវិនិច្ឆ័យដោយសេចក្តីផ្សេងគ្នានៃទេសនា

បណ្តាខវិនិច្ឆ័យទាំងនោះ ខថា **ដោយសេចក្តីផ្សេងគ្នានៃទេសនា** នោះអធិប្បាយថា ការសម្តែងបដិច្ចសមុប្បាទរបស់ព្រះមានព្រះភាគជាម្ចាស់មាន ៤ ន័យ គឺទ្រង់សម្តែងតាំងអំពីខាងដើមទៅទល់នឹងទីបំផុត (ខាងចុង) ខ្លះ, តាំងពីកណ្តាល

ទៅទីទល់នឹងបំផុតខ្លះ, ម្យ៉ាងទៀត ទ្រង់សម្តែងតាំងពីទីបំផុតទៅខាងដើមខ្លះ, តាំងពីកណ្តាលទៅខាងដើមខ្លះ, ដូចការចាប់វល្លិ៍របស់បុរស ៤ នាក់ អ្នកនាំវល្លិ៍ទៅដូច្នោះ ៕

## សម្តែងអំពីបដិច្ចសមុប្បាទយ៉ាងទី ១

ដូចយ៉ាងថា បណ្តាបុរស ៤ នាក់ អ្នកនាំវល្លិ៍ទៅម្នាក់ឃើញគល់វល្លិ៍មុនតែប៉ុណ្ណោះ, គេទើបកាត់គល់វល្លិ៍នោះ ចាប់ទាញវល្លិ៍ទាំងអស់នោះទៅប្រើក្នុងការងារយ៉ាងណា, ព្រះមានព្រះភាគ ក៏យ៉ាងនោះដែរ ទ្រង់រមែងសម្តែងបដិច្ចសមុប្បាទតាំងពីខាងដើម រហូតដល់សូម្បីទីបំផុតថា **“ឥតិ ខោ ភិក្ខវេ អវិជ្ជាបច្ចយា សង្ខារា ។ បេ ។ ជាតិប្បច្ចយា ជរាមរណំ** = ម្នាលភិក្ខុទាំងឡាយ សង្ខារទាំងឡាយកើតមាន ព្រោះអវិជ្ជាជាបច្ច័យ ។ ល ។ ជរា និងមរណៈកើតមានព្រោះជាតិជាបច្ច័យ ដោយប្រការដូច្នេះនេះ”[២] ៕

## សម្តែងអំពីបដិច្ចសមុប្បាទយ៉ាងទី ២

ដូចយ៉ាងថា ក្នុងបុរសទាំងនោះ មនុស្សម្នាក់ឃើញត្រង់កណ្តាលវល្លិ៍ជាមុន, គេទើបកាត់ត្រង់កណ្តាល បោចយកចំណែកកំណាត់លើប៉ុណ្ណោះ មកប្រើក្នុងការងារយ៉ាងណា, ព្រះមានព្រះភាគក៏យ៉ាងនោះដែរ រមែងទ្រង់សម្តែងតាំងពីកណ្តាលទៅរហូតដល់សូម្បីទីបំផុតថា **“តស្ស តំ វេទនំ អភិនន្ទតោ អភិវទតោ**

---

[២] ម. មូ. ។

**អជ្ឈោសាយ តិដ្ឋតោ ឧប្បជ្ជតិ នន្ទិ យា វេទនាសុ នន្ទិ, តទុបាទានំ, តស្សុបាទានបច្ចយា ភវោ, ភវបច្ចយា ជាតិ** = កាលកុមារនោះត្រេកអរពោលសរសើរញយៗ រហូតដល់ជាប់ចិត្តក្នុងវេទនានោះ សេចក្តីភ្លើតភ្លើនក៏កើតឡើង; សេចក្តីភ្លើតភ្លើនក្នុងវេទនាទាំងឡាយនោះ ជាឧបាទាន; ព្រោះឧបាទានជាបច្ច័យទើបមានភព ព្រោះភពជាបច្ច័យ ទើបមានជាតិ (ព្រោះជាតិជាបច្ច័យ ទើបមានជរា និងមរណៈ)[៣] ៕

## សម្តែងអំពីបដិសម្ភុប្បាទយ៉ាងទី ៣

ដូចយ៉ាងថា ក្នុងបុរសទាំងនោះ មនុស្សម្នាក់ឃើញចុងវល្លិ៍មុនគេ, ទើបចាប់ចុងស្រាវយកមកទាំងវល្លិ៍រហូតដល់គល់ តាមលំអានរបស់ចុង ហើយនាំទៅប្រើក្នុងការងារ យ៉ាងណា, ព្រះមានព្រះភាគក៏យ៉ាងនោះដែរ រមែងទ្រង់សម្តែងបដិច្ច-សមុប្បាទតាំងពីខាងចុង រហូតដល់សូម្បីខាងដើមថា **“ជាតិបច្ចយា ជរាមរណន្តិ ឥតិ ខោ បនេតំ វុ បេ វុ អវិជ្ជាបច្ចយា សង្ខារា** = ក៏ខថា ជរា **និងមរណៈ កើតមាន ព្រោះជាតិជាបច្ច័យដូច្នេះនោះ តថាគតពោលហើយមែន, ម្នាលភិក្ខុទាំងឡាយ ព្រោះជាតិជាបច្ច័យ ជរា និងមរណៈទើបកើតមាន, ក្នុងខនេះ ជាយ៉ាងនេះ មិនមែនឬ ?** (ពួកភិក្ខុក្រាបទូលថា) បពិត្រព្រះអង្គដ៏ចម្រើន ព្រោះជាតិជាបច្ច័យ ទើបមានជរា និងមរណៈ; ក៏ខដែលថា **បពិត្រព្រះអង្គដ៏ចម្រើន ព្រោះជាតិជាបច្ច័យ ទើបមានជរា និងមរណៈទើប**

---

[៣] ម. មូ.។

មាន, ក្នុងខនេះមានសេចក្តីពិតយ៉ាងនេះហើយថា ជាតិមាន ព្រោះភពជាបច្ច័យដូច្នេះនោះ តថាគតពោលហើយ ។ ល ។ (ព្រះមានព្រះភាគជាម្ចាស់) ក៏ខដែលថា ព្រោះអវិជ្ជាជាបច្ច័យ ទើបមានសង្ខារទាំងឡាយដូច្នេះនោះ តថាគតពោលហើយ, ម្នាលភិក្ខុទាំងឡាយ ព្រោះអវិជ្ជាជាបច្ច័យ ទើបមានសង្ខារទាំងឡាយ, ក្នុងខនេះជាយ៉ាងនេះ មិនមែនឬ ? (ពួកភិក្ខុ) បពិត្រព្រះអង្គ ព្រោះអវិជ្ជាជាបច្ច័យទើបមានសង្ខារ, ក្នុងខនេះ ក៏ជាយ៉ាងនេះថា ព្រោះអវិជ្ជាជាបច្ច័យ ទើបមានសង្ខារទាំឡាយ”[៤] ៕

## សម្តែងអំពីបដិច្ចសមុប្បាទខទី ៤

ដូចយ៉ាងថា ក្នុងបុរសទាំងនោះ មនុស្សម្នាក់ឃើញត្រង់កណ្តាលវល្លិ៍មុនតែប៉ុណ្ណោះ, គេក៏កាត់ត្រង់កណ្តាលចាប់ស្រាវចុះមកខាងក្រោម រហូតដល់គល់នាំទៅប្រើការយ៉ាងណា, ព្រះមានព្រះភាគ ក៏យ៉ាងនោះដែរ រមែងទ្រង់សម្តែងតាំងពីកណ្តាលរហូត ដល់ខាងដើមថា “ម្នាលភិក្ខុទាំងឡាយ ក៏អាហារទាំង ៤ នោះ មានអ្វីជាហេតុ, មានអ្វីជាសមុទ័យ, មានអ្វីជាកំណើត, មានអ្វីជាដែនកើត ។ អាហារទាំង ៤ នេះ មានតណ្ហាជាហេតុ, មានតណ្ហាជាសមុទ័យ, មានតណ្ហាជាកំណើត, មានតណ្ហាជាដែនកើត; ម្នាលភិក្ខុទាំងឡាយ ក៏តណ្ហានេះ មានអ្វីជាហេតុ, មានអ្វីជាសមុទ័យ, មានអ្វីជាកំណើត, មានអ្វីជាដែនកើត ។ តណ្ហាមានវេទនាជាហេតុ, មានវេទនាជាសមុទ័យ, មានវេទនាជាកំណើត, មានវេទនាជាដែនកើត; ម្នាលភិក្ខុ

[៤] សំ. និ. ៣១ ។

ទាំងឡាយ ។ល។ វេទនា... ផស្សៈ... សឡាយតនៈ... នាមរូប... វិញ្ញាណ... សង្ខារទាំងឡាយមានអ្វីជាហេតុ, មានអ្វីជាសមុទ័យ, មានអ្វីជាកំណើត, មានអ្វីជាដែនកើត; សង្ខារទាំងឡាយ មានអវិជ្ជាជាហេតុ, មានអវិជ្ជាជាសមុទ័យ, មានអវិជ្ជាជាកំណើត, មានអវិជ្ជាជាដែនកើត”[៥] ដូច្នេះ ។

**សួរថា** ព្រោះហេតុអ្វី ទើបព្រះអង្គទ្រង់សម្តែងយ៉ាងនេះ ?

ឆ្លើយថា ព្រោះបដិច្ចសមុប្បាទជាធមិចម្រើនគ្រប់ផ្នែក និងព្រះមានព្រះភាគសោត ក៏ទ្រង់ដល់ភាពជាអ្នកល្អដោយទេសនា។

ពិតណាស់ បដិច្ចសមុប្បាទដែលជាធមិចម្រើនគ្រប់ផ្នែក រមែងប្រព្រឹត្តទៅព្រមដើម្បីចាក់ធ្លុះនូវញេយ្យធមិដោយទេសនានោះៗ ឯង,ម្យ៉ាង ព្រះមានព្រះភាគទ្រង់ដល់ភាពជាអ្នកល្អដោយទេសនា ព្រោះទ្រង់ប្រកបដោយវេសារជ្ជញ្ញាណ ៤ និងបដិសម្ភិទាញាណ ៤ និងដល់ទ្រង់ដល់ភាពជ្រាលជ្រៅ (ក្នុងបដិច្ចសមុប្បាទ) ៤ យ៉ាង; ព្រះអង្គទ្រង់សម្តែងធមិដោយន័យផ្សេងៗ ក៏ព្រោះទ្រង់ដល់ភាពជាអ្នកល្អដោយ ទេសនានោះឯង ។

តែកាលពោលប្លែកគ្នានៃបដិច្ចសមុប្បាទនេះ ទេសនាណាជាទេសនាដោយអនុលោមចាប់ផ្តើមតាំងពីដើម, ទេសនានោះ បណ្ឌិតគប្បីជ្រាបថា ជាទេសនាដែលព្រះមានព្រះភាគទ្រង់ពិចារណាឃើញនូវវេនេយ្យជន អ្នកជ្រុលជ្រប់ក្នុងការចែកហេតុដែលប្រព្រឹត្តទៅទ្រង់ប្រកាសហើយ ដើម្បីបង្ហាញការប្រព្រឹត្តិទៅតាមហេតុដែលគួរដល់ខ្លួន និងដើម្បីទ្រង់បង្ហាញដល់លំដាប់នៃសេចក្តីកើតឡើង ។

---

[៥] សំ. និ. ៣១ ។

ទេសនាណាដែលទ្រង់សម្តែងដោយបដិលោមតាំងពីទីបំផុតបញ្ច្រាស់ទៅ ទេសនានោះ គប្បីជ្រាបថា ជាទេសនាដែលព្រះអង្គពិចារណាឃើញលោកដែលដល់សេចក្តីលំបាក ដោយន័យមានជាអាទិ៍ថា "លោកនេះដល់សេចក្តីលំបាកហ្ន៎ ! រមែងកើត រមែងចាស់ និងរមែងស្លាប់"[៦] ។ ទ្រង់ប្រកាសហើយ ដើម្បីទ្រង់បង្ហាញ ដល់ហេតុនៃទុក្ខមានជរា និងមរណៈជាដើមនោះៗ ដែលព្រះអង្គទ្រង់សម្រេចហើយ ដោយទំនងនៃការចាក់ធ្លុះក្នុងចំណែកខាងដើម ។ ម្យ៉ាងវិញទៀត ទេសនាណាទ្រង់សម្តែងតាំងពីពាក់កណ្តាល ទៅរហូតដល់ខខាងដើម, ទេសនានោះ ព្រះអង្គទ្រង់ប្រកាសហើយ ដើម្បីទ្រង់នាំអតីតកាលមក សម្តែងដោយលំដាប់នៃហេតុ និងផលចាប់ផ្តើមពីអតីតកាលមកទៀត ដោយទំនងនៃការកំណត់នូវតណ្ហាជាហេតុនៃអាហារ ។ តែទេសនាណាដែលទ្រង់សម្តែងតាំងពីកណ្តាល រហូតដល់ទីបំផុត, ទេសនានោះ ជាទេសនាដែលទ្រង់ប្រកាសដើម្បីទ្រង់បង្ហាញអនាគតកាល ចាប់ផ្តើមពីសមុដ្ឋាននៃហេតុរបស់អនាគតកាលក្នុងបច្ចុប្បន្នកាល ។

ក្នុងទេសនា ៤ ទាំងនោះ ទេសនាណាដែលត្រាស់សម្តែងដោយអនុលោមតាំងពីដើម ដើម្បីបង្ហាញសេចក្តីប្រព្រឹត្តទៅតាមហេតុរបស់ខ្លួន ដល់វេនេយ្យជនអ្នកជ្រុលជ្រប់ក្នុងហេតុដែលប្រព្រឹត្តទៅ និងដើម្បីទ្រង់បង្ហាញលំដាប់នៃសេចក្តីកើតឡើងនោះ ទេសនានោះគប្បីជ្រាបថា ព្រះមានព្រះភាគទ្រង់តាំងទុកហើយ ក្នុងបដិច្ចសមុប្បាទវិភង្គនេះ ។

---

[៦] ទី. ម.។

*សួរថា* ក៏ព្រោះហេតុអ្វី ក្នុងបដិច្ចសមុប្បាទនេះ ព្រះដ៏មានព្រះភាគជាម្ចាស់ ទើបទ្រង់ត្រាស់អវិជ្ជាទុកពីខាងដើម, សូម្បីអវិជ្ជាក៏មិនមានអ្វីជាហេតុ ជាហេតុដើម របស់លោក ដូចសេចក្ដីនៅដដែលរបស់ពួកបកតិវាទីឬ ?

ឆ្លើយថា អវិជ្ជាមិនមែនមិនមានហេតុទេ; ហេតុនៃអវិជ្ជា ព្រះអង្គត្រាស់ថា "**អាសវសមុទយា អវិជ្ជាសមុទយោ** = អវិជ្ជាកើតឡើង ព្រោះអាសវៈកើតឡើង" ។

*សួរថា* ក៏បរិយាយដែលជាហេតុដើមមានដោយសភាវៈណា, ក៏សភាវៈនោះបានដល់អ្វី ?

ឆ្លើយថា បានដល់សភាវៈដែលជាប្រធានរបស់វដ្ដកថា (កថាអំពីវដ្ដៈ) ។

ពិតណាស់ ព្រះមានព្រះភាគកាលត្រាស់វដ្ដកថា ក៏ត្រាស់ធម៌ ២ យ៉ាង ធ្វើឱ្យជាប្រធាន ឬត្រាស់អវិជ្ជា ជាប្រធាន ដូចយ៉ាងដែលត្រាស់ទុកថា "**បុរិមា ភិក្ខវេ កោដិ ន បញ្ញាយតិ អវិជ្ជាយ ឥតោ បុព្វេ អវិជ្ជា នាហោសិ, អថ បច្ឆា សម្ភវីតិ; ឯវញ្ចេតំ ភិក្ខវេ វុច្ចតិ, អថ ច បន បញ្ញាយតិ ឥទប្បច្ចយា អវិជ្ជា** = ម្នាលភិក្ខុទាំងឡាយ ទីបំផុត (ចំណែកខាងដើម) នៃអវិជ្ជាមិនប្រាកដថា ក្នុងកាលមុនអំពីនេះ អវិជ្ជាមិនមាន, តែកាលក្រោយទើបមាន' ; ព្រោះហេតុនោះ យើងទើបពោលពាក្យនោះ យ៉ាងនេះថា ក៏កាលបើមានហេតុដូច្នោះ អវិជ្ជាមានខនេះជាបច្ច័យ ទើបប្រាកដ"[៧] ។

---

[៧] អំ. ទសក. ។

ម្យ៉ាងទៀត ត្រាស់ភវតណ្ហាជាប្រធាន ដូចយ៉ាងដែលត្រាស់ថា “ម្នាលភិក្ខុទាំងឡាយ ចំណែកខាងដើមនៃភវតណ្ហា មិនប្រាកដថា ‘ក្នុងកាលមុនអំពីនេះ ភវតណ្ហាមិនមាន, តែកាលខាងក្រោយទើបមាន’ , ព្រោះហេតុនោះ តថាគតទើបពោលពាក្យនេះ យ៉ាងនេះថា ‘ក៏កាលបើមានហេតុយ៉ាងនោះ ភវតណ្ហាមានខនេះជាបច្ច័យទើបប្រាកដ” [៧] ។

***សួរថា*** ព្រោះហេតុអ្វី ព្រះមានព្រះភាគកាលទ្រង់ត្រាស់វដ្តកថា ទើបត្រាស់ធម៌ ២ នេះ ធ្វើឱ្យជាប្រធាន ?

ឆ្លើយថា ***ព្រោះអវិជ្ជា*** ជាហេតុពិសេសនៃកម្មដែលឱ្យសត្វដល់ទុគ្គតិ ឬសុគ្គតិ ។ ពិតណាស់ អវិជ្ជាជាហេតុពិសេសនៃកម្មដែលឱ្យសត្វដល់ទុគ្គតិ ។ ព្រោះហេតុអ្វី ? ព្រោះបុថុជ្ជនដែលអវិជ្ជាគ្របសង្កត់ហើយ រមែងផ្តើមធ្វើកម្មដែលឱ្យខ្លួនដល់ទុគ្គតិជាអនេកប្បការ មានបាណាតិបាតជាដើម ដែលមិនមានសេចក្តីសប្បាយចិត្ត ព្រោះសេចក្តីក្តៅក្រហាយដោយកិលេសខ្លះ, ដែលនាំសេចក្តីវិនាសដល់ខ្លួនព្រោះត្រូវធ្លាក់ទៅកាន់ទុគ្គតិខ្លះ ដូចមេគោដែលនឹងត្រូវគេសម្លាប់ ត្រូវសេចក្តីគ្រាំគ្រាគ្របសង្កត់ ព្រោះក្តៅក្រហាយដោយភ្លើង និងត្រូវគេវាយដោយព្រនង់ និងដូចការផឹកទឹកក្តៅ ដែលមិនមានសេចក្តីសប្បាយ ព្រោះភាពជាអ្នកស្រេកឃ្លាន ដោយការគ្រាំគ្រានោះ សូម្បីនាំមកនូវសេចក្តីវិនាសដល់ខ្លួន ។

ចំណែក***ភវតណ្ហា*** ជាហេតុពិសេសនៃកម្ម ដែលញ៉ាំងសត្វឱ្យដល់សុគ្គតិ; ព្រោះហេតុអ្វី ? ព្រោះបុថុជ្ជនអ្នកដែលភវតណ្ហាគ្របសង្កត់ហើយ រមែងធ្វើកម្មដែលឱ្យដល់សុគ្គតិជាអនេកប្បការ មានចេតនាជាគ្រឿងវៀរចាកបាតិណោបាតជាដើម

ដែលមានតែការសង្រួមចិត្ត ព្រោះវៀរចាកសេចក្តីក្តៅក្រហាយដោយកិលេស និងបន្ទោបង់សេចក្តីគ្រាំគ្រាដោយទុក្ខក្នុងទុគ្គតិរបស់ខ្លួន ។ ព្រោះដល់សុគតិ ដូចមេគោមានប្រការតាមដែលពោលហើយ ចាប់ផ្តើមផឹកទឹកត្រជាក់ដែលមានតែសេចក្តីសប្បាយចិត្ត ដោយសេចក្តីប្រាថ្នាក្នុងទឹកត្រជាក់ និងបន្ទោបង់ភាពគ្រាំគ្រារបស់ខ្លួនដូច្នោះ ។

ក៏បណ្តាធមិដែលជាប្រធាននៃវដ្តកថាទាំងនេះ ក្នុងកន្លែងខ្លះ ព្រះមានព្រះភាគទ្រង់សម្តែងទេសនាដែលមានអង្គធមិតែម្យ៉ាងជាមូល; តើយ៉ាងណា ? គឺដូចយ៉ាងដែលត្រាស់ទុកថា **“ម្នាលភិក្ខុទាំងឡាយ ដោយហេតុដូច្នេះឯង សង្ខារទាំងឡាយមានអវិជ្ជាជាទីអាស្រ័យ, វិញ្ញាណមានសង្ខារជាទីអាស្រ័យ”** [៨] ជាដើម; ម្យ៉ាងទៀត បានត្រាស់ថា **“ម្នាលភិក្ខុទាំងឡាយ កាលភិក្ខុឃើញសេចក្តីពេញចិត្តរឿយៗ ក្នុងធម៌ទាំងឡាយដែលជាបច្ច័យដល់ឧបាទានហើយ តណ្ហារមែងចម្រើន, ព្រោះតណ្ហាជាបច្ច័យ ទើបឧបាទានកើតមាន”** [៩] ជាដើម ។ ក្នុងទីកន្លែងខ្លះ ទ្រង់សម្តែងធម៌សូម្បីទាំង ២ ឱ្យជាមូល; តើដូចម្តេច ? គឺដូចយ៉ាងដែលត្រាស់ថា **“ម្នាលភិក្ខុទាំងឡាយ កាយរបស់មនុស្សពាល ដែលអវិជ្ជានីវរណៈប្រកបព្រមដោយតណ្ហា កើតឡើងហើយយ៉ាងនេះ; ក៏កាយនេះផង នាមរូបខាងក្រៅទាំងនេះ រមែងមាន ដោយប្រការដូច្នេះ, ព្រោះអាស្រ័យកាយ និងនាមរូប ខាងក្រៅទាំងពីរ ទើបកើតផស្សៈ និងសឡា**

---

[៨] សំ. និ. ៣១។

[៩] សំ. និ. ៣១។

យតនៈទាំងឡាយ, មនុស្សពាលដែលផស្សៈ និងសឡាយតនៈទាំង ២ នោះ ឯងពាល់ត្រូវហើយ ក៏រមែងសោយចំពោះសុខ ឬទុក្ខ”[១០] ជាដើម ។

បណ្ដាទេសនាទាំងនោះ៧ ទេសនាក្នុងអធិការនេះ ដោយអំណាចអវិជ្ជាថា “សង្ខារទាំងឡាយរមែងកើតមាន ព្រោះអវិជ្ជាបច្ច័យ” បណ្ឌិតគប្បីជ្រាបថា មានធម៌មួយជាមូល (ឯកធម្មមូលិកា) ។

គប្បីជ្រាបថាវិនិច្ឆ័យដោយសេចក្ដីផ្សេងគ្នា នៃទេសនាក្នុងបដិច្ចសមុប្បាទនេះ ដោយប្រការដូច្នេះសិន ៕

## សម្ដែងអំពីការវិនិច្ឆ័យដោយអត្ថ

បទថា **ដោយអត្ថ** បានដល់ ដោយអត្ថ (សេចក្ដី) នៃបទទាំងឡាយមានអវិជ្ជាជាដើម; គឺយ៉ាងណា ? គឺកាយទុច្ចរិតជាដើម ឈ្មោះថា **អវិន្ទិយំ** (ធម្មជាតិមិនគួរបាន) ព្រោះអត្ថថា មិនគួរបំពេញ, គឺវត្ថុដែលមិនគួរបាន; (វិគ្រោះថា) **តំ អវិន្ទិយំ វិន្ទតីតិ អវិជ្ជា** ឈ្មោះថា **អវិជ្ជា** ព្រោះអត្ថថា រមែងបានវត្ថុដែលគួរបាននោះ ។

កាយសុចរិតជាដើម ឈ្មោះថា ធម្មជាតិដែលគួរបាន ព្រោះជាភាវៈដែលផ្ទុយគ្នានឹងកាយទុច្ចរិតជាដើមនោះ, (វិគ្រោះថា) **តំ វិន្ទិយំ ន វិន្ទតីតិ អវិជ្ជា** ឈ្មោះថា **អវិជ្ជា** ព្រោះអត្ថថា រមែងមិនបានវត្ថុដែលគួរបាននោះ ។

---

[១០] សំ. និ. ៣១ ។

ក៏ឈ្មោះថា **អវិជ្ជា** ព្រោះអត្ថថា រមែងធ្វើ (បញ្ញា) មិនឱ្យដឹងច្បាស់ នូវអត្ថ គឺគំនរនៃខន្ធទាំងឡាយ, នូវអត្ថ គឺអណ្តូងនៃអាយតនៈទាំងឡាយ, នូវអត្ថនៃការទទេរបស់ធាតុទាំងឡាយ, នូវអត្ថដែលពិតរបស់សច្ចៈទាំងឡាយ នូវអត្ថជាអធិបតីរបស់ឥន្ទ្រិយទាំងឡាយ ។

ក៏ឈ្មោះថា **អវិជ្ជា** សូម្បីព្រោះអត្ថថា រមែងធ្វើអត្ថ ៤ ៗ យ៉ាង [១១] តាមដែលត្រាស់ទុកដោយអំណាចនៃការបៀតបៀន (ឃាំង) ទុកជាដើម របស់ទុក្ខសច្ចជាដើម ។

---

[១១] ក្នុងវិសុទ្ធិមគ្គបាលីត្រង់ញាណទស្សនវិសុទ្ធិ សម្តែងថា ៖

**អត្ថនៃទុក្ខ**

-**បីឡនដ្ឋោ** មានអត្ថថា ការបៀតបៀន

-**សង្ខតដ្ឋោ** មានអត្ថថា ការប្រជុំតាក់តែង

-**សន្តាបដ្ឋោ** មានអត្ថថា ធ្វើឱ្យក្តៅក្រហាយ

-**វិបរិណាមដ្ឋោ** មានអត្ថថា ប្រែប្រួល ។

**អត្ថនៃសមុទ័យ**

-**អាយូហនដ្ឋោ** មានអត្ថថា ប្រមូលមក

-**និទានដ្ឋោ** មានអត្ថថា ហេតុជាដែនកើត

-**សំយោគដ្ឋោ** មានអត្ថថា ប្រកបទុក

-**បលិពោធដ្ឋោ** មានអត្ថថា កង្វល់ ។

**អត្ថនៃនិរោធ**

-**និស្សរណដ្ឋោ** មានអត្ថថា រលាស់ចេញ

ក៏ឈ្មោះថា **អវិជ្ជា** ព្រោះអត្ថថា រមែងញ៉ាំងសត្វឱ្យអន្ទោលទៅក្នុងសង្សារ ដែលមិនមានទីបំផុត គឺក្នុងកំណើត គតិ ភព វិញ្ញាណដ្ឋិតិ និងសត្តាវាស ។

ក៏ឈ្មោះថា **អវិជ្ជា** ព្រោះអត្ថថា រមែងស្ទុះទៅក្នុងស្រីប្រុសជាដើម ដែលមិនមានដោយបរមត្ថ, រមែងមិនស្ទុះទៅក្នុងធម៌មានខន្ធជាដើម សូម្បីដែលជារបស់មានហើយ ។

ម្យ៉ាងទៀត ក៏ឈ្មោះថា **អវិជ្ជា** សូម្បីព្រោះបិទបាំងធម៌ដែលអាស្រ័យនូវគ្នានឹងគ្នា គឺបដិច្ចសមុប្បាទ ហើយកើតឡើងដោយអំណាចនៃវត្ថុ អារម្មណ៍ និងចក្ខុវិញ្ញាណជាដើម; **យំ បដិច្ច ផលមេតិ សោ បច្ចយោ** = ផលអាស្រ័យធម៌ណាកើតឡើងប្រព្រឹត្តទៅ ព្រោះហេតុនោះ ធម៌នោះទើបឈ្មោះថា **បច្ច័យ** ។ ពាក្យថា "**បដិច្ច** = អាស្រ័យ" បានដល់ មិនវៀរធម៌នោះ គឺបើវៀរធម៌នោះហើយ ក៏មិនប្រាកដ ។ ពាក្យថា **ឯតិ** បានដល់ រមែងកើតឡើង និងរមែងប្រព្រឹត្តទៅ ។ ម្យ៉ាងវិញទៀត អត្ថនៃបច្ច័យមានសេចក្តីសម្គាល់ដល់ឧបការធម៌, **អវិជ្ជា ច សា**

---

-**វិវេកដ្ឋោ** មានអត្ថថា ស្ងាត់ចាកទុក្ខ

-**អសង្ខតដ្ឋោ** មានអត្ថថា មិនមានប្រជុំតាក់តែង

-**អមតដ្ឋោ** មានអត្ថថា ជាអមតៈ ។

**អត្ថនៃមគ្គ**

-**និយ្យានដ្ឋោ** មានអត្ថថា នាំចេញ

-**ហេតុដ្ឋោ** មានអត្ថថា ដែលជាហេតុ

-**ទស្សនដ្ឋោ** មានអត្ថថា ឃើញនូវព្រះនិព្វាន

-**អធិបតេយ្យដ្ឋោ** មានអត្ថថា ជាអធិបតីក្នុងការសម្រេចកិច្ច ។

**បច្ចយោ ចាតិ អវិជ្ជា បច្ចយោ** = អវិជ្ជានោះផង ជាបច្ច័យផង ព្រោះហេតុនោះ ទើបឈ្មោះថា **អវិជ្ជាបច្ចយោ** (បច្ច័យអវិជ្ជា) ព្រោះអវិជ្ជាជាបច្ច័យនោះ ។ **សង្ខតមភិសំខរោន្តីតិ សង្ខារា** = ធម៌ដែលឈ្មោះថា សង្ខារ ព្រោះអត្ថថា រមែងតាក់តែងសង្ខតធម៌ ។

ន័យមួយទៀត សង្ខារមាន ២ គឺ

- សង្ខារដែលមានព្រោះអវិជ្ជាជាបច្ច័យ ១
- សង្ខារដែលមកដោយសព្ទថា សង្ខារ ១ ។

បណ្ដាសង្ខារទាំង ២ នោះ សង្ខារដែលមាន ព្រោះអវិជ្ជាជាបច្ច័យមាន ៦ យ៉ាងនេះ គឺសង្ខារ ៣ បានដល់ **បុញ្ញាភិសង្ខារ អបុញ្ញាភិសង្ខារ អានេញ្ជាភិសង្ខារ** និងសង្ខារ ៣ ទៀត គឺ **កាយសង្ខារ វចីសង្ខារ និងចិត្តសង្ខារ**; សូម្បីសង្ខារទាំងអស់នោះ គ្រាន់តែជាលោកិយកុសល និងអកុសលចេតនាប៉ុណ្ណោះ ។

ក៏សង្ខារទាំង ៤ នេះ ដែលមកហើយដោយសង្ខារសព្ទទាំងនេះ គឺសង្ខតសង្ខារ អភិសង្ខតសង្ខារ អភិសង្ខរណកសង្ខារ និងបយោគាភិសង្ខារ ។ បណ្ដាសង្ខារទាំងនោះ ធម៌ព្រមទាំងបច្ច័យដែលព្រះមានព្រះភាគត្រាស់ក្នុងប្រយោគមានជាអាទិ៍ថា **"អនិច្ចា វត សង្ខារា"**[១២] សូម្បីទាំងអស់ ឈ្មោះថា សង្ខតសង្ខារ ។ រូបធម៌ និងអរូបធម៌ ប្រព្រឹត្តទៅក្នុងភូមិ ៣ ដែលកើតអំពីកម្មដែលពោលទុកក្នុងអដ្ឋកថា ឈ្មោះថា អភិសង្ខតសង្ខារ ។ សូម្បីរូបធម៌ និងអរូបធម៌ទាំងនោះ រមែង

[១២] ទី. ម. ១៦, សំ. ស., សំ. និ. ៣១ ។

សង្គ្រោះចូលក្នុងបាលីនេះថា **“អនិច្ចា វត សង្ខារា”** ដូច្នេះទាំងអស់អំពីអាគតស្ថាននៃធម៌ទាំងនោះ មិនប្រាកដមួយចំណែក; ក៏ចេតនាដែលជាកុសល និងអកុសលដែលប្រព្រឹត្តទៅក្នុងភូមិ ៣ លោកហៅថា អភិសង្ខតសង្ខារ, អាគតស្ថាននៃអភិសង្ខរណកសង្ខារនោះ រមែងប្រាកដក្នុងប្រយោគមានពាក្យថា “ម្នាលភិក្ខុទាំងឡាយ បុគ្គលធ្លាក់ក្នុងអំណាចនៃអវិជ្ជា រមែងត្រូវអភិសង្ខារ គឺបុណ្យតាក់តែង” [១៣] ជាដើម ។

ម្យ៉ាងទៀត សេចក្តីព្យាយាមដែលប្រព្រឹត្តទៅតាមផ្លូវកាយ និងចិត្ត លោកហៅថា បយោគាភិសង្ខារ ។ បយោគាភិសង្ខារនោះ មានមកក្នុងប្រយោគនេះថា “កង់នោះកាលនាយជាងរថបង្វិលទៅ ក៏វិលទៅបានប៉ុនដែលនាយជាងរថបង្វិលទៅហើយតាំងនៅបាន ដូចជានៅក្នុងភ្លៅដូច្នោះ” ជាដើម [១៤] ។

ម្យ៉ាងវិញទៀត មិនមែនតែសង្ខារទាំងនេះតែម្យ៉ាងប៉ុណ្ណោះទេ, សូម្បីសង្ខារដទៃទៀតជាអនេកដែលមានមកដោយសព្ទសង្ខារដោយន័យមានជាអាទិ៍ថា “ម្នាលវិសាខៈដ៏មានអាយុ កាលភិក្ខុចូលសញ្ញាវេទយិតនិរោធ វចីសង្ខាររមែងរលត់មុន,

---

[១៣] សំ. និ. ៣១ ។

[១៤] អំ. តិក. ។

បន្ទាប់មក កាយសង្ខារក៏រលត់, បន្ទាប់មកទៀត ចិត្តសង្ខារទើបរលត់” [១៥]; បណ្ដាសង្ខារទាំងនោះ សង្ខារដែលមិនសង្គ្រោះចូលក្នុងសង្ខតសង្ខារ រមែងមិនមានឡើយ ។

ខាងមុខអំពីនេះទៅ ពាក្យណាដែលត្រាស់ទុកក្នុងប្រយោគមានជាអាទិ៍ថា “**សង្ខារប្បច្ចយា វិញ្ញាណំ** = វិញ្ញាណកើតព្រោះសង្ខារជាបច្ច័យ” , ពាក្យនោះ គប្បីជ្រាបដោយន័យដែលលោកពោលហើយនុ៎ះឯង; ឯក្នុងពាក្យដែលនៅមិនទាន់បានពោលនោះ គប្បីជ្រាបវិនិច្ឆ័យតទៅនេះ ៖

**វិជានាតីតិ វិញ្ញាណំ** ឈ្មោះថា **វិញ្ញាណ** ព្រោះអត្ថថា រមែងដឹងច្បាស់ ។

**នមតីតិ នាមំ** ឈ្មោះថា **នាម** ព្រោះអត្ថថា រមែងបង្អោនទៅ ។

**រុប្បតីតិ រូបំ** ឈ្មោះថា **រូប** ព្រោះអត្ថថា រមែងបែកធ្លាយ ។

**អាយេ តនោតិ អាយតញ្ច នយតីតិ អាយតនំ** ក៏ឈ្មោះថា **អាយតនៈ** ព្រោះអត្ថថា រមែងផ្សាយទៅនូវអាយៈ (នាមរូប) ដែលជាអណ្ដូងកើតឡើងនៃទុក្ខ និងរមែងនាំទៅកាន់សំសារដ៏យូរ ។

**ផុស្សតីតិ ផស្សោ** ឈ្មោះថា **ផស្សៈ** ព្រោះអត្ថថា ពាល់ត្រូវ ។

**វេទយតីតិ វេទនា** ឈ្មោះថា **វេទនា** ព្រោះអត្ថថា សោយអារម្មណ៍ ។

**បរិតស្សតីតិ តណ្ហា** ឈ្មោះថា **តណ្ហា** ព្រោះអត្ថថា ប្រាថ្នាយ៉ាងក្រៃលែង ។

**ឧបាទិយតីតិ ឧបាទានំ** ឈ្មោះថា **ឧបាទាន** ព្រោះអត្ថថា ប្រកាន់មាំ ។

---

[១៥] ម. មូ.។

**ភវតីតិ ភាវយតិ ចាតិ ភវោ** ឈ្មោះថា ភព ព្រោះអត្ថថា រមែងកើត រមែងឱ្យកើត ។

**ជននំ ជាតិ** ការកើត ឈ្មោះថា **ជាតិ** ។

**ជីរណំ ជរា** ការគ្រាំគ្រា ឈ្មោះថា **ជរា** ។

**មរន្តិ ឯតេនាតិ មរណំ** ឈ្មោះថា **មរណៈ** ព្រោះអត្ថថា ជាហេតុស្លាប់របស់សត្វទាំងឡាយ ។

**សោចនំ សោកោ** សេចក្ដីសោកសៅ ឈ្មោះថា **សោក**

**បរិទេវនំ បរិទេវោ** សេចក្ដីខ្សឹកខ្សួលយំឈ្មោះថា **បរិទេវៈ**

**ទុក្ខយតីតិ ទុក្ខំ** ឈ្មោះថា **ទុក្ខ** ព្រោះអត្ថថា ធ្វើឱ្យលំបាក; ប្រការមួយទៀត ឈ្មោះថា **ទុក្ខ** ព្រោះអត្ថថា រមែងជីក ២ យ៉ាង ដោយអំណាចនៃឧប្បាទនិងឋិតិ ។

**ទុម្មនស្ស ភាវោ ទោមនស្សំ** ភាវៈនៃទុមនៈ (ចិត្តអាក្រក់) ឈ្មោះថា **ទោមនស្ស** ។

**ភុសោ អាយាសោ ឧបាយាសោ** សេចក្ដីចង្អៀតចង្អល់យ៉ាងខ្លាំងឈ្មោះថា **ឧបាយាសៈ** ។

បទថា **សម្ភវន្តិ** = រមែងកើត; បណ្ឌិតគប្បីធ្វើការប្រកបសព្ទសម្ភវន្តិដោយបទមានសេចក្ដីសោកជាដើមតែម្យ៉ាងប៉ុណ្ណោះក៏ទេ; តាមពិត គួរធ្វើការប្រកប ដោយបទទាំងអស់ ព្រោះកាលបើពោលថា **"អវិជ្ជាបច្ចយា សង្ខារា"** ក្រៅអំពីសម្ភវន្តិសព្ទនេះ ធម៌ គឺអវិជ្ជា និងសង្ខារ ក៏មិនគប្បីប្រាកដថា រមែងធ្វើ

នូវកិច្ចអ្វី ដល់គ្នានឹងគ្នា; តែកាលមានការប្រកបដោយបទថា **សម្ភវន្តិ**សព្ទ ក៏ជាការកំណត់ធម៌ដែលជាបច្ច័យ និងធម៌ដែលកើតឡើងព្រោះបច្ច័យ [១៦] ថា "អវិជ្ជានោះផង ជាបច្ច័យនោះផង ឈ្មោះថា **អវិជ្ជាជាបច្ច័យ**, ព្រោះហេតុដូច្នោះ សង្ខារទាំងឡាយ រមែងកើតឡើង ព្រោះអវិជ្ជាជាបច្ច័យ" ។ ក្នុងបទទាំងឡាយ ក៏ន័យនេះដែរ ។

បទថា "**ឯវំ** = ដោយប្រការដូច្នេះ" នេះ ជាបទអធិប្បាយន័យនៃបដិច្ចសមុប្បាទដែលព្រះអង្គទ្រង់សម្ដែងហើយ; អធិប្បាយថា ដោយបទថា **ឯវំ**នោះ ព្រះមានព្រះភាគទ្រង់សម្ដែងថា "ធម៌ដែលជាបច្ចយាការទាំងនេះ រមែងកើតព្រោះហេតុទាំងឡាយមានអវិជ្ជាជាដើមប៉ុណ្ណោះ មិនមែនកើតឡើងដោយហេតុមានព្រះសិរៈនិមិត្តជាដើមទេ" ។

បទថា "**ឯតស្ស** = នេះ" បានដល់ តាមដែលពោលហើយ ។

បទថា **កេវលស្ស** បានដល់ (កងទុក្ខ) ដែលមិនច្រឡូកច្រឡំគ្នា ឬថាទាំងមូល ។

បទថា "**ទុក្ខក្ខន្ធស្ស** = កងទុក្ខ" បានដល់ ប្រជុំនៃទុក្ខ, មិនមែនប្រជុំនៃសត្វ មិនមែនប្រជុំនៃវិបល្លាស មានសេចក្ដីសុខ និងសេចក្ដីស្អាតជាដើម ។

បទថា **សមុទយោ** បានដល់ ហេតុកើត ។

បទថា **ហោតិ** បានដល់ រមែងកើត ។

គប្បីជ្រាបវិនិច្ឆ័យដោយអត្ថនៃបដិច្ចសមុប្បាទនេះ ដោយប្រការដូច្នេះ ៕

---

[១៦] គឺដែលជាបច្ចយធម៌ និងបច្ចយុប្បន្នធម៌ ។

## សង្ខេបអំពីការវិនិច្ឆ័យដោយលក្ខណៈជាដើម

ខថា **អំពីលក្ខណៈជាដើម** បានដល់ ដោយធម៌ ៤ មានលក្ខណៈជាដើម បដិច្ចសមុប្បាទមានអវិជ្ជាជាដើម; តើដូចម្តេចខ្លះ ? គឺអវិជ្ជា ៖

### ១. លក្ខណាទិចតុក្កៈរបស់អវិជ្ជា

**អញ្ញាណលក្ខណា** មានការមិនដឹងជាលក្ខណៈ

**សម្មោហនរសា** មានការវង្វេងជាកិច្ច

**ឆាទនបច្ចុប្បដ្ឋានា** មានការបិទបាំងសភាវារម្មណ៍ជាផល

**អាសវបទដ្ឋានា** មានអាសវៈជាបទដ្ឋាន ។

### ២. លក្ខណាទិចតុក្កៈរបស់សង្ខារ

**អភិសង្ខរណលក្ខណា** សង្ខារមានការតាក់តែងជាលក្ខណៈ

**អាយូហនរសា** មានសេចក្តីខ្វល់ខ្វាយជាកិច្ច

**ចេតនាបច្ចុប្បដ្ឋានា** មានចេតនាជាផល

**អវិជ្ជាបទដ្ឋានា** មានអវិជ្ជាជាបទដ្ឋាន ។

### ៣. លក្ខណាទិចតុក្កៈរបស់វិញ្ញាណ

**វិជាននលក្ខណំ** វិញ្ញាណមានការដឹងអារម្មណ៍ជាលក្ខណៈ

**បុព្វង្គមរសំ** មានភាពជាប្រធានជាកិច្ច

**បដិសន្ធិបច្ចុប្បដ្ឋានំ** មានការកើតបន្តជាផល
**សំខារបទដ្ឋានំ** មានសង្ខារជាបទដ្ឋាន
**វត្ថារម្មណបទដ្ឋានំ វា** ឬមានវត្ថុ និងអារម្មណ៍ជាបទដ្ឋាន ។

## ៤. លក្ខណាទិចតុក្កៈរបស់នាម

**នមនលក្ខណំ** នាមមានការបង្អោនទៅជាលក្ខណៈ
**សម្បយោគរសំ** មានការប្រកបព្រមគ្នាជាកិច្ច
**អវិនិព្ភោគបច្ចុប្បដ្ឋានំ** មានការមិនញែកចេញពីចិត្តជាផល
**វិញ្ញាណបទដ្ឋានំ** មានវិញ្ញាណជាបទដ្ឋាន ។

## ៥. លក្ខណាទិចតុក្កៈរបស់រូប

**រុប្បនលក្ខណំ** រូបមានការប្រែប្រួលជាលក្ខណៈ
**វិកិរណរសំ** មានការខ្ចាត់ខ្ចាយទៅជាកិច្ច
**អព្យាកតបច្ចុប្បដ្ឋានំ** មានអព្យាកតធម៌ជាផល
**វិញ្ញាណបទដ្ឋានំ** មានវិញ្ញាណជាបទដ្ឋាន ។

## ៦. លក្ខណាទិចតុក្កៈរបស់សឡាយតនៈ

**អាយតនលក្ខណំ** សឡាយតនៈមានការធ្វើវដ្តៈឱ្យយូរជាលក្ខណៈ
**ទស្សនាទិរសំ** មានការធ្វើសេចក្ដីឃើញជាដើមជាកិច្ច

**វត្ថុទ្វារារម្មណបច្ចុប្បដ្ឋានំ** មានវត្ថុ និងទ្វារជាផល

**នាមរូបបទដ្ឋានំ** មាននាមរូបជាបទដ្ឋាន ។

### ៧-លក្ខណាទិចតុក្កៈរបស់ផស្សៈ

**ផុសនលក្ខណោ** ផស្សៈមានការប៉ះខ្ទប់ជាលក្ខណៈ

**សំឃដ្ដនរសោ** មានការប្រសព្វអារម្មណ៍ និងចិត្តជាកិច្ច

**សង្គតិបច្ចុប្បដ្ឋានោ** មានការប្រជុំ (វត្ថុ អារម្មណ៍ និងចិត្ត) ជាផល

**សឡាយតនបទដ្ឋានោ** មានសឡាយតនៈជាបទដ្ឋាន ។

### ៨-លក្ខណាទិចតុក្កៈរបស់វេទនា

**អនុភវនលក្ខណា** វេទនាមានការសោយអារម្មណ៍ជាលក្ខណៈ

**វិសយរសសម្ភោគរសា**

មានការបរិភោគរួមគ្នានូវរសនៃអារម្មណ៍ ជាកិច្ច ។

**សុខទុក្ខបច្ចុប្បដ្ឋានា** មានសុខ និងទុក្ខជាបច្ចុប្បដ្ឋាន

**ផស្សបទដ្ឋានា** ផស្សៈជាបទដ្ឋាន ។

### ៩-លក្ខណាទិចតុក្កៈរបស់តណ្ហា

**ហេតុលក្ខណា** តណ្ហាមានហេតុ ជាលក្ខណៈ

**អភិនន្ទនរសា** មានសេចក្តីត្រេកអរក្រៃលែងជាកិច្ច

**អតិត្តិភាវបច្ចុប្បដ្ឋានា** មានសេចក្តីមិនឆ្អែតក្នុងអារម្មណ៍ជាផល

**វេទនាបទដ្ឋានា** មានវេទនាជាបទដ្ឋាន ។

## ១០. លក្ខណាទិចតុក្កៈរបស់ឧបាទាន

**គហណលក្ខណំ** ឧបាទានមានការប្រកាន់ទុកជាលក្ខណៈ

**អមុញ្ចនរសំ** មានការមិនលែងជាកិច្ច

**តណ្ហាទឡ្ហត្តទិដ្ឋិបច្ចុប្បដ្ឋានា** មានសេចក្តីមាំទាំដោយតណ្ហា និង ការឃើញខុសក្នុងអត្តាជាផល ។

**តណ្ហាបទដ្ឋានំ** មានតណ្ហាជាបទដ្ឋាន ។

## ១១. លក្ខណាទិចតុក្កៈរបស់ភព

**កម្មកម្មផលលក្ខណោ** ភពមានកម្ម និងផលរបស់កម្មជាលក្ខណៈ

**ភាវនភវនរសោ** មានសេចក្តីធ្វើឱ្យកើតឡើង និងសេចក្តីកើតឡើងជាកិច្ច ។

**កុសលាកុសលាព្យាកតបច្ចុប្បដ្ឋានោ** មានកុសល អកុសល និង អព្យាក្រឹតជាផល ។

**ឧបាទានបទដ្ឋានោ** មានឧបាទានជាបទដ្ឋាន ។

ធម៌មានលក្ខណៈជាដើមនៃបច្ចយាការមានជាតិ គប្បីជ្រាបដោយន័យដែលពោលហើយក្នុងសច្ចវិភង្គនោះចុះ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងបច្ចយាការនេះ សូម្បីដោយលក្ខណៈជាដើម ដោយការប្រកបដូច្នេះ ៕

## សម្ដែងអំពីការវិនិច្ឆ័យដោយមានតែម្យ៉ាងជាដើម

ក្នុងខថា **ដោយមានតែម្យ៉ាងជាដើម** នេះ គប្បីជ្រាបឈ្មោះថា **អវិជ្ជា** មានតែម្យ៉ាង ព្រោះជាអញ្ញាណៈ (មិនដឹង), អទស្សនៈ (មិនឃើញ) និងមោហៈ (សេចក្ដីវង្វេង) ជាដើម ។ ក៏ឈ្មោះថា មាន ២ យ៉ាង ព្រោះសេចក្ដីមិនបដិបត្តិ និងបដិបត្តិ ។ ម្យ៉ាងទៀត ព្រោះជា **សសង្ខារ** និង**អសង្ខារ**, ក៏ឈ្មោះថា មាន ៣ យ៉ាង ព្រោះសម្បយុត្តដោយវេទនា ៣, ក៏ឈ្មោះថា មាន ៤ យ៉ាង ព្រោះមិនធ្លាក់ចុះសច្ចៈ ៤, ក៏ឈ្មោះថា មាន ៥ យ៉ាង ព្រោះបិទបាំងទោសនៃគតិ ៥ [១៧]; ម្យ៉ាងវិញទៀត ពោលអំពីទ្វារ និងអារម្មណ៍ អវិជ្ជានោះ មាន ៦ យ៉ាង សូម្បីក្នុងអរូបធម៌ទាំងអស់ ។

**សង្ខារ** ឈ្មោះថា មានតែមួយ ព្រោះជាសាសវវិបាកធម្មធម៌ជាដើម, តែឈ្មោះថា មាន ២ យ៉ាង ព្រោះជាកុសល និងអកុសល, ម្យ៉ាង ព្រោះជាបរិត្តធម៌ និងមហគ្គតធម៌, ព្រោះជាហីនធម៌ និងមជ្ឈិមធម៌, និងព្រោះជាមិច្ឆត្តនិយតធម៌ និងមិច្ឆត្តអនិយតធម៌, ក៏ឈ្មោះថា មាន ៣ យ៉ាង ព្រោះជាបុញ្ញាភិសង្ខារជាដើម, ឈ្មោះថា មាន ៤ យ៉ាង ព្រោះប្រព្រឹត្តទៅក្នុងកំណើត ៤, ឈ្មោះថា មាន ៥ យ៉ាង ព្រោះជាផ្លូវនៃគតិ ៥ ។

---

[១៧] បិទបាំងគតិ ៥ គឺផ្លូវទៅកើតជាសត្វនរក តិរច្ឆាន បិត្តិវិស័យ មនុស្ស និងទេវតា ។

**វិញ្ញាណ** ឈ្មោះថា មាន ១ យ៉ាង ព្រោះជាលោកិយវិបាកជាដើម, ឈ្មោះថា មាន ២ យ៉ាង ព្រោះជាសហេតុកៈ និងអហេតុកៈជាដើម, ឈ្មោះថា មាន ៣ យ៉ាង ព្រោះរាប់បញ្ចូលដោយភព ៣ ព្រោះប្រកបព្រមដោយវេទនា ៣ និងព្រោះជាអហេតុកៈ ទុហេតុកៈ និងតិហេតុកៈ, ឈ្មោះថា ៤ យ៉ាង និង ៥ យ៉ាង ដោយអំណាចនៃកំណើត ៤ និងគតិ ។

**នាមរូប** ឈ្មោះថា មាន ១ យ៉ាង ព្រោះអាស្រ័យវិញ្ញាណ និងដោយកម្មជាបច្ច័យ, ឈ្មោះថា មាន ២ យ៉ាង ព្រោះជាសារម្មណ៍ និងអនារម្មណ៍, ឈ្មោះថា មាន ៣ យ៉ាង ព្រោះជាអតីតៈជាដើម, ឈ្មោះថា មាន ៤ និង ៥ យ៉ាង ដោយអំណាចនៃកំណើត ៤ និងគតិ ៥ ។

**សឡាយតនៈ** ឈ្មោះថា មាន ១ យ៉ាង ព្រោះជាទីកើត និងជាទីប្រជុំ, ឈ្មោះថា មាន ២ យ៉ាង ព្រោះជាភូតរូប បសាទរូប និងវិញ្ញាណ [១៨] ជាដើម, ឈ្មោះថា មាន ៣ យ៉ាង ព្រោះអារម្មណ៍ដែលជាសម្បត្តៈ អសម្បត្តៈ និងមិនមែនទាំងពីរ (គឺផ្លូវមនោទ្វារ), ឈ្មោះថា មាន ៤ យ៉ាង និង ៥ យ៉ាង ព្រោះរាប់បញ្ចូល ដោយកំណើត ៤ និងគតិ ៥ នុ៎ះឯង ។ បណ្ឌិតគប្បីជ្រាបសូម្បីធម៌មានផស្សៈជាដើមថា ជាធម៌ ១ យ៉ាងជាដើមដោយន័យនេះចុះ ។

គប្បីជ្រាបវិនិច្ឆ័យក្នុងបច្ចយាការនេះ សូម្បីជាធម៌មាន ១ យ៉ាង ជាដើម យ៉ាងនេះ ៕

[១៨] ទ្វិបញ្ចវិញ្ញាណ ។

## សម្តែងអំពីការវិនិច្ឆ័យដោយការកំណត់អង្គ

ខថា **ដោយការកំណត់អង្គ** បានសេចក្តីថា ក៏ក្នុងបច្ចយាការនេះ សេចក្តីសោកជាដើម ព្រះមានព្រះភាគទ្រង់ត្រាស់ទុក ដើម្បីសម្តែងសេចក្តីមិនកាត់ផ្តាច់របស់ភវចក្រ; ព្រោះសេចក្តីសោកជាដើមនោះ រមែងកើតដល់មនុស្សពាល អ្នកត្រូវជរា និងមរណៈបៀតបៀនហើយ; ដូចយ៉ាងដែលត្រាស់ទុកថា "ម្នាលភិក្ខុទាំងឡាយ បុថុជ្ជនអ្នកមិនបានស្តាប់ កាលទុក្ខវេទនាផ្លូវកាយពាល់ត្រូវហើយ រមែងសោយសោក រមែងលំបាក រមែងកន្ទក់កន្ទេញ រមែងគក់ទ្រូងទ្រហោយំ រមែងដល់ការវង្វេងវង្វាន់"[១៩] ជាដើម ។

ម្យ៉ាងទៀត អវិជ្ជានៅប្រព្រឹត្តដរាបដែលសេចក្តីសោកជាដើមទាំងនោះ នៅប្រព្រឹត្តទៅ ព្រោះហេតុនោះ ការទាក់ទងគ្នាថា "**អវិជ្ជាបច្ចយា សង្ខារា** = សង្ខារកើតមាន ព្រោះអវិជ្ជាជាបច្ច័យ" សូម្បីម្តងទៀត ក៏ជាភវចក្រមែនពិត; ព្រោះហេតុដូច្នោះ គប្បីជ្រាបអង្គនៃបដិច្ចសមុប្បាទមានត្រឹម ១២ យ៉ាងប៉ុណ្ណោះ ព្រោះប្រមូលសូម្បីសេចក្តីសោកជាដើមនោះ ចូលជាមួយគ្នានឹងជរាមរណៈនោះឯង; គប្បីជ្រាបវិនិច្ឆ័យ ក្នុងបច្ចយាការនេះ សូម្បីដោយការកំណត់អង្គទាំងឡាយទុកដោយប្រការដូច្នេះ ។

កថាអំពីសង្ខេបក្នុងបច្ចយាការនេះ ដោយអំណាចនៃឧទ្ទេសវារៈ មានត្រឹមតែប៉ុណ្ណោះ ៕

### ចប់ការពណ៌នាឧទ្ទេសវារៈ

---

[១៩] សំ. សឡា. ។

## សម្ដែងអំពីនិទ្ទេសនៃអវិជ្ជា

ឥឡូវនេះ ជាការអំពីពិស្ដារ ដោយអំណាចនៃនិទ្ទេសវារៈ; មែនពិត ព្រះមានព្រះភាគត្រាស់ថា **“អវិជ្ជាបច្ចយា សង្ខារា”** ; ក្នុងព្រះបាលីនោះ កាលនឹងទ្រង់សម្ដែងសង្ខារទាំងឡាយ ដែលមានអវិជ្ជាជាបច្ច័យ ព្រោះបុគ្គលកាលនឹងនិយាយដល់បុត្រ ក៏រមែងពោលដល់បិតាជាមុន; ព្រោះថា កាលបើយ៉ាងនេះ បុត្រក៏ជាពាក្យនិយាយបានល្អថា “បុត្ររបស់នាយមិត្ត បុត្ររបស់នាយទត្ត” ; ព្រោះហេតុនោះ ព្រះសាស្ដាទ្រង់ជាអ្នកឆ្លាតក្នុងទេសនា ដើម្បីទ្រង់សម្ដែងអវិជ្ជា ដូចជាបិតា ដោយអត្ថថា ញ៉ាំងសង្ខារទាំងឡាយឱ្យកើតមុន ទើបទ្រង់ត្រាស់ពាក្យ **“តត្ថ កតមា អវិជ្ជា, ទុក្ខេ អញ្ញាណំ** = ក្នុងបច្ចយាការទាំងនោះ អវិជ្ជាតើដូចម្ដេច ? គឺសេចក្ដីមិនដឹងទុក្ខ” ជាដើម ។

ក្នុងព្រះបាលីនោះ ព្រោះអវិជ្ជានេះរមែងមិនឱ្យដើម្បីដឹង ដើម្បីឃើញ ដើម្បីចាក់ធ្លុះនូវលក្ខណៈ ព្រមទាំងកិច្ចតាមសេចក្ដីពិតរបស់ទុក្ខសច្ចៈ ទើបបិទបាំង រួបរឹតប្រកាន់ទុក ព្រោះហេតុដូច្នោះ ទើបត្រាស់ថា **“ទុក្ខេ អញ្ញាណំ** = សេចក្ដីមិនដឹងក្នុងទុក្ខ” ។ ម្យ៉ាងទៀត ព្រោះអវិជ្ជារមែងមិនឱ្យដើម្បីដឹង ដើម្បីឃើញ ដើម្បីចាក់ធ្លុះនូវលក្ខណៈ ព្រមទាំងកិច្ចតាមសេចក្ដីពិតនៃទុក្ខសមុទ័យ, ទុក្ខនិរោធ, ទុក្ខនិរោធគាមិនីបដិបទា បិទបាំងហើយ រួបរឹតហើយ ប្រកាន់ទុកហើយ, ព្រោះហេតុដូច្នោះ ទើបត្រាស់ថា “សេចក្ដីមិនដឹងក្នុងទុក្ខសមុទ័យ សេចក្ដីមិនដឹងក្នុងទុក្ខនិរោធ សេចក្ដីមិនដឹងក្នុងទុក្ខនិរោធគាមិនីបដិបទា” សេចក្ដីមិនដឹង (អញ្ញាណ) ត្រាស់ថា អវិជ្ជាក្នុងឋានៈទាំង ៤ នេះ ដោយបរិយាយនៃព្រះសូត្រ ។

តែដោយបរិយាយនៃព្រះអភិធម្មក្នុងនិក្ខេបកណ្ឌ ទ្រង់កាន់យកអញ្ញាណ (សេចក្ដីមិនដឹង) សូម្បីក្នុងឋានៈដទៃ ៤ ទៀតថា “**បុព្វន្តេ អញ្ញាណំ** = ការមិនដឹងក្នុងអតីតៈ” ជាដើម ។ ក្នុងព្រះបាលីនោះ ពាក្យថា **បុព្វន្តោ** បានដល់ អតីតអទ្ធា គឺខន្ធ ធាតុ និងអាយតនៈទាំងឡាយដែលកន្លងហើយ ។ បទថា **អបរន្តោ** បានដល់ អនាគតអទ្ធា គឺខន្ធ ធាតុ និងអាយតនៈទាំងឡាយដែលនៅមិនទាន់មកដល់ ។ បទថា **បុព្វន្តាបរន្តោ** បានដល់ កាលទាំងពីរនៃខន្ធ ធាតុ និងអាយតនៈ ដែលកន្លងហើយ និងនៅមិនទាន់មកដល់នោះ ។ បទថា **ឥទប្បច្ចយតា** (ភាវៈនៃធម៌នេះ មានជាបច្ច័យ) បានដល់ អង្គទាំងឡាយ មានអវិជ្ជាជាដើម ដែលជាហេតុនៃធម៌ទាំងឡាយ មានសង្ខារជាដើម ។ បទថា “**បដិច្ចសមុប្បន្នធម្មា** = ធម៌ដែល អាស្រ័យគ្នានឹងគ្នាកើតឡើង” បានដល់ ធម៌ទាំងឡាយមានសង្ខារជាដើមដែលកើតឡើងអំពីធម៌ទាំងឡាយមានអវិជ្ជាជាដើម; ក្នុងធម៌ទាំងនោះ ព្រោះអវិជ្ជានេះ រមែងមិនឱ្យដើម្បីដឹង ដើម្បីឃើញ ដើម្បីចាក់ធ្លុះនូវលក្ខណៈ ព្រមទាំងកិច្ចតាមសេចក្ដីពិតនៃខន្ធជាដើមដែលជាអតីតៈ, រមែងបិទបាំង រួបរឹត ប្រកាន់យកទុក, ព្រោះហេតុដូច្នោះ ទើបព្រះភគវាត្រាស់ថា “**បុព្វន្តេ អញ្ញាណំ** = សេចក្ដីមិនដឹងក្នុងអតីតៈ” ។ ម្យ៉ាងទៀត ព្រោះអវិជ្ជានេះ រមែងមិនឱ្យដើម្បីដឹង ដើម្បីឃើញ ដើម្បីចាក់ធ្លុះនូវលក្ខណៈ ព្រមទាំងកិច្ចតាមសេចក្ដីពិតនៃខន្ធជាដើម ដែលជាអនាគត ។ល។ នៃខន្ធជាដើមដែលមានទាំងអតីតៈ និងអនាគត ។ល។ រមែងមិនឱ្យដើម្បីដឹង ដើម្បីឃើញ ដើម្បីចាក់ធ្លុះនូវលក្ខណៈ ព្រមទាំងកិច្ចតាមសេចក្ដីពិតនៃធម៌នេះជាបច្ច័យ និងធម៌ដែលអាស្រ័យ នូវគ្នានឹងគ្នាកើតឡើង, រមែងបិទបាំង

រូបរឹត ប្រកាន់យកទុក, ព្រោះហេតុដូច្នោះ ព្រះភគវាទើបត្រាស់ "សេចក្តីមិនដឹងក្នុងធម៌នេះជាបច្ច័យក្នុងធម៌ទាំងឡាយដែលអាស្រ័យគ្នានឹងគ្នាកើតឡើង" ។ ត្រាស់សេចក្តីមិនដឹង ដោយបរិយាយនៃព្រះអភិធម្មក្នុងឋានទាំង ៨ នេះ ហៅថាជា **អវិជ្ជា** ។

*សួរថា* ដោយលក្ខណៈយ៉ាងនេះ តើជាការដែលព្រះអង្គត្រាស់ដល់អ្វី ? ឆ្លើយថា ឈ្មោះថា ជាការត្រាស់ដល់អវិជ្ជា ដោយកិច្ច និងដោយជាតិ ។ តើដូចម្តេច ? ក៏អវិជ្ជានេះរមែងមិនឱ្យដើម្បីដឹង ដើម្បីឃើញ ដើម្បីចាក់ធ្លុះក្នុងឋានៈទាំង ៨ នេះ ព្រោះហេតុដូច្នោះ ទើបត្រាស់ដោយកិច្ច; ឯអវិជ្ជានេះ សូម្បីកាលកើតឡើង ក៏រមែងកើតក្នុងឋានៈទាំង ៨ នេះ ព្រោះហេតុដូច្នោះ ទើបត្រាស់ដោយជាតិ; លុះត្រាស់យ៉ាងនេះហើយ ទ្រង់កាន់យកបទ ២៥ មានជាអាទិ៍ថា "**យំ ឯវរូបំ អញ្ញាណំ អទស្សនំ** = ការមិនដឹង ការមិនឃើញយ៉ាងណា មានសភាពយ៉ាងនេះ" ដូច្នេះទៀត ដើម្បីទ្រង់សម្តែងលក្ខណៈនៃអវិជ្ជាតទៅ ។

ក្នុងអធិការនេះ ព្រោះអវិជ្ជានេះសូម្បីត្រាស់ហើយដោយបទទាំង ៨ នេះ កាលនៅមិនទាន់ត្រាស់ដល់លក្ខណៈដោយបទ ២៥ ទៀត ឈ្មោះថាជាការត្រាស់ល្អហើយ មិនទាន់បានទេ, តែការត្រាស់ដល់លក្ខណៈដោយបទ ២៥ ហើយ ឈ្មោះថាជាការត្រាស់ល្អហើយ; ដូចបុរសកាលកំពុងស្វែងរកគោដែលបាត់ទៅ គប្បីសួរពួកមនុស្សថា "នៃនាយ លោកបានឃើញគោស, គោក្របាមដែរឬទេ ?" , ពួកមនុស្ស ក៏គប្បីនិយាយយ៉ាងនេះថា "ក្នុងដែននេះមានគោស ក្របាមច្រើនណាស់, គោរបស់លោកមានលក្ខណៈដូចម្តេចទៅ ?" ; លំដាប់នោះ កាលបុរសនោះ

និយាយថា **"ជារូបសំពត់ជ្រលក់ពណ៌ទឹកអម្ចត់ ឬដងនង្គ័ល"** ដូច្នេះ គោទើបឈ្មោះថា ជាសត្វដែលគេប្រាប់ល្អហើយ យ៉ាងណា; អវិជ្ជានេះក៏យ៉ាងនោះដូចគ្នា សូម្បីត្រាស់ដោយបទទាំង ៨ នៅមិនទាន់បានត្រាស់ដោយលក្ខណៈដោយបទ ២៥ ទៀត រមែងឈ្មោះថាត្រាស់ល្អហើយក៏ទេ, តែកាលត្រាស់ដល់ដោយលក្ខណៈហើយនុ៎ះឯង ទើបឈ្មោះថា ត្រាស់ទុកល្អហើយ, ព្រោះហេតុដូច្នោះ ដើម្បីសម្ដែងលក្ខណៈនៃអវិជ្ជានោះ គប្បីជ្រាបដោយអំណាចនៃបទសូម្បីទាំង ២៥ ដែលព្រះមានព្រះភាគជាម្ចាស់ ត្រាស់ទុកហើយមែនពិត ។ សេចក្ដីនេះ តើយ៉ាងណា ?

## អវិជ្ជាមានលក្ខណៈ ២៥

គឺបញ្ញាឈ្មោះថា **ញាណ**, បញ្ញានោះ រមែងធ្វើសច្ចៈធម៌ ៤ ដែលជាផល និងជាផល, ដែលជាហេតុ និងជាហេតុ ដែលដឹងហើយប្រាកដ; តែអវិជ្ជានេះ កើតឡើងហើយ រមែងមិនឱ្យធ្វើសច្ចៈធម៌ ៤ នោះ ឱ្យដឹង ឱ្យប្រាកដ ព្រោះហេតុដូច្នោះ ទើបឈ្មោះថា **អញ្ញាណ** (សេចក្ដីមិនដឹង) ព្រោះជាបដិបក្ខចំពោះញាណ ។

បញ្ញាឈ្មោះថា **ទស្សនៈ** (សេចក្ដីឃើញ) ក៏មាន, បញ្ញាសូម្បីនោះ រមែងឃើញនូវអាការៈនៃសច្ចៈធម៌ ៤ តាមដែលបានពោលហើយនោះ; តែអវិជ្ជាកាលកើតឡើង រមែងមិនឱ្យដើម្បីឃើញសច្ចធម៌ ៤ នោះ ព្រោះហេតុដូច្នោះ ទើបឈ្មោះថា **អទស្សនៈ** ។

បញ្ញា ឈ្មោះថា **អភិសម័យ** (ការត្រាស់ដឹង) ក៏មាន, បញ្ញានោះ រមែងត្រាស់ដឹងនូវអាការៈនៃសច្ចធម៌ ៤ តាមដែលបានពោលហើយនោះឯង; តែអវិជ្ជា

កើតឡើង ហើយរមែងមិនឱ្យដើម្បីត្រាស់ដឹងអរិយសច្ចៈ ៤ នោះ ព្រោះហេតុដូច្នោះ ទើបឈ្មោះ **អនភិសម័យ** ។

បញ្ញានោះឈ្មោះថា **អនុពោធ** (សេចក្តីត្រាស់ដឹងតាម), សម្ពោធៈ (ការត្រាស់ដឹងព្រម), បដិវេធៈ (ការចាក់ធ្លុះ) ក៏មាន; បញ្ញានោះ រមែងដឹងតាម រមែងត្រាស់ដឹងព្រម រមែងចាក់ធ្លុះនូវអាការនៃសច្ចធម៌ ៤ តាមដែលពោលហើយនោះ; តែអវិជ្ជាកើតឡើងហើយ រមែងមិនឱ្យដើម្បីត្រាស់ដឹងតាម ដើម្បីត្រាស់ដឹងព្រម ដើម្បីចាក់ធ្លុះសច្ចធម៌នោះ ព្រោះហេតុនោះ ទើបឈ្មោះថា **អននុពោធ អសម្ពោធ** និង**អប្បដិវេធ** ។

បញ្ញាឈ្មោះថា **សល្លក្ខណា** (ការកាន់យកត្រូវ) ក៏មាន, បញ្ញានោះ កាន់យកហើយ សាកល្បងមើលហើយ ទើបកាន់យកដោយអាការនោះ, តែអវិជ្ជា កើតឡើងហើយ រមែងមិនឱ្យដើម្បីកាន់យក មិនសាកល្បងមើលហើយ ទើបកាន់យកនូវអាការនោះ ព្រោះហេតុដូច្នោះ ទើបឈ្មោះថា **អសល្លក្ខណា** ។

បញ្ញា ឈ្មោះថា **បរិយោគាហណា** (សេចក្តីល្បងមើលដោយជុំវិញ), បញ្ញានោះ ល្បងមើលហើយ ជ្រួតជ្រាបហើយនូវអាការនោះ ទើបកាន់យក; តែអវិជ្ជាកើតឡើងហើយ រមែងមិនឱ្យដើម្បីល្បងមើល ជ្រួតជ្រាបហើយ ទើបកាន់យក ព្រោះហេតុដូច្នោះ ទើបឈ្មោះថា **អបរិយោគាហណា** ។

បញ្ញាឈ្មោះថា **សមបេក្ខនា** (សេចក្តីពិនិត្យពិច័យ) ក៏មាន, បញ្ញានោះ រមែងពិចារណាអាការនោះដោយប្រក្រតី និងដោយប្រពៃ; តែអវិជ្ជាកើតឡើងហើយ មិនឱ្យដើម្បីពិចារណាអាការៈនោះដោយប្រក្រតី និងដោយប្រពៃ (សព្វគ្រប់)

ព្រោះហេតុនោះ ទើបឈ្មោះថា **អសមបេក្ខនា** ។

បញ្ញាឈ្មោះថា **បច្ចវេក្ខណា** ( ការពិចារណា) ក៏មាន, បញ្ញានោះ រមែងពិចារណាអាការនោះ; តែអវិជ្ជាកើតឡើហើយ រមែងមិនឱ្យដើម្បីពិចារណាអាការនោះ ព្រោះហេតុដូច្នោះ ទើបឈ្មោះថា **អប្បច្ចវេក្ខណា** ។

**កម្ម** យ៉ាងណាមួយដែលប្រចក្ស រមែងមិនមានដល់អវិជ្ជានោះ, និងកម្មដែលខ្លួនឯង ( គឺអវិជ្ជា) មិនពិចារណាហើយធ្វើរមែងមាន ព្រោះហេតុនោះ អវិជ្ជានេះទើបឈ្មោះថា **អប្បច្ចវេក្ខកម្ម** ( មានកម្មដែលមិនពិចារណា ធ្វើឱ្យប្រចក្ស) ។

**អវិជ្ជា** ឈ្មោះថា **ទុម្មេជ្ឈំ** ( ការទន់ខ្សោយបញ្ញា) ព្រោះសេចក្ដីល្ងង់ ។

**អវិជ្ជា** ឈ្មោះថា **ពាល្យៈ** (ភាពល្ងង់ខ្លៅ) ព្រោះជាធម្មជាតិល្ងង់ខ្លៅ ។

**បញ្ញា** ឈ្មោះថា **សម្បជញ្ញៈ** ( ការដឹងទូទៅ) ក៏មាន, បញ្ញានោះ រមែងដឹងទូទៅនូវសច្ចធម៌ ៤ ដែលជាផល និងជាផល, ដែលជាហេតុ និងជាហេតុដោយជុំវិញ; តែអវិជ្ជាកើតឡើងហើយរមែងមិនឱ្យដើម្បីដឹងទូទៅនូវអាការនោះ ព្រោះហេតុដូច្នោះ ទើបឈ្មោះថា **អសម្បជញ្ញៈ** ។

**អវិជ្ជា** ឈ្មោះថា **មោហៈ** ( ការវង្វេង) ដោយអំណាចនៃសេចក្ដីល្ងង់ ។

**អវិជ្ជា** ឈ្មោះថា **បមោហៈ** ( ការឈ្លក់វង្វេង) ដោយអំណាចនៃសេចក្ដីវង្វេងទូទៅ ។

**អវិជ្ជា** ឈ្មោះថា **សម្មោហៈ** ( ការវង្វេងវង្វាន់) ដោយអំណាចនៃសេចក្ដីភ្លេចភ្លាំង ។

**អវិជ្ជា** ឈ្មោះថា **អវិជ្ជា** ដោយអំណាចនៃអត្ថមានជាអាទិ៍ថា "រមែងដឹងវត្ថុដែលមិនគួរដឹង" ។

**អវិជ្ជា** ឈ្មោះថា **អវិជ្ជោឃៈ** (ឱឃៈ គឺអវិជ្ជា) ព្រោះរមែងនាំចុះ គឺឱ្យលិចចុះក្នុងវដ្ដៈ ។

**អវិជ្ជា** ឈ្មោះថា **អវិជ្ជាយោគៈ** (យោគៈ គឺអវិជ្ជា) ព្រោះប្រកបដោយទុក្ខក្នុងវដ្ដៈ ។

**អវិជ្ជា** ឈ្មោះថា **អវិជ្ជានុសយៈ** (អនុស័យ គឺអវិជ្ជា) ដោយអំណាចការនៅមិនទាន់បានលះ និងព្រោះកើតឡើងញយៗ ។

**អវិជ្ជា** ឈ្មោះថា **អវិជ្ជាបរិយុដ្ឋាន** (ការរួបរឹតចិត្ត គឺអវិជ្ជា) ព្រោះរមែងរួបរឹត រមែងចាប់ រមែងប្លន់កុសលចិត្តដូចពួកចោរពួនស្ទាក់ក្នុងចន្លោះផ្លូវ ប្លន់អ្នកដំណើរដូច្នោះ ។

**អវិជ្ជា** ឈ្មោះថា **អវិជ្ជាលង្គី** (គន្លឹះដែក គឺអវិជ្ជា) ព្រោះអត្ថថា កាលចន្ទាស គឺគន្លឹះដែកត្រង់ទ្វារក្រុងធ្លាក់ទៅហើយ រមែងកាត់ដាច់នូវការចេញទៅខាងក្រៅក្រុងរបស់ពួកមនុស្ស ខាងក្នុងក្រុងខ្លះ នូវការចូលទៅខាងក្នុងរបស់ពួកមនុស្សខាងក្រៅក្រុងខ្លះ យ៉ាងណា, អវិជ្ជានេះ ធ្លាក់ទៅក្នុងនគរកាយរបស់ខ្លួននៃបុគ្គលណា, រមែងកាត់ដាច់ការដើរទៅ គឺញាណដែលឱ្យដល់ព្រះនិព្វាន របស់បុគ្គលនោះដូច្នោះ ។

**អវិជ្ជា** ឈ្មោះថា **អកុសលមូល** ព្រោះអត្ថថា អកុសលនោះជាមូល ឬព្រោះអត្ថថា អវិជ្ជាជាមូលនៃអកុសលទាំងឡាយ ។ ក៏អកុសលមូលនោះ មិនមែន

ដទៃទេ, ក្នុងទីនេះទ្រង់បំណងយក **មោហៈ** ព្រោះហេតុដូច្នោះ ទើបឈ្មោះថា **អកុសលមូល គឺមោហៈ** ។

បទថា **អយំ វុច្ចតិ** = នេះហៅថា សេចក្ដីថា ព្រះភគវាទ្រង់ត្រាស់ថា នេះឈ្មោះថា អវិជ្ជា មានលក្ខណៈយ៉ាងនេះឯង ។

គប្បីជ្រាបលក្ខណៈអវិជ្ជាដោយអំណាចនៃបទ ២៥ ដោយប្រការដូច្នេះ ។

ម្យ៉ាងទៀត អវិជ្ជានេះមានលក្ខណៈយ៉ាងនេះ សូម្បីត្រាស់ថា "ការមិនដឹងក្នុងទុក្ខ" ជាដើម ក៏រមែងជាចំណែកមួយនៃទុក្ខសច្ចៈ, ជាធម៌កើតព្រមគ្នា, រមែងធ្វើទុក្ខសច្ចៈនោះឱ្យជាអារម្មណ៍, តែរមែងបិទបាំងទុក្ខសច្ចៈនោះ ។ មិនមែនជាចំណែកមួយនៃសមុទយសច្ចៈ, ជាធម៌កើតព្រមគ្នា, រមែងធ្វើសមុទយសច្ចៈនោះ ឱ្យជាអារម្មណ៍, រមែងបិទបាំងសមុទយសច្ចៈនោះ ។ មិនមែនជាចំណែកមួយរបស់និរោធសច្ចៈ, មិនកើតព្រមគ្នា, មិនធ្វើនិរោធសច្ចៈនោះឱ្យជាអារម្មណ៍, រមែងបិទបាំងតែម្យ៉ាង ។ មិនមែនជាចំណែកមួយសូម្បីនៃមគ្គសច្ចៈ, មិនកើតព្រមគ្នា, មិនធ្វើមគ្គសច្ចៈនោះឱ្យជាអារម្មណ៍, រមែងបិទបាំងតែម្យ៉ាង ។

អវិជ្ជារមែងកើតឡើង ព្រោះការមានទុក្ខជាអារម្មណ៍, ក៏រមែងបិទបាំងទុក្ខដែលជាអារម្មណ៍នោះ; អវិជ្ជារមែងកើតឡើង ព្រោះការមានសមុទ័យជាអារម្មណ៍, ក៏រមែងបិទបាំងសមុទ័យដែលជាអារម្មណ៍នោះ; អវិជ្ជារមែងមិនកើតឡើង ព្រោះមាននិរោធជាអារម្មណ៍, ក៏រមែងបិទបាំងនិរោធនោះ; អវិជ្ជារមែងមិនកើត ឡើងព្រោះមានមគ្គជាអារម្មណ៍, តែរមែងបិទបាំងមគ្គនោះ ។

សច្ចៈ ២ ឈ្មោះថា **ជ្រាលជ្រៅ** (គម្ភីរ) ព្រោះឃើញបានដោយលំបាក, សច្ចៈ ២ ឈ្មោះថា ឃើញបានដោយលំបាក ព្រោះជារបស់ជ្រាលជ្រៅ ។ ម្យ៉ាងទៀត អរិយសច្ចៈ គឺទុក្ខនិរោធជាសភាវៈជ្រាលជ្រៅ និងឃើញបានដោយលំបាក ។ បណ្ដាសច្ចៈទាំងនោះ ឈ្មោះថា **ទុក្ខ** ព្រោះជាសភាវៈប្រាកដ, តែដែលឈ្មោះថា **ជ្រាលជ្រៅ** ព្រោះឃើញលក្ខណៈបានដោយលំបាក ។ សូម្បីក្នុងសមុទ័យ ក៏មានន័យដូចគ្នានេះដែរ; ប្រៀបដូចជាធម្មតាថា ការកូរមហាសមុទ្រ ហើយនាំយកឱជះចេញមកជាភារៈ ហើយនាំយកឱជះចេញមកជាភារៈ (របស់ធ្ងន់), ធម្មតាថា ការជញ្ជូនខ្សាច់អំពីជើងភ្នំសិនេរុ ក៏ជាភារៈ, ធម្មតាថា ការច្របាច់ភ្នំ ហើយនាំរសចេញមក ក៏ជាភារៈយ៉ាងណា, សច្ចៈទាំង ២ ក៏ដូចគ្នាដែរ ឈ្មោះថា **ឃើញបានលំបាក** ព្រោះជាសភាវៈជ្រាលជ្រៅដោយពិត; តែនិរោធសច្ចៈទាំងជ្រាលជ្រៅក្រៃលែង និងឃើញបានយ៉ាងលំបាកក្រៃលែង ព្រោះហេតុដូច្នោះ សេចក្ដីងងឹត គឺមោហៈដែលបិទបាំងអរិយសច្ចៈ ៤ ក៏ឈ្មោះថា **ជ្រាលជ្រៅ** ព្រោះឃើញបានដោយសែនលំបាក និងឈ្មោះថា **ឃើញបានលំបាក** ព្រោះសេចក្ដីជ្រាលជ្រៅនេះ ដោយប្រការដូច្នេះទើបត្រាស់ហៅថា **អវិជ្ជា** ៕

**ចប់និទ្ទេសនៃអវិជ្ជា**

## សម្ដែងអំពីសង្ខារនិទ្ទេស

គប្បីជ្រាបវិនិច្ឆ័យ**ក្នុងនិទ្ទេសនៃសង្ខារ** តទៅ ៖

ព្រះមានព្រះភាគជាម្ចាស់កាលនឹងទ្រង់សម្ដែងចំពោះសង្ខារ ដែលមាន

អវិជ្ជាជាបច្ច័យប៉ុណ្ណោះ ដែលមិនទាក់ទងសង្ខារដែលមកដោយសង្ខារសព្ទក្នុងសង្ខារ តាមដែលត្រាស់ទុកក្នុងពេលមុន ទើបត្រាស់ពាក្យថា **“តត្ថ កតមេ អវិជ្ជា-បច្ចយា សង្ខារា, បុញ្ញាភិសង្ខារោ** = បណ្តាបច្ចយាការទាំងនោះ សង្ខារកើតមាន ព្រោះអវិជ្ជាជាបច្ច័យ តើដូចម្តេច ?, គឺបុញ្ញាភិសង្ខារ” ជាដើម ។

ក្នុងព្រះបាលីនោះ សភាវៈដែលឈ្មោះថា **បុញ្ញៈ** ព្រោះអត្ថថា រមែងជម្រះកម្មដែលជាការធ្វើរបស់ខ្លួន, គឺរមែងញ៉ាំងអធ្យាស្រ័យរបស់អ្នកធ្វើនោះ ឱ្យបរិបូណ៌, និងញ៉ាំងភពដែលគួរបូជាឱ្យកើតឡើង ។ ក៏ឈ្មោះថា **អភិសង្ខារ** ព្រោះអត្ថថា រមែងតាក់តែងវិបាក និងកដត្តារូប ។ **អភិសង្ខារ** = សភាពដែលតាក់តែង គឺបុញ្ញៈ ឈ្មោះថា **បុញ្ញាភិសង្ខារ** ។ សភាវៈដែលឈ្មោះថា **អបុញ្ញោ** = អបុញ្ញៈ ព្រោះជាបដិបក្ខចំពោះបុញ្ញៈ ។ អភិសង្ខារ គឺអបុញ្ញៈ ឈ្មោះថា **អបុញ្ញាភិសង្ខារ** ។ ក៏ឈ្មោះថា **អានេញ្ជៈ** ព្រោះអត្ថថា រមែងមិនញាប់ញ័រ, ក៏ឈ្មោះថា **អានេញ្ជាភិសង្ខារ** ព្រោះអត្ថថា អភិសង្ខារ គឺអានេញ្ជៈ (ការមិនញាប់ញ័រ), និងសភាពតាក់តែងភពដែលមិនញាប់ញ័រ ។ ក៏ឈ្មោះថា **កាយសង្ខារ** ព្រោះអត្ថថា ជាសង្ខារ (តាក់តែង) នូវកាយឱ្យប្រព្រឹត្តទៅ ឬព្រោះកាយប្រព្រឹត្តទៅដល់កាយ ។ សូម្បីវចីសង្ខារ និងចិត្តសង្ខារ ក៏ន័យនេះដែរ ។

ក្នុងសង្ខារទាំងនោះ សង្ខារ ៣ ខាងដើម ទ្រង់កាន់យកដោយអំណាចនៃ **បរិវីមំសនសូត្រ** ។ មែនពិត ក្នុងសូត្រនោះ ព្រះមានព្រះភាគទ្រង់ត្រាស់ទុកថា **“បើថាបុគ្គលរមែងតាក់តែងសង្ខារ** (សភាពតាក់តែង) **ដែលជាបុណ្យ, វិញ្ញាណក៏ចូលដល់ភាវៈជាបុណ្យ; បើថាបុគ្គលរមែងតាក់តែងសង្ខារដែលជាអបុញ្ញៈ,**

វិញ្ញាណក៏ចូលដល់ភាវៈ ជាអបុញ្ញៈ (បាប); បើថាបុគ្គលរមែងតាក់តែងសង្ខារដែលជាអានេញ្ជៈ, វិញ្ញាណក៏ចូលដល់ភាវៈជាអានេញ្ជៈ"[២០] ។ សង្ខារ ៣ ទី ២ ទ្រង់កាន់យកដោយអំណាចនៃវិភង្គសូត្រ ដែលជាលំដាប់នៃបរិវីមំសនសូត្រនោះ; សូម្បីនឹងពោលថា ទ្រង់កាន់យកដោយបរិយាយនៃសម្មាទិដ្ឋិសូត្រដូច្នេះ ក៏គួរដូចគ្នា ។ ព្រោះវិភង្គសូត្រនោះត្រាស់ទុកថា "**ម្នាលភិក្ខុទាំងឡាយ សង្ខារនេះ មាន ៣; សង្ខារ ៣ តើដូចម្តេច ? គឺកាយសង្ខារ វចីសង្ខារ និងចិត្តសង្ខារ**"[២១] ។

**សួរថា** ក៏ព្រោះហេតុអ្វី ទើបទ្រង់កាន់យកសង្ខារទាំងនោះ ដោយអំណាចនៃសូត្រទាំងនោះវិញ ?

ឆ្លើយថា ដើម្បីសម្តែងបទនេះថា "**ធម្មតាព្រះអភិធម្មនេះ ព្រះមានព្រះភាគ ទ្រង់មិនបានធ្វើទុកក្នុងពេលនេះទេ, ពួកឥសីខាងក្រៅ ឬពួកសាវ័ក ឬពួកទេវតាមិនបានពោលទុកដែរ; ក៏ព្រះអភិធម្មនេះ ជាភាសិតរបស់ព្រះជិនស្រីជាម្ចាស់ ជាសព្វញ្ញុពុទ្ធ; ព្រោះក្នុងព្រះអភិធម្មក្តី ក្នុងព្រះសូត្រក្តី ជាព្រះបាលីមានបែបផែន ដែលលើកឡើងសម្តែងចេញដូចគ្នាទាំងអស់**" ៕

## សម្តែងអំពីបុញ្ញាភិសង្ខារ

ឥឡូវនេះ ដើម្បីទ្រង់សម្តែងសង្ខារទាំងនោះដោយប្រភេទផ្សេងៗ ទើបត្រាស់ពាក្យមានជាអាទិ៍ថា "**តត្ថ កតមោ បុញ្ញាភិសង្ខារោ** = ក្នុងសង្ខារទាំង

---

[២០] សំ. និ. ៣១ ។

[២១] សំ. និ. ៣១ ។

នោះ បុញ្ញាភិសង្ខារ តើដូចម្ដេច ?” ។

ក្នុងព្រះបាលីនោះ សូម្បីចេតនាដែលប្រព្រឹត្តទៅក្នុងភូមិ ៤ ត្រាស់ដោយមិនកំណត់ទុកថា “ចេតនាដែលជាកុសល” ; តែព្រោះទ្រង់កំណត់ថា **“កាមាវចរ រូបាវចរ”** ដូច្នេះ ចេតនា ១៣ ដួង គឺកាមាវចរកុសលចេតនា ៨ ដួង និងរូបាវចរកុសលចេតនា ៥ ដួង ឈ្មោះថា **បុញ្ញាភិសង្ខារ** ។ ដោយបទទាំងឡាយថា **“ទានមយា** = ទានមយៈ” ជាដើម ទ្រង់សម្ដែងការប្រព្រឹត្តទៅដោយអំណាចបុញ្ញកិរិយាវត្ថុនៃចេតនាទាំងនោះនុ៎ះឯង ។

ក្នុងព្រះបាលីនោះចេតនា ៨ ដួង ជាកាមាវចររមែងសម្រេចដោយទាន និងសីលប៉ុណ្ណោះ; តែចេតនាសូម្បីទាំង ១៣ ដួង សម្រេចដោយភាវនា; ប្រៀបដូចបុគ្គលស្វាធ្យាយធម៌រត់មាត់ រមែងមិនដឹងនូវធម៌ដែលប្រព្រឹត្តទៅសូម្បី ១ សន្ធិ, សូម្បី ២ សន្ធិ, ពេលនឹកដល់ទើបដឹងក្នុងកាលខាងក្រោយ យ៉ាងណា, កាលព្រះយោគាវចរធ្វើកសិណបរិកម្មពិចារណាឈាន ដែលស្ទាត់ជំនាញហើយ និងកាលមនសិការកម្មដ្ឋានដែលស្ទាត់ជំនាញហើយ ក៏ដូច្នោះដែរ ចេតនាសូម្បីប្រាសចាកញាណ ក៏រមែងសម្រេចជាភាវនា; ដោយហេតុនោះ ខ្ញុំទើបពោលថា “សូម្បីចេតនាទាំង ១៣ ដួង សម្រេចដោយភាវនា” ។

ក្នុងទេសនានោះ ទេសនានេះជាការសម្ដែងដោយសង្ខេបក្នុងបុញ្ញកិរិយាវត្ថុមានទានជាដើមថា **“ចេតនា សញ្ចេតនា** = ការតាំងចិត្ត” គិតប្រារព្ធទាន ធ្វើទានឱ្យជាធំឯណា រមែងកើតឡើង នេះហៅថា **បុញ្ញាភិសង្ខារសម្រេចដោយ**

**ទាន**; ចេតនា ការតាំងចិត្ត ការគិតប្រារព្ធសីល ។ល។ ប្រារព្ធភាវនា ធ្វើភាវនាឱ្យជាធំឯណា, នេះហៅថា **បុញ្ញាភិសង្ខារសម្រេចដោយភាវនា**”[២២] ។

ចំណែកកថានេះជាការពោលដោយពិស្តារថា បណ្តាបច្ច័យ ៤ មានចីវរប្បច្ច័យជាដើម ឬបណ្តាអារម្មណ៍ ៦ មានរូបារម្មណ៍ជាដើម ឬទានវត្ថុ ១០ មានការឱ្យបាយជាដើម ចេតនារបស់បុគ្គលអ្នកឱ្យវត្ថុនោះៗ ដែលប្រព្រឹត្តទៅក្នុងកាលទាំង ៣ គឺ ក្នុងបុព្វភាគ (ចំណែកខាងដើម) ចាប់ផ្តើមតាំងអំពីការកើតឡើងនៃរបស់នោះៗ ១, ក្នុងវេលាបរិច្ចាគ ១, ក្នុងការរឭកដល់ដោយចិត្តសោមនស្សជាខាងក្រោយ ១ ឈ្មោះថា **ទានមយៈ** ។ ឯចេតនាដែលប្រព្រឹត្តទៅដល់បុគ្គលអ្នកទៅកាន់វិហារ អ្នកតាំងចិត្តថា “យើងនឹងបួសដើម្បីបំពេញសីល” ដូច្នេះ បួសហើយ ញ៉ាំងមនោរថឱ្យដល់ទីបំផុតហើយរំពឹងថា “យើងបួសហើយជាការល្អហ្ន៎ៗ” ហើយសង្រួមព្រះបាដិមោក្ខ ពិចារណានូវបច្ច័យទាំងឡាយមានចីវរប្បច្ច័យជាដើម រវាំងនូវចក្ខុទ្វារជាដើម ក្នុងអារម្មណ៍មានរូបារម្មណ៍ជាដើមដែលមកកាន់គន្លង និងជម្រះអាជីវៈឱ្យបរិសុទ្ធហ្មត់ចត់ ឈ្មោះថា **សីលមយៈ** ។ ចេតនាដែលប្រព្រឹត្តទៅដល់ព្រះយោគាវចរ អ្នកចម្រើននូវចក្ខុដោយជារបស់មិនទៀង ជាទុក្ខ ជាអនត្តា; ចម្រើននូវរូបទាំងឡាយ ។ល។ ចម្រើននូវធម៌ទាំងឡាយ; ចម្រើននូវចក្ខុវិញ្ញាណ ។ល។ ចម្រើននូវមនោវិញ្ញាណ; ចម្រើននូវចក្ខុសម្ផស្ស ។ល។ ចម្រើនមនោសម្ផស្ស; ចម្រើនចក្ខុសម្ផស្សជាវេទនា ។ល។ ចម្រើនមនោសម្ផស្សជាវេទនា; ចម្រើនរូបសញ្ញា ។ល។ ចម្រើនធម្មសញ្ញា; ចម្រើនជរាមរណៈដោយជារបស់មិនទៀង ជា

---

[២២] អភិ. ។

ទុក្ខ ជាអនត្តា ដោយផ្លូវនៃវិបស្សនាដែលពោលទុកក្នុងបដិសម្ភិទាមគ្គ [២៣] ឈ្មោះថា **ភាវនាមយៈ** ៕

## សំដែងអំពីអបុញ្ញាភិសង្ខារ

គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេស **អបុញ្ញាភិសង្ខារ** តទៅ ៖

បទថា **“អកុសលា ចេតនា** = អកុសលចេតនា” បានដល់ ចេតនាដែលសម្បយុត្តដោយអកុសលចិត្ត ១២ ដួង ។ បទថា **“កាមាវចរា** = ជាកាមាវចរ” សេចក្តីថា បណ្តាអកុសលចេតនា ១២ ដួងនោះ វៀរចេតនាដែលសហគតៈដោយទោមនស្ស ២ ដួងចេញ ចេតនាដ៏សេសរមែងកើតឡើងសូម្បីក្នុងរូបភព និងអរូបភព ក៏ពិតមែនហើយ, ប៉ុន្តែថា ក៏មិនទាញបដិសន្ធិមកក្នុងរូបភព និងអរូបភពនោះ, រមែងញ៉ាំងវិបាកឱ្យត្រាច់ទៅក្នុងកាមាវចរ ដោយអំណាចបដិសន្ធិនោះឯង ព្រោះហេតុដូច្នោះ ទើបត្រាស់ថា ជាកាមាវចរប៉ុណ្ណោះ ៕

## សំដែងអំពីអានេញ្ជាភិសង្ខារ

គប្បីជ្រាបវិនិច្ឆ័យក្នុងនិទ្ទេសនៃ **អានេញ្ជាភិសង្ខារ** តទៅ ៖

បទថា **“កុសលា ចេតនា អរូបាវចរា** = កុសលចេតនាជាអរូបាវចរ” បានដល់ កុសលចេតនាជាអរូបាវចរ ៤; ពិតមែន កុសលចេតនាជាអរូបាវចរទាំង ៤ នេះ ត្រាស់ហៅថា **អានេញ្ជាភិសង្ខារ** ព្រោះអត្ថថា មិនញាប់ញ័រ និងព្រោះអត្ថថា

---

[២៣] ខុ. បដិ. ។

តាក់តែងសេចក្តីមិនញាប់ញ័រ; ព្រោះថា ធម៌ ១៥ គឺ ចេតនាជាកុសល វិបាក និង កិរិយា ដែលកើតអំពីចតុត្ថជ្ឈានដែលជារូបាវចរ ៣ ដួង ចេតនាដែលជាអរូបាវចរ ១២ ដួង ឈ្មោះថា **អានេញ្ជា** ព្រោះអត្ថថា មាំមួន ព្រោះអត្ថថា មិនញាប់ញ័រ ។ បណ្តាចេតនាទាំង ១៥ នោះ រូបាវចរកុសលចេតនា សូម្បីមានសភាពមិនញាប់ញ័រ, តែក៏ឱ្យកើតរូប និងអរូបដែលដូចខ្លួនខ្លះ មិនដូចខ្លួនខ្លះ ឱ្យមានសេចក្តីញាប់ញ័រខ្លះ មិនមានសេចក្តីញាប់ញ័រខ្លះ ព្រោះហេតុដូច្នោះ ទើបមិនឈ្មោះថា **អានេញ្ជាភិសង្ខារ**; ចំណែករូបាវចរវិបាកចេតនា និងរូបាវចរកិរិយាចេតនា រមែងតាក់តែងវិបាកមិនបាន ព្រោះមិនមានវិបាក ទើបឈ្មោះថា ជាអានេញ្ជាភិសង្ខារមិនបាន; ចេតនាដែលជាអរូបាវចរវិបាក និងកិរិយា ក៏ជាអានេញ្ជាភិសង្ខារមិនបានដូចគ្នា ព្រោះហេតុដូច្នោះ ចេតនាសូម្បីទាំង ១១ ដួងនេះ ទើបជា **អានេញ្ជា** (ការមិនញាប់ញ័រ) ប៉ុណ្ណោះ មិនមែនជាអភិសង្ខារ ។ តែអរូបាវចរកុសលចេតនា ៤ ដួង ប៉ុណ្ណោះ ត្រាស់ហៅថា **អានេញ្ជាភិសង្ខារ** ព្រោះអត្ថថា រមែងឱ្យកើតអរូបដែលមិនញាប់ញ័រដូចខ្លួន ដូចស្រមោលរបស់ដំរី សេះជាដើម ក៏ដូចជាសត្វមានដំរីសេះជាដើម ព្រោះហេតុដូច្នោះ សូម្បីចេតនាទាំងអស់នេះ គឺកាមាវចរកុសលចេតនា ១៣ ដួង ដោយអំណាចនៃបុញ្ញាភិសង្ខារ, អកុសលចេតនា ១២ ដួង ដោយអំណាចនៃអបុញ្ញាភិសង្ខារ, អរូបាវចរកុសលចេតនា ៤ ដួង ដោយអំណាចនៃអានេញ្ជាភិសង្ខារ ប្រមូលសរុបមកជាចេតនា ២៩ ដួង ដោយប្រការដូច្នេះ ។

ព្រះមានព្រះភាគទ្រង់កំណត់ចេតនាជាកុសល និងអកុសលដែលកើតឡើងដល់ពួកសត្វរកប្រមាណមិនបាន ក្នុងចក្រវាឡដែលប្រមាណមិនអស់ ដោយព្រះ

សព្វញ្ញុតញ្ញាណទ្រង់សម្តែងចេតនាទុក ២៩ ដួងប៉ុណ្ណោះ ដូចទ្រង់ថ្លឹងដោយជញ្ជីងដែលធំ និងដូចទ្រង់វាល់ដាក់ទុកក្នុងនាឡិនោះឯង ដោយប្រការដូច្នេះ ៕

## សម្តែងអំពីទ្វារនៃកម្ម

ឥឡូវនេះ ព្រះមានព្រះភាគកាលនឹងទ្រង់សម្តែងទ្វារនៃកម្ម ៣ ដែលពួកសត្វរកប្រមាណមិនបាន ក្នុងចក្រវាឡដែលរាប់ប្រមាណមិនអស់ អ្នកប្រកបហើយនូវកុសលកម្ម និងអកុសលកម្មរមែងប្រកបដោយទ្វារទាំងនោះ ទើបត្រាស់ពាក្យថា **“តត្ថ កតមោ កាយសង្ខារោ, កាយសញ្ចេតនា** = ក្នុងសង្ខារទាំងនោះ កាយសង្ខារតើដូចម្តេច ? គឺកាយសញ្ចេតនា” ជាដើម ។

ក្នុងព្រះបាលីនោះ ពាក្យថា **កាយសញ្ចេតនា** បានដល់ ចេតនា ២០ គត់ គឺ កាមាវចរកុសលចេតនា ៨ ដួង, អកុសលចេតនា ១២ ដួង ដែលប្រព្រឹត្តទៅដោយកាយទ្វារញ៉ាំងកាយវិញ្ញត្តិឱ្យតាំងឡើង; សូម្បីនឹងពោលថា ចេតនាដែលជាកុសល និងអកុសល ២០ ដែលកើតឡើងឱ្យដល់ការកម្រើកទៅដោយការទាញតោង និងការកាន់យកក្នុងកាយទ្វារ ដូច្នេះក៏គួរ ។

ពាក្យថា **វចីសញ្ចេតនា** បានដល់ ចេតនា ២០ ដួងនោះៗ ឯង ប្រព្រឹត្តទៅតាមផ្លូវវចីទ្វារ ញ៉ាំងវចីវិញ្ញត្តិឱ្យតាំងឡើង; សូម្បីនឹងពោលថា “ចេតនា ២០ ដួងដែលកើតឡើងឱ្យកម្រើកដល់ការបញ្ចេញវាចា ក្នុងវចីទ្វារ” ដូច្នេះក៏គួរ ។ តែក្នុងអធិការនេះ អភិញ្ញាចេតនារមែងមិនជាបច្ច័យដល់វិបាកវិញ្ញាណខាងមុខ ព្រោះហេតុនោះ លោកទើបមិនកាន់យក; សូម្បីឧទ្ធច្ចចេតនាក៏មិនជាបច្ច័យ ដូចអភិញ្ញា

ចេតនាដែរ; ព្រោះហេតុដូច្នោះ សូម្បីឧទ្ធច្ចចេតនានោះ ក៏គប្បីនាំចេញអំពីសេចក្តីជាបច្ច័យរបស់វិញ្ញាណ; ក៏ចេតនាសូម្បីទាំងអស់នេះ រមែងកើតមាន ព្រោះអវិជ្ជាជាបច្ច័យ ។

ពាក្យថា **មនោសញ្ចេតនា** បានដល់ ចេតនា ២៩ ដួងសូម្បីទាំងអស់ដែលកើតឡើងក្នុងមនោទ្វារ សូម្បីមិនបានញ៉ាំងវិញ្ញត្តិទាំង ២ ឱ្យតាំងឡើង ។

ព្រះមានព្រះភាគទ្រង់សម្តែងទ្វារនៃកម្ម ដែលសត្វព្យាយាមទុកថា “**សត្វទាំងឡាយក្នុងចក្រវាឡដែលរាប់ប្រមាណមិនបាន កាលប្រកបដោយកុសលកម្ម និងអកុសលកម្មរមែងប្រកបដោយទ្វារទាំង ៣ នេះ**” ដោយប្រការដូច្នេះឯង ៕

## សម្តែងអំពីសម្បយោគនៃអភិសង្ខារ ៣

ម្យ៉ាងទៀត គប្បីជ្រាបសម្បយោគ (ការប្រកបព្រមគ្នា) នៃពួក ៣ សូម្បីទាំង ២ នេះ ទៅវិញទៅមក តទៅ ៖

តើសម្បយោគគ្នាដូចម្តេច ? **គឺបុញ្ញាភិសង្ខារ** គប្បីជាកាយសង្ខារដល់បុគ្គលអ្នកវៀរចាកកាយទុច្ចរិតក៏មាន, គប្បីជាវចីសង្ខារដល់បុគ្គលអ្នកវៀរចាកវចីទុច្ចរិត ក៏មាន; ព្រោះហេតុដូច្នោះ **កុសលចេតនា ៨ ដួង** ទើបជាកាមាវចរ ជាបុញ្ញាភិសង្ខារ ជាកាយសង្ខារ និងវចីសង្ខារ ។ ចំណែក **ចេតនា ១៣ ដួង** ដែលកើតក្នុងមនោទ្វារ ជាបុញ្ញាភិសង្ខារ និងចិត្តសង្ខារ ។

សូម្បីអបុញ្ញាភិសង្ខារ គប្បីជាកាយសង្ខារក្នុងវេលាប្រព្រឹត្តទៅដោយអំណាច

កាយទុច្ចរិតនោះឯងក៏មាន, គប្បីជាវចីសង្ខារក្នុងវេលាដែលប្រព្រឹត្តទៅដោយអំណាចវចីទុច្ចរិតក៏មាន, គប្បីជាចិត្តសង្ខារក្នុងវេលាដែលប្រព្រឹត្តទៅក្នុងមនោទ្វារ វៀរទ្វារ ២ ក៏មាន ព្រោះហេតុដូច្នោះ អបុញ្ញាភិសង្ខារ ទើបជាកាយសង្ខារខ្លះ ជាវចីសង្ខារខ្លះ ជាចិត្តសង្ខារខ្លះ ។ ក៏កាយសង្ខារគប្បីជាបុញ្ញាភិសង្ខារក៏មាន, ជាអបុញ្ញាភិសង្ខារក៏មាន, តែមិនជាអានេញ្ជាភិសង្ខារទេ ។ **វចីសង្ខារ** ក៏ដូចគ្នា (គឺជាបុញ្ញាភិសង្ខារក៏មាន ជាអបុញ្ញាភិសង្ខារក៏មាន មិនជាអានេញ្ជាភិសង្ខារទេ); តែ**ចិត្តសង្ខារ** គប្បីជាបុញ្ញាភិសង្ខារក៏មាន, ជាអបុញ្ញាភិសង្ខារក៏មាន, ជាអានេញ្ជាភិសង្ខារក៏មាន ព្រោះហេតុដូច្នោះ ឈ្មោះថា សង្ខារទាំងឡាយកើតមាន ព្រោះអវិជ្ជាជាបច្ច័យ ៕

## សម្ដែងអំពីសង្ខារមានអវិជ្ជាជាបច្ច័យ តើដូចម្ដេច ?

***សួរថា*** ក៏ខនេះ នឹងគប្បីជ្រាបបានដូចម្ដេចថា សង្ខារទាំងឡាយនេះ រមែងមានព្រោះអវិជ្ជាជាបច្ច័យ ? ឆ្លើយថា ដឹងបានព្រោះសេចក្ដីដែលអវិជ្ជាមានសង្ខារទើបមាន; មែនពិត បុគ្គលណានៅលះអញ្ញាណ (ការមិនដឹង) ពោលគឺអវិជ្ជា ក្នុងសច្ចៈ ៤ មានទុក្ខជាដើមមិនទាន់បាន, បុគ្គលនោះ ក៏នឹងប្រកាន់សង្សារទុក្ខ ដោយសេចក្ដីសម្គាល់ថាជាសុខ ដោយសេចក្ដីមិនដឹងធម៌មានខន្ធក្នុងអតីតៈជាដើមឡើយ ហើយរមែងប្រារព្ធសូម្បីសង្ខារទាំង ៣ (មានបុញ្ញាភិសង្ខារជាដើម) ដែលជាហេតុនៃសង្សារទុក្ខនោះ ។ ដោយសេចក្ដីមិនដឹងក្នុងទុក្ខសមុទ័យ កាលគេសម្គាល់ដោយវិបល្លាសហើយ ក៏រមែងប្រារព្ធសង្ខារទាំងឡាយ ដែលជាបរិវាររបស់តណ្ហាសូម្បីជាហេតុនៃទុក្ខដោយសេចក្ដីកាន់យកថាជាហេតុនៃសុខ ។ ម្យ៉ាងទៀត ព្រោះសេចក្ដី

ដែលមិនដឹងក្នុងនិរោធ និងមគ្គ ទើបបុគ្គលមានសេចក្ដីសម្គាល់ក្នុងទុក្ខនិរោធ (ការរលត់ទុក្ខ) ក្នុងគតិពិសេសសូម្បី មិនមែនសេចក្ដីរំលត់ទុក្ខ និងមានសេចក្ដីសម្គាល់ក្នុងពិធីកម្មទាំងឡាយមានការបូជាយញ្ញ និងបំពេញតបៈដើម្បីឱ្យទៅកើតជាទេវតាជាដើម សូម្បីមិនមែនជាផ្លូវនៃសេចក្ដី រំលត់ទុក្ខថាជាផ្លូវរំលត់ទុក្ខ កាលប្រាថ្នាទុក្ខនិរោធ (សេចក្ដីរលត់ទុក្ខ) យ៉ាងនេះ ក៏រមែងប្រារព្ធ សូម្បីសង្ខារទាំង ៣ យ៉ាងដោយបំណងពិធីកម្មមានការបូជាយញ្ញ និងធ្វើតបៈដើម្បីភាពជាទេវតាជាដើម ។

ម្យ៉ាងវិញទៀត ព្រោះបុគ្គលនោះនៅមិនទាន់បានលះអវិជ្ជាក្នុងសច្ចៈទាំង ៤ នោះ ទើបមិនដឹងនូវទុក្ខ ពោលគឺផលនៃបុណ្យសូម្បីលាយដោយទោសជាអនេកមានជាតិ ជរា និងមរណៈជាដើម ដោយសេចក្ដីជាទុក្ខពិសេស រមែងប្រារព្ធ**បុញ្ញាភិសង្ខារ** ដែលផ្សេងដោយកាយសង្ខារ និងវចីសង្ខារ ដើម្បីពន្លុះទុក្ខនោះ ដូចអ្នកត្រូវការនាងទេពធីតា (ទេពអប្សរ) ប្រាថ្នាកើតជាទេវបុត្រដូច្នោះ; ក៏កាលបុគ្គលនោះសូម្បីមិនឃើញទោសក្នុងផលនៃបុណ្យនោះ សូម្បីសម្មតិថាជាសុខដែលដល់សេចក្ដីជាទុក្ខ ព្រោះប្រែប្រួលដែលញុំាងសេចក្ដីក្ដៅក្រហាយធំ ឱ្យកើតឡើងក្នុងពេលចុងក្រោយ ព្រោះផលនៃបុណ្យនោះមានសេចក្ដីសុខតិច រមែងប្រារព្ធបុញ្ញាភិសង្ខារ មានប្រការតាមដែលពោលហើយនុ៎ះឯង ដែលមានផលបុណ្យនោះជាបច្ច័យដូចសត្វមមាចបែមុខទៅរកអណ្ដាតភ្លើង និងដូចបុគ្គលជាប់ចិត្តក្នុងតំណក់ទឹកឃ្មុំព្រមជាមួយការលិទ្ធមុខសាស្ត្រាដ៏មុតដែលលាបដោយទឹកឃ្មុំដូច្នោះ ។

ម្យ៉ាងវិញទៀត កាលមិនឃើញទោសក្នុងធម៌ដែលមានវិបាក មានការសេពកាមជាដើម រមែងប្រារព្ធ**អបុញ្ញាភិសង្ខារ** សូម្បីប្រព្រឹត្តទៅដោយទ្វារ ៣ ព្រោះ

សម្គាល់ថាជាសុខ និងព្រោះភាពជាអ្នកត្រូវកិលេសគ្របសង្កត់ហើយ ដូចទារកលេង នូវលាមកដ៏បដិកូល ឬដូចអ្នកត្រូវការស្លាប់បរិភោគថ្នាំពិសដូច្នោះ; ក៏កាលមិនត្រាស់ដឹងសេចក្ដីទុក្ខដែលមានសេចក្ដីប្រែប្រួលនៃសង្ខារ សូម្បីក្នុងវិបាករបស់អរូបក៏រមែងប្រារព្ធ**អានេញ្ជាភិសង្ខារ** ដែលជាចិត្តសង្ខារដោយវិបល្លាស មានសេចក្ដីទៀងជាដើម ដូចមនុស្សវង្វេងទិស ចាប់ផ្ដើមដើរផ្លូវឆ្ពោះមុខទៅកាន់នគរបិសាច (ប្រេត) ដូច្នោះ ។ ព្រោះសេចក្ដីដែលអវិជ្ជាមាននោះឯង សង្ខារទើបមាន, មិនមែនព្រោះសេចក្ដីមិនមានទេ; ព្រោះហេតុដូច្នោះ សេចក្ដីនេះទើបជ្រាបបានថា "**សង្ខារទាំងនេះ រមែងមានព្រោះអវិជ្ជាជាបច្ច័យ**" ដោយប្រការដូច្នេះ សូម្បីពាក្យនេះព្រះមានព្រះភាគក៏ត្រាស់ទុកថា "**ម្នាលភិក្ខុទាំងឡាយ មនុស្សល្ងង់ខ្លៅធ្លាក់ទៅក្នុងអវិជ្ជាហើយ ព្រោះសេចក្ដីមិនដឹង រមែងតាក់តែងបុញ្ញាភិសង្ខារខ្លះ, រមែងតាក់តែងអបុញ្ញាភិសង្ខារខ្លះ, រមែងតាក់តែងអានេញ្ជាភិសង្ខារខ្លះ;** ម្នាលភិក្ខុទាំងឡាយ ក្នុងកាលណា ភិក្ខុលះអវិជ្ជាចេញបានហើយ, វិជ្ជាក៏កើតឡើង, ព្រោះការបន្ថយអវិជ្ជា ព្រោះសេចក្ដីកើតឡើងនៃវិជ្ជា ក្នុងកាលនោះភិក្ខុនោះរមែងមិនតាក់តែងបុញ្ញាភិសង្ខារជាដើម" ៕

## សម្ដែងអំពីអវិជ្ជាជាបច្ច័យដល់សង្ខារ តើដូចម្ដេច ?

*សួរថា* ក្នុងអធិការនេះ បើមានអ្នកពោលថា ពួកយើងព្រមទទួលថា **អវិជ្ជាជាបច្ច័យដល់សង្ខារទាំងឡាយ** នេះទុកសិន, តែពាក្យដែលពោលទុកថា "អវិជ្ជាជាបច្ច័យតើដូចម្ដេច ? បានដល់ សង្ខារពួកណាទៅ ?" ។

ក្នុងបញ្ហាកម្មនេះ លោករមែងពោលពាក្យនេះថា ៖

**"បច្ចយោ ហោតិ បុញ្ញានំ ទុវិធានេកធា បន**
**បរេសំ បច្ឆិមានំ សា ឯកធា បច្ចយោ មតា ២**

អវិជ្ជានោះ ជាបច្ច័យដល់បុញ្ញាភិសង្ខារ ២ យ៉ាង ជាបច្ច័យដល់អបុញ្ញាភិសង្ខារ ដែលមានខាងមុខច្រើនយ៉ាង ជាបច្ច័យដល់អានេញ្ជាភិសង្ខារ ទីបំផុតមួយយ៉ាង" ។

ក្នុងការពោលឆ្លើយបញ្ហានោះ ខថា **អវិជ្ជាជាបច្ច័យដល់បុញ្ញាភិសង្ខារ ២ យ៉ាង** បានដល់ ជាបច្ច័យ ២ យ៉ាង គឺដោយអារម្មណប្បច្ច័យ និងឧបនិស្សយប្បច្ច័យ; មែនពិត អវិជ្ជានោះ ជាបច្ច័យដល់បុញ្ញាភិសង្ខារដែលជាកាមាវចរ ក្នុងការពិចារណាសង្ខារដោយសេចក្ដីអស់ទៅ សូន្យទៅ និងជាបច្ច័យដល់បុញ្ញាភិសង្ខារដែលជារូបាវចរក្នុងការដឹងចិត្តមានមោហៈដោយអភិញ្ញាចិត្ត **ដោយអារម្មណប្បច្ច័យ**។ ម្យ៉ាងទៀត កាលបុគ្គលបំពេញនូវបុញ្ញកិរិយាវត្ថុដែលជាកាមាវចរ មានការឱ្យទានជាដើម និងកាលបុគ្គលញ៉ាំងរូបាវចរជ្ឈានទាំងឡាយឱ្យកើតឡើង ដើម្បីឈានកន្លងអវិជ្ជានោះ ក៏ជាបច្ច័យដល់បុញ្ញាភិសង្ខារ សូម្បីទាំងពីរ **ដោយឧបនិស្សយប្បច្ច័យ** មែនពិត; ឯកាលបុគ្គលប្រាថ្នាសម្បត្តិក្នុងកាមភព និងរូបភព ហើយធ្វើឱ្យបុណ្យទាំងនោះឯង ក៏រមែងជាបច្ច័យដោយឧបនិស្សយប្បច្ច័យដូចគ្នា ព្រោះសេចក្ដីវង្វេងភ្លេចដោយអវិជ្ជា ។

ម្យ៉ាងទៀត ខថា **អវិជ្ជាជាបច្ច័យដល់អបុញ្ញាភិសង្ខារ ដែលមាននៅខាងមុខ ច្រើនយ៉ាង** បានដល់ អវិជ្ជាជាបច្ច័យដល់អបុញ្ញាភិសង្ខារច្រើន; តើដូច

ម្ដេច ? គឺអវិជ្ជានេះ ប្រារព្ធអវិជ្ជា ក្នុងកាលកើតកិលេសមានរាគៈជាដើម ក៏ជាបច្ច័យដោយ**អារម្មណប្បច្ច័យ**, ក្នុងវេលាដែលត្រេកអរធ្វើឱ្យធ្ងន់ ក៏ជាបច្ច័យដោយ **អារម្មណាធិបតិប្បច្ច័យ និងអារម្មណូបនិស្សយប្បច្ច័យ**, កាលបុគ្គលវង្វេងភ្លេចដោយអវិជ្ជា មិនឃើញទោសធ្វើនូវបាណាតិបាតជាដើម ក៏ជាបច្ច័យដោយ **ឧបនិស្សយប្បច្ច័យ**, ជាបច្ច័យដល់ជវនទី ២ ជាដើម **ដោយអនន្តរប្បច្ច័យ សមនន្តរប្បច្ច័យ ឧបនិស្សយប្បច្ច័យ អាសេវនប្បច្ច័យ នត្ថិប្បច្ច័យ និងវិគតប្បច្ច័យ**, កាលធ្វើអកុសលយ៉ាងណាមួយ ក៏ជាបច្ច័យច្រើនយ៉ាង **គឺដោយហេតុប្បច្ច័យ សហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ សម្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ និងអវិគតប្បច្ច័យ** ។

ខថា **អវិជ្ជាជាបច្ច័យដល់អានេញ្ជាភិសង្ខារទីបំផុតមានតែមួយយ៉ាងនោះ** សេចក្ដីថា អវិជ្ជា ជាបច្ច័យដល់អានេញ្ជាភិសង្ខារ **ដោយឧបនិស្សយប្បច្ច័យ**តែមួយប៉ុណ្ណោះ; ក៏សេចក្ដីដែលអវិជ្ជាជាឧបនិស្សយប្បច្ច័យនោះ គប្បីជ្រាបដោយន័យដែលពោលក្នុងបុញ្ញាភិសង្ខារនោះឯង ។

ក៏ក្នុងទីនេះ បើមានអ្នកសង្ស័យពោល**សួរថា** “ក៏អវិជ្ជានេះតែមួយប៉ុណ្ណោះជាបច្ច័យដល់សង្ខារទាំងឡាយ, ឬថា សូម្បីធម៌ពួកដទៃជាបច្ច័យក៏មានឬ ?” គប្បីឆ្លើយថា ក្នុងខនេះនឹងមានពាក្យអ្វីពោលទៅ បើមានអវិជ្ជាតែមួយប៉ុណ្ណោះ, វាទៈថា ហេតុសម្រាប់ធ្វើមានតែមួយ ក៏នឹងប្រាកដ; បើធម៌សូម្បីដទៃជាបច្ច័យមាន, ការអធិប្បាយដល់ហេតុមួយយ៉ាងថា “**សង្ខារទាំងឡាយ រមែងមាន**

ព្រោះអវិជ្ជាជាបច្ច័យ” ក៏មិនកើតឡើង; រមែងមិនកើតឡើង ព្រោះហេតុអ្វី ? ព្រោះថា ៖

**“ឯកំ ន ឯកតោ ឥធ នានេកមនេកតោបិ នោ ឯកំ**
**ផលមត្ថិ អត្ថិ បន ឯក- ហេតុផលទីបនេ អត្ថោ ។**

ក្នុងលោកនេះ ផលមួយយ៉ាងរមែងមាន ព្រោះហេតុមួយយ៉ាងក៏ទេ ផលច្រើនយ៉ាងរមែងមាន ព្រោះហេតុមួយយ៉ាងក៏ទេ ផលមួយយ៉ាងរមែងមាន ព្រោះហេតុច្រើនយ៉ាងក៏ទេ តែថាប្រយោជន៍ក្នុងការសម្តែងហេតុ និងផលតែមួយយ៉ាង១ រមែងមាន” ។

អធិប្បាយថា ក្នុងលោកនេះ ផលមួយយ៉ាងរមែងមាន ព្រោះហេតុមួយយ៉ាងក៏ទេ, ផលច្រើនយ៉ាង រមែងមាន ព្រោះហេតុមួយយ៉ាងក៏ទេ; ផលមួយយ៉ាង រមែងមាន ព្រោះសូម្បីហេតុច្រើនយ៉ាងក៏ទេ, តែថា ផលច្រើនយ៉ាងប៉ុណ្ណោះ រមែងមាន ព្រោះហេតុច្រើនយ៉ាង; ពិតមែន ផល (ពូជឈើ) ពោលគឺពន្លកមានរូប (ពណ៌) ក្លិន រសជាដើម ដែលកើតឡើងមិនមែនតិចឡើយ រមែងប្រាកដបាន ព្រោះហេតុទាំងឡាយជាអនេក គឺឧតុ ផែនដី ពូជ និងទឹក ។ ក៏ប៉ុន្តែថា ការសម្តែងហេតុ និងផលតែមួយយ៉ាង១ នេះថា **“អវិជ្ជាបច្ចយា សង្ខារា, សង្ខារប្បច្ចយា វិញ្ញាណំ** = សង្ខារទាំងឡាយកើតមាន ព្រោះអវិជ្ជាជាបច្ច័យ, វិញ្ញាណកើតមាន ព្រោះសង្ខារជាបច្ច័យ” ដែលទ្រង់ធ្វើទុកហើយ, សេចក្តីត្រូវការ គឺប្រយោជន៍ក្នុងការអធិប្បាយហេតុផលតែមួយយ៉ាង១ មានមែនពិត ។ ព្រោះថា

ព្រះមានព្រះភាគ រមែងទ្រង់សម្តែងហេតុ ឬផលមួយយ៉ាងប៉ុណ្ណោះ ដោយសមគួរដល់ទេសនាវិលាស (សេចក្តីពីរោះនៃទេសនា) និងដល់ពួកវេនេយ្យសត្វ ព្រោះក្នុងកន្លែងខ្លះ មានហេតុ និងផលជាប្រធាន; ព្រោះក្នុងកន្លែងខ្លះ មានហេតុ និងផលប្រាកដហើយ កន្លែងខ្លះ មានហេតុ និងផលជាអសាធារណៈ ។

មែនពិត ក្នុងខថា **"ផស្សប្បច្ចយា វេទនា** = វេទនារមែងកើតមានព្រោះផស្សៈជាបច្ច័យ"[២៤] ដូច្នេះនេះ **ព្រះអង្គត្រាស់ហេតុ និងផលមួយយ៉ាងប៉ុណ្ណោះ** ។ ព្រោះផស្សៈជាបធានហេតុ (ហេតុដែលជាប្រធាន) របស់វេទនា ព្រោះទ្រង់កំណត់វេទនាតាមផស្សៈ; និងវេទនាក៏ជាបធានផល (ផលដែលជាប្រធាន) របស់ផស្សៈ ព្រោះទ្រង់កំណត់ផស្សៈតាមវេទនា ។

ក្នុងខថា **"សេម្ហសមុដ្ឋានា អាពាធា** = អាពាធទាំងឡាយរមែងកើតព្រោះសេម្ហៈជាសមុដ្ឋាន"[២៥] នេះ ព្រះអង្គត្រាស់ហេតុមួយយ៉ាង ព្រោះជារបស់ប្រាកដជាក់ច្បាស់ហើយ ក៏ក្នុងអធិការនេះសេម្ហៈប្រាកដ, មិនមែនកម្មជាដើមប្រាកដទេ ។

ក្នុងខថា **"យេ កេចិ ភិក្ខវេ អកុសលា ធម្មា, សព្វេ តេ អយោនិសោ មនសិការមូលកា** = ម្នាលភិក្ខុទាំងឡាយ ពួកអកុសលធម៌ណា

---

[២៤] ទី. ម. ។

[២៥] ខុ. មហា. ។

[២៥] សំ. និ. ៣១ ។

[២៥] ម. មូ. ។

នីមួយ រមែងមាន, ពួកអកុសលធម៌ទាំងអស់នោះ មានអយោនិសោមនសិការជាមូល" ត្រាស់ហេតុតែម្យ៉ាង ព្រោះជាហេតុមិនទូទៅ ។ មែនពិត អកុសលធម៌ទាំងឡាយ មានអយោនិសោមនសិការជាអសាធារណហេតុ, តែមានវត្ថុ និងអារម្មណ៍ជាដើម ជាសាធារណហេតុដូច្នេះឯង ។ ព្រោះហេតុដូច្នោះ ក្នុងអធិការនេះ អវិជ្ជានេះ កាលធម៌ដទៃៗ មានវត្ថុអារម្មណ៍ និងសហជាតធម៌ជាដើម សូម្បីដែលជាហេតុនៃសង្ខារមាន បណ្ឌិតក៏គប្បីជ្រាបថា ព្រះអង្គទ្រង់សម្តែងដោយជាហេតុប្រធាននៃសង្ខារទាំងឡាយ ព្រោះពាក្យថា **"ហេតុ"** ដូច្នេះ ជាប្រធាននៃហេតុរបស់សង្ខារ សូម្បីពួកដទៃមានតណ្ហាជាដើម ដោយព្រះបាលីថា "កាលបុគ្គលមានប្រក្រតីតាមឃើញ សេចក្តីពេញចិត្តរឿយៗ តណ្ហារមែងចម្រើន" [១៨] ដូច្នេះ និងព្រះបាលីថា "អាសវសមុទ័យរមែងកើតព្រោះអវិជ្ជាសមុទ័យ" [១៩] និងព្រោះជាហេតុប្រាកដ និងជាអសាធារណហេតុ ព្រោះព្រះបាលីថា "ម្នាលភិក្ខុទាំងឡាយ ព្រោះសេចក្តីមិនដឹងមនុស្សល្ងង់ខ្លៅ អ្នកធ្លាក់នៅក្នុងអវិជ្ជា រមែងតាក់តែងនូវបុញ្ញាភិសង្ខារជាដើមខ្លះ" ។ ក៏ដោយពាក្យឆ្លើយការសម្តែងហេតុ និងផល តែមួយយ៉ាងៗ នោះឯង គប្បីជ្រាបប្រយោជន៍ក្នុងការសម្តែងហេតុ និងផលក្នុងទីទាំងពួងដោយប្រការដូច្នេះចុះ ។

ក្នុងខនេះ បើមានអ្នកពោលសួរថា សូម្បីកាលបើដូច្នោះ អវិជ្ជាជាធម៌ មានទោស ជាផលមិនគួរប្រាថ្នាដោយចំណែកមួយ តើគួរដល់សេចក្តីជាបច្ច័យដល់បុញ្ញាភិសង្ខារ និងអានេញ្ជាភិសង្ខារបានដូចម្តេច; ព្រោះអំពៅ រមែងមិនកើតអំពីពូជ

ស្តៅ ? ឆ្លើយថា អវិជ្ជានោះនឹងមិនគួរដល់សេចក្តីជាបច្ច័យដល់បុញ្ញាភិសង្ខារ និងអានេញ្ជាភិសង្ខារបានដូចម្តេច; ព្រោះក្នុងលោកនេះ ៖

**ធម៌ទាំងឡាយដែលសម្រេចជាបច្ច័យហើយ ខុសឋានគ្នាក៏មាន ដូចឋានគ្នាក៏មាន ម្យ៉ាងទៀត ដូចគ្នា និងមិនដូចគ្នាក៏មាន ធម៌ទាំងនោះ មិនមែនវិបាកតែម្យ៉ាងទេ ។**

អធិប្បាយថា បច្ច័យនៃធម៌ទាំងឡាយដែលឱ្យសម្រេចហើយក្នុងលោក ជាធម៌ដែលខុសប្លែកគ្នា **ដោយឋានៈ ដោយភាវៈ និងដោយកិច្ច** (នាទី) ជាដើមក៏មាន ដែលមិនខុសគ្នាក៏មាន; មែនពិត ចិត្តដួងដំបូងជាបច្ច័យដែលខុសឋានរបស់ចិត្តដួងក្រោយ, ឯការសិក្សារសិល្បៈគ្រាដំបូងជាដើម **ជាបច្ច័យដោយខុសឋាន** ដល់ការធ្វើសិល្បៈជាដើម ដែលកំពុងប្រព្រឹត្តទៅក្នុងខាងក្រោយ ។ កម្មជាបច្ច័យដែលខុសសភាវៈរបស់រូប, ទឹកដោះស្រស់ជាបច្ច័យដែលខុសសភាវៈរបស់ទឹកដោះជូរជាដើម; ពន្លឺរស្មីជាបច្ច័យដែលខុសកិច្ចរបស់ចក្ខុវិញ្ញាណ, ឯផែនស្ករអំពៅជាដើមជាបច្ច័យដែលខុសកិច្ចរបស់គ្រឿងត្រាំជាដើម ។

ចំណែកចក្ខុ និងរូបជាដើម ជាបច្ច័យមិនខុសឋានៈរបស់ចក្ខុវិញ្ញាណជាដើម; ជវ័នដួងដំបូងជាដើម ជាបច្ច័យដែលមិនខុសសភាវៈ និងមិនខុសកិច្ចជវ័នដួងក្រោយជាដើម ។ ម្យ៉ាងទៀត បច្ច័យដែលសម្រេចហើយ ខុសឋានគ្នា និងមិនខុសឋានគ្នារមែងមានយ៉ាងណា, សូម្បីបច្ច័យដែលសម្រេចហើយដែលដូចគ្នា និងមិនដូចគ្នាក៏មានដូច្នេះដែរ ។ មែនពិត រូប ពោលគឺឧតុ និងអាហារដូចគ្នានោះឯង ជាបច្ច័យដល់រូប, ពូជស្រូវសាលីជាដើម ជាបច្ច័យដល់ផលនៃស្រូវសាលីជាដើម ។ សូម្បីវត្ថុ

ដែលមិនដូចគ្នា គឺរូបជាបច្ច័យដល់អរូប អរូបជាបច្ច័យដល់រូបក៏បាន, ឯរោមគោ រោមកេះ ស្នែងសត្វ ទឹកដោះជូរ ប្រេងល្ង និងម្សៅជាដើម រមែងជាបច្ច័យដល់ស្មៅព្រិច ស្លឹកគ្រៃ [២៦] ; ម្យ៉ាងវិញទៀត ពួកធម៌ណាដែលមានបច្ច័យខុសគ្នា និងមិនខុសគ្នា និងមិនដូចគ្នា, ពួកធម៌នោះមិនមែនជាវិបាកនៃពួកធម៌នោះទេ; សូម្បីអវិជ្ជានេះ ជាធម៌មានទោស ដោយអំណាចនៃការឱ្យផល (វិបាក) និងដោយអំណាចសភាវៈ ដែលមានផលមិនគួរប្រាថ្នាដោយចំណែកតែម្យ៉ាង ក៏គប្បីជ្រាបថា អាចជាបច្ច័យដល់បុញ្ញាភិសង្ខារជាដើមនេះ សូម្បីទាំងអស់តាមសមគួរ ដោយអំណាចនៃបច្ច័យដែលខុសគ្នា និងមិនខុសគ្នា ដោយឋាន ដោយកិច្ច ដោយសភាវៈ និងដោយអំណាចនៃបច្ច័យដែលដូចគ្នា និងមិនដូចគ្នា មានប្រការដូច្នេះ ។

ក៏សេចក្ដីដែលអវិជ្ជាជាបច្ច័យនោះ ខ្ញុំពោលទុកដោយន័យមានជាអាទិ៍ ថា "មែនពិត បុគ្គលណា លះអញ្ញាណៈ (ការមិនដឹង) ពោលគឺអវិជ្ជាក្នុងសច្ចៈ ៤ មានទុក្ខសច្ចៈជាដើមមិនបាន, បុគ្គលនោះ ក៏នឹងប្រកាន់សង្សារទុក្ខ ដោយការមិនដឹងក្នុងទុក្ខ និងក្នុងខន្ធដែលជាចំណែកអតីតៈជាដើម ដោយសេចក្ដីសម្គាល់ថា ជាសុខមុនហើយ រមែងប្រារព្ធសង្ខារសូម្បី ៣ យ៉ាង (មានបុញ្ញាភិសង្ខារជាដើម) ដែលជាហេតុនៃទុក្ខនោះ" ៕

## សម្ដែងអំពីអវិជ្ជាជាបច្ច័យដល់សង្ខារម្យ៉ាងទៀត

ក៏គប្បីជ្រាបបរិយាយសូម្បីដទៃ ដូចតទៅនេះថា ៖

---

[២៦] ពាក្យថា ស្លឹកគ្រៃនេះ ជាឱសថពិសេស (សម្មោ. អដ្ឋ.) ។

**“បុគ្គលណា វង្វេងនៅក្នុងការស្លាប់ និងការកើត** (ចុតិ និងឧប្បត្តិ) **ក្នុងសង្សារ ក្នុងលក្ខណៈនៃសង្ខារទាំងឡាយ ក្នុងធម៌ដែលអាស្រ័យគ្នាហើយកើតឡើង បុគ្គលនោះរមែងតាក់តែងសង្ខារទាំង ៣ នេះ ព្រោះហេតុដែលអវិជ្ជាជាបច្ច័យដល់សង្ខារសូម្បីទាំង ៣ នេះ”** ។

ម្យ៉ាងទៀត បើមានអ្នកសួរថា ក៏បុគ្គលអ្នកវង្វេងក្នុងធម៌ទាំងនោះ រមែងធ្វើសង្ខារសូម្បីទាំង ៣ នេះ បានដូចម្តេច ?

សូមឆ្លើយថា **បុគ្គលអ្នកវង្វេងក្នុងការស្លាប់** (ចុតិ) ជាមុន កាលបើគេមិនកាន់យកនូវចុតិថា “ការបែកធ្លាយនៃខន្ធទាំងឡាយ ឈ្មោះថា **មរណៈ** ក្នុងទីគ្រប់កន្លែង” រមែងកំណត់ថា សត្វរមែងស្លាប់ គឺការឈានទៅកាន់កាយដទៃរបស់សត្វជាដើម ។ **អ្នកវង្វេងក្នុងការកើត** (ឧប្បត្តិ) ការមិនកាន់យកនូវការកើតថា ការប្រាកដនៃខន្ធទាំងឡាយក្នុងទីទាំងពួង ឈ្មោះថា **ជាតិ**, រមែងកំណត់ថាសត្វកើត គឺការដែលសត្វប្រាកដមានសរីរៈថ្មីជាដើម ។ **អ្នកលិចចុះក្នុងសង្សារវដ្ត** ការមិនកាន់ យកនូវសង្សារ ដែលលោកពណ៌នាទុកយ៉ាងនេះថា ៖

**“ខន្ធានញ្ច បដិបាដិ ធាតុអាយតនានញ្ច**
**អព្វោច្ឆិន្នា វត្តមានា សំសារោតិ បវុច្ចតិ ។**

លំដាប់នៃខន្ធ ធាតុ និងអាយតនៈទាំងឡាយ
ប្រព្រឹត្តទៅនៅមិនដាច់ខ្សែ ហៅថា សង្សារ” ។

រមែងកំណត់ហេតុជាដើមថា “សត្វនេះរមែងទៅកាន់លោកដទៃ អំពីលោកនេះ រមែងមកកាន់លោកនេះ អំពីលោកដទៃ” ។ **អ្នកវង្វេងក្នុងលក្ខណៈ**

**នៃសង្ខារទាំងឡាយ** កាលមិនកាន់យកសភាវលក្ខណៈ (លក្ខណៈនៃការមានរបស់ខ្លួន) និងសាមញ្ញលក្ខណៈ (លក្ខណៈដែលស្មើគ្នា) របស់សង្ខារទាំងឡាយ ក៏រមែងកំណត់សង្ខារទាំងឡាយ ដោយជាខ្លួន ដោយជារបស់ជាប់ជាមួយនឹងខ្លួន ដោយសេចក្តីថា ឋិតថេរ ដោយសេចក្តីថាល្អ និងដោយសេចក្តីថា សុខ ។ **អ្នកវង្វេងក្នុងធម៌ដែលអាស្រ័យគ្នាកើតឡើង** កាលមិនកាន់យកសេចក្តីប្រព្រឹត្តទៅនៃធម៌មានសង្ខារជាដើម ព្រោះបច្ច័យមានអវិជ្ជាជាដើម ក៏រមែងកំណត់ថា "អត្តារមែងដឹងខ្លះ រមែងមិនដឹងខ្លះ, អត្តានោះឯង រមែងធ្វើ រមែងញុំាងអ្នកដទៃឱ្យធ្វើ; អត្តានោះ រមែងកើតក្នុងបដិសន្ធិ, អណ្ឌូ និងព្រះសិវៈជាដើម តាំងសរីរៈរបស់អត្តានោះទុក ដោយសេចក្តីជាកលលៈជាដើម ហើយញុំាងឥន្ទ្រិយទាំងឡាយឱ្យបរិបូណ៌; អត្តានោះ បរិបូណ៌ដោយឥន្ទ្រិយ រមែងពាល់ត្រូវ រមែងសោយ រមែងកាន់យក រមែងប្រកាន់មាំ រមែងបន្ត, អត្តានោះ នឹងមានក្នុងភពដទៃទៀត" ខ្លះថា "សត្វទាំងឡាយទាំងពួង ជាអ្នកប្រែប្រួលទៅ ជារបស់ទៀង ជារបស់ជាប់ទាក់ទងគ្នា"[២៧] ដូច្នេះខ្លះ; បុគ្គលនោះដែលត្រូវអវិជ្ជាធ្វើឱ្យខ្វាក់ហើយ ការកំណត់យ៉ាងនេះ រមែងតាក់តែងអភិសង្ខារ គឺបុណ្យខ្លះ បាបខ្លះ អានេញ្ជាខ្លះ ដូចមនុស្សខ្វាក់ភ្នែក កាលត្រាច់ទៅលើផែនដី រមែងដើរក្នុងផ្លូវខ្លះ ក្រៅផ្លូវខ្លះ ទីខ្ពស់ខ្លះ ទីទាបខ្លះ ស្មើគ្នាខ្លះ មិនស្មើគ្នាខ្លះ" ; ដោយហេតុនោះ បណ្ឌិតនឹងពោលគាថានេះទុកថា ៖

**"យថាបិ នាម ជច្ចន្ធោ នរោ អបរិនាយកោ**
**ឯកទា យាតិ មគ្គេន ឧម្មគ្គេនាបិ ឯកទា ។**

---

[២៧] ទី. សី. ។

ធម្មតា មនុស្សខ្វាក់តាំងពីកំណើត មិនមានអ្នកណានាំទៅ ក្នុងពេលខ្លះ
ដើរតាមផ្លូវ ពេលខ្លះដើរទៅក្រៅផ្លូវ យ៉ាងណាមិញ ។

**សំសារេ សំសរំ ពាលោ តថា អបរិនាយកោ**
**ករោតិ ឯកទា បុញ្ញំ អបុញ្ញំបិ ឯកទា ។**

បុគ្គលពាលក៏យ៉ាងនោះដែរ កាលត្រេចទៅក្នុងវដ្តសង្សារ មិនមានអ្នក
ណាដឹកនាំ ប្រៀនប្រដៅ ក្នុងពេលខ្លះធ្វើបុណ្យ ពេលខ្លះធ្វើបាប ។

**យទា ញត្វា ច សោ ធម្មំ សច្ចានិ អភិសមេស្សតិ**
**តទា អវិជ្ជូបសមា ឧបសន្តោ ចរិស្សតិ ។**

ម្យ៉ាងទៀត កាលណាបុគ្គលពាលនោះ ត្រាស់ដឹងធម៌ហើយ
នឹងត្រាស់ដឹងសច្ចៈទាំងឡាយ កាលនោះ គេនឹងចូលដល់
ការស្ងប់ ព្រោះត្រាច់ទៅទាំងអវិជ្ជាស្ងប់ហើយ” ។
នេះជាកថាពិស្តារក្នុងបទថា **អវិជ្ជាបច្ចយា សង្ខារា** ៕

**ចប់និទ្ទេសនៃអវិជ្ជាជាបច្ច័យ**

## សម្តែងអំពីនិទ្ទេសនៃសង្ខារជាបច្ច័យដល់វិញ្ញាណ

គប្បីជ្រាបវិនិច្ឆ័យក្នុងបទថា **ចក្ខុវិញ្ញាណំ** ជាដើម ក្នុងនិទ្ទេសនៃបទថា **វិញ្ញាណកើតមាន ព្រោះសង្ខារជាបច្ច័យ** តទៅ ៖

ចក្ខុវិញ្ញាណ មាន ២ យ៉ាង គឺជាកុសលវិបាក និងអកុសលវិបាក ។ សោតវិញ្ញាណ ឃានវិញ្ញាណ ជិវ្ហាវិញ្ញាណ និងកាយវិញ្ញាណ ក៏មាន ២ យ៉ាងៗ ដូចគ្នា (ហៅថា ទ្វិបញ្ចវិញ្ញាណ ១០) ។ ចំណែកមនោវិញ្ញាណមាន ២២ យ៉ាង គឺ

-មនោធាតុដែលជាកុសល និងអកុសលវិបាក ២

-អហេតុកមនោវិញ្ញាណធាតុ ៣

-សហេតុកាមាវចរវិបាកចិត្ត ៨

-រូបាវចរវិបាកចិត្ត ៥

-អរូបាវចរវិបាកចិត្ត ៤ ។

សូម្បីលោកិយវិញ្ញាណទាំងអស់ មាន ៣២ ដែលសង្គ្រោះ (រួបរួមទុក) ដោយវិញ្ញាណទាំង ៦ យ៉ាងនេះ ដោយប្រការដូច្នេះ; ចំណែកលោកុត្តរវិញ្ញាណទាំងឡាយ មិនគួរក្នុងវដ្តកថា ព្រោះហេតុដូច្នោះ ទើបមិនកាន់យក ។

ក្នុងនិទ្ទេសសង្ខារជាបច្ច័យដល់វិញ្ញាណនោះ ប្រសិនបើមានពាក្យសួរថា ក៏ខនេះ នឹងគប្បីដឹងបានដូចម្តេចថា វិញ្ញាណមានប្រការតាមដែលពោលមកនេះ រមែងមាន ព្រោះសង្ខារជាបច្ច័យ ?

ឆ្លើយថា ដឹងបាន ព្រោះកាលដែលមិនមានកម្មសាងទុក វិបាកក៏មិនមាន ។

មែនពិត វិញ្ញាណនេះជាវិបាក, ក៏វិបាករមែងមិនកើត ព្រោះមិនមានកម្មដែលសាងទុក; បើថា នឹងគប្បីកើតសោត វិបាកទាំងអស់ ក៏គប្បីកើតដល់ពួកសត្វគ្រប់ជំពូក, តែក៏មិនអាចកើតទេ ព្រោះហេតុដូច្នោះ ខនេះ ក៏នឹងគប្បីជ្រាបបានថា "វិញ្ញាណនេះ រមែងមាន ព្រោះសង្ខារជាបច្ច័យ" ។

បើមានពាក្យសួរថា វិញ្ញាណណាមាន ព្រោះសង្ខារណា ជាបច្ច័យ ?

ឆ្លើយថា កុសលវិបាកចិត្ត ១៦ ដួង គឺចក្ខុវិញ្ញាណជាដើម ដែលជាកុសលវិបាក ៥ ដួង, មនោធាតុដែលជាកុសលវិបាក ១ ដួង, មនោវិញ្ញាណ

ធាតុ (កុសលវិបាក) **២ ដួង, កាមាវចរមហាវិបាក ៨ ដួង** មានព្រោះបុញ្ញាភិសង្ខារដែលជាកាមាវចរជាបច្ច័យមុន ។

ដូចយ៉ាងដែលត្រាស់ទុកថា **“ចក្ខុវិញ្ញាណដែលជាវិបាកចិត្តកើតឡើងព្រោះកាមាវចរកុសលកម្ម ដែលធ្វើទុកហើយ ដែលសន្សំទុកហើយ** ។ សោតវិញ្ញាណ ឃានវិញ្ញាណ ជិវ្ហាវិញ្ញាណ និងកាយវិញ្ញាណ ក៏កើតឡើងដូចគ្នា (រួម ៥ ដង) ។ មនោធាតុដែលជាកុសលវិបាក (សម្បដិច្ឆន្នចិត្ត ១ ដួង) ក៏កើតឡើង ។ មនោវិញ្ញាណធាតុ ២ ដួង គឺដែលសម្បយុត្តដោយសោមនស្ស និងសម្បយុត្តដោយឧបេក្ខា ក៏កើតឡើង ។ **កាមាវចរមហាវិបាក ៨ គឺមនោវិញ្ញាណធាតុ** ដែលសហគតៈដោយសោមនស្ស, សម្បយុត្តដោយញ្ញាណជាអសង្ខារ (មិនមានការដឹកនាំ) ១ ដួង, ដែលសហគតៈដោយសោមនស្ស សម្បយុត្តដោយញ្ញាណជាសសង្ខារ ១ ដួង, ដែលសហគតៈដោយសោមនស្ស ជាញ្ញាណវិប្បយុត្តជាអសង្ខារ ១ ដួង, ដែលសហគតៈដោយសោមនស្ស ជាញ្ញាណវិប្បយុត្តជាសង្ខារ ១ ដួង, ដែលសហគតៈដោយឧបេក្ខា សម្បយុត្តដោយញ្ញាណជាអសង្ខារ ១ ដួង, ដែលសហគតៈដោយឧបេក្ខា សម្បយុត្តដោយញ្ញាណជាសសង្ខារ ១ ដួង, ដែលសហគតៈដោយឧបេក្ខា ជាញ្ញាណវិប្បយុត្តជាអសង្ខារ ១ ដួង, ដែលសហគតៈដោយឧបេក្ខា ជាញ្ញាណវិប្បយុត្តជាសសង្ខារ ១ ដួង ក៏កើតឡើង”[២៨] ។

ម្យ៉ាងទៀត រូបាវចរវិបាក ៥ ដួង កើតព្រោះ **បុញ្ញាភិសង្ខារដែលជារូបាវចរ ជាបច្ច័យ** ។ ដូចយ៉ាងដែលត្រាស់ទុកថា **“កាលយោគាវចរបុគ្គលនោះឯង**

---

[២៨] អភិ. ៧៨ ។

ស្ងាត់ចាក កាមទាំងឡាយហើយ ពន្លុះបឋមជ្ឈាន ។ល។ ពន្លុះបញ្ចមជ្ឈានដែលជាវិបាក ព្រោះរូបាវចរដែលបានធ្វើទុកហើយ បានមានការសន្សំទុកហើយ”[២៩] ។

វិញ្ញាណ ២១ ដួងមាន ព្រោះបុញ្ញាភិសង្ខារជាបច្ច័យ ដោយប្រការដូច្នេះ ។ ម្យ៉ាងទៀត វិញ្ញាណ ៧ ដួង គឺ ចក្ខុវិញ្ញាណជាដើម ដែលជាអកុសលវិបាក ៥ ដួង, មនោធាតុ (សម្បដិច្ឆន្នចិត្ត) ១ ដួង, មនោវិញ្ញាណធាតុ ១ ដួង មានព្រោះ **អបុញ្ញាភិសង្ខារជាបច្ច័យ** ។

ដូចយ៉ាងដែលត្រាស់ទុកថា “**ចក្ខុវិញ្ញាណដែលជាវិបាកកើតឡើង ព្រោះអកុសលកម្មដែលធ្វើទុកហើយ ដែលសន្សំទុកហើយ** ។ សោតវិញ្ញាណ ឃានវិញ្ញាណ ជិវ្ហាវិញ្ញាណ និងកាយវិញ្ញាណដែលជាវិបាក ក៏កើតឡើងដូចគ្នា (រួមត្រូវជា ៥ ដួង) មនោធាតុវិបាក ១ ដួង, មនោវិញ្ញាណធាតុ (សន្តីរណចិត្ត) ១ ដួង”[៣០] ។

វិញ្ញាណ ៤ ដួងយ៉ាងនេះ គឺ អរូបវិបាក ៤ ដួង **មានព្រោះអានេញ្ជាភិសង្ខារជាបច្ច័យ**; ដូចយ៉ាងដែលត្រាស់ទុកថា “ព្រះយោគាចរបុគ្គលឈានកន្លងរូបសញ្ញា ដោយប្រការទាំងពួង ទើបពន្លុះចតុត្ថជ្ឈានភូមិដែលជាវិបាក សហគតៈដោយអាកាសានញ្ចាយតនសញ្ញា ។ល។ វិញ្ញាណញ្ចាយតនសញ្ញា ។ល។ អាកិញ្ចញ្ញាយតនសញ្ញា ។ល។ ដែលសហគតៈដោយនេវសញ្ញានាសញ្ញាយតនសញ្ញា ព្រោះលះសុខចេញបាន ព្រោះអរូបាវចរកុសលកម្មនោះនុ៎ះឯង ដែលបានធ្វើទុក

---

[២៩] អភិ. ៧៨ ។

[៣០] អភិ. ៧៨ ។

ហើយ សន្សំទុកហើយ”[៣១] ៕

## សម្តែងអំពីបវត្តិវិញ្ញាណ ២ យ៉ាង

វិញ្ញាណណា រមែងមានព្រោះសង្ខារជាបច្ច័យ, បណ្ឌិតគប្បីជ្រាបវិញ្ញាណនោះ តាមដែលពណ៌នាមកដូច្នេះហើយ ឥឡូវនេះ គប្បីជ្រាបបវត្តិ (ការប្រព្រឹត្តទៅ) របស់វិញ្ញាណនោះ ដូចតទៅ ៖

មែនពិត វិញ្ញាណទាំងអស់នេះឯង រមែងប្រព្រឹត្តទៅ ២ យ៉ាង ដោយអំណាចនៃបវត្តិវិញ្ញាណ និងបដិសន្ធិវិញ្ញាណ; ក្នុងវិញ្ញាណទាំង ២ នោះ ទ្វិបញ្ចវិញ្ញាណ (វិញ្ញាណ ១០ ដួង) មនោធាតុ ២ ដួង អហេតុកមនោវិញ្ញាណធាតុ ដែលសហគតដោយសោមនស្ស ១ ដួង រួមជា ១៣ ដួងទាំងនេះ រមែងប្រព្រឹត្តទៅក្នុងបវត្តិកាលក្នុងបញ្ចវោការភពប៉ុណ្ណោះ; វិញ្ញាណដ៏សេស ១៩ ដួង រមែងប្រព្រឹត្តទៅក្នុងបវត្តិកាលខ្លះ ក្នុងបដិសន្ធិកាលខ្លះ តាមសមគួរក្នុងភពទាំង ៣ ។ តើដូចម្តេច ?

## វិញ្ញាណក្នុងបញ្ចវោការភពក្នុងបវត្តិកាល ១៣ ដួង

វិញ្ញាណ ៥ មានចក្ខុវិញ្ញាណជាដើមដែលជាកុសលវិបាកជាមុនសិន សម្រាប់អ្នកកើតដោយកុសលវិបាក ឬអកុសលវិបាក អ្នកមានឥន្ទ្រិយ៍ដែលចូលដល់ភាពចាស់ក្លាតាមលំដាប់ ប្រារព្ធអារម្មណ៍មានរូបារម្មណ៍ជាដើម ដែលគួរប្រាថ្នា ឬមិនគួរប្រាថ្នា ដែលមកកាន់គន្លងនៃចក្ខុទ្វារជាដើម អាស្រ័យប្រាសាទមានចក្ខុប្រាសាទ

---

[៣១] អភិ. ៧៨ ។

ជាដើម ទើបឱ្យសម្រេច**ទស្សនកិច្ច** (ការឃើញ); **សវនកិច្ច** (ការបានឮ); **ឃាយនកិច្ច** (ការបានហិតក្លិន); **សាយនកិច្ច** (ការលិទ្ធរស); **ផុស្សនកិច្ច** (ការប៉ះពាល់)ហើយប្រព្រឹត្តទៅ ។ វិញ្ញាណ ៥ ដែលជាអកុសលវិបាកក៏ដូចគ្នាដែរ ។ ក៏វិញ្ញាណ ៥ ដែលជាអកុសលវិបាកទាំងនោះមានរូបជាដើម ជាអារម្មណ៍ **ជាអនិដ្ឋារម្មណ៍** និង**ជាអនិដ្ឋមជ្ឈត្តារម្មណ៍**ត្រឹមតែម្យ៉ាង, សេចក្ដីនេះប៉ុណ្ណោះដែលប្លែកគ្នា; ក៏សូម្បីវិញ្ញាណ ទាំង ១០ នេះ មានទ្វារដែលប្រាកដ អារម្មណ៍ដែលប្រាកដ វត្ថុដែលប្រាកដ និងមានកិច្ចដែលប្រាកដដូចគ្នា ។

តអំពីនោះ មនោធាតុដែលជាកុសលវិបាកក្នុងលំដាប់នៃចក្ខុវិញ្ញាណជាដើម ដែលជាកុសលវិបាក ប្រារព្ធអារម្មណ៍នៃចក្ខុវិញ្ញាណជាដើមទាំងនោះឯង អាស្រ័យហទយវត្ថុ ញុំាងសម្បដិច្ឆន្នកិច្ច (កិច្ចទទួលអារម្មណ៍) ឱ្យសម្រេចហើយប្រព្រឹត្តទៅ។ មនោធាតុដែលជាអកុសលវិបាក ក្នុងលំដាប់នៃចក្ខុវិញ្ញាណជាដើម ដែលជាអកុសលវិបាកក៏ដូចគ្នាដែរ ។ ក៏ប៉ុន្តែថា មនោធាតុទាំង ២ នេះ (គឺដែលជាកុសលវិបាក និងអកុសលវិបាក) មានទ្វារ និងអារម្មណ៍មិនប្រាកដ មានវត្ថុប្រាកដ និងមានកិច្ច (នាទី) ប្រាកដ ។

ចំណែកមនោវិញ្ញាណធាតុ ជាអហេតុកៈ ដែលសហគតដោយសោមនស្ស ប្រារព្ធអារម្មណ៍ របស់ចក្ខុវិញ្ញាណជាដើមទាំងនោះឯង ក្នុងលំដាប់នៃមនោធាតុដែលជាកុសលវិបាក អាស្រ័យហទយវត្ថុ ញុំាងសន្តីរណកិច្ចឱ្យសម្រេច កាត់ផ្ដាច់វីថិដោយភវង្គក្នុងអារម្មណ៍ ដែលមានកម្លាំងក្នុងទ្វារ ៦ ក្នុងទីបំផុតនៃជវ័ន ដែលសម្បយុត្តដោយលោភៈខ្លះ របស់សត្វក្នុងកាមាវចរ ដោយច្រើន រមែងប្រព្រឹត្តទៅមួយ

គ្រាខ្លះ ពីរគ្រាខ្លះ ដោយអំណាចនៃតទារម្មណ៍ក្នុងអារម្មណ៍ដែលជវ៌នសោយហើយ ។ តែក្នុងការរាប់សេចក្ដីប្រព្រឹត្តទៅរបស់ចិត្ត ក្នុងតទារម្មណ៍គ្រប់ទ្វារទាំងឡាយ មានវារៈនៃចិត្ត ២ ខណៈប៉ុណ្ណោះមកហើយ, ក៏ចិត្តនេះ បានឈ្មោះ ២ យ៉ាង គឺតទាលម្ពណៈ និងទិដ្ឋិភវង្គ (ភវង្គដួងចុងក្រោយ) មានទ្វារ និងអារម្មណ៍មិនប្រាកដ; មានវត្ថុប្រាកដ; មានឋានៈ និងកិច្ច មិនប្រាកដ; ចិត្ត ១៣ ដួង គប្បីជ្រាបថា រមែងប្រព្រឹត្តទៅក្នុងបញ្ចវោការភព ក្នុងបវត្តិកាល ដោយប្រការយ៉ាងនេះ ៕

## សម្ដែងអំពីចិត្តក្នុងបវត្តិកាល និង បដិសន្ធិកាល ក្នុងភព ៣ ១៩ ដួង

បណ្ដាចិត្ត ១៩ ដួងដ៏សេស ចិត្តអ្វីៗ រមែងមិនប្រព្រឹត្តទៅក្នុងបដិសន្ធិតាមសមគួរដល់ខ្លួនៗ មិនមានទេ; តែក្នុងបវត្តិកាល មនោវិញ្ញាណធាតុដែលជាអហេតុកៈ ២ ដួង គឺជាកុសលវិបាក និងអកុសលវិបាក ក្នុងខាងដើមឱ្យសម្រេចកិច្ច ៤ យ៉ាង គឺ **សន្តីរណកិច្ច** ក្នុងលំដាប់នៃមនោធាតុដែលជាកុសលវិបាក ឬអកុសលវិបាក ក្នុងបញ្ចទ្វារ ១ ដួង; **ជាតទារម្មណកិច្ច** ក្នុងទ្វារ ៦ ដោយន័យដែលពោលទុកក្នុងខាងដើមនោះឯង ១ ដួង; **ជាភវង្គកិច្ច** ក្នុងកាលផុតអំពីបដិសន្ធិដែលខ្លួនឱ្យហើយ មិនមានចិត្តុប្បាទចូលទៅកាត់ផ្ដាច់នូវភវង្គ ១ ដួង **និងចុតិកិច្ច** ក្នុងទីបំផុត ១ ដួង; មានហទយវត្ថុប្រាកដ មានទ្វារ មានអារម្មណ៍ ឋាន និងកិច្ចមិនប្រាកដហើយប្រព្រឹត្តទៅ ។

សហេតុកចិត្តដែលជាកាមាវចរ ៨ ដួង រមែងញ៉ាំងកិច្ច ៣ យ៉ាង ឱ្យសម្រេច គឺ **ជាតទារម្មណកិច្ច** ក្នុងទ្វារទាំង ៦ ដោយន័យដែលបានពោលទុកក្នុងបវត្តិកាល ១ ដួង; **ជាភវង្គកិច្ច** ក្នុងកាលជាទីបំផុតអំពីបដិសន្ធិកិច្ចដែលខ្លួនឱ្យហើយ មិនមានចិត្តុប្បាទ ដែលចូលទៅកាត់នូវភវង្គ ១ ដួង; **ចុតិកិច្ច** ក្នុងកាលជាទីបំផុត ១ ដួង; មានវត្ថុប្រាកដ មានទ្វារអារម្មណ៍ ឋាន និងកិច្ចមិនប្រាកដ ហើយប្រព្រឹត្តទៅ ។

រូបាវចរវិបាកចិត្ត ៥ ដួង និងអរូបាវចរវិបាកចិត្ត ៤ ដួង រមែងញ៉ាំងកិច្ច ២ យ៉ាងឱ្យប្រព្រឹត្តទៅ គឺ **ជាភវង្គកិច្ច** ក្នុងកាលជាទីបំផុតអំពីបដិសន្ធិកិច្ចដែលខ្លួនឱ្យហើយ មិនមានចិត្តុប្បាទដទៃចូលទៅកាត់ផ្តាច់នូវភវង្គ ១ ដួង **និងចុតិកិច្ច** ក្នុងកាលជាទីបំផុត ១ ដួង ។ បណ្តាវិបាកចិត្ត ៩ ដួងនោះ រូបាវចរវិបាកចិត្ត មានវត្ថុ និងអារម្មណ៍ប្រាកដ មានឋាន និងកិច្ចមិនប្រាកដឡើយ វិបាកចិត្តក្រៅនេះ មិនមានវត្ថុ (អរូប) មានអារម្មណ៍ប្រាកដ មានឋាន និងកិច្ចមិនប្រាកដ ហើយប្រព្រឹត្តទៅ ។

សូម្បីវិញ្ញាណ (ជាវិបាក) ៣២ ដួង រមែងប្រព្រឹត្តទៅ ព្រោះសង្ខារជាបច្ច័យក្នុងបវត្តិកាល ដោយប្រការយ៉ាងនេះសិន ក្នុងបវត្តិកាលនោះ សង្ខារពួកនោះ៧ រមែងជាបច្ច័យដល់វិញ្ញាណ ៣២ នោះ ដោយកម្មប្បច្ច័យ និងឧបនិស្សយប្បច្ច័យ ៕

## សម្តែងអំពីហេតុដែលតទារម្មណ៍មិនប្រព្រឹត្តទៅ ក្នុងរូបភូមិ និង អរូបភូមិ

ក្នុងវិបាកវិញ្ញាណទាំង ៣២ ដួងនោះ ត្រាស់តទារម្មណចិត្ត ១១ ដួងនោះ

ទុក ក្នុងវិបាកតទាលម្ពណចិត្តទាំង ១១ នោះ, សូម្បីក្នុងវិបាកចិត្ត ១ ដួង ជាតទារម្មណ៍ក្នុងរូបភព និងអរូបភព ប្រព្រឹត្តទៅមិនបានឡើយ; ព្រោះហេតុអ្វី ? ព្រោះមិនមានពូជ; ពិតមែន ក្នុងរូបភូមិ និងអរូបភូមិនោះ ពូជ គឺបដិសន្ធិ ពោលគឺកាមាវចរវិបាកដែលឱ្យកើតក្នុងតទារម្មណកិច្ច ក្នុងអារម្មណ៍មានរូបជាដើម រមែងមិនមាន; បើមានអ្នកដទៃឆ្ងល់ថា បើយ៉ាងនោះ ចក្ខុវិញ្ញាណជាដើម ក៏មិនមានប្រាកដក្នុងរូបភពមិនមែនឬ ? ឆ្លើយថា មិនមែនដូច្នេះឡើយ; ព្រោះអានុភាពនៃការប្រព្រឹត្តទៅរបស់ឥន្ទ្រិយ និងចិត្តនិយមក្នុងកាលផ្សេងគ្នានៃទ្វារវិថិ ។

ក៏តទារម្មណ៍នេះ រមែងមិនប្រព្រឹត្តទៅក្នុងរូបភព និងអរូបភពពិតប្រាកដយ៉ាងណា, ក៏រមែងមិនជាប់តាមធម៌ ដែលមិនមែនកាមាវចរសូម្បីទាំងអស់យ៉ាងនោះ; ព្រោះហេតុអ្វី ? ព្រោះមិនមែនជាកាមាវចរធម៌ ធ្វើឱ្យតទារម្មណ៍កើតមិនបាន និងព្រោះមិនដូចជាមួយធម៌ដែលខ្លួនធ្វើឱ្យកើត ។ ពិតមែន តទារម្មណ៍នោះប្រៀបដូចជាទារកវ័យក្មេង ចេញអំពីផ្ទះត្រូវការទៅខាងក្រៅ ក៏តោងចាប់ដៃបិតាអ្នកឱ្យកំណើតរបស់ខ្លួន ឬញាតិអ្នកប្រាថ្នាប្រយោជន៍ដូចបិតាហើយទៅ; មិនមែនជាប់តាមមនុស្សដទៃមានរាជបុរសជាដើមទៅទេ យ៉ាងណា; សូម្បីតទារម្មណ៍នេះក៏ដូច្នោះដែរ រមែងជាប់តាមកាមាវចរជវ័នប៉ុណ្ណោះ ដែលជាបិតាបង្កើតរបស់ខ្លួន ឬអ្នកជាញាតិដូចបិតារបស់ខ្លួន ព្រោះជាធម៌ដែលចេញទៅខាងក្រៅពីអារម្មណ៍; ភវង្គក៏ដូចគ្នាដែរ រមែងមិនជាប់តាមចិត្តដទៃ គឺមហគ្គតៈ ឬលោកុត្តរៈ ។

ម្យ៉ាងទៀត តទារម្មណ៍នេះ រមែងមិនជាប់តាមមហគ្គតៈ និងលោកុត្តរធម៌យ៉ាងណា, សូម្បីកាមាវចរធម៌ទាំងនេះ ក៏ដូច្នោះដែរ កាលណាចិត្តជាធម៌ មាន

មហគ្គតៈជាអារម្មណ៍ប្រព្រឹត្តទៅ, កាលនោះតទារម្មណ៍នេះ ក៏រមែងមិនជាប់តាម ធម៌ ដែលមានមហគ្គតៈជាអារម្មណ៍ទាំងនោះទៅទេ; ព្រោះហេតុអ្វី ? ព្រោះជាកន្លែងដែលមិនធ្លាប់ទៅ និងព្រោះភាវៈនៃខ្លួនជាបរិត្តៈ (កាម) អារម្មណ៍ ដោយចំណែកមួយ ។ មែនពិត តទារម្មណ៍នោះ ប្រៀបដូចទារកដែលនៅវ័យក្មេង កាលជាប់តាមបិតា ឬញាតិអ្នកដូចជាបិតាទៅ ក៏ទៅត្រឹមទ្វារផ្ទះ ចន្លោះផ្លូវ ឬត្រឹមផ្លូវបែកជា ៤ ជាដើមប៉ុណ្ណោះ រមែងមិនជាប់តាមអ្នកទៅកាន់ព្រៃ ឬសមរភូមិយ៉ាងណា, សូម្បីតទារម្មណ៍នោះ ក៏ដូច្នោះដែរ កាលជាប់តាមកាមាវចរធម៌ទាំងឡាយ ក៏រមែងជាប់តាមធម៌ទាំងឡាយទៅក៏ជាប់តាមធម៌ទាំងនោះ ដែលប្រព្រឹត្តទៅក្នុងកន្លែងធ្លាប់ទៅ មានធម៌ដែលមិនមែនមហគ្គតៈជាដើមប៉ុណ្ណោះ, មិនមែនជាប់តាមគឺប្រារព្ធមហគ្គតៈ និងលោកុត្តរធម៌ទាំងនោះទៅទេ; និងព្រោះអារម្មណ៍ដែលជាបរិត្តៈ (កាម) ដោយចំណែកតែម្យ៉ាង ដែលពោលទុកយ៉ាងនេះថា "កាមាវចរវិបាកទាំងអស់ កិរិយាមនោធាតុ កិរិយាអហេតុកមនោវិញ្ញាណធាតុ ធម៌ដែលសហគតៈដោយសោមនស្សទាំងនេះជាបរិត្តារម្មណ៍" ; ព្រោះហេតុនោះ តទារម្មណ៍នេះបណ្ឌិតគប្បីជ្រាបថា សូម្បីមិនជាប់តាមកាមាវចរធម៌ ដែលមានសហគ្គតធម៌ និងលោកុត្តរធម៌ជាអារម្មណ៍ប្រព្រឹត្តទៅដូច្នោះ ។

ម្យ៉ាងទៀត នឹងមានប្រយោជន៍អ្វីដោយយុត្តិកថា (ពាក្យប្រកបអាង) នេះ; ព្រោះព្រះអដ្ឋកថាចារ្យពោលទុកក្នុងអដ្ឋកថាដោយចំណែកតែម្យ៉ាងថា តទារម្មណចិត្ត ១១ ដួង រមែងមិនទទួលតទារម្មណ៍ ក្នុងកាលដែលជវ័នប្រារព្ធនាម និងគោត្រហើយស្ទុះទៅ តទារម្មណ៍រមែងមិនបានក្នុងកាលជវ័នដែលប្រារព្ធបញ្ញត្តិហើយ

ស្ងុះទៅ ។ តទារម្មណ៍ រមែងមិនបានក្នុងវិបស្សនាដែលមានអារម្មណ៍ជាត្រៃលក្ខណ៍, តទារម្មណ៍រមែងមិនកើតក្នុងពលវិបស្សនាដែលជាវុដ្ឋានគាមិនី, តទារម្មណ៍រមែងមិនបានកើតក្នុងជវ័នដែលប្រារព្ធធម៌ជារូប និងអរូបហើយស្ទុះទៅ, តទារម្មណ៍រមែងមិនកើតក្នុងធម៌ដែលជាមិច្ឆត្តនិយតៈ, តទារម្មណ៍រមែងមិនកើតក្នុងធម៌ដែលជាសម្មត្តនិយតៈ, តទារម្មណ៍រមែងមិនកើតនៅក្នុងជវ័ន ដែលប្រារព្ធលោកុត្តរធម៌ហើយស្ទុះទៅឡើយ, តទារម្មណ៍រមែងមិនកើតក្នុងជវ័នដែលប្រារព្ធអភិញ្ញាញាណ, តទារម្មណ៍រមែងមិនកើតក្នុងកាលជវ័នដែលប្រារព្ធបដិសម្ភិទាញាណ ហើយស្ទុះទៅឡើយ, តទារម្មណ៍រមែងមិនកើតក្នុងកាមាវចរដែលមានអារម្មណ៍ទុព្វលភាព, តែរមែងបានក្នុងអារម្មណ៍ដែលមានកម្លាំងមកកាន់គន្លងក្នុងទ្វារទាំង ៦ នោះ, ក៏តទារម្មណ៍នោះ កាលកើត រមែងកើតក្នុងកាមាវចរតែម្យ៉ាង, ឈ្មោះថា តទារម្មណ៍ក្នុងរូបភព និងអរូបភពនោះឯង មិនមានសោះឡើយ ។

ម្យ៉ាងវិញទៀត ពាក្យណាដែលខ្ញុំបានពោលទុកថា “បណ្ដាចិត្ត ១៩ ដួងដ៏សេស ចិត្តអ្វី១ មិនប្រព្រឹត្តទៅដោយអំណាចបដិសន្ធិ តាមសមគួរដល់ខ្លួន” , ពាក្យនោះនរណា១ ក៏យល់ចូលចិត្តបានដោយកម្រ ព្រោះសង្ខេបពេក; ព្រោះហេតុនោះ ដើម្បីសម្ដែងន័យដោយពិស្ដារសម្រាប់ពាក្យនោះ ខ្ញុំនឹងពោលនូវពាក្យសួរថា “**បដិសន្ធិមានប៉ុន្មាន ?, បដិសន្ធិចិត្តមានប៉ុន្មាន ?, បដិសន្ធិមានក្នុងភូមិណា ? ដោយចិត្តអ្វី ?, អារម្មណ៍របស់បដិសន្ធិចិត្តមានដូចម្ដេច ?**” ៕

## សម្តែងអំពីបដិសន្ធិ ២០ ប្រភេទ

ក្នុងបញ្ហាកម្មនោះ វិស្សជ្ជនាថា បដិសន្ធិមាន ២០ ប្រភេទ រួមទាំងអសញ្ញីបដិសន្ធិផង, បដិសន្ធិមានចិត្ត ១៩ ដួង មានប្រការដូចពោលហើយនោះឯង ។ បណ្តាបដិសន្ធិចិត្តទាំងនោះ បដិសន្ធិក្នុងអបាយភូមិ ៤ រមែងមានដោយអហេតុកមនោវិញ្ញាណធាតុដែលជាអកុសលវិបាក ១ ដួង, បដិសន្ធិរបស់សត្វអ្នកខ្វាក់អំពីកំណើត ថ្លង់អំពីកំណើត ឆ្កួតអំពីកំណើត អ្នកទាំងថ្លង់ ទាំងគអំពីកំណើត និងខ្ទើយជាដើម ក្នុងមនុស្សលោក និងភូម្មទេវតា រមែងមានដោយអហេតុកមនោវិញ្ញាណធាតុដែលជាកុសលវិបាក ១ ដួង; បដិសន្ធិរបស់អ្នកមានបុណ្យទាំងឡាយ ក្នុងពួកទេវតាជាន់កាមាវចរ និងក្នុងពួកមនុស្ស រមែងមានដោយសហេតុកមហាវិបាក ៨ ដួង, បដិសន្ធិរបស់អ្នកមានបុណ្យក្នុងរូបព្រហ្ម រមែងមានដោយរូបាវចរវិបាក ៥ ដួង, បដិសន្ធិរបស់អ្នកមានបុណ្យក្នុងអរូបព្រហ្ម រមែងមានដោយអរូបាវចរវិបាក ៤ ដួង; ក៏បដិសន្ធិរមែងមានក្នុងភូមិណា ដោយចិត្តណា, បដិសន្ធិនោះឯង ឈ្មោះថាបដិសន្ធិ សមគួរដល់ចិត្តដួងនោះៗ ៕

## សម្តែងអំពីអារម្មណ៍របស់បដិសន្ធិ ៣ យ៉ាង

សម្តែងដោយសង្ខេប **អារម្មណ៍របស់បដិសន្ធិចិត្តមាន ៣** គឺ

- **កម្ម** អំពើ
- **កម្មនិមិត្ត** និមិត្តនៃកម្ម
- **គតិនិមិត្ត** និមិត្តនៃគតិ (ដំណើរ) ។

បណ្ដាអារម្មណ៍ទាំង ៣ នេះ ចេតនាជាកុសល និងអកុសលដែលធ្វើហើយ ឈ្មោះថា **កម្ម**; កម្មរមែងប្រកបវត្ថុណាធ្វើឱ្យជាអារម្មណ៍ វត្ថុនោះ ឈ្មោះថា **កម្មនិមិត្ត**; ក្នុងកម្ម និងកម្មនិមិត្តនោះ កាលកម្មដែលសត្វធ្វើទុកក្នុងអតីតៈ សូម្បីក្នុងទីបំផុតនៃសែនកោដិកប្បមកហើយ កម្មនោះរមែងមកប្រាកដជាកម្ម ឬកម្មនិមិត្តក្នុងខណៈនោះ ។ ក្នុងសេចក្ដីនេះមានរឿងសាធកនៃកម្មនិមិត្ត ដូចតទៅនេះ ៖

## រឿងនាយគោបកសីវលី

បានឮមកថា បុរសឈ្មោះគោបកសីវលី ញ៉ាំងបុគ្គលឱ្យសាងព្រះចេតិយ ក្នុងវិហារ ឈ្មោះថា **តាលបិដ្ឋិកៈ**, កាលគេដេកលើគ្រែជិតមរណៈ ព្រះចេតិយប្រាកដហើយ; គេកាន់យកចេតិយនោះឯងជានិមិត្ត ស្លាប់ហើយ ទៅកើតក្នុងទេវលោក ។

## រឿងការស្លាប់របស់អ្នកវង្វេង

នៅមានរឿងស្លាប់មួយទៀត ឈ្មោះថា **សម្មុឡ្ហកាលកិរិយា** (ការធ្វើកាលកិរិយារបស់អ្នកវង្វេង); ពិតមែន កាលបុគ្គលកំពុងដើរទៅខាងមុខ បុគ្គលម្នាក់យកដាវដ៏មុតកាត់សីសៈអំពីខាងក្រោយក្ដី, ឬកាលបុគ្គលដេកលក់ស៊ប់ បុគ្គលម្នាក់យកដាវដ៏មុតមកកាត់សីសៈក្ដី, ឬត្រូវបុគ្គលចាប់ច្រមុជទឹកឱ្យស្លាប់ក្ដី, ក្នុងហេតុការណ៍បើយ៉ាងនេះ កម្ម ឬកម្មនិមិត្តយ៉ាងណាមួយ រមែងប្រាកដ ៕

## វិនិច្ឆ័យរឿងស្លាប់ឆាប់រហ័ស

នៅមានរឿងស្លាប់មួយទៀត ឈ្មោះថា **លហុកមរណៈ** = ស្លាប់រហ័ស; ពិតមែន បុគ្គលយកញញួរដំរុយខៀវ (របោម) ដែលដេកនៅលើដងពន្លាក; សូម្បីយ៉ាងនេះ កម្ម ឬកម្មនិមិត្ត ក៏រមែងប្រាកដ; មួយវិញទៀត កាលមេរុយត្រូវដំដោយញញួរយ៉ាងនេះ ភវង្គនៅមិនវិលទៅមក ជាអាវជ្ជនៈផ្លូវកាយទ្វារទេ, រមែងកម្រើកមកកាន់ ចំពោះមនោទ្វារាវជ្ជនៈតែម្យ៉ាង; រំពេចនោះ ជវ័នក៏ស្ទុះទៅធ្លាក់ចុះកាន់ភវង្គ ។ ក្នុងវារៈទី ២ ភវង្គទើបផ្លាស់ (វិល) មកកាន់អាវជ្ជនៈ ផ្លូវកាយទ្វារ, ពេលនោះ វីថិចិត្តទាំងឡាយ គឺកាយវិញ្ញាណ សម្បដិច្ឆន្នៈ សន្តីរណៈ វោដ្ឋព្វនៈ នឹងប្រព្រឹត្តទៅ; ជវ័នក៏ស្ទុះទៅហើយ ធ្លាក់ចុះកាន់ភវង្គ ។ ក្នុងវារៈទី ៣ ភវង្គផ្លាស់វិលមកកាន់មនោទ្វារាវជ្ជនៈ, លំដាប់នោះ ជវ័នក៏ធ្លាក់ចុះកាន់ភវង្គ, មេរុយនោះ ក៏ធ្វើកាលកិរិយាទៅ ក្នុងឋានៈនេះ [៣២] ។ សេចក្តីនេះ លោកនាំមកដើម្បីអ្វី ? ដើម្បីសម្តែងថា ឈ្មោះថា អារម្មណ៍របស់អរូបធម៌ទាំងឡាយ ប្រព្រឹត្តទៅរហ័សយ៉ាងនេះ ។

---

[៣២] ពាក្យថា ក្នុងឋានៈនេះ សំដៅដល់ មរណាសន្នវីថិ (វីថិជិតស្លាប់) ប្រភេទណានីមួយ ក្នុងប្រភេទ ៤ យ៉ាងនេះ គឺ

ប្រភេទទី ១ ចិត្តសេពជវ័ន ៥ ដង មានតទារម្មណ៍ ២ ដង ហើយចុតិ

ប្រភេទទី ២ ចិត្តសេពជវ័ន ៥ ដង ហើយចុតិ

ប្រភេទទី ៣ ចិត្តសេពជវ័ន ៥ ដង មានតទារម្មណ៍ ២ ដង និងមានភវង្គ... ហើយចុតិ ។

**ភាវៈ** (វណ្ណៈ) មួយទៀត ប្រាកដក្នុងភូមិឱកាសរបស់សត្វដែលកើតឡើង ឈ្មោះថា **គតិនិមិត្ត**; ក្នុងគតិនិមិត្តនោះ កាលនរកប្រាកដ ក៏នឹងប្រាកដឡើងមានសភាពដូចលោហកុម្ភី (ឆ្នាំងទង់ដែង), កាលមនុស្សលោកប្រាកដក្នុងផ្ទៃនៃមាតានឹងប្រាកដដូចសំពត់កម្ពល និងយាន, កាលទេវលោកប្រាកដ ក៏នឹងប្រាកដជាដើមកប្បព្រឹក្សវិមាន និងទីដេកជាដើម; បដិសន្ធិមានអារម្មណ៍ ៣ យ៉ាង ដោយសង្ខេប គឺកម្ម កម្មនិមិត្ត និងគតិនិមិត្ត ដោយប្រការយ៉ាងនេះ ។

ន័យមួយទៀត **បដិសន្ធិមានអារម្មណ៍ ៣ យ៉ាង** គឺ

**-អារម្មណ៍អតីត**

**-អារម្មណ៍បច្ចុប្បន្ន**

**-អារម្មណ៍ជានវត្តព្វារម្មណ៍**[៣៣] ។

អសញ្ញីបដិសន្ធិ មិនមានអារម្មណ៍; បណ្តាបដិសន្ធិទាំងនោះ វិញ្ញាណញ្ចាយតនបដិសន្ធិ និងនេវសញ្ញានាសញ្ញាយតនបដិសន្ធិ មានអារម្មណ៍ជាអតីតៈតែម្យ៉ាង, កាមាវចរ ១០ មានអារម្មណ៍ជាអតីតៈខ្លះ ជាបច្ចុប្បន្នខ្លះ, បដិសន្ធិដ៏សេសមានអារម្មណ៍មិនគប្បីពោលឡើយ ។ ក៏បដិសន្ធិដែលកំពុងប្រព្រឹត្តទៅ ក្នុងអារម្មណ៍ ៣ យ៉ាង រមែងប្រព្រឹត្តទៅក្នុងលំដាប់នៃចុតិដែលមានអតីតៈជាអារម្មណ៍ ឬមាន

---

ប្រភេទទី ៤ ចិត្តសេពជវន ៥ ដង មានភវង្គ... ហើយចុតិ ។ ក្នុងឋានៈនេះ មេរុយងាប់ក្នុងប្រភេទទី ៤ ។

[៣៣] អារម្មណ៍មានសភាពបែបនេះ ត្រូវគ្នានឹងអារម្មណ៍បញ្ញត្តិ គឺបញ្ញត្តិកម្មនិមិត្ត និងបញ្ញត្តិមហគ្គតកម្មនិមិត្ត របស់អ្នកដែលនឹងទៅកើតក្នុងព្រហ្មលោក ។

អារម្មណ៍ដែលមិនគប្បីពោល, តែឈ្មោះថា ចុតិចិត្តដែលមានអារម្មណ៍ជាបច្ចុប្បន្ន មិនបានមានទេ, ព្រោះហេតុដូច្នោះ គប្បីជ្រាបអាការៈដែលប្រព្រឹត្តទៅនៃបដិសន្ធិមានអារម្មណ៍យ៉ាងណានីមួយ បណ្តាអារម្មណ៍ ៣ យ៉ាង ក្នុងលំដាប់នៃចុតិមានអារម្មណ៍យ៉ាងណានីមួយ បណ្តាអារម្មណ៍ ២ យ៉ាង ដោយអំណាចសុគ្គតិ និងទុគ្គតិ ។ សេចក្តីនេះ តើយ៉ាងណា ?

## បដិសន្ធិមានអារម្មណ៍ជាអតីតៈ តអំពីចុតិមានអារម្មណ៍ជាអតីតៈ

ក្នុងសេចក្តីខាងដើម បាបកម្មតាមដែលខ្លួនសន្សំទុក ឬកម្មនិមិត្ត រមែងមកកាន់គន្លងមនោទ្វារ ដល់បុគ្គលដែលដេកនៅលើគ្រែមរណៈ ព្រោះព្រះបាលីថា "ក៏បាបកម្មទាំងនោះ រមែងចូលប្រាកដដល់បុគ្គលដែលមានបាបកម្មតាំងនៅក្នុងកាមាវចរសុគ្គតិក្នុងសម័យនោះ"[៣៤] ; ចុតិចិត្តក៏ធ្វើភវង្គវិស័យ (គឺអារម្មណ៍នៃភវង្គ) ឱ្យជាអារម្មណ៍កើតឡើងក្នុងទីបំផុតនៃតទារម្មណ៍ ឬក្នុងជវនសុទ្ធៗ កើត ឡើងប្រារព្ធយកកម្ម ឬកម្មនិមិត្តនោះ; ចុតិចិត្តនោះរលត់ហើយ ក៏កើតបដិសន្ធិ ចិត្តដែលរាប់បញ្ចូលដោយទុគ្គតិភូមិ[៣៥] ដោយកម្លាំងនៃកិលេសនៅមិនទាន់បានកាត់

---

[៣៤] ម. ឧ. ។

[៣៥] ពាក្យដែលថា រាប់បញ្ចូលដោយទុគ្គតិ បានដល់ ការសង្គ្រោះចូលដោយអំណាចនៃការប្រព្រឹត្តទៅក្នុងទុគ្គតិ (សម្មោ. អដ្ឋ.) ។

ឱ្យបង្អោនទៅក្នុងបាបកម្មផ្សេងៗ ហើយប្រារព្ធកម្ម ឬកម្មនិមិត្តដែលមកកាន់គន្លងនោះៗ ឯង ។

នេះជាបដិសន្ធិមានអារម្មណ៍ជាអតីតៈ តអំពីចុតិ ដែលមានអារម្មណ៍ជាអតីតៈ ។

## បដិសន្ធិមានអារម្មណ៍បច្ចុប្បន្ន តអំពីចុតិ មានអារម្មណ៍អតីតៈ

ក្នុងមរណសម័យនៃបុគ្គលម្នាក់ទៀត និមិត្តនៃទុគ្គតិភូមិមានសភាពដ៏ខ្លោចផ្សា (គួរខ្លាច) ជាដើម ក្នុងនរកជាដើម មកកាន់គន្លងនៃមនោទ្វារ ដោយអំណាចនៃកម្មមានប្រការដូចដែលពោលហើយ; កាលភវង្គរបស់បុគ្គលនោះ កើតរលត់ ២ ដងហើយ កើតវីថិចិត្តទាំង ៣ គឺអាវជ្ជនៈដែលប្រារព្ធអារម្មណ៍នោះ ១, ជវ័ន ៥ ដួង ព្រោះមានកម្លាំងទន់ខ្សោយដោយជិតស្លាប់ ១ និងតទារម្មណ៍ ២ ដួង ១; តអំពីនោះ ចុតិចិត្ត ១ ដួង ធ្វើភវង្គវិស័យឱ្យជាអារម្មណ៍; ដោយលំដាប់ពាក្យមានប្រមាណប៉ុណ្ណេះ, ខណៈចិត្ត រមែងកន្លងទៅ ១១ ដួង; ក្នុងលំដាប់នោះ បដិសន្ធិចិត្តនឹងកើតឡើងក្នុងអារម្មណ៍ ដែលមានអាយុនៃខណៈចិត្តដ៏សេស ៥ ខណៈនោះឯង; នេះបដិសន្ធិមានអារម្មណ៍បច្ចុប្បន្ន តអំពីចុតិចិត្តមានអារម្មណ៍អតីតៈ ។

ក្នុងមរណសម័យរបស់បុគ្គលដទៃទៀត ហីនារម្មណ៍ (អារម្មណ៍ថោកទាប) មានរាគៈជាដើមជាហេតុ រមែងមកកាន់គន្លងនៃទ្វារ ក្នុងទ្វារទាំង ៥ យ៉ាងណាមួយ; ក្នុងទីបំផុតនៃវោដ្ឋព្វនៈដែលកើតឡើងតាមលំដាប់ជវ័ន ៥ ដួង និងតទា-

រម្មណ៍ ២ ដួង របស់បុគ្គលនោះ រមែងកើត ព្រោះមានកម្លាំងខ្សោយ ដោយជិតចំពោះសេចក្តីស្លាប់; តពីនោះចុតិចិត្ត ១ ដួង ក៏ធ្វើភវង្គវិស័យឱ្យជាអារម្មណ៍; ដោយពាក្យមានប្រមាណប៉ុណ្ណេះ ខណៈនៃចិត្តរមែងជាការកន្លងទៅបាន ១៥ ខណៈ គឺ ភវង្គ ២ ខណៈ, អាវជ្ជនៈ ១ ខណៈ, ទស្សនៈ ១ ខណៈ, សម្បដិច្ឆន្នៈ ១ ខណៈ, សន្តីរណៈ ១ ខណៈ, វោដ្ឋព្វនៈ ១ ខណៈ, ជវ័ន ៥ ខណៈ, តទារម្មណ៍ ២ ខណៈ និងចុតិចិត្ត ១ ដួង; លំដាប់នោះ បដិសន្ធិចិត្តទើបកើតឡើងក្នុងអារម្មណ៍ដែលមានអាយុខណៈចិត្ត ១ ខណៈ ដែលនៅសល់នោះនុ៎ះឯង; សូម្បីបដិសន្ធិនេះ ក៏មានអារម្មណ៍បច្ចុប្បន្នតអំពីចុតិមានអារម្មណ៍អតីតៈ ៕

## បដិសន្ធិមានអារម្មណ៍អតីតៈ និងបច្ចុប្បន្ន ក្នុងលំដាប់ចុតិមានអារម្មណ៍ជាអតីតៈ

គប្បីជ្រាបអាការនៃការប្រព្រឹត្តទៅរបស់បដិសន្ធិក្នុងទុគ្គតិភូមិ ដែលមានអារម្មណ៍អតីតៈ និងបច្ចុប្បន្ន ក្នុងលំដាប់នៃចុតិ ក្នុងសុគ្គតិភូមិដែលមានអារម្មណ៍អតីតៈនេះសិន ។ ចំណែកកម្មដែលប្រាសចាកទោសនោះ ឬកម្មនិមិត្តរមែងមកកាន់គន្លងមនោទ្វាររបស់បុគ្គលអ្នកតាំងនៅក្នុងទុគ្គតិភូមិ មានកម្មដែលប្រាសចាកទោសដែលសន្សំទុកហើយ ដោយន័យដែលពោលហើយនោះឯង; ព្រោះហេតុដូច្នោះ គប្បីវៀរធម៌ដែលជាចំណែកស (បរិសុទ្ធិ) ទុកក្នុងធម៌ដែលជាចំណែកខ្មៅហើយ គប្បីជ្រាបពាក្យទាំងអស់ដោយន័យមុននោះចុះ; នេះជាអាការនៃសេចក្តីប្រព្រឹត្តទៅនៃបដិសន្ធិក្នុងសុគ្គតិភូមិ ដែលមានអារម្មណ៍អតីតៈ និងបច្ចុប្បន្ន តអំពីចុតិ ក្នុងទុគ្គតិភូមិដែលមានអារម្មណ៍ជាអតីតៈ ៕

## បដិសន្ធិមានអារម្មណ៍ជាអតីតៈ ឬនវត្តព្វៈ ក្នុងលំដាប់ចុតិមានអារម្មណ៍ជាអតីតៈ

ម្យ៉ាង កម្មដែលប្រាសចាកទោស ឬកម្មនិមិត្ត រមែងមកកាន់គន្លងមនោទ្វារ របស់បុគ្គលអ្នកតាំងនៅក្នុងសុគ្គតិភូមិ អ្នកមានកម្មប្រាសចាកទោសដែលសន្សំទុកហើយ ដេកលើគ្រែមរណៈ ដោយព្រះបាលីមានជាអាទិ៍ថា **"តានិ ចស្ស តស្មឹ សមយេ ឱលម្ពន្តិ** = ក៏អំពើល្អ គឺកាយសុចរិត វចីសុចរិត មនោសុច្ចរិតទាំងនោះ រមែងចូលទៅប្រាកដដល់បុគ្គលអ្នកដេកលើគ្រែក្នុងសម័យនោះ" [៤៥] ជាដើម; ឯកម្មដែលប្រាសចាកទោស ឬកម្មនិមិត្តនោះ រមែងមកកាន់គន្លងមនោទ្វារ របស់បុគ្គលអ្នកមានកល្យាណកម្ម ដែលប្រាសចាកទោស ជាកាមាវចរ ដែលសន្សំទុកហើយនោះឯង; ចំណែកកម្មនិមិត្តមួយយ៉ាង រមែងមកកាន់គន្លងមនោទ្វារ របស់បុគ្គលអ្នកមានមហគ្គតកល្យាណកម្មដែលសន្សំទុកហើយ; ចុតិចិត្តធ្វើភវង្គវិស័យឱ្យជាអារម្មណ៍ ហើយកើតឡើង ក្នុងលំដាប់នៃតទារម្មណ៍ ឬក្នុងជវនវីថិសុទ្ធៗ [៤៦] ដែលកើតឡើង ព្រោះប្រារព្ធកម្មនិមិត្តនោះឯង; កាលចុតិចិត្តនោះរលត់ បដិសន្ធិចិត្តដែលរាប់បញ្ចូលដោយសុគ្គតិភូមិ ត្រូវកម្លាំងនៃកិលេសដែលនៅមិនទាន់បានលះបង់ហើយឱ្យបង្អោន ទៅកើតឡើង ព្រោះប្រារព្ធកម្ម ឬកម្មនិមិត្តដែលមកកាន់គន្លងនោះឯង ។ នេះជាបដិសន្ធិ មានអារម្មណ៍ជាអតីតៈ ឬអារម្មណ៍ដែលមិន

---

[៤៥] ម. ឧ. ។

[៤៦] ជវនវីថិសុទ្ធៗ ព្រោះប្រាសចាកនូវតទារម្មណ៍ (សម្មោ. អដ្ឋ.) ។

គប្បីពោល (នវត្តព្វារម្មណ៍) តអំពីចុតិមានអារម្មណ៍ជាអតីតៈ ៕

## បដិសន្ធិមានអារម្មណ៍បច្ចុប្បន្ន តពីចុតិ មានអារម្មណ៍ជាអតីតៈ

ក្នុងមរណសម័យរបស់បុគ្គលដទៃទៀត សុគ្គតិនិមិត្ត ពោលគឺផ្ទៃមាតាក្នុងមនុស្សលោក ឬឧទ្យាន និងដើមកប្បព្រឹក្សក្នុងទេវលោក រមែងមកកាន់គន្លងមនោទ្វារដោយអំណាចកម្មដែលប្រាសចាកទោស ដែលជាកាមាវចរ; បដិសន្ធិចិត្ត រមែងកើតឡើងដល់បុគ្គលនោះ ក្នុងលំដាប់នៃចុតិ ដោយលំដាប់ដែលសម្តែងទុកក្នុងទុគ្គតិនិមិត្តនោះឯង ។

នេះជាបដិសន្ធិមានអារម្មណ៍ជាបច្ចុប្បន្ន ក្នុងលំដាប់នៃចុតិមានអារម្មណ៍ជាអតីតៈ ។

ក្នុងមរណសម័យរបស់បុគ្គលដទៃផ្សេងទៀត ពួកញាតិនាំគ្នាសម្តែងអារម្មណ៍ពោលថា “បពិត្រលោកឪពុក នេះជាការបូជាដល់ព្រះពុទ្ធជាម្ចាស់, កូនធ្វើប្រយោជន៍នេះដល់ពុក, សូមពុកញុំាំងចិត្តឱ្យជ្រះថ្លាឡើង” ហើយសម្តែងរូបារម្មណ៍ដោយអំណាចនៃផ្លូងផ្កាឈើ ទង់ជ័យ និងទង់បដា (ទង់សំពត់) ជាដើម ឬសម្តែងសទ្ទារម្មណ៍ដោយអំណាចនៃការស្តាប់ធម៌ និងតូរិយបូជាជាដើម ឬសម្តែងគន្ធារម្មណ៍ដោយអំណាចនៃក្លិនធូប ក្លិនគ្រឿងក្រអូបជាដើម ឬពោលថា “បពិត្រលោកឪពុក ពុកចូរលះបង់ទេយ្យធម៌នេះ ដែលគេថ្វាយដើមប្រយោជន៍ដល់ពុក” ហើយសម្តែងរសារម្មណ៍ដោយអំណាចនៃទឹកឃ្មុំ និងទឹកអំពៅជាដើម ឬពោលថា “បពិត្រលោក

ឪពុក ពុកចូរសម្ផស្ស (ពាល់ត្រូវ) ទេយ្យធម៌នេះ ដែលគេថ្វាយដើម្បីប្រយោជន៍ដល់ពុក” ហើយសម្តែងផោដ្ឋព្វារម្មណ៍ ដោយអំណាចសំពត់ចិន និងសំពត់សោមារៈជាដើម បង្អោនចូលក្នុងទ្វារ ៥; ជវ័ន ៥ ដួង រមែងកើតឡើងដល់បុគ្គលនោះព្រោះមានកម្លាំងទន់ខ្សោយដោយជិតនឹងស្លាប់ ក្នុងទីបំផុតនៃវោដ្ឋព្វនៈ ដែលកើតឡើងតាមលំដាប់នៃអារម្មណ៍មានរូបជាដើម ដែលមកកាន់គន្លងនោះឯង និងរមែងកើតតទារម្មណ៍ ២ ដួង; លំដាប់នោះ ចុតិចិត្ត ១ ដួង ធ្វើភវង្គវិស័យឱ្យជាអារម្មណ៍, ក្នុងទីបំផុតនៃចុតិនោះឯង បដិសន្ធិក៏កើតឡើងក្នុងអារម្មណ៍ ដែលតាំងនៅក្នុងខណៈចិត្ត ១ ដួងនោះឯង ។

សូម្បីបដិសន្ធិចិត្តនេះ ក៏មានអារម្មណ៍ជាបច្ចុប្បន្ន តអំពីចុតិមានអារម្មណ៍អតីតៈ ៕

## បដិសន្ធិមានអារម្មណ៍ ៣ យ៉ាងណានីមួយ តពីចុតិចិត្តមានអារម្មណ៍ដែលមិនគប្បីពោល

ន័យមួយទៀត ក្នុងមរណសម័យរបស់បុគ្គលដទៃទៀត តាំងនៅក្នុងសុគ្គតិភូមិ បានដល់មហគ្គតៈដោយអំណាចនៃឈានមានបឋវីកសិណជាដើម បណ្តាកុសលកម្ម កម្មនិមិត្ត និងគតិនិមិត្តដែលជាកាមាវចរយ៉ាងណាមួយ ឬនិមិត្តមានបឋវី-កសិណជាដើម ឬក៏មហគ្គតចិត្ត រមែងមកកាន់គន្លងមនោទ្វារ ឬថាអារម្មណ៍ដែលប្រណីត ដែលមានការកើតឡើងនៃកុសលជាហេតុ រមែងមកកាន់គន្លងនៃចក្ខុ ឬសោតទ្វារយ៉ាងណាមួយ, ជវ័ន ៥ ខណៈ រមែងកើតឡើងដល់បុគ្គលនោះ ព្រោះ

មានកម្លាំងទន់ខ្សោយដោយជិតមរណៈ ក្នុងទីបំផុតនៃវោដ្ឋព្វនៈដែលកើតឡើងតាមលំដាប់; តែថា តទារម្មណ៍រមែងមិនមានដល់ពួកសត្វ អ្នកមានមហគ្គតចិត្តជាគតិ; ព្រោះហេតុដូច្នោះ ទើបកើតចុតិ ១ ដួង ធ្វើភវង្គវិស័យឱ្យជាអារម្មណ៍ក្នុងលំដាប់នៃជវ័ននោះឯង; ក្នុងទីបំផុតនៃចុតិនោះ រមែងកើតបដិសន្ធិចិត្តមានអារម្មណ៍យ៉ាងណាមួយ បណ្ដាអារម្មណ៍ទាំងឡាយ តាមការប្រាកដដែលរាប់បញ្ចូលក្នុងសុគ្គតិ ឬមហគ្គតចិត្ត ។ បដិសន្ធិនេះ មានអារម្មណ៍ជាអតីតៈ បច្ចុប្បន្ន អារម្មណ៍ដែលមិនគប្បីពោលយ៉ាងណាមួយ តអំពីចុតិដែលមានអារម្មណ៍ជានវត្តព្វៈ ។

គប្បីជ្រាបបដិសន្ធិ ក្នុងលំដាប់សូម្បីចុតិក្នុងអរូបភូមិដោយទំនងយ៉ាងនេះ ។ នេះជាអាការប្រព្រឹត្តទៅនៃបដិសន្ធិមានអារម្មណ៍ជាអតីតៈ មានអារម្មណ៍មិនគប្បីពោល មានអារម្មណ៍ជាបច្ចុប្បន្ន តអំពីចុតិក្នុងសុគ្គតិភូមិមានអារម្មណ៍ជាអតីតៈ និងនវត្តព្វៈ ៕

## បដិសន្ធិមានអារម្មណ៍អតីតៈ និងបច្ចុប្បន្ន តពីចុតិមានអារម្មណ៍អតីតៈ

ចំណែកបុគ្គលអ្នកតាំងនៅក្នុងទុគ្គតិភូមិដែលមានបាបកម្ម កម្ម និងកម្មនិមិត្ត ឬគតិនិមិត្តនោះ រមែងមកកាន់គន្លងក្នុងមនោទ្វារដោយន័យដែលពោលហើយនោះឯង, តែអារម្មណ៍ដែលជាហេតនាំឱ្យកើតអកុសល រមែងមកកាន់គន្លងក្នុងបញ្ចទ្វារ; លំដាប់នោះ បដិសន្ធិចិត្តរបស់បុគ្គលនោះមានអារម្មណ៍យ៉ាងណាមួយ បណ្ដាអារម្មណ៍ទាំង ៣ នោះ ដែលរាប់ក្នុងទុគ្គតិភូមិក្នុងទីបំផុតនៃចុតិចិត្តតាមលំដាប់ ក៏កើត

ឡើង ។ នេះជាអាការដែលប្រព្រឹត្តទៅនៃបដិសន្ធិចិត្ត មានអារម្មណ៍ជាអតីតៈ និងបច្ចុប្បន្នក្នុងលំដាប់តអំពីចុតិក្នុងទុគ្គតិភូមិ ដែលមានអារម្មណ៍ជាអតីតៈដូច្នេះឯង; ដោយលំដាប់នៃពាក្យមានប្រមាណប៉ុណ្ណេះ រមែងជាការសម្តែងសេចក្តីប្រព្រឹត្តទៅនៃវិញ្ញាណ ១៩ ដួង ដោយអំណាចនៃបដិសន្ធិ ។

ម្យ៉ាងទៀត វិញ្ញាណទាំងអស់ ១៩ ដួងនេះ ៖

**កាលប្រព្រឹត្តទៅក្នុងបដិសន្ធិ រមែងប្រព្រឹត្តទៅដោយកម្ម ២ យ៉ាង និងវិញ្ញាណដែលផ្សេងគ្នាប្រព្រឹត្តទៅ ២ យ៉ាងជាដើម ដោយសេចក្តីផ្សេងគ្នានៃធម៌ដែលលាយគ្នាជាដើម ។**

ពិតមែន សូម្បីវិបាកវិញ្ញាណ ១៩ ដួងនេះ កាលនឹងប្រព្រឹត្តទៅក្នុងបដិសន្ធិ រមែងប្រព្រឹត្តទៅដោយកម្ម ២ យ៉ាង; ព្រោះថា កម្មដែលឱ្យកើតវិបាកវិញ្ញាណ ១៩ ដួងនោះ រមែងជាបច្ច័យដោយនានាក្ខណិកកម្មប្បច្ច័យ និងឧបនិស្សយប្បច្ច័យ តាមគួរដល់ភារៈរបស់ខ្លួន; ខនេះសមដូចពាក្យដែលត្រាស់ទុកថា **"កុសលា កុសលំ កម្មវិបាកស្ស ឧបនិស្សយប្បច្ចយេន បច្ចយោ** = កុសល និងអកុសល ជាបច្ច័យដល់កម្មវិបាកដោយឧបនិស្សយប្បច្ច័យ" [៤៧] ; ក៏កាលបើវិញ្ញាណនេះ ប្រព្រឹត្តទៅយ៉ាងនេះ ក៏គប្បីជ្រាបសូម្បីសេចក្តីផ្សេងគ្នាមាន ២ យ៉ាងជាដើម ដោយសេចក្តីផ្សេងគ្នានៃធម៌ដែលលាយគ្នាជាដើម; តើដូចម្តេច ? គឺវិញ្ញាណនេះ សូម្បីប្រព្រឹត្តទៅ

---

[៤៧] អភិ. ។

តែម្យ៉ាងដោយអំណាចបដិសន្ធិ ឈ្មោះថា មាន ២ យ៉ាង ដោយសេចក្តីផ្សេងគ្នានៃធម៌ដែលលាយគ្នា និងមិនលាយគ្នាជាមួយរូប, មាន ៣ យ៉ាង ព្រោះសេចក្តីផ្សេងគ្នានៃកាមភព រូបភព និងអរូបភព, មាន ៤ យ៉ាង ដោយអំណាចនៃកំណើតអណ្ឌជៈ ជលពុជៈ សំសេទជៈ និងឧប្បាតិកៈ, មាន ៥ យ៉ាង ដោយអំណាចគតិ (មានដំណើរទៅកាន់នរកជាដើម), មាន ៧ យ៉ាង ដោយអំណាចវិញ្ញាណដ្ឋិតិ, មាន ៨ យ៉ាង ដោយអំណាចនៃសត្តាវាស ។

បណ្តាវិញ្ញាណទាំងនោះ ៖

**វិញ្ញាណដែលលាយជាមួយរូប ២ យ៉ាង ព្រោះសេចក្តីផ្សេងគ្នានៃភាវៈ និងក្នុងវិញ្ញាណទាំង ២ នោះ; វិញ្ញាណដែលមានភាវៈ ២ យ៉ាង មាន ២ ទសកៈខ្លះ ៣ ទសកៈខ្លះ កំណត់យ៉ាងទាបបំផុតកើតព្រមជាមួយវិញ្ញាណដែលលាយជាមួយរូបខាងដើម ។**

ពាក្យថា **វិញ្ញាណដែលលាយជាមួយរូបមាន ២ យ៉ាង ព្រោះសេចក្តីផ្សេងគ្នានៃភាវៈនោះ** សេចក្តីថា ពិតណាស់ បណ្តាវិញ្ញាណទាំងនោះ បដិសន្ធិវិញ្ញាណនោះ លាយដោយរូបហើយកើតឡើង ព្រោះវៀរអរូបភព, បដិសន្ធិវិញ្ញាណនោះ មាន ២ យ៉ាង គឺ មានភាវៈ ១ មិនមានភាវៈ ១ ព្រោះក្នុងរូបភពកើតឡើងវៀរចាកភាវៈ គឺឥត្ថិន្ទ្រិយ និងបុរិសិន្ទ្រិយ ព្រោះក្នុងកាមភពកើតព្រមជាមួយភាវៈវៀរតែបដិសន្ធិ របស់បណ្ឌកខ្ទើយពីកំណើត ។

ពាក្យថា **និងក្នុងវិញ្ញាណទាំង ២ នោះ វិញ្ញាណដែលមានភាវៈ ២**

**យ៉ាង**នោះ សេចក្ដីថា សូម្បីក្នុងវិញ្ញាណទាំងនោះ វិញ្ញាណមានភាវៈ ២ យ៉ាង ដោយការកើតព្រមគ្នានៃឥត្ថីភាវៈ ឬបុរិសភាវៈ យ៉ាងណានីមួយនោះឯង ។

ពាក្យថា **មាន ២ ទសកៈខ្លះ មាន ៣ ទសកៈខ្លះ កំណត់យ៉ាងទាបកើតព្រមជាមួយវិញ្ញាណដែលលាយជាមួយរូបខាងដើម** សេចក្ដីថា ក្នុងវិញ្ញាណទាំងនេះ វិញ្ញាណ ២ យ៉ាង គឺវិញ្ញាណដែលលាយច្រឡំជាមួយរូប និងមិនលាយជាមួយរូប បដិសន្ធិវិញ្ញាណ ដែលលាយជាមួយរូប ដែលជាខាងដើមនេះណា កើតព្រមគ្នា ២ ទសកៈ គឺកាយទសកៈ និងវត្ថុទសកៈ ឬ ៣ ទសកៈ គឺវត្ថុទសកៈ កាយទសកៈ និងភាវទសកៈ យ៉ាងទាបបំផុតមិនមានរូបថយ (តិច) ចុះជាងនោះ ។

ក៏បដិសន្ធិវិញ្ញាណនេះនោះឯង មានការកំណត់រូបយ៉ាងទាបត្រឹមប៉ុណ្ណេះ កាលកើតឡើង ក៏រមែងកើតឡើងជាធម្មជាតិបានការរាប់ថា **ជាកលលៈ** មានប្រមាណប៉ុនតំណក់ប្រេងល្ងថ្លាដែលជាប់នឹងចុងរោម ១ នៃសត្វទ្រាយ; ក្នុងកំណើតទាំង ២ ដែលមានឈ្មោះថា អណ្ឌជៈ និងជលាពុជៈ បណ្ឌិតគប្បីជ្រាបសេចក្ដីផ្សេងគ្នានៃការកើតក្នុងកំណើតទាំងនោះ ដោយអំណាចនៃគតិរបស់កំណើតទាំងឡាយ ។

មែនពិត បណ្ដាការកើតដោយអំណាចនៃគតិទាំងនោះ ៖

**និរយេ ភុម្មវជ្ជេសុ ទេវេសុ ច ន យោនិយោ**
**តិស្សោ បុរិមិកា ហោន្តិ ចតស្សោបិ គតិត្តយេ ។**

កំណើត ៣ ខាងដើម [៤៨] រមែងមិនមានក្នុងនរក និង

---

[៤៨] គឺជលាពុជៈ អណ្ឌជៈ និងសំសេទជៈ ។

មិនមានក្នុងពួកទេវតាទាំងឡាយ វៀរភុម្មទេវតា កំណើត ៤

រមែងមានក្នុងគតិ ៣ ។

ក្នុងគាថានោះ ដោយចសព្ទ ក្នុងបទថា **ទេវេសុ ច** នេះ កំណើត ៣ ខាងដើម គប្បីជ្រាបថា មិនមានក្នុងនិជ្ឈាមតណ្ហិកប្រេត ដូចមិនមានក្នុងនរក និងក្នុងទេវតាទាំងឡាយ វៀរភុម្មទេវតាចេញ; ព្រោះសត្វទាំងនោះជាឱបបាតិកកំណើតតែម្យ៉ាង; តែកំណើត ៤ មានក្នុងគតិ ៣ ដ៏សេស ពោលគឺសត្វតិរច្ឆានបេតវិស័យ មនុស្ស និងពួកភុម្មទេវតាដែលវៀរទុកខាងដើមហើយ ។

បណ្ដាកំណើតទាំងនោះ ៖

**ក្នុងរូបព្រហ្ម រមែងកើតរូបបាន ៣៩ កលាបៈ ក្នុងសំសេទជៈកំណើត និងឱបបាតិកៈកំណើត រមែងកើតរូបបាន ៧០ កលាបៈ ដោយកំណត់យ៉ាងខ្ពស់ ឬយ៉ាងទាបមាន ៣០ កលាបៈ ។**

ក្នុងរូបព្រហ្មដែលកើតជាឱបបាតិកៈកំណើតជាមុនសិន រូប ៣៩ កលាបៈ រមែងកើតព្រមជាមួយនឹងបដិសន្ធិវិញ្ញាណ ដោយអំណាចនៃកលាបៈ ៤ គឺចក្ខុទសកៈ សោតទសកៈ វត្ថុទសកៈ និងជីវិតិន្ទ្រិយនវកៈ ។ ចំណែកក្នុងសំសេទជៈកំណើត និងឱបបាតិកៈកំណើតដទៃទៀត វៀររូបព្រហ្មចេញ រមែងកើតបានរូប ៧០ កលាបៈយ៉ាងច្រើន ដោយអំណាចនៃចក្ខុទសកៈ សោតទសកៈ ឃានទសកៈ ជិវ្ហាទសកៈ កាយទសកៈ ភាវទសកៈ និងវត្ថុទសកៈ; រូបទាំង ៧០ កលាបៈនេះ រមែងកើតក្នុងពួកទេវតាជាន់ខ្ពស់ជានិច្ច; ក្នុងរូបដែលជាទសកៈទាំងនោះ ក៏កងរូបទាំង ១០ នេះ គឺវណ្ណៈ ១ គន្ធៈ ១ រស ១ ឱជា ១ និងធាតុ ៤ (ដី ទឹក ភ្លើង ខ្យល់) ចក្ខុ

បសាទ ១ និងជីវិតិន្ទ្រិយ ១ ឈ្មោះថា **ចក្ខុទសកៈ**; សោតទសកៈជាដើមដ៏សេស ក៏គប្បីជ្រាបយ៉ាងនេះដែរ ។

ម្យ៉ាងទៀត កំណត់រូបយ៉ាងតិចមាន ៣០ កលាបៈ រមែងកើតព្រមជាមួយ បដិសន្ធិវិញ្ញាណ ដោយអំណាចនៃជិវ្ហាទសកៈ កាយទសកៈ វត្ថុទសកៈ ដល់បុគ្គល អ្នកខ្វាក់ថ្លង់តាំងពីកំណើត អ្នកមិនមានឃានបសាទ និងនបុំសកៈតាំងពីកំណើត ។ បណ្ឌិតគប្បីជ្រាបការកំណត់ដោយសមគួរ ក្នុងចន្លោះរូបដែលកំណត់យ៉ាងច្រើន និង យ៉ាងតិច កាលដឹងយ៉ាងនេះហើយ ៖

**គប្បីកំណត់ដឹងធម៌ពិសេសនៃការផ្សេងគ្នា និងមិនផ្សេង គ្នារបស់ចុតិ និងបដិសន្ធិ ដោយខន្ធ អារម្មណ៍ គតិ ហេតុ វេទនា បីតិ វិតក្កៈ និងវិចារៈដូចតទៅ ៖**

អធិប្បាយថា ក៏បដិសន្ធិ ២ យ៉ាង ដែលលាយដោយរូប និងមិនលាយ ដោយរូបណា និងចុតិក្នុងលំដាប់នៃអតីតៈរបស់បដិសន្ធិនេះឯង, បណ្ឌិតគប្បីជ្រាប ធម៌ពិសេសនៃការផ្សេងគ្នា និងមិនផ្សេងគ្នានៃចុតិ និងបដិសន្ធិទាំងនោះ ដោយខន្ធ ជាដើម; គឺយ៉ាងណា ? គឺគ្រាខ្លះ ខន្ធ ៤ ប៉ុណ្ណោះ ជាបដិសន្ធិដោយមិនផ្សេងគ្នា សូម្បីអារម្មណ៍ក្នុងលំដាប់នៃចុតិក្នុងអរូបភូមិដែលមានខន្ធ ៤ គ្រាខ្លះជាបដិសន្ធិក្នុង អរូបភូមិមានអារម្មណ៍ជាមហគ្គតៈ និងអារម្មណ៍ខាងក្នុងតពីចុតិដែលមានអារម្មណ៍ មិនមែនមហគ្គតៈ និងមានអារម្មណ៍ខាងក្រៅ; នេះជាន័យក្នុងអរូបភូមិតែម្យ៉ាង ជា មុនសិន ។

ន័យមួយទៀត ក្នុងគ្រាខ្លះអរូបខន្ធ ៤ ជាបដិសន្ធិក្នុងអរូបភូមិ តពីចុតិក្នុង

កាមាវចរ ឬចុតិក្នុងរូបាវចរមានខន្ធ ៥ ដោយអាការយ៉ាងនេះ បដិសន្ធិខ្លះក៏មានអារម្មណ៍បច្ចុប្បន្នតពីចុតិមានអារម្មណ៍អតីតៈ ។ បដិសន្ធិក្នុងទុគ្គតិ ពួកខ្លះក៏តពីចុតិក្នុងសុគ្គតិភូមិ បដិសន្ធិពួកខ្លះដែលជាសហេតុកៈតពីចុតិដែលជាអហេតុកៈ, បដិសន្ធិដែលជាតិហេតុកៈ តពីចុតិដែលជាទុហេតុកៈ, បដិសន្ធិដោយសោមនស្សសហគតៈតពីចុតិដែលជាឧបេក្ខាសហគតៈ, បដិសន្ធិដែលមានបីតិ តពីចុតិដែលមិនមានបីតិ, បដិសន្ធិមានវិតក្កៈ តពីចុតិដែលមិនមានវិតក្កៈ, បដិសន្ធិជាសវិចារៈ តពីចុតិដែលមិនមានវិចារៈ, បដិសន្ធិជាសវិតក្កៈ និងសវិចារៈតពីចុតិដែលជាអវិតក្កៈ និងអវិចារៈ ព្រោះហេតុដូច្នោះ បណ្ឌិតគប្បីប្រកបតាមសមគួរដោយសេចក្ដីផ្សេងគ្នានៃវិញ្ញាណនោះៗ ចុះ ។

**លទ្ធប្បច្ចយមិតិ ធម្ម- មត្តមេតំ ភវន្តរមុបេតិ**
**នាស្ស តតោ សង្កន្តិ ន តតោ ហេតុំ វិនា ហោតិ ។**

វិញ្ញាណនេះគ្រាន់តែជាធមិដែលមានបច្ច័យឯណាបានហើយ
រមែង ចូលដល់ភពដទៃ ដោយប្រការដូច្នេះ វិញ្ញាណនោះ ទើបមិន
មានការឃ្លាតទៅចាកភពនេះ តែវៀរហេតុក្នុងភពអតីតហើយ
វិញ្ញាណក៏ប្រាកដមិនបាន ។

ពិតណាស់ វិញ្ញាណនេះមានបច្ច័យដែលបានហើយ ត្រឹមតែជាធមិអាស្រ័យរូប និងអរូប កាលកើតឡើងហើយហៅថា រមែងចូលដល់ភពដទៃ, វិញ្ញាណនេះមិនមែនសត្វ, មិនមែនជីវៈ; វិញ្ញាណនោះ ទើបមិនមានការឈានកន្លងចាកភពអតីតៈមកកាន់ភពនេះ តែវៀរហេតុក្នុងភពអតីតៈហើយ វិញ្ញាណនោះក៏មិនប្រាកដ

ក្នុងភពនេះ ។ ខ្ញុំនឹងពោលប្រកាសវិញ្ញាណនេះ ដោយលំដាប់នៃចុតិ និងបដិសន្ធិ របស់មនុស្សសត្វ តាមដែលប្រាកដតទៅ ៖

## សម្តែងអំពីចុតិវិញ្ញាណ និង បដិសន្ធិវិញ្ញាណ

ពិតណាស់ កាលសត្វជិតនឹងដល់សេចក្តីស្លាប់ ដោយសភាវៈតាមប្រក្រតី ឬ ដោយសេចក្តីព្យាយាមក្នុងអតីតអត់ធន់មិនបាននូវសេចក្តីទុក្ខលំបាកនៃសស្ត្រា ដែលមានវេទនាស្ទើរតែនឹងស្លាប់ ដែលកាត់នូវសរសៃដែលជាប្រធាន (ក្បាលតំណរ) នៃអវយវៈតូចធំទាំងពួង ដែលនរណា។ ក៏ទ្រាំមិនបាន កាលសរីរៈស្លេកស្លាំងដោយលំដាប់ ដូចស្លឹកត្នោតស្រស់ដែលហាលទុកកណ្តាលថ្ងៃ; កាលឥន្ទ្រិយមានចក្ខុឥន្ទ្រិយ៍ជាដើមរលត់ហើយ; កាលកាយិន្ទ្រិយ មនិន្ទ្រិយ និងជីវិតិន្ទ្រិយដែលតាំងនៅក្នុងឋានត្រឹមតែហទយវត្ថុ វិញ្ញាណអាស្រ័យហទយវត្ថុដែលសល់នៅក្នុងខណៈនោះ ប្រារព្ធ-កម្ម ពោលគឺសង្ខារមានបច្ច័យដែលនៅសល់ បានហើយយ៉ាងណាមួយ ក្នុងគរុកម្ម អាចិណ្ណកម្ម អាសន្នកម្ម និងកម្មដែលធ្វើទុកមកពីមុន ឬប្រារព្ធអារម្មណ៍ ពោលគឺកម្ម កម្មនិមិត្ត និងគតិនិមិត្ត ដែលចូលទៅប្រាកដហើយនោះ; វិញ្ញាណនោះ។ ឯងកាលនឹងប្រព្រឹត្តទៅ ព្រោះលះតណ្ហា និងអវិជ្ជាមិនទាន់បាន ទើបត្រូវតណ្ហាឱ្យបង្អោនទៅ សង្ខារដែលជាសហជាតធម៌រមែងនាំទៅក្នុងអារម្មណ៍នោះ ដែលនៅជាទោស ដែលអវិជ្ជាបិទបាំងហើយនោះ, វិញ្ញាណនោះត្រូវតណ្ហាឱ្យបង្អោនទៅ ដែលសង្ខារទាំងឡាយនាំទៅហើយដោយអំណាចនៃការបន្ត រមែងលះហទយៈទីអាស្រ័យដែលមានមកមុន ទោះត្រេកអរក៏ដោយ និងមិនត្រេកអរក៏ដោយ នូវហទយៈដែល

ជាទីអាស្រ័យ ដែលកម្មឱ្យតាំងឡើងដទៃទៀត រមែងប្រព្រឹត្តទៅដោយបច្ច័យទាំងឡាយមានអារម្មណ៍ជាដើមដោយពិត ដូចបុរសទាញខ្សែដែលចងជាមួយនឹងដើមឈើត្រើយអាយ ឆ្លងរំលងប្រឡាយស្នាមភ្លោះទៅដូច្នោះដែរ ។

ម្យ៉ាងទៀត ក្នុងវិញ្ញាណទាំងឡាយនេះ វិញ្ញាណដួងមុន ហៅថា **ចុតិ** ព្រោះឃ្លាតទៅ, ដួងក្រោយ ហៅថា **បដិសន្ធិ** ព្រោះបន្តមកភពដទៃជាដើម; បដិសន្ធិវិញ្ញាណនេះនោះឯង បណ្ឌិតគប្បីជ្រាបថា **មិនមែនមកពីភពមុនមកក្នុងភពនេះទេ**, សូម្បីវៀរហេតុមានកម្ម សង្ខារ គតិ និងអារម្មណ៍ជាដើមអំពីភពមុននោះក៏មិនប្រាកដ ។

**សិយុំ និទស្សនានេត្ថ បដិឃោសាទិកា អថ**

**សន្តានពន្ធតោ នត្ថិ ឯកតា នាបិ នានតា**

ប្រៀបដូចសំឡេងជះត្រឡប់ (បដិឃោស) ជាដើម

គប្បីជាឧទាហរណ៍បានក្នុងរឿងនេះ ក៏សំឡេងជះត្រឡប់នោះ

មិនមែនជាសំឡេងតែមួយ ទាំងមិនមែនជាសំឡេងផ្សេងគ្នា

(ជាមួយសំឡេងដើម) ព្រោះជាប់គ្នាដោយការបន្តមក ។

ក៏ធម៌ដែលចែកដោយសំឡេងជះត្រឡប់ ពន្លឺប្រទីប ស្នាមត្រា និងស្រមោលគប្បីជាឧទាហរណ៍ក្នុងរឿងនេះ គឺក្នុងការដែលវិញ្ញាណនេះ មិនមកក្នុងភពនេះអំពីភពមុន និងសេចក្តីដែលវិញ្ញាណនេះ កើតឡើងដោយហេតុដែលរាប់បញ្ចូលដោយអតីតភពដូច្នេះ; ដូចយ៉ាងថា សំឡេងជះត្រឡប់ ពន្លឺប្រទីប ស្នាមត្រា និងស្រមោលមានហេតុតមកអំពីសំឡេងខាងដើម មិនបានញែកគ្នាទៅក្នុងទីណា យ៉ាងណា, ចិត្ត

ក៏ដូច្នោះដែរ; ក៏ក្នុងឋាននេះ ចិត្តនេះមិនមែនជាដួងតែមួយ ទាំងមិនមែនផ្សេងគ្នា ព្រោះជាប់គ្នាដោយការបន្តមក; ពិតមែន កាលបើមានសេចក្ដីជាប់គ្នា ដោយការបន្តមកតែមួយ, គប្បីមានដោយចំណែកមួយសោត ទឹកដោះជូរ ក៏មិនគប្បីកើតពីទឹកដោះស្រស់; បើថាសេចក្ដីផ្សេងគ្នាគប្បីមានដោយចំណែកមួយសោត, ទឹកដោះជូរក៏មិនគប្បីមានព្រោះទឹកដោះស្រស់ជាធំ ។ ក្នុងហេតុដែលកើតឡើងនៃហេតុទាំងអស់ ក៏ន័យនេះដែរ ។ កាលបើយ៉ាងនេះ ក៏នឹងគប្បីជាការកាត់នូវវោហារនៃលោកទាំងអស់ចេញ; ក៏ការកាត់នូវវោហាររបស់លោកទាំងអស់នោះ មិនគួរកាន់យក, ព្រោះហេតុនោះ ក្នុងរឿងនេះ មិនគួរចូលចិត្ត សេចក្ដីតែមួយ ឬសេចក្ដីផ្សេងគ្នាដោយចំណែកមួយដូច្នោះឡើយ ។

ក៏ក្នុងអធិការនេះ បើមានអ្នកសួរថា កាលបើសេចក្ដីមិនឃ្លាត សេចក្ដីប្រាកដនៅមានយ៉ាងនេះ ហេតុដែលខន្ធក្នុងអត្តភាពជាមនុស្សនេះរលត់ហើយ និងហេតុដែលកម្មជាបច្ច័យដល់ផល មិនបានប្រព្រឹត្តទៅក្នុងទីដែលកើតផលនោះ ផលនោះរបស់កម្មដទៃ ក៏គប្បីមានអំពីកម្មដទៃ មិនមែនឬ ? ក៏កាលអ្នកចូលទៅសោយមិនមាន ផលនោះគប្បីមានដល់នរណា ? ព្រោះហេតុនោះ វិធីនេះមិនល្អទេ; ក្នុងសេចក្ដីនោះ ទើបលោកប្រព័ន្ធគាថានេះទុកថា ៖

**“សន្តានេ យំ ផលំ ឯតំ នាញ្ញស្ស ន ច អញ្ញតោ**
**វីជានំ អភិសង្ខារោ ឯតស្សត្ថស្ស សាធកោ**

ផលណា ក្នុងការបន្តមក ផលនេះមិនមែនរបស់កម្មដទៃ និងមិនមែនអំពីកម្មដទៃ សភាពតាក់តែងពូជទាំងឡាយ ជា

គ្រឿងសាធកៈក្នុងសេចក្ដីនេះ” ។

មែនពិត ផលកាលកើតឡើងក្នុងសេចក្ដីតចំពោះតែមួយ ក៏ព្រោះសេចក្ដីតែមួយ និងផ្សេងគ្នា ទើបសម្រេចបានដោយចំណែកមួយក្នុងផលនោះ ទើបមិនមានថា ជារបស់កម្មដទៃ ឬអំពីកម្មដទៃ; ក៏សភាពតាក់តែងពូជទាំងឡាយជាគ្រឿងសាធកៈក្នុងសេចក្ដីនេះ ព្រោះកាលបុគ្គលដាំពូជស្វាយជាដើម ផលពិសេសក្នុងកាលដទៃបានបច្ច័យក្នុងការបានបន្តនៃពូជនោះៗ កាលកើតរមែងមិនកើតដល់ពូជដទៃ, រមែងមិនកើតអំពីបច្ច័យជាគ្រឿងតាក់តែងដទៃ; ម្យ៉ាងទៀត ពូជទាំងនោះ ឬគ្រឿងតាក់តែងនោះ រមែងមិនដល់ឋានជាផលបាន; គប្បីជ្រាបការឧបមេយ្យនេះដូច្នោះចុះ; ក៏គប្បីជ្រាបសេចក្ដីនេះ ដោយវិជ្ជាសិល្បៈ និងឱសថជាដើម ដែលប្រើប្រកបក្នុងរាងកាយក្មេង ទំនុកបំរុងរាងកាយឱ្យធំធាត់ជាដើមក្នុងកាលដទៃ និងពាក្យដែលពោលថា កាលមិនមានអ្នកចូលទៅសោយផលនេះ គប្បីមានដល់នរណាដូច្នេះ ។ ក្នុងសេចក្ដីនោះគឺ ៖

**សម្មតិថា អ្នកសោយសម្រេច ព្រោះសេចក្ដីកើតឡើងនៃផល (ផ្លែ) ដូចសម្មតិថា ដើមឈើតែងមានផល ព្រោះការកើតឡើងនៃផលដូច្នោះ ។**

ដូចយ៉ាងថា ដើមឈើ សត្វលោកតែងតែហៅថា រមែងផលិតផល ឬបញ្ចេញផលហើយ ព្រោះការកើតឡើងនៃផលរបស់ដើមឈើនោះ ដែលជាចំណែកមួយរបស់ធម៌ដែលហៅថាដើមឈើនោះឯង យ៉ាងណា, ទេវតា ឬមនុស្ស លោកក៏ហៅថា អ្នកចូលទៅសោយ ឬហៅថា អ្នកមានសុខ និងអ្នកមានទុក្ខ ព្រោះការកើត

ឡើងនៃផល គឺសុខ និងទុក្ខ ដែលហៅថាអ្នកចូលទៅសោយ ដែលជាចំណែកមួយនៃខន្ធទាំងឡាយ ពោលគឺទេវតា និងមនុស្សនោះឯង; ព្រោះហេតុនោះ ក្នុងទីនេះទើបមិនមានសេចក្តីអ្វីៗ ដោយបុគ្គលដទៃដែលឈ្មោះថា **អ្នកចូលទៅសោយ**។

សូម្បីបុគ្គលណាមួយនឹងនិយាយថា "កាលបើយ៉ាងនេះ សង្ខារទាំងឡាយនេះ មានក៏ដោយ មិនមានក៏ដោយ ក៏គប្បីជាបច្ច័យដល់ផលបាន; ក៏បើថា សង្ខារនៅមាន វិបាកក៏គប្បីមានដល់សង្ខារទាំងនោះក្នុងខណៈនៃការប្រព្រឹត្តទៅប៉ុណ្ណោះ; តែបើសង្ខារទាំងនោះមិនមាន ក៏នឹងគប្បីនាំមកនូវផលជានិច្ច ទាំងមុន ទាំងក្រោយអំពីការប្រព្រឹត្តទៅ" ។ បញ្ហាកម្មនោះ គប្បីឆ្លើយយ៉ាងនេះ ៖

**សង្ខារទាំងនេះជាបច្ច័យ ព្រោះជាអ្នកធ្វើ និងមិនមែននាំផលមកឱ្យជានិច្ច ក្នុងសេចក្តីនោះ គប្បីជ្រាបរឿងនាយកូនបំណុលជាដើម ជាឧទាហរណ៍ ។**

មែនពិត សង្ខារទាំងឡាយរមែងជាបច្ច័យដល់ផលរបស់ខ្លួន ព្រោះជាអ្នកធ្វើកម្ម, មិនមែនព្រោះមាន ឬមិនមានឡើយ; ដូចយ៉ាងថាដែលត្រាស់ទុកថា "ចក្ខុវិញ្ញាណដែលជាវិបាកកើតឡើង ព្រោះការធ្វើ ព្រោះការសន្សំកុសលកម្ម ដែលជាកាមាវចរ" [៤៩] ជាដើម; ក៏នឹងជាបច្ច័យដល់ផលរបស់ខ្លួនតាមការគួរ មិនមែននាំផលដដែលៗ មកឱ្យម្តងទៀតទេ ព្រោះភាវជាវិបាកដែលឱ្យផលហើយ ។ ក៏ក្នុងការជាក់ច្បាស់នៃសេចក្តីនេះ គប្បីជ្រាបរឿងនាយកូនបំណុលជាឧទាហរណ៍ ដូចតទៅ

---

[៤៩] អភិ. ។

នេះ ៖

ដូចយ៉ាងថា នាយកូនបំណុលបុគ្គលណាមួយក្នុងលោក ការព្រមព្រៀងទទួលភារៈជាអ្នកបម្រើការងារម្ចាស់បំណុល ក៏ព្រោះអាស្រ័យខ្លួនបានទទួលប្រយោជន៏ខ្លះ, ទើបទិញជាទំនិញជំពាក់ខ្លះ, រមែងបុល (បណ្ដាក់) ខ្លះ, ហើយធ្វើការងារនោះ ការធ្វើការងារនោះ ក៏គ្រាន់តែជាការធ្វើការងាររបស់បំណុលនោះៗ ឯង ជាបច្ច័យក្នុងការដែលខ្លួនគេបានប្រយោជន៏នោះៗ, មិនមែនកិរិយាមាន ឬមិនមានទេ; ព្រោះរូបគេមិនព្រមធ្វើជាអ្នកបម្រើឱ្យហួសពីបំណុល ដែលគេជំពាក់នោះទេ; ព្រោះហេតុអ្វី ? ព្រោះការព្រមព្រៀងជាដើម ខ្លួនគេបានកំណត់ទុកហើយ យ៉ាងណា; សូម្បីសង្ខារទាំងឡាយដែលធ្វើកម្មក៏ដូច្នោះដែរ រមែងជាបច្ច័យដល់ផលរបស់ខ្លួន ព្រោះខ្លួនជាអ្នកធ្វើ និងមិននាំផលសូម្បីលើសជាងការឱ្យផល តាមសមគួរនោះឡើយ ។

ដោយពាក្យមានប្រមាណប៉ុណ្ណេះ រមែងជាការសម្ដែងនូវការប្រព្រឹត្តទៅនៃបដិសន្ធិវិញ្ញាណដែលកំពុងប្រព្រឹត្តទៅទាំង ២ យ៉ាង ដោយអំណាចនៃធម៌ដែលលាយដោយរូប និងមិនលាយដោយរូប ព្រោះសង្ខារជាបច្ច័យ ។

ឥឡូវនេះ ដើម្បីការពារសេចក្ដីវង្វេងក្នុងវិញ្ញាណទាំង ៣២ ដួង ទាំងអស់នោះៗ ឯង ៖

**គប្បីជ្រាបសង្ខារទាំងនោះថាជាបច្ច័យដល់វិញ្ញាណទាំងឡាយណា និងជាបច្ច័យ ដោយប្រការណា ដោយអំណាចនៃបដិសន្ធិកាល និងបវត្តិកាល ក្នុងទីទាំងឡាយមានភពជាដើម ។**

ក្នុងគាថានោះ មានអធិប្បាយថា ធមិទាំងនេះ គឺភព ៣ , កំណើត ៤, គតិ ៥, វិញ្ញាណដ្ឋិតិ ៧ និងសត្តាវាស ៩ ឈ្មោះថា ភពជាដើម; ក្នុងភពជាដើមនេះ សង្ខារទាំងនេះជាបច្ច័យដល់វិបាកវិញ្ញាណទាំងឡាយណា និងសង្ខារទាំងនោះជាបច្ច័យក្នុងបដិសន្ធិកាល និងបវត្តិកាល ដោយប្រការណា, បណ្ឌិតគប្បីជ្រាបដោយប្រការនោះចុះ ៕

## សម្ដែងអំពីបុញ្ញាភិសង្ខារជាបច្ច័យ

បណ្ដាសង្ខារទាំងនោះ គប្បីជ្រាបវិនិច្ឆ័យក្នុងបុញ្ញាភិសង្ខារជាមុនសិន ៖

ពោលអំពីការមិនផ្សេងគ្នា បុញ្ញាភិសង្ខារចែកដោយចេតនា ៨ ដួង ក្នុងកាមាវចរបានបច្ច័យ ២ យ៉ាង គឺដោយកម្មប្បច្ច័យដែលកើតផ្សេងខណៈគ្នា និងដោយឧបនិស្សយប្បច្ច័យក្នុងបដិសន្ធិ ដល់វិបាកវិញ្ញាណ ៩ ដួង ក្នុងបដិសន្ធិកាមសុគ្គតិភូមិ; បុញ្ញាភិសង្ខារដែលចែកដោយកុសលចេតនា ៥ ដួង ក្នុងរូបាវចរ ក៏ជាបច្ច័យដល់វិបាកវិញ្ញាណ ៥ ដួង, ក្នុងបដិសន្ធិកាលរូបភពដូចគ្នា; តែកាមាវចរប្រភេទតាមដែលពោលមកជាបច្ច័យ ២ យ៉ាង ក្នុងបវត្តិកាល, មិនមែនបដិសន្ធិកាលដល់បរិត្តវិបាកវិញ្ញាណ ៧ ដួង វៀរមនោវិញ្ញាណធាតុអហេតុកៈដែលសហគតដោយឧបេក្ខាក្នុងកាមភពសុគតិ ដោយន័យដែលពោលហើយនុ៎ះឯង; បុញ្ញាភិសង្ខារនោះឯង ជាបច្ច័យក្នុងបវត្តិកាល, មិនមែនក្នុងបដិសន្ធិកាល សូម្បីវិបាកវិញ្ញាណ ៥ ដួង ក្នុងរូបភព ក៏យ៉ាងនោះដែរ ។

ក៏ក្នុងកាមភពទុគ្គតិភូមិ ក៏ជាបច្ច័យដល់បរិត្តវិបាកវិញ្ញាណទាំង ៨ ដួង

ក្នុងបវត្តិកាល, មិនមែនក្នុងបដិសន្ធិកាលយ៉ាងនោះដែរ; ក្នុងកាមភពទុគ្គតិភូមិនោះ បុញ្ញាភិសង្ខារនោះជាបច្ច័យ ដោយការប្រសប់ឥដ្ឋារម្មណ៍ក្នុងនរក ក្នុងពេលត្រេច ទៅក្នុងនរកជាដើម របស់ព្រះមហាមោគ្គល្លានត្ថេរ ។ តែឥដ្ឋារម្មណ៍រមែងបានក្នុង ពួកសត្វតិរច្ឆាន និងក្នុងពួកនាគ សុបណ្ណៈ (គ្រុឌ) និងប្រេតអ្នកមានឫទ្ធិច្រើនមែន ពិត; បុញ្ញាភិសង្ខារនោះឯង ជាបច្ច័យក្នុងបវត្តិកាល និងក្នុងបដិសន្ធិកាលដល់កុសល វិបាកវិញ្ញាណទាំង ១៦ ដួង ក្នុងកាមភពសុគតិភូមិ; ពោលអំពីការមិនប្លែកគ្នា បុញ្ញាភិសង្ខារជាបច្ច័យក្នុងបវត្តិកាល និងបដិសន្ធិកាល ដល់វិបាកវិញ្ញាណ ១០ ដួង ក្នុងរូបភពយ៉ាងនោះដូចគ្នា ៕

## សម្តែងអំពីអបុញ្ញាភិសង្ខារជាបច្ច័យ

អបុញ្ញាភិសង្ខារ ចែកដោយអកុសលចេតនា ១២ ដួង ជាបច្ច័យក្នុងបដិសន្ធិ កាល, មិនជាបច្ច័យក្នុងបវត្តិកាល ដល់វិញ្ញាណ ៤ ដួង ក្នុងកាមភពទុគ្គតិភូមិដូចគ្នា នុ៎ះឯង; ជាបច្ច័យក្នុងបវត្តិកាល, មិនជាបច្ច័យក្នុងបដិសន្ធិកាល ដល់វិញ្ញាណ ៦ ដួង; ជាបច្ច័យទាំងក្នុងបវត្តិកាល និងបដិសន្ធិកាលដូចគ្នានោះឯង ដល់អកុសល វិបាកវិញ្ញាណ ៧ ដួង; តែក្នុងកាមសុគតិភូមិ ជាបច្ច័យក្នុងបវត្តិកាល មិនជាបច្ច័យ ក្នុងបដិសន្ធិកាលដល់អកុសលវិបាកវិញ្ញាណ ៧ ដួងទាំងនោះដូចគ្នាដែរ, ជាបច្ច័យ ក្នុងបវត្តិកាល, មិនមែនជាបច្ច័យក្នុងបដិសន្ធិកាលយ៉ាងនោះឯង ដល់វិញ្ញាណ ៤ ដួង ក្នុងរូបភព ។ ក៏អបុញ្ញាភិសង្ខារនោះឯង ជាបច្ច័យដល់វិញ្ញាណក្នុងកាមាវចរ ដោយ អំណាចនៃការឃើញរូប ឮសំឡេងដែលមិនគួរប្រាថ្នាជាដើម; តែក្នុងព្រហ្មលោក

ឈ្មោះថា រូបជាដើមដែលមិនគួរប្រាថ្នាមិនបានមានទេ, សូម្បីក្នុងទេវលោកកាមាវចរ ក៏មិនមានរូបជាដើមដែលមិនគួរប្រាថ្នាដូចគ្នាដែរ ៕

## សម្តែងអំពីអានេញ្ជាភិសង្ខារជាបច្ច័យ

ក៏អានេញ្ជាភិសង្ខារជាបច្ច័យដូចគ្នា ដល់វិបាកវិញ្ញាណ ៤ ដួង ទាំងក្នុងបវត្តិ-កាល ទាំងក្នុងបដិសន្ធិកាល ក្នុងអរូបភពដែរ ៕

## សម្តែងអំពីកាយសង្ខារ ២០ ដួងជាបច្ច័យ

ម្យ៉ាងទៀត ពោលដោយកុសល និងអកុសលក្នុងកាមាវចរ កាយសង្ខារចែកដោយចេតនាទាំង ២០ ដួង ដោយសព្វសង្គាហិកន័យ ជាបច្ច័យ ២ យ៉ាង គឺដោយកម្មប្បច្ច័យដែលកើតផ្សេងខណៈគ្នា និងដោយឧបនិស្សយប្បច្ច័យ ក្នុងបដិ-សន្ធិកាល ដល់វិបាកវិញ្ញាណ ១០ ដួង ក្នុងកាមភព; កាយសង្ខារនោះ។ ឯង ជាបច្ច័យយ៉ាងនោះដូចគ្នា ក្នុងបវត្តិកាល មិនមែនក្នុងបដិសន្ធិកាល ដល់វិបាកវិញ្ញាណ ១៣ ដួង ក្នុងកាមភព, ដល់វិបាកវិញ្ញាណ ៩ ដួងក្នុងរូបភព។ កាយសង្ខារនោះ។ ឯង ជាបច្ច័យដូចនោះ ទាំងក្នុងបវត្តិកាល ទាំងក្នុងបដិសន្ធិកាល ដល់វិបាកវិញ្ញាណ ២៣ ដួង ក្នុងកាមភព; សូម្បីក្នុងវចីសង្ខារ ក៏មានន័យដូចគ្នានេះដែរ ៕

## សម្តែងអំពីចិត្តសង្ខារ ២៩ ដួងជាបច្ច័យ

ចំណែកចិត្តសង្ខារ ដែលចែកដោយចេតនា ២៩ ដួង ជាបច្ច័យដូចក្នុងបដិ-

សន្ធិកាលនោះដែរ, មិនមែនក្នុងបវត្តិកាល ដល់វិបាកវិញ្ញាណ ១៩ ដួង ក្នុងភពទាំង ៣; ចិត្តសង្ខារនោះឯង ជាបច្ច័យក្នុងបវត្តិកាល មិនមែនបដិសន្ធិកាល, ដល់វិបាក-វិញ្ញាណ ២២ ដួង គឺដល់វិបាកវិញ្ញាណ ១៣ ដួង ក្នុងកាមភព និងដល់វិបាកវិញ្ញាណ ៩ ដួង ក្នុងរូបភព តាមដែលពោលមកហើយក្នុងភពទាំង ២; ម្យ៉ាងទៀត ចិត្តសង្ខារនោះ ជាបច្ច័យយ៉ាងនោះឯង ទាំងក្នុងបវត្តិកាល ទាំងក្នុងបដិសន្ធិកាល ដល់វិបាក-វិញ្ញាណ ៣២ ដួង ក្នុងភព ៣ ។

បណ្ឌិតគប្បីយល់សង្ខារទាំងនោះថា ជាបច្ច័យដល់វិញ្ញាណទាំងឡាយណា និងជាបច្ច័យដោយប្រការណានោះ ដោយអំណាចនៃបដិសន្ធិកាល និងបវត្តិកាលក្នុងភពទាំងឡាយយ៉ាងនេះសិន ។ **សូម្បីក្នុងកំណើតជាដើម** ក៏គប្បីជ្រាបដោយន័យនេះដូចគ្នាដែរ ៕

## សម្តែងអំពីសង្ខារជាបច្ច័យដល់វិញ្ញាណ

ក្នុងនិទ្ទេសនៃសង្ខារជាបច្ច័យ ដល់វិញ្ញាណនោះ ពាក្យដែលប្រកាសល្មមជាប្រធានបទតាំងអំពីដើម មានដូច្នេះ ៖

ក៏បណ្តាសង្ខារទាំងនេះ **បុញ្ញាភិសង្ខារ** ញុំាងបដិសន្ធិឱ្យកើតវិបាកទាំងអស់របស់ខ្លួនក្នុងភពទាំង ២ សិន, រមែងញុំាងបដិសន្ធិឱ្យកើតវិបាកទាំងអស់របស់ខ្លួនដូចគ្នាក្នុងកំណើត ៤ មានអណ្ឌជៈកំណើតជាដើម, ក្នុងគតិ ២ ពោលគឺទេវគតិ និងមនុស្សគតិ, ក្នុងវិញ្ញាណដ្ឋិតិ ៤ ពោលគឺអ្នកមានកាយផ្សេងគ្នា មានសញ្ញាផ្សេងគ្នា ១; មានកាយផ្សេងគ្នាមានសញ្ញាដូចគ្នា ១; មានកាយដូចគ្នាមានសញ្ញាផ្សេងគ្នា ១;

មានកាយដូចគ្នាមានសញ្ញាដូចគ្នា ១; ដោយអំណាចនៃមនុស្សទាំងឡាយ និងក្នុង បឋមជ្ឈានភូមិ ទុតិយជ្ឈានភូមិ និងតតិយជ្ឈានភូមិ; តែក្នុងអសញ្ញសត្តាវាស បុញ្ញា-ភិសង្ខារនេះ រមែងតាក់តែងត្រឹមតែរូបប៉ុណ្ណោះ ទើបអំណោយបដិសន្ធិឱ្យកើតវិបាក ទាំងអស់របស់ខ្លួន ក្នុងសត្តាវាស ៤ (ដូចវិញ្ញាណដ្ឋិតិ) នោះៗ ឯង ព្រោះហេតុនោះ បុញ្ញាភិសង្ខារនេះ ទើបជាបច្ច័យទាំងក្នុងបដិសន្ធិកាល ទាំងក្នុងបវត្តិកាល ដល់វិបាក-វិញ្ញាណ ២១ ដួង តាមសមគួរដល់ការកើតឡើងក្នុងភព ២, កំណើត ៤, គតិ ២, វិញ្ញាណដ្ឋិតិ ៤ និងសត្តាវាសទាំង ៤ នេះ ដោយន័យដែលពោលហើយនោះចុះ ។

ម្យ៉ាងទៀត **អបុញ្ញាភិសង្ខារ** រមែងឱ្យវិបាក ដោយអំណាចនៃបដិសន្ធិ ក្នុងកាមភព ១ ប៉ុណ្ណោះ ក្នុងកំណើត ៤, ក្នុងគតិ ៣ ដ៏សេស, ក្នុងវិញ្ញាណដ្ឋិតិ ១ គឺ មានកាយផ្សេងគ្នា មានសញ្ញាដូចគ្នា និងក្នុងសត្តាវាស ១ ដូចវិញ្ញាណដ្ឋិតិនោះដែរ; ព្រោះហេតុដូច្នោះ អបុញ្ញាភិសង្ខារនេះ ទើបជាបច្ច័យទាំងក្នុងបដិសន្ធិកាល ទាំងក្នុង បវត្តិកាល ដល់វិញ្ញាណ ៧ ដួង ក្នុងភព ១, កំណើត ៤, គតិ ៣, វិញ្ញាណដ្ឋិតិ ១, និងក្នុងសត្តាវាស ១ ដោយន័យដែលពោលហើយនោះឯង ។

តែ **អានេញ្ជាភិសង្ខារ** រមែងឱ្យវិបាកដោយអំណាចនៃបដិសន្ធិ ក្នុងអរូប-ភព ១, ក្នុងឱបបាតិកកំណើត ១, ក្នុងទេវគតិ ១, ក្នុងវិញ្ញាណដ្ឋិតិ ៣, មានអាកា-សានញ្ចាយតនៈជាដើម និងក្នុងសត្តាវាស ៤ មានអាកាសានញ្ចាយតនៈជាដើម; ព្រោះហេតុដូច្នោះ អានេញ្ជាភិសង្ខារនេះ ទើបជាបច្ច័យទាំងក្នុងបដិសន្ធិកាល ទាំង ក្នុងបវត្តិកាល ដល់វិញ្ញាណ ៤ ដួង ក្នុងភព ១ ប៉ុណ្ណោះ, ក្នុងកំណើត ១, ក្នុងគតិ ១, ក្នុងវិញ្ញាណដ្ឋិតិ ៣ និងក្នុងសត្តាវាស ៤ តាមន័យដែលពោលហើយនោះឯង ។

**សូម្បីកាយសង្ខារ** ក៏គួរញុំាងបដិសន្ធិឱ្យវិបាករបស់ខ្លួនទាំងអស់កើតឡើង ក្នុងកាមភព ១, ក្នុងកំណើត ៤, ក្នុងគតិ ៥, ក្នុងវិញ្ញាណដ្ឋិតិ ២ និងក្នុងសត្តាវាស ២; ព្រោះហេតុដូច្នោះ កាយសង្ខារនោះ ទើបជាបច្ច័យដូចយ៉ាងនោះដែរ ទាំងក្នុងបដិសន្ធិកាល ទាំងក្នុងបវត្តិកាល ដល់វិបាកវិញ្ញាណ ២៣ ដួង ក្នុងភព ១, ក្នុងកំណើត ៤, ក្នុងគតិ ៥, ក្នុងវិញ្ញាណដ្ឋិតិ ២ និងក្នុងសត្តាវាស ២។ សូម្បីក្នុងវចីសង្ខារ ក៏មានន័យដូចគ្នានេះដែរ ។

**ចំណែកចិត្តសង្ខារ** វៀរសត្តាវាស (អសញ្ញីសត្វ) ម្យ៉ាង នឹងមិនឱ្យផលក្នុងទីណាៗ រមែងមិនមាន, ព្រោះហេតុដូច្នោះ ទើបចិត្តសង្ខារនេះដូចគ្នាដែរ ទាំងក្នុងបដិសន្ធិកាល ទាំងក្នុងបវត្តិកាល ដល់វិបាកវិញ្ញាណទាំង ៣២ ដួង តាមសមគួរ ក្នុងភព ៣, កំណើត ៤, គតិ ៥, វិញ្ញាណដ្ឋិតិ ៧ និងក្នុងសត្តាវាស ៨; ម្យ៉ាងទៀត ក្នុងសត្តាវាសដែលមិនមានវិញ្ញាណ វិញ្ញាណក៏មិនកើត ព្រោះសង្ខារជាបច្ច័យ ។

ម្យ៉ាងវិញទៀត **បុញ្ញាភិសង្ខារ** ជាបច្ច័យដល់**កដត្តារូបទាំងឡាយ** ក្នុងពួកអសញ្ញីសត្វ ដោយកម្មប្បច្ច័យដែលកើតផ្សេងខណៈគ្នា; ដោយប្រការដូច្នេះឯង ៖

**បណ្ឌិតគប្បីជ្រាបសង្ខារទាំងនោះ ជាបច្ច័យដល់**
**វិញ្ញាណទាំងឡាយណា និងដោយប្រការណា ដោយ**
**អំណាចនៃបដិសន្ធិកាល និងបវត្តិកាល ក្នុងឋានទាំង-**
**ឡាយ មានភពជាដើម ៕**

**ចប់និទ្ទេសនៃសង្ខារជាបច្ច័យដល់វិញ្ញាណ**

## សម្តែងអំពីនាមរូបនិទ្ទេស

ក្នុងនិទ្ទេសនៃនាមរូបកើតមាន ព្រោះវិញ្ញាណជាបច្ច័យ ៖

បណ្ឌិតគប្បីជ្រាបការវិនិច្ឆ័យ ដោយប្រភេទនៃទេសនា
ដោយសេចក្តីប្រព្រឹត្តទៅ ក្នុងឋានទាំងឡាយ មានភពជា
ដើម ដោយការសង្គ្រោះ និងដោយន័យនៃបច្ច័យ ៕

## សម្តែងអំពីការវិនិច្ឆ័យដោយប្រភេទនៃទេសនា

បទថា **ដោយប្រភេទទេសនា** អធិប្បាយថា ព្រះមានព្រះភាគទ្រង់ធ្វើទេសនាដល់រូបបទដូចគ្នា គឺដោយមិនផ្សេងគ្នា ទាំងក្នុងព្រះសូត្រ ទាំងក្នុងនាមរូប-និទ្ទេសនេះ យ៉ាងនេះថា **“តត្ថ កតមំ រូបំ, ចត្តារោ ច មហាភូតា ចតុន្នញ្ច មហាភូតានំ ឧបាទាយរូបំ** = បណ្តានាម និងរូបទាំងនោះ រូបតើដូចម្តេច ? មហាភូតរូប ៤ និងរូបដែលអាស្រ័យមហាភូតរូប ៤” [៤១]។ តែបទថា **នាម** ទ្រង់ធ្វើទេសនាទុកផ្សេងគ្នា; ព្រោះក្នុងព្រះសូត្រ ត្រាស់ទុកថា **“ក្នុងនាម និងរូបនោះ នាមតើដូចម្តេច ? វេទនា សញ្ញា ចេតនា ផស្សៈ និងមនសិការ”**, តែក្នុងព្រះអភិធម្មនេះ ទ្រង់ត្រាស់ថា វេទនាខន្ធ សញ្ញាខន្ធ និងសង្ខារក្ខន្ធ ព្រោះថា ក្នុងព្រះសូត្រនោះ សូម្បីនាមណា រមែងកើតឡើង ព្រោះចក្ខុវិញ្ញាណជាបច្ច័យ, ក៏នាមណាដែលកើតហើយ កាលនឹងទ្រង់សម្តែងនាមនោះ ដែលកំពុងប្រាកដ ដោយសេចក្តី

[៤១] ម. មូ., សំ. និ. ៣១។

មិនគួរកាន់យក ដោយអាស្រ័យរួមជាមួយធម៌ដទៃ យ៉ាងនេះថា "សេចក្តីតាំងនៅនៃចិត្ត ជាអាយុរបស់អរូបធម៌ទាំងឡាយ" ; ទើបទ្រង់សម្តែងចែក សង្ខារក្ខន្ធជា ៣ យ៉ាង ដោយអំណាចនៃចេតនា ផស្សៈ និងមនសិការ ព្រមជាមួយនឹងខន្ធ ២ ទៀត (គឺវេទនាខន្ធ និងសញ្ញាខន្ធ)។ តែក្នុងព្រះអភិធម្មនេះ កាលនឹងទ្រង់សង្គ្រោះនាមទាំងអស់ ដែលត្រាស់ហើយក្តី នៅមិនទាន់បានត្រាស់ក្តី ក្នុងព្រះសុត្តន្តៈនោះ ទើបត្រាស់ថា "**តយោ ខន្ធា វេទនាខន្ធោ សញ្ញាខន្ធោ សង្ខារក្ខន្ធោ** = ខន្ធ ៣ គឺវេទនាខន្ធ សញ្ញាខន្ធ និងសង្ខារក្ខន្ធ" ។

**សួរថា** ខន្ធទាំង ៣ នេះប៉ុណ្ណោះ ឈ្មោះថា ជានាម, វិញ្ញាណមិនឈ្មោះថាជានាមឬ ?

ឆ្លើយថា វិញ្ញាណមិនមែនមិនជានាមក៏ទេ; តែកាលបើកាន់យកវិញ្ញាណនោះ ជានាមផង វិញ្ញាណទាំង ២ គឺវិញ្ញាណដែលជានាម និងវិញ្ញាណដែលជាបច្ច័យក៏នឹងប្រាកដរួមគ្នា; ព្រោះហេតុដូច្នោះ ទើបត្រាស់ខន្ធ ៣ ដើម្បីទ្រង់សម្តែងនាមដែលកើតឡើង ព្រោះបច្ច័យ វៀរវិញ្ញាណទុកក្នុងឋានជាបច្ច័យ។ គប្បីជ្រាបការវិនិច្ឆ័យដោយប្រភេទនៃទេសនា ដោយប្រការដូច្នេះសិន ៕

## សម្តែងអំពីការវិនិច្ឆ័យដោយសេចក្តីប្រព្រឹត្តទៅក្នុងភពជាដើម

ក៏ក្នុងបទថា **ដោយការប្រព្រឹត្តទៅក្នុងឋានទាំងឡាយមានភពទាំងអស់ជាដើម** នេះ អធិប្បាយថា លើកវៀរសត្តាវាស (អសញ្ញសត្តភូមិ) មួយហើយ នាមរមែងប្រព្រឹត្តទៅក្នុងភព កំណើត គតិ វិញ្ញាណដ្ឋិតិ និងក្នុងសត្តាវាសដ៏សេស

ទាំងអស់ ។ តែរូបរមែងប្រព្រឹត្តទៅក្នុងភព ២, កំណើត ៤, គតិ ៥, វិញ្ញាណដ្ឋិតិ ៤ និងសត្តាវាស ៥ ខាងដើម; កាលនាម និងរូបនេះ ប្រព្រឹត្តទៅយ៉ាងនេះ ក៏ព្រោះក្នុងខណៈបដិសន្ធិរបស់គព្ភសេយ្យកៈ មិនមានភាវៈ និងអណ្ឌជៈ រមែងប្រាកដ សន្តតិរូបដែលជាប្រធាន ២ យ៉ាង ដោយរូប ដោយអំណាចនៃវត្ថុ កាយ (ទសកៈ) និងអរូប-ក្ខន្ធ ៣; ព្រោះហេតុដូច្នោះ ពោលដោយពិស្តាររបស់សត្វទាំងនោះ ធម៌ ២៣ ទាំងរូប ទាំងអរូប គឺ ធម៌ (ដែលជារូប) ២០; ខន្ធដែលជាអរូប ៣ ទាំងនេះ គប្បីជ្រាបថា "នាមរូបកើតមាន ព្រោះវិញ្ញាណជាបច្ច័យ" ។

តែកាលពោលដោយការកាន់យក ចំនួនដែលនៅមិនទាន់បានកាន់យកទៀត ក៏បានធម៌ ១៤ ដោយដកយករូបធម៌ ៩ ចេញអំពីសន្តតិរូបដែលជាប្រធាន ១, សម្រាប់សត្វអ្នកមានភាវៈ ក៏បន្ថែមភាវទសកៈចូលជា ៣៣; ម្យ៉ាងទៀត កាលពោលដោយការកាន់យក ចំនួនដែលនៅមិនទាន់បានកាន់យក សូម្បីរបស់សត្វទាំងនោះ ក៏បានធម៌ ១៥ ដោយនាំរូបធម៌ ១៨ ចេញពីសន្តតិរូបដែលជាប្រធានទាំង ២; ក៏ព្រោះក្នុងខណៈបដិសន្ធិ របស់រូបព្រហ្មជាដើម ក្នុងចំពូកសត្វដែលជាឱបបាតិកៈកំណើត រមែងប្រាកដសន្តតិរូបដែលជាប្រធាន ៤ ដោយជារូបរូប ដោយអំណាចនៃចក្ខុទសកៈ សោតទសកៈ វត្ថុទសកៈ ជីវិតិន្ទ្រិយនវកៈ និងអរូបក្ខន្ធ ៣; ព្រោះហេតុដូច្នោះ កាលពោលដោយពិស្តារដល់កំណើតទាំងនោះ ធម៌ ៤២ គឺរូបធម៌ ៣៩ ដោយរូបរូប និងអរូបក្ខន្ធ ៣ នេះ គប្បីជ្រាបថា "នាមរូបកើតមាន ព្រោះវិញ្ញាណជាបច្ច័យ"; តែកាលពោលដោយសភាវៈ ដែលកាន់យកហើយ មិនកាន់យកទៀត ក៏នឹងបានធម៌ ១៥ យ៉ាង ដោយនាំយករូបធម៌ ២៧ ចេញអំពីសន្តតិរូប ដែលជាប្រធានទាំង ៣; ក៏ព្រោះ

ក្នុងកាមភព ក្នុងខណៈបដិសន្ធិរបស់ឱបបាតិកៈដ៏សេស ឬសំសេទជៈដែលមានភាវៈ និងអាយតនៈបរិបូណ៌ រមែងប្រាកដសន្តតិរូបដែលជាប្រធាន ៧ ដោយរូបរូប និង អរូបក្ខន្ធ ៣; ព្រោះហេតុដូច្នោះ ពោលដោយពិស្តារនៃធម៌ទាំងនោះ ក៏បានធម៌ ទាំងអស់ ៧៣ នេះ គឺ (រូប) ធម៌ ៧០ ដោយរូបរូប និងអរូបក្ខន្ធទាំង ៣ នេះ គប្បី ជ្រាបថា "នាមរូបកើតមាន ព្រោះវិញ្ញាណជាបច្ច័យ" ; តែកាលពោលដោយការ កាន់យកហើយ មិនកាន់យកទៀត ក៏បានធម៌ ១៩ ដោយនាំធម៌ ៥៤ ចេញពី សន្តតិរូបដែលជាប្រធាន ៦; នេះពោលដោយឧក្រិដ្ឋ ។

តែកាលពោលដោយយ៉ាងទាប បណ្ឌិតគប្បីបន្ថយចុះៗ នៃធម៌ គឺសន្តតិរូប ដែលជាប្រធានមានការខ្វះខាតនោះៗ ដោយអំណាចនៃសត្វនោះៗ ហើយជ្រាបធម៌ ពោលគឺនាមរូបកើត ព្រោះបដិសន្ធិវិញ្ញាណ ទាំងដោយសង្ខេប ទាំងដោយពិស្តារ។ ចំណែកអរូបព្រហ្ម បានជាអរូបក្ខន្ធកើតមាន ព្រោះបដិសន្ធិវិញ្ញាណជាបច្ច័យ តែ សម្រាប់អសញ្ញីសត្វទាំងឡាយ បានជីវិតិន្ទ្រិយនវកៈ (ជីវិតិន្ទ្រិយ ៩ កលាបៈ) ដោយ រូបតែម្យ៉ាងនោះឯង នេះជាន័យក្នុងបដិសន្ធិកាល ជាមុនសិន ។

ចំណែកក្នុងបវត្តិកាល សុទ្ធដ្ឋកៈ (អវិនិព្ភោគរូប ៨ សុទ្ធ) ដែលមានឧតុជា សមុដ្ឋាន, តែឧតុដែលប្រព្រឹត្តទៅជាមួយនឹងបដិសន្ធិចិត្ត រមែងប្រាកដក្នុងឋិតិខណៈ របស់បដិសន្ធិចិត្ត ដែលជាដែនអាស្រ័យប្រព្រឹត្តទៅរបស់រូបទាំងអស់; តែថា បដិ- សន្ធិចិត្តរមែងញ៉ាំងរូបឱ្យតាំងឡើងមិនបាន; ក៏បដិសន្ធិចិត្តនោះ មិនអាចដើម្បីញ៉ាំង រូបឱ្យតាំងឡើងបាន ព្រោះសេចក្ដីដែលវត្ថុនៅមានកម្លាំងខ្សោយ ដូចបុរសធ្លាក់ចុះ

ទៅក្នុងជ្រោះ មិនអាចនឹងជួយសង្គ្រោះអ្នកដទៃបានដូច្នោះ ។ តែកាលផុតពីបដិសន្ធិ-ចិត្តទៅហើយ ចាប់ផ្តើមតាំងពីបឋមភវង្គទៅ សុទ្ធដ្ឋករូបដែលមានចិត្តជាសមុដ្ឋាន ក៏តាំងឡើង; ក្នុងកាលប្រាកដនៃសំឡេង រមែងប្រាកដជាសទ្ទនវករូប អំពីឧតុជរូប ដែលប្រព្រឹត្តទៅខាងមុខបដិសន្ធិចិត្ត និងអំពីចិត្ត ។ គព្ភសេយ្យកសត្វទាំងឡាយណា រស់នៅដោយកវឡិង្ការាហារ ក្នុងសរីរៈរបស់សត្វទាំងនោះ ជ្រួតជ្រាបទៅដោយអា-ហារដែលមាតាទំពាស៊ីចូលទៅ ដោយព្រះបាលីថា ៖

> **“ក៏មាតារបស់គព្ភសេយ្យកសត្វនោះ រមែងបរិភោគ បាយ និងទឹកណា នរៈដែលរស់នៅក្នុងគភ៌របស់មាតា នោះ ក៏ញុំាំងអត្តភាពឱ្យប្រព្រឹត្តទៅដោយបាយ និងទឹក នោះ ក្នុងគភ៌នោះដែរ”** [៤២] ។

សម្រាប់ឱបបាតិកៈកំណើត ក្នុងវេលាដែលខ្លួនលេបទឹកមាត់ចូលទៅក្នុងមាត់ ទឹកមាត់ដំបូងបង្អស់នោះ ក៏ប្រាកដជាសុទ្ធដ្ឋករូបដែលមានអាហារជាសមុដ្ឋានដែរ, តែកាលពោលដោយសង្ខេប បានដល់ ធម៌ ៩៩ យ៉ាង គឺ រូប ២៦ ដោយអំណាច នៃសុទ្ធដ្ឋករូបដែលមានអាហារជាសមុដ្ឋាន និងនវករូបទាំង ២ ដោយឧក្រិដ្ឋនៃរូប ដែលមានឧតុ និងចិត្តជាសមុដ្ឋាន និងរូប ៧០ ប្រភេទ មានកម្មជាសមុដ្ឋាន ដែល កើតឡើង ៣ គ្រា ក្នុងខណៈនៃចិត្តតែ ១ ដួង ដែលពោលហើយក្នុងខាងដើមនេះ

---

[៤២] សំ. ស. ។

រួមជារូប ៩៦ យ៉ាង និងអរូបក្ខន្ធ ៣។ មា្យ៉ាងទៀត ព្រោះសំឡេងមិនប្រាកដក្នុងកាលខ្លះ ៗ; ព្រោះហេតុដូច្នេះ នាំសំឡេងទាំង ២ នោះចេញហើយ ធម៌ ៩៧ ទាំងនេះ គប្បីជ្រាបថា នាមរូបកើតមាន ព្រោះវិញ្ញាណជាបច្ច័យដល់សព្វសត្វទាំងឡាយ តាមដែលកើតឡើងបាន ។

ក៏ធម៌ (ទាំងរូប និងអរូប) ទាំងនេះ រមែងកើតព្រោះវិញ្ញាណជាបច្ច័យដល់សត្វទាំងនោះ អ្នកប្រមាទខ្លះ អ្នកកំពុងត្រាច់ទៅខ្លះ អ្នកកំពុងទំពាស៊ីខ្លះ អ្នកកំពុងផឹកខ្លះ ទាំងថ្ងៃ ទាំងយប់។ ក៏សេចក្ដីដែលវិញ្ញាណជាបច្ច័យ ដល់រូបទាំងឡាយនោះ ខ្ញុំនឹងពណ៌នាតទៅខាងមុខ ។

មា្យ៉ាងទៀត ក្នុងអធិការនេះ កម្មជរូបនេះឯង សូម្បីតាំងនៅគ្រាដំបូងក្នុងទីទាំងពួង គឺក្នុងភព កំណើត គតិ វិញ្ញាណដ្ឋិតិ និងក្នុងសត្តាវាស ដែលសមុដ្ឋានិករូបទាំង ៣ មិនឧបត្ថម្ភហើយ រមែងមិនអាចដើម្បីតាំងនៅបាន, សូម្បីសមុដ្ឋានិករូបទាំង ៣ នោះ ដែលកម្មជរូបនោះ មិនឧបត្ថម្ភហើយ ក៏តាំងនៅមិនបាន; តាមពិតរូបទាំងនេះផ្សេងគ្នា តែក៏ឧបត្ថម្ភនូវគ្នានឹងគ្នាមិនឱ្យធ្លាក់ទៅ ទើបតាំងនៅបាន ១ ឆ្នាំខ្លះ ២ ឆ្នាំខ្លះ ។ ល ។ ១០០ ឆ្នាំខ្លះ រហូតដល់អស់អាយុ ឬអស់បុណ្យរបស់សត្វទាំងនោះទៅ ដូចជាស្នោកមានដើមបបោសជាដើម ដែលដុះញឹកប្រទាក់ប្រទងគ្នាទាំង ៤ ទិស ទោះត្រូវខ្យល់បក់ហើយ ក៏នៅតែរស់បាន ឬប្រៀបដូចមនុស្សមានពាហនៈ គឺទូកដែលធ្លាយក្នុងមហាសមុទ្រ គាប់ជួនបានទីពឹងហើយ សូម្បីត្រូវកម្លាំងរលកបោក ក៏នៅរស់បានដូច្នោះ។ គប្បីជ្រាបវិនិច្ឆ័យក្នុងអធិការនេះ ដោយសេចក្ដីប្រព្រឹត្តទៅក្នុងឋានទាំងឡាយ មានភពជាដើមទាំងអស់ ដោយប្រការដូច្នេះ ៕

## សម្តែងអំពីការវិនិច្ឆ័យដោយសង្គ្រោះ

ក៏ក្នុងបទថា **ដោយសង្គ្រោះ** នេះ អធិប្បាយថា បណ្ឌិតគប្បីសង្គ្រោះដោយសរុបឯកសេសន័យនេះថា នាមតែម្យ៉ាងកើតព្រោះវិញ្ញាណជាបច្ច័យក្នុងបវត្តិកាលនិងបដិសន្ធិកាល ក្នុងអរូបភព និងក្នុងបវត្តិកាល ក្នុងបញ្ចវោការភពណា, ក៏រូបតែម្យ៉ាងកើតមាន ព្រោះវិញ្ញាណជាបច្ច័យក្នុងបដិសន្ធិកាល និងបវត្តិកាលទាំងអស់ ក្នុងពួកអសញ្ញីភព និងក្នុងបវត្តិកាលក្នុងបញ្ចវោការភពណា, ក៏នាមរូបដែលកើត ព្រោះវិញ្ញាណជាបច្ច័យក្នុងកាលទាំងពួង ក្នុងបញ្ចវោការភពណា, នាមផង រូបផង និងនាមរូបផង ទាំងអស់នោះ ឈ្មោះថា នាមរូបដូច្នេះ ហើយសូមជ្រាបថា នាមរូបកើតមាន ព្រោះវិញ្ញាណជាបច្ច័យ ។

បើមានអ្នកសង្ស័យ **សួរថា** ព្រោះសេចក្តីដែលអសញ្ញីសត្វ មិនមានវិញ្ញាណ វិញ្ញាណទើបមិនគួរឬ ?

ឆ្លើយថា មិនមែនមិនគួរទេ ។

មែនពិត វិញ្ញាណនេះ ( លោកពោលទុកថា) ៖

**នាមរូបស្ស យំ ហេតុ វិញ្ញាណន្តំ ទ្វិធា មតំ**
**វិបាកមវិបាកញ្ច យុត្តមេវ តតោ ឥទំ ។**

វិញ្ញាណណា ជាហេតុនៃនាមរូប វិញ្ញាណនោះ
លោកពោលទុក ២ យ៉ាង គឺវិញ្ញាណដែលជាវិបាក
និងវិញ្ញាណដែលមិនជាវិបាក វិញ្ញាណនេះ ទើបសមគួរ
ជាបច្ច័យ ដល់រូបក្នុងអសញ្ញីភពនោះមែនពិត ។

ពិតណាស់ វិញ្ញាណណាជាហេតុនៃនាមរូប, វិញ្ញាណនោះ លោកពោលទុក ២

យ៉ាង ដោយចែកជាវិបាក និងមិនមែនជាវិបាក; ឯរូបក្នុងអសញ្ញីសត្វទាំងឡាយ ក៏កើតព្រោះវិញ្ញាណជាអភិសង្ខារ ដែលប្រព្រឹត្តទៅក្នុងបញ្ចវោការភពជាបច្ច័យ ព្រោះសេចក្ដីដែលរូបទាំងនោះ មានកម្មជាសមុដ្ឋាន, ក្នុងបញ្ចវោការភពនៃបវត្តិកាលក្នុងខណៈនៃចិត្តជាកុសលជាដើម ក៏មានកម្មជាសមុដ្ឋានដូចគ្នាដែរ ព្រោះហេតុដូច្នោះវិញ្ញាណនេះ ទើបសមគួរជាបច្ច័យដូចគ្នា។ គប្បីជ្រាបវិនិច្ឆ័យដោយសង្គ្រោះ ក្នុងអធិការនេះ ដោយប្រការដូច្នេះ ៕

## សំដែងអំពីការវិនិច្ឆ័យដោយបច្ច័យ

ក៏គប្បីជ្រាបការវិនិច្ឆ័យក្នុងបទថា **ដោយន័យនៃបច្ច័យ** នេះ តទៅ ៖

**នាមស្ស បាកវិញ្ញាណំ នវធា ហោតិ បច្ចយោ**
**វត្ថុរូបស្ស នវធា សេសរូបស្ស អដ្ឋធា ។**
**អភិសង្ខារវិញ្ញាណំ ហោតិ រូបស្ស ឯកធា**
**តទញ្ញំ បន វិញ្ញាណំ តស្ស តស្ស យថារហំ ។**

វិបាកវិញ្ញាណជាបច្ច័យ ដល់នាម ៩ យ៉ាង ជាបច្ច័យដល់វត្ថុរូប ៩ ជាបច្ច័យ ដល់រូបដ៏សេស ៨ យ៉ាង; អភិសង្ខារវិញ្ញាណជាបច្ច័យ ដល់រូបតែម្យ៉ាង ចំណែកវិញ្ញាណក្រៅពីនោះ ជាបច្ច័យដល់នាមរូបនោះៗ តាមការគួរ ។

ពិតណាស់ នាម ពោលគឺវិបាកក្នុងបដិសន្ធិកាល ឬក្នុងបវត្តិកាលនេះឯង, បដិសន្ធិវិញ្ញាណ ឬវិបាកវិញ្ញាណដទៃ ជាបច្ច័យ ៩ យ៉ាង ដល់នាមនោះដែលលាយខ្លះ មិនលាយខ្លះដោយរូប ដោយសហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ

សម្បយុត្តប្បច្ច័យ វិបាកប្បច្ច័យ អាហារប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ អត្ថិប្បច្ច័យ និងអវិ-គតប្បច្ច័យ ។ ជាបច្ច័យដល់វត្ថុរូបក្នុងបដិសន្ធិកាល ៩ បច្ច័យ ដោយសហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ វិបាកប្បច្ច័យ អាហារប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ វិប្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ និងអវិគតប្បច្ច័យ ។ ជាបច្ច័យដល់រូបដ៏សេស ៨ បច្ច័យ វៀរវត្ថុរូបចេញ ហើយនាំអញ្ញមញ្ញប្បច្ច័យក្នុងបច្ច័យ ៩ បច្ច័យនេះចេញ ។

ចំណែកអភិសង្ខារវិញ្ញាណ ជាបច្ច័យដល់អសញ្ញីសត្តរូប ឬដល់កម្មជរូបក្នុងបញ្ចវោការភព ដោយអំណាចនៃឧបនិស្សយប្បច្ច័យ តែម្យ៉ាងប៉ុណ្ណោះ ដោយបរិយាយដែលមកក្នុងព្រះសុត្តន្ត; វិញ្ញាណទាំងអស់ដ៏សេស ចាប់តាំងអំពីបឋមភវង្គ គប្បីជ្រាបថា ជាបច្ច័យដល់នាមរូបនោះៗ តាមការគួរ ។ ម្យ៉ាងទៀត កាលនឹងសម្តែងន័យរបស់បច្ច័យនៃនាមរូបនោះ ដោយពិស្តារ បណ្ឌិតក៏នឹងគប្បីញ៉ាំងសូម្បីបដ្ឋានកថាទាំងអស់ ឱ្យទូលំទូលាយ ព្រោះហេតុដូច្នោះ ទើបខ្ញុំនៅមិនទាន់ផ្តើមបដ្ឋានកថានោះ ។

ក្នុងសេចក្តីនោះ បើមានអ្នក*សួរថា* ក៏សេចក្តីនេះនឹងគប្បីដឹងបានយ៉ាងណាថា "នាមរូបក្នុងបដិសន្ធិកាលមានវិញ្ញាណជាបច្ច័យ ?" ឆ្លើយថា ដឹងបានដោយព្រះសូត្រ និងដោយយុត្តិ (សេចក្តីត្រឹមត្រូវដោយហេតុផល); ព្រោះក្នុងព្រះសូត្រ សេចក្តីនៃធម៌មានវេទនាជាដើម ជាបច្ច័យសម្រេចហើយដោយច្រើន មានន័យជាអាទិ៍ថា **"ចិត្តានុបរិវត្តិនោ ធម្មា** = ធម៌ទាំងឡាយប្រព្រឹត្តទៅតាមចិត្ត[៥០]; ចំណែកយុត្តិថា ៖

---

[៥០] អភិ. ។

សេចក្តីពិត វិញ្ញាណរមែងសម្រេចបាន ដោយ
ចិត្តជួររូបដែលឃើញបាន ក្នុងលោកនេះ សូម្បីវិញ្ញាណ
ក៏ជាបច្ច័យសូម្បីដល់រូបដែលឃើញមិនបាននោះឯង ។

ពិតមែន កាលចិត្តជួរផង ឬមិនជួរផងក៏ដោយ រូបទាំងឡាយដែលគួរដល់ចិត្តនោះ កាលកើតឡើង វិញ្ញាណទើបឃើញ, ក៏ការអនុមាន (ប៉ាន់ស្មាន) រូបដែលឃើញមិនបាន រមែងមានដោយរូបដែលឃើញបាន ព្រោះហេតុដូច្នោះ សេចក្តីនេះគប្បីដឹងបានដោយបទនេះថា វិញ្ញាណរមែងជាបច្ច័យដល់រូប ក្នុងបដិសន្ធិ សូម្បីដែលឃើញមិនបាន ដោយចិត្តជួររូបដែលឃើញបាន ក្នុងលោកនេះ។ ព្រោះសេចក្តីដែលរូបក្នុងបដិសន្ធិនោះ សូម្បីមានកម្មជាសមុដ្ឋាន ជាបច្ច័យមកហើយក្នុងបដ្ឋាន ដូចរូបដែលមានចិត្តជាសមុដ្ឋាន។ ក្នុងអធិការនេះ គប្បីជ្រាបវិនិច្ឆ័យដោយន័យរបស់បច្ច័យមានប្រការដូច្នេះ ។

ក៏កាលព្រះមានជោគ ត្រាស់នៅក្នុងបទថា **“វិញ្ញាណប្បច្ចយា នាមរូបំ** = នាមរូបកើតមាន ព្រោះវិញ្ញាណជាបច្ច័យ” នេះ ឈ្មោះថា ទ្រង់ប្រកាសព្រះធម្មចក្រដ៏កំពូល ដែលសមណៈក្តី ព្រាហ្មណ៍ក្តី ទេវតាក្តី មារក្តី ព្រហ្មក្តី ឬថា អ្នកឯណានីមួយ ក្នុងលោកនេះក្តី ផ្លាស់ប្តូរមិនបាន ព្រោះបើបណ្ឌិតចូលទៅពិចារណាហើយ រមែងឃើញមានត្រឹមតែនាមរូប ដោយបរមត្ថប៉ុណ្ណោះ កំពុងប្រព្រឹត្តទៅ មិនមែនសត្វ ឬបុគ្គលឡើយ ៕

**ចប់និទ្ទេសនៃនាមរូបមានវិញ្ញាណជាបច្ច័យ**

## សម្តែងអំពីសឡាយតននិទ្ទេស

គប្បីជ្រាបការវិនិច្ឆ័យក្នុងនិទ្ទេសនៃសឡាយតនៈកើតមាន ព្រោះនាមរូបជាបច្ច័យតទៅ ៖

**នាមំ ខន្ធត្តយំ រូបំ ភូតវត្ថាទិកំ មតំ**
**កតេកសេសំតន្តស្ស តាទិសស្សេវ បច្ចយោ ។**

នាម គឺខន្ធ ៣; រូប បានដល់ រូបដែលពោលថា
ភូត និងវត្ថុជាដើម នាមរូបនោះ លោកធ្វើឯកសេស-
ន័យថា ជាបច្ច័យដល់សឡាយតនៈនោះដូច្នោះឯង ។

មែនពិត ក្នុងនាមរូបដែលជាបច្ច័យដល់សឡាយតនៈនោះ ខន្ធ ៣ មានវេទនាខន្ធជាដើម ឈ្មោះថា **នាម** ចំណែករូបដែលរាប់បញ្ចូលដោយសន្តតិរបស់ខ្លួន គប្បីជ្រាបថា លោកហៅថា ភូតៈ និងវត្ថុ ដោយកំណត់យ៉ាងនេះ គឺភូតរូប ៤ វត្ថុរូប ៦ និងជីវិតិន្ទ្រិយ; ក៏នាមរូបនោះ លោកធ្វើជាឯកសេសន័យទុក យ៉ាងនេះថា “នាមផង រូបផង និងនាមរូបផង ឈ្មោះថា **នាមរូប**”។ នាមរូបនោះ គប្បីជ្រាបថា ជាបច្ច័យដល់សឡាយតនៈ ដែលលោកធ្វើជាឯកសេសន័យយ៉ាងនោះឯង ដោយលក្ខណៈយ៉ាងនេះថា “**ឆដ្ឋាយតនញ្ច សឡាយតនញ្ច សឡាយតនំ** = អាយតនៈទី ៦ ផង អាយតនៈ ៦ ផង ឈ្មោះថា **សឡាយតនៈ**” ; ព្រោះហេតុអ្វី ? ព្រោះក្នុងអរូបភព នាមតែម្យ៉ាងជាបច្ច័យ; ឯនាមនោះ ក៏ជាបច្ច័យដល់អាយតនៈទី ៦ ប៉ុណ្ណោះ; មិនជាបច្ច័យដល់អាយតនៈដទៃទេ ព្រោះក្នុងអព្យាកតវារៈ ព្រះមានព្រះភាគត្រាស់ថា “**នាមប្បច្ចយា ឆដ្ឋាយតនំ** = អាយតនៈទី ៦ កើតមាន ព្រោះ

នាមជាបច្ច័យ” ; ក៏នាមដែលទ្រង់សង្គ្រោះទុកក្នុងទីនេះ គប្បីជ្រាបថា ទ្រង់ចែកទុកក្នុងអព្យាកតវារៈ នោះឯង[៥១] ។

ក្នុងសេចក្តីនោះ បើមានអ្នក*សួរថា* ក៏សេចក្តីនេះនឹងគប្បីជ្រាបបានដូចម្តេចថា “នាមរូបជាបច្ច័យដល់សឡាយតនៈទាំងនុ៎ះ ?” ឆ្លើយថា ជ្រាបបាន ព្រោះកាលនាមរូបមានសឡាយតនៈ ក៏មាន; មែនពិត កាលនាម និងរូបនោះៗ មាន អាយតនៈនោះៗ ក៏មានដែរ, មិនមែនកើតមានដោយប្រការដទៃឡើយ; ក៏សឡាយតនៈនោះមាន ព្រោះភាវៈនៃនាមរូបនោះមាន នឹងជាក់ច្បាស់ក្នុងន័យរបស់បច្ច័យមែនពិត; ព្រោះហេតុដូច្នោះ ៖

នាមរូបណា ជាបច្ច័យដល់អាយតនៈណា
ក្នុងបដិសន្ធិកាល ឬក្នុងបវត្តិកាល និងជាបច្ច័យដោយ
ប្រការណា បណ្ឌិតគប្បីណែនាំដោយប្រការនោះចុះ៕

## សម្តែងអំពីនាមជាបច្ច័យដល់អាយតនៈ

បណ្តានាមរូបដែលជាបច្ច័យនោះ មានសេចក្តីអធិប្បាយដូច្នេះ ៖

សេចក្តីពិត ពោលដោយការកំណត់យ៉ាងទាប
នាមតែម្យ៉ាង ជាបច្ច័យ ៧ យ៉ាង ដល់អាយតនៈទី ៦
ក្នុងអរូបភព ទាំងក្នុងបដិសន្ធិកាល និងបវត្តិកាល ។

[៥១] អភិ. វិ. ។

នាមជាបច្ច័យដូចម្ដេច ? គឺក្នុងបដិសន្ធិកាល ពោលដោយការកំណត់យ៉ាងទាបជាមុនសិន នាមជាបច្ច័យ ៧ យ៉ាង ដល់អាយតនៈទី ៦ ដោយសហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ សម្បយុត្តប្បច្ច័យ វិបាកប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ; ម្យ៉ាងទៀត ក្នុងបដិសន្ធិកាលនេះ ក៏មានបច្ច័យសូម្បីដោយប្រការដទៃទៀត យ៉ាងនេះ គឺនាមខ្លះជាបច្ច័យ ដោយហេតុប្បច្ច័យ, នាមខ្លះ ជាបច្ច័យ ដោយអាហារប្បច្ច័យ; បណ្ឌិតគប្បីជ្រាបការកំណត់បច្ច័យយ៉ាងទាប និងយ៉ាងខ្ពស់ ដោយអំណាចនៃបច្ច័យ មានហេតុប្បច្ច័យជាដើមនោះចុះ ។

សូម្បីក្នុងបវត្តិកាល នាម គឺវិបាក ជាបច្ច័យដោយន័យដែលពោលមកហើយដូចគ្នា; តែនាមក្រៅពីនេះ ដែលមិនមែនវិបាក ជាបច្ច័យ ៦ យ៉ាង កំណត់យ៉ាងទាប វៀរវិបាកប្បច្ច័យ ក្នុងបណ្ដាបច្ច័យទាំងឡាយ តាមដែលពោលហើយ; ក៏ក្នុងបវត្តិកាលនោះ ក៏មានបច្ច័យសូម្បីដោយប្រការដទៃយ៉ាងនេះ គឺនាមខ្លះ ជាបច្ច័យដោយហេតុប្បច្ច័យ, នាមខ្លះ ជាបច្ច័យដោយអាហារប្បច្ច័យ; បណ្ឌិតគប្បីកំណត់យ៉ាងខ្ពស់ និងយ៉ាងទាប ដោយអំណាចនៃបច្ច័យមានហេតុប្បច្ច័យជាដើម ។

**សូម្បីក្នុងភពដទៃ នាមក៏ជាបច្ច័យដល់អាយតនៈ**
**ទី ៦ ក្នុងបដិសន្ធិកាល ក៏យ៉ាងនោះដែរ និងនាមនោះ**
**នៅជាបច្ច័យដោយអាការៈ ៦ យ៉ាង ដល់អាយតនៈ**
**ទាំងឡាយក្រៅពីអាយតនៈទី ៦ នេះ ។**

ពិតមែន សូម្បីក្នុងភពដទៃក្រៅអំពីរូបភព គឺក្នុងបញ្ចវោការភព នាមដែលជាវិបាកនោះ ជាសហាយរបស់ហទយវត្ថុ ជាបច្ច័យ ៧ យ៉ាង ដល់អាយតនៈទី ៦ គឺមនាយតនៈ ដោយកំណត់យ៉ាងទាបដូចពោលទុកក្នុងអរូបភូមិនោះឯង; ម្យ៉ាងទៀត

នាមនោះជាសហាយនឹងមហាភូតរូប ៤ ជាបច្ច័យដល់អាយតនៈ ៥ មានចក្ខាយតនៈជាដើម ក្រៅអំពីអាយតនៈទី ៦ នេះ ដោយអាការ ៦ យ៉ាង ដោយអំណាចនៃសហជាតប្បច្ច័យ និស្សយប្បច្ច័យ វិបាកប្បច្ច័យ វិប្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ; ក៏ក្នុងបដិសន្ធិកាលនេះ មានបច្ច័យសូម្បីដទៃទៀត យ៉ាងនេះ គឺនាមខ្លះជាបច្ច័យ ដោយហេតុប្បច្ច័យ, នាមខ្លះ ជាបច្ច័យដោយអាហារប្បច្ច័យ; បណ្ឌិតគប្បីជ្រាបការកំណត់យ៉ាងខ្ពស់ និងយ៉ាងទាប ដោយអំណាចនៃហេតុប្បច្ច័យជាដើមនោះ ។

**សូម្បីក្នុងបវត្តិកាល នាមដែលជាវិបាក ក៏ជាបច្ច័យ**
**ដល់អាយតនៈដែលជាវិបាកដូចគ្នា នាមដែលមិនមែន**
**វិបាក ក៏ជាបច្ច័យ ៦ យ៉ាង ដល់អាយតនៈ ទី ៦ ដែល**
**មិនមែនជាវិបាក ។**

ពិតមែន សូម្បីក្នុងបវត្តិកាល ក្នុងបញ្ចវោការភព នាមដែលជាវិបាក ក៏ជាបច្ច័យដល់វិបាក គឺអាយតនៈទី ៦ ដោយកំណត់យ៉ាងទាប ៧ បច្ច័យ ដូចក្នុងបដិសន្ធិកាលនោះដែរ; ចំណែកនាមដែលមិនមែនវិបាក ជាបច្ច័យដល់នាមដែលមិនមែនវិបាក គឺអាយតនៈទី ៦ ដោយកំណត់យ៉ាងទាប ៦ យ៉ាង ដោយនាំវិបាកប្បច្ច័យ ចេញពីបច្ច័យទាំង ៧ នោះ និងក្នុងបវត្តិកាលនេះ ក៏គប្បីជ្រាបការកំណត់យ៉ាងខ្ពស់ និងយ៉ាងទាប ដោយន័យដែលពោលហើយដូចគ្នា ។

**ក្នុងបវត្តិកាលនោះៗ ឯង នាមដែលជាវិបាក ក៏ជា**
**បច្ច័យ ៤ យ៉ាង ដល់អាយតនៈ ៥ ដ៏សេស សូម្បីនាម**
**ដែលមិនមែនវិបាក ក៏ទ្រង់ប្រកាសទុកយ៉ាងនោះដែរ។**

ពិតមែន ក្នុងបវត្តិកាលនោះឯង នាមដែលជាវិបាកអាស្រ័យវត្ថុ មានចក្ខុ-ប្បសាទជាដើមខ្លះ វត្ថុក្រៅពីនេះខ្លះ ជាបច្ច័យ ៤ យ៉ាង ដល់អាយតនៈដ៏សេស ៥ មានចក្ខាយតនៈជាដើម ដោយបច្ឆាជាតប្បច្ច័យ វិប្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ អវិគត-ប្បច្ច័យ; សូម្បីនាមដែលមិនមែនវិបាក ក៏ទ្រង់ប្រកាសដូចនាមដែលជាវិបាកនោះដែរ; ព្រោះហេតុដូច្នោះ សូម្បីនាមដែលផ្សេងដោយកុសលជាដើម ក៏គប្បីជ្រាបថា ជាបច្ច័យ ៤ យ៉ាង ដល់អាយតនៈទាំង ៥ នោះ; នាមតែម្យ៉ាង ជាបច្ច័យដល់អាយតនៈណាៗ និងដោយប្រការណា ក្នុងបដិសន្ធិកាល ឬក្នុងបវត្តិកាល, គប្បីជ្រាបអាយតនៈនោះៗ ដោយប្រការនោះៗ យ៉ាងនេះចុះ ៕

## សម្តែងអំពីរូបជាបច្ច័យដល់អាយតនៈ

**ក៏ក្នុងអាយតនៈទាំងនេះ រូបមិនជាបច្ច័យ ដល់អាយតនៈសូម្បីតែមួយក្នុងអរូបភព តែជាបច្ច័យក្នុងភពដែលមានខន្ធ ៥; ពោលអំពីរូប និងវត្ថុរូប ក្នុងបដិសន្ធិកាល ជាបច្ច័យ ៦ យ៉ាងដល់អាយតនៈទី ៦ ភូតរូបទាំងឡាយជាបច្ច័យ ៤ យ៉ាង ដល់អាយតនៈ ៥ ដោយមិនខុសប្លែកគ្នា ។**

មែនពិត ពោលអំពីរូប វត្ថុរូប ក្នុងបដិសន្ធិកាល ជាបច្ច័យដល់អាយតនៈទី ៦ គឺមនាយតនៈ ៦ យ៉ាង ដោយសហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ វិប្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ និងអវិគតប្បច្ច័យ។ ចំណែកភូតរូប ៤ ជាបច្ច័យ ៤ យ៉ាង សូម្បីដល់អាយតនៈទាំង ៥ មានចក្ខាយតនៈជាដើម ដោយសហជាតប្បច្ច័យ

និស្សយប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ ដោយអំណាចនៃអាយតនៈដែលកើតឡើងនោះៗ ទាំងក្នុងបដិសន្ធិកាល ទាំងក្នុងបវត្តិកាល ដោយមិនខុសប្លែកគ្នា ។

**ជីវិតរូបជាបច្ច័យ ៣ យ៉ាង ដល់វត្ថុទាំងនេះ និង អាហាររូប ក៏ជាបច្ច័យ ៣ យ៉ាង ដល់វត្ថុទាំងនោះ ក្នុងបវត្តិកាល អាយតនៈទាំង ៥ នោះ ជាបច្ច័យ ៦ យ៉ាង ដល់អាយតនៈទី ៦ វត្ថុរូប ជាបច្ច័យ ៥ យ៉ាង ដល់អាយតនៈទី ៦ នោះ ។**

ក៏ជីវិតរូបក្នុងបដិសន្ធិ និងបវត្តិកាល ជាបច្ច័យ ៣ យ៉ាង ដល់វត្ថុទាំង ៥ មានចក្ខុវត្ថុជាដើម ដោយអំណាចនៃអត្ថិប្បច្ច័យ អវិគតប្បច្ច័យ និងឥន្ទ្រិយប្បច្ច័យ ។

ក៏ពាក្យថា **និងអាហារ** គឺអាហារក៏ជាបច្ច័យ ៣ យ៉ាងដែរ ដោយអំណាចនៃអត្ថិប្បច្ច័យ អវិគតប្បច្ច័យ អាហារប្បច្ច័យ; ក៏អាហារនោះឯង ជាបច្ច័យក្នុងបវត្តិ-កាលប៉ុណ្ណោះ, មិនមែនក្នុងបដិសន្ធិកាល ក្នុងពេលដែលមានអាហារជ្រួតជ្រាបរបស់សត្វអ្នកមានអាហារចិញ្ចឹមជីវិតទាំងនោះ;ម្យ៉ាងទៀត អាយតនៈ ៥ មានចក្ខា-យតនៈជាដើមនោះ ជាបច្ច័យក្នុងបវត្តិកាល មិនមែនក្នុងបដិសន្ធិកាល ដល់មនាយតនៈដែលជាអាយតនៈទី ៦ ពោលគឺចក្ខុវិញ្ញាណ សោតវិញ្ញាណ ឃានវិញ្ញាណ ជិវ្ហាវិញ្ញាណ និងកាយវិញ្ញាណ ដោយអាការៈ ៦ យ៉ាង ដោយអំណាចនៃនិស្សយប្បច្ច័យ បុរេជាត-ប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ វិប្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ និងអវិគតប្បច្ច័យ; ចំណែកវត្ថុរូប ជាបច្ច័យ ៥ យ៉ាង ក្នុងបវត្តិកាល, មិនមែនក្នុងបដិសន្ធិកាល ដល់មនាយតនៈដ៏សេស លើកវៀរវិញ្ញាណ ៥ នោះឯង ដោយអំណាចនៃនិស្សយប្បច្ច័យ បុរេជាត-

ប្បច្ច័យ វិប្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ និងអវិគតប្បច្ច័យ; រូបតែម្យ៉ាង ជាបច្ច័យដល់អាយតនៈណាៗ ក្នុងបដិសន្ធិកាល ឬក្នុងបវត្តិកាល, ក៏នឹងអាចមានដោយប្រការណា, គប្បីជ្រាបដោយប្រការនោះ យ៉ាងនេះចុះ ៕

## សម្តែងអំពីនាមរូបជាបច្ច័យដល់អាយតនៈ

**ក៏នាមរូបទាំង ២ ណា ជាបច្ច័យដល់អាយតនៈ**
**ណា និងដោយប្រការណា បណ្ឌិតគប្បីជ្រាបសូម្បី**
**នាមរូបទាំងនោះឯង ដោយប្រការនោះក្នុងទីទាំងពួង។**

គប្បីជ្រាបដូចម្តេច ? គឺខាងដើម នាមរូប ពោលគឺនាមក្ខន្ធ ៣ និងវត្ថុរូប ក្នុងបដិសន្ធិកាល បញ្ចវោការភព ជាបច្ច័យដល់សឡាយតនៈ ដោយសហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ សម្បយុត្តប្បច្ច័យ វិប្បយុត្តប្បច្ច័យ វិបាកប្បច្ច័យ អត្ថិប្បច្ច័យ និងអវិគតប្បច្ច័យជាដើម ។

ពាក្យដែលមកពោលនេះ ល្មមជាប្រធានក្នុងបទថា **នាមរូបជាបច្ច័យដល់អាយតនៈ** នេះ; តែបុគ្គលអ្នកឆ្លាតអាចប្រកបសេចក្តីទាំងអស់ ដោយទំនងនៃពាក្យដែលពោលហើយ ព្រោះហេតុដូច្នោះ ទើបខ្ញុំមិនសម្តែងសេចក្តីពិស្តារទុកក្នុងសេចក្តីនេះ ដោយប្រការដូច្នេះឯង ៕

**ចប់និទ្ទេសនៃសឡាយតនៈកើតមាន**
**ព្រោះនាមរូបជាបច្ច័យ**

## សម្តែងអំពីផស្សនិទ្ទេស

គប្បីជ្រាបការវិនិច្ឆ័យ ក្នុងនិទ្ទេសនៃផស្សៈកើតមាន ព្រោះសឡាយតនៈជាបច្ច័យតទៅ ៖

**ពោលដោយសង្ខេប ផស្សៈមាន ៦ យ៉ាងប៉ុណ្ណោះ មានចក្ខុសម្ផស្ស ជាដើម តែដោយពិស្តារ ផស្សៈទាំងនោះ ក៏មាន ៣២ យ៉ាងដូចវិញ្ញាណដែរ។**

ពិតមែន ពោលដោយសង្ខេប ផស្សៈមានត្រឹម ៦ យ៉ាងប៉ុណ្ណោះ មានពាក្យជាអាទិ៍ថា "**ចក្ខុសម្ផស្សោ** = ចក្ខុសម្ផស្ស" មកហើយក្នុងព្រះបាលី ។ តែដោយពិស្តារ សូម្បីផស្សៈទាំងអស់មាន ៣២ យ៉ាង ដូចវិញ្ញាណតាមដែលពោលហើយ ព្រោះសង្ខារជាបច្ច័យយ៉ាងនេះ គឺផស្សៈទាំងឡាយ មានចក្ខុសម្ផស្សជាដើម ដែលជា កុសលវិបាក ៥; ជាអកុសលវិបាក ៥; ព្រោះហេតុដូច្នោះ ទើបរួមជា ១០, ផស្សៈ ដ៏សេស ២២ បានដល់ ផស្សៈដែលសម្បយុត្តដោយវិបាកវិញ្ញាណ ដែលជាលោកិយ ២២ នោះឯង ៕

## សម្តែងអំពីសឡាយតនៈជាបច្ច័យដល់ផស្សៈ

ក៏ក្នុងសឡាយតនៈជាបច្ច័យដល់ផស្សៈទាំង ៣២ នោះ ៖

**បណ្ឌិតទាំងឡាយ ប្រាថ្នាអាយតនៈខាងក្នុង**
**មានចក្ខាយតនៈជាដើម រួមនឹងអាយតនៈ ទី ៦ សូម្បី**
**ជាមួយអាយតនៈខាងក្រៅ ៦ ឈ្មោះថា សឡាយតនៈ។**

ក្នុងព្រះបាលីថា "ផស្សៈកើតមាន ព្រោះសឡាយតនៈជាបច្ច័យ" នោះ

មានអធិប្បាយថា បណ្ឌិតទាំងឡាយណារមែងសម្តែងបច្ច័យ និងបច្ចយុប្បន្នៈ (ធម៌ដែលកើតព្រោះបច្ច័យ) ដែលរាប់បញ្ចូលដោយសន្តតិតែមួយប៉ុណ្ណោះថា "នេះជាកថាសម្តែងសេចក្តីប្រព្រឹត្តទៅនៃឧបាទិន្នកសង្ខារ" បណ្ឌិតទាំងនោះ រមែងប្រាថ្នាអាយតនៈខាងក្នុង មានចក្ខាយតនៈជាដើម ជាមួយនឹងអាយតនៈទី ៦ ថា ឈ្មោះថា **សឡាយតនៈ** ព្រោះការធ្វើសរុបេកសេសន័យ ដោយឯកទ្ទេសថា អាយតនៈទី ៦ ក្នុងអរូបភព និងអាយតនៈ ៦ ដោយរួមក្នុងទីដទៃទាំងអស់ ជាបច្ច័យដល់ផស្សៈ ដោយទំនងនៃព្រះបាលីថា "ផស្សៈកើតមាន ព្រោះអាយតនៈទី ៦ ជាបច្ច័យ" ដូច្នេះ; មែនពិត អាយតនៈនោះ ព្រោះធ្វើបទទាំងនេះ ឱ្យជាឯកសេសសមាសថា អាយតនៈទី ៦ នោះផង សឡាយតនៈផង រមែងដល់ការរាប់ថា "**សឡាយតនៈ**" ; ចំណែកបណ្ឌិតទាំងឡាយណា រមែងសម្តែងបច្ចយុប្បន្នធម៌ (ធម៌ដែលកើតអំពីបច្ច័យ) ជាធម៌រាប់បញ្ចូលដោយសន្តតិតែមួយ, តែបច្ច័យដែលមានសន្តានផ្សេងគ្នា ក៏មានបណ្ឌិតទាំងនោះ កាលសម្តែងអាយតនៈទាំងអស់ ដែលជាបច្ច័យដល់ផស្សៈនោះ ក៏កំណត់យកនូវអាយតនៈសូម្បីខាងក្រៅ រមែងប្រាថ្នាអាយតនៈខាងក្នុងនោះឯង ជាមួយនឹងអាយតនៈទី ៦ ព្រមជាមួយនឹងរូបាយតនៈជាដើម សូម្បីជាអាយតនៈខាងក្រៅថា ឈ្មោះថា **សឡាយតនៈ** ព្រោះសូម្បីអាយតនៈខាងក្រៅនោះ រមែងដល់ការរាប់ថា ជាសឡាយតនៈដូចគ្នា ព្រោះលោកធ្វើឯកសេសសមាសនៃបទទាំងនេះថា អាយតនៈទី ៦ ផង សឡាយតនៈផង ឈ្មោះថា **សឡាយតនៈ** ដូច្នេះ ។

ក្នុងសេចក្តីនេះ បើមានអ្នក**សួរថា** ផស្សៈមួយ រមែងមិនកើតអំពីអាយតនៈទាំងអស់ សូម្បីផស្សៈទាំងអស់ ក៏មិនកើតអំពីអាយតនៈមួយ, ក៏ផស្សៈនេះ ព្រះ

មានព្រះភាគទ្រង់ត្រាស់ថា មានតែមួយប៉ុណ្ណោះ ដោយព្រះតម្រាស់ថា **“សឡា-យតនប្បច្ចយា ផស្សោ** = ផស្សៈកើតមាន ព្រោះសឡាយតនៈជាបច្ច័យ” ព្រោះហេតុអ្វី ?

ក្នុងបញ្ហាកម្មនេះ មានវិសជ្ជនាដូច្នេះ ៖ សេចក្ដីនេះជាការពិត; ផស្សៈមួយ រមែងមិនកើតអំពីអាយតនៈទាំងអស់ ឬផស្សៈទាំងអស់ រមែងមិនកើតអំពីអាយតនៈមួយ, ក៏ប៉ុន្តែថា ផស្សៈមួយរមែងកើតអំពីអាយតនៈច្រើនយ៉ាង, ដូចជាចក្ខុសម្ផស្ស កើតអំពីចក្ខាយតនៈ រូបាយតនៈ មនាយតនៈ ពោលគឺចក្ខុវិញ្ញាណ និងអំពីធម្មាយតនៈដ៏សេស ដែលសម្បយុត្តជាមួយគ្នា យ៉ាងណា, ក្នុងផស្សៈទាំងពួង ក៏ដូច្នោះដែរ គប្បីប្រកបតាមសមគួរ ដោយប្រការដូច្នេះ ។

ក៏ព្រោះហេតុនោះនុ៎ះឯង ៖

> **ផស្សៈនេះ ព្រះមានព្រះភាគជាតាទិបុគ្គល (អ្នកនឹងធឹង) ទើបទ្រង់សម្ដែងថា ផស្សៈមួយមានអាយតនៈជាអនេក (ច្រើនយ៉ាង) ជាដែនកើត តែដោយនិទ្ទេសជាឯកវចនៈក្នុងបទថា “ផស្សោ សឡាយតនប្បច្ចយា” នេះ ។**

ពាក្យថា **និទ្ទេសជាឯកវចនៈ** នោះ សេចក្ដីថា ព្រះមានព្រះភាគជាតាទិ-បុគ្គល ទ្រង់សម្ដែងថា “ផស្សៈមួយរមែងកើតអំពីអាយតនៈច្រើនយ៉ាង” តែដោយនិទ្ទេសជាឯកវចនៈនេះថា **សឡាយតនប្បច្ចយា ផស្សោ** = ផស្សៈកើតមាន ព្រោះ សឡាយតនៈជាបច្ច័យ ។ ចំណែកក្នុងអាយតនៈទាំងឡាយ ( ត្រាស់ថា) ៖

**អាយតនៈខាងក្នុង ៥ ជាបច្ច័យ ៦ យ៉ាង តអំពីនោះ អាយតនៈមួយ (មនាយតនៈ) ជាបច្ច័យ ៩ យ៉ាង និងគប្បីពន្យល់អាយតនៈខាងក្រៅទាំងឡាយ ក្នុងសេចក្តីជាបច្ច័យដល់ផស្សៈនេះ តាមដែលកើតឡើង ។**

ក្នុងគាថានោះ មានអធិប្បាយដូច្នេះ ៖

អាយតនៈខាងក្នុង មានចក្ខាយតនៈជាដើម ជាបច្ច័យ ៦ យ៉ាង ដល់ផស្សៈ ៥ យ៉ាង ដោយអំណាចនៃនិស្សយប្បច្ច័យ បុរេជាតប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ វិប្បយុត្ត-ប្បច្ច័យ អត្ថិប្បច្ច័យ និងអវិគតប្បច្ច័យដល់ផស្សៈ ៥ យ៉ាង ដែលផ្សេងដោយចក្ខុ-សម្ផស្សជាដើម។ ខាងមុខអំពីនោះ អាយតនៈមួយ គឺមនាយតនៈដែលជាវិបាកជាបច្ច័យ ៩ យ៉ាង ដល់មនោសម្ផស្សដែលជាវិបាក ដោយប្រភេទជាអនេក ដោយអំណាចនៃសហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ វិបាកប្បច្ច័យ អាហារ-ប្បច្ច័យ ឥន្ទ្រិយប្បច្ច័យ សម្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ និងអវិគតប្បច្ច័យ; តែគប្បីអធិប្បាយអាយតនៈខាងក្រៅ ៦ ក្នុងសេចក្តីជាបច្ច័យដល់ផស្សៈនេះ តាមដែលកើតឡើង យ៉ាងនេះថា បណ្តាអាយតនៈខាងក្រៅទាំងឡាយ រូបាយតនៈជាបច្ច័យដល់ចក្ខុសម្ផស្ស ដោយអំណាចនៃអារម្មណប្បច្ច័យ បុរេជាតប្បច្ច័យ អត្ថិប្បច្ច័យ និងអវិគតប្បច្ច័យ; សទ្ទាយតនៈជាដើម ក៏ជាបច្ច័យដល់សោតសម្ផស្សជាដើម យ៉ាងនោះដែរ; តែថា អាយតនៈខាងក្រៅ និងធម្មាយតនៈទាំងនោះ ជាបច្ច័យដល់មនោ-សម្ផស្សដោយប្រការនោះ និងដោយត្រឹមតែជាអារម្មណប្បច្ច័យប៉ុណ្ណោះ មានប្រការដូច្នេះឯង ៕

## សម្តែងអំពីវេទនានិទ្ទេស

គប្បីជ្រាបការវិនិច្ឆ័យនិទ្ទេសវេទនាកើតមាន ព្រោះផស្សៈជាបច្ច័យតទៅ ៖

**ពោលអំពីទ្វារ ព្រះមានព្រះភាគត្រាស់វេទនាទុក ៦ យ៉ាងប៉ុណ្ណោះ មានវេទនាកើតអំពីចក្ខុសម្ផស្សជាដើម តែដោយប្រភេទនៃវេទនាទាំងនោះ ត្រាស់ទុក ៨៩ យ៉ាង ។**

ពិតមែន ពោលដោយទ្វារ វេទនាមាន ៦ យ៉ាងប៉ុណ្ណោះ មានវេទនាកើតអំពីចក្ខុសម្ផស្សជាដើមនេះ ត្រាស់ទុកក្នុងបាលីដោយន័យមានជាអាទិ៍ថា **“ចក្ខុសម្ផស្សជា វេទនា** = វេទនាកើតអំពីចក្ខុសម្ផស្ស” ; តែដោយប្រភេទនៃវេទនាទាំងនោះ គប្បីជ្រាបថា មាន ៨៩ ព្រោះសម្បយុត្តជាមួយនឹងចិត្ត ៨៩ ដួងនោះឯង ។

**ក៏បណ្តាវេទនាទាំង ៨៩ ប្រភេទនេះ ត្រាស់វេទនាដែលប្រកបដោយវិបាកចិត្ត ៣២ ដួងប៉ុណ្ណោះ ទ្រង់បំណងយកក្នុងបទថា “ផស្សប្បច្ចយា វេទនា” នេះ។**

**ផស្សៈជាបច្ច័យ ៨ យ៉ាង ដល់វេទនា ៥ ក្នុងបញ្ចទ្វារនោះ ជាបច្ច័យតែម្យ៉ាង ដល់វេទនាដ៏សេស សូម្បីក្នុងមនោទ្វារ ផស្សៈនេះ ក៏ជាបច្ច័យយ៉ាងនោះដែរ ។**

ពិតមែន ក្នុងបញ្ចទ្វារនោះ ផស្សៈកើតអំពីចក្ខុសម្ផស្សជាដើម ជាបច្ច័យ ៨ យ៉ាង ដល់វេទនា ៥ ដែលមានចក្ខុប្រសាទជាដើម ជាវត្ថុដែលកើតដោយអំណាចនៃសហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ វិបាកប្បច្ច័យ អាហារប្បច្ច័យ សម្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ និងអវិគតប្បច្ច័យ; ក៏ផស្សៈមានចក្ខុសម្ផស្សជាដើម ជាបច្ច័យតែម្យ៉ាងប៉ុណ្ណោះ ដោយអំណាចនៃឧបនិស្សយប្បច្ច័យដល់កាមាវចរ-

វិបាក វេទនាដ៏សេស ដែលប្រព្រឹត្តទៅដោយអំណាចនៃសម្បដិច្ឆន្នៈ សន្តីរណៈ និងតទារម្មណ៍ក្នុងទ្វារនីមួយៗ គ្រប់ៗ ទ្វារ ។

បទថា **សូម្បីក្នុងមនោទ្វារ ផស្សៈនោះ ក៏ជាបច្ច័យដូចយ៉ាងនោះដែរ** បានសេចក្តីថា ផស្សៈនោះ គឺសហជាតមនោសម្ផស្ស ជាបច្ច័យ ៨ យ៉ាងដូចគ្នានោះដែរ និងដល់កាមាវចរវិបាក វេទនាដែលប្រព្រឹត្តទៅដោយអំណាចនៃតទារម្មណ៍សូម្បីក្នុងមនោទ្វារ; ក៏ជាបច្ច័យសូម្បីដល់វិបាកវេទនាក្នុងភូមិ ៣ ដែលប្រព្រឹត្តទៅដោយអំណាចនៃបដិសន្ធិ ភវង្គ និងចុតិ។ ម្យ៉ាងទៀត មនោសម្ផស្សដែលសម្បយុត្តដោយអាវជ្ជនៈ ជាបច្ច័យតែម្យ៉ាង ដោយអំណាចនៃឧបនិស្សយប្បច្ច័យ ក្នុងមនោទ្វារ ដល់កាមាវចរវេទនា ដែលប្រព្រឹត្តទៅដោយអំណាចនៃតទារម្មណ៍ ក្នុងមនោទ្វារនោះ ៕

ចប់និទ្ទេសនៃវេទនាកើតមាន ព្រោះផស្សៈជាបច្ច័យ

## សម្តែងអំពីតណ្ហានិទ្ទេស

គប្បីជ្រាបវិនិច្ឆ័យនិទ្ទេសនៃតណ្ហាកើតមាន ព្រោះវេទនាជាបច្ច័យតទៅ ៖

**តណ្ហា ៦ យ៉ាង ព្រះអង្គទ្រង់សម្តែងទុកក្នុងនិទ្ទេសនេះ ដោយសេចក្តីផ្សេងនៃរូបតណ្ហាជាដើម ក្នុងតណ្ហាទាំង ៦ នោះ ចំពោះតណ្ហានីមួយៗ ត្រាស់ទុក ៣ យ៉ាង ដោយអាការដែលប្រព្រឹត្តទៅ ។**

ក៏ក្នុងនិទ្ទេសតណ្ហាកើតមាន ព្រោះវេទនាជាបច្ច័យនេះ មានអធិប្បាយថា តណ្ហាទាំង ៦ យ៉ាងនេះ ព្រះអង្គទ្រង់សម្តែងហើយ គឺប្រកាសហើយ ត្រាស់ហើយ ដោយអំណាចនៃឈ្មោះ ពោលគឺអារម្មណ៍ថា **"រូបតណ្ហា សទ្ទតណ្ហា គន្ធតណ្ហា**

**រសតណ្ហា ផោដ្ឋព្វតណ្ហា ធម្មតណ្ហា”** ដូចបុត្រដែលគេប្រកាសឈ្មោះតាមបិតាថា “**សេដ្ឋិបុត្តោ** = បុត្រសេដ្ឋី, **ព្រាហ្មណបុត្តោ** = បុត្រព្រាហ្មណ៍” ។ បណ្ដាតណ្ហាទាំង ៦ នោះ គប្បីជ្រាបអត្ថនៃពាក្យដោយន័យនេះថា “**រូបេ តណ្ហា > រូបតណ្ហា** = តណ្ហាក្នុងរូប ឈ្មោះថា ***រូបតណ្ហា***” ៕

## **សម្ដែងអំពីតណ្ហា ១៨ យ៉ាង** (ជាតណ្ហា ១០៨)

ក៏បណ្ដាតណ្ហាទាំងនោះ តណ្ហានីមួយៗ ត្រាស់ទុក ៣ យ៉ាងនេះ **គឺកាម-តណ្ហា *ភវតណ្ហា* និង*វិភវតណ្ហា*** តាមអាការដែលប្រព្រឹត្តទៅ; ពិតមែន ក្នុងកាលណារូបតណ្ហានោះឯង ត្រេកអរក្នុងរូបារម្មណ៍ដែលមកកាន់គន្លងចក្ខុ ដោយអំណាចនៃសេចក្ដីត្រេកអរក្នុងកាម ហើយប្រព្រឹត្តទៅ, ក្នុងកាលនោះ ឈ្មោះថា **កាមតណ្ហា**; ក្នុងកាលណា រូបតណ្ហាប្រព្រឹត្តទៅព្រមដោយទិដ្ឋិ ដែលដំណើរទៅថា “រូបារម្មណ៍នោះនុ៎ះឯង ទៀង ឋិតថេរ” , ក្នុងកាលនោះ ឈ្មោះថា ***ភវតណ្ហា***; ព្រោះថា រាគៈកើតរួមជាមួយនឹងសស្សតទិដ្ឋិ ត្រាស់ហៅថា *ភវតណ្ហា*; តែក្នុងកាលណា រូបតណ្ហានោះ កើតព្រមជាមួយនឹងឧច្ឆេទទិដ្ឋិដែលប្រព្រឹត្តទៅថា “រូបារម្មណ៍នោះនុ៎ះឯង ដាច់សូន្យ រមែងវិនាស” , ក្នុងកាលនោះ ឈ្មោះថា ***វិភវតណ្ហា***; ព្រោះថា រាគៈកើតរួមជាមួយនឹងឧច្ឆេទទិដ្ឋិ ត្រាស់ហៅថា *វិភវតណ្ហា* ។ សូម្បីក្នុងសទ្ទតណ្ហាជាដើម ក៏ន័យនេះដែរ ព្រោះហេតុដូច្នោះ តណ្ហាទាំងនេះ ទើបរួមជា ១៨ ។

តណ្ហាទាំងនោះ រូបខាងក្នុងជាដើមមាន ១៨ យ៉ាង, រូបខាងក្រៅក៏មាន ១៨ យ៉ាង ព្រោះហេតុដូច្នោះ **ទើបជាតណ្ហា ៣៦ យ៉ាង**; តណ្ហាទាំងនោះ ជាអតីតៈ ៣៦, ជាអនាគត ៣៦ និងបច្ចុប្បន្ន ៣៦ រួមជាតណ្ហា ១០៨ ដោយប្រការដូច្នេះ ។

ក៏តណ្ហាទាំង ១០៨ នោះ កាលបំប្រួញចុះមក គប្បីជ្រាបថា **ជាតណ្ហា ៦** ដោយអំណាចនៃអារម្មណ៍មានរូបជាដើម **ឬជាតណ្ហា ៣ ប៉ុណ្ណោះ** ដោយអំណាចនៃកាមតណ្ហាជាដើម ។

ក៏ព្រោះសត្វទាំងនោះ ត្រេកអរចំពោះវេទនាដែលកើតដោយអំណាចនៃអារម្មណ៍ មានរូបារម្មណ៍ជាដើម ទើបធ្វើសក្ការៈធំដល់ចិត្រករ (ជាងគំនូរ) **គន្ធព្វៈ** (អ្នកតន្ត្រី) អ្នកតាក់តែងដោយរបស់ក្រអូប អ្នកគ្រួជាងតម្បាញ និងពេទ្យ អ្នកធ្វើវិធីផ្សេងៗ ឱ្យកើតការត្រេកអរជាដើម ដែលឱ្យនូវអារម្មណ៍មានរូបារម្មណ៍ជាដើម ដោយប្រកាន់វេទនាថាជារបស់យើង ដូចបុគ្គលអ្នកស្រឡាញ់ជាប់ជំពាក់ក្នុងបុត្រ ដោយសេចក្តីប្រកាន់បុត្រថា "របស់យើង" ក៏ធ្វើសក្ការៈធំដល់មេដោះ; ព្រោះហេតុដូច្នោះ សូម្បីតណ្ហាទាំងអស់នេះ គប្បីជ្រាបថា កើតមាន ព្រោះវេទនាជាបច្ច័យមែនពិត ៕

## សម្តែងអំពីសុខវេទនាដែលមានវិបាកជាបច្ច័យ

ព្រោះតែក្នុងនិទ្ទេសថា "**វេទនាបច្ចយា តណ្ហា**" នេះ ទ្រង់បំណងយកសុខវេទនាដែលជាវិបាកតែម្យ៉ាងប៉ុណ្ណោះ ព្រោះហេតុដូច្នោះ វេទនានេះទើបជាបច្ច័យតែម្យ៉ាងប៉ុណ្ណោះ ដល់តណ្ហា ។

ពាក្យថា ជាបច្ច័យតែម្យ៉ាង គឺជាបច្ច័យដោយឧបនិស្សយប្បច្ច័យ ៕

## សម្តែងអំពីវេទនា ៣ ជាបច្ច័យ

ម្យ៉ាងទៀត ព្រោះថា៖

មនុស្សមានទុក្ខ រមែងប្រាថ្នាសុខ មនុស្សមានសុខ ក៏រមែងប្រាថ្នាសុខឱ្យក្រៃលែងឡើងទៅទៀត; ឯឧបេក្ខាត្រាស់ថា សុខនុ៎ះឯង ព្រោះជាធម៌ស្ងប់ ។

ព្រោះហេតុដូច្នោះ វេទនាសូម្បីទាំង ៣ ក៏ជា
បច្ច័យដល់តណ្ហា ទើបព្រះមហាឥសីត្រាស់ថា តណ្ហា
កើតមាន ព្រោះវេទនាជាបច្ច័យ ។

ម្យ៉ាងទៀត ព្រោះវៀរអនុស័យចេញហើយ តណ្ហារមែងមិនកើតព្រោះវេទនាជាបច្ច័យ ព្រោះហេតុនោះ តណ្ហានោះទើបមិនមានដល់ព្រាហ្មណ៍ ដែលមានព្រហ្មចរិយៈចប់រួចរាល់ហើយ ៕

ចប់និទ្ទេសនៃតណ្ហាកើតមាន ព្រោះវេទនាជាបច្ច័យ

## សម្តែងអំពីឧបាទាននិទ្ទេស

គប្បីជ្រាបវិនិច្ឆ័យនិទ្ទេសនៃឧបាទានកើតមាន ព្រោះតណ្ហាជាបច្ច័យតទៅ៖

បណ្ឌិតគប្បីពន្យល់ឧបាទានទាំង ៤ នោះ ដោយការ
ចែក ដោយអត្ថ ដោយសង្ខេប ដោយធម៌ពិស្តារ និង
ដោយលំដាប់ ។

ពិតមែន ក្នុងព្រះបាលីទ្រង់លើកឧបាទានទាំង ៤ នេះឡើង ដោយព្រះតម្រាស់ដែលត្រាស់ថា ពាក្យថា **ឧបាទាន** បានដល់ កាមុបាទាន ទិដ្ឋុបាទាន សីលព្វតុបាទាន និងអត្តវាទុបាទាន ៕

## សម្តែងអំពីការចែកដោយអត្ថ

ការចែកដោយអត្ថនៃឧបាទានទាំង ៤ នោះ ដូច្នេះ ៖

ធម៌ដែលឈ្មោះថា **កាមុបាទាន** ព្រោះអត្ថថា ប្រកាន់មាំក្នុងកាម ពោលគឺវត្ថុកាម ។ ម្យ៉ាងទៀត កាមនោះផង ជាឧបាទានផង ព្រោះហេតុដូច្នោះ ទើបឈ្មោះថា **កាមុបាទាន** ។

ពាក្យថា **ឧបាទាន** បានដល់ ការប្រកាន់មាំ; ព្រោះ**ឧបសព្ទ**ក្នុងពាក្យថា ឧបាទាននេះ មានអត្ថថា **មាំ** ដូចក្នុងសព្ទមានពាក្យថា **ឧបាយាសះ** (សេចក្តីចង្អៀតចង្អល់ចិត្ត); **ឧបកដ្ឋះ** (វេលាជិតចូលមកដល់ហើយ) ជាដើម។ ម្យ៉ាងទៀត ទិដ្ឋិនោះផង ជាឧបាទានផង ទើបឈ្មោះថា **ទិដ្ឋុបាទាន**; ម្យ៉ាងវិញទៀត ក៏ឈ្មោះថា **ទិដ្ឋុបាទាន** ព្រោះអត្ថថា ប្រកាន់មាំក្នុងទិដ្ឋិ; ព្រោះទិដ្ឋិក្រោយ រមែងប្រកាន់មាំជាងទិដ្ឋិមុនៗ ដូចក្នុងប្រយោគមានជាអាទិ៍ថា "អត្តា និងលោកទៀង"។ ម្យ៉ាងទៀត ក៏ឈ្មោះថា **សីលព្វតុបាទាន** ព្រោះអត្ថថា ប្រកាន់មាំក្នុងសីល និងវត្ត។ សីល និងវត្តនោះផង ជាឧបាទានផង ដូច្នេះឈ្មោះថា **សីលព្វតុបាទាន**; ព្រោះគោសីល (មានប្រក្រតីដូចគោ) គោវត្ត (ការប្រព្រឹត្តបដិបត្តិដូចគោ) ជាដើម ជាតួឧបាទាននោះឯង ព្រោះប្រកាន់មាំថា "សេចក្តីបរិសុទ្ធិមានដោយអាការយ៉ាងនេះ" ។ ម្យ៉ាងទៀត

ក៏ឈ្មោះថា **វាទៈ** ព្រោះជាហេតុពោលរបស់មនុស្សទាំងឡាយ, ក៏ឈ្មោះថា **ឧបាទាន** ព្រោះជាហេតុប្រកាន់មាំរបស់មនុស្សទាំងឡាយ; **សួរថា** រមែងពោលនូវអ្វី ឬប្រកាន់មាំនូវអ្វី ? ឆ្លើយថា ពោលអត្តា; ប្រកាន់មាំថា មានអត្តា គឺការប្រកាន់មាំនូវវាទៈរបស់ខ្លួន ឈ្មោះថា **អត្តវាទុបាទាន** ។ មួយទៀត អត្តាក៏គ្រាន់តែជាការពោលដល់ខ្លួនប៉ុណ្ណោះ ព្រោះហេតុដូច្នោះ ទើបឈ្មោះថា **អត្តវាទុបាទាន** ព្រោះអត្ថថា ជាហេតុប្រកាន់មាំរបស់មនុស្សទាំងឡាយ; នេះជាការចែកដោយអត្ថនៃឧបាទានទាំង ៤ នោះ ត្រឹមតែប៉ុណ្ណេះសិន ៕

## សម្តែងអំពីសេចក្តីសង្ខេប និងសេចក្តីពិស្តារនៃធម៌

ក៏គប្បីជ្រាបការវិនិច្ឆ័យ ក្នុងសេចក្តីសង្ខេប និងពិស្តារនៃធម៌ តទៅ ៖

**កាមុបាទាន** ជាមុនសិន ពោលដោយសង្ខេបត្រាស់ថា សេចក្តីប្រកាន់មាំដោយតណ្ហា ព្រោះព្រះបាលីមកហើយថា “**បណ្តាឧបាទានទាំង ៤ នោះ កាមុ-បាទាន តើដូចម្តេច ?; សេចក្តីពេញចិត្ត គឺការប្រាថ្នា, សេចក្តីតម្រេក គឺការប្រាថ្នា, សេចក្តីរីករាយ គឺការប្រាថ្នា, តណ្ហា គឺការប្រាថ្នា, ស្នេហា គឺការប្រាថ្នា, សេចក្តីអន្ទះអន្ទែង គឺការប្រាថ្នា, សេចក្តីទោរទន់ គឺការប្រាថ្នា, សេចក្តីងប់ជ្រប់ គឺការប្រាថ្នាក្នុងកាមទាំងឡាយណា នេះហៅថា កាមុបាទាន**”; តណ្ហាក្រោយកើតឡើងមាំមួនខ្លាំងក្លា ដោយឧបនិស្សយប្បច្ច័យ ព្រោះតណ្ហាមុនៗនោះឯង ឈ្មោះថា សេចក្តីប្រកាន់មាំដោយតណ្ហា ៕

## មតិរបស់អាចារ្យពួកខ្លះ

តែអាចារ្យពួកខ្លះពោលថា "សេចក្តីប្រាថ្នានូវអារម្មណ៍ដែលមិនទាន់មកដល់ ឈ្មោះថា **តណ្ហា** ដូចចោរលូកដៃទៅដើម្បីរាវរករបស់ក្នុងទីងងឹត; ការទទួលអារម្មណ៍ដែលមកដល់ហើយ ឈ្មោះថា **ឧបាទាន** ដូចចោរនោះឯង ចាប់ភណ្ឌៈទុក ក៏ធម៌ (គឺតណ្ហា និងឧបាទាន) ទាំងនោះ ជាបដិបក្ខចំពោះសេចក្តីប្រាថ្នាតិច និងសេចក្តីសន្តោស; ម្យ៉ាងទៀត ក៏ពួកធម៌ទាំងនេះ នៅជាមូលហេតុនៃទុក្ខ ព្រោះត្រូវស្វែងរក និងរក្សា" ដូច្នេះ; ឯឧបាទាន ៣ ដ៏សេស ដោយសង្ខេប ក៏គ្រាន់តែជាទិដ្ឋិប៉ុណ្ណោះ ។

តែកាលពោលដោយពិស្តារ សេចក្តីប្រកាន់មាំដោយតណ្ហាទាំង ១០៨ ប្រភេទ តាមដែលពោលទុកក្នុងអារម្មណ៍ មានរូបារម្មណ៍ជាដើម ខាងដើមឡើយ ឈ្មោះថា **កាមុបាទាន** ។

មិច្ឆាទិដ្ឋិមានវត្ថុ ១០ ឈ្មោះថា **ទិដ្ឋុបាទាន**; ដូចយ៉ាងដែលត្រាស់ទុកថា **"បណ្តាឧបាទានទាំង ៤ នោះ ទិដ្ឋុបាទាន តើដូចម្តេច ? សេចក្តីយល់ឃើញថា ទានដែលឱ្យហើយ មិនមានផល; ការបូជា មិនមានផល ។ ល ។ សមណព្រាហ្មណ៍ដែលធ្វើឱ្យជាក់ច្បាស់ នូវលោកនេះ និងលោកដទៃ ដោយបញ្ញាដ៏ក្រៃលែងដោយខ្លួនឯង ហើយប្រកាសឱ្យអ្នកដទៃដឹងបាន មិនមានក្នុងលោក ទិដ្ឋិ ។ ល ។ ការប្រកាន់ដោយវិបល្លាស មានសភាពបែបនេះឯង, នេះហៅថា ទិដ្ឋុបាទាន"** [៥២] ។

---

[៥២] អភិ. ៧៨ ។

ម្យ៉ាងទៀត ការប្រកាន់មាំថា សេចក្តីបរិសុទ្ធិមានដោយសីល និងវត្ត ឈ្មោះថា **សីលព្វតុបាទាន**; ដូចយ៉ាងដែលត្រាស់ទុកថា "បណ្តាឧបាទានទាំង ៤ នោះ សីលព្វតុបាទាន តើដូចម្តេច ? ការយល់ឃើញខុស ។ល។ ការប្រកាន់ដោយវិបល្លាស ដោយលក្ខណៈនេះថា សេចក្តីបរិសុទ្ធិរមែងមានដោយសីល; ដោយវត្ត; ដោយសីល និងវត្តរបស់សមណព្រាហ្មណ៍ទាំងឡាយ ខាងក្រៅសាសនានេះ មានសភាពបែបនេះឯង, នេះហៅថា **សីលព្វតុបាទាន**"[៥៣] ។

សក្កាយទិដ្ឋិមានវត្ថុ ២០ ឈ្មោះថា **អត្តវាទុបាទាន**; ដូចយ៉ាងដែលត្រាស់ថា "បណ្តាឧបាទានទាំង ៤ នោះ **អត្តវាទុបាទាន** តើដូចម្តេច ? បុថុជ្ជនក្នុងលោកនេះ ដែលគ្មានការសិក្សា មិនបានឃើញសប្បុរសទាំងឡាយ មិនឈ្លាសក្នុងធម៌របស់សប្បុរស មិនបានហ្វឹកហាត់ក្នុងធម៌របស់សប្បុរស រមែងឃើញនូវរូបដោយ (សេចក្តីសម្គាល់ថា) ជាអត្តា ។ល។ ការប្រកាន់ដោយវិបល្លាស, នេះហៅថា **អត្តវាទុបាទាន**"[៥៤] ។ នេះជាសេចក្តីសង្ខេប និងពិស្តារនៃធម៌ ក្នុងអធិការនេះ ៕

## សម្តែងអំពីលំដាប់ ៣ យ៉ាង

ក៏ក្នុងបទថា **ដោយលំដាប់** នេះ លំដាប់មាន ៣ យ៉ាង គឺ៖

---

[៥៣] អភិ. ៧៨, ៧៩ ។

[៥៤] អភិ. ៧៨, ៧៩ ។

- **ឧប្បត្តិក្កមោ** លំដាប់នៃការកើត
- **បហានក្កមោ** លំដាប់នៃការលះ
- **ទេសនាក្កមោ** លំដាប់នៃទេសនា ។

បណ្ដាលំដាប់ទាំង ៣ នោះ លំដាប់នៃការកើតឡើងរបស់កិលេសទាំងឡាយ មិនត្រាស់ទុកដោយនិប្បរិយាយ (ដោយត្រង់) ទេ ព្រោះមិនមានពាក្យថា "ឧបាទាននេះកើតឡើងមុន ក្នុងសង្សារមានខាងដើម និងទីបំផុត ដែលបុគ្គលដឹងមិនបានឡើយ"; តែក៏ទ្រង់ត្រាស់ទុកដោយបរិយាយ (ដោយអម) ថា ជាសេចក្ដីប្រកាន់មាំក្នុងសស្សតៈ និងឧច្ឆេទៈ ដែលមានការប្រកាន់អត្តានេះជាធំ ក្នុងភពមួយៗ ដោយច្រើន; តពីនោះ កាលប្រកាន់ថា "អត្តានេះទៀង" ទើបកើតសីលព្វតុបាទាន ដើម្បីសេចក្ដីបដិបត្តិដែលឱ្យបរិសុទ្ធនៃអត្តា, ពេលប្រកាន់ថា "អត្តារមែងដាច់សូន្យ" ក៏នឹងកើតកាមុបាទានដល់បុគ្គលអ្នកមិនមានសេចក្ដីអាល័យ ក្នុងលោកដទៃ ព្រោះហេតុដូច្នោះ អត្តវាទុបាទានទើបកើតឡើងមុន, បន្ទាប់មក ក៏កើតទិដ្ឋុបាទាន សីលព្វតុបាទាន និងកាមុបាទានដូច្នេះ នេះជាលំដាប់នៃការកើតឡើងរបស់ឧបាទានទាំងនោះក្នុងភពមួយៗ ដោយប្រការដូច្នេះ ។

ក៏ក្នុងបទថា លំដាប់នៃការលះនេះ ទិដ្ឋុបាទានជាដើម ដែលបុគ្គលរមែងលះមុន ព្រោះជាកិលេសដែលសោតាបត្តិមគ្គគប្បីប្រហារ; ខាងក្រោយ ទើបលះកាមុបាទាន ព្រោះជាកិសេលដែលអរហត្តមគ្គគប្បីប្រហារ នេះជាលំដាប់នៃការលះឧបាទានទាំងនោះ ដោយប្រការដូច្នេះ ។

ក៏បណ្ដាឧបាទានទាំង ៤ នោះ ទ្រង់សម្ដែងកាមុបាទានជាមុន ព្រោះជាកិលេស

មានអារម្មណ៍ច្រើន និងព្រោះជាកិលេសដែលប្រាកដហើយ; ពិតមែន កាមុបាទាននោះ ឈ្មោះថា មានអារម្មណ៍ច្រើន ព្រោះប្រកបដោយ (លោភមូល) **ចិត្ត ៨ ដួង**, ឧបាទានក្រៅពីនេះ ឈ្មោះថា មានអារម្មណ៍តិច ព្រោះប្រកបដោយ (លោភមូលចិត្ត ដែលសម្បយុត្តដោយទិដ្ឋិ) **ចិត្ត ៤ ដួង** ។ ម្យ៉ាងទៀត កាមុបាទានប្រាកដដល់ពពួកសត្វ ព្រោះសេចក្តីអាល័យ និងសេចក្តីត្រេកអរដោយច្រើន, ឧបាទានក្រៅនេះមិនមែនដូច្នោះឡើយ; ម្យ៉ាងវិញទៀត កាមុបាទានដោយភាគច្រើន មានដល់បុគ្គលដែលប្រកាន់មង្គលភ្ញាក់ផ្អើលជាដើម ដើម្បីពន្លះវត្ថុកាមទាំងឡាយ, សស្សតទិដ្ឋិមិនមែនដូច្នោះឡើយ ព្រោះហេតុដូច្នោះ ទើបទ្រង់សម្តែងទិដ្ឋុបាទាន ក្នុងលំដាប់តពីកាមុបាទាននោះ; ទិដ្ឋុបាទាននោះ កាលចែកក៏មានពីរយ៉ាង ដោយអំណាចនៃសីលព្វតុបាទាន និងអត្តវាទុបាទាន ។ ក្នុងឧបាទាន ២ នោះ ទ្រង់សម្តែងសីលព្វតុបាទាន ដែលមានអារម្មណ៍គ្រោតគ្រាតជាមុន ព្រោះបុគ្គលសូម្បីឃើញកិរិយារបស់គោ ឬកិរិយារបស់សុនខហើយ ក៏ដឹងបាន ទើបទ្រង់សម្តែងអត្តវាទុបាទានក្នុងទីបំផុត ព្រោះជាធម៌មានអារម្មណ៍ល្អិត។ នេះជាលំដាប់នៃទេសនារបស់ឧបាទានទាំងឡាយ ដោយប្រការដូច្នេះ ៕

## សម្តែងអំពីតណ្ហាជាបច្ច័យដល់ឧបាទាន

ក៏បណ្តាឧបាទានទាំងនេះ តណ្ហាជាបច្ច័យ តែម្យ៉ាងដល់ឧបាទានខាងដើម សូម្បីតណ្ហានោះ ជាបច្ច័យ ៧ យ៉ាងខ្លះ ៨ យ៉ាងខ្លះ ដល់ឧបាទាន ៣ ដ៏សេស ។

ក៏ក្នុងឧបាទានទាំង ៤ ដែលទ្រង់សម្ដែងទុកក្នុងនិទ្ទេសនេះ ដោយអាការយ៉ាងនេះ កាមតណ្ហារមែងជាបច្ច័យតែម្យ៉ាង ដោយអំណាចនៃឧបនិស្សយប្បច្ច័យដល់កាមុបាទានខាងដើម ព្រោះកើតក្នុងអារម្មណ៍ទាំងឡាយ ដែលពេញចិត្តដោយតណ្ហា; តែតណ្ហានោះរមែងជាបច្ច័យ ៧ យ៉ាង ដោយអំណាចនៃសហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ សម្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ និងហេតុប្បច្ច័យ ឬជាបច្ច័យ ៨ យ៉ាង ព្រមដោយឧបនិស្សយប្បច្ច័យ ដល់ឧបាទាន ៣ ដ៏សេស; ម្យ៉ាងទៀត កាលណា តណ្ហានោះជាបច្ច័យដោយអំណាចនៃឧបនិស្សយប្បច្ច័យ, កាលនោះ តណ្ហានោះ រមែងមិនកើតព្រមគ្នាមែនពិត ៕

**ចប់និទ្ទេសនៃឧបាទានកើតមាន ព្រោះតណ្ហាជាបច្ច័យ**

## សម្ដែងអំពីនិទ្ទេសនៃភព

**ក្នុងនិទ្ទេសនៃភពកើតមាន ព្រោះឧបាទានជាបច្ច័យ ៖**

**គប្បីជ្រាបវិនិច្ឆ័យដោយអត្ថ ដោយធម៌ ដោយពិនិត្យសារឡើងវិញនូវបទដែលមានប្រយោជន៍ ដោយញែកភព រួមភព និងដោយឧបាទានណាជាបច្ច័យដល់ភពណា ។**

ក្នុងព្រះបាលីនោះ គប្បីជ្រាបការវិនិច្ឆ័យថា ក៏ឈ្មោះថា **ភវ** ព្រោះអត្ថថាមាន = **ភវតីតិ > ភវោ** ។ បទថា **“ទុវិធេន** = ភព ២” មានអធិប្បាយថាកំណត់ដោយអាការ ២ យ៉ាង; ម្យ៉ាងទៀត បទថា **ទុវិធេន** ជាតតិយាវិភត្តិប្រើក្នុងបឋមាវិភត្តិ, មានអធិប្បាយថា ស្មើគ្នាដោយពាក្យថា **ទុវិធោ** = ២ យ៉ាង ។ បទថា **អត្ថិ** = មានព្រម = **អត្ថីតិ > សំវិជ្ជតិ** ។

ភព គឺកម្ម ឈ្មោះថា **កម្មភព**។ ភព គឺសេចក្ដីកើតឡើង ឈ្មោះថា **ឧប្បត្តិ-ភព**។ ក្នុងកម្មភព និងឧប្បត្តិភពនេះ សេចក្ដីកើតឡើង ឈ្មោះថា **ភព** ព្រោះអត្ថថា រមែងមាន, ចំណែកកម្ម គប្បីជ្រាបថា ឈ្មោះថា **ភព** ដោយវោហារថាជាផល ព្រោះកម្មជាហេតុរបស់ភព ដូចយ៉ាងដែលត្រាស់ទុកថា “**សុខោ ពុទ្ធានំ ឧប្បាទោ** = ការកើតឡើងនៃព្រះពុទ្ធជាម្ចាស់ទាំងឡាយ នាំមកនូវសេចក្ដីសុខ”[៥៥] ព្រោះជាហេតុនាំមកនូវសេចក្ដីសុខ ។

ពាក្យថា “**តត្ថ ភវោ កម្មភវោ** = ក្នុងភព ២ នោះ កម្មភពតើដូចម្ដេច” សេចក្ដីថា បណ្ដាភពទាំង ២ នោះ កម្មភពដែលត្រាស់ហើយនោះ តើដូចម្ដេច ? បុញ្ញាភិសង្ខារជាដើម មានសេចក្ដីតាមដែលពោលហើយនោះឯង ។

បទថា “**សព្វំ** = ទាំងពួង” បានដល់ មិនមានចំណែកសល់ ។

កម្មដែលឈ្មោះថា **ភវគាមី** ព្រោះអត្ថថា រមែងទៅ គឺរមែងឱ្យសត្វដល់ភព; ដោយបទថា **កម្មជាហេតុឱ្យដល់ភព** នេះ លោកបដិសេធលោកុត្តរ; ព្រោះកថានេះជាវដ្ដកថា (កថាដែលសម្ដែងដល់វដ្ដៈ), ក៏លោកុត្តរនោះ លោកពោលថា ជាធម៌អាស្រ័យវិវដ្ដៈ ។

ក៏ឈ្មោះថា **កម្ម** ព្រោះអត្ថថា ជាវត្ថុដែលគេធ្វើ។ បណ្ដាកាមភពជាដើមភព ពោលគឺកាម ឈ្មោះថា **កាមភព**។ ក្នុងរូបភព និងអរូបភព ក៏ន័យនេះដែរ។ ក៏ឈ្មោះថា **សញ្ញាភព** ព្រោះអត្ថថា ជាភពរបស់ពួកសត្វអ្នកមានសញ្ញា ឬសញ្ញា

---

[៥៥] ខុ. ធ. ។

រមែងមាននៅក្នុងភពនេះ ។ ក៏ឈ្មោះថា **អសញ្ញាភព** ដោយបរិយាយដែលផ្ទុយគ្នា ។ ក៏ឈ្មោះថា **នេវសញ្ញានាសញ្ញាភព** ព្រោះអត្ថថា មានសញ្ញា ក៏មិនមែន មិនមានសញ្ញា ក៏មិនមែន ព្រោះមិនមានសញ្ញាគ្រោតគ្រាត និងព្រោះមានសញ្ញាល្អិតក្នុងភពនេះ ។ ភពដែលបរិបូណ៌ច្រើនដោយរូបខន្ធតែម្យ៉ាង ឈ្មោះថា **ឯកវោការភព** ។ ម្យ៉ាងទៀត ឈ្មោះថា **ឯកវោការភព** ព្រោះអត្ថថា ភពនេះមានខន្ធ ១ ។ ក្នុងចតុវោការភព និងបញ្ចវោការភព ក៏ន័យនេះដែរ ។

បទថា "**អយំ វុច្ចតិ ឧប្បត្តិ ភវោ** = នេះហៅថា ឧប្បត្តិភព" បានដល់ សូម្បីភពទាំង ៩ យ៉ាង ក៏ទ្រង់ត្រាស់ហៅឈ្មោះថា ឧប្បត្តិភពដែរ ។ គប្បីជ្រាប ការវិនិច្ឆ័យ **ដោយអត្ថ** ក្នុងអធិការនេះ យ៉ាងនេះសិនចុះ ។

ចែកបទវិនិច្ឆ័យ **ដោយធម៌** ក៏ក្នុងនិទ្ទេសនេះ **ពោលដោយធម៌** បុញ្ញាភិសង្ខារ បានដល់ ចេតនា ១៣ ដួង, អបុញ្ញាភិសង្ខារ បានដល់ ចេតនា ១២ ដួង, អានេញ្ជាភិសង្ខារ បានដល់ ចេតនា ៤ ដួង ។

ព្រោះបទថា "**សព្វម្បិ ភវគាមិកម្មំ** = សូម្បីកម្មដែលជាហេតុឱ្យទៅកាន់ភពទាំងអស់" នេះ ទ្រង់សង្គ្រោះធម៌សូម្បីទាំងអស់នេះ ដែលសម្បយុត្តដោយចេតនា ឬធម៌ដែលជាអាចយគាមី ពោលគឺកម្មចូលផង អធិប្បាយថា ទ្រង់សង្គ្រោះឧបាទិន្នក្ខន្ធ ៥ ដែលជាកាមភព រូបភពក៏ដូចគ្នាដែរ; ខន្ធ ៤ ដែលជាអរូបភព, ខន្ធ ៤ និង ៥ ដែលជាសញ្ញាភព, ឧបាទិន្នក្ខន្ធ ១ ដែលជាអសញ្ញាភព, ខន្ធ ៤ ដែលជានេវសញ្ញានាសញ្ញាភព; ខន្ធ ១ ខន្ធ ៤ ខន្ធ ៥ ដែលជាឯកវោការភពជាដើម ដោយឧបាទិន្នក្ខន្ធទាំងឡាយនោះឯង ។ គប្បីជ្រាបការវិនិច្ឆ័យសូម្បីដោយធម៌ ក្នុងនិទ្ទេសនេះ

ដោយប្រការដូច្នេះ ។

បទថា **ដោយការត្រួតពិនិត្យសារឡើងវិញនូវបទដែលមានប្រយោជន៍** នេះ សេចក្ដីថា បុញ្ញាភិសង្ខារជាដើមនោះឯង ត្រាស់ទុកក្នុងនិទ្ទេសនៃសង្ខារ គឺកម្ម ដូចក្នុងនិទ្ទេសនៃភពនោះឯង, សូម្បីកាលបើយ៉ាងនោះ ត្រាស់បុញ្ញាភិសង្ខារជាដើម ដែលកើតមុនៗ ទុក ព្រោះជាបច្ច័យដល់បដិសន្ធិក្នុងអធិការនេះ ដោយអំណាចនៃ អតីតកម្ម; តែបុញ្ញាភិសង្ខារជាដើមនេះ ត្រាស់ទុកព្រោះភាវៈជាបច្ច័យ ដល់បដិសន្ធិ តទៅមុខ ដោយអំណាចនៃកម្ម ក្នុងបច្ចុប្បន្ន ព្រោះហេតុដូច្នោះ ការត្រាស់បញ្ជាក់ ទើបឈ្មោះថា មានប្រយោជន៍មែនពិត ។

ម្យ៉ាង ក្នុងខាងដើមត្រាស់ចំពោះចេតនាប៉ុណ្ណោះថាជាសង្ខារ ដោយន័យមាន ជាអាទិ៍យ៉ាងនេះថា **“ក្នុងអភិសង្ខារទាំងនោះ បុញ្ញាភិសង្ខារ តើដូចម្ដេច ? កុសលចេតនាជាកាមាវចរ”** ដូច្នេះ; តែក្នុងនិទ្ទេសនៃភពកើតមាន ព្រោះឧបាទាន ជាបច្ច័យនេះ ធម៌សូម្បីសម្បយុត្តដោយចេតនាក៏ត្រាស់ថា **សង្ខារ** ព្រោះព្រះបាលីថា **“សព្វម្បិ ភវគាមិកម្មំ** = សូម្បីកម្មដែលជាហេតុឱ្យទៅកាន់ភពទាំងអស់” ; ម្យ៉ាងទៀត ក្នុងខាងដើមត្រាស់ថា កម្មជាបច្ច័យឱ្យចំពោះតែវិបាកវិញ្ញាណប៉ុណ្ណោះ ទើបជាសង្ខារ (សង្ខារប្បច្ចយា វិញ្ញាណំ), តែក្នុងពេលនេះ សូម្បីកម្មដែលមានវិបាក-វិញ្ញាណជាបច្ច័យ ទាំងឱ្យកើតឡើងក្នុងអសញ្ញាភព ក៏ត្រាស់ថា **សង្ខារ**; ក៏ការ និយាយច្រើនទៅពេក នឹងមានប្រយោជន៍អ្វី, ព្រោះធម៌ដែលជាកុសល និងអកុសល គឺបុញ្ញាភិសង្ខារជាដើមនោះឯង ត្រាស់ទុកក្នុងបទថា **“អវិជ្ជាបច្ចយា សង្ខារា”** នេះ; ម្យ៉ាងវិញទៀត ត្រាស់ធម៌ទាំងឡាយ ដែលជាកុសល អកុសល និងអព្យាកតៈ

ព្រោះសូម្បីឧប្បត្តិភព ក៏ទ្រង់សង្គ្រោះក្នុងបទថា **"ឧបាទានបច្ចយា ភវោ** = ភពកើតមាន ព្រោះឧបាទានជាបច្ច័យ" នេះ; ព្រោះហេតុដូច្នោះ ការត្រាស់ម្តងទៀតនេះ ទើបឈ្មោះថា មានប្រយោជន៍ដោយប្រការទាំងពួងមែនពិត។ គប្បីជ្រាបការវិនិច្ឆ័យសូម្បីដោយបទថា ការត្រួតពិនិត្យសារឡើងវិញ នូវបទដែលមានប្រយោជន៍ក្នុងអធិការនេះ ដោយប្រការដូច្នេះ ។

បទថា **ដោយការញែកចេញ និងរួមចូលគ្នាបាន** គឺការញែក និងការរួមចូលគ្នានៃភព ព្រោះឧបាទានជាបច្ច័យ។ មែនពិត កម្មដែលសត្វធ្វើឱ្យកើតឡើង ក្នុងកាមភព ព្រោះកាមុបាទានជាបច្ច័យនោះ ឈ្មោះថា **កម្មភព**។ ខន្ធទាំងឡាយ ដែលកើតឡើងអំពីកម្មនោះ ឈ្មោះថា **ឧប្បត្តិភព**។ ក្នុងរូប និងអរូប ក៏ន័យនេះដែរ។ ដោយប្រការដូច្នេះ កាមភពមានកាមុបាទានជាបច្ច័យ ទើបមាន ២ យ៉ាង, សញ្ញាភព និងបញ្ចវោការភព ក៏រួមនៅខាងក្នុងកាមភពនោះឯង; រូបភពមានកាមុបាទានជាបច្ច័យ ក៏មាន ២ យ៉ាង; សញ្ញាភព អសញ្ញាភព ឯកវោការភព បញ្ចវោការភព រួមនៅខាងក្នុងរូបភពនោះឯង; អរូបភពមានកាមុបាទានជាបច្ច័យ ក៏មាន ២ យ៉ាង, សញ្ញាភព នេវសញ្ញានាសញ្ញាភព និងចតុវោការភព ក៏រួមនៅខាងក្នុងអរូបភពដូចគ្នា ព្រោះហេតុដូច្នោះ ភពដែលមានកាមុបាទានជាបច្ច័យ ទើបមាន ៦ ភព ព្រមជាមួយភពទាំងឡាយ ដែលរួមបញ្ចូលជាមួយគ្នាផង។ ក៏ភព ៦ ដែលមានកាមុបាទានជាបច្ច័យ ព្រមទាំងភពទាំងឡាយ ដែលរួមបញ្ចូលជាមួយគ្នា យ៉ាងណា, សូម្បីភពទាំងឡាយដែលមានឧបាទាន (៣) ដ៏សេសជាបច្ច័យ ក៏ដូច្នោះដែរ ភពទាំងឡាយទើបជា ២៤ ព្រមទាំងភពដែលរាប់បញ្ចូលជាមួយគ្នា ដោយការញែកបំបែកចេញ

ព្រោះឧបាទាន ៤ ជាបច្ច័យយ៉ាងនេះ ដោយប្រការដូច្នេះ ។

ចំណែក **ដោយការនៅរួមគ្នា** មានអធិប្បាយថា រួមកម្មភព និងឧប្បត្តិភព ព្រមទាំងភពដែលរួមបញ្ចូលជាមួយគ្នា កើតមានព្រោះកាមុបាទានជាបច្ច័យ ជាកម្មភពមួយ, រូបភព និងអរូបភព ក៏មានន័យដូចគ្នាដែរ ព្រោះហេតុដូច្នោះ ទើបជា ៣ ភព; សូម្បីភពដែលមានឧបាទាន ៣ ដ៏សេស ក៏ដូចគ្នាដែរ ទើបជាភព ១២ ព្រមទាំងភព ដែលរួមបញ្ចូលជាមួយគ្នា ដោយការសង្គ្រោះ (គឺរួមគ្នា) ព្រោះឧបាទាន (៤) ជាបច្ច័យយ៉ាងនេះ ដោយប្រការដូច្នេះ ។

មា្យ៉ាងទៀត ពោលដោយមិនផ្សេងគ្នា កម្មដែលឱ្យសត្វចូលដល់កាមភព ព្រោះឧបាទានជាបច្ច័យ ឈ្មោះថា **កម្មភព,** ខន្ធទាំងឡាយដែលកើតឡើងក្នុងកាមភពនោះ ឈ្មោះថា **ឧប្បត្តិភព** ។ ក្នុងរូបភព និងអរូបភព ក៏មានន័យដូចគ្នាដែរ; ដោយប្រការដូច្នេះ ទើបជា ៦ ភព ដោយការសង្គ្រោះ (រួមគ្នា); បរិយាយមួយទៀត គឺកាមភព ២; រូបភព ២ និងអរូបភព ២ ព្រមទាំងភពដែលរួមបញ្ចូលគ្នាមាន ព្រោះឧបាទានជាបច្ច័យ ។

មា្យ៉ាងវិញទៀត ចាត់ជាភព ៣ ដោយអំណាចនៃកាមភពជាដើម ព្រមទាំងភពដែលរួមបញ្ចូលជាមួយគ្នាផង ដោយមិនចែកកម្មភព និងឧប្បត្តិភព ចេញអំពីគ្នា និងមិនចាត់ជាភព ២ ដោយអំណាចនៃកម្មភព និងឧប្បត្តិភព ដោយមិនបំបែកកម្មភពជាដើម និងចាត់ជាភពតែមួយ ដោយអំណាចនៃភពថា ភពដែលកើត ព្រោះឧបាទានជាបច្ច័យ ដោយមិនអាស្រ័យការចែកកម្មភព និងឧប្បត្តិភព។ គប្បីជ្រាបការវិនិច្ឆ័យក្នុងអធិការនេះ សូម្បីដោយការចែក និងការរួមគ្នានៃភព មានឧបាទានជា

បច្ច័យ ដោយប្រការដូច្នេះ ។

បទថា **ដោយឧបាទានណា ជាបច្ច័យដល់ភពណា** អធិប្បាយថា ក៏ក្នុងនិទ្ទេសនេះ គប្បីជ្រាបការវិនិច្ឆ័យ សូម្បីដោយឧបាទានណា ជាបច្ច័យដល់ភពណានោះ ក៏ក្នុងនិទ្ទេសនេះ ឧបាទានណា ជាបច្ច័យដល់ភពណា តើដូចម្ដេច ? គឺឧបាទានយ៉ាងណាមួយ តែងជាបច្ច័យដល់ភពណាមួយបានមែនពិត, ព្រោះបុថុជ្ជន ប្រៀបដូចមនុស្សឆ្កួត; បុថុជ្ជននោះ មិនបានពិចារណាថា "វត្ថុនេះគួរ វត្ថុនេះមិនគួរ" ដូច្នេះ ប្រាថ្នាភពណាមួយ ដោយអំណាចនៃឧបាទានយ៉ាងណាមួយ រមែងធ្វើកម្មយ៉ាងណាមួយ; ព្រោះហេតុដូច្នោះ ពាក្យដែលអាចារ្យពួកខ្លះពោលថា "រូបភព និងអរូបភព រមែងមិនមានព្រោះសីលព្វតុបាទាន" នោះ, បណ្ឌិតមិនគួរកាន់យក; តែពាក្យថា "ភពទាំងអស់រមែងកើតមាន ព្រោះឧបាទានទាំងអស់" ដូច្នេះ គួរកាន់យក។ តើដូចម្ដេច ? គឺបុគ្គលខ្លះក្នុងលោកនេះ គិតថា "ឈ្មោះថា កាមទាំងនេះជារបស់សម្រេចហើយ ក្នុងត្រកូលក្សត្រមហាសាលជាដើម ក្នុងមនុស្សលោក និងទេវលោក កាមាវចរ ៦ ជាន់" ដូច្នេះ ដោយអំណាចនៃន័យដែលបានស្ដាប់មក ឬដោយទំនងដែលបានឃើញមក ត្រូវបញ្ឆោតឱ្យសេពអសទ្ធម្មជាដើម ដើម្បីឱ្យសម្រេចកាមទាំងនោះហើយសម្គាល់ថា "កាមទាំងឡាយ រមែងសម្រេចដោយកម្មយ៉ាងនេះ" ដូច្នេះ ទើបធ្វើកាយទុច្ចរិតជាដើម ដោយអំណាចនៃឧបាទាន គឺកាម; ទើបបុគ្គលនោះកើតក្នុងអបាយ ព្រោះបរិបូណ៌ដោយទុច្ចរិត។ ក៏កាលប្រាថ្នាកាមទាំងឡាយ ដែលខ្លួនឃើញហើយ ឬកាលនឹងរក្សាកាមដែលខ្លួនបានមកហើយ រមែងធ្វើកាយទុច្ចរិតជាដើម ដោយអំណាចនៃកាមុបាទាន; បុគ្គលនោះរមែងកើតក្នុងអបាយ ព្រោះបរិបូណ៌

ដោយទុច្ចរិត ។ កម្មដែលជាហេតុឱ្យបុគ្គលនោះ កើតក្នុងអបាយនោះ ឈ្មោះថា **កម្មភព**, ខន្ធដែលកើតឡើងអំពីកម្មនោះ ឈ្មោះថា **ឧប្បត្តិភព**; ចំណែកសញ្ញាភព និងបញ្ចវោការភព ក៏រួមចូលក្នុងកម្មភព និងឧប្បត្តិភពនោះដែរ ។

ចំណែកបុគ្គលមួយទៀត មានសេចក្ដីដឹងដោយការស្ដាប់ព្រះសទ្ធម្មជាដើមទៅឡើង ហើយសម្គាល់ថា "កាមទាំងឡាយរមែងសម្រេចដោយកម្មនេះ" ទើបធ្វើកាយសុចរិតជាដើម ដោយអំណាចនៃកាមុបាទាន; បុគ្គលនោះរមែងកើតក្នុងឋានសួគ៌ ឬក្នុងមនុស្សទាំងឡាយ ព្រោះសេចក្ដីបរិបូណ៌ដោយសុចរិត ។ កម្មដែលជាហេតុឱ្យគេកើតក្នុងសុគតិ មានទេវតាជាដើមនោះ ឈ្មោះថា **កម្មភព**, ខន្ធទាំងឡាយដែលកើតអំពីកម្មនោះ ឈ្មោះថា **ឧប្បត្តិភព**; ក៏សញ្ញាភព និងបញ្ចវោការភព ក៏រួមចូលក្នុងកម្មភព និងឧប្បត្តិភពនោះដូចគ្នា; កាមុបាទានជាបច្ច័យដល់កាមភព ព្រមទាំងប្រភេទ ព្រមទាំងភពដែលរួមបញ្ចូលជាមួយគ្នា ដោយប្រការដូច្នេះ ។

បុគ្គលមួយទៀត បានស្ដាប់មក ឬគិតដោយខ្លួនឯងថា "ក្នុងរូបភព និងអរូបភព កាមទាំងឡាយឱ្យសម្រេចល្អជាងកាមភពនោះ" ដូច្នេះហើយ ទើបញ៉ាំងរូប និងអរូបសមាបត្តិឱ្យកើតឡើង ដោយអំណាចនៃកាមុបាទាន ហើយកើតឡើងក្នុងលោកនៃរូបព្រហ្ម ឬអរូបព្រហ្មដោយកម្លាំងនៃសមាបត្តិ ។ ក្នុងការកើតឡើងក្នុងរូបព្រហ្ម ឬអរូបព្រហ្មនោះ កម្មដែលជាហេតុឱ្យបុគ្គលនោះកើត ឈ្មោះថា **កម្មភព**, ខន្ធទាំងឡាយ ដែលកើតអំពីកម្មនោះ ឈ្មោះថា **ឧប្បត្តិភព**; ចំណែកសញ្ញាភព អសញ្ញាភព នេវសញ្ញានាសញ្ញាភព ឯកវោការភព ចតុវោការភព និងបញ្ចវោការភព ក៏រួមនៅក្នុងរូបភព ឬអរូបភពនោះឯង ។ កាមុបាទានជាបច្ច័យ

សូម្បីដល់រូបភព និងអរូបភព ព្រមទាំងប្រភេទ ព្រមទាំងភព ដែលរួមបញ្ចូលគ្នា ដោយប្រការដូច្នេះ ។

បុគ្គលម្នាក់ទៀត អាស្រ័យឧច្ឆេទទិដ្ឋិថា "ឈ្មោះថា អត្តានេះដាច់សូន្យហើយ ក្នុងភពដែលជាសម្បត្តិរបស់កាមាវចរ ឬថាបណ្ដារូបភព និងអរូបភព ភពណាមួយ រមែងដាច់សូន្យដោយពិត" ទើបធ្វើកម្មដែលចូលដល់ភពនោះ។ កម្មនោះរបស់បុគ្គលនោះ ឈ្មោះថា **កម្មភព**, ខន្ធទាំងឡាយដែលកើតអំពីកម្មនោះ ឈ្មោះថា **ឧប្បត្តិភព**; ចំណែកភពមានសញ្ញាភពជាដើម ក៏រួមនៅក្នុងកម្មភព និងឧប្បត្តិភពនោះឯង; ទិដ្ឋុបាទានជាបច្ច័យដល់កាមភព រូបភព និងអរូបភពទាំង ៣ ព្រមទាំងប្រភេទ ព្រមទាំងភពដែលរួមបញ្ចូលជាមួយគ្នា ដោយប្រការដូច្នេះ ។

បុគ្គលដទៃទៀត កំណត់ថា "ឈ្មោះថា អត្តានេះ រមែងមានសេចក្ដីសុខ ប្រាសចាកសេចក្ដីក្ដៅអន្ទះអន្ទែង ក្នុងភពដែលជាសម្បត្តិក្នុងកាមាវចរ ឬបណ្ដារូបភព និងអរូបភព ភពណាមួយ" ដូច្នេះហើយ ទើបធ្វើកម្មដែលឱ្យចូលដល់ភពនោះ ដោយអត្តវាទុបាទាន។ កម្មនោះរបស់បុគ្គលនោះ ឈ្មោះថា **កម្មភព**, ខន្ធទាំងឡាយដែលកើតឡើងអំពីកម្មភពនោះ ឈ្មោះថា **ឧប្បត្តិភព**; ចំណែកសញ្ញាភពជាដើម ក៏រួមនៅក្នុងកម្មភព និងឧប្បត្តិភពនោះនុ៎ះឯង; អត្តវាទុបាទាន ជាបច្ច័យដល់ភព ៣ ព្រមទាំងប្រភេទ ព្រមទាំងភព ដែលរួមបញ្ចូលជាមួយគ្នា ដោយប្រការដូច្នេះ។

បុគ្គលដទៃផ្សេងទៀត មានសេចក្ដីយល់ឃើញថា "ឈ្មោះថា សីល និងវត្តនេះ រមែងឱ្យដល់សេចក្ដីសុខដ៏បរិបូណ៌ដល់បុគ្គលអ្នកបំពេញ ក្នុងភពដែលជាសម្បត្តិរបស់កាមាវចរ ឬបណ្ដារូបភព ឬក៏អរូបភព ភពណាមួយ" ដូច្នេះ ទើបធ្វើកម្មដែល

ចូលដល់ភពនោះ ដោយអំណាចនៃសីលព្វតុបាទាន ។ កម្មនោះរបស់បុគ្គលនោះ ឈ្មោះថា **កម្មភព**, ខន្ធទាំងឡាយដែលកើតអំពីកម្មភពនោះឈ្មោះថា **ឧប្បត្តិភព**; ចំណែកសញ្ញាភពជាដើម ក៏រួមនៅខាងក្នុងកម្មភព និងឧប្បត្តិភពនោះឯង ។ សីលព្វតុបាទានរមែងជាបច្ច័យដល់ភពទាំង ៣ ព្រមទាំងប្រភេទ ព្រមទាំងភពដែលរួមបញ្ចូលជាមួយគ្នាដូច្នេះឯង ។ គប្បីជ្រាបការវិនិច្ឆ័យសូម្បីដោយឧបាទានណា ជាបច្ច័យដល់ភពណា ក្នុងនិទ្ទេសនេះឯង ដោយប្រការដូច្នេះ ។

បើមានអ្នកសង្ស័យ ***សួរថា*** "ក៏ក្នុងនិទ្ទេសនេះ ឧបាទានជាអ្វី ?, ជាបច្ច័យដូចម្តេច ?, ដល់ភពណា ?" ដូច្នេះសោត ។

ឆ្លើយថា ៖

**បញ្ហាកម្មនោះ គប្បីជ្រាបថា ឧបាទានជាឧប-និស្សយប្បច្ច័យដល់រូបភព និងអរូបភព, ឧបាទាននោះ ជាបច្ច័យសូម្បីដល់កម្មភព ដោយបច្ច័យមានសហជាតប្បច្ច័យជាដើម ។**

ពិតមែន ក៏ឧបាទានទាំង ៤ នេះ ជាបច្ច័យដល់រូបភព អរូបភព និងឧប្បត្តិ-ភព ដែលជាកុសលកម្មក្នុងកម្មភព ដែលរាប់បញ្ចូលដោយកាមភព ដោយឧប-និស្សយប្បច្ច័យតែម្យ៉ាង ។ ឧបាទាន ៤ នោះ ជាបច្ច័យដល់អកុសលកម្មភព ដែលសម្បយុត្តដោយអត្តាក្នុងកាមភព ដោយសហជាតប្បច្ច័យជាដើម គឺសហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ និស្សយប្បច្ច័យ សម្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ អវិគតប្បច្ច័យ និងហេតុប្បច្ច័យ, តែជាបច្ច័យដល់ភពដែលវិប្បយុត្តគ្នា ដោយឧបនិស្សយប្បច្ច័យតែម្យ៉ាងប៉ុណ្ណោះដូច្នេះឯង ៕

**ចប់និទ្ទេសនៃភពកើតមាន ព្រោះឧបាទានជាបច្ច័យ**

## សម្តែងអំពីនិទ្ទេសនៃជាតិ

គប្បីជ្រាបវិនិច្ឆ័យក្នុងបច្ចយាការ មានជាតិជាដើម ក្នុងនិទ្ទេសនៃជាតិកើតមាន ព្រោះភពជាបច្ច័យជាដើម ដោយន័យដែលពោលទុកក្នុងសច្ចវិភង្គនោះឯង។ តែពាក្យថា **ភព** ក្នុងទីនេះ ទ្រង់ប្រាថ្នាយកកម្មភពប៉ុណ្ណោះ; ព្រោះកម្មភពនោះជាបច្ច័យដល់ជាតិ មិនមែនឧប្បត្តិភពជាបច្ច័យដល់ជាតិទេ; ឯកម្មភពនោះ ជាបច្ច័យ ២ យ៉ាងប៉ុណ្ណោះ ដោយអំណាចនៃកម្មប្បច្ច័យ និងឧបនិស្សយប្បច្ច័យ ។

ប្រសិនបើមានអ្នក**សួរថា** សេចក្តីនេះនឹងគប្បីដឹងបានយ៉ាងណាថា "ភពជាបច្ច័យដល់ជាតិ" ។

ឆ្លើយថា ដឹងបាន ព្រោះសម្តែងសេចក្តីផ្សេងគ្នានៃភាវៈ មានសេចក្តីអាក្រក់ និងប្រណីតជាដើម សូម្បីក្នុងហេតុត្រឹមតែជាបច្ច័យខាងក្រៅ ។

ពិតណាស់ កាលបច្ច័យខាងក្រៅមានមាតាបិតា ទឹកសុក្កៈ (ឈាមរដូវរបស់ស្ត្រី) ប្រចាំខែ និងអាហារជាដើម សូម្បីរបស់កូនភ្លោះ ក្នុងអត្តភាពដែលដូចគ្នា ក៏នៅមានប្រាកដផ្សេងគ្នាដោយភាវៈ មានសេចក្តីអាក្រក់គ្រោតគ្រាត និងប្រណីតជាដើម ក៏ភាពផ្សេងគ្នាដោយសេចក្តីអាក្រក់ និងប្រណីតនោះ មិនមែនមិនមានហេតុ ព្រោះសភាវៈទាំងពួង មិនមាននៅក្នុងកាលទាំងពួង ដល់ពួកសត្វទាំងអស់ ហើយទាំងមិនមែនហេតុដទៃក្រៅអំពីកម្មភព ព្រោះមិនមានហេតុដទៃ ក្នុងសន្តានដែលមានខាងក្នុងរបស់ពួកសត្វអ្នកកើតពីកម្មភពនោះ ព្រោះហេតុដូច្នោះ ទើបសត្វនោះមានកម្មភពជាហេតុដោយពិត; តាមពិត កម្មក៏ជាហេតុដែលប្លែកគ្នា ក្នុងសេចក្តី

គ្រោតគ្រាត និងប្រណីតជាដើម របស់សត្វទាំងឡាយ; ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា **“កម្មំ សត្តេ វិភជតិ យទិទំ ហីនប្បណីតតាយ** = កម្មរមែងចែកសត្វទាំងឡាយ ឱ្យអាក្រក់ និងប្រណីត” ព្រោះហេតុដូច្នោះ សេចក្តីនេះ គប្បីជ្រាបថា ភពជាបច្ច័យដល់ជាតិ [៥៦] ។

ម្យ៉ាងទៀត កាលជាតិមិនមាន ជរា និងមរណៈ ក៏ឈ្មោះថា មិនមានដែរ, ឯធម៌ មានសេចក្តីសោកជាដើម ក៏មិនមាន; តែកាលជាតិមាន ជរា និងមរណៈ និងធម៌មាន សេចក្តីសោកជាដើម ដែលជាប់ទាក់ទងជាមួយជរា និងមរណៈ របស់មនុស្សពាលដែលត្រូវទុក្ខធម៌ គឺជរា និងមរណៈគ្របសង្កត់ហើយ ឬមិនជាប់ទាក់ទងដោយជរា និងមរណៈរបស់មនុស្សពាល ដែលទុក្ខធម៌នោះៗ គ្របសង្កត់ហើយ; ព្រោះហេតុដូច្នោះ បណ្ឌិតគប្បីជ្រាបថា ជាតិនេះជាបច្ច័យដល់ជរា និងមរណៈ និងដល់ធម៌មានសេចក្តីសោកជាដើម; ក៏ជាតិនោះជាបច្ច័យតែម្យ៉ាងប៉ុណ្ណោះ ដោយអំណាចនៃឧបនិស្សយប្បច្ច័យ ៕

## ចប់និទ្ទេសនៃជាតិកើតមាន ព្រោះភពជាបច្ច័យជាដើម

[៥៦] ម. ឧ.។

# សម្មោហវិនោទនី

## អធិប្បាយភវចក្រ ១២

គប្បីជ្រាបអត្ថនៃបទ មានបទជាដើមថា “**ឯវមេតស្ស** = ការកើតឡើង... នេះ រមែងមានដោយប្រការដូច្នេះនោះ” ដោយន័យដែលពោលហើយ ក្នុងនិទ្ទេសវារៈ ។ បទថា “**សង្គតិ** = ទៅរួម” * ជាដើម ជាពាក្យវេវចនៈរបស់បទថា “**សមុទយោ** = ការកើតមានឡើង” មែនពិត ។

ក៏ព្រោះក្នុងបច្ចយាការវិភង្គនេះ ធម៌មានសេចក្ដីសោកជាដើម ត្រាស់ទុកចុងក្រោយ, ព្រោះហេតុដូច្នោះ អវិជ្ជានោះឯង ដែលត្រាស់ទុកខាងដើមនៃភវចក្រនេះយ៉ាងនេះថា “**អវិជ្ជាបច្ចយា សង្ខារា** = **សង្ខារទាំងឡាយកើតមាន ព្រោះអវិជ្ជាជាបច្ច័យ**”, អវិជ្ជានោះ សម្រេចហើយពីធម៌មានសេចក្ដីសោកជាដើម ។

ភវចក្រនេះ មានខាងដើមមិនប្រាកដ វៀរចាកអ្នកសាង និងអ្នកសោយសូន្យទទេពីសេចក្ដីទំនេរ ១២ យ៉ាង បណ្ឌិតគប្បីជ្រាបថា ប្រព្រឹត្តទៅរួមគ្នាដូច្នេះ ប្រសិនបើមានអ្នកសង្ស័យ **សួរថា** ក៏ក្នុងភវចក្រនេះ អវិជ្ជាសម្រេចពីធម៌មានសេចក្ដីសោកជាដើម តើយ៉ាងណា ?

ភវចក្រនេះ មានខាងដើមមិនប្រាកដ តើយ៉ាងណា ?

វៀរអ្នកសាង និងអ្នកសោយ តើយ៉ាងណា ? សូន្យទទេអំពីសេចក្ដីទំនេរ ១២ យ៉ាង តើយ៉ាងណា ?

ក៏ពាក្យឆ្លើយក្នុងទីនេះ គឺសោក ទុក្ខ ទោមនស្ស និងឧបាយាស មិនបាត់ទៅ

---

* សង្គតិ សមាគមោ សមោធានំ បាតុភាវោ = ការទៅរួម មករួម ការប្រជុំ ការប្រាកដ។

អំពីអវិជ្ជា, និងឈ្មោះថា **បរិទេវៈ** (សេចក្ដីខ្សឹកខ្សួល) រមែងមានដល់មនុស្សឈ្លក់វង្វេង, ព្រោះហេតុដូច្នោះ កាលសោក ទុក្ខ ទោមនស្ស ឧបាយាស និងបរិទេវៈនោះសម្រេចហើយ អវិជ្ជាក៏ជាការសម្រេចហើយមែនពិត; ម្យ៉ាងទៀត នេះក៏ជាពាក្យត្រាស់ទុកថា "ព្រោះអាសវៈកើតមាន ទើបអវិជ្ជាកើតមាន" ដូច្នេះ និងបទថា **ធម៌មានសេចក្ដីសោកជាដើម** នេះ រមែងមានព្រោះអាសវៈកើតមាន; សេចក្ដីនេះតើយ៉ាងណា ? គឺសេចក្ដីសោកមានព្រោះការប្រាត់ប្រាសអំពីវត្ថុកាម ព្រោះអាសវៈកើតមានប៉ុណ្ណោះ; ដូចយ៉ាងដែលត្រាស់ទុកថា ៖

**"តស្ស ចេ កាមយមានស្ស ឆន្ទជាតស្ស ជន្តុនោ តេ កាមា បរិហាយន្តិ សល្លវិទ្ធោវរុប្បតិ** = កាលបើសត្វនោះ កើតមានសេចក្ដីចង់បានហើយ កាមទាំងនោះ រមែងសាបសូន្យ សត្វនោះរមែងមិនរីករាយ ឬស្រពោនដូចត្រូវសរចាក់ដូច្នោះ"[៥១] ។

និងដូចយ៉ាងដែលត្រាស់ទុកថា **"កាមតោ ជាយតិ សោកោ = សេចក្ដីសោករមែងកើតពីកាម"**[៥២] ; ក៏សូម្បីសេចក្ដីសោកជាដើមទាំងអស់នេះ រមែងកើតពីទិដ្ឋាសវៈ; ដូចយ៉ាងដែលត្រាស់ថា "កាលបើគេប្រកាន់ថា យើងជារូប, រូបជារបស់យើង" រមែងកើតនូវសោក បរិទេវៈ ទុក្ខ ទោមនស្ស ឧបាយាស ព្រោះសភាពនៃរូបនោះ តែងមានការផ្លាស់ប្ដូរទៅ[៥៣] ។ ម្យ៉ាងវិញទៀត ធម៌មានសេចក្ដី

---

[៥១] ខុ. សុត្ត. ។

[៥២] សំ. ខន្ធ. ។

[៥៣] ខុ. ធ. ។

សោកជាដើម រមែងកើតមានសូម្បីព្រោះភវាសវៈកើតមាន ដូចទិដ្ឋាសវៈ កើតមានដែរ; ដូចដែលត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ សូម្បីពួកទេវតាដែលមានអាយុវែង មានវណ្ណៈ ច្រើនដោយកាមសុខ តាំងនៅអស់កាលយូរ ក្នុងវិមានខ្ពស់, សូម្បីទេវតាទាំងនោះ បានស្តាប់ព្រះធម្មទេសនារបស់តថាគតហើយ ដោយច្រើននាំគ្នាដល់នូវសេចក្តីខ្លាច សេចក្តីភ្ញាក់ផ្អើល សេចក្តីស្លុតចិត្ត"[៥៤] ដូចពួកទេវតាឃើញបុព្វនិមិត្ត ៥ នាំគ្នាភ្ញាក់ព្រើត ព្រោះខ្លាចសេចក្តីស្លាប់ដូច្នោះ ។ មួយវិញសោត ធម៌មានសេចក្តីសោកជាដើម រមែងកើតឡើង សូម្បីព្រោះការកើតឡើងនៃអវិជ្ជា ដូចភវាសវៈកើតឡើងដូច្នោះ; ដូចដែលត្រាស់ទុកថា "ម្នាលភិក្ខុទាំងឡាយ មនុស្សពាលនោះឯង រមែងសោយទុក្ខទោមនស្ស (ព្រោះគិតអាក្រក់ និយាយអាក្រក់ ធ្វើអាក្រក់) ៣ យ៉ាង ក្នុងទិដ្ឋធម៌ (បច្ចុប្បន្ន)"[៥៥] ព្រោះធម៌ (មានសេចក្តីសោកជាដើម) នេះ រមែងកើតមាន ព្រោះអាសវៈកើតមាន, ព្រោះហេតុដូច្នោះ ធម៌ទាំងនេះ កាលសម្រេចទើបញុំាងអាសវៈទាំងឡាយ ដែលជាហេតុនៃអវិជ្ជាឱ្យសម្រេច; ឯកាលអាសវៈទាំងឡាយ សម្រេចហើយ អវិជ្ជាក៏ជាការសម្រេចដែរ ព្រោះកាលបើមានបច្ច័យ ទើបមានបាន ។ ក្នុងទីនេះគប្បីជ្រាបថា អវិជ្ជាសម្រេចហើយ ដោយធម៌មានសេចក្តីសោកជាដើម យ៉ាងនេះសិន ។

ក៏ព្រោះកាលបើអវិជ្ជាសម្រេចហើយ ព្រោះកាលបើបច្ច័យមាន ទើបមានយ៉ាងនេះ, សេចក្តីបន្តគ្នាទៅនៃហេតុ និងផល យ៉ាងនេះថា "សង្ខារទាំងឡាយកើត

---

[៥៤] សំ. ខ., អំ. ចតុក្ក. ។

[៥៥] ម. ឧ. ។

មាន ព្រោះអវិជ្ជាជាបច្ច័យ, វិញ្ញាណកើតមាន ព្រោះសង្ខារជាបច្ច័យ” ជាដើម មិនមានទីបំផុត ព្រោះហេតុនោះ ភវចក្រមានអង្គ ១២ ដែលប្រព្រឹត្តទៅដោយអំណាចនៃការជាប់ទាក់ទងគ្នានូវហេតុ និងផលនោះ ទើបសម្រេចថា មានខាងដើមមិនបានប្រាកដ ។

បើមានអ្នកសង្ស័យ **សួរថា** កាលបើមានខាងដើមមិនបានប្រាកដដូច្នេះ កាលពោលពាក្យថា អវិជ្ជាជាធម៌ខាងដើមនេះថា **“ព្រោះអវិជ្ជាជាបច្ច័យ ទើបមានសង្ខារទាំងឡាយ”** ក៏ខុសទៅ មិនមែនឬ ?

ឆ្លើយថា សេចក្ដីនេះ មិនមែនជាការពោលអវិជ្ជាត្រឹមតែធម៌ខាងដើមទេ, តែសេចក្ដីនេះ ជាការពោលធម៌ដែលជាប្រធាន; ពិតណាស់ អវិជ្ជាជាប្រធាននៃវដ្ដៈ ៣ [៥៦]; ព្រោះថា ដោយការប្រកាន់ខ្ជាប់នូវអវិជ្ជា កិលេសវដ្ដៈដ៏សេស និងកម្មវដ្ដៈជាដើម រមែងចងព័ន្ធមនុស្សពាលទុក ដូចការចាប់ក្បាលពស់ សរីរៈដ៏សេសក៏នឹងរុំដៃ; តែកាលកាត់អវិជ្ជាដាច់ហើយ រមែងរួចផុតអំពីវដ្ដៈទាំងនោះ ដូចបុគ្គលកាត់ក្បាលពស់ហើយ ក៏នឹងផុតអំពីការរុំដៃដូច្នោះដែរ; ដូចយ៉ាងដែលត្រាស់ថា “ព្រោះកម្ចាត់បង់អវិជ្ជាដោយមិនសល់ ទើបសង្ខាររលត់” [៥៧] ជាដើម។ កាលបុគ្គលប្រកាន់ធម៌ណា ការចងព័ន្ធរមែងមាន និងកាលពន្លែងធម៌ណា សេចក្ដីរបួតផុតរមែងមាន, ការពោលនេះ ជាការពោលដែលជាប្រធាន (គឺអវិជ្ជា) នោះ, មិនមែនការពោលធម៌ត្រឹមតែខាងដើម; គប្បីជ្រាបភវចក្រនេះថា **“មានខាងដើមមិនបានប្រាកដ”**

---

[៥៦] គឺកិលេសវដ្ដៈ កម្មវដ្ដៈ និងវិបាកវដ្ដៈ ។

[៥៧] វិនយ. ៦, សំ. និ. ៣១។

ដោយប្រការដូច្នេះឯង ។

ភវចក្រនេះឯង ព្រោះហេតុទាំងឡាយ មានអវិជ្ជាជាដើម ជាបច្ច័យដល់ធម៌មានសង្ខារជាដើម ហេតុនេះទើបវៀរអ្នកសាងសង្សារវដ្ដ ក្រៅអំពីអវិជ្ជាជាដើមនោះ ដូចព្រហ្មជាដើម ដែលគេស្មានទុកជាមុនយ៉ាងនេះថា "ព្រហ្ម មហាព្រហ្មជាអ្នកប្រសើរបំផុត, ជាអ្នកចាត់ដោយឡែក១" ដូច្នេះ ទើបវៀរអំពីអត្តភាពអ្នកសោយសុខ និងទុក្ខ ដែលគេសន្មតថា "ក៏អត្តារបស់យើងនេះឯង ជាអ្នកពោល ជាអ្នកសោយ" ; បណ្ឌិតគប្បីជ្រាបថា វៀរអំពីកម្មអ្នកសាង និងអ្នកសោយ ដោយប្រការដូច្នេះ ។

ម្យ៉ាងទៀត ព្រោះក្នុងភវចក្រនេះ **អវិជ្ជា** ឈ្មោះថា ក្រៅអំពីការយឺតយូរ ព្រោះជាធម៌កើតឡើង និងមានការរលត់ទៅជាធម្មតា, ឈ្មោះថា ក្រៅអំពីសេចក្ដីល្អស្អាត ព្រោះជាធម៌សៅហ្មង និងព្រោះប្រកបដោយសង្កិលេស, ឈ្មោះថា ក្រៅអំពីសេចក្ដីសុខ ព្រោះត្រូវកើតមាន ការរលត់ និងការឈ្លេចឈ្លី, ឈ្មោះថា ក្រៅអំពីអត្តភាពអ្នកគ្រប់គ្រងអំណាច ព្រោះមានការប្រព្រឹត្តទៅជាប់ដោយបច្ច័យ ។ សូម្បីអង្គទាំងឡាយមានសង្ខារជាដើម ក៏ដូចគ្នាដែរ ។

ម្យ៉ាងវិញទៀត ព្រោះអវិជ្ជាមិនមែនអត្តា, មិនមែនរបស់អត្តា, មិនមែនមានក្នុងអត្តា, មិនមែនមានអត្តា, សូម្បីអង្គទាំងឡាយ មានសង្ខារជាដើម ក៏ដូចគ្នាដែរ; ព្រោះហេតុដូច្នោះ គប្បីជ្រាបថា **ភវចក្រនេះ សោះសូន្យដោយសភាពសូន្យ ១២ យ៉ាង** ដោយប្រការដូច្នេះ ។

ក៏ជ្រាបយ៉ាងនេះហើយ គប្បីជ្រាបទៀតថា ៖

**ភវចក្រនោះ មានអវិជ្ជា និងតណ្ហាជាមូល, មាន**

**កាល ៣ មានអតីតកាលជាដើម, ក្នុងកាលទាំងនោះ ដោយសង្ខេបបានអង្គ ២ (អវិជ្ជា និងសង្ខារ) អង្គ ៨ (មានវិញ្ញាណជាដើម) និងអង្គ ២ (គឺជាតិ ជរា និង មរណៈ) ប៉ុណ្ណោះដូច្នេះ ។**

អធិប្បាយធម៌ ២ គឺ អវិជ្ជា និងតណ្ហា គប្បីជ្រាបថា ជាមូលនៃភវចក្រនេះឯង; ភវចក្រនេះ ទើបមាន ២ យ៉ាង គឺអវិជ្ជាជាមូល មានវេទនាជាទីបំផុត ព្រោះនាំពីចំណែកខាងដើម, តណ្ហាជាមូល មានជរា និងមរណៈជាទីបំផុត ព្រោះបន្តក្នុងចំណែកខាងចុង; បណ្តាភវចក្រទាំង ២ នោះ ភវចក្រដំបូង ត្រាស់ដោយអំណាចនៃបុគ្គលអ្នកមានទិដ្ឋិចរិត, ភវចក្រខាងក្រោយ ត្រាស់ដោយអំណាចនៃបុគ្គលអ្នកមានតណ្ហាចរិត; ព្រោះបុគ្គលទាំងឡាយអ្នកមានទិដ្ឋិចរិត អវិជ្ជាជាតួនាំទៅកាន់សង្សារ, តែបុគ្គលមានតណ្ហាចរិត តណ្ហាជាតួនាំទៅកាន់សង្សារ ។

ន័យម្យ៉ាងទៀត ភវចក្រដំបូង ត្រាស់ទុកដើម្បីដកឡើងនូវឧច្ឆេទទិដ្ឋិ ព្រោះទ្រង់ប្រកាសការមិនកាត់ផ្តាច់នៃហេតុទាំងឡាយ របស់ការកើតឡើងនៃផល, ភវចក្រទី ២ ត្រាស់ដើម្បីដកឡើងនូវសស្សតទិដ្ឋិ ព្រោះទ្រង់ប្រកាសជរា និងមរណៈរបស់ពួកសត្វដែលកើតឡើង ។

ន័យម្យ៉ាងវិញទៀត ភវចក្រដំបូង ត្រាស់ដោយអំណាចនៃសត្វដែលកើតក្នុងគភ៌, ព្រោះទ្រង់សម្តែងការប្រព្រឹត្តទៅតាមលំដាប់ (អាយតនៈដែលកើតមាន), ភវចក្រក្រោយ ត្រាស់ដោយអំណាចនៃសត្វដែលជាឱបបាតិកៈ ព្រោះទ្រង់សម្តែងការកើតមានឡើងព្រមគ្នា (នៃអាយតនៈ) ៕

## អធិប្បាយកាល ៣

ម្យ៉ាងទៀត កាលរបស់ភវចក្រនោះ មាន ៣ គឺ អតីតៈ បច្ចុប្បន្ន និងអនាគត។ ក្នុងកាលទាំង ៣ នោះ ពោលដោយអំណាចនៃកាលដែលមកក្នុងព្រះបាលី ដោយសរុបគប្បីជ្រាបថា មានអង្គ ២ គឺ អវិជ្ជា និងសង្ខារ ជាអតីតកាល។ អង្គ ៨ មានវិញ្ញាណជាដើម មានភពជាទីបំផុត [៥៨] ជាបច្ចុប្បន្នកាល ។ ឯអង្គ ២ គឺ ជាតិ ជរា និងមរណៈ ជាអនាគតកាល, និងគប្បីជ្រាបទៀតថា ៖

## អធិប្បាយសន្ធិ ៣

ក៏ភវចក្រនេះ មានសន្ធិ ៣ គឺ ហេតុផលសន្ធិ ១ [៥៩] ផលហេតុសន្ធិ ១ ហេតុបុព្វកផលសន្ធិ ១ និងមានសង្គហៈ ៤ ប្រភេទ គឺ អាការ ២០ មានវដ្ត ៣ រមែងវិលទៅមិនមានកំណត់ ។

បណ្តាភវចក្រទាំងឡាយនោះ ក្នុងចន្លោះសង្ខារ និងបដិសន្ធិវិញ្ញាណទាំងឡាយ ជាសន្ធិវិញ្ញាណមួយ ឈ្មោះថា **ហេតុផលសន្ធិ**, ក្នុងចន្លោះវេទនា និងតណ្ហា ជាសន្ធិមួយ ឈ្មោះថា **ផលហេតុសន្ធិ**, ក្នុងចន្លោះភព និងជាតិ ជាសន្ធិមួយ ឈ្មោះថា **ហេតុបុព្វកផលសន្ធិ**; ព្រោះហេតុនោះ ភវចក្រនេះ បណ្ឌិតគប្បីជ្រាបថា មានសន្ធិ ៣ គឺ ហេតុផលសន្ធិ ១, ផលហេតុសន្ធិ ១ និងហេតុបុព្វកផលសន្ធិ ១ ដោយ

---

[៥៨] អដ្ឋកថាថា *ភវាសវានិ*, តែច្បាប់ភូមាថា *ភវាវសានានិ* ។

[៥៩] ហេតុផលសន្ធិដំបូង បានដល់ សង្ខារជាហេតុអតីតៈ បន្តជាមួយវិញ្ញាណដែលជាផល ក្នុងបច្ចុប្បន្ន, ផលហេតុសន្ធិទី ២ បានដល់ វេទនាដែលជាបច្ចុប្បន្នផល តជាមួយតណ្ហាក្នុងបច្ចុប្បន្នហេតុ និងហេតុផលសន្ធិចុងក្រោយ បានដល់ ភពជាបច្ចុប្បន្នហេតុ តជាមួយជាតិដែលជាអនាគតផល ។

ប្រការដូច្នេះឯង ៕

## អធិប្បាយសង្គហៈ ៤ [៦០]

មួយទៀត ភវចក្រនេះ មានសង្គហៈ ៤ ដែលកំណត់យកភវចក្រតាំងអំពីខាងដើម (គឺអវិជ្ជា) និងទីបំផុត (គឺជរា និងមរណៈ) នៃសន្ធិទាំងឡាយ ។ សេចក្ដីនេះ ជាយ៉ាងណា ? គឺអវិជ្ជា និងសង្ខារ ជាសង្គហៈទី ១, វិញ្ញាណ នាមរូប សឡាយតនៈ ផស្សៈ និងវេទនា ជាសង្គហៈទី ២, តណ្ហា ឧបាទាន និងភព ជាសង្គហៈទី ៣, ជាតិ ជរា និងមរណៈ ជាសង្គហៈទី ៤ គប្បីជ្រាបថា ភវចក្រនេះ មានសង្គហៈ ៤ ប្រភេទ ដោយប្រការដូច្នេះ ៕

## អធិប្បាយអាការ ២០

ម្យ៉ាងទៀត គប្បីជ្រាបថា ភវចក្រមានអាការ ២០, ដោយអាការ ២០ ទាំងនេះ គឺ

ក្នុងអតីតៈមានហេតុ ៥, ក្នុងបច្ចុប្បន្នមានផល ៥, ក្នុងបច្ចុប្បន្នមានហេតុ ៥ និងក្នុងអនាគតមានផល ៥ ។

បណ្ដាភវចក្រទាំងឡាយនេះ ពាក្យថា **ក្នុងអតីតៈមានហេតុ ៥** សេចក្ដីថា អង្គទាំង ២ នេះ គឺ អវិជ្ជា និងសង្ខារ ត្រាស់ទុកមុនមែនពិត; ប៉ុន្តែព្រោះបុគ្គលអ្នកល្ងង់ខ្លៅរមែងភ្ញាក់, បុគ្គលអ្នកភ្ញាក់រមែងប្រកាន់មាំ, ទើបភពកើតមាន ព្រោះឧបា-

---

[៦០] ពាក្យថា សង្គហៈ ៤ ក្នុងអភិធម្មត្ថសង្គហៈ លោកហៅថា សង្ខេប ។

ទានជាបច្ច័យដល់បុគ្គលនោះ; ដោយហេតុនោះ ទើបទ្រង់កាន់យកសូម្បីតណ្ហា ឧបាទាន និងភពផង; ព្រោះហេតុនោះ ទើបព្រះធម្មសេនាបតីសារីបុត្រពោលថា "មោហៈ គឺអវិជ្ជា, កម្មដែលប្រកប គឺសង្ខារ, សេចក្ដីប្រាថ្នា គឺតណ្ហា, ការចូលដល់ គឺឧបាទាន, ចេតនា គឺភព; ធម៌ទាំង ៥ នេះ ក្នុងកម្មភពមុន ជាបច្ច័យដល់បដិសន្ធិក្នុងភពនេះ"[៦១]។ ក្នុងពាក្យទាំងនេះ ពាក្យថា **ក្នុងកម្មភពមុន** បានដល់ កម្មភពដែលកើតមុន គឺកម្មភពដែលធ្វើទុកក្នុងអតីតជាតិ; ពាក្យថា **មោហៈ គឺអវិជ្ជា** អធិប្បាយថា មោហៈ (ការវង្វេង) ក្នុងសច្ចៈមានទុក្ខសច្ចជាដើម ក្នុងកាលណោះ, សត្វនោះវង្វេងហើយ រមែងធ្វើកម្មដោយមោហៈណា មោហៈនោះជាអវិជ្ជា។ ពាក្យថា **កម្មដែលប្រកប គឺសង្ខារ** បានដល់ ចេតនាដំបូងរបស់អ្នកធ្វើកម្មនោះ, ដូចការញ៉ាំងចិត្តឱ្យកើតឡើង ដោយការគិតថា "យើងនឹងថ្វាយទាន" ដូច្នេះ ហើយចាត់ចែងនូវឧបករណ៍នៃការឱ្យទាន មួយខែខ្លះ, មួយឆ្នាំខ្លះ; ក៏ចេតនារបស់បុគ្គលដែលញ៉ាំងទក្ខិណាទាន ឱ្យតាំងឡើងក្នុងដៃរបស់បដិគ្គាហកៈទាំងឡាយ លោកហៅថា **ភព**។ម្យ៉ាងទៀត ចេតនាក្នុងជវ័ន ៦ ដែលមានអាវជ្ជនៈតែមួយជាមួយគ្នា ឈ្មោះថា **អាយូហនសង្ខារ** (កម្មដែលប្រកប គឺសង្ខារ), ចេតនាជួងទី ៧ ឈ្មោះថា **ភព**; មួយវិញទៀត ចេតនាយ៉ាងណានិមួយ ឈ្មោះថា **ភព**, ធម៌ដែលសម្បយុត្តដោយចេតនានោះ ឈ្មោះថា **អាយូហនសង្ខារ**។ ពាក្យថា **សេចក្ដីប្រាថ្នា គឺតណ្ហា** សេចក្ដីថា សេចក្ដីប្រាថ្នា គឺការចង់បានក្នុងឧប្បត្តិភព ដែលជាផលរបស់បុគ្គលអ្នកធ្វើកម្មនោះ ឈ្មោះថា **តណ្ហា**។ ពាក្យថា **សេចក្ដីចូលដល់ គឺឧបាទាន** សេចក្ដីថា ការចូលដល់ ការប្រតោង ការប្រកាន់

---

[៦១] ខុ. បដិ.។

ដែលប្រព្រឹត្តទៅដោយន័យមានជាអាទិ៍ថា "យើងធ្វើកម្មនេះឱ្យជាបច្ច័យដល់ភព ហើយ នឹងសេពកាមក្នុងឋានឈ្មោះឯណោះ នឹងដាច់សូន្យ" យ៉ាងណា, នេះឈ្មោះថា **ឧបាទាន** ។ ពាក្យថា **ចេតនា គឺភព** បានដល់ ចេតនាដែលប្រព្រឹត្តទៅក្នុងទីបំផុតនៃកម្មដែលប្រកប ឈ្មោះថា **ភព** គប្បីជ្រាបសេចក្ដីនេះ ដោយប្រការដូច្នេះចុះ ។

ពាក្យថា **ក្នុងបច្ចុប្បន្នមានផល ៥** បានដល់ ភវចក្រមានវិញ្ញាណជាដើម មានវេទនាជាចុង មកក្នុងព្រះបាលីនោះឯង; ដូចយ៉ាងដែលព្រះធម្មសេនាបតីសារីបុត្តពោលថា "ក្នុងឧប្បត្តិភពនេះ បដិសន្ធិ គឺវិញ្ញាណ ១, ការឈានចុះ គឺនាមរូប ១, បសាទ គឺអាយតនៈ ១, ការពាល់ត្រូវ គឺផស្សៈ ១, ការសោយអារម្មណ៍ គឺវេទនា ១, ធម៌ទាំង ៥ នេះ ជាបច្ច័យដល់កម្មដែលធ្វើហើយមុន ក្នុងឧប្បត្តិភពនេះ"[៦២] ។ ក្នុងធម៌ទាំង ៥ នោះ ពាក្យថា **បដិសន្ធិ គឺវិញ្ញាណ** ដែលលោកពោលថា ឈ្មោះថា **បដិសន្ធិ** ព្រោះសេចក្ដីកើតឡើង ដោយអំណាចនៃការបន្តមកក្នុងភពដទៃ" យ៉ាងណា, នេះ ឈ្មោះថា **វិញ្ញាណ** ។ ពាក្យថា **ការឈានចុះ គឺនាមរូប** សេចក្ដីថា ការចុះកាន់គភ៌របស់រូបធម៌ និងអរូបធម៌ ដូចជាមកហើយចូលទៅ យ៉ាងណា, នេះហៅថា **នាមរូប** ។ ពាក្យថា **បសាទ គឺអាយតនៈ** នេះ ពោលទុកដោយអំណាចនៃអាយតនៈ ៥ មានចក្ខាយតនៈជាដើម ។ ពាក្យថា **ការពាល់ត្រូវ គឺផស្សៈ** បានដល់ ការពាល់ត្រូវហើយ ឬកំពុងពាល់ត្រូវនូវអារម្មណ៍ យ៉ាងណានិមួយ, នេះហៅថា **ផស្សៈ** ។ ពាក្យថា **ការសោយអារម្មណ៍ គឺវេទនា** បានដល់ ការសោយវិបាកដែលកើតឡើងព្រមដោយបដិសន្ធិវិញ្ញាណ ឬផស្សៈដែលមានសឡាយតនៈជាបច្ច័យ យ៉ាង

---

[៦២] ខុ. បដិ. ។

ណានីមួយ នេះហៅថា **វេទនា** ។ គប្បីជ្រាបសេចក្ដីនេះ ដោយប្រការដូច្នេះ ។

ពាក្យថា **ក្នុងបច្ចុប្បន្នមានហេតុ ៥** បានដល់ ហេតុទាំងឡាយ មានតណ្ហាជាដើម មកហើយក្នុងព្រះបាលីនោះឯង គឺតណ្ហា ឧបាទាន និងភព; កាលកាន់យកភពហើយ ក៏ជាការកាន់យកសង្ខារ ដែលជាបុព្វភាគនៃភពនោះ ឬធម៌ដែលសម្បយុត្តដោយភពនោះដូចគ្នា និងដោយការកាន់យកតណ្ហា និងឧបាទាន ក៏ជាការកាន់ យកអវិជ្ជាដែលសម្បយុត្តដោយតណ្ហា និងឧបាទាននោះ ឬថា ជាហេតុឱ្យមនុស្សដែលវង្វេងធ្វើកម្មនោះ ព្រោះហេតុដូច្នោះ អង្គនៃភវចក្រនោះ ទើបមាន ៥ ដោយប្រការដូច្នេះ; ដោយហេតុនោះ ទើបព្រះធម្មសេនាបតីសារីបុត្តពោលថា "ព្រោះកាលដែលអាយតនៈទាំងឡាយ ក្នុងលោកនេះចាស់ក្លាហើយ មោហៈ គឺអវិជ្ជា, កម្មដែលប្រកប គឺសង្ខារ, សេចក្ដីប្រាថ្នា គឺតណ្ហា, ការចូលដល់ គឺឧបាទាន, ចេតនា គឺភព, ធម៌ទាំង ៥ ដូចពោលមកនេះ ក្នុងភពនេះ ជាបច្ច័យដល់បដិសន្ធិវិញ្ញាណក្នុងអនាគត"[៦៣] ។ បណ្ដាពាក្យទាំងនោះ ពាក្យថា **ព្រោះការដែលអាយតនៈទាំងឡាយ ក្នុងលោកនេះ ចាស់ក្លាហើយ** នោះ សម្ដែងដល់បុគ្គលដែលវង្វេងវង្វាន់ ក្នុងពេលធ្វើកម្មរបស់សត្វ អ្នកមានអាយតនៈចាស់ក្លាហើយ ។ ពាក្យដ៏សេសមានសេចក្ដីងាយស្រួលមែនពិត ។

ពាក្យថា **ក្នុងអនាគតមានផល ៥** បានដល់ ផល ៥ មានវិញ្ញាណជាដើម ។ ផល ៥ មានវិញ្ញាណជាដើមនោះ ខ្ញុំពោលទុកដោយសព្ទថា **ជាតិ**; ចំណែកជរា និងមរណៈ ក៏ជាជរា និងមរណៈរបស់ផលទាំង ៥ មានវិញ្ញាណជាដើមនោះឯង; ដោយ

---

៦៣-៦៤ ខុ. បដិ. ។

ហេតុនោះ ទើបព្រះធម្មសេនាបតីសារីបុត្តពោលថា “ក្នុងអនាគត បដិសន្ធិ គឺវិញ្ញាណ, ការឈានចុះ គឺនាមរូប, បសាទ គឺអាយតនៈ, ការពាល់ត្រូវ គឺផស្សៈ, ការសោយអារម្មណ៍ គឺវេទនា, ធម៌ទាំង ៥ ដូចពោលនេះ ក្នុងឧប្បត្តិភព ក្នុងអនាគត ជាបច្ច័យដល់កម្មដែលធ្វើទុកហើយក្នុងភពនេះ” [៦៤] ។ ភវចក្រនេះ មានអាការ ២០ ដោយប្រការដូច្នេះ ។

បណ្ដាភវចក្រ មានអាការទាំង ២០ នោះ ក្នុងភពមុន មានអង្គប្រកប គឺកម្ម (ដែលជាហេតុ) ៥ យ៉ាង, ក្នុងបច្ចុប្បន្ន មានធម៌ដែលជាវិបាក ៥ យ៉ាង; ក្នុងបច្ចុប្បន្ន មានអង្គប្រកប គឺកម្ម ៥ យ៉ាង, ក្នុងអនាគត មានធម៌ដែលជាវិបាក ៥ យ៉ាង ព្រោះហេតុដូច្នោះ ទើបរួមធម៌ដែលជាកម្ម ១០ យ៉ាង, ជាវិបាក ១០ យ៉ាង ដោយអាការដែលពោលអំពីកម្មក្នុងឋានទាំងពីរ ទើបឈ្មោះថា **កម្ម**, វិបាកក្នុងឋានទាំង ២ ឈ្មោះថា **វិបាក**; សូម្បីភវចក្រទាំងអស់នេះ មានទាំងកម្ម មានទាំងវិបាករបស់កម្មវិលទៅដោយ **បច្ចយាការ** មានប្រការដូច្នេះ ។

ម្យ៉ាងទៀត កម្មក្នុងឋានទាំង ២ ឈ្មោះថា **កម្មសង្ខេប** = សង្ខេបកម្ម, វិបាកក្នុងឋានទាំង ២ នេះ ឈ្មោះថា **វិបាកសង្ខេប** = សង្ខេបវិបាក, ព្រោះហេតុ-ដូច្នោះ ភវចក្រទាំងអស់នេះ ទើបជាកម្មវដ្ដៈ និងវិបាកវដ្ដៈ។ ម្យ៉ាងវិញសោត កម្មក្នុងឋានទាំង ២ ឈ្មោះថា **កម្មភព**, វិបាកក្នុងឋានទាំង ២ ឈ្មោះថា **វិបាកភព** ព្រោះហេតុដូច្នោះ ភវចក្រទាំងអស់នេះ ទើបមានទាំងជាកម្មភព និងវិបាកភព។ កម្មក្នុងឋានទាំង ២ ឈ្មោះថា **កម្មបវត្ត**, វិបាកក្នុងឋានទាំង ២ ឈ្មោះថា **វិបាកបវត្ត** ព្រោះហេតុដូច្នោះ ភវចក្រទាំងអស់នេះ ទើបមានទាំងជាកម្មបវត្ត និងវិបាកបវត្ត;

ពុំនោះសោត កម្មក្នុងឋានទាំង ២ ឈ្មោះថា **កម្មសន្តតិ**, វិបាកក្នុងឋានទាំង ២ ឈ្មោះថា **វិបាកសន្តតិ** ព្រោះហេតុនោះ ភវចក្រទាំងអស់នេះ ទើបមានទាំងកម្មសន្តតិ និងវិបាកសន្តតិ; ម្យ៉ាងវិញទៀត កម្មក្នុងឋានទាំង ២ ឈ្មោះថា **កិរិយា**, វិបាកក្នុងឋានទាំង ២ ឈ្មោះថា ផលរបស់កិរិយា ព្រោះហេតុដូច្នោះ ភវចក្រទាំងអស់នេះ ទើបមានទាំងកិរិយា និងផលរបស់កិរិយា ដោយប្រការដូច្នេះ ។

ភវចក្រនេះ កើតឡើងព្រមហើយ ប្រកបដោយហេតុ ជាទុក្ខ, មិនទៀង មានសេចក្តីញាប់ញ័រ, ប្រែប្រួល មិនជាអចិន្ត្រៃយ៍; ធម៌ទាំងឡាយរមែងកើតអំពីធម៌ទាំងឡាយ ដែលជាហេតុ ព្រោះក្នុងធម៌ទាំងនេះ រកតួខ្លួន និងអ្នកដទៃមិនមាន ។

ធម៌ និងអធម៌ រមែងញុំាងធម៌ និងអធម៌ឱ្យកើតឡើងដោយខ្លួនឯង ព្រោះបច្ច័យ គឺហេតុជាអង្គប្រកប; ក៏ធម៌ដែលព្រះភគវាទ្រង់សម្តែងទុក ដើម្បីសេចក្តីរលត់នូវហេតុទាំងឡាយ ។

កាលហេតុទាំងឡាយ រលត់ហើយ វដ្តៈក៏អស់មិនវិលវល់ទៀត; អ្នកប្រព្រឹត្តព្រហ្មចរិយៈ ក្នុងព្រះធម្មវិន័យនេះ រមែងធ្វើនូវទីបំផុតនៃទុក្ខដោយប្រការដូច្នេះ; ម្យ៉ាងទៀត កាលរកភាពជាសត្វមិនមាន ការដាច់សូន្យ និងតាំងនៅរហូត ក៏រមែងមិនមាន ។

ក៏ក្នុងពាក្យថា "វដ្តៈ ៣ តែងតែវិលទៅ មិនមានកំណត់" នេះ អធិ

ប្បាយថា ភវចក្រនេះ មានវដ្តៈ ៣, ដោយវដ្តៈ ៣ នេះ គឺ “សង្ខារ និងភព ជាកម្មវដ្តៈ, អវិជ្ជា តណ្ហា និងឧបាទាន ជាកិលេសវដ្តៈ, វិញ្ញាណ នាមរូប សឡាយតនៈ ផស្សៈ និងវេទនា ជាវិបាកវដ្តៈ” គប្បីជ្រាបថា រមែងវិលទៅដោយការវិលទៅជុំវិញញយៗ ឈ្មោះថា មិនមានកំណត់ ព្រោះមានបច្ច័យមិនដាច់ខ្សែ រហូតវេលាដែលកិលេសវដ្តៈនៅមិនទាន់អស់មែនពិត ។ ភវចក្រនេះ កាលវិលទៅយ៉ាងនេះ ៖

គប្បីជ្រាបដោយសេចក្តីថា **ជាសច្ចៈ និងជាដែនកើតនៃសច្ចៈ ១, ដោយកិច្ច ១, ដោយការហាម ១, ដោយការឧបមា ១, ដោយប្រភេទនៃសេចក្តីជ្រាលជ្រៅ ១, ដោយប្រភេទរបស់ន័យ ១ តាមសមគួរ ៕**

## គប្បីជ្រាបដោយសេចក្តីជាសច្ចៈ និងជាដែនកើតមាន

ក្នុងគាថានោះ ព្រោះព្រះតម្រាស់ដែលត្រាស់ទុកក្នុងសច្ចវិភង្គថា “កុសល-ធម៌ និងអកុសលធម៌ ជាសមុទយសច្ច ដោយមិនប្លែកគ្នា” ព្រោះហេតុដូច្នោះ ពាក្យថា “**អវិជ្ជាបច្ចយា សង្ខារា**” បានដល់ សង្ខារទាំងឡាយកើតមាន ព្រោះអវិជ្ជាចាត់ជាសច្ចៈទី ២ មានសច្ចៈទី ២ ជាដែនកើត, វិញ្ញាណកើតពីសង្ខារទាំងឡាយចាត់ជាសច្ចៈទី ១ មានសច្ចៈទី ២ ជាដែនកើតមាន, នាមរូបជាដើម មានវិបាកវេទនាជាទីបំផុតកើតមាន ព្រោះវិញ្ញាណជាដើម ចាត់ជាសច្ចៈទី ១ មានសច្ចៈទី ១ ជាដែនកើត, តណ្ហាកើតមានពីវេទនា ចាត់ជាសច្ចៈទី ២ មានសច្ចៈទី ១ ជាដែនកើត, ឧបាទានកើត មានពីតណ្ហា ចាត់ជាសច្ចៈទី ២ មានសច្ចៈទី ២ ជាដែនកើតមាន, ភពកើតមានពី ឧបាទាន ចាត់ជាសច្ចៈទី ២ គឺ ទី ១ និងទី ២ មានសច្ចៈទី ២

ជាដែនកើត ។ ជាតិ កើតមានពីភព ចាត់ជាសច្ចៈទី ១ មានសច្ចៈទី ២ ជាដែនកើត, ជរា និងមរណៈកើត មានពីជាតិ ចាត់ជាសច្ចៈទី ១ មានសច្ចៈទី ១ ជាដែនកើត។ ភវចក្រនេះ គប្បីជ្រាប ដោយសេចក្តីជាសច្ចៈ និងជាដែនកើតមាន តាមការគួរ ដូចពណ៌នាមកដូច្នេះសិន ៕

## គប្បីជ្រាបសេចក្តីជាភវចក្រដោយកិច្ច

ម្យ៉ាងទៀត ព្រោះក្នុងភវចក្រនេះ អវិជ្ជារមែងញ៉ាំងពួកសត្វឱ្យឈ្លក់វង្វេងក្នុងវត្ថុទាំងឡាយ, និងជាបច្ច័យ ព្រោះការប្រាកដនៃសង្ខារទាំងឡាយ ។ ម្យ៉ាងវិញទៀត សង្ខារទាំងឡាយរមែងតាក់តែងសង្ខតធម៌ និងជាបច្ច័យដល់វិញ្ញាណ។ សូម្បីវិញ្ញាណក៏រមែងដឹងច្បាស់នូវវត្ថុ និងរមែងជាបច្ច័យដល់នាមរូប។ សូម្បីនាមរូបក៏ឧបត្ថម្ភនូវគ្នានឹងគ្នា និងរមែងជាបច្ច័យដល់សឡាយតនៈ ។ សូម្បីសឡាយតនៈក៏ប្រព្រឹត្តទៅក្នុងវិស័យរបស់ខ្លួន និងរមែងជាបច្ច័យដល់ផស្សៈ ។ សូម្បីផស្សៈក៏ពាល់ត្រូវនូវអារម្មណ៍ និងរមែងជាបច្ច័យដល់វេទនា, សូម្បីវេទនាក៏សោយនូវអារម្មណ៍ និងជាបច្ច័យដល់តណ្ហា។ សូម្បីតណ្ហា ក៏ត្រេកអរក្នុងធម៌ដែលជាទីតាំងនៃសេចក្តីត្រេកអរ និងរមែងជាបច្ច័យដល់ឧបាទាន, សូម្បីឧបាទាន ក៏ប្រកាន់នូវធម៌ដែលជាទីតាំងនៃសេចក្តីប្រកាន់ និងរមែងជាបច្ច័យដល់ភព។ សូម្បីភព ក៏ច្របូកច្របល់ទៅក្នុងគតិផ្សេង ៗ, និងរមែងជាបច្ច័យដល់ជាតិ។ សូម្បីជាតិក៏ញ៉ាំងខន្ធទាំងឡាយ ឱ្យកើតមាន, ព្រោះខន្ធនោះ ប្រព្រឹត្តទៅដោយសភាវៈ គឺការកើតមានដោយចំពោះ និងរមែងជាបច្ច័យដល់ជរា និងមរណៈ។ សូម្បីជរា និងមរណៈ ក៏នៅប្រឈមមុខនឹងការចាស់ ការ

បែកធ្លាយនៃខន្ធទាំងឡាយ, និងរមែងជាបច្ច័យដល់ការប្រាកដក្នុងភពដទៃ, ព្រោះខន្ធទាំងឡាយ ជាទីទទួលយកនូវសេចក្ដីសោក ព្រោះហេតុនោះ ភវចក្រនេះ បណ្ឌិតគប្បីជ្រាបសូម្បី**ដោយកិច្ច** ដែលប្រព្រឹត្តទៅ ២ យ៉ាង ក្នុងបទទាំងឡាយតាមសមគួរ ៕

## គប្បីជ្រាបសេចក្ដីជាភវចក្រដោយការហាម

ម្យ៉ាងវិញទៀត ព្រោះក្នុងភវចក្រនេះ ពាក្យថា **"សង្ខារទាំងឡាយកើតមាន ព្រោះអវិជ្ជាជាបច្ច័យ"** ដូច្នេះ ជាពាក្យហាមការយល់ឃើញថា មានអ្នកបង្កើត ។ ពាក្យថា **វិញ្ញាណកើតមាន ព្រោះសង្ខារជាបច្ច័យ** នេះ ជាពាក្យហាមការយល់ឃើញថា អត្តាឃ្លាតចាកទី (ពីកន្លែងមួយទៅកន្លែងមួយ) បាន ។ ពាក្យថា **នាមរូបកើតមាន ព្រោះវិញ្ញាណជាបច្ច័យ** នេះ ជាការហាមសេចក្ដីសំគាល់ថាជាដុំ ព្រោះឃើញការបែកធ្លាយទៅនៃវត្ថុដែលសន្មតថា មានអត្តា, ក្នុងពាក្យថា **"សឡាយតនៈកើតមាន ព្រោះនាមរូបជាបច្ច័យ"** ដូច្នេះជាដើម ជាការហាមសេចក្ដីយល់ឃើញ មានជាអាទិ៍យ៉ាងនេះថា "អត្តារមែងឃើញ ។ ល ។ រមែងដឹង, រមែងពាល់ត្រូវ, រមែងសោយ, រមែងប្រកាន់ខ្ជាប់, រមែងប្រកាន់ទុក, រមែងមាន, រមែងកើត, រមែងចាស់, រមែងស្លាប់"; ព្រោះហេតុដូច្នេះ គប្បីជ្រាបភវចក្រនេះ **ដោយការហាម**សេចក្ដីយល់ឃើញខុសតាមគួរចុះ ៕

## គប្បីជ្រាបសេចក្ដីជាភវចក្រដោយការឧបមា

ក៏ព្រោះក្នុងភវចក្រនេះ អវិជ្ជាប្រៀបដូចមនុស្សខ្វាក់ ព្រោះមិនឃើញធម៌

ទាំងឡាយ ដោយអំណាចនៃសភាវលក្ខណៈ និងសាមញ្ញលក្ខណៈ, សង្ខារទាំងឡាយ ដែលកើតមាន ព្រោះអវិជ្ជាជាបច្ច័យ ប្រៀបដូចការរអិលរបស់មនុស្សខ្វាក់, វិញ្ញាណ ដែលកើតមាន ព្រោះសង្ខារជាបច្ច័យ ប្រៀបដូចការដួលរបស់មនុស្សខ្វាក់ដែលរអិល នោះ, នាមរូបដែលកើតមាន ព្រោះវិញ្ញាណជាបច្ច័យ ប្រៀបដូចការប្រាកដពកហើម របស់មនុស្សខ្វាក់ដែលដួលហើយ, សឡាយតនៈដែលកើតមាន ព្រោះនាមរូបជា បច្ច័យ ប្រៀបដូចការបែកធ្លាយរបស់មុខរបួស, ផស្សៈដែលកើតមាន ព្រោះសឡា-យតនៈជាបច្ច័យ ប្រៀបដូចការខ្ទប់នឹងមុខរបួស, វេទនាដែលកើតមាន ព្រោះផស្សៈ ជាបច្ច័យ ប្រៀបដូចសេចក្ដីមិនសប្បាយ (ទុក្ខ) ព្រោះការខ្ទប់, តណ្ហាដែលកើតមាន ព្រោះវេទនាជាបច្ច័យ ប្រៀបដូចអ្នកត្រូវការបំបាត់ទុក្ខ, ឧបាទានដែលកើតមាន ព្រោះតណ្ហាជាបច្ច័យ ប្រៀបដូចការកាន់យកថ្នាំដែលមិនល្អមក ដោយប្រាថ្នាដើម្បី បំបាត់រោគ, ភពដែលកើតមាន ព្រោះឧបាទានជាបច្ច័យ ប្រៀបដូចការលាបថ្នាំមិន ល្អដែលខ្លួនយកមក, ជាតិដែលកើតមាន ព្រោះភពជាបច្ច័យ ប្រៀបដូចការប្រាកដ ជារបួសក្លាយ ដោយការលាបថ្នាំដែលមិនល្អនោះ, ជរា និងមរណៈ ដែលកើតមាន ព្រោះជាតិជាបច្ច័យ ប្រៀបដូចការបែកនៃបូស ព្រោះបូសក្លាយ ។

ឬថា ព្រោះក្នុងភវចក្រនេះ អវិជ្ជារមែងគ្របសង្កត់សត្វទាំងឡាយ ដោយ ភាវៈដែលមិនបដិបត្តិ និងភាវៈដែលបដិបត្តិខុស ដូចសំពត់បិទភ្នែក, ក៏មនុស្សពាល ត្រូវអវិជ្ជាគ្របសង្កត់ហើយ រមែងចងខ្លួនទុកដោយសង្ខារទាំងឡាយ ដែលឱ្យកើត មានក្នុងភពថ្មី ដូចដង្កូវនាងរុំខ្លួនទុកដោយចំណែកនៃសម្បុកនាង ។ វិញ្ញាណដែល កំណត់ទុកដោយសង្ខារ តែងបានទីអាស្រ័យក្នុងគតិទាំងឡាយ ដូចព្រះរាជកុមារ

ដែលបរិនាយកផ្គងឡើងហើយ រមែងបានសោយរាជសម្បត្តិ។ វិញ្ញាណរមែងញ៉ាំងនាមរូបមានប្រការជាអនេក ឱ្យកើតមានក្នុងបដិសន្ធិ ព្រោះការកំណត់និមិត្តនៃការឧប្បត្តិ ដូចនាយមាយាករញ៉ាំងមាយាកលឱ្យកើតមាន។ សឡាយតនៈអាស្រ័យនាមរូបហើយ រមែងដល់ការចម្រើនលូតលាស់វិបុលសុខ ដូចគុម្ពឈើព្រៃអាស្រ័យក្នុងភូមិភាគដ៏ល្អ។ ផស្សៈរមែងកើតមាន ព្រោះការប៉ះខ្ទប់នៃអាយតនៈ ដូចភ្លើងដែលកើតមាន ព្រោះការពួតគ្នានៃឈើពួតភ្លើង។ វេទនារមែងប្រាកដដល់បុគ្គលអ្នកប៉ះខ្ទប់ដោយផស្សៈ ដូចការក្តៅរបស់បុគ្គលអ្នកពាល់ត្រូវភ្លើង; តណ្ហារមែងចម្រើនដល់បុគ្គលដែលសោយនូវអារម្មណ៍ ដូចការស្រេកឃ្លានរបស់អ្នកផឹកទឹកអំបិល; បុគ្គលស្រេកឃ្លានហើយ រមែងធ្វើសេចក្តីប្រាថ្នាក្នុងភពទាំងឡាយ ដូចបុគ្គលដែលស្រេកឃ្លានក្នុងការផឹកទឹក។ ការធ្វើសេចក្តីប្រាថ្នានោះ ជាឧបាទានរបស់គេ តែងប្រកាន់ភពដោយឧបាទាន ដូចត្រីជាប់សន្ទូចដោយការជាប់ជំពាក់ក្នុងនុយ; កាលភពមានជាតិ ក៏មាន ដូចកាលគ្រាប់ពូជមាន ពន្លកក៏ត្រូវមាន។ បុគ្គលកើតហើយ រមែងចូលដល់ជរា និងមរណៈ យ៉ាងពិតប្រាកដ ដូចដើមឈើកើតឡើងហើយ ក៏ត្រូវរលំ (ដួល) ដូច្នោះ; ភវចក្រនេះ បណ្ឌិតគប្បីជ្រាប**ដោយការឧបមាទាំងឡាយ** តាមសមគួរ មានប្រការដូច្នេះ ៕

## គប្បីជ្រាបសេចក្តីជាភវចក្រដោយប្រភេទនៃសេចក្តីជ្រាលជ្រៅ

ម្យ៉ាងទៀត ព្រោះព្រះមានព្រភាគទ្រង់សំដៅយកសេចក្តីជ្រាលជ្រៅដោយអត្ថខ្លះ, ធម៌ខ្លះ, ទេសនាខ្លះ និងដោយការចាក់ធ្លុះខ្លះ ទើបត្រាស់ថា "ម្នាលអានន្ទ

បដិច្ចសមុប្បាទនេះ ជាធម៌ជ្រាលជ្រៅ ទាំងមានខ្សែ (អត្ថ) ជ្រាលជ្រៅ"[៦៥] ព្រោះហេតុនោះ សូម្បីភវចក្រនេះ បណ្ឌិតគប្បីជ្រាបដោយប្រភេទនៃសេចក្ដីជ្រាលជ្រៅតាមសមគួរ ។

ក្នុងសេចក្ដីជ្រាលជ្រៅ ដោយអត្ថជាដើមនោះ ព្រោះជរា និងមរណៈ នឹងមិនមានមកពីជាតិ (ការកើត) ក៏មិនមែន, វៀរជាតិចេញហើយ ក៏រមែងមិនកើតអំពីវត្ថុដទៃ, និងរមែងប្រាកដព្រោះជាតិដោយពិត, ព្រោះហេតុដូច្នោះ អត្ថថា កើត និងប្រាកដ ព្រោះជាតិជាបច្ច័យដល់ជរា និងមរណៈ ទើបឈ្មោះថា **ជ្រាលជ្រៅ**; ព្រោះអត្ថថា ប្រាកដឡើង ព្រោះមានជាតិជាបច្ច័យ ដែលសត្វត្រាស់ដឹងបានដោយលំបាក ដោយប្រការដូច្នេះ ។ អត្ថថា **កើតមាន និងប្រាកដ** ព្រោះភពជាបច្ច័យដល់ជាតិ ។ ល ។ ព្រោះអវិជ្ជាជាបច្ច័យដល់សង្ខារទាំងឡាយ ក៏ឈ្មោះថា **ជ្រាលជ្រៅ** ព្រោះហេតុដូច្នេះ ភវចក្រនេះ ឈ្មោះថា **ជ្រាលជ្រៅដោយអត្ថ**, នេះជាសេចក្ដីជ្រាលជ្រៅដោយអត្ថ ក្នុងភវចក្រនេះជាមុនសិន ។

ក៏ផលដែលកើតពីហេតុ ត្រាស់ហៅថា អត្ថ; ដូចយ៉ាងដែលត្រាស់ថា "**ញាណ** (ការដឹង) ក្នុងផលរបស់ហេតុ ឈ្មោះថា **អត្ថប្បដិសម្ភិទា**"[៦៦] ជាដើម ។

ម្យ៉ាងទៀត ព្រោះអវិជ្ជាមានកិរិយាដែលតាំងចុះយ៉ាងណា ដោយអាការណា ទើបជាបច្ច័យដល់សង្ខារទាំងនោះៗ, អត្ថថា ជាបច្ច័យដល់សង្ខារទាំងឡាយរបស់អវិជ្ជា ព្រោះកិរិយា និងអាការនោះ ដែលសត្វត្រាស់ដឹងបានដោយលំបាក

---

[៦៥] សំ. និទាន. ។

[៦៦] អភិ. ។

ទើបឈ្មោះថា **ជ្រាលជ្រៅ**; អត្ថថា ជាបច្ច័យដល់វិញ្ញាណ របស់សង្ខារទាំងឡាយ ។ ល ។ អត្ថថា ជាបច្ច័យដល់ជរា និងមរណៈរបស់ជាតិ ក៏ឈ្មោះថា **ជ្រាលជ្រៅ** ដូចគ្នា; ព្រោះហេតុដូច្នោះ ភវចក្រនេះ ទើបឈ្មោះថា **ជ្រាលជ្រៅដោយធម៌**, នេះ ជាសេចក្តីជ្រាលជ្រៅដោយធម៌ក្នុងភវចក្រនេះ ។

ក៏ពាក្យថា **ធម៌** នេះ ជាឈ្មោះរបស់ហេតុ; ដូចយ៉ាងដែលត្រាស់ថា **“ញាណ** គឺសេចក្តីដឹងក្នុងហេតុ ឈ្មោះថា ធម្មប្បដិសម្ភិទា” ជាដើម, ម្យ៉ាងទៀត ព្រោះសូម្បីទេសនានូវភវចក្រនោះ ក៏ឈ្មោះថា **ជ្រាលជ្រៅ** ព្រោះព្រះអង្គទ្រង់ឱ្យប្រព្រឹត្តទៅដោយហេតុនោះៗ ដោយប្រការនោះៗ ញាណដទៃៗ ក្រៅអំពីសព្វញ្ញុតញ្ញាណហើយ រមែងមិនស្ទាត់ជំនាញក្នុងទេសនានេះ; ព្រោះភវចក្រនេះ ក្នុងសូត្រខ្លះទ្រង់សម្តែងដោយអនុលោម, កន្លែងខ្លះ សម្តែងដោយបដិលោម, កន្លែងខ្លះទ្រង់សម្តែងទាំងអនុ-លោម និងបដិលោម, កន្លែងខ្លះ ទ្រង់សម្តែងដោយអនុលោមខ្លះ បដិលោមខ្លះ តាំងពីពាក់កណ្តាលទៅ; កន្លែងខ្លះ ក៏ទ្រង់សម្តែងជាសន្ធិ ៣ និងសង្ខេប ៤, កន្លែងខ្លះ ទ្រង់សម្តែងសន្ធិ ២ និងសង្ខេប ៣, កន្លែងខ្លះ ទ្រង់សម្តែងសន្ធិ ១ និងសង្ខេប ២; ព្រោះហេតុដូច្នោះ ភវចក្រនេះ ទើបឈ្មោះថា **ជ្រាលជ្រៅដោយទេសនា** នេះជាសេចក្តីជ្រាលជ្រៅដោយទេសនា មានប្រការដូច្នេះ ។

ម្យ៉ាងទៀត ព្រោះក្នុងភវចក្រនេះ សភាវៈនៃធម៌មានអវិជ្ជាជាដើម យ៉ាងណា, ធម៌មានអវិជ្ជាជាដើម រមែងជាធម៌ដែលបុគ្គលចាក់ធ្លុះដោយលក្ខណៈរបស់ខ្លួនដោយការចាក់ធ្លុះឯណា, សភាវៈនោះ ឈ្មោះថា ជ្រាលជ្រៅ ព្រោះស្ទាបស្ទង់បានដោយលំបាក; ព្រោះហេតុដូច្នោះ ភវចក្រនេះ ទើបឈ្មោះថា **ជ្រាលជ្រៅដោយការ**

ចាក់ធ្លុះ; ព្រោះក្នុងភវចក្រនេះ អត្ថនៃអវិជ្ជាជាអញ្ញាណ គឺការមិនដឹង ជាអទស្សនៈ (ការមិនឃើញ) និងការចាក់ធ្លុះនូវសច្ចៈ ជាអត្ថដ៏ជ្រាលជ្រៅ។ អត្ថនៃសង្ខារទាំង-ឡាយថា សភាពតាក់តែង ការប្រកបកម្ម ប្រព្រឹត្តទៅជាមួយរាគៈ និងប្រាសចាករាគៈ ជាអត្ថដ៏ជ្រាលជ្រៅ។ អត្ថនៃវិញ្ញាណថា សុញ្ញតៈ (សូន្យទទេ) មិនខ្វល់ខ្វាយមិនឃ្លាតទៅ និងប្រាកដទៅជាបដិសន្ធិ ជាអត្ថដ៏ជ្រាលជ្រៅ ។ អត្ថនៃនាមរូបថាសភាពកើតព្រមគ្នា ញែកគ្នាបាន ញែកគ្នាមិនបាន បង្អោនទៅ និងប្រែប្រួលទៅ ជាអត្ថដ៏ជ្រាលជ្រៅ។ អត្ថនៃសឡាយតនៈថា អធិបតី (ជាធំក្រៃលែង) ជាលោក ជាទ្វារ ជាខេត្ត និងជាអារម្មណ៍ ជាអត្ថដ៏ជ្រាលជ្រៅ។ អត្ថនៃផស្សៈថា ការពាល់ត្រូវការខ្ទប់ ការជួប និងការប្រជុំ ជាអត្ថដ៏ជ្រាលជ្រៅ ។ អត្ថនៃវេទនាថា ការសោយអារម្មណ៍ជាសុខ ជាទុក្ខ ការនៅព្រងើយ និងសោយអារម្មណ៍ដែលមិន មានជីវៈ ជាអត្ថដ៏ជ្រាលជ្រៅ។ អត្ថនៃតណ្ហាថា ការភ្លើតភ្លើន ការប្រាថ្នានូវសេចក្តីភ្លើតភ្លើននោះជារបស់ឱ្យពេញបានដោយលំបាក ដូចខ្សែទឹក ស្ទឹង ទន្លេ, តណ្ហា គឺសមុទ្រ ជាអត្ថដ៏ជ្រាលជ្រៅ ។ អត្ថនៃឧបាទានថា ការប្រតោង ការប្រកាន់យក ការប្រកាន់មាំ ការស្ទាបអង្អែល ឈានកន្លងតណ្ហាបានដោយលំបាក ជាអត្ថដ៏ជ្រាលជ្រៅ។ អត្ថនៃភពថា ការរសាត់ទៅក្នុងកំណើត គតិ វិញ្ញាណដ្ឋិតិ សត្តាវាស ព្រោះការប្រជុំតាក់តែងនៃការធ្វើកម្ម ជាអត្ថដ៏ជ្រាលជ្រៅ។ អត្ថនៃជាតិថា ការកើតមាន ការកើតមានព្រម ការឈានចូល ការបង្កើត និងការប្រាកដ ជាអត្ថដ៏ជ្រាលជ្រៅ។ អត្ថនៃជរានិងមរណៈថា ការអស់ ការវិនាស ការបែកធ្លាយ និងការប្រែប្រួល ជាអត្ថដ៏ជ្រាលជ្រៅ ដោយការចាក់ធ្លុះក្នុងភវចក្រនេះ មានប្រការដូច្នេះ ៕

## គប្បីជ្រាបសេចក្តីជាភវចក្រដោយប្រភេទនៃន័យ

ម្យ៉ាងទៀត ក្នុងភវចក្រនេះ មានអត្ថន័យ ៤ គឺ

- **ឯកត្តន័យ** ន័យដែលមានអត្ថជាមួយគ្នា
- **នានត្តន័យ** ន័យដែលមានអត្ថផ្សេងគ្នា
- **អព្យាបារន័យ** ន័យដែលមិនមានការខ្វល់ខ្វាយ
- **ឯវំ ធម្មតាន័យ** ន័យដែលមានយ៉ាងនេះជាធម្មតា ។

ព្រោះហេតុដូច្នោះ គប្បីជ្រាបភវចក្រនេះ សូម្បីដោយន័យផ្សេងៗ តាមសមគួរចុះ ។

បណ្ដាន័យទាំង ៤ នេះ ការមិនដាច់នៃសន្តាន (ការបន្ត) ដូចកាលដែលគ្រាប់ពូជកើតជាដើមឈើ ដោយការមានពន្លកជាដើម យ៉ាងនេះ គឺព្រោះអវិជ្ជាជាបច្ច័យ ទើបកើតមានសង្ខារទាំងឡាយ, ព្រោះសង្ខារជាបច្ច័យ ទើបកើតមានវិញ្ញាណដូច្នេះជាដើម ទើបឈ្មោះថា **ឯកត្តន័យ**។ កាលព្រះយោគាវចរឃើញភវចក្រដ៏ប្រសើរ រមែងលះឧច្ឆេទទិដ្ឋិបាន ព្រោះត្រាស់ដឹងនូវការមិនដាច់ទៅនៃការបន្តដែលប្រព្រឹត្តទៅដោយការទាក់ទងគ្នាទាំងហេតុ និងផល, កាលឃើញខុសរមែងប្រកាន់សស្សតទិដ្ឋិដោយការប្រកាន់ជាមួយគ្នា មិនមានកំណត់នៃការបន្ត ដែលកំពុងប្រព្រឹត្តទៅដោយការពាក់ព័ន្ធគ្នានូវហេតុ និងផល ។

ចំណែកការកំណត់លក្ខណៈនៃភវចក្រ មានអវិជ្ជាជាដើម តាមភាវៈរបស់ខ្លួន ឈ្មោះថា **នានត្តន័យ**; កាលព្រះយោគាវចរឃើញភវចក្រដោយប្រពៃ រមែងលះសស្សតទិដ្ឋិបាន ព្រោះឃើញការកើតឡើងនៃសភាវៈថ្មីៗ, កាលយល់ឃើញខុស

រមែងប្រកាន់ដោយឧច្ឆេទទិដ្ឋិ ព្រោះប្រកាន់សេចក្តីផ្សេងគ្នា នៃការបន្តដែលបែកទៅ ព្រោះធ្លាក់ទៅក្នុងសន្តានតែមួយនោះឯង ។

ការដែលអវិជ្ជាមិនមានសេចក្តីខ្វាយខ្វល់ថា សង្ខារទាំងឡាយ ដែលយើងគប្បីឱ្យកើតមានឡើង, ឬការដែលសង្ខារទាំងឡាយ មិនមានសេចក្តីខ្វាយខ្វល់ថា "វិញ្ញាណដែលពួកយើងគប្បីឱ្យកើតមានឡើង" ដូច្នេះជាដើម ដោយប្រការដូច្នេះ ឈ្មោះថា **អព្យាបារន័យ**, កាលព្រះយោគាវចរយល់ឃើញដោយប្រពៃ រមែងលះអត្តទិដ្ឋិ ព្រោះយល់ឃើញថាមិនមានអ្នកសាង, កាលយល់ឃើញខុសរមែងប្រកាន់អកិរិយទិដ្ឋិ ព្រោះការមិនប្រកាន់ហេតុ ដែលសម្រេចដោយការកំណត់សភាវៈនៃអវិជ្ជាជាដើម ព្រោះមិនមានសេចក្តីខ្វាយខ្វល់នោះឯង ។

ម្យ៉ាងទៀត ការកើតឡើងនៃធម៌មានសង្ខារជាដើម ដោយហេតុទាំងឡាយមានអវិជ្ជាជាដើម មិនមែនជាធម៌ពួកដទៃ ដូចធម្មជាតិនៃទឹកដោះជូរជាដើម កើតពីទឹកដោះស្រស់ជាដើមដូច្នោះ នេះ ឈ្មោះថា **ឯវំ ធម្មតាន័យ**, កាលព្រះយោគីយល់ឃើញដោយប្រពៃ រមែងលះអហេតុកទិដ្ឋិ និងអកិរិយទិដ្ឋិបាន ព្រោះនៅដឹងផលដ៏សមគួរដល់បច្ច័យ, កាលយល់ឃើញខុសរមែងប្រកាន់អហេតុកទិដ្ឋិ និងនិយតវាទៈ (ការឃើញថាទៀង) ព្រោះមិនប្រកាន់យកសេចក្តីប្រព្រឹត្តទៅនៃផល ដែលគួរដល់បច្ច័យ មិនប្រកាន់ការកើតរបស់សភាវៈអ្វីៗ ពីទីណាៗ ឡើយ ព្រោះហេតុដូច្នោះ ភវចក្រនេះ ៖

**បណ្ឌិតគប្បីជ្រាបដោយភាពជាសច្ចៈ និងជាដែនកើតនៃសច្ចៈ ១, ដោយកិច្ច ១, ដោយការហាម ១, ដោយឧបមា ១, ដោយប្រភេទដែល**

ជ្រាលជ្រៅ ១ និងដោយប្រភេទនៃន័យ ១ តាមសមគួរ មានប្រការដូច្នេះ ។

ពិតណាស់ ភវចក្រ ឈ្មោះថា **ស្ទានមិនដល់** ព្រោះជ្រាលជ្រៅ ឈ្មោះថា **ឈានកន្លងបានដោយលំបាក** ព្រោះត្រូវសិក្សាដោយន័យផ្សេងៗ នរណាៗ នៅមិនទាន់ទម្លាយភវចក្រ (ការវិលទៅនៃភព) ដែលញាំញីជានិច្ច ដូចអសនីបាត ដោយដាវ គឺញាណដែលសំលៀងល្អហើយ លើថ្ម គឺសមាធិដ៏ប្រសើរ ហើយនឹងឆ្លងផុតភ័យ គឺសង្សារ រមែងមិនមានសូម្បីក្នុងចន្លោះនៃការយល់សប្តិបានឡើយ; សេចក្តីនេះ សមដូចព្រះតម្រាស់ដែលព្រះមានព្រះភាគត្រាស់ទុកថា **"ម្នាលអានន្ទ បដិច្ច-សមុប្បាទនេះ ជាធម៌ជ្រាលជ្រៅ ទាំងមានខ្សែ (អត្ថ) សេចក្តីជ្រាលជ្រៅ, ម្នាលអានន្ទ ព្រោះមិនដឹង មិនត្រាស់ដឹង មិនចាក់ធ្លុះធម៌នេះ ពួកសត្វនេះទើបជាអ្នកពាក់ព័ន្ធ ដូចសរសៃអំបោះរបស់ជាងតម្បាញ កើតជាចំណងកញ្ចុំសរសៃអំបោះ ដូចជាស្មៅដំណេកទន្សាយ និងស្មៅយ៉ាប្លង រមែងមិនកន្លងផុតអបាយ ទុគ្គតិ វិនិបាត សង្សារ"**[៦៧]; ព្រោះហេតុដូច្នោះ បណ្ឌិតក្នុងលោកនេះ ដែលបដិបត្តិដើម្បីប្រយោជន៍ ដើម្បីសេចក្តីសុខដល់ខ្លួន ឬដល់ជនពួកដទៃគប្បីលះកិច្ចដែលសល់ហើយ ៖

គប្បីជាអ្នកមានសតិគ្រប់កាល ប្រកបសេចក្តី
ព្យាយាមរឿយៗ ក៏នឹងគប្បីបានការឈានចុះ ក្នុង
ប្រភេទនៃបច្ចយាការ ដ៏ជ្រាលជ្រៅនេះបាន ៕

ចប់ការពណ៌នាអំពីសុត្តន្តភាជនិយ

[៦៧] សំ. និ. ៣១, ទី. ម. ។

## ពណ៌នាអំពីអភិធម្មភាជនិយ

ព្រះសាស្ដាមានព្រះញាណដែលមិនមានអ្វីរារាំង ក្នុងធម៌ទាំងពួង គ្រាទ្រង់សម្ដែងបច្ចយាការដែលប្រាសចាកការសាំញ៉ាំ និងមិនស្មុគស្មាញក្នុងសុត្តន្តភាជនិយ ដោយអំណាចនៃចិត្តផ្សេង១ ដូចទ្រង់លាតផ្ទៃមហាបឋវី និងដូចទ្រង់ពង្រីកនភាកាស ដោយប្រការដូច្នេះហើយ ឥឡូវនេះ ព្រោះបច្ចយាការនេះ នឹងមានក្នុងចិត្តផ្សេង១ គ្នាតែម្យ៉ាងប៉ុណ្ណោះ ក៏មិនមែន, តែមានសូម្បីក្នុងចិត្តមួយខណៈមែនពិត, ព្រោះហេតុដូច្នោះ ដើម្បីនឹងទ្រង់សម្ដែងបច្ចយាការ ដែលកើតក្នុងខណៈចិត្តដួងជាមួយគ្នា ដោយប្រការផ្សេង១ ដោយអំណាចនៃអភិធម្មភាជនិយ ទើបទ្រង់តាំងមាតិកាទុកមុន ដោយន័យមានជាអាទិ៍ថា “**អវិជ្ជាបច្ចយា សង្ខារោ** = សង្ខារកើតមាន ព្រោះអវិជ្ជាជាបច្ច័យ” ។ ក៏មាតិកាដែលទ្រង់តាំងទុក យ៉ាងនេះថា ៖

**អវិជ្ជាទីហិ មូលេហិ នវ មូលបទានវ**
**នយា តត្ថចតុក្កានិ វារភេទញ្ច ទីបយេ**

**បណ្ឌិតគប្បីសម្ដែងពួក ៤ (នៃបច្ច័យ)**
**គឺប្រភេទនៃវារៈក្នុងន័យទាំង ៩ ដែលមាន**
**៥ បទនៃមូលទាំង ៩ មានអវិជ្ជាជាដើម ៕**

## អធិប្បាយន័យរបស់មាតិកាមានអវិជ្ជាជាមូល

ក្នុងគាថានោះ មានការអធិប្បាយដូចតទៅនេះ ៖

ពិតណាស់ ក្នុងបដិច្ចសមុប្បាទនេះ មាន ៩ ន័យ មានបទដែលជាមូល ៩

បទនេះ គឺ មានអវិជ្ជាជាដើម ១, មានសង្ខារជាដើម ១, មានវិញ្ញាណជាដើម ១, មាននាមជាដើម ១, មានអាយតនៈ ៦ ជាដើម ១, មានផស្សៈជាដើម ១, មានវេទនាជាដើម ១, មានតណ្ហាជាដើម ១ និងមានឧបាទានជាដើម ១; ដោយបទដែលជាមូល ៩ បទ មានអវិជ្ជាជាដើម គឺ ដោយប្រភេទនៃអវិជ្ជា សង្ខារ វិញ្ញាណ នាម អាយតនៈទី ៦ ផស្សៈ វេទនា តណ្ហា និងឧបាទាន ។

បណ្ដាន័យទាំង ៩ នោះ ន័យមានអវិជ្ជាជាដើមជាមុនសិន ក្នុងន័យនេះ ដែលមានអវិជ្ជាជាដើមនោះ មានចតុក្កៈ ៤ គឺ

- **បច្ចយចតុក្កៈ** ពួក ៤ កំណត់ដោយបច្ចយធម៌
- **ហេតុចតុក្កៈ** ពួក ៤ កំណត់ដោយហេតុធម៌
- **សម្បយុត្តចតុក្កៈ** ពួក ៤ កំណត់ដោយសម្បយុត្តធម៌
- **អញ្ញមញ្ញចតុក្កៈ** ពួក ៤ កំណត់ដោយអញ្ញមញ្ញធម៌ ។

សូម្បីន័យដ៏សេស ក៏ដូចក្នុងន័យមានអវិជ្ជានេះដែរ ព្រោះហេតុដូច្នោះ ក្នុង ១ ន័យៗ ទើបរួមជា ៣៦ ចតុក្កៈ ដោយអំណាចនៃចតុក្កៈ ៤។ បណ្ដាចតុក្កៈទាំងនោះ ព្រោះរួមវារៈម្យ៉ាងៗ ៤ ដោយតែមួយចតុក្កៈៗ ទើបជា ១៦ វារៈ ក្នុង ១ ន័យ ដោយអំណាចនៃចតុក្កៈទាំង ៤ នោះ គប្បីជ្រាបថា ជា ១៤៤ វារៈ ៕

## សម្ដែងអំពីបច្ច័យចតុក្កៈ

បណ្ដាចតុក្កៈទាំង ៤ នោះ បច្ច័យចតុក្កៈក្នុងន័យមានអវិជ្ជាជាមូលមុនជាងន័យទាំងអស់នេះសិន, ក្នុងបច្ចយចតុក្កៈនោះ វារៈទី ១ ឈ្មោះថា **ឯកមូលកន័យ** =

វារៈប្រកបដោយអង្គ ១២, ប្រកបដោយអង្គ ២ មិនបរិបូណ៌ ព្រោះត្រាស់នាមទុកក្នុងកន្លែងនៃនាមរូប និងត្រាស់អាយតនៈ ៦ ទុកក្នុងកន្លែងនៃសឡាយតនៈ។ វារៈទី ២ ឈ្មោះថា **ឯកាទសង្គិកវារៈ** = វារៈប្រកបដោយអង្គ ១១, ដែលប្រកបដោយអង្គ ១ មិនបរិបូណ៌ ព្រោះត្រាស់នាមតែម្យ៉ាង ក្នុងកន្លែងនៃនាមរូប និងមិនត្រាស់អង្គអ្វីៗ ក្នុងកន្លែងនៃសឡាយតនៈ។ វារៈទី ៣ ឈ្មោះថា **ទ្វាទសង្គិកវារៈ** = វារៈប្រកបដោយអង្គ ១២, ប្រកបដោយអង្គ ១ មិនបរិបូណ៌ ព្រោះត្រាស់អាយតនៈទី ៦ ទុកក្នុងកន្លែងនៃសឡាយតនៈ; តែវារៈទី ៤ មានអង្គ ១២ បរិបូណ៌ហើយមែនពិត។

ក្នុងសេចក្តីនេះ ប្រសិនបើមានការសង្ស័យថា សូម្បីវារៈទី ៣ នេះ ក៏ប្រកបដោយអង្គមិនបរិបូណ៌ដូចគ្នា ព្រោះត្រាស់ថា **“ឆដ្ឋាយតនប្បច្ចយា ផស្សោ** = ផស្សៈកើតមាន ព្រោះអាយតនៈទី ៦ ជាបច្ច័យ” , សេចក្តីនេះ សូមឆ្លើយថា មិនមែនដូច្នោះទេ ព្រោះអាយតនៈទី ៦ នោះ មិនមែនជាអង្គ; សេចក្តីពិត ផស្សៈតែម្យ៉ាងប៉ុណ្ណោះ ជាអង្គក្នុងវារៈទី ៣ នេះ, មិនមែនអាយតនៈ ៦ ជាអង្គទេ; ព្រោះហេតុដូច្នោះ វារៈទី ៣ នេះ មិនមែនប្រកបអង្គ ១ បរិបូណ៌ទេ ព្រោះអាយតនៈទី ៦ នោះ មិនមែនជាអង្គដូច្នោះឡើយ ។ ម្យ៉ាង ក្នុងអដ្ឋកថាលោកពោលថា “វារៈទី ១ ព្រះអង្គទ្រង់កាន់យក ដោយអត្ថថា ទ្រង់រួបរួមអង្គទុកទាំងអស់, វារៈទី ២ ទ្រង់កាន់យក ដោយអត្ថថា ជាសេចក្តីផ្សេងគ្នានៃបច្ច័យ, វារៈទី ៣ ទ្រង់កាន់យកដោយអំណាចនៃសត្វដែលកើតមានក្នុងគភ៌, វារៈទី ៤ ទ្រង់កាន់យកដោយអំណាចនៃសត្វជាឱបបាតិកៈ, ម្យ៉ាងទៀត វារៈទី ១ ទ្រង់កាន់យកដោយអត្ថថា ការរួបរួមអង្គទុកទាំងអស់, វារៈទី ២ ទ្រង់កាន់យកដោយអត្ថថា សេចក្តីផ្សេងគ្នានៃបច្ច័យ, វារៈទី

៣ ទ្រង់កាន់យកដោយអំណាចនៃសត្វមានអាយតនៈមិនបរិបូណ៌, វារៈទី ៤ ទ្រង់កាន់យកដោយអំណាចនៃសត្វមានអាយតនៈបរិបូណ៌ ។ ម្យ៉ាងវិញទៀត វារៈទី ១ ទ្រង់កាន់យកដោយអត្ថថា រួបរួមអង្គទាំងអស់នោះឯង, វារៈទី ២ ទ្រង់កាន់យកដោយអំណាចនៃ**មហានិទានសូត្រ**, វារៈទី ៣ ទ្រង់កាន់យកដោយអំណាចនៃរូបភព, វារៈទី ៤ ទ្រង់កាន់យកដោយអំណាចនៃកម្មភព" ។

បណ្ដាវារៈទាំង ៤ នោះ វារៈទី ១ ត្រាស់ថា **សព្វសង្គាហិក** = រួបរួមអង្គទុកទាំងអស់ ព្រោះក្នុងវារៈទាំង ៣ មានវារៈទី ២ ជាដើមនេះ នឹងមិនរួមចូលទៅក្នុងទីណា ៗ ឡើយ; សេចក្ដីផ្សេងគ្នាក្នុងវារៈដែលនៅសល់ នឹងជាក់ច្បាស់ខាងមុខ ។ ដើម្បីសេចក្ដីជាក់ច្បាស់នៃវារៈទី ១ នោះ គប្បីជ្រាបថា ៖

> អង្គបដិច្ចសមុប្បាទណា ក្នុងវារៈណា ដែលត្រាស់ដោយប្រការដទៃ និងសូម្បីអង្គបដិច្ចសមុប្បាទណា ដែលមិនត្រាស់ទុកក្នុងវារៈណា អង្គបដិច្ចសមុប្បាទណា ជាបច្ច័យដល់អង្គបដិច្ចសមុប្បាទណា ដោយប្រការណា គប្បីចូលទៅកំណត់អង្គទាំងអស់នោះចុះ ។

**ក្នុងគាថានោះ មានន័យដូចតទៅនេះ ៖**

ពោលអំពីសេចក្ដីមិនផ្សេងគ្នាជាមុនសិន ។ **សួរថា** បណ្ដាវារៈទាំង ៤ នេះ ព្រះភគវាមិនបានត្រាស់ថា "**សង្ខារា** = សង្ខារទាំងឡាយ" ដូចក្នុងសុត្តន្តភាជនិយទេ, តែត្រាស់ថា "**សង្ខារោ** = សង្ខារ", នោះព្រោះហេតុអ្វី ?

ឆ្លើយថា ព្រោះសង្ខារប្រកបដោយខណៈនៃចិត្តមួយ; ពិតណាស់ ក្នុងសុត្តន្ត-ភាជនិយនោះ ទ្រង់ចែកបច្ចយាការដែលប្រព្រឹត្តទៅក្នុងខណៈនៃចិត្តផ្សេងៗ គ្នា, ក្នុងអភិធម្មភាជនិយនេះ ទ្រង់ប្រារព្ធបច្ចយាការដែលប្រព្រឹត្តទៅក្នុងខណៈតែមួយ; ក៏ក្នុងខណៈនៃចិត្តជាមួយគ្នា រមែងមិនមានចេតនា (គឺសង្ខារ) ច្រើន ទើបមិនត្រាស់ថា "**សង្ខារា** = សង្ខារទាំងឡាយ" , តែត្រាស់ថា "**សង្ខារោ** = សង្ខារ គឺចេតនា"។

ម្យ៉ាងទៀត បណ្ដាវារៈទាំងនេះ ក្នុងវារៈទី ១ ទ្រង់លះចោលរូបចេញ ត្រាស់ថា "**វិញ្ញាណប្បច្ចយោ នាមំ** = នាមប៉ុណ្ណោះមានវិញ្ញាណជាបច្ច័យ" ព្រោះទ្រង់រួបរួមធម៌ដែលរាប់បញ្ចូលក្នុងខណៈនៃចិត្តមួយ និងព្រោះជាធម៌សាធារណៈទៅក្នុងទីទាំងអស់។ ពិតណាស់ នាមធម៌នោះ រាប់ខាងក្នុងខណៈចិត្តជាមួយគ្នា និងជាធម៌សាធារណៈទៅក្នុងទីទាំងអស់, តែមិនប្រព្រឹត្តទៅក្នុងខណៈនៃការបន្តរបស់វិញ្ញាណក្នុងទីណាៗ មិនមានឡើយ; ក៏ព្រោះវារៈទី ១ នេះ ផស្សៈក៏មានមួយប៉ុណ្ណោះ រាប់បញ្ចូលក្នុងខណៈនៃចិត្តជាមួយគ្នា, ព្រោះហេតុដូច្នោះ កាលទ្រង់កាន់យកអាយតនៈដែលជាបច្ច័យ ដ៏សមគួរដល់ផស្សៈនោះ ទើបត្រាស់ **មនាយតនៈ**មួយប៉ុណ្ណោះថា "**នាមប្បច្ចយា ឆដ្ឋាយតនំ** = អាយតនៈទី ៦ កើតមាន ព្រោះនាមជាបច្ច័យ" ទុកក្នុងឋាននៃសឡាយតនៈ; ព្រោះថា មនាយតនៈនោះ ជាបច្ច័យដ៏សមគួរដល់ផស្សៈដែលជាអកុសលមួយដួង; ឯមនាយតនៈនេះ ក៏ត្រាស់ទុកក្នុងពាក្យនេះថា "**សង្ខារប្បច្ចយា វិញ្ញាណំ** = វិញ្ញាណកើតមាន ព្រោះសង្ខារជាបច្ច័យ" ក៏ពិត

មែន, តែដើម្បីទ្រង់សម្តែងសេចក្តីផ្សេងគ្នានៃហេតុ និងផល និងដើម្បីបង្គ្រប់អង្គ ទើបទ្រង់កាន់យកក្នុងទីនេះទៀត ។ ព្រោះក្នុងសុត្តន្តភាជនិយនោះ សង្ខារជាហេតុផ្សេងគ្នា ដល់មនាយតនៈនេះ, នាមជាផលដោយមិនផ្សេងគ្នា; តែក្នុងអភិធម្មភាជនិយនេះ នាម ជាហេតុដោយមិនផ្សេងគ្នាដល់មនាយតនៈនេះ, ផស្សៈជាផលដោយការផ្សេងគ្នា ។

ចំណែកធម៌ទាំងអស់ មានសេចក្តីសោកជាដើម ព្រោះមិនកើតក្នុងខណៈនៃចិត្តជាមួយគ្នា, មិនប្រព្រឹត្តទៅក្នុងឋាននៃចិត្ត និងក្នុងចិត្តទាំងអស់ ព្រោះហេតុដូច្នោះទើបទ្រង់មិនកាន់យក; តែជាតិ ជរា និងមរណៈ សូម្បីរាប់ប្រមាណខណៈនៃចិត្តមិនបាន ក៏ទ្រង់កាន់យកដើម្បីបង្គ្រប់អង្គ (នៃបច្ចយាការ) ដែរ ព្រោះបន្ថែមចូលទៅខាងក្នុងខណៈចិត្ត; ក្នុងវារៈទី ១ អង្គបដិច្ចសមុប្បាទណា ត្រាស់ដោយប្រការដទៃ និងអង្គបដិច្ចសមុប្បាទណា មិនត្រាស់ទុក; គប្បីជ្រាបអង្គបដិច្ចសមុប្បាទនោះ ដោយប្រការដូច្នេះជាមុន ។

ម្យ៉ាងទៀត ក្នុងវារៈនេះ អង្គបដិច្ចសមុប្បាទណា ដែលត្រាស់ទុកក្នុងវារៈដទៃពីវារៈទី ១ នេះ គប្បីជ្រាបអត្ថនៃអង្គបដិច្ចសមុប្បាទនោះ ដោយន័យដែលពោលហើយនោះឯង; តែសេចក្តីផ្សេងគ្នាណាៗ មកហើយក្នុងវារៈណាៗ ខ្ញុំនឹងប្រកាសអត្ថដែលផ្សេងគ្នានោះៗ ក្នុងវារៈនោះៗ ទាំងអស់ ។

ចំណែកក្នុងពាក្យថា **អង្គបដិច្ចសមុប្បាទណា ជាបច្ច័យដល់អង្គបដិច្ចសមុប្បាទណា ដោយប្រការណា** នេះ មានអធិប្បាយថា អវិជ្ជាជាបច្ច័យដល់សង្ខារ ៧ យ៉ាង គឺដោយបច្ច័យ ៦ យ៉ាង មានសហជាតប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ

និស្សយប្បច្ច័យ សម្បយុត្តប្បច្ច័យ អត្ថិប្បច្ច័យ និងអវិគតប្បច្ច័យ ដែលទូទៅដល់សម្បយុត្តធម៌ និងដោយហេតុប្បច្ច័យ ។ បណ្តាបច្ច័យទាំងនោះ ចតុក្កៈ ៣ មានហេតុចតុក្កៈជាដើម ខាងមុខត្រាស់ទុកដោយ អំណាចនៃអវិគតប្បច្ច័យ សម្បយុត្តប្បច្ច័យ និងអញ្ញមញ្ញប្បច្ច័យ, ព្រោះហេតុដូច្នោះ ក្នុងបច្ចយចតុក្កៈនេះ គប្បីនាំបច្ច័យទាំង ៣ នោះចេញហើយ គប្បីជ្រាបថា អវិជ្ជាជាបច្ច័យដល់សង្ខារ ៤ ដោយអំណាចនៃបច្ច័យដែលនៅសល់ ។

សង្ខារជាបច្ច័យដល់វិញ្ញាណ ៨ យ៉ាង គឺ ដោយបច្ច័យដែលជាសាធារណៈ ៦ យ៉ាង, ដោយកម្មប្បច្ច័យ ១ និងអាហារប្បច្ច័យ ១, តែក្នុងបច្ចយចតុក្កៈនេះ គប្បីនាំទាំង ៣ បច្ច័យនោះឯងចេញ ក៏គប្បីបានបច្ច័យសូម្បី ៥ យ៉ាង ។

វិញ្ញាណជាបច្ច័យដល់នាម ៩ យ៉ាង គឺដោយបច្ច័យដែលជាសាធារណប្បច្ច័យ ៦ យ៉ាង, ដោយឥន្ទ្រិយប្បច្ច័យ ១, អាហារប្បច្ច័យ ១ និងអធិបតិប្បច្ច័យ ១, តែក្នុងបច្ចយចតុក្កៈនេះ គប្បីនាំបច្ច័យទាំង ៣ នោះឯងចេញ គង់បានបច្ច័យ ៦ យ៉ាង ។

នាមជាបច្ច័យដល់អាយតនៈទី ៦ នេះ ដោយបច្ច័យដែលជាសាធារណៈ ៦ យ៉ាង, ពាក្យថា **នាមជាបច្ច័យដល់អាយតនៈទី ៦** នេះ នាមខ្លះ ជាបច្ច័យដល់អធិបតិប្បច្ច័យ, នាមខ្លះ ជាបច្ច័យដល់អាហារប្បច្ច័យ ព្រោះហេតុដូច្នោះ នាមទើបជាបច្ច័យបានច្រើនយ៉ាង; តែក្នុងបច្ចយចតុក្កៈនេះ គប្បីនាំយកបច្ច័យទាំង ៣ នោះឯងចេញហើយ គង់បានបច្ច័យ ៣ យ៉ាងខ្លះ ៤ យ៉ាងខ្លះ ៥ យ៉ាងខ្លះ។ អាយតនៈទី ៦ ជាបច្ច័យដល់ផស្សៈ ដូចវិញ្ញាណជាបច្ច័យដល់នាម។ ផស្សៈជាបច្ច័យដល់វេទនា ៧ យ៉ាង គឺ ដោយសាធារណប្បច្ច័យ ៦ យ៉ាង និងអាហារប្បច្ច័យ ១; តែក្នុងបច្ចយ-

ចតុក្កៈនេះ គប្បីនាំយកបច្ច័យទាំង ៣ នោះឯងចេញ គង់បានបច្ច័យ ៤ យ៉ាង ។

វេទនាជាបច្ច័យដល់តណ្ហា ៨ យ៉ាង គឺ ដោយសាធារណប្បច្ច័យ ៦ យ៉ាង ដោយឈានប្បច្ច័យ ១ និងឥន្ទ្រិយប្បច្ច័យ ១, តែក្នុងបច្ចយចតុក្កៈនេះ គប្បីនាំបច្ច័យទាំង ៣ នោះឯងចេញ គង់បានបច្ច័យ ៥ យ៉ាង ។

តណ្ហាជាបច្ច័យដល់ឧបាទាន ដូចអវិជ្ជាជាបច្ច័យដល់សង្ខារ, ឧបាទានជាបច្ច័យដល់ភព ៧ យ៉ាង គឺ ដោយសាធារណប្បច្ច័យ ៦ យ៉ាង និងដោយមគ្គប្បច្ច័យ ១, តែក្នុងបច្ចយចតុក្កៈនេះ គប្បីនាំបច្ច័យទាំង ៣ នោះឯងចេញ ក៏បានបច្ច័យ ៤ យ៉ាង ។

ភពជាបច្ច័យដល់ជាតិ ដោយឧបនិស្សយប្បច្ច័យប៉ុណ្ណោះ ដោយបរិយាយ (អម) ព្រោះក្នុងពាក្យថា **ជាតិ** នេះ ប្រាថ្នាយក**សង្ខតលក្ខណៈ** ជាតិជាបច្ច័យដល់ជរា និងមរណៈ ដោយឧបនិស្សយប្បច្ច័យតែម្យ៉ាងដូចគ្នា។ ចំណែកអាចារ្យពួកណាពោលយ៉ាងនេះថា "ក្នុងចតុក្កៈនេះ សូម្បីអវិជ្ជាទាំងអស់ជាបច្ច័យដល់សង្ខារជាដើម ដោយសហជាតប្បច្ច័យ; ព្រោះវារៈទី ១ ទ្រង់ផ្តើមដោយអំណាចនៃសហជាតប្បច្ច័យប៉ុណ្ណោះ" អាចារ្យពួកនោះ ដែលអ្នកណា។ គប្បីសម្តែងសេចក្តីមិនមាននៃភពជាដើមយ៉ាងនោះ និងសម្តែងការកើតឡើងនៃបច្ច័យដ៏សេសហើយ គប្បីបដិសេធ; ព្រោះភពមិនមែនជាសហជាតប្បច្ច័យដល់ជាតិ, ជាតិក៏មិនជាសហជាតប្បច្ច័យដល់ជរា និងមរណៈ; ចំណែកបច្ច័យណាដែលនៅសល់ ត្រាស់ទុកដល់សង្ខារជាដើមនោះ, សូម្បីបច្ច័យទាំងនោះ នៅមានមែនពិត; ព្រោះហេតុដូច្នោះ ទើបមិនអាចលះចោលចេញបាន ។

**អង្គបដិច្ចសមុប្បាទណា ក្នុងវារៈណា ដែលត្រាស់ទុកដោយប្រការដទៃ, និងសូម្បីអង្គបដិច្ចសមុប្បាទណា ដែលមិនត្រាស់ទុកក្នុងវារៈណា, អង្គ**

បដិច្ចសមុប្បាទណា ជាបច្ច័យដល់អង្គបដិច្ចសមុប្បាទណា ដោយប្រការណា, គប្បីជ្រាបថា អង្គបដិច្ចសមុប្បាទនោះ ជាបច្ច័យដល់អង្គបដិច្ចសមុប្បាទនោះ ដោយប្រការដូច្នេះ ក្នុងវារៈទី ១ យ៉ាងនេះសិន ។

សូម្បីក្នុងវារៈទី ២ ជាដើម ក៏មានន័យដូចគ្នានេះដែរ ៕

## សម្តែងអំពីសេចក្តីផ្សេងគ្នាក្នុងវារៈទី ២

ចំណែកសេចក្តីផ្សេងគ្នា គប្បីជ្រាបដូច្នេះ ៖

**សួរថា** ក្នុងវារៈទី ២ ត្រាស់ថា **“នាមប្បច្ចយា ផស្សោ** = ផស្សៈកើតមាន ព្រោះនាមជាបច្ច័យ” មិនបានត្រាស់ពាក្យអ្វីៗ ទុកក្នុងកន្លែងនៃសឡាយតនៈ, ពាក្យនោះ មិនបានត្រាស់ដើម្បីអ្វី ?

ឆ្លើយថា ដើម្បីសម្តែងសេចក្តីផ្សេងគ្នានៃបច្ច័យ និងដើម្បីសង្គ្រោះចូលដោយទេសនាក្នុង**មហានិទានសូត្រ** ។

ពិតណាស់ ប្រសិនបើ ផស្សៈមានសឡាយតនៈជាបច្ច័យតែម្យ៉ាងប៉ុណ្ណោះ ក៏មិនមែន, តាមពិត សូម្បីខន្ធ ៣ មានវេទនាខន្ធជាដើម ជាបច្ច័យតែម្យ៉ាង; ក៏ក្នុងមហានិទានសូត្រ ព្រះមានព្រះភាគត្រាស់បដិច្ចសមុប្បាទមានអង្គ ១១ ទ្រង់លះសឡាយតនៈចេញ យ៉ាងនេះថា “ម្នាលអានន្ទ កាលអ្នកត្រូវគេសួរថា ផស្សៈមានវត្ថុនេះជាបច្ច័យឬ ? អ្នកគប្បីឆ្លើយថា មាន; បើគេសួរថា ផស្សៈមាន

**អ្វីជាបច្ច័យ ? អ្នកគប្បីឆ្លើយថា មានរូបជាបច្ច័យ"** [៦៨] , ព្រោះហេតុដូច្នោះ ដើម្បីសម្តែងសេចក្តីផ្សេងគ្នានៃបច្ច័យនេះ និងដើម្បីទ្រង់កំណត់ទេសនាក្នុងមហា-និទានសូត្រនេះ ទើបត្រាស់ថា **"នាមប្បច្ចយា ផស្សោ"** ទុកក្នុងវារៈទី ២, មិនបាន ត្រាស់ពាក្យអ្វីៗ ទុកក្នុងកន្លែងនៃសឡាយតនៈ ។ នេះជាសេចក្តីផ្សេងគ្នាក្នុងទុតិយវារៈជាមុន ៕

## សម្តែងអំពីសេចក្តីផ្សេងគ្នាក្នុងវារៈទី ៣

ចំណែកក្នុងវារៈទី ៣ ត្រាស់អង្គទី ៤ ដែលមានមកក្នុងសុត្តន្តភាជនិយថា **"វិញ្ញាណប្បច្ចយា នាមរូបំ** = នាមរូបកើតមាន ព្រោះវិញ្ញាណជាបច្ច័យ" ។ ប្រសិនបើមានអ្នក**សួរថា** អង្គទី ៤ នោះ មិនគួរក្នុងបច្ចយចតុក្កៈនេះ ព្រោះការដែលបច្ចយាការប្រព្រឹត្តទៅក្នុងខណៈចិត្តមួយ ?, គប្បីឆ្លើយថា អង្គទី ៤ (នាមរូប) នោះ មិនគួរមិនបាន, ព្រោះហេតុអ្វី ?

ព្រោះជាបច្ច័យក្នុងលក្ខណៈរបស់ខ្លួន; ពិតមែន សូម្បីបើថា ក្នុងនាមរូបនោះ រូបនឹងតាំងនៅច្រើនជាងខណៈរបស់ចិត្ត, តែវិញ្ញាណនោះ ក៏ជាបច្ច័យដល់រូបនោះ ក្នុងលក្ខណៈរបស់ខ្លួន; សេចក្តីនេះជាយ៉ាងណា ? គឺខាងដើមវិញ្ញាណជាបច្ច័យដោយភាពជាបច្ច័យដល់រូប ដែលមានចិត្តជាសមុដ្ឋានដែលកើតមុនខ្លះ ដល់រូបដែលកើតខាងក្រោយខ្លះ; សេចក្តីនេះ សមនឹងព្រះតម្រាស់ដែលត្រាស់ថា **"បច្ឆាជាតា**

---

[៦៨] ទី. មហា. ។

**ចិត្តចេតសិកា ធម្មា បុរេជាតស្ស ឥមស្ស កាយស្ស បច្ឆាជាតប្បច្ចយេន បច្ចយោ** = ធម៌ គឺចិត្ត និងចេតសិក ដែលកើតខាងក្រោយ ជាបច្ច័យដល់កាយនេះ ដែលកើតមានក្នុងកាលមុន ដោយបច្ឆាជាតប្បច្ច័យ” [៦៩] ។ ម្យ៉ាងទៀត វិញ្ញាណនៅជា បច្ច័យដល់រូបដែលកើតព្រមគ្នា ដែលមានចិត្តជាសមុដ្ឋាន ដោយនិស្សយប្បច្ច័យ; ដូចដែលត្រាស់ថា “ធម៌ទាំងឡាយ គឺចិត្ត និងចេតសិក ជាបច្ច័យដល់រូបទាំងឡាយ ដែលមានចិត្តជាសមុដ្ឋាន ដោយនិស្សយប្បច្ច័យ” ។

**សួរថា** បើដូច្នោះ ព្រោះហេតុអ្វី ក្នុងវារៈដំបូង ទើបមិនត្រាស់យ៉ាងនេះ ?

ឆ្លើយថា ព្រោះទ្រង់សម្តែងសំដៅដល់កន្លែងដែលរូបប្រព្រឹត្តទៅ ។

ពិតណាស់ បច្ចយាការនេះ ព្រះអង្គទ្រង់សម្តែងក្នុងកម្មភព ជាកន្លែងដែលរូបប្រព្រឹត្តទៅ ដោយអំណាចនៃសត្វដែលកើតក្នុងគភ៌នៃឱបបាតិកៈ មានអាយតនៈមិនបរិបូណ៌ និងទេវតាក្នុងរូបាវចរ; ដោយហេតុនោះឯង ក្នុងវារៈទី ៣ នេះ ទើបមិនត្រាស់ថា “**នាមរូបប្បច្ចយា សឡាយតនំ** = សឡាយតនៈកើតមានព្រោះនាមរូបជាបច្ច័យ” , តែត្រាស់ថា “**ឆដ្ឋាយតនំ** = អាយតនៈទី ៦” ; ក្នុងនាមរូបនោះ **នាម** មានន័យតាមដែលពោលទុកក្នុងខាងក្រោយនោះឯង; ចំណែករូប គប្បីជ្រាបថា **ហទយរូប**; ហទយរូបនោះ ជាបច្ច័យដល់អាយតនៈទី ៦ នេះមាន ២ យ៉ាង គឺដោយនិស្សយប្បច្ច័យ និងបុរេជាតប្បច្ច័យ ។ នេះជាវារៈដែលផ្សេងគ្នាក្នុងវារៈទី ៣ ៕

---

[៦៩] អភិ. ។

## សម្តែងអំពីសេចក្តីផ្សេងគ្នាក្នុងវារៈទី ៤

ក៏វារៈទី ៤ ត្រាស់ទុកដោយអំណាចនៃពួកសត្វដែលជា **សំសេទជៈ** និង **ឱបបាតិកៈ** ដោយអំណាចនៃកំណើតពួកសត្វដែលមានអាយតនៈបរិបូណ៌ ដោយអំណាចនៃអាយតនៈពួកសត្វក្នុងកាមាវចរ ដោយអំណាចនៃភព; ដោយហេតុនោះឯង ក្នុងវារៈទី ៤ នេះ ទើបត្រាស់ថា "**នាមរូបប្បច្ចយា សឡាយតនំ** = សឡាយតនៈកើតមាន ព្រោះនាមរូបជាបច្ច័យ" ; ក្នុងនាមរូបនោះ នាមជាបច្ច័យដល់អាយតនៈទី ៦ ដោយសហជាតប្បច្ច័យជាដើម, ជាបច្ច័យដល់អាយតនៈ មានចក្ខាយតនៈជាដើម ដោយបច្ឆាជាតប្បច្ច័យ; បណ្តារូបទាំងឡាយ ហទយរូបជាបច្ច័យដល់អាយតនៈទី ៦ ដោយនិស្សយប្បច្ច័យ និងបុរេជាតប្បច្ច័យ, មហាភូតរូប ៤ ជាបច្ច័យដល់ចក្ខាយតនៈជាដើម ដោយសហជាតប្បច្ច័យ និស្សយៈ អត្ថិ និងអវិគតប្បច្ច័យ; ក៏ព្រោះបច្ចយាការនេះ ប្រព្រឹត្តទៅក្នុងខណៈចិត្តមួយ, ព្រោះហេតុដូច្នោះ ទើបមិនត្រាស់ក្នុងវារៈទី ៤ នេះថា "**សឡាយតនប្បច្ចយា** = ព្រោះសឡាយតនៈជាបច្ច័យ", ត្រាស់ថា "**ឆដ្ឋាយតនប្បច្ចយា ផស្សោ** = ផស្សៈកើតមាន ព្រោះអាយតនៈទី ៦ ជាបច្ច័យ" ។ នេះជាសេចក្តីផ្សេងគ្នាក្នុងវារៈទី ៤ ដោយប្រការដូច្នេះ ។

បណ្ឌិតកាលជ្រាបហេតុផ្សេងគ្នានៃវារៈទាំង ៤ នេះ យ៉ាងនេះហើយ គប្បីជ្រាបទៀតថា ក្នុងវារៈទាំង ៤ នោះឯង វារៈ ២ ខាងដើម ត្រាស់ដើម្បីសម្តែងបច្ចយាការក្នុងអរូបភព ព្រោះអង្គបដិច្ចសមុប្បាទដែលមិនលាយដោយរូប ដែលប្រព្រឹត្តទៅក្នុងអរូបភព។ វារៈទី ៣ ត្រាស់ទុកដើម្បីសម្តែងបច្ចយាការក្នុងរូបភព

ព្រោះថាកាលសេចក្ដីលាយច្រឡូកច្រឡំដោយរូបនៅមាន សឡាយតនៈក៏រមែងមិនប្រព្រឹត្តទៅក្នុងរូបភព ។ វារៈទី ៤ ត្រាស់ដើម្បីទ្រង់សម្ដែងបច្ចយាការក្នុងកម្មភព ព្រោះថា សឡាយតនៈទាំងអស់ រមែងប្រព្រឹត្តទៅក្នុងកម្មភព ។ ម្យ៉ាងទៀតក្នុងវារៈទី ៣ ត្រាស់សំដៅយកខណៈអកុសលប្រព្រឹត្តទៅដល់ពួកសត្វ ដែលមានអាយតនៈមិនបរិបូណ៌ក្នុងរូបភព និងកម្មភព; វារៈទី ៤ ត្រាស់សំដៅយកសត្វអ្នកមានអាយតនៈគ្រប់គ្រាន់ក្នុងកម្មភព ។

ន័យម្យ៉ាងទៀត វារៈទី ១ ត្រាស់សំដៅយកចិត្តដែលប្រព្រឹត្តទៅក្នុងកន្លែងទាំងអស់; ព្រោះថា វារៈទី ១ នោះ នឹងមិនប្រព្រឹត្តទៅក្នុងកន្លែងដែលចិត្តប្រព្រឹត្តទៅទីណាៗ មិនមានឡើយ ។

វារៈទី ២ ត្រាស់សំដៅយកភាពផ្សេងគ្នានៃបច្ច័យ; ព្រោះថា សភាវៈនៃវារៈមានអង្គ ១១ និងសភាវៈនៃផស្សៈមាននាមជាបច្ច័យ ជាសភាពផ្សេងគ្នានៃបច្ច័យក្នុងវារៈទី ២ នេះ។ វារៈទី ៣ ត្រាស់សំដៅយកកំណើត ២ ខាងដើម; ព្រោះថា វារៈទី ៣ នោះ រមែងមានក្នុងកំណើត ២ ខាងដើម ព្រោះសភាវៈនៃសឡាយតនៈមិនកើតគ្រប់កាលក្នុងកំណើត ២ ខាងដើមនោះទេ; វារៈទី ៤ ត្រាស់សំដៅយកកំណើត ២ ខាងក្រោយ; ព្រោះថា វារៈទី ៤ នោះ មិនមានក្នុងកំណើត ២ ខាងក្រោយ ព្រោះសភាវៈនៃសឡាយតនៈកើតមានឡើងគ្រប់កាល ក្នុងកំណើត ២ ខាងក្រោយនោះឯង ។

ក៏ដោយលំដាប់នៃពាក្យមានត្រឹមតែប៉ុណ្ណេះ អង្គណាដែលពោលទុកក្នុងវារៈ

ទាំង ៤ ថា ៖

"អង្គបដិច្ចសមុប្បាទណា ក្នុងវារៈណា ដែលត្រាស់ទុកដោយប្រការដទៃ និងសូម្បីអង្គបដិច្ចសមុប្បាទណា ដែលមិនត្រាស់ទុកក្នុងវារៈណា អង្គបដិច្ចសមុប្បាទណា ជាបច្ច័យដល់អង្គបដិច្ចសមុប្បាទណា ដោយប្រការណា គប្បីចូលទៅកំណត់អង្គទាំងអស់នោះ" , ការសម្ដែងសេចក្ដីនៃគាថា រមែងជាហេតុដែលខ្ញុំធ្វើហើយ ដោយប្រការដូច្នេះ ។

តអំពីចតុក្កៈនេះទៅ បណ្ឌិតគប្បីជ្រាបន័យទាំងអស់នេះ និងសេចក្ដីផ្សេងគ្នា សូម្បីក្នុងចតុក្កៈដទៃ ដោយទំនងនេះៗ ឯង ៕

## សម្ដែងអំពីហេតុចតុក្កៈ

បណ្ដាចតុក្កៈទាំងនោះ ន័យដែលត្រាស់ទុកក្នុងបច្ចយចតុក្កៈមុននោះ ប្រាកដច្បាស់ហើយក្នុងចតុក្កៈទាំងអស់មែនពិត; ចំណែកសេចក្ដីផ្សេងគ្នា ក្នុងហេតុចតុក្កៈជាដើម គប្បីជ្រាបក្នុងហេតុចតុក្កៈ យ៉ាងនេះជាមុនថា ៖

**អវិជ្ជា ហេតុ អស្សាតិ អវិជ្ជាហេតុកោ** = អវិជ្ជាជាហេតុនៃសង្ខារនេះ ព្រោះហេតុនោះ សង្ខារនេះ ទើបឈ្មោះថា **អវិជ្ជា ហេតុកោ** = មានអវិជ្ជាជាហេតុ, មានអធិប្បាយថា សង្ខារនេះមានអវិជ្ជាប្រព្រឹត្តទៅ គឺទៅរហូតដល់ខណៈរលត់ ព្រោះប្រព្រឹត្តទៅ (កើតមាន) ព្រមគ្នា ។

ម្យ៉ាងទៀត ព្រះអង្គកាលទ្រង់សម្ដែងថា អវិជ្ជាជាបច្ច័យដល់សង្ខារ ដោយសាធារណប្បច្ច័យ ដោយអំណាចនៃបច្ច័យ មានសហជាតប្បច្ច័យជាដើម ដោយព្រះ

តម្រាស់ត្រឹមតែប៉ុណ្ណេះថា “**អវិជ្ជាបច្ចយា** = ព្រោះអវិជ្ជាជាបច្ច័យ” ដូច្នេះហើយ ទើបទ្រង់សម្ដែងសភាវៈនៃអវិជ្ជា ជាអវិគតប្បច្ច័យដោយពិសេស ដោយព្រះតម្រាស់ថា “**អវិជ្ជាហេតុកោ** = មានអវិជ្ជាជាហេតុ” ទៀត ។ សូម្បីពាក្យមានជាអាទិ៍ថា “**សង្ខារប្បច្ចយា វិញ្ញាណំ សង្ខារហេតុកំ** = វិញ្ញាណមានសង្ខារជាហេតុកើតមាន ព្រោះសង្ខារជាបច្ច័យ” ក៏មានន័យដូចគ្នានេះដែរ ។

***សួរថា*** ក៏ព្រោះហេតុអ្វីក្នុងអង្គមានភពជាដើម ទើបទ្រង់មិនត្រាស់សព្ទថា **ហេតុចតុក្កៈ** ទុក ?

ឆ្លើយថា ព្រោះអង្គមានភពជាដើមនោះ មិនមានការកំណត់ដោយអវិគតប្បច្ច័យ និងព្រោះមិនមានអវិគតប្បច្ច័យ ។ ព្រោះពាក្យថា **តត្ថ** ក្នុងហេតុចតុក្កៈជាឈ្មោះរបស់ខន្ធ ៤ ដែលមានឧបាទានជាបច្ច័យ ដោយមានព្រះបាលីថា “**តត្ថ កតមោ ឧបាទានប្បច្ចយា ភវោ ។ បេ ។ អយំ វុច្ចតិ ឧបាទានប្បច្ចយា ភវោ** = ក្នុងព្រះបាលីនោះ ភពកើតមាន ព្រោះឧបាទានជាបច្ច័យ តើដូចម្ដេច ? វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ និងវិញ្ញាណក្ខន្ធ វៀរឧបាទាននេះចេញ ហៅថា ភពកើតមាន ព្រោះឧបាទានជាបច្ច័យ” ។ ម្យ៉ាងទៀត ជាតិ ជរា និងមរណៈ ក៏សង្គ្រោះចូលក្នុងសង្ខារក្ខន្ធដោយព្រះបាលីនេះ មានជាអាទិ៍ថា “**ជាតិ ទ្វីហិ ខន្ធេហិ សង្គហិតា** = ជាតិសង្គ្រោះចូលដោយខន្ធ ២” ។

ក្នុងព្រះបាលីនោះ ឧបាទានរមែងមិនជាអវិគតប្បច្ច័យ ដល់ភពដោយពិត ព្រោះការមិនបានជាតិ ជរា និងមរណៈ រហូតដល់វេលាដែលមានឧបាទាន, សភាពជាអវិគតប្បច្ច័យរមែងមិនកើតដល់ជាតិ ក្នុងសង្ខតលក្ខណៈទាំងឡាយ ព្រោះភាវៈ

នៃភព ពោលគឺជរា និងមរណៈ មិនមានត្រឹមតែខណៈនៃចិត្តឡើយ ដោយព្រះបាលីមានជាអាទិ៍ថា **“ជាតិ** (ការកើតមាន) នៃធម៌នោះៗ យ៉ាងណា ?” , ភាពជាអវិគតប្បច្ច័យរមែងមិនកើតដល់ជាតិ ព្រោះភាវៈនៃជាតិ ជាធម្មជាតិមិនមានក្នុងខណៈនៃជរា និងមរណៈដោយពិត ។

មួយវិញទៀត ភពជាបច្ច័យដល់ជាតិ, ឯជាតិជាបច្ច័យដល់ជរា និងមរណៈដោយឧបនិស្សយប្បច្ច័យតែម្យ៉ាង; ព្រោះហេតុដូច្នោះ គប្បីជ្រាបថា ទ្រង់មិនបានធ្វើសព្ទថាហេតុចតុក្កៈក្នុងអង្គទាំងឡាយ មានភពជាដើម ព្រោះមិនមានកំណត់ដោយអវិគតប្បច្ច័យ និងព្រោះការមិនមានអវិគតប្បច្ច័យ សូម្បីដោយប្រការទាំងពួង ។

ចំណែកអាចារ្យពួកខ្លះ ពោលថា ភពដែលលាយដោយឧប្បត្តិ ព្រោះព្រះបាលីថា **“ភពមាន ២ យ៉ាង”** , ឯឧបាទានជាអវិគតប្បច្ច័យដល់ឧប្បត្តិភព ព្រោះហេតុដូច្នោះ ទើបព្រះភគវាមិនត្រាស់ថា “ភពមានឧបាទានជាហេតុកើត មានព្រោះឧបាទានជាបច្ច័យ” , តែត្រាស់ថា “ភពកើតមាន ព្រោះឧបាទានជាបច្ច័យ” ព្រោះទ្រង់កាត់ចេញហើយក្នុងហេតុចតុក្កៈនេះ; សូម្បីខាងមុខ ក៏មិនបានត្រាស់ទុក; ឧបាទាននោះ មិនសមគួរ ព្រោះក្នុងទីនេះ ទ្រង់មិនប្រាថ្នាយកភពដែលលាយដោយឧប្បត្តិ; ព្រោះថា អរូបក្ខន្ធមកក្នុងទីនេះថា **ភព** ។

មួយវិញសោត ក្នុងពាក្យថា **“ជាតិកើតមាន ព្រោះភពជាបច្ច័យ”** នេះ ភពដែលនៅសល់វៀរពីជាតិ ជរា និងមរណៈហើយ គប្បីជ្រាបថា ជាបច្ច័យដល់ជាតិ; ព្រោះហេតុអ្វី ? ព្រោះជាតិជាដើម មិនជាបច្ច័យដល់ជាតិ; បើជាយ៉ាងនោះ វៀរជាតិ ជរា និងមរណៈហើយ ភពក៏គួរត្រាស់ថា ជាបច្ច័យដល់ជាតិ ។ គួរឆ្លើយថា

ត្រូវហើយ, តែព្រះភគវាមិនបានត្រាស់ទុក ព្រោះមិនមានពាក្យអាងដែលគួរត្រាស់; ក៏ក្នុងនិទ្ទេសនៃអង្គទី ១០ គួរត្រាស់ដល់ភពដែលកើតមាន ព្រោះឧបាទានជាបច្ច័យ, ក្នុងនិទ្ទេសនៃអង្គទី ១១ គួរត្រាស់ដល់ជាតិ; តែភពជាបច្ច័យដល់ជាតិ មិនមានពាក្យអាងគួរពោលដល់បទនោះ ព្រោះហេតុដូច្នោះ ទើបមិនត្រាស់ ព្រោះមិនមានពាក្យអាងដែលគប្បីត្រាស់; **សូម្បីមិនបានត្រាស់ ក៏គួរកាន់យកដែរ** ។

ក៏ក្នុងពាក្យថា **នាមរូបកើតមាន ព្រោះវិញ្ញាណជាបច្ច័យ** ជាដើម ទ្រង់នឹងសម្ដែងពាក្យថា មានវិញ្ញាណជាដើមជាហេតុ ព្រោះវិញ្ញាណជាដើម កើតព្រមជាមួយអវិគតប្បច្ច័យ ។ នេះជាសេចក្ដីផ្សេងគ្នា ក្នុងហេតុចតុក្កៈ ៕

## សម្ដែងអំពីសម្បយុត្តចតុក្កៈ

សូម្បីក្នុងសម្បយុត្តចតុក្កៈ ក៏ទ្រង់សម្ដែងសេចក្ដីដែលសង្ខារ មានអវិជ្ជាជាបច្ច័យ ដោយអំណាចនៃបច្ច័យ មានសហជាតប្បច្ច័យជាដើម ដោយត្រាស់ត្រឹមតែប៉ុណ្ណេះថា **អវិជ្ជាបច្ចយា** (ព្រោះអវិជ្ជាជាបច្ច័យ) ហើយទ្រង់សម្ដែងសភាវៈនៃអវិជ្ជា ជាសម្បយុត្តប្បច្ច័យថា **អវិជ្ជាសម្បយុត្តោ** = សម្បយុត្តដោយអវិជ្ជាដូច្នេះ; សូម្បីបទដ៏សេស ក៏មានន័យដូចគ្នានេះដែរ ។ តែព្រោះអរូបធម៌ មិនប្រកបជាមួយរូបធម៌ទាំងឡាយ ព្រោះហេតុដូច្នោះ សូម្បីក្នុងពាក្យថា **វិញ្ញាណប្បច្ចយា នាមរូបំ** (នាមរូបកើតមាន ព្រោះវិញ្ញាណជាបច្ច័យ) ជាដើម ក៏កាន់យកចំពោះតែអង្គដែលបាន ប៉ុណ្ណោះ ដោយន័យមានជាអាទិ៍ថា **"វិញ្ញាណសម្បយុត្តំ នាមំ** = នាមសម្បយុត្តដោយវិញ្ញាណ" ក្នុងបទវារៈទី ៣ និងទី ៤, នេះជាសេចក្ដីផ្សេង

គ្នា ក្នុងសម្បយុត្តចតុក្កៈ ។

## សម្ដែងអំពីអញ្ញមញ្ញចតុក្កៈ

ម្យ៉ាងទៀត ក្នុងអញ្ញមញ្ញចតុក្កៈ ព្រះអង្គទ្រង់សម្ដែងសភាវៈនៃសង្ខារមាន អវិជ្ជាជាបច្ច័យ ដោយអំណាចនៃបច្ច័យ មានសហជាតប្បច្ច័យជាដើមថា **អវិជ្ជា-បច្ចយា** (ព្រោះអវិជ្ជាជាបច្ច័យ) ហើយសម្ដែងសភាវៈនៃអវិជ្ជា ជាអញ្ញមញ្ញប្បច្ច័យថា "**សង្ខារប្បច្ចយា អវិជ្ជាបិ** = សូម្បីអវិជ្ជាក៏កើតមាន ព្រោះសង្ខារជាបច្ច័យ" ។ សូម្បីក្នុងបទដ៏សេស ក៏មានន័យដូចគ្នានេះដែរ ។ តែព្រោះភពជានិប្បទេស (គឺទ្រង់សម្ដែងដោយសព្វគ្រប់), ឧបាទានជាសប្បទេស (គឺទ្រង់សម្ដែងបន្តិចបន្តួច), និងធម៌ដែលជាសប្បទេស ជាបច្ច័យដល់ធម៌ដែលជានិប្បទេស, ធម៌ដែលជានិប្បទេស មិនជាបច្ច័យដល់ធម៌ដែលជាសប្បទេស, ព្រោះហេតុដូច្នោះ ក្នុងអញ្ញមញ្ញចតុក្កៈនេះ ទើបមិនត្រាស់ថា "**ភវប្បច្ចយាបិ ឧបាទានំ** = ឧបាទានកើតមាន សូម្បីព្រោះភពជាបច្ច័យ" ; ន័យមួយទៀត មិនបានត្រាស់យ៉ាងនេះ ព្រោះទ្រង់កាត់ចេញហើយ ដោយទេសនាទុកក្នុងខាងក្រោយ; តែព្រោះសឡាយតនៈមាន ព្រោះនាមរូបជាបច្ច័យ, នាមរូបរមែងមិនមាន ព្រោះសឡាយតនៈជាបច្ច័យក្នុងខណៈចិត្តជាមួយគ្នា សឡាយតនៈគប្បីជាអញ្ញមញ្ញប្បច្ច័យដល់នាមរូបណា, ព្រោះហេតុដូច្នោះ ក្នុងវារៈទី ៤ ទើបទ្រង់កាន់យកចំពោះអង្គដែលបាន ក្នុងពាក្យថា "**សឡាយតនប្បច្ចយាបិ នាមរូបំ** = នាមរូបកើតមាន ព្រោះសូម្បី

សឡាយតនៈជាបច្ច័យ" ។ នេះជាសេចក្ដីផ្សេងគ្នា ក្នុងអញ្ញមញ្ញចតុក្កៈ ៕

**ចប់មាតិការបស់ន័យមានអវិជ្ជាជាមូល**

## អធិប្បាយន័យរបស់មាតិកា មានសង្ខារជាមូលជាដើម

ឥឡូវនេះ ព្រះភគវាទ្រង់ផ្ដើមន័យមានសង្ខារជាមូលថា **សង្ខារប្បច្ចយា អវិជ្ជា** = អវិជ្ជាកើតមាន ព្រោះសង្ខារជាបច្ច័យ, សូម្បីក្នុងបាលីមានសង្ខារជាមូលជាដើមនោះ ក៏គប្បីជ្រាបចតុក្កៈ ៤ និងវារៈ១៦ ដូចក្នុងន័យដែលមានអវិជ្ជាជាមូល៕

## សម្ដែងអំពីចតុក្កនិទ្ទេសទី ១

ក៏ក្នុងចតុក្កៈទី ១ ព្រះអង្គទ្រង់សម្ដែងចំពោះវារៈទី ១ ប៉ុណ្ណោះ ហើយទ្រង់សង្ខេបទេសនាទុក; សូម្បីក្នុងន័យដែលមានវិញ្ញាណជាមូលជាដើម ក៏ដូចក្នុងន័យដែលមានសង្ខារជាមូលនេះដែរ; បណ្ដាន័យទាំងនោះ ព្រះអង្គទ្រង់សម្ដែងភាវៈនៃអវិជ្ជាមានសង្ខារជាដើម ជាបច្ច័យដោយអំណាចនៃបច្ច័យ មានសហជាតប្បច្ច័យជាដើម ដោយន័យមានជាអាទិ៍ថា "**សង្ខារប្បច្ចយា អវិជ្ជា** = អវិជ្ជាកើតមាន ព្រោះសង្ខារជាបច្ច័យ" ក្នុងន័យទាំង ៨ មានសង្ខារជាមូលជាដើមនោះ ទាំងអស់តែម្ដង ហើយទើបទ្រង់សម្ដែងការប្រព្រឹត្តទៅនៃចក្រ គឺបច្ចយាការ សូម្បីក្នុងខណៈនៃចិត្តជាមួយគ្នា ដោយន័យមានជាអាទិ៍ថា "**អវិជ្ជា បច្ចយា សង្ខារោ** = សង្ខារកើតមាន ព្រោះអវិជ្ជាជាបច្ច័យ" ដូច្នេះទៀត ។

*សួរថា* ក៏ព្រោះហេតុអ្វី ទើបមិនត្រាស់ន័យទាំងឡាយ មានភពជាមូល ឬមានជាតិ ជរា និងមរណៈជាមូល, អវិជ្ជារមែងមិនមាន ព្រោះភពជាបច្ច័យឬ ? ឆ្លើយថា មិនមានក៏ទេ។ តែកាលត្រាស់ពាក្យមានជាអាទិ៍យ៉ាងនេះថា **"សង្ខារៈ ប្បច្ចយា អវិជ្ជា** = អវិជ្ជាកើតមាន ព្រោះសង្ខារជាបច្ច័យ" ក៏នឹងមិនបានត្រាស់ធម៌ដែលរាប់បញ្ចូលដោយភពណា១ ជាបច្ច័យដល់អវិជ្ជា; ព្រោះហេតុដូច្នោះ ទើបមិនត្រាស់ន័យមានភពជាមូល ព្រោះមិនមានធម៌ដទៃ ដែលមិននៅខាងដើម ជាបច្ច័យ ដល់អវិជ្ជាដែលគួរត្រាស់; និងសូម្បីអវិជ្ជា ក៏រមែងដល់ការសង្គ្រោះទុកដោយសព្ទថា ភព, ព្រោះហេតុនោះ កាលព្រះអង្គត្រាស់ថា **"ភវប្បច្ចយា អវិជ្ជា** = អវិជ្ជាកើតមាន ព្រោះភពជាបច្ច័យ" ក៏គប្បីជាការត្រាស់ថា **"អវិជ្ជាបច្ចយា អវិជ្ជា** = អវិជ្ជាកើតមាន ព្រោះអវិជ្ជាជាបច្ច័យ" ដោយពោលក្នុងខណៈមួយ អវិជ្ជារមែងមិនឈ្មោះថា ជាបច្ច័យដល់អវិជ្ជា ព្រោះទ្រង់កាត់ចេញក្នុងភពនោះឯង សូម្បីន័យមាន ជាតិ ជរា និងមរណៈជាមូល ក៏ទ្រង់មិនកាន់យក; ន័យមួយទៀត សូម្បីជាតិ ជរា និងមរណៈ ក៏ទ្រង់សង្គ្រោះចូលក្នុងភព, ឯជាតិ ជរា និងមរណៈទាំងនេះ នឹងជាបច្ច័យដល់អវិជ្ជា ក្នុងខណៈនៃចិត្តមួយជាមួយគ្នា ក៏មិនមែន; ព្រោះហេតុដូច្នោះ ទើបមិនត្រាស់ន័យដែលមានភពជាមូល ឬមានជាតិ ជរា និងមរណៈ ជាមូលឡើយ ៕

**(ចប់មាតិកាកថា)**

## អធិប្បាយអកុសលនៃចតុក្កនិទ្ទេសទី ១

ឥឡូវនេះ ព្រះភគវាមិនបានត្រាស់យកកុសល (ក្នុងបច្ចយាការ) ជាមុនទេ ព្រោះនិទ្ទេសនៃអកុសលនេះ ទ្រង់មិនបានតាំងមាតិកា ដូចក្នុងចិត្តុប្បាទកណ្ឌខាងក្រោយ ទ្រង់នឹងធ្វើកុសលត្តិកៈទុកខាងដើម ហើយទ្រង់ចែកកុសលមុន ដោយលំដាប់មាតិកាដែលទ្រង់តាំងទុក, ដើម្បីនឹងទ្រង់សម្តែងចែកអង្គបដិច្ចសមុប្បាទ មានអវិជ្ជាជាដើម តាមលំដាប់ដែលទ្រង់តាំងទុកក្នុងមាតិកា ដោយអំណាចនៃអកុសលធម៌ថា "**អវិជ្ជាបច្ចយា សង្ខារា** = សង្ខារកើតមាន ព្រោះអវិជ្ជាជាបច្ច័យ" ប៉ុណ្ណោះ ទើបត្រាស់ពាក្យមានជាអាទិ៍ថា "**កតមេ ធម្មា អកុសលា** = ធម៌ជាអកុសលតើដូចម្តេច ?" ។ សេចក្តីនៃព្រះបាឡីនោះ គប្បីជ្រាបដោយន័យដែលត្រាស់ទុកក្នុងចិត្តុប្បាទកណ្ឌខាងក្រោយនោះៗ ឯង ។

ម្យ៉ាងទៀត ព្រោះតណ្ហា និងកាមុបាទានរមែងមិនកើតក្នុងខណៈនៃចិត្តជាមួយគ្នា ព្រោះហេតុដូច្នោះ ក្នុងទីនេះ ដើម្បីទ្រង់សម្តែងឧបាទានដែលកើតមាន ព្រោះតណ្ហាជាបច្ច័យនោះៗ ឯង ទើបត្រាស់ពាក្យមានជាអាទិ៍ថា "**ទិដ្ឋិ ទិដ្ឋិគតំ**" ។

ម្យ៉ាងវិញទៀត ព្រោះក្នុងនិទ្ទេសនៃភព ឧបាទានដល់ការសង្គ្រោះចូលក្នុងសង្ខារក្ខន្ធ; ព្រោះហេតុដូច្នោះ ទើបត្រាស់ថា "**វេទនាខន្ធ សញ្ញាខន្ធ សង្ខារក្ខន្ធ និងវិញ្ញាណក្ខន្ធ វៀរឧបាទានចេញ**" ; ព្រោះការត្រាស់យ៉ាងនេះ ក៏នឹងគប្បីប្រាកដក្នុងការដែលឧបាទានជាបច្ច័យដល់ឧបាទាន, ក៏ឧបាទាននោះឯង រមែងមិនជាបច្ច័យដល់ឧបាទាននោះ ។

ក្នុងនិទ្ទេសនៃជាតិជាដើម ព្រោះធម៌ទាំងនេះ មានជាតិជាដើម ជាការកើត

មុនដំបូងរបស់អរូបធម៌ទាំងឡាយ, ព្រោះហេតុដូច្នោះ ទើបមិនត្រាស់ថា **“ការដែលធ្វេញចាក់ សក់ស្កូវ ស្បែកជ្រីវជ្រួញ ចុតិ និងកិរិយាដែលចុតិ”** ។

ព្រះអង្គទ្រង់តាំងវារៈទី ១ យ៉ាងនេះហើយ តទៅក៏ទ្រង់សម្ដែងបច្ចយាការក្នុងវារៈទី ២ ដោយវារៈទី ១ ក្នុងសម័យណា, ក្នុងសម័យនោះ ដើម្បីទ្រង់សម្ដែងបច្ចយាការដោយន័យសូម្បីដទៃទៀត ទើបមិនត្រាស់វារៈកំណត់សម័យទុកទាំងស្រុងហើយទ្រង់ទេសនាដោយន័យមានជាអាទិ៍ថា **“តស្មឹ សមយេ អវិជ្ជាបច្ចយា សង្ខារោ** = សង្ខារកើតមាន ព្រោះអវិជ្ជាជាបច្ច័យក្នុងសម័យនោះ” ។

បណ្ដាពាក្យទាំងនោះ ពាក្យថា **វៀរផស្សៈ** នេះ ទ្រង់ត្រាស់ទុកដើម្បីនាំផស្សៈចេញអំពីនាម ព្រោះសូម្បីផស្សៈក៏រាប់បញ្ចូលក្នុងនាម ។

ក្នុងវារៈទី ៣ វិញ្ញាណជាបច្ច័យដល់រូប ដែលមានចិត្តជាសមុដ្ឋាន កាលរូបមានចិត្តជាសមុដ្ឋានកំពុងប្រព្រឹត្តទៅ ព្រោះចក្ខាយតនៈជាដើម ជារូបដែលមានចិត្តជាសមុដ្ឋាននោះហើយ រមែងប្រាកដ, ព្រោះហេតុដូច្នោះ ទើបត្រាស់ថា **“ចក្ខាយតនស្ស ឧបបច្ចយោ** = កិរិយាកើតមានឡើងនៃចក្ខាយតនៈ” ជាដើម ។ ម្យ៉ាងទៀត ព្រោះវិញ្ញាណជាបច្ច័យដោយបច្ឆាជាតប្បច្ច័យ សូម្បីដល់កម្មជរូបដែលកំពុងប្រព្រឹត្តទៅក្នុងសម័យនោះ, ព្រោះហេតុនោះឯង ទើបត្រាស់យ៉ាងនេះ; ក្នុងវារៈទី ៣ នោះ ទ្រង់កាន់យកសន្តតិ ២ គឺសន្តតិរូបកើតមានពីកម្ម និងសន្តតិរូបដែលមានចិត្តជាសមុដ្ឋាន ក៏ពិតមែនហើយ, តែសូម្បីសន្តតិ ២ ក្រៅនេះ ក៏គប្បីកាន់យកដែរ; ព្រោះវិញ្ញាណក៏ជាបច្ច័យដល់សន្តតិ ២ ក្រៅនេះដូចគ្នា ។

ចំណែកក្នុងវារៈទី ៤ ក៏ព្រោះសូម្បីក្នុងខណៈចិត្ត ជាមួយនឹងចក្ខាយតនៈ

ជាដើម មានមហាភូតរូបជាបច្ច័យ, អាយតនៈទី ៦ មានហទយៈជាបច្ច័យ, និងសូម្បីអាយតនៈទាំងអស់មាន ព្រោះនាមជាបច្ច័យ ប្រព្រឹត្តទៅដោយអំណាចនៃបច្ឆាជាតប្បច្ច័យ និងសហជាតប្បច្ច័យជាដើម តាមសមគួរ, ព្រោះហេតុដូច្នោះ ទើបត្រាស់ពាក្យមានជាអាទិ៍ថា **"តត្ថ កតមំ នាមរូបប្បច្ចយា សឡាយតនំ ចក្ខាយតនំ** = ក្នុងបច្ចយាការនោះ សឡាយតនៈកើតមាន ព្រោះនាមរូបជាបច្ច័យ តើដូចម្តេច ? គឺចក្ខាយតនៈ" ៕

**ចប់ចតុក្កនិទ្ទេសទី ១**

## ចតុក្កនិទ្ទេសទី ២

ពាក្យទាំងអស់ក្នុងចតុក្កៈទី ២ ងាយស្រួលមែនពិត ៕

## ចតុក្កនិទ្ទេសទី ៣

ក្នុងចតុក្កៈទី ៣ សភាវៈជាសម្បយុត្តប្បច្ច័យ មិនមានដល់បច្ច័យណា, បច្ចយាការណាមាន, ដើម្បីទ្រង់សម្តែងបច្ចយាការនោះៗ ទុកមួយផ្នែក ទើបត្រាស់ថា **"ឥទំ វុច្ចតិ វិញ្ញាណប្បច្ចយា នាមរូបំ វិញ្ញាណសម្បយុត្តំ នាមំ** = នេះហៅថា នាមរូប ហៅថា នាម សម្បយុត្តដោយវិញ្ញាណ កើតមានឡើង ព្រោះវិញ្ញាណជាបច្ច័យ" ៕

**ចប់ចតុក្កនិទ្ទេសទី ៣**

## ចតុក្កនិទ្ទេសទី ៤

និទ្ទេសនៃនាមកើតមាន ព្រោះផស្សៈជាបច្ច័យ ក្នុងចតុក្កៈទី ៤ សូម្បីមិនបានត្រាស់ថា "**វេទនាខន្ធ ។ ល ។ វិញ្ញាណក្ខន្ធ វៀរផស្សៈ នេះហៅថា នាមកើតមាន ព្រោះផស្សៈជាបច្ច័យ**" ក៏ពិតមែន, តែព្រោះបានត្រាស់ថា "**វេទនាខន្ធ ។ ល ។ វិញ្ញាណក្ខន្ធ វៀរផស្សៈ**" ក្នុងនិទ្ទេសនៃបទអតីតៈ ដោយលំដាប់នោះ សូម្បីមិនបានត្រាស់ ក៏រាប់ថាជាការត្រាស់ហើយដោយពិត; ព្រោះនាមណាជាបច្ច័យដល់ផស្សៈនោះឯង, សូម្បីផស្សៈក៏ជាបច្ច័យដល់នាមនោះដែរ ៕

**ចប់ចតុក្កនិទ្ទេសទី ៤**

ម្យ៉ាងទៀត គប្បីជ្រាបន័យទាំង ៨ សូម្បីមានសង្ខារជាមូលជាដើម ដូចន័យទី ១ មានអវិជ្ជាជាមូល ដែលចែកទុក ១៦ វារៈ ក្នុងចតុក្កៈ ៤ ដែលទ្រង់ប្រកាសទុកក្នុងអកុសលចិត្តដួងទី ១ នេះ, ចំណែកព្រះបាលីទ្រង់សង្ខេបទុក នឹងគប្បីជ្រាបថា ក្នុងអកុសលចិត្តដួងទី ១ នោះឯង មាន ៩ ន័យ, ៣៦ ចតុក្កៈ និង ១៤៤ វារៈ ដោយប្រការដូច្នេះ ។

ឥឡូវនេះ ដើម្បីនឹងទ្រង់សម្តែងបច្ចយាការ សូម្បីក្នុងអកុសលចិត្តដ៏សេសដោយន័យនេះឯង ទើបផ្តើមពាក្យមានជាអាទិ៍ថា "**កតមេ ធម្មា អកុសលា** = ធម៌ជាអកុសលតើដូចម្តេច ?" ។

ក្នុងព្រះបាលីនោះ ព្រោះចិត្តដែលប្រាសចាកទិដ្ឋិ មិនមានឧបាទានកើតមានព្រោះតណ្ហាជាបច្ច័យ, ព្រោះហេតុដូច្នោះ ទើបទ្រង់បន្ថែមអធិមោក្ខដែលជានិបាត

ធ្វើឱ្យមាំទាំ ដូចជាឧបាទានកើតក្នុងកន្លែងឧបាទាន។ ក៏ព្រោះក្នុងចិត្តដែលសហគតៈដោយទោមនស្ស សូម្បីតណ្ហាដែលមានវេទនាជាបច្ច័យ ក៏មិនមាន, ព្រោះហេតុ-ដូច្នោះ ទើបទ្រង់បន្ថែមបទបដិឃៈដែលជាកិលេសមានកម្លាំង ដូចជាតណ្ហាកើតក្នុងតណ្ហា ទ្រង់បន្ថែមបទអធិមោក្ខនោះឯង ក្នុងទីនៃឧបាទាន ។

ចំណែកអកុសលចិត្ត ដែលសម្បយុត្តដោយវិចិកិច្ឆា រមែងមិនមានសូម្បីអធិមោក្ខ ព្រោះមិនមានការសន្និដ្ឋាន (ស្ទាបស្ទង់), ព្រោះហេតុដូច្នោះ ទើបទ្រង់បន្ថែមបទ ដោយវិចិកិច្ឆាដែលជាកិលេសមានកម្លាំងទុកក្នុងកន្លែងនៃតណ្ហា, បន្ថយឋានៈនៃឧបាទាន ។

ចំណែកក្នុងអកុសលចិត្តដែលសម្បយុត្តដោយវិចិកិច្ឆា សូម្បីអធិមោក្ខក៏មិនមាន ព្រោះមិនមានការកាត់ក្តី, ព្រោះហេតុដូច្នោះ ទើបទ្រង់បន្ថែមដោយវិចិកិច្ឆាដែលជាកិលេសមានកម្លាំងទុកក្នុងកន្លែងនៃតណ្ហា បន្ថយឋាននៃឧបាទានចេញ តែក្នុងអកុសលចិត្តដែលសម្បយុត្តដោយឧទ្ធច្ចៈ មានអធិមោក្ខ ព្រោះហេតុដូច្នោះ ទើបទ្រង់បន្ថែមបទដោយឧទ្ធច្ចៈ ដែលជាកិលេសមានកម្លាំងក្នុងកន្លែងនៃតណ្ហា។ ទ្រង់បន្ថែមបទអធិមោក្ខនោះឯង ទុកក្នុងកន្លែងនៃឧបាទាន។ ក៏ព្រះភគវាសម្តែងហេតុត្រឹមតែថា សេចក្តីផ្សេងគ្នាក្នុងអកុសលទាំងអស់ ហើយទ្រង់សង្ខេបព្រះបាលីទុក។ ក៏សេចក្តីផ្សេងគ្នានេះ ទ្រង់សម្តែងទុកក្នុងនិទ្ទេសនៃអធិមោក្ខនោះ, និទ្ទេសនោះ ជានិទ្ទេសដែលនៅមិនបានធ្លាប់សម្តែងមកក្នុងកាលមុន ពាក្យដ៏សេសមានមកក្នុងខាងក្រោយទាំងអស់ ។

ក៏ក្នុងនិទ្ទេសនៃអធិមោក្ខ មានវិនិច្ឆ័យថា ៖

ក៏ឈ្មោះថា **អធិមោក្ខ** ព្រោះអាចកាត់ក្តីអារម្មណ៍បាន; ម្យ៉ាងទៀត ក៏ឈ្មោះថា **អធិមោក្ខ** (ការសម្រេចចិត្ត) ព្រោះអត្ថថា បង្អោនចិត្តទៅក្នុងអារម្មណ៍នោះ គឺដល់សេចក្តីយល់ព្រម ព្រោះមិនមានការសង្ស័យ ។ អាការដែលកាត់ក្តីអារម្មណ៍ ឈ្មោះថា **អធិមុច្ចនា** (កិរិយាដែលសម្រេចចិត្ត), ក៏ឈ្មោះថា **តទធិមុត្តតា** (ការសម្រេចចិត្ត ក្នុងអារម្មណ៍នោះ) ព្រោះអត្ថថា ការបង្អោនទៅក្នុងអារម្មណ៍នោះ, ក៏ក្នុងចិត្តគ្រប់ខណៈ គប្បីជ្រាបប្រភេទន័យរបស់ចតុក្កៈ ដោយន័យដែលពោលទុកក្នុងបឋមចិត្ត (អកុសល) នោះឯង ក៏ព្រោះក្នុងអកុសលចិត្តដែលសម្បយុត្តដោយវិចិកិច្ឆា មិនមានន័យថា មានឧបាទានជាមូលតែម្យ៉ាង ទើបមាន ៨ ន័យ, ៣២ ចតុក្កៈ និងជា ១២៨ វារៈ ដូច្នេះឯង ៕

ចប់អកុសលនិទ្ទេស

## អធិប្បាយកុសលនិទ្ទេស

ឥឡូវនេះ ព្រះភគវាទ្រង់ប្រាថ្នាដើម្បីសម្តែងបច្ចយាការក្នុងកុសលចិត្តជាដើម ដោយន័យនេះឯង ទើបផ្តើមពាក្យមានជាអាទិ៍ថា “**កតមេ ធម្មា កុសលា** = ធម៌ជាកុសលតើដូចម្តេច ?” ។

ក៏ក្នុងអកុសលចិត្ត ព្រះអង្គទ្រង់តាំងមាតិកាទុកមុនហើយ ទ្រង់ធ្វើនិទ្ទេសទុកខាងក្រោយ, តែក្នុងកុសលនិទ្ទេសនេះ ព្រះអង្គទ្រង់មិនបានធ្វើដូច្នោះទេ; ព្រោះហេតុអ្វី ? ព្រោះសេចក្តីផ្សេងគ្នាក្នុងវារៈពោលអំពីអប្បនា; ព្រោះថា ក្នុងលោកិយ-កុសលចិត្តជាដើម រមែងជាអប្បនា ដោយព្រះបាលីថា “**ឯវមេតស្ស កេវលស្ស**

**ទុក្ខខន្ធស្ស** = កងទុក្ខទាំងមូលនេះ រមែងមានដោយប្រការយ៉ាងនេះ” ព្រោះភាវៈនៃធម៌ទាំងនោះ រាប់បញ្ចូលក្នុងទុក្ខសច្ច, ក្នុងលោកុត្តរកុសលជាដើម រមែងជាអប្បនាដល់ធម៌ទាំងនោះដោយប្រការដូច្នេះ ព្រោះហេតុដូច្នោះ ក្នុងកុសលជាដើមនេះ ទើបព្រះអង្គមិនអាចដើម្បីទ្រង់តាំងមាតិកាជាសាធារណៈ ទ្រង់លើកមាតិកានៃកុសលជាដើមនោះៗ ឡើងសម្ដែងតែម្យ៉ាងៗ ហើយទ្រង់ធ្វើនិទ្ទេស ក្នុងកុសលទាំងនោះ ព្រោះមិនមានអវិជ្ជារួមជាមួយកុសលសង្ខារ ក្នុងខណៈនៃចិត្តជាមួយគ្នា ព្រោះហេតុដូច្នោះ ទើបមិនត្រាស់អវិជ្ជានោះ ហើយត្រាស់កុសលមូល ឱ្យជាឫសគល់នៃកុសលទាំងឡាយ ដូចអវិជ្ជាជាឫសគល់នៃអកុសលទាំងឡាយ, និងព្រោះការមិនមានតណ្ហា ឧបាទាន ទើបត្រាស់បសាទៈ (សេចក្ដីថ្លាបរិសុទ្ធិ) ដែលចុះកាន់អារម្មណ៍ ដូចតណ្ហាដែលតាំងនៅក្នុងទីនៃតណ្ហា, ត្រាស់អធិមោក្ខ ឈ្មោះថា ការយល់ព្រមយ៉ាងមាំទាំ ដូចឧបាទានតាំងនៅក្នុងទីនៃឧបាទានដូច្នោះ ។ ពាក្យដ៏សេស គប្បីជ្រាបដោយន័យដែលពោលហើយ ខាងក្រោយនោះចុះ ៕

ចប់កុសលនិទ្ទេស

## អធិប្បាយអព្យាកតនិទ្ទេស

អព្យាកតៈទ្រង់ចែកទុកដោយលំដាប់ដែលមានមក ក្នុងចិត្តុប្បាទកណ្ឌខាងក្រោយនោះឯងហើយ; ក៏ក្នុងវារៈទាំងអស់ ទ្រង់លះន័យមានអវិជ្ជាជាមូល; ព្រោះហេតុអ្វី ? ព្រោះមិនមានធម៌ដែលគួរតាំងទុកក្នុងឋាននៃអវិជ្ជា; ពិតណាស់ ក្នុងកុសលចិត្តទាំងឡាយ គប្បីមានកុសលមូលដែលតាំងទុក ក្នុងឋាននៃអវិជ្ជា, ក្នុង

អហេតុកចិត្តមានចក្ខុវិញ្ញាណជាដើម ក៏មិនមាន; តែក្នុងសហេតុកចិត្តទាំងឡាយ មានកុសលមូលដោយពិត, កាលបើដូច្នោះ ទើបព្រះអង្គទ្រង់លះសហេតុកចិត្តនេះចេញ ទ្រង់មិនកាន់យកក្នុងអហេតុកចិត្តនោះ, ក្នុងក្រសែនៃវិញ្ញាណ ៥ គប្បីជ្រាបថា ទ្រង់ធ្វើទេសនាជាសភាពឱ្យធ្លាក់ទៅក្នុងក្រសែតែមួយ (គឺសម្តែងដោយលំដាប់) ។

ម្យ៉ាងទៀត ពោលអំពីសេចក្តីផ្សេងគ្នា ក្នុងអព្យាកតៈនេះ ទ្រង់លះឋាននៃតណ្ហា និងឧបាទាន ក្នុងអហេតុកចិត្តមានចក្ខុវិញ្ញាណជាដើម; ព្រោះហេតុអ្វី ? ព្រោះមិនមានធម៌ដ៏មានកម្លាំង ដែលសមគួរដល់ឋាននៃតណ្ហា និងព្រោះវៀរចាកអធិមោក្ខ; តែក្នុងអហេតុកចិត្តដែលសល់ ទ្រង់លះឋាននៃតណ្ហាដោយពិត ។

ក្នុងសហេតុកចិត្តទាំងឡាយ ទ្រង់បន្ថែមបទបសាទៈ ក្នុងកន្លែងនៃតណ្ហា ព្រោះជាសភាពនៃសេចក្តីបរិសុទ្ធិ។ បណ្តាអព្យាកតៈទាំងនេះ ក្នុងអហេតុកចិត្តមានចក្ខុវិញ្ញាណជាដើម ដែលជាកុសលវិបាក និងអកុសលវិបាក គប្បីជ្រាបន័យម្យ៉ាងៗ ៦ ដែលមានសង្ខារ វិញ្ញាណ នាម សឡាយតនៈ ផស្សៈ និងវេទនាជាមូល, ក្នុងអហេតុកចិត្តដ៏សេស គប្បីជ្រាបថា មានន័យម្យ៉ាងៗ ៧ ជាមួយន័យដែលមានអធិ-មោក្ខជាមូល, ចំណែកក្នុងសហេតុកចិត្តទាំងឡាយ គប្បីជ្រាបន័យម្យ៉ាងៗ ៨ ជាមួយបសាទៈជាមូល ។

បណ្តាអព្យាកតៈទាំងនោះ សូម្បីត្រាស់វារៈខាងដើមរបស់ចតុក្កៈទាំង ៤ ទុកម្យ៉ាង សូម្បីក្នុងចក្ខុវិញ្ញាណជាដើម ។ វារៈទី ២ សូម្បីបានដោយអត្ថថា សេចក្តីផ្សេងគ្នានៃបច្ច័យ ក៏មិនត្រាស់ទុក, វារៈទី ៣ និងទី ៤ មិនត្រាស់ទុក ព្រោះមិនមាននោះឯង, ក៏វារៈទី ៣ និងទី ៤ លាយដោយរូប និងចក្ខុវិញ្ញាណជាដើម រមែងញុំាង

រូបឱ្យតាំងឡើងមិនបាន; សូម្បីក្នុងចតុក្កៈដ៏សេស ក៏បានដូចក្នុងចតុក្កៈទី ១ ដែលមាន ២ វារៈដែរ, ព្រោះហេតុដូច្នោះ គប្បីជ្រាបទុតិយវារៈក្នុងបឋមចតុក្កៈ និងវារៈក្នុងចតុក្កៈដ៏សេស មួយចតុក្កៈពីរ ៧ វារៈ សូម្បីមិនបានត្រាស់ទុក ក៏គប្បីជ្រាបថាត្រាស់ទុកហើយដែរ, ក្នុងអព្យាកតៈនៃអហេតុកដ៏សេស បានវារៈសូម្បីក្នុងចតុក្កៈទាំង-អស់, តែព្រោះការកាត់ចេញក្នុងចតុក្កៈនេះ ទើបទ្រង់មិនកាន់យកខាងមុខ, ទេសនាដែលធ្លាក់ទៅក្នុងក្រសែ ទ្រង់ធ្វើហើយដោយប្រការដូច្នេះ។ សូម្បីក្នុងវិបាកមានអហេតុកដ៏សេស ក៏មានន័យដូចគ្នានេះដែរ វៀរតែអរូបាវចរវិបាក; ព្រោះអរូបា-វចរវិបាក បាន ២ វារៈប៉ុណ្ណោះ ៕

**ចប់អព្យាកតនិទ្ទេស**

## អវិជ្ជាមូលកកុសលនិទ្ទេស

## សម្ដែងអំពីកុសលនិទ្ទេសម្យ៉ាងទៀត

ឥឡូវនេះ ព្រះភគវាដើម្បីទ្រង់សម្ដែងបច្ចយាការ ក្នុងខណៈនៃចិត្តជាមួយគ្នាដោយបរិយាយដទៃ ទើបផ្ដើមពាក្យមានជាអាទិ៍ថា **“កតមេ ធម្មា កុសលា”** ទៀត ។

ក្នុងព្រះបាលីនោះ ពាក្យថា **ព្រោះអវិជ្ជាជាបច្ច័យ** នេះ ត្រាស់សំដៅយកសភាពជាឧបនិស្សយប្បច្ច័យ, ដោយហេតុនោះឯង ក្នុងនិទ្ទេសវារៈ ទើបទ្រង់មិនបានចែកថា **“តត្ថ កតមា អវិជ្ជា** = ក្នុងបច្ចយាការនោះ អវិជ្ជាតើដូចម្ដេច ?”

ទ្រង់ចែកថា **“តត្ថ កតមោ អវិជ្ជាបច្ចយា សង្ខារា** = ក្នុងបច្ចយាការនោះ សង្ខារកើតមាន ព្រោះអវិជ្ជាជាបច្ច័យ តើដូចម្តេច ?” ព្រោះសង្ខារ ពោលគឺកុសលចេតនាតែម្យ៉ាងប៉ុណ្ណោះ កើតមានរួមជាមួយចិត្តក្នុងសម័យនោះ, មិនមែនអវិជ្ជាទេ ។

ក្នុងព្រះបាលីនោះ អវិជ្ជាជាបច្ច័យដល់លោកិយកុសល មានន័យដូចដែលពោលទុកហើយ ក្នុងសុត្តន្តភាជនិយខាងក្រោយនោះឯង, ព្រោះបុគ្គលលះអវិជ្ជាមិនទាន់បាន ទើបចម្រើនលោកុត្តរកុសលដើម្បីលះអវិជ្ជា ។ ព្រោះហេតុដូច្នោះ សង្ខារគឺកុសលចេតនានោះ ទើបជាបច្ច័យបានដោយអំណាចនៃការឈានកន្លងអវិជ្ជានោះឯង, ពិតណាស់ កាលបុគ្គលនៅមានអវិជ្ជានោះ ទើបប្រកបកុសល, ការប្រកបកុសលរបស់បុគ្គលក្រៅនេះ មិនមានក្នុងការប្រកបកុសលនោះទេ រមែងបានការប្រកបកុសលដែលប្រព្រឹត្តទៅក្នុងភូមិ ៣ ដោយអំណាចនៃសម្មោហៈវង្វេងវង្វាន់ខ្លះ, ដោយអំណាចនៃការចម្រើនដើម្បីឈានកន្លងខ្លះ, ក្នុងលោកុត្តរកុសល រមែងបានដោយភាវនាកាត់ផ្តាច់ដូច្នេះឯង, ពាក្យដ៏សេស មានន័យតាមដែលពោលហើយនោះចុះ ។

ចំណែកសេចក្តីផ្សេងគ្នា មានដូចតទៅនេះ ÷

ក្នុងកុសលតែម្យ៉ាង ខាងក្រោយបានកុសល ១៦ ពួក រួម ៩ ពួក ដោយអំណាចនៃចតុក្កៈបួន ៧ ដួង ក្នុងទីនេះ មិនដូចគ្នាយ៉ាងនោះទេ, ព្រោះហេតុអ្វី ? ព្រោះអវិជ្ជាមិនជាអវិគតប្បច្ច័យ សម្បយុត្តប្បច្ច័យ អញ្ញមញ្ញប្បច្ច័យ, ក៏ក្នុងកុសលមានអវិជ្ជាជាមូលនេះ រមែងបានចតុក្កៈទី ១ ប៉ុណ្ណោះ ដោយអំណាចនៃឧបនិស្សយ-

ប្បច្ច័យ, សូម្បីចតុក្កៈទី ១ នោះ ក៏ទ្រង់សម្តែងសង្ខេបទុកចំពោះវារៈទី ១ ប៉ុណ្ណោះ, តែបណ្ឌិត ក៏គួរនាំមកសម្តែងចេញដូច្នេះដែរ ៕

ចប់អវិជ្ជាកុសលនិទ្ទេស

## អកុសលមូលវិបាកនិទ្ទេស

## សម្តែងអំពីអកុសលវិបាកចិត្ត ៧

ឥឡូវនេះ ព្រះមានព្រះភាគទ្រង់ប្រាថ្នានឹងសម្តែងបច្ចយាការ សូម្បីក្នុងអព្យាកតៈទាំងឡាយ ដោយន័យដទៃទៀត ទើបទ្រង់ផ្តើមពាក្យមានជាអាទិ៍ថា “**កតមេ ធម្មា អព្យាកតា** = ធម៌ជាអព្យាកតៈ តើដូចម្តេច ?” ។

ក្នុងព្រះបាលីនោះ សូម្បីពាក្យថា **ព្រោះកុសលមូលជាបច្ច័យ** នេះ ត្រាស់សំដៅយកសភាវៈជាឧបនិស្សយប្បច្ច័យ; ពិតណាស់ កុសលមូលរមែងជាបច្ច័យដល់កុសលវិបាក, ឯអកុសលមូល ជាឧបនិស្សយប្បច្ច័យដល់អកុសលវិបាក, តែមិនគួរពោលដល់កម្មប្បច្ច័យ ដែលកើតផ្សេងខណៈគ្នាទេ; ព្រោះហេតុដូច្នោះ បច្ច័យដែលជាកុសលមូល និងអកុសលមូលនេះ ទើបជាបច្ច័យដោយឧបនិស្សយប្បច្ច័យ និងកម្មប្បច្ច័យ ដែលកើតផ្សេងខណៈគ្នា; ដោយហេតុនោះឯង ក្នុងនិទ្ទេសវារៈ ទើបមិនចែកថា “**តត្ថ កតមំ កុសលមូលំ** = ក្នុងបច្ចយាការនោះ កុសលមូល តើដូចម្តេច ?” ទ្រង់ចែកថា “**តត្ថ កតមោ កុសលមូលបច្ចយា សង្ខារោ** = ក្នុង

បច្ចយាការនោះ សង្ខារកើតមាន ព្រោះកុសលមូលជាបច្ច័យ តើដូចម្តេច ?”។ សូម្បីក្នុងអកុសលវិបាក ក៏មានន័យដូចគ្នានេះដែរ ។

ម្យ៉ាងទៀត សូម្បីក្នុងវិបាកនិទ្ទេសនេះ រមែងបានចំពោះបច្ចយចតុក្កៈទី ១ ប៉ុណ្ណោះ ដូចក្នុងនិទ្ទេសនៃអកុសលមានអវិជ្ជាជាមូល, សូម្បីក្នុងបច្ចយចតុក្កៈនោះ ក៏ទ្រង់សម្តែងបឋមវារៈ ហើយទ្រង់សង្ខេបទុក; ព្រោះហេតុនោះ គប្បីជ្រាបប្រភេទ ក្នុងន័យដែលមានកុសលជាមូល និងអកុសលជាមូល ដោយអំណាចនៃចតុក្កៈតែមួយ ចតុក្កៈ ក្នុងវិបាកចិត្តតែមួយខណៈ; តែព្រោះអវិជ្ជា កុសលមូល និងអកុសលមូល រមែងមិនបានជាឧបនិស្សយប្បច្ច័យ ដល់ធម៌ដែលជាកិរិយា, ព្រោះហេតុដូច្នោះ ទើប មិនគួរពោលបច្ចយាការ ដោយអំណាចនៃកិរិយាទេ ។

ដោយប្រការដូច្នេះ ដោយបច្ចយាការនេះ ដែលព្រះមានព្រះភាគទ្រង់មាន វាទៈដ៏ប្រសើរ ត្រាស់ទុកដោយប្រភេទមិនមែនតិច ក្នុងធម៌ដែលជាកុសល អកុសល និងអព្យាកតៈ, ចំណែកក្នុងវិបាកនៃកុសល និងអកុសល ត្រាស់ទុកតែម្យ៉ាងប៉ុណ្ណោះ ដោយអំណាចនៃឧបនិស្សយប្បច្ច័យ; ដើម្បីភាពជំនាញប្រើជាញាណ (បញ្ញា) ក្នុង ប្រភេទធម៌ដែលជាបច្ច័យ ព្រោះការរៀនលំដាប់នៃបរិយត្តិ ការស្តាប់ ការគិត ការ បដិបត្តិ រមែងមិនចាក់ធ្លុះប្រើជាញាណក្នុងបច្ចយាការនេះ សូម្បីក្នុងកាលណា។; ព្រោះហេតុដូច្នោះ អ្នកប្រាជ្ញដែលមានបញ្ញាចេះចាំ គួរធ្វើក្នុងបច្ចយាការនោះ ដោយ លំដាប់នៃបរិយត្តិ **ការស្តាប់ ការគិត និងការបដិបត្តិគ្រប់កាល** ព្រោះកិច្ចដទៃ

ដែលគួរធ្វើឱ្យក្រៃលែងជាងបច្ចយាការនោះ រមែងមិនមានសោះឡើយ ៕

**ចប់ការពណ៌នាអំពីអភិធម្មភាជនិយ**

ក៏បច្ចយាការនេះ ព្រះអង្គទ្រង់នាំចេញមក
សម្តែងចែកទុក ២ បរិវដ្ត គឺដោយអំណាចនៃសុត្តន្ត-
ភាជនិយ និងអភិធម្មភាជនិយប៉ុណ្ណោះដូច្នេះឯង ៕

**បដិច្ចសមុប្បាទវិភង្គនិទ្ទេស**

**ចប់**

# ៧. អដ្ឋកថាសតិបដ្ឋានវិភង្គ

## ពណ៌នាអំពីសុត្តន្តភាជនិយ

ឥឡូវនេះ គប្បីជ្រាបការវិនិច្ឆ័យក្នុងសតិបដ្ឋានវិភង្គ ដែលជាលំដាប់តអំពីបដិច្ចសមុប្បាទវិភង្គនោះតទៅ ៖

ពាក្យថា ៤ ជាពាក្យកំណត់ចំនួន, ដោយពាក្យនោះ ព្រះសាស្ដាទ្រង់សម្ដែងកំណត់សតិបដ្ឋានទុកថា “**មានចំនួនមិនតិចជាងនោះ មិនច្រើនជាងនោះ**” ។

ពាក្យថា **សតិបដ្ឋាន** បានដល់ សតិបដ្ឋាន ៣ យ៉ាង គឺ សតិគោចរ ១, ភារៈនៃព្រះសាស្ដាស្ដេចប្រព្រឹត្តកន្លងសេចក្ដីត្រេកអរ និងការប្រទូសរ៉ាយ ក្នុងពួកសាវ័កអ្នកបដិបត្តិ ៣ យ៉ាង ១ និងតួសតិ ១ ។

ពិតមែន សតិគោចរ (អារម្មណ៍របស់សតិ) លោកហៅថា **សតិបដ្ឋាន** ក្នុងពាក្យថា “ម្នាលភិក្ខុទាំងឡាយ តថាគតនឹងសម្ដែងហេតុនាំឱ្យកើត និងការរលត់ទៅនៃសតិបដ្ឋាន ៤, អ្នកទាំងឡាយចូរស្ដាប់ពាក្យនោះ; ចូរធ្វើមនសិការឱ្យល្អ ។ល។ ម្នាលភិក្ខុទាំងឡាយ ក៏អ្វីទៅជាហេតុនាំឱ្យកើតកាយ ? ការកើតឡើងនៃកាយ រមែងមានព្រោះការកើតឡើងនៃអាហារ”[៧០] ជាដើម; ដោយទំនងនោះ កាយរមែងជាអារម្មណ៍ប្រាកដ, **មិនមែនសតិប្រាកដទេ** ។

គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា **សតិបដ្ឋាន**[៧១] **និងសតិជាដើម** ។ សេចក្ដីនៃពាក្យនោះ គប្បីជ្រាបថា ក៏ឈ្មោះថា **បដ្ឋាន** ព្រោះអត្ថថា ជាទីតាំងមាំ ។

***សួរថា*** អ្វីរមែងតាំងមាំ ?

---

[៧០] សំ. ម.។

[៧១] ពាក្យថា **សតិបដ្ឋាន** = ការចូលទៅតាំងសតិ ។

ឆ្លើយថា **សតិ** ។ ឋានជាទីតាំងមាំនៃសតិ ទើបឈ្មោះថា **សតិបដ្ឋាន** ។

ម្យ៉ាងទៀត ទីតាំងមាំដែលជាប្រធាន ឈ្មោះថា **បដ្ឋាន**, ទីតាំងដែលជាប្រធាននៃសតិ ទើបឈ្មោះថា **សតិបដ្ឋាន** ដូចពាក្យថា ទីដែលជាទីតាំងនៅរបស់ដំរី និងរបស់សេះជាដើមដូច្នោះ [៧២] ។

ការដែលព្រះសាស្តាទ្រង់ប្រព្រឹត្តកន្លងសេចក្តីត្រេកអរ និងការប្រទូសរ៉ាយក្នុងពួកសាវ័កអ្នកបដិបត្តិ ៣ យ៉ាង លោកហៅថា **សតិបដ្ឋាន** ។ ក្នុងពាក្យនេះថា "ព្រះសាស្តាទើបជាអរិយៈសេពធម៌ណា, ធម៌នោះ គឺសតិបដ្ឋាន ៣, ក៏កាលសេពធម៌នោះ ទើបគួរដើម្បីតាមទូន្មានពួកគណៈ" [៧៣] ។ សេចក្តីនៃពាក្យនោះ គប្បីជ្រាបថា ឈ្មោះថា **បដ្ឋាន** ព្រោះជាធម៌គួរឱ្យតាំងទុក, អធិប្បាយថា ព្រោះគួរឱ្យប្រព្រឹត្តទៅ ។

***សួរថា*** គួរឱ្យតាំងទុកដោយធម៌អ្វី ?

ឆ្លើយថា ដោយសតិ, ការឱ្យតាំងទុកដោយសតិ ទើបឈ្មោះថា **សតិបដ្ឋាន** ។

ក៏តួសតិនោះឯង លោកហៅថា **សតិបដ្ឋាន** ក្នុងពាក្យជាដើមថា "សតិ-បដ្ឋាន ៤ ដែលបុគ្គលចម្រើនហើយ ធ្វើឱ្យច្រើនហើយ រមែងញុំាងពោជ្ឈង្គ ៧ **ឱ្យបរិបូរណ៍**" [៧៤] ដូច្នេះ ។ សេចក្តីនៃពាក្យនោះ គប្បីជ្រាបថា ឈ្មោះថា បដ្ឋាន ព្រោះអត្ថថា រមែងតាំងនៅ, អធិប្បាយថា រមែងប្រាកដ គឺឈានចុះហើយ រមែងត្រាច់ទៅ រមែងប្រព្រឹត្តទៅ ។ សតិនោះឯង ឈ្មោះថា **សតិបដ្ឋាន** ព្រោះអត្ថថា តាំងនៅ (ឬការតាំងមាំ) ។ ម្យ៉ាងទៀត ឈ្មោះថា **សតិ** ព្រោះអត្ថថា ការរឭក, ឈ្មោះថា

---

[៧២-៧៣] ចាកសឡាយតនវិភង្គសូត្រ ( ម. ឧ.) ។

[៧៤] ចាកសឡាយតនវិភង្គសូត្រ ( ម. ឧ.) ។

**បដ្ឋាន** ព្រោះអត្ថថា ចូលទៅតាំងមាំ ។ ដោយប្រការដូច្នេះ សតិនោះផង បដ្ឋាននោះផង ទើបឈ្មោះថា **សតិបដ្ឋាន** ។ សតិបដ្ឋាននោះ ព្រះមានព្រះភាគជាម្ចាស់ទ្រង់ប្រាថ្នាយកក្នុងទីនេះ ។

**សួរថា** កាលបើដូច្នេះ ព្រោះហេតុអ្វី លោកទើបធ្វើពាក្យសតិបដ្ឋាន ឱ្យជាពហុវចនៈទៅវិញ ?

ឆ្លើយថា ព្រោះសភាវៈនៃសតិមានច្រើន ។

ពិតមែន លោកធ្វើសតិទុកច្រើន ក៏ព្រោះសេចក្តីផ្សេងគ្នានៃអារម្មណ៍ ។

**សួរថា** ព្រោះហេតុអ្វី ទើបព្រះមានព្រះភាគជាម្ចាស់ ត្រាស់សតិបដ្ឋានទុក ៤ ប៉ុណ្ណោះ ដោយមិនខ្វះ មិនលើស ?

ឆ្លើយថា ព្រោះនឹងឱ្យជាប្រយោជន៍ដ៏សមគួរដល់វេនេយ្យសត្វ។ ពិតមែន សត្វទាំងឡាយ ប្រភេទតណ្ហាចរិត និងទិដ្ឋិចរិត ឬសមថយានិក និងវិបស្សនាយានិក ប្រព្រឹត្តទៅ ២ យ៉ាង ដោយអំណាចនៃមន្ទបុគ្គល និងតិក្ខបុគ្គល (គឺចរិតទន់ខ្សោយ និងចាស់ក្លា) កាយានុបស្សនាសតិបដ្ឋាន ដែលជាឱឡារិក (គ្រោតគ្រាត) ជាផ្លូវនៃសេចក្តីបរិសុទ្ធិរបស់បុគ្គលអ្នកមានតណ្ហាចរិតយ៉ាងទន់ខ្សោយ ។ វេទនានុបស្សនា-សតិបដ្ឋានដែលសុខុម ជាផ្លូវនៃសេចក្តីបរិសុទ្ធិរបស់បុគ្គលអ្នកមានតណ្ហាចរិតយ៉ាងចាស់ក្លា ។ ចិត្តានុបស្សនាសតិបដ្ឋានដែលមានអារម្មណ៍ ញែកចែកទៅមិនច្រើនពេក ជាផ្លូវនៃសេចក្តីបរិសុទ្ធិ របស់បុគ្គលអ្នកមានទិដ្ឋិចរិតយ៉ាងទន់ ។ ធម្មានុបស្សនាសតិបដ្ឋាន ដែលមានអារម្មណ៍ញែកចែកចេញច្រើន ជាផ្លូវនៃសេចក្តីបរិសុទ្ធិរបស់បុគ្គលអ្នកមានទិដ្ឋិចរិត យ៉ាងចាស់ក្លា ។

មួយទៀត សតិបដ្ឋានទី ១ ដែលមាននិមិត្ត ដែលបុគ្គលគប្បីសម្រេចបាន ដោយមិនលំបាកជាផ្លូវនៃសេចក្ដីបរិសុទ្ធិរបស់បុគ្គល អ្នកជាសមថយានិកយ៉ាងទន់, សតិបដ្ឋានទី ២ ជាផ្លូវនៃសេចក្ដីបរិសុទ្ធិរបស់បុគ្គលអ្នកជាសមថយានិកយ៉ាងចាស់-ក្លា ព្រោះមិនកើតក្នុងអារម្មណ៍ដែលគ្រោតគ្រាត។ សតិបដ្ឋានទី ៣ មានអារម្មណ៍ដែលញែកចេញមិនច្រើនពេក ជាផ្លូវនៃសេចក្ដីបរិសុទ្ធិរបស់បុគ្គលអ្នកជាវិបស្សនា-យានិកយ៉ាងទន់ ។ សតិបដ្ឋានទី ៤ មានអារម្មណ៍ដែលញែកចេញច្រើនក្រៃលែង ជាផ្លូវនៃសេចក្ដីបរិសុទ្ធិរបស់បុគ្គល អ្នកជាវិបស្សនាយានិកយ៉ាងចាស់ក្លា ។

**ព្រោះហេតុនោះ ព្រះមានព្រះភាគជាម្ចាស់ ត្រាស់សតិបដ្ឋានទុក ៤ ដោយមិនខ្វះ មិនលើស មានប្រការដូច្នេះឯង ៕**

## សតិបដ្ឋានតាមន័យរបស់បករណ៍ [៧៥]

ព្រះមានព្រះភាគត្រាស់សតិបដ្ឋាន ៤ ដើម្បីលះវិបល្លាស ៤ ជាដើម ។

ម្យ៉ាងទៀត ព្រះអង្គត្រាស់សតិបដ្ឋានទុក ៤ ក៏ដើម្បីលះសុភវិបល្លាស សុខវិបល្លាស និច្ចវិបល្លាស អត្តវិបល្លាស គឺយល់ថា ជាសុភ (ល្អ) ជាសុខ ជារបស់ទៀង ជាអត្តា។ ពិតមែន កាយជាអសុភ, តែសត្វទាំងឡាយយល់ខុសដោយសុភវិ-បល្លាសក្នុងកាយនោះ។ ព្រះមានព្រះភាគជាម្ចាស់ ទើបត្រាស់សតិបដ្ឋានទី ១ ទុក ដើម្បីនឹងឱ្យសត្វពួកនោះ លះវិបល្លាសនោះ ដោយការសម្ដែងដល់សភាពជាអសុភក្នុងកាយ។ មួយទៀត បណ្ដាធម៌ទាំងឡាយ មានវេទនាជាដើម សូម្បីដែលសត្វកាន់

---

[៧៥] ន័យនេះ រចនាឡើងដោយភាសារបស់អ្នកកោះលង្កា ។

យកហើយថា ជាសុខ ជារបស់ទៀង ជាអត្តា, តាមពិតវេទនាជាទុក្ខ; ចិត្តក៏មិនទៀង, ធម៌ទាំងឡាយក៏ជាអនត្តា។ តែថា សត្វទាំងឡាយយល់ខុស មានសេចក្តីយល់ឃើញឃ្លៀងឃ្លាតក្នុងធម៌ទាំងឡាយ មានវេទនាជាដើមនោះថា ជាសុខ ជារបស់ទៀង ជាអត្តា។ ព្រះមានព្រះភាគជាម្ចាស់ត្រាស់សតិបដ្ឋាន ៣ ដែលនៅសល់ក៏ដើម្បីឱ្យសត្វពួកនោះ លះវិបល្លាសនោះ ដោយការសម្តែងដល់សភាវៈជាទុក្ខជាដើម ក្នុងធម៌មានវេទនាជាដើមនោះ គប្បីជ្រាបថា "បានត្រាស់សតិបដ្ឋានទុក ៤ ប៉ុណ្ណោះ មិនខ្វះ មិនលើស" ដើម្បីលះវិបល្លាសក្នុងសេចក្តីយល់ឃើញថា ជាសុភ ជាសុខ ជារបស់ទៀង ជាអត្តា យ៉ាងនេះ ដោយប្រការដូច្នេះ។ ក៏ដើម្បីការលះវិបល្លាសប៉ុណ្ណោះ ក៏មិនមែន, សេចក្តីពិត គប្បីជ្រាបថា ព្រះអង្គត្រាស់សតិបដ្ឋានទុក ៤ ដើម្បីលះឱឃៈ ៤ យោគៈ ៤ អាសវៈ ៤ គន្ថៈ ៤ ឧបាទាន ៤ អគតិ ៤ និងដើម្បីឱ្យកំណត់ដឹងអាហារ ៤ ដែរ ៕

## ន័យរបស់បករណ៍មានត្រឹមតែប៉ុណ្ណេះ

## ន័យរបស់អដ្ឋកថា

ក៏ក្នុងអដ្ឋកថា លោកពោលពាក្យទុកត្រឹមប៉ុណ្ណេះថា "សតិបដ្ឋានមានតែម្យ៉ាងប៉ុណ្ណោះ ដោយអំណាចនៃការរឭក និងដោយអំណាចនៃការប្រជុំដោយសេចក្តីតែម្យ៉ាងជាមួយគ្នា, តែថា មាន ៤ ដោយអំណាចនៃអារម្មណ៍"។ ដូចឧបមាថា ក្នុងនគរមួយមានទ្វារ ៤ ជនទាំងឡាយអ្នកមកអំពីទិសខាងកើត កាន់យករបស់ដែលមាននៅទិសខាងកើត ហើយក៏ចូលទៅកាន់នគរ តាមទ្វារទិសខាងកើតនោះ

ឯង ។ អ្នកមកពីទិសខាងត្បូង, អ្នកមកពីទិសខាងលិច, អ្នកមកពីទិសខាងជើង កាន់យករបស់ដែលមាននៅទិសខាងជើងហើយ ក៏ចូលទៅកាន់នគរ តាមទ្វារទិសខាងជើងនោះឯងយ៉ាងណា, ពាក្យឧបមាជាគ្រឿងញុំាងឧបមេយ្យឱ្យដល់ព្រមនេះ បណ្ឌិតគប្បីជ្រាបដូច្នោះចុះ ។ ពិតមែន **ព្រះនិព្វាន** ប្រៀបដូច**ជាមហានគរ** ។ **លោកុត្តរៈមគ្គ** ដែលប្រកបដោយអង្គ ៨ ប្រៀបដូច**ជាទ្វារ** ។ **កាយជាដើម** ប្រៀបដូច**ទិសខាងកើតជាដើម** ។ ជនទាំងឡាយអ្នកមកអំពីទិសខាងកើត កាន់យករបស់ដែលមាននៅទិសខាងកើតហើយ ក៏ចូលទៅកាន់នគរតាម ទ្វារទិសខាងកើតនោះឯងយ៉ាងណា, ព្រះយោគាវចរទាំងឡាយ អ្នកមកដោយកាយានុបស្សនាជាប្រធាន ក៏ដូច្នោះដែរ, ចម្រើនកាយានុបស្សនាដោយ ១៤ បព្វៈ ហើយធ្លាក់ចុះកាន់ព្រះនិព្វានតែម្តង ដោយអរិយមគ្គដែលកើតឡើង ព្រោះអានុភាពនៃការចម្រើនកាយានុបស្សនា ។

ជនទាំងឡាយអ្នកមកអំពីទិសខាងត្បូង កាន់យករបស់ដែលមាននៅទិសខាងត្បូងហើយ ក៏ចូលទៅកាន់នគរ តាមទ្វារទិសខាងត្បូងនោះឯង យ៉ាងណា, ព្រះយោគាវចរទាំងឡាយ អ្នកមកដោយវេទនានុបស្សនាជាប្រធាន ក៏យ៉ាងនោះដែរ ចម្រើនវេទនានុបស្សនាដោយ ៩ បព្វៈ ហើយធ្លាក់ចុះកាន់ព្រះនិព្វានតែម្តង ដោយអរិយមគ្គកើតឡើង ព្រោះអានុភាពនៃការចម្រើនវេទនានុបស្សនា ។

ជនទាំងឡាយអ្នកមកពីទិសខាងលិច កាន់យករបស់ដែលមាននៅទិសខាងលិច ហើយចូលទៅកាន់នគរតាមទ្វារទិសខាងលិចនោះឯង យ៉ាងណា, ព្រះយោគីទាំងឡាយអ្នកមកដោយចិត្តានុបស្សនាជាប្រធាន ក៏យ៉ាងនោះដែរ ចម្រើនចិត្តានុបស្សនា ១៦ បព្វៈ ហើយធ្លាក់ចុះកាន់ព្រះនិព្វានតែម្តង ដោយអរិយមគ្គដែលកើត

ឡើង ព្រោះអានុភាពនៃការចម្រើនចិត្តានុបស្សនា ។

ជនទាំងឡាយអ្នកមកពីទិសខាងជើង កាន់យករបស់ដែលមាននៅទិសខាងជើង ហើយចូលទៅកាន់នគរ តាមទ្វារទិសខាងជើងនោះឯង យ៉ាងណា, ព្រះយោគាវចរទាំងឡាយអ្នកមកដោយធម្មានុបស្សនាជាប្រធាន ក៏យ៉ាងនោះដែរ, ចម្រើនធម្មានុបស្សនាដោយ ៥ បព្វៈ ហើយធ្លាក់ចុះកាន់ព្រះនិព្វានតែម្តង ដោយអរិយមគ្គដែលកើតឡើង ព្រោះអានុភាពនៃការចម្រើនធម្មានុបស្សនា ។

ដោយប្រការដូច្នេះ គប្បីជ្រាបថា **"ព្រះមានព្រះភាគជាម្ចាស់ ត្រាស់សតិបដ្ឋានទុក ១ ប៉ុណ្ណោះ ដោយអំណាចនៃការរឭក និងដោយអំណាចនៃការប្រជុំដោយសេចក្តីតែមួយជាមួយគ្នា, តែត្រាស់សតិបដ្ឋានទុក ៤ ដោយអំណាចនៃអារម្មណ៍"** ៕

## កាយានុបស្សនានិទ្ទេស
## ឧទ្ទេសវារកថា

**អធិប្បាយពាក្យថា "ឥធ ភិក្ខុ = ភិក្ខុក្នុងសាសនានេះ"** ៖

ក្នុងពាក្យថា **"ឥធ ភិក្ខុ"** នេះ ព្រះមានព្រះភាគជាម្ចាស់ប្រថាប់នៅទេវលោក ត្រាស់សតិបដ្ឋានវិភង្គនេះ, សូម្បីភិក្ខុមួយរូប ឈ្មោះថា អង្គុយក្នុងសំណាក់របស់ព្រះអង្គក្នុងទេវលោកនោះ មិនមាន ក៏ពិតមែន; កាលបើយ៉ាងនោះ (ព្រោះហេតុអ្វី ទើបព្រះអង្គត្រាស់ពាក្យថា **"ឥធ ភិក្ខុ"** នេះ, ក៏ព្រោះសតិបដ្ឋាននោះ ជាអារម្មណ៍របស់ភិក្ខុ, ភិក្ខុទាំងឡាយក៏ចម្រើនសតិបដ្ឋាននេះ, ព្រោះហេតុនោះ ទើប

ព្រះអង្គត្រាស់ពាក្យថា “**ឥធ ភិក្ខុ**” ។

**សួរថា** ក៏ពួកភិក្ខុប៉ុណ្ណោះឬ ចម្រើនសតិបដ្ឋាននេះ ភិក្ខុនីជាដើម មិនចម្រើនទេឬ ?

ឆ្លើយថា **សូម្បីជនពួកដទៃមានភិក្ខុនីជាដើមក៏ចម្រើនបានដែរ, តែភិក្ខុទាំងឡាយ ជាបរិស័ទថ្នាក់ប្រសើរ** ទើបព្រះមានព្រះភាគជាម្ចាស់ ត្រាស់ថា “**ឥធ ភិក្ខុ**” ព្រោះភិក្ខុជាបរិស័ទថ្នាក់ឧត្តម ដោយប្រការដូច្នេះ។ ម្យ៉ាងទៀត ព្រះអង្គត្រាស់យ៉ាងនោះ ក៏ព្រោះដើម្បីសម្ដែងភាវៈជាភិក្ខុដោយការបដិបត្តិ; ពិតមែន បុគ្គលណាធ្វើដំណើរទៅកាន់ការបដិបត្តិនេះ, បុគ្គលនោះ ឈ្មោះថា **ភិក្ខុ**; ព្រោះថា បុគ្គលអ្នកបដិបត្តិ នឹងជាទេវតា ឬជាមនុស្សក៏ដោយ, រមែងដល់ការរាប់ថា **ភិក្ខុទាំងអស់**; ដូចយ៉ាងព្រះគាថាដែលត្រាស់ទុកថា ៖

**“សូម្បីបើថា អ្នកណាមានធម៌ដែលប្រដាប់ហើយ អ្នកស្ងប់ហើយ អ្នកទូន្មានខ្លួនហើយ អ្នកទៀង អ្នកប្រព្រឹត្តព្រហ្មចរិយៈ, លះបង់អាជ្ញាក្នុងសត្វទាំងពួង ប្រព្រឹត្តធម៌ដែលស្ងប់ អ្នកនោះ ជាព្រាហ្មណ៍ ជាសមណៈ ជាភិក្ខុ”** [៧៦] ៕

## អធិប្បាយពាក្យថា
## “អជ្ឈត្តំ កាយេ ៈ ក្នុងកាយខាងក្នុង”

ពាក្យថា **អជ្ឈត្តំ** ដូច្នេះ លោកប្រាថ្នាយកកាយខាងក្នុងដែលជារបស់ខ្លួន។ ព្រោះហេតុនោះ ពាក្យថា “**អជ្ឈត្តំ កាយេ**” ទើបបានដល់ ក្នុងកាយរបស់ខ្លួន។

---

[៧៦] ខុ. ធ.។

បណ្ដាពាក្យទាំងនោះ ពាក្យថា **“កាយេ”** បានដល់ ក្នុងរូបកាយ។ ពិតមែន រូបកាយ **ប្រាថ្នាយកថាកាយ** ក្នុងទីនេះ ដូចកាយដំរី កាយសេះ និងកាយរថជាដើម ព្រោះអត្ថថា ជាទីប្រជុំនៃធម៌ គឺអវយវៈតូចធំទាំងឡាយ និងកោដ្ឋាសៈទាំងឡាយ មានសក់ជាដើម។ ក៏រូបកាយលោកប្រាថ្នាយកថា **កាយ** ព្រោះអត្ថថា ជាទីប្រជុំ (សមូហដ្ឋេន) យ៉ាងណា, រូបកាយ លោកក៏ប្រាថ្នាយកកាយ ព្រោះអត្ថថា ជាអណ្ដូងកើតនៃវត្ថុអាក្រក់ (កុច្ឆិតានំ អាយដ្ឋេន)។ ពិតមែន ក៏ឈ្មោះថា កាយ ព្រោះជាអណ្ដូងកើតនៃកោដ្ឋាសៈទាំងឡាយ មានសក់ជាដើម ដែលអាក្រក់ គឺដែលគួរខ្ពើមយ៉ាងក្រៃលែង។ ប្រទេសដែលជាអណ្ដូងកើត ឈ្មោះថា **អាយៈ** ។ គប្បីជ្រាបវិចនត្ថៈក្នុងពាក្យថា **អាយៈ** នេះដូច្នេះ ៖

កាយ ឈ្មោះថា **អាយៈ** (អណ្ដូងកើត) ព្រោះអត្ថថា ជាដែនកើតនៃធម៌ទាំងឡាយ (ឬថាធម៌ទាំងឡាយរមែងកើតពីកាយនេះ ដូច្នេះ កាយនេះទើបឈ្មោះថា **អាយៈ**); **សួរថា** ធម៌ពួកណារមែងកើត ? ឆ្លើយថា កោដ្ឋាសៈទាំងឡាយ មានសក់ជាដើម ដែលគួរខ្ពើមរមែងកើត, ព្រោះហេតុនោះ កាយ ក៏គឺ**អណ្ដូងកើតនៃកោដ្ឋាសៈទាំងឡាយ មានសក់ជាដើម ដែលគួរខ្ពើមក្រៃលែង** ដោយប្រការដូច្នេះ ៕

## អធិប្បាយពាក្យថា

## **កាយេ កាយានុបស្សី** = មានប្រក្រតីតាមឃើញកាយក្នុងកាយ

ពាក្យថា **កាយានុបស្សី** បានដល់ មានប្រក្រតីតាមឃើញកាយ ឬថា

ឃើញកាយរឿយៗ; ក៏ពាក្យនេះ បណ្ឌិតគប្បីជ្រាបថា ព្រះមានព្រះភាគជាម្ចាស់ សូម្បីត្រាស់ពាក្យថា **កាយេ** ដូច្នេះ ហើយទ្រង់ធ្វើសព្ទកាយទី ២ ថា **"កាយានុបស្សី"** ទៀត ដើម្បីនឹងសម្ដែងការកំណត់ និងការញែកឃនៈជាដើមមិនឱ្យលាយគ្នា ។ ព្រោះហេតុនោះ ទើបមិនបានត្រាស់ថា **មានប្រក្រតីតាមឃើញវេទនាក្នុងកាយ** ឬថា **មានប្រក្រតីតាមឃើញចិត្ត, មានប្រក្រតីតាមឃើញធម៌ក្នុងកាយឡើយ**; តាមពិត ទ្រង់សម្ដែងការកំណត់មិនឱ្យលាយគ្នា ដោយការសម្ដែងអាការគឺការតាមឃើញកាយក្នុងវត្ថុ ពោលគឺកាយ ក្នុងពាក្យថា **"កាយេ កាយានុបស្សីយេវ** = មានប្រក្រតីតាមឃើញកាយក្នុងកាយប៉ុណ្ណោះ" ។ ដោយទំនងតែមួយជាមួយគ្នា ក៏មិនត្រាស់ថា មានប្រក្រតីតាមឃើញធម៌ដទៃត្រឹមតែម្យ៉ាង ក្រៅអំពីអវយវៈតូច ធំក្នុងកាយ, ទាំងមិនត្រាស់ថា មានប្រក្រតីតាមឃើញ **ស្រី ប្រុស ក្រៅអំពីសក់រោមជាដើម** ។ សូម្បីកាយណា ពោលគឺការប្រជុំនៃភូតរូប និងឧបាទាយរូប មានសក់រោមជាដើម មានក្នុងកាយនេះ ទើបមិនបានត្រាស់ថា មានប្រក្រតីតាមឃើញ ធម៌ត្រឹមតែមួយក្រៅអំពីភូតរូប និងឧបាទាយរូបសូម្បីក្នុងកាយនោះ ។ ការពិតទ្រង់សម្ដែងការចែកឃនៈចេញ ដោយការសម្ដែងវត្ថុពោលគឺកាយ ដោយអំណាចនៃកាយ គឺជាទីប្រជុំនោះឯង ដោយប្រការផ្សេងៗ ថា ជាអ្នកមានប្រក្រតីតាមឃើញការប្រជុំនៃអវយវៈតូចធំទាំងឡាយ ប្រៀបដូចបុគ្គលអ្នកត្រួតមើលចំណែកប្រកបនៃរថ, ជាអ្នកមានប្រក្រតីតាមឃើញនូវកោដ្ឋាសៈទាំងឡាយមានសក់ជាដើម ប្រៀបដូចបុគ្គលអ្នកត្រួតមើលចំណែកប្រកបតូចធំរបស់ក្រុង, ជាអ្នកមានប្រក្រតីតាមឃើញ ការប្រជុំរបស់ភូតរូប ឧបាទាយរូបទាំងឡាយ ប្រៀបដូច

បុគ្គលបកសន្ទបចេក យកបណ្តូលចេញពីដើម និងប្រៀបដូចអ្នកលាកណ្តាប់ដៃដែលទទេដូច្នោះ។ ពិតមែន ក្នុងអធិការនេះ នឹងជាការដែលក្រៅពីកាយ គឺទីប្រជុំតាមដែលពោលហើយក៏ដោយ នឹងជាស្រី ជាប្រុស ឬថា ជាធម៌អ្វីៗ ដទៃក៏ដោយ រមែងមិនប្រាកដ ។ តែថាសត្វទាំងឡាយ រមែងធ្វើការប្រកាន់មាំ ព្រោះសេចក្តីយល់ឃើញខុសក្នុងហេតុត្រឹមតែថា ការប្រជុំនៃធម៌តាមដែលពោលហើយដោយមានប្រការនោះៗ; ព្រោះហេតុនោះ ទើបបុរាណាចារ្យទាំងឡាយពោលថា៖

**“យំ បស្សតិ ន តំ ទិដ្ឋំ យំ ទិដ្ឋំ តំ ន បស្សតិ**
**អបស្សំ ពជ្ឈតេ មុឡ្ហោ ពជ្ឈមានោ ន មុច្ចតិ**

បុគ្គលឃើញនូវវត្ថុណា[៧៧] វត្ថុនោះ[៧៨] ឈ្មោះថា គេ
ឃើញហើយ ក៏មិនមែន, វត្ថុណា[៧៩] ដែលគេឃើញហើយ
គេឈ្មោះថា រមែងមិនឃើញនូវវត្ថុនោះ, បុគ្គលអ្នកវង្វេង
កាលមិនឃើញរមែងជាប់, កាលជាប់រមែងមិនរួចផុត”។

ពាក្យថា **មានប្រក្រតីតាមឃើញ** (ពិចារណា) **កាយក្នុងកាយ** លោកពោលហើយ ដើម្បីសម្តែងការចែកឃនៈជាដើម ដោយប្រការដូច្នេះ។ មួយទៀត ក្នុងអធិការនេះបណ្ឌិតគប្បីជ្រាបសូម្បីសេចក្តីនេះ ដោយអាទិសព្ទថា៖ ពិតមែន ព្រះយោគាវចរមានប្រក្រតី តាមឃើញកាយក្នុងកាយនេះប៉ុណ្ណោះ, មិនមែនមានប្រក្រតីឃើញធម៌ដទៃទេ ។ **សួរថា** សេចក្តីនេះ លោកអធិប្បាយទុកយ៉ាងណា ?

---

[៧៧] គឺឃើញជាស្រី ជាប្រុស ។

[៧៨-៧៩] សំដៅដល់រូបាយតនៈ ។

ឆ្លើយថា លោកអធិប្បាយថា "ជនទាំងឡាយអ្នកមានប្រក្រតីតាមឃើញថ្ងៃបណ្តើរកូន សូម្បីដែលមិនមានទឹកថា ជាទឹកយ៉ាងណា, ព្រះយោគាវចរ អ្នកតាមឃើញកាយនេះ ដែលជារបស់មិនទៀង ជាទុក្ខ ជាអនត្តា ជាអសុភនោះឯងថា ជារបស់ទៀង ជាសុខ ជាអត្តា ជាសុភ យ៉ាងនោះក៏មិនបាន, តាមពិត មានប្រក្រតីតាមឃើញកាយ ក៏គឺមានប្រក្រតីតាមឃើញការប្រជុំនៃអាការរបស់មិនទៀង ជាទុក្ខ ជាអនត្តា ជាអសុភប៉ុណ្ណោះ" ។

ម្យ៉ាងទៀត បណ្ឌិតគប្បីជ្រាបសេចក្តីសូម្បីយ៉ាងនេះថា កាយនេះណា មានខ្យល់អស្សាសបស្សាសៈជាខាងដើម និងមានឆ្អឹងដែលបែកទៅជាកម្ទេចជាទីបំផុត ដែលព្រះមានព្រះភាគជាម្ចាស់ ត្រាស់ទុកក្នុងមហាសតិបដ្ឋានដោយន័យថា **"ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងសាសនានេះ នៅក្នុងព្រៃក៏ដោយ ។ ល ។ លោករមែងមានសតិពិចារណាខ្យល់ដកដង្ហើមចូល"** ជាដើម ។ ឯកាយណា ដែលព្រះធម្មសេនាបតីសារីបុត្តពោលទុកក្នុងបដិសម្ភិទាថា "ភិក្ខុពួកខ្លះ ក្នុងសាសនានេះ រមែងតាមឃើញកាយ គឺបឋវី ដោយសភាពជារបស់មិនទៀង, ដោយទំនងជាមួយគ្នា រមែងតាមឃើញកាយ គឺអាបោ, កាយ គឺតេជោ, កាយ គឺវាយោ, កាយ គឺសក់, កាយ គឺរោម, កាយ គឺសម្បុរ, កាយ គឺស្បែក, កាយ គឺសាច់, កាយ គឺឈាម, កាយ គឺសរសៃ, កាយ គឺឆ្អឹង, កាយ គឺខួរក្នុងឆ្អឹង" [៨០] ដោយសភាពជារបស់មិនទៀងជាដើម; ក៏ព្រោះការតាមឃើញនៅក្នុងកាយនេះឯង នៃកាយទាំងពួង ទើបឈ្មោះថា **កាយេ កាយានុបស្សី = មានប្រក្រតីតាមឃើញកាយ**

---

[៨០-៨១] ខុ. បដិ. ។

ក្នុងកាយ ។

មួយយ៉ាងទៀត គប្បីជ្រាបអត្ថយ៉ាងនេះថា ឈ្មោះថា មានប្រក្រតីតាមឃើញកាយ ពោលគឺទីប្រជុំនៃធម៌ មានសក់ជាដើមក្នុងកាយ ដោយការមិនតាមឃើញអ្វីៗ ដែលគប្បីកាន់យកក្នុងកាយយ៉ាងនេះថា ជាយើង ឬថា ជារបស់យើង, តែព្រោះការតាមឃើញទីប្រជុំនៃធម៌ផ្សេងៗ មានសក់ និងរោមជាដើមនោះនុ៎ះឯង ទើបឈ្មោះថា **កាយេ កាយានុបស្សី** ។

ម្យ៉ាងវិញទៀត គប្បីជ្រាបសេចក្តីសូម្បីយ៉ាងនេះថា ឈ្មោះថា មានប្រក្រតីតាមឃើញកាយក្នុងកាយ សូម្បីព្រោះការតាមឃើញកាយ ពោលគឺទីប្រជុំនៃអាការៈដែលមានអនិច្ចលក្ខណៈជាដើមទាំងពួង ដែលមានន័យមកហើយ ក្នុងបដិសម្ភិទាមគ្គដោយលំដាប់ថា "ភិក្ខុរមែងតាមឃើញក្នុងកាយនេះដោយសេចក្តីថា ជារបស់មិនទៀង មិនមែនដោយសេចក្តីថា ជារបស់ទៀង [៨១] ជាដើម ។ ពិតយ៉ាងនោះ មែនភិក្ខុនេះធ្វើដំណើរទៅកាន់ការបដិបត្តិ គឺការតាមឃើញកាយក្នុងកាយ [៨២] រមែងតាមឃើញកាយនេះ ដោយសភាពជារបស់មិនទៀង ដោយអំណាចនៃអនុបស្សនា ៧ មានអនិច្ចានុបស្សនាជាដើម មិនមែនតាមឃើញដោយសភាពជារបស់ទៀង, រមែងតាមឃើញដោយសេចក្តីជាទុក្ខ មិនមែនតាមឃើញដោយសេចក្តីជាសុខ, រមែងតាមឃើញដោយសេចក្តីជាអនត្តា មិនមែនតាមឃើញដោយភាពជាអត្តា, រមែងនឿយណាយ មិនមែនរីករាយ, រមែងប្រាសចាកតម្រេក មិនមែនតម្រេក, រមែងឱ្យរលត់ មិនមែនឱ្យកើត,រមែងលះបង់ចោល មិនមែនប្រកាន់; ភិក្ខុនោះកាលតាមឃើញ

---

[៨២] ឬប្រើពាក្យថា ពិចារណាកាយក្នុងកាយរឿយៗ ក៏បាន ។

កាយនោះ ដោយសភាពជារបស់មិនទៀង រមែងលះនិច្ចសញ្ញា, កាលតាមឃើញដោយសេចក្ដីថាជាទុក្ខ រមែងលះសុខសញ្ញា, កាលតាមឃើញដោយសេចក្ដីថា ជាអនត្តា រមែងលះអត្តសញ្ញា, កាលនឿយណាយ រមែងលះសេចក្ដីរីករាយ, កាលប្រាសចាកតម្រេក រមែងលះរាគៈ, កាលបើរលត់ រមែងលះសមុទ័យ និងកាលបើលះបង់ចោល រមែងលះការប្រកាន់” [៨៣] ៕

## អធិប្បាយពាក្យថា វិហរតិ = នៅ

ពាក្យថា **វិហរតិ** នោះ ជាពាក្យសម្ដែងការប្រកបការនៅដោយឥរិយាបថយ៉ាងណាមួយ ក្នុងការនៅដោយឥរិយាបថ ៤ ឥរិយាបថណាមួយ, អធិប្បាយថា កាត់ដាច់ការបៀតបៀនឥរិយាបថមួយដោយឥរិយាបថនោះ ហើយទើបនាំអត្តភាពដែលនៅមិនទាន់ធ្លាក់ទៅ ឱ្យប្រព្រឹត្តទៅ ៕

## អធិប្បាយពាក្យថា

## **ពហិទ្ធា កាយេ** = ក្នុងកាយខាងក្រៅ ជាដើម

ពាក្យថា “**ពហិទ្ធា កាយេ**” បានដល់ ក្នុងកាយរបស់អ្នកដទៃ ។

ពាក្យថា “**អជ្ឈត្តពហិទ្ធា កាយេ**” សេចក្ដីថា ក្នុងកាយរបស់ខ្លួន តាមកាលដ៏សមគួរ, ក្នុងកាយរបស់អ្នកដទៃតាមកាលដ៏សមគួរ ។ ក៏ន័យដំបូង លោកពោលដោយការកំណត់យកកាយរបស់ខ្លួន, ន័យទី ២ លោកពោលដោយការកំណត់

---

[៨៣] ខុ. បដិ. ។

យកកាយរបស់អ្នកដទៃ, ន័យទី ៣ លោកពោលដោយការកំណត់យកកាយរបស់ខ្លួនតាមកាលសមគួរ, ក្នុងកាយរបស់អ្នកដទៃតាមកាលសមគួរ ។ **ក៏ឈ្មោះថាអារម្មណ៍ដែលប៉ះខ្ទប់ទាំងខាងក្នុង ទាំងខាងក្រៅ (ព្រមគ្នា) រមែងមិនមាន**, តែថា លោកពោលកាលជាទីសញ្ចររបស់កម្មដ្ឋាន ដែលស្ទាត់ជំនាញហើយៗ ទុកក្នុងពាក្យថា "**អជ្ឈត្តពហិទ្ធា**" នេះ ៕

## អធិប្បាយពាក្យថា
## អាតាបី សម្បជានោ សតិមា

ពាក្យថា "**អាតាបី** = មានសេចក្ដីព្យាយាម" នេះ ជាពាក្យសម្ដែងការប្រកបសេចក្ដីព្យាយាមរបស់អ្នកកំណត់កាយ (ជាអារម្មណ៍); ក៏ព្រោះហេតុដែលភិក្ខុនោះប្រកបសេចក្ដីព្យាយាមដែលលោកឱ្យឈ្មោះថា **អាតបៈ** ព្រោះជាគ្រឿងដុតបំផ្លាញកិលេសទាំងឡាយក្នុងភពទាំង ៣ ក្នុងសម័យនោះ, ព្រោះហេតុដូច្នោះទើបព្រះមានព្រះភាគត្រាស់ថា **អាតាបី** ។ ពាក្យថា "**សម្បជានោ** = មានសម្បជញ្ញៈ" គឺអ្នកប្រកបព្រមដោយញាណ ពោលគឺសម្បជញ្ញៈដែលកំណត់យកនូវកាយ (ជាអារម្មណ៍) ។

ពាក្យថា "**សតិមា** = មានសតិ" គឺអ្នកប្រកបដោយសតិដែលកំណត់កាយ ។ ក៏ព្រោះហេតុដែលភិក្ខុនេះ កំណត់អារម្មណ៍ដោយសតិហើយ ក៏នៅតាមឃើញដោយបញ្ញា ។ ពិតមែន ក៏ឈ្មោះថា ការតាមឃើញរបស់ភិក្ខុអ្នកវៀរចាកសតិ រមែងមិនមាន ។ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា "**ម្នាលភិក្ខុទាំងឡាយ**

តថាគតពោលសតិនុ៎ះឯងថា ជាធម៌មានប្រយោជន៍ក្នុងទីទាំងពួង"[៨៤] ; ព្រោះហេតុនោះ កាយានុបស្សនាសតិបដ្ឋានកម្មដ្ឋានក្នុងពាក្យថា **កាយេ កាយានុ-បស្សី វិហរតិ** នេះ រមែងជាពាក្យអធិប្បាយដែលព្រះមានព្រះភាគត្រាស់ហើយដោយពាក្យមានប្រមាណប៉ុណ្ណេះ ។ ម្យ៉ាងទៀត គប្បីជ្រាបថា ព្រោះសេចក្តីរួញរាខាងក្នុង ជាធម៌ធ្វើសេចក្តីអន្តរាយដល់ភិក្ខុអ្នកមិនមានអាតាបី, អ្នកមិនមានសម្ប-ជញ្ញៈ រមែងវង្វេងក្នុងការកំណត់ធម៌ដែលជាឧបាយ និងក្នុងការវៀរចាកវត្ថុដែលមិនមែនឧបាយ, អ្នកមានសតិភ្លេច ក៏រមែងជាអ្នកមិនអាចក្នុងការមិនលះបង់ឧបាយ និងក្នុងការកំណត់វត្ថុដែលមិនមែនឧបាយ, ព្រោះហេតុនោះ កម្មដ្ឋានរបស់គេទើបមិនរុងរឿង; ព្រោះហេតុនោះ កម្មដ្ឋាននោះរមែងរុងរឿងដោយអានុភាពនៃធម៌ពួកណា, ដើម្បីការសម្តែងធម៌ពួកនោះ ទើបព្រះមានព្រះភាគត្រាស់ពាក្យនេះថា **"អាតាបី សម្បជានោ សតិមា"** ។ គ្រាទ្រង់សម្តែងកាយានុបស្សនាសតិបដ្ឋាន និងសម្បយោគ (ការប្រកបព្រម) យ៉ាងនេះហើយ ឥឡូវនេះ ដើម្បីនឹងទ្រង់សម្តែងអង្គនៃការលះបង់ ទើបត្រាស់ថា **"វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ"** ៕

## អធិប្បាយពាក្យថា
## វិនេយ្យ លោកេ អភិជ្ឈាទោមនស្សំ[៨៥]

បណ្តាពាក្យទាំងនោះ ពាក្យថា **វិនេយ្យ** បានដល់ នាំចេញហើយ ដោយ

---

[៨៤] សំ. ម. ។

[៨៥] ប្រែថា គប្បីកម្ចាត់អភិជ្ឈា និងទោមនស្សចេញបានក្នុងលោក ។

តទង្គវិន័យ ឬវិក្ខម្ភនវិន័យ។ កាយនេះឯងដែលផ្សេងដោយកាយខាងក្នុងជាដើម ដែលទ្រង់កំណត់ក្នុងពាក្យថា **លោកេ** នេះ; **កាយនោះឯង** ឈ្មោះថា លោកក្នុងទីនេះ, អធិប្បាយថា នាំអភិជ្ឈាទោមនស្សក្នុងលោកនេះចេញ។ តែព្រោះក្នុងទីនេះ កាមច្ឆន្ទៈរមែងដល់ការសង្គ្រោះដោយ**អភិជ្ឈាសព្ទ**, ព្យាបាទរមែងសង្គ្រោះ ដោយទោមនស្សសព្ទ, ព្រោះហេតុដូច្នោះ គប្បីជ្រាបថា “ការលះនីវរណៈជាពាក្យដែលព្រះមានព្រះភាគត្រាស់ទុកដោយការសម្តែងធម៌ ២ យ៉ាង ដែលមានកម្លាំង ដែលរាប់បញ្ចូលក្នុងនីវរណៈនេះ” ។

មួយទៀត ពោលដោយពិសេស ក្នុងទីនេះ គប្បីជ្រាបថា ព្រះមានព្រះភាគជាម្ចាស់ ត្រាស់ការលះសេចក្តីត្រេកអរដែលមានកាយសម្បត្តិជាមូល ដោយការនាំអភិជ្ឈាចេញ លះការប្រទូសរ៉ាយដែលមានកាយវិបត្តិជាមូល ដោយការនាំទោមនស្សចេញ ត្រាស់ការលះសេចក្តីត្រេកអរក្រៃលែងក្នុងកាយ ដោយការនាំអភិជ្ឈាចេញ លះការមិនត្រេកអរក្រៃលែងក្នុងកាយភាវនា (ការចម្រើនកាយ) ដោយការនាំទោមនស្សចេញ និងត្រាស់ការលះនូវការដាក់បន្ថែមក្នុងវត្ថុដែលមិនមានក្នុងកាយដែលមានសេចក្តីមិនល្អ សេចក្តីសុខជាដើម ដោយការនាំអភិជ្ឈាចេញ លះការនាំចេញនូវវត្ថុដែលមិនមានក្នុងកាយដែលមានសេចក្តីមិនល្អ សេចក្តីសុខជាដើម ដោយការនាំទោមនស្សចេញ។ ដោយពាក្យនោះ អានុភាពនៃសេចក្តីព្យាយាម និងភាពជាអ្នកអាចក្នុងសេចក្តីព្យាយាម រមែងជាពាក្យដែលព្រះមានព្រះភាគសម្តែងហើយដល់ព្រះយោគាវចរ។ ពិតមែន អានុភាពនៃសេចក្តីព្យាយាមនោះ រមែងរួចផុតពីសេចក្តីត្រេកអរ ប្រទូសរ៉ាយ អត់ធន់ចំពោះសេចក្តីមិនត្រេកអរ និងសេចក្តីត្រេកអរ

ទាំងវៀរចាកការដាក់បន្ថែមក្នុងវត្ថុដែលមិនមាន និងវៀរចាកការនាំវត្ថុ ដែលមានចេញទៅ។ ក៏ព្រះយោគាវចរនោះ វៀរចាកសេចក្ដីត្រេកអរ ប្រទូសរ៉ាយ អត់ធន់ចំពោះសេចក្ដីមិនត្រេកអរ និងត្រេកអរ ការមិនដាក់បន្ថែមក្នុងវត្ថុដែលមិនមាន និងមិននាំវត្ថុដែលមានចេញទៅ ទើបឈ្មោះថាអ្នកមានអំណាចក្នុងការព្យាយាម ។

ន័យមួយទៀត គប្បីជ្រាបក្នុងពាក្យថា **"កាយេ កាយានុបស្សី"** នេះ ព្រះមានព្រះភាគត្រាស់កម្មដ្ឋានទុកដោយអនុបស្សនា(ការតាមឃើញ) ។ ក្នុងពាក្យថា **"វិហរតិ"** នេះ ត្រាស់ការរក្សាកាយរបស់អ្នកបដិបត្តិកម្មដ្ឋាន ដោយការនៅតាមដែលពោលហើយ ។ ក្នុងពាក្យថា **"អាតាបី"** ជាដើម ត្រាស់សម្មប្បធានទុកដោយអាតបៈ, ត្រាស់កម្មដ្ឋានដែលមានប្រយោជន៍ទាំងពួង ឬឧបាយជាគ្រឿងរក្សាកម្មដ្ឋានទុកដោយសតិសម្បជញ្ញៈ ។ ត្រាស់ការបានសមថៈ ដោយសតិ ឬដោយអំណាចនៃកាយានុបស្សនា, ត្រាស់វិបស្សនាទុកដោយសម្បជញ្ញៈ, និងត្រាស់ផលនៃភាវនាទុក ដោយការនាំអភិជ្ឈាទោមនស្សចេញ ៕

ចប់ការពណ៌នានៃឧទ្ទេស កាយានុបស្សនាសតិបដ្ឋាន

## ពណ៌នាអំពីអត្ថនៃវេទនានុបស្សនានិទ្ទេសជាដើម

វិនិច្ឆ័យក្នុងឧទ្ទេស **នៃវេទនានុបស្សនាសតិបដ្ឋាន** ជាដើម គប្បីជ្រាប **វេទនា**ខាងក្នុងជាដើម ដោយន័យដែលពោលហើយនុ៎ះឯង; ក៏បណ្ដាវេទនាជាដើមនោះ ព្រះមានព្រះភាគជាម្ចាស់ត្រាស់ការកំណត់ទុក ៣ យ៉ាង គឺក្នុងវេទនាជាដើមរបស់ខ្លួន ១, ក្នុងវេទនាជាដើមរបស់អ្នកដទៃ ១, ក្នុងវេទនាជាដើមរបស់ខ្លួនតាម

កាលដ៏សមគួរ និងរបស់អ្នកដទៃតាមកាលដ៏សមគួរ ១។ ក៏ប្រយោជន៍ក្នុងការពោលម្ដងទៀតនូវធម៌មានវេទនាជាដើម ក្នុងពាក្យទាំងឡាយមានពាក្យថា **"វេទនាសុ វេទនានុបស្សី"** ជាដើម គប្បីជ្រាបដោយន័យដែលពោលហើយ ក្នុងកាយានុ-បស្សនានោះចុះ ។

ក្នុងពាក្យថា **"វេទនាសុ វេទនានុបស្សី, ចិត្តេ ចិត្តានុបស្សី, ធម្មេសុ ធម្មានុបស្សី"** នេះ ពាក្យថា **"វេទនា"** បានដល់ វេទនា ៣, ឯវេទនានោះ ក៏ត្រឹមតែជាលោកិយប៉ុណ្ណោះ។ សូម្បីចិត្តក៏ជាលោកិយ, សូម្បីធម៌ទាំងឡាយ ក៏យ៉ាងនោះដែរ។ ការចែកធម៌ពួកនោះ នឹងប្រាកដក្នុងនិទ្ទេសវារៈ; តែក្នុងទីនេះ វេទនាដែលភិក្ខុគប្បីតាមឃើញ (ពិចារណា) បានដោយប្រការណា, កាលតាមឃើញដោយប្រការនោះ ក៏គប្បីជ្រាបថា **"ជាអ្នកមានប្រក្រតី តាមឃើញវេទនាក្នុងវេទនាទាំងឡាយ"** ។ ក្នុងចិត្ត និងធម៌ទាំងឡាយ ក៏ន័យនេះដែរ ។

**សួរថា វេទនា**ព្រះយោគាវចរនឹងគប្បីតាមឃើញយ៉ាងណា ?

ឆ្លើយថា **សុខវេទនាជាមុនសិន** គប្បីតាមឃើញដោយសេចក្ដីជាទុក្ខ, ទុក្ខវេទនា គប្បីតាមឃើញដោយសេចក្ដីដូចជាកូនសរ (គ្រាប់ព្រួញ), អទុក្ខមសុខ-វេទនា គប្បីតាមឃើញដោយសេចក្ដីជារបស់មិនទៀង; ដូចដែលព្រះមានព្រះភាគត្រាស់ទុកថា ៖

**"ភិក្ខុណាឃើញសុខ ដោយសេចក្ដីជាទុក្ខ, ឃើញទុក្ខ ដោយសេចក្ដីជាកូនសរ, ឃើញអទុក្ខមសុខដែលស្ងប់ហើយ ដោយសេចក្ដីជាសភាពមិន**

**ទៀង; ភិក្ខុនោះឯងជាអ្នកឃើញប្រពៃ និងជាអ្នកស្ងប់ហើយត្រាច់ទៅ”** [៨៦] ។

មួយទៀត វេទនាទាំងអស់តែម្តង គប្បីតាមឃើញថា ជាទុក្ខប៉ុណ្ណោះក៏បាន; សេចក្តីនេះសមដូចព្រះមានព្រះភាគត្រាស់ទុកថា **“វេទនាយ៉ាងណាមួយ វេទនានោះទាំងអស់ តថាគតពោលថា ជាទុក្ខ”** [៨៧] ។ សុខវេទនា គប្បីតាមឃើញដោយសេចក្តីជាទុក្ខ ក៏បាន; ដូចពាក្យដែលត្រាស់ទុកថា “ម្នាលវិសាខៈមានអាយុ សុខវេទនាកាលតាំងនៅ ក៏ជាសុខ កាលប្រែប្រួលទៅ ក៏ជាទុក្ខ” [៨៨]; បណ្ឌិតគួរញុំាងពាក្យទាំងអស់ឱ្យពិស្តារ ។

ម្យ៉ាងទៀត គប្បីតាមឃើញវេទនា ដោយអំណាចនៃអនុបស្សនា ៧ មានអនិច្ចានុបស្សនាជាដើមខ្លះក៏បាន ។ ពាក្យដែលនៅសល់ នឹងមានច្បាស់ក្នុងនិទ្ទេសវារៈ ។ សូម្បីក្នុងចិត្ត និងធម៌ទាំងឡាយ ចំពោះចិត្ត គប្បីតាមឃើញដោយអំណាចនៃអនុបស្សនា ៧ មានអនិច្ចានុបស្សនាជាដើម ដែលមានប្រភេទផ្សេងគ្នាដោយសេចក្តីជា**អារម្មណ៍ អធិបតី សហជាត ភូមិ កម្មវិបាក និងកិរិយា**ជាដើម និងដោយអំណាចនៃការប្លែកផ្សេងៗ គ្នានៃចិត្ត មានរាគៈជាដើមដែលមានមកហើយក្នុងនិទ្ទេសវារៈ ។ ធម៌ទាំងឡាយ គប្បី**តាមឃើញដោយអំណាចនៃសលក្ខណៈ និងសាមញ្ញលក្ខណៈ សុញ្ញតាធម៌ អនុបស្សនា ៧ មានអនិច្ចានុបស្សនាជាដើម** និងដោយអំណាចនៃការផ្សេងដោយធម៌ដែលស្ងប់ និងមិនស្ងប់ជាដើម ដែលមានមកហើយក្នុងនិទ្ទេសវារៈ ។ ពាក្យដែលនៅសល់ មានន័យដូចដែលពោលហើយនុ៎ះឯង ។ ក៏ក្នុងអធិការនេះ អភិជ្ឈា ទោមនស្សក្នុងលោក ពោលគឺកាយ

---

៨៦-៨៧-៨៨ សំ. សឡា. ។

ដែលបុគ្គលណា លះបានហើយ, អភិជ្ឈា ទោមនស្សនោះ សូម្បីក្នុងលោក ពោល គឺវេទនាជាដើម ក៏ឈ្មោះថា បុគ្គលនោះ លះបានហើយដូចគ្នាដែរ ក៏ពិតមែន, តែ ព្រះមានព្រះភាគជាម្ចាស់ ត្រាស់ក្នុងសតិបដ្ឋានទាំងអស់ ដោយអំណាចនៃបុគ្គល ផ្សេងៗ និងដោយអំណាចនៃការចម្រើនសតិបដ្ឋាន ដែលកើតឡើងក្នុងខណៈនៃចិត្ត ដែលប្លែកផ្សេងគ្នា ។ ពិតមែន ការលះអភិជ្ឈា ទោមនស្ស ក្នុងលោកមួយចេញបាន ហើយ, ក៏ឈ្មោះថា លះអភិជ្ឈា ទោមនស្ស ក្នុងលោកដែលនៅសល់បាន ។ ដោយ ហេតុនោះឯង គប្បីជ្រាបថា ព្រះមានព្រះភាគជាម្ចាស់ ត្រាស់ពាក្យនោះទុក ក៏ដើម្បីសម្តែងការលះអភិជ្ឈា ទោមនស្ស ក្នុងលោកនោះរបស់បុគ្គលនោះឯង ៕

**ចប់ឧទ្ទេសវារកថា**

## និទ្ទេសវារកថា [៨៩]

## ពណ៌នាអំពីកាយានុបស្សនា

ឥឡូវនេះ ព្រះមានព្រះភាគជាម្ចាស់ទ្រង់ប្រាថ្នានឹងធ្វើសត្វទាំងឡាយ ឱ្យ សម្រេចគុណវិសេសផ្សេងៗ មានប្រការមិនមែនតិច ដោយសតិបដ្ឋានទេសនា ទើប ទ្រង់ចែកសម្មាសតិមួយខន្ទុះឯង ចេញជា ៤ ចំណែក ជាសតិបដ្ឋាន ៤ ដោយអំ-ណាចនៃអារម្មណ៍ ដោយន័យថា **“ភិក្ខុក្នុងសាសនានេះ ពិចារណាឃើញកាយ ក្នុងកាយរឿយៗ”** ជាដើមហើយ កាលនឹងទ្រង់កាន់យកសតិបដ្ឋានមួយៗ ពីសតិ-ប្បដ្ឋាន ៤ នោះចែកចេញទៅ ទើបផ្ដើមត្រាស់និទ្ទេសវារៈ ដោយន័យជាដើមថា

---

[៨៩] ម. មូ. ។

**“ក៏ភិក្ខុពិចារណាឃើញកាយ ក្នុងកាយរឿយៗ តើដូចម្ដេច”** ប្រៀបដូចជាងត្បាញដែលឈ្លាស ត្រូវការនឹងធ្វើឧបករណ៍ទាំងឡាយ មានកន្ទេលផែងប្រភេទសាច់គ្រោតគ្រាត សាច់ល្អិត និងជាលជាដើម បានឃើញឫស្សីធំមួយដើម ហើយកាត់ចេញជា ៤ កំណាត់ កាន់យកកំណាត់មួយៗ ពី ៤ កំណាត់នោះ ពុះចេញហើយ ធ្វើឧបករណ៍នោះៗ, ឬថា ប្រៀបដូចជាងមាសដែលឈ្លាស ត្រូវការនឹងធ្វើគ្រឿងប្រដាប់ប្រើប្រាស់ប្រភេទផ្សេងៗ បានមាសដែលបរិសុទ្ធយ៉ាងល្អ កាត់ចេញជា ៤ ចំណែក ហើយកាន់យកមួយចំណែកៗ ពី ៤ ចំណែកនោះ ធ្វើគ្រឿងប្រដាប់ប្រើប្រាស់នោះៗ ។

បណ្ដាពាក្យទាំងនោះ ពាក្យថា **“កថញ្ច** = តើដូចម្ដេច” ជាដើម ជាពាក្យសួរដោយប្រាថ្នានឹងឱ្យពិស្ដារ ។ ក៏ក្នុងអធិការនេះ មានសេចក្ដីដោយសង្ខេបដូច្នេះថា ៖ “ដោយអាការៈយ៉ាងណា ដោយប្រការយ៉ាងណា, ភិក្ខុនោះ ឈ្មោះថា ពិចារណាឃើញកាយក្នុងកាយ” សូម្បីក្នុងវារៈនៃពាក្យសួរដែលនៅសល់ក៏ន័យនេះដែរ ។

ពាក្យថា **“ឥធ ភិក្ខុ”** គឺភិក្ខុក្នុងសាសនានេះ; សព្ទថា **ឥធ** ក្នុងទីនេះ ជាពាក្យសម្ដែងដល់សាសនា ដែលជាទីអាស្រ័យ របស់បុគ្គលអ្នកធ្វើកាយានុបស្សនាដោយប្រការទាំងពួង ដោយអំណាចនៃកាយក្នុងកាយជាដើមឱ្យកើតឡើង និងបដិសេធសេចក្ដីជាយ៉ាងនោះរបស់សាសនាដទៃ; ដូចដែលត្រាស់ទុកថា “ម្នាលភិក្ខុទាំងឡាយ សមណៈមានតែក្នុងសាសនានេះប៉ុណ្ណោះ ។ ល ។ សាសនាដទៃ ទទេចាកសមណៈ” [៩០] ។ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគជាម្ចាស់ ត្រាស់ថា **“ភិក្ខុក្នុងសាសនានេះ”** ។

[៩០] អំ. ចតុក្ក. ។

ពាក្យថា **អជ្ឈត្តំ កាយំ** គឺកាយរបស់ខ្លួន ។

ពាក្យថា **ឧទ្ធំ បាទតលា** គឺពីផ្ទៃបាតជើងឡើងទៅខាងលើ ។

ពាក្យថា **អធោ កេសមត្ថកា** គឺពីចុងសក់ចុះមកខាងក្រោម ។

ពាក្យថា **តចបរិយន្តំ** គឺមានស្បែកដណ្ដប់នៅដោយជុំវិញ ។

ពាក្យថា **បូរន្នានប្បការស្ស អសុចិនោ បច្ចវេក្ខតិ** សេចក្ដីថា ព្រះ-យោគាវចររមែងឃើញថា កាយនេះពេញទៅដោយរបស់មិនស្អាត មានកេសា (សក់) ជាដើម ដែលមានប្រការផ្សេងៗ ។ គឺយ៉ាងណា ? គឺ **អត្ថិ ឥមស្មឹ កាយេ កេសា លោមា ។ បេ ។ មុត្តំ ។**

បណ្ដាពាក្យទាំងនោះ ពាក្យថា **អត្ថិ** = មានព្រម * ។ ពាក្យថា **ឥមស្មឹ** បានដល់ ក្នុងកាយដែលលោកពោលថា ខាងលើ តាំងពីផ្ទៃបាតជើងឡើងទៅ ខាងក្រោម តាំងពីចុងសក់ចុះមក មានស្បែកដណ្ដប់នៅដោយជុំវិញ ពេញទៅដោយរបស់មិនស្អាត មានប្រការផ្សេងៗ នេះ ។ ពាក្យថា **កាយេ** បានដល់ ក្នុងសរីរៈ ។ ពិតមែន សរីរៈ លោកហៅថា **កាយ** ព្រោះសន្សំទុកនូវរបស់មិនស្អាត ជាអណ្ដូងកើតនៃកោដ្ឋាសៈទាំងឡាយ មានសក់ជាដើមដែលគួររង្កៀស ទាំងជាអណ្ដូងកើតនៃរោគជាច្រើនរយ មានរោគភ្នែកជាដើម ។

ពាក្យថា **កេសា លោមា** ជាដើមនេះ គឺអាការ ៣២ មានសក់ជាដើម ។

គប្បីជ្រាបសេចក្ដីសម្ពន្ធ (គឺការជាប់ទាក់ទងគ្នា) ក្នុងកោដ្ឋាសៈពួកនោះ

---

* អត្ថីតិ **សំវិជ្ជន្តិ** ។

យ៉ាងនេះថា សក់មាននៅក្នុងកាយនេះ រោមមាននៅក្នុងកាយនេះជាដើម; ពិតមែន ក្នុងកឡេវរៈ គឺអត្តភាពប្រមាណមួយព្យាមនេះ ខាងលើតាំងពីបាតជើងឡើងទៅ ខាងក្រោមតាំងពីចុងសក់ចុះមក ដោយទីបំផុតជុំវិញៗ តាំងពីស្បែកចូលទៅ ការស្វែងរក សូម្បីអាការៈគ្រប់យ៉ាង នរជនណាៗ រមែងមិនជួបអ្វីៗ គឺនឹងជាកែវមុក្តា, កែវមណី, កែវពិទូរ្យ, ក្រឹស្នា, ចន្ទក្របាម, កប្ហូរ ឬលំអិតសម្រាប់អប់ជាដើម ឬថា វត្ថុដែលជារបស់ស្អាតសូម្បីត្រឹមតែមួយប្រភេទ, តាមពិត រមែងជួបតែវត្ថុដែលមិនស្អាតទាំងអស់ ដែលផ្សេងដោយសក់រោមជាដើម មានប្រការផ្សេងៗ ដែលមានក្លិនស្អុយគួរខ្ពើមយ៉ាងក្រៃលែង ទាំងការមើលក៏មិនជាសិរី ។ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា **"អត្ថិ ឥមស្មឹ កាយេ កេសា លោមា ។ល។ មុត្តំ"** ។ នេះជាការពណ៌នាបទសម្ពន្ធ ក្នុងអធិការនេះ ៕

## កម្មដ្ឋានពោលដោយអំណាចនៃសមថៈឧគ្គហកោសល្យ

ក៏កុលបុត្តអ្នកប្រាថ្នាចម្រើនកម្មដ្ឋាននេះ ដើម្បីសម្រេចអរហត្តជាដើម ត្រូវជម្រះសីល ៤ ឱ្យបរិសុទ្ធ តាំងនៅក្នុងសីលដែលបរិសុទ្ធល្អហើយ កាត់បលិពោធដែលមាន, ញ៉ាំងបឋមជ្ឈានឱ្យកើតឡើង ដោយការចម្រើនបដិកូលមនសិការកម្មដ្ឋាន ធ្វើឈានឱ្យជាបាទ ផ្តើមតាំងវិបស្សនា ក៏គប្បីរៀនយកក្នុងសំណាក់របស់កល្យាណ-មិត្ត អ្នកសម្រេចអរហត្ត ឬក្នុងសំណាក់ព្រះអនាគាមិបុគ្គលជាដើម រូបណាមួយ ដោយកំណត់យ៉ាងទាបបំផុត សូម្បីអ្នកជាតន្តិអាចារ្យ (អ្នកបង្រៀនពុទ្ធវចនៈ) ដែលជំនាញក្នុងព្រះបាលីព្រមទាំងអដ្ឋកថា; តែកាលមិនបានកល្យាណមិត្តដ៏បរិសុទ្ធ

ដូច្នោះ ក្នុងវិហារជាមួយគ្នា គប្បីទៅកាន់ទីនៅរបស់លោកហើយរៀនយកចុះ។ បណ្ដាពិធីការនោះ ការជម្រះសីល ៤ ឱ្យបរិសុទ្ធ ការកាត់បលិពោធ និងពិធីការចូលទៅកាន់សំណាក់របស់អាចារ្យ សូម្បីទាំងអស់នោះ ខ្ញុំបានពោលទុកដោយពិស្ដារហើយក្នុងបករណ៏វិសុទ្ធិមគ្គ [៩២] , ព្រោះហេតុនោះ គប្បីជ្រាបកិច្ចនោះ ដោយន័យដែលពោលហើយក្នុងបករណ៏វិសុទ្ធិមគ្គនោះចុះ ៕

## **វចសា** (ប្រាប់ដោយវាចា)

ក៏អាចារ្យអ្នកប្រាប់កម្មដ្ឋាន គប្បីប្រាប់ដោយពិធីការ ៣ យ៉ាងនោះ គឺ សម្រាប់ភិក្ខុដែលរៀនកម្មដ្ឋានតាមប្រក្រតី ក្នុងវារៈដែលលោកមកអង្គុយហើយ អាចារ្យគប្បីឱ្យលោកធ្វើការស្វាធ្យាយមួយដង ឬពីរដង ហើយទើបប្រាប់។ សម្រាប់ភិក្ខុអ្នកត្រូវការនឹងនៅក្នុងសំណាក់អាចារ្យរៀនយកកម្មដ្ឋាន អាចារ្យគប្បីប្រាប់ក្នុងវេលាដែលលោកមកហើយ ។ សម្រាប់ភិក្ខុអ្នកត្រូវការរៀន ហើយទៅក្នុងទីដទៃ អាចារ្យគប្បីប្រាប់កម្មដ្ឋានកុំឱ្យស្មុគស្មាញ កុំឱ្យសង្ស័យ ដោយកុំធ្វើឱ្យពិស្ដារពេក និងកុំសង្ខេបពេក ។

***សួរថា*** កាលនឹងប្រាប់អាចារ្យ គប្បីប្រាប់យ៉ាងណា ?

ឆ្លើយថា គប្បីប្រាប់ឧគ្គហកោសល្យ ៧ យ៉ាង និងមនសិការកោសល្យ ១០ យ៉ាង ក្នុងពីរយ៉ាងនោះ អាចារ្យគប្បីប្រាប់ឧគ្គហកោសល្យ ៧ យ៉ាង យ៉ាងនេះ គឺ

**១. វចសា** ដោយវាចា

---

[៩២] វិសុទ្ធិ. ១ (សមាធិនិទ្ទេស) ។

**២. មនសា** ដោយចិត្ត

**៣. វណ្ណតោ** ដោយពណ៌

**៤. សណ្ឋានតោ** ដោយសណ្ឋាន

**៥. ទិសតោ** ដោយទិស

**៦. ឱកាសតោ** ដោយឱកាស

**៧. បរិច្ឆេទតោ** ដោយបរិច្ឆេទ ៕

## គប្បីស្វាធ្យាយដោយវាចា

ក៏ក្នុងបដិកូលមនសិការកម្មដ្ឋាននេះ សូម្បីភិក្ខុនោះទ្រទ្រង់ព្រះត្រៃបិដក ក៏គប្បីធ្វើការស្វាធ្យាយដោយវាចាជាមុន ក្នុងពេលដែលមនសិការ ។ ព្រោះកាលបើលោកតែម្នាក់ឯងធ្វើការស្វាធ្យាយ កម្មដ្ឋានរមែងប្រាកដ ដូចព្រះថេរៈ ២ រូប ដែលរៀនកម្មដ្ឋានក្នុងសំណាក់របស់ព្រះមហាទេវត្ថេរ អ្នកនៅក្នុង**មលយប្រទេស** ។

បានឮថា ព្រះមហាទេវត្ថេរ ដែលព្រះថេរៈ ២ រូបនោះ សូមកម្មដ្ឋានហើយ បានឱ្យទ្វត្តឹសាការបាលី ដោយប្រាប់ថា **“អ្នកទាំងឡាយ ចូរធ្វើការស្វាធ្យាយយ៉ាងនេះ រហូតដល់អស់ ៤ ខែ”** ព្រះថេរៈទាំង ២ រូបនោះ សូម្បីមាននិកាយ ២-៣ នោះ ស្ទាត់ជំនាញហើយ ក៏ពិតមែន, តែព្រោះភាពដែលខ្លួនមានប្រក្រតីទទួលយកឱវាទដោយសេចក្ដីគោរព ទើបស្វាធ្យាយទ្វត្តឹសាការរហូតដល់អស់ ៤ ខែ បានជាសោតាបន្នហើយ ។

ព្រោះហេតុនោះ អាចារ្យកាលនឹងប្រាប់កម្មដ្ឋាន គប្បីប្រាប់អន្តេវាសិកថា

**“មុនដំបូងលោកចូរស្វាធ្យាយដោយវាចាសិន”** ក៏កាលនឹងធ្វើការស្វាធ្យាយ គប្បីកំណត់តចបញ្ចកកម្មដ្ឋានជាដើម ហើយធ្វើការស្វាធ្យាយដោយអំណាចនៃអនុលោម និងបដិលោម ៕

## **វចសា** (វិធីស្វាធ្យាយដោយវាចា)

ពិតមែន ភិក្ខុនោះកាលពោលថា **“កេសា លោមា នខា ទន្តា តចោ”** ដូច្នេះហើយ គប្បីពោលដោយបដិលោមទៀតថា **“តចោ ទន្តា នខា លោមា កេសា”** ។

គ្រាថា **“មំសំ នហារូ អដ្ឋិ អដ្ឋិមិញ្ជំ វក្កំ”** ក្នុងវក្កបញ្ចកៈដែលជាលំដាប់នៃតចបញ្ចកៈនុ៎ះហើយ គប្បីពោលបដិលោមទៀតថា **“វក្កំ អដ្ឋិមិញ្ជំ អដ្ឋិ នហារូ មំសំ តចោ ទន្តា នខា លោមា កេសា”** ។

លំដាប់នោះ គ្រាពោលក្នុងបប្ផាសបញ្ចកៈថា **“ហទយំ យកនំ កិលោមកំ បិហកំ បប្ផាសំ”** ដូច្នេះហើយ គប្បីពោលបដិលោមទៀតថា **“បប្ផាសំ បិហកំ កិលោមកំ យកនំ ហទយំ, វក្កំ អដ្ឋិមិញ្ជំ អដ្ឋិ នហារូ មំសំ, តចោ ទន្តា នខា លោមា កេសា”** ។

លំដាប់នោះ គប្បីលើក **មត្ថលុង្គំ** ដែលមានមកក្នុងបដិសម្ភិទាមគ្គ [៩៣] សូម្បីមិនបានឡើងកាន់បាលីនេះ [៩៤] ឱ្យឡើងកាន់បាលី ក្នុងទីបំផុតនៃ**ករីសៈ** ហើយ

---

[៩៣] ខុ. បដិ. ។

[៩៤] គឺបាលីក្នុងសតិប្បដ្ឋានវិភង្គនេះ ។

ពោលក្នុងមត្ថលុង្គបញ្ចកៈ នេះថា “**អន្តំ អន្តគុណំ ឧទរិយំ ករីសំ មត្ថលុង្គំ**” ដូច្នេះហើយ គប្បីពោលបដិលោមទៀតថា “**មត្ថលុង្គំ ករីសំ ឧទរិយំ អន្តគុណំ អន្តំ, បប្ផាសំ បិហកំ កិលោមកំ យកនំ ហទយំ, វក្កំ អដ្ឋិមិញ្ជំ អដ្ឋិ នហារូ មំសំ, តចោ ទន្តា នខា លោមា កេសា**” ។

លំដាប់នោះ គប្បីពោលក្នុងមេទឆក្កៈថា “**បិត្តំ សេម្ហំ បុព្វោ លោហិតំ សេទោ មេទោ**” ដូច្នេះហើយ គប្បីពោលបដិលោមទៀតថា “**មេទោ សេទោ លោហិតំ បុព្វោ សេម្ហំ បិត្តំ, មត្ថលុង្គំ ករីសំ ឧទរិយំ អន្តគុណំ អន្តំ, បប្ផាសំ បិហកំ កិលោមកំ យកនំ ហទយំ, វក្កំ អដ្ឋិមិញ្ជំ អដ្ឋិ នហារូ មំសំ, តចោ ទន្តា នខា លោមា កេសា**” ។

លំដាប់នោះ គប្បីពោលក្នុងមុត្តឆក្កៈថា “**អស្សុ វសា ខេឡោ សិង្ឃា-ណិកា លសិកា មុត្តំ**” ហើយគប្បីពោលបដិលោមទៀតថា “**មុត្តំ លសិកា សិង្ឃាណិកា ខេឡោ វសា អស្សុ, មេទោ សេទោ លោហិតំ បុព្វោ សេម្ហំ បិត្តំ, មត្ថលុង្គំ ករីសំ ឧទរិយំ អន្តគុណំ អន្តំ, បប្ផាសំ បិហកំ កិលោមកំ យកនំ ហទយំ, វក្កំ អដ្ឋិមិញ្ជំ អដ្ឋិ នហារូ មំសំ, តចោ ទន្តា នខា លោមា កេសា**” ។

គប្បីធ្វើការស្វាធ្យាយមួយរយដងខ្លះ, មួយពាន់ដងខ្លះ, មួយសែនដងខ្លះ ដោយវាចាដូចពណ៌នាមកនេះ ។ ពិតមែន របៀបនៃកម្មដ្ឋាន រមែងជាហេតុដែលស្ទាត់ជំនាញ ព្រោះការស្វាធ្យាយដោយវាចា, ចិត្តរមែងមិនត្រាច់ទៅខាងណោះ ខាង-ណេះ, កោដ្ឋាសៈទាំងឡាយរមែងប្រាកដដូចខ្សែដៃ ដូចជួរបង្កោលរបងដូច្នោះ ៕

## **មនសា** (វិធីស្វាធ្យាយដោយចិត្ត)

ក៏ព្រះយោគាវចរ គប្បីធ្វើការស្វាធ្យាយដោយវាចា យ៉ាងណា, សូម្បីការស្វាធ្យាយដោយចិត្ត ក៏យ៉ាងនោះដែរ; ព្រោះការស្វាធ្យាយដោយវាចា ជាបច្ច័យដល់ការស្វាធ្យាយដោយចិត្ត, ការស្វាធ្យាយដោយចិត្ត ជាបច្ច័យដល់ការចាក់ធ្លុះនូវលក្ខណៈ, ការចាក់ធ្លុះនូវលក្ខណៈជាបច្ច័យដល់ការចាក់ធ្លុះនូវមគ្គ និងផល ៕

## **វណ្ណតោទិ** (កំណត់ដោយពណ៌ជាដើម)

ខថា **វណ្ណតោ** សេចក្ដីថា គប្បីកំណត់ពណ៌នៃកោដ្ឋាសៈទាំងឡាយ មានសក់ជាដើម ។ ពាក្យថា **សណ្ឋានតោ** គឺគប្បីកំណត់សណ្ឋាននៃកោដ្ឋាសៈទាំងឡាយមានសក់ជាដើមនោះនុ៎ះឯង ។ ពាក្យថា **ទិសតោ** សេចក្ដីថា ក្នុងសរីរៈនេះ ទិសខាងលើតាំងពីនាភី (ផ្ចិត) ឡើងទៅ, ទិសខាងក្រោម តាំងពីនាភីចុះមក; ព្រោះហេតុនោះ គប្បីកំណត់**ទិស**ថា "កោដ្ឋាសៈនេះនៅក្នុងទិសឈ្មោះនេះ" ។ ពាក្យថា **ឱកាសតោ** សេចក្ដីថា គប្បីកំណត់ឱកាសនៃកោដ្ឋាសៈនោះៗ យ៉ាងនេះថា "កោដ្ឋាសៈនេះ តាំងនៅក្នុងឱកាសឈ្មោះនេះ" ។ ពាក្យថា **បរិច្ឆេទតោ** បានដល់ ការកំណត់ ២ យ៉ាង គឺសភាគបរិច្ឆេទ = កំណត់ចំណែកដែលស្មើគ្នា និងវិសភាគបរិច្ឆេទ = កំណត់ចំណែកដែលមិនស្មើគ្នា ។ ក្នុងការកំណត់ ២ យ៉ាងនោះ គប្បីជ្រាបសភាគបរិច្ឆេទយ៉ាងនេះថា "កោដ្ឋាសៈនេះ កំណត់កាត់ផ្ដាច់ដោយកោដ្ឋាសៈឈ្មោះនេះ ទាំងខាងក្រោម ខាងលើ និងខាងទទឹងដោយជុំវិញ" ។ គប្បីជ្រាបវិសភាគបរិច្ឆេទ ដោយអំណាចនៃការមិនលាយគ្នានៃកោដ្ឋាសៈយ៉ាងនេះថា "**សក់មិនមែនរោម, សូម្បីរោម ក៏មិនមែនសក់**" ជាដើម ៕

## ឧគ្គហកោសល្ល ៧ មុននឹងប្រាប់ឧគ្គហកោសល្ល

ក៏លោកអាចារ្យកាលនឹងប្រាប់ឧគ្គហកោសល្ល ៧ យ៉ាង យ៉ាងនេះ គួរជ្រាប ថា "កម្មដ្ឋាននេះ ព្រះមានព្រះភាគជាម្ចាស់ត្រាស់ទុកក្នុងព្រះសូត្រឯណោះ ដោយអំណាចនៃបដិកូល, កម្មដ្ឋាននេះ ត្រាស់ទុកក្នុងព្រះសូត្រឯណោះ ដោយអំណាចនៃធាតុ" ដូច្នេះហើយ ទើបប្រាប់ ។

ពិតមែន កាយានុបស្សនាសតិបដ្ឋាននេះ ព្រះមានព្រះភាគជាម្ចាស់ត្រាស់ទុកក្នុងមហាសតិបដ្ឋាន [៩៥] ដោយអំណាចនៃបដិកូលប៉ុណ្ណោះ, តែក្នុង**មហាហត្ថិបទោបមសូត្រ មហារាហុលោវាទសូត្រ** និង**ធាតុវិភង្គ** [៩៦] ត្រាស់ទុកដោយអំណាចនៃធាតុ ។ ក៏ក្នុង**កាយគតាសតិសូត្រ** [៩៧] ត្រាស់ចែកឈាន ៤ **សំដៅយកឈានដែលប្រាកដដោយពណ៌នៃកោដ្ឋាសៈ** ។

បណ្តាកម្មដ្ឋាន ២ យ៉ាងនោះ វិបស្សនាកម្មដ្ឋាន ត្រាស់ដោយអំណាចនៃធាតុ, សមថកម្មដ្ឋានត្រាស់ដោយអំណាចនៃបដិកូល ។ អាចារ្យពួកខ្លះពោលថា "សមថកម្មដ្ឋាននេះឯង ព្រះមានជោគត្រាស់ទុកក្នុងសតិបដ្ឋានវិភង្គ" នេះ ដោយអំណាចនៃសាធារណកម្មដ្ឋានទាំងពួង ដោយមិនប្លែកគ្នានោះឯង ៕

---

[៩៥] ទី. ម. ១៧, ម. មូ.។

[៩៦] ម. មូ., ម. ម., ម. ឧ.។

[៩៧] ម. ឧ.។

## មនសិការកោសល្យ ១០

ព្រះមានព្រះភាគជាម្ចាស់ គ្រាទ្រង់ប្រាប់ឧគ្គហកោសល្យ ៧ យ៉ាង យ៉ាងនេះហើយ ទើបប្រាប់មនសិការកោសល្យ ១០ យ៉ាង យ៉ាងនេះ គឺ

| | |
|---|---|
| **១. អនុបុព្វតោ** | ដោយលំដាប់ |
| **២. នាតិសីឃតោ** | ដោយមិនប្រញាប់ពេកទេ |
| **៣. នាតិសណិកតោ** | ដោយមិនយូរបង្អួសពេកទេ |
| **៤. វិក្ខេបបដិពាហនតោ** | ដោយការហាមសេចក្ដីរវើរវាយ |
| **៥. បណ្ណត្តិសមតិក្កមនតោ** | ដោយការឈានកន្លងបញ្ញត្តិ |
| **៦. អនុបុព្វមុញ្ចនតោ** | ដោយការបណ្ដោយតាមលំដាប់ |
| **៧. អប្បនាតោ** | ដោយអប្បនា |
| **៨.៩.១០. តយោ ច សុត្តន្តា** | ដោយសុត្តន្តៈ ៣ ៕ |

## មនសិការដោយលំដាប់

បណ្ដាកោសល្យទាំង ១០ នោះ ខថា **អនុបុព្វតោ** សេចក្ដីថា ព្រះយោគាវចរ គប្បីធ្វើកម្មដ្ឋាននោះទុកក្នុងចិត្តដោយលំដាប់ គឺតាំងពីការស្វាធ្យាយទៅ, មិនគប្បីវៀរកម្មដ្ឋានមួយទុកក្នុងចន្លោះ; ព្រោះកាលបើមនសិការ វៀរកម្មដ្ឋានមួយទុកក្នុងចន្លោះ ចិត្តក៏នឹងនឿយហត់ រមែងធ្លាក់ចេញទៅពីអារម្មណ៍ ព្រោះសេចក្ដីមិនសម្រេចតាមពេញចិត្តដែលនឹងគប្បីបាន ដោយអំណាចនៃ**ភាវនាសម្បត្តិ** រមែងមិនធ្វើភាវនាឱ្យសម្រេច ប្រៀបដូចបុរសអ្នកមិនឆ្លាត ឈានឡើងកាំជណ្ដើរ ៣២ កាំ

ដោយឆ្លង (រំលង) ទៅមួយកាំក្នុងចន្លោះដូច្នោះ ៕

## មនសិការដោយមិនប្រញាប់ពេក

មួយទៀត សូម្បីកាលមនសិការទៅដោយលំដាប់ ក៏កុំគប្បីមនសិការដោយប្រញាប់; ព្រោះថា កាលមនសិការដោយប្រញាប់ហួសពេកទៅ កម្មដ្ឋានរមែងដល់ទីបំផុតតែម្យ៉ាង តែមិនច្បាស់ ទាំងមិននាំមកនូវគុណវិសេស ប្រៀបដូចកាលបុរសដើរផ្លូវ ៣ យោជន៍ មិនបានកំណត់ផ្លូវបត់បែន និងផ្លូវបំបែកទុក ដើរទៅ ដើរមកដោយរហ័ស សូម្បីទាំង ៧ ដង ផ្លូវរមែងអស់ទៅរហ័ស ក៏ពិតមែនហើយ, តែក៏ត្រូវសួរអ្នកដទៃគ្រប់គ្រា ទើបនឹងដើរផ្លូវទៅបាន ព្រោះហេតុនោះ ព្រះយោគាវចរមិនគប្បីមនសិការដោយរហ័សពេកទេ ៕

## មនសិការដោយមិនយឺតពេក

ក៏ព្រះយោគាវចរ មនសិការដោយមិនប្រញាប់ពេក យ៉ាងណា, គប្បីមនសិការដោយមិនយឺតពេកដូច្នោះដែរ ។ ព្រោះថា កាលមនសិការដោយយឺតពេកទៅ កម្មដ្ឋាននឹងមិនដល់ទីបំផុត ទាំងមិនជាបច្ច័យដល់ការសម្រេចគុណវិសេស ប្រៀបដូចបុរសអ្នកត្រូវការដើរផ្លូវឆ្ងាយ ៣ យោជន៍ទុំះឯង វរល់តែយឺតយូរឈប់សម្រាកតាមគល់ឈើ ជើងភ្នំជាដើម ក្នុងចន្លោះផ្លូវ ផ្លូវក៏មិនដល់ការអស់ទៅ ត្រូវដើរទៅ ២-៣ ថ្ងៃ ទើបនឹងដល់ទីបំផុតផ្លូវបាន ៕

## មនសិការដោយហាមការរវើរវាយ

ខថា **វិក្ខេបបដិពាហនតោ** សេចក្ដីថា គប្បីហាមចិត្តដែលលះបង់កម្មដ្ឋាន រវើរវាយទៅកាន់អារម្មណ៍ខាងក្រៅចេញ; ព្រោះកាលបើមិនហាមចិត្តទុក កាលចិត្ត រវើរវាយទៅខាងក្រៅ កម្មដ្ឋានរមែងសាបសូន្យទៅ ប្រៀបដូចកាលបុគ្គលដើរផ្លូវ ឆ្លងជ្រោះ ដែលជាផ្លូវដើរបានតែម្នាក់ មិនបានកំណត់ផ្លូវដែលជាន់ រវល់តែក្រឡេក មើលផ្លូវឯណោះ ផ្លូវឯណេះ រមែងជាន់ភ្លាត់ ពេលនោះ គេនឹងធ្លាក់ចុះទៅក្នុងជ្រោះ ជ្រៅមួយរយសន្ទុងបុរស ព្រោះហេតុនោះ គប្បីមនសិការដោយការហាមសេចក្ដី រវើរវាយចេញ ៕

## មនសិការដោយការឈានកន្លងបញ្ញត្តិ

បទថា **បណ្ណត្តិសមតិក្កមនតោ** សេចក្ដីថា ព្រះយោគាវចរគប្បីឈានកន្លង បញ្ញត្តិថា "សក់ រោម" ជាដើម និងគប្បីធ្វើទុកក្នុងចិត្តថា "នុ៎ះជារបស់បដិកូល"។ គឺក្នុងគ្រាដំបូង ភាពជារបស់បដិកូលរមែងប្រាកដ; លំដាប់នោះ គប្បីឈានកន្លង បញ្ញត្តិថា **"កេសា លោមា"** ហើយដាក់ចិត្តទុកក្នុងភាពជារបស់បដិកូលប៉ុណ្ណោះ ប្រៀបដូចក្នុងវេលាដែលទឹករកបានដោយលំបាក ពួកមនុស្សឃើញទីមានទឹកក្នុង ព្រៃ ទើបចងអ្វីៗ មានស្លឹកត្នោតជាដើមទុកជាសញ្ញាណ (គ្រឿងចំណាំ) ក្នុងទីនោះ ពួកគេរមែងមកងូតទឹក និងផឹកដោយសញ្ញាណនោះ។ ក៏ក្នុងកាលណា ស្នាមជើង របស់ពួកគេសញ្ជរទៅមកញយៗ ប្រាកដហើយ, ក្នុងកាលនោះ ក៏មិនមានការចាំបាច់ ដោយសញ្ញាណនោះទៀត គេរមែងទៅងូត និងផឹកបាន ក្នុងខណៈដែលត្រូវការៗ ៕

## មនសិការដោយការបណ្ដោយតាមលំដាប់

បទថា **អនុបុព្វមុញ្ចនតោ** សេចក្ដីថា កោដ្ឋាសៈណា។ មិនប្រាកដ, កាលបណ្ដោយតាមកោដ្ឋាសៈនោះ។ ក៏គប្បីមនសិការទៅ ដោយការបណ្ដោយតាមលំដាប់; គឺថាព្រះយោគាវចរ[៥៨] ជាអាទិកម្មិកៈ (អ្នកផ្ដើមធ្វើដំបូង) កាលមនសិការថា **"កេសា"** ក៏មនសិការទៅដរាបដល់កោដ្ឋាសៈចុងបំផុតថា **"មុត្តំ"** នេះ; និងកាលមនសិការថា **"មុត្តំ"** ក៏មនសិការទៅ ដរាបដល់កោដ្ឋាសៈថា **"កេសា"** នេះនោះឯង; ពេលនោះ កាលមនសិការកោដ្ឋាសៈនោះ កោដ្ឋាសៈខ្លះ រមែងប្រាកដ, ខ្លះមិនប្រាកដ; កោដ្ឋាសៈណា។ ប្រាកដដោយមនសិការនោះ, គប្បីធ្វើកម្មដ្ឋាននោះ។ ជាមុនសិន; បណ្ដាកោដ្ឋាសៈទាំងនោះ កាលកោដ្ឋាសៈ ២ ប្រាកដ កោដ្ឋាសៈមួយប្រាកដល្អជាង; មនសិការកោដ្ឋាសៈនោះនុ៎ះឯងញយ។ ក៏គប្បីឱ្យអប្បនាកើតបាន។ ក្នុងសេចក្ដីនេះ មានឧបមាដូច្នេះ ៖

**ដូចយ៉ាងថា នាយព្រានត្រូវការនឹងចាប់ស្វា ដែលនៅក្នុងព្រៃត្នោត មានដើមត្នោត ៣២ ដើម យកកូនសរបាញ់ទៅកាន់ស្លឹកត្នោតដើមដំបូង ហើយស្រែកដេញ; កាលនាយព្រានសូម្បីទៅត្រង់ដើមត្នោតនោះហើយ ក៏ធ្វើយ៉ាងនោះឯង; ស្វានោះ ក៏គប្បីមកកាន់ដើមត្នោតដំបូង ដោយន័យនោះឯងទៀត; ស្វានោះកាលទៅដោយលំដាប់ញយ។ ហើយ យ៉ាងនេះ ក៏នឹងប្រាកដខ្លួនចេញទៅក្នុងទីដែលនាយព្រានបណ្ដេញប៉ុណ្ណោះ ហើយនឹងបង្អោនចុះ**

---

[៥៨] យោគំ វីរិយំ អវចរតិ ករោតីតិ > **យោគាវចរោ** = បុគ្គលណាដែលបំពេញនូវការប្រកប គឺធ្វើនូវសេចក្ដីព្យាយាម បុគ្គលនោះ ឈ្មោះថា យោគាវចរ (អត្ថយោជនា)។

ត្រង់ដើម ត្នោតមួយដើម ដោយលំដាប់ទៀត ទើបចាប់តោងកំពូលត្នោតត្រង់កណ្ដាលនុ៎ះឯងទុកយ៉ាងមាំ សូម្បីនឹងត្រូវនាយព្រានបាញ់ ក៏មិនចៀសទៅយ៉ាងណា ពាក្យឧបមេយ្យនេះ ក៏គប្បីជ្រាបយ៉ាងនោះចុះ ។ ក្នុងសេចក្ដីនេះ ក៏មានពាក្យប្រៀបធៀបឧបមា និងឧបមេយ្យដូចតទៅនេះ ៖

## ការឧបមា និងឧបមេយ្យ

កោដ្ឋាសៈ ៣២ ក្នុងកាយនេះ ប្រៀបដូចដើមត្នោត ៣២ ដើម ក្នុងព្រៃត្នោត; ចិត្តប្រៀបដូចស្វា។ ព្រះយោគាវចរប្រៀបដូចនាយព្រាន។ ការដែលចិត្តរបស់ព្រះយោគាវចរត្រាច់ទៅរឿយៗ ក្នុងកាយដែលមានកោដ្ឋាសៈ ៣២ ដោយអំណាចនៃអារម្មណ៍ ប្រៀបដូចការដែលស្វានៅក្នុងព្រៃត្នោត ដែលមានដើមត្នោត ៣២ ដើម។ ការដែលព្រះយោគាវចរផ្ដើមមនសិការថា **“កេសា”** ជាដើម ចិត្តក៏ដំណើរទៅតាមលំដាប់ ហើយឈប់នៅត្រង់កោដ្ឋាសៈចុងបំផុត, ប្រៀបដូចនាយព្រានយកកូនសរបាញ់ទៅកាន់ស្លឹកត្នោតដើមដំបូង ហើយដេញ; ស្វានឹងលោតទៅត្រង់ដើមត្នោតនោះៗ ហើយទៅកាន់ដើមត្នោតចុងបំផុត។ សូម្បីក្នុងកាលដែលស្វាត្រឡប់មកទៀត ក៏ន័យនេះដែរ។ ការដែលព្រះយោគាវចរមនសិការរឿយៗ គ្រាកាលកោដ្ឋាសៈយ៉ាងណាមួយប្រាកដហើយ លះចោលកោដ្ឋាសៈដែលមិនប្រាកដ ធ្វើបរិកម្មក្នុងកោដ្ឋាសៈដែលប្រាកដ ប្រៀបដូចការប្រាកដរបស់ស្វា ដែលទៅដោយលំដាប់ហើយញយៗ ក្នុងទីដែលនាយព្រានដេញហើយញយៗ ។ ការដែលកោដ្ឋាសៈ ២ ប្រាកដ កោដ្ឋាសៈណាប្រាកដល្អជាង, ព្រះយោគាវចរមនសិការកោដ្ឋាសៈនោះ

នុំះឯងញយ១ ហើយញុំាំងអប្បនា ឱ្យកើតឡើងក្នុងកាលជាទីបំផុត ប្រៀបដូចការដែលស្ទាបង្ហោនចុះត្រង់ដើមត្នោតមួយដើម១ ដោយលំដាប់ ហើយចាប់តោងកំពូលត្នោតត្រង់កណ្ដាលនោះឯង ទុកយ៉ាងមាំ សូម្បីត្រូវនាយព្រានបាញ់ ក៏មិនជៀសទៅដូច្នោះ ។ គប្បីជ្រាបពាក្យឧបមា សូម្បីដទៃទៀតថា ៖

ប្រៀបដូចភិក្ខុ អ្នកមានបិណ្ឌបាតជាវត្ត [៩៩] អាស្រ័យផ្ទះ ៣២ ត្រកូល បានភិក្ខា ២ (ចាន) ក្នុងផ្ទះ ១ ខ្នងហើយ គប្បីវៀរផ្ទះមួយខ្នងខាងមុខ, ក្នុងថ្ងៃស្អែកបានភិក្ខា ៣ (ចាន) គប្បីវៀរ ២ ខ្នងខាងមុខ, ក្នុងថ្ងៃទី ៣ បានភិក្ខាពេញបាត្រ ក្នុងផ្ទះខ្នងដំបូងនោះឯង ហើយទៅកាន់អាសនះឆាន់ភិក្ខាយ៉ាងណា, សេចក្ដីឧបមេយ្យនេះ គប្បីជ្រាបដូច្នោះចុះ ។ ពិតមែន អាការ ៣២ ប្រៀបដូចផ្ទះ ៣២ ត្រកូល ។ ព្រះយោគាវចរ ប្រៀបដូចភិក្ខុមានបិណ្ឌបាតជាវត្ត ។ ការដែលព្រះយោគាវចរធ្វើបរិកម្មអាការ៣២ ប្រៀបដូចភិក្ខុនោះ ចូលទៅអាស្រ័យផ្ទះទាំងនោះ ។ ការដែលព្រះយោគាវចរមនសិការទៅ លះចោលកោដ្ឋាសៈទាំងឡាយដែលមិនប្រាកដ ធ្វើបរិកម្មក្នុងកោដ្ឋាសៈទាំង ២ ដែលប្រាកដ ប្រៀបដូចភិក្ខុបានភិក្ខា ២ (ចាន) ក្នុងផ្ទះខ្នងដំបូង ហើយវៀរ ផ្ទះមួយខាងមុខចេញ និងប្រៀបដូចក្នុងថ្ងៃទី ២ បានភិក្ខា ៣ (ចាន) ហើយវៀរ ផ្ទះ ២ ខាងមុខ ។ ការដែលកោដ្ឋាសៈ ២ ប្រាកដហើយ កោដ្ឋាសៈណាល្អជាង ក៏មនសិការកោដ្ឋាសៈនោះនុំះឯងញយ១ ហើយញុំាំងអប្បនាឱ្យកើតបាន ប្រៀបដូចក្នុងថ្ងៃទី ៣ បានភិក្ខាពេញបាត្រក្នុងផ្ទះខ្នងដំបូងនុំះឯង ហើយទៅអង្គុយឆាន់ក្នុងអាសនះសាលា ៕

---

[៩៩] របៀបការកាន់បិណ្ឌបាតជាវត្ត របស់លោកក្នុងសម័យនោះ បច្ចុប្បន្ននេះ យល់បានដោយលំបាក ។

## ដោយអប្បនា

បទថា **អប្បនាតោ** បានដល់ កោដ្ឋាសៈដែលជាអប្បនា, ក្នុងសេចក្ដីនេះ មានអធិប្បាយថា គប្បីជ្រាបថា បណ្ដាកោដ្ឋាសៈទាំងឡាយ មានកេសាជាដើម គ្រប់ៗ កោដ្ឋាសៈ ជាអប្បនាបាន ៕

## ដោយសុត្តន្តៈ ៣

ក្នុងពាក្យថា **“តយោ ច សុត្តន្តា”** នេះ មានអធិប្បាយថា គប្បីជ្រាប សុត្តន្ត ៣ យ៉ាងទាំងនេះ ដើម្បីប្រយោជន៍ដល់វីរិយៈ និងសមាធិ គឺអធិចិត្តសូត្រ សីតិភាវនាសូត្រ និងពោជ្ឈង្គកោសល្លសូត្រ ៕

## អធិចិត្តសូត្រ

បណ្ដាសូត្រទាំងនោះ ព្រះសូត្រនេះថា “ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកប្រ-កបរឿយៗ នូវអធិចិត្ត គប្បីមនសិការនិមិត្ត ៣ ដោយកាលដ៏សមគួរ គឺគប្បីមន-សិការ **សមាធិនិមិត្ត** ដោយកាលដ៏សមគួរ, គប្បីមនសិការ **បគ្គហនិមិត្ត** ដោយកាលដ៏សមគួរ, គប្បីមនសិការ **ឧបេក្ខានិមិត្ត** ដោយកាលដ៏សមគួរ ។ ម្នាលភិក្ខុទាំងឡាយ បើភិក្ខុប្រកបរឿយៗ នូវអធិចិត្ត គប្បីមនសិការសមាធិនិមិត្តដោយចំណែក តែមួយប៉ុណ្ណោះនុ៎ះសោត, ឋាននោះគប្បីឱ្យប្រព្រឹត្តទៅដើម្បីកោសជ្ជៈបាន, ម្នាលភិក្ខុទាំងឡាយ បើភិក្ខុប្រកបរឿយៗ នូវអធិចិត្ត គប្បីមនសិការបគ្គហនិមិត្ត ដោយចំណែកតែមួយនោះទេ, ឋាននោះគប្បីឱ្យចិត្តប្រព្រឹត្តទៅដើម្បីឧទ្ធច្ចៈបាន ។

ម្នាលភិក្ខុទាំងឡាយ បើភិក្ខុប្រកបរឿយៗ នូវអធិចិត្ត គប្បីមនសិការឧបេក្ខានិមិត្ត ដោយចំណែកតែមួយនោះ, ឋាននោះចិត្តរមែងមិនតាំងមាំដោយប្រពៃ ដើម្បីសេចក្តីអស់ទៅនៃអាសវៈទាំងឡាយ ។

ម្នាលភិក្ខុទាំងឡាយ ក្នុងកាលណា ភិក្ខុប្រកបរឿយៗ នូវអធិចិត្ត មនសិការនូវសមាធិនិមិត្ត, បគ្គហនិមិត្ត និងឧបេក្ខានិមិត្ត ដោយកាលដ៏សមគួរ ចិត្តនោះរមែងជាធម្មជាតទន់ គួរដល់ការងារ ជាបភស្សរៈ, មិនទន់ខ្សោយ (គឺមិនយ៉ាប់), រមែងតាំងមាំដោយប្រពៃ ដើម្បីសេចក្តីអស់ទៅនៃអាសវៈទាំងឡាយ ។ ម្នាលភិក្ខុទាំង-ឡាយ ប្រៀបដូចនាយជាងមាស ឬកូនគូលីរបស់ជាងមាសប្រកបបាវ (គឺធ្វើជើងក្រានសម្រាប់ស្លរំលាយមាស) កាលប្រកបបាវហើយ ក៏ផ្តុំភ្លើងគុក, កាលផ្តុំភ្លើងហើយ ក៏យកដង្កាបចាប់មាសគ្របដាក់ចូលទៅត្រង់មាត់បាវ លុះដាក់ចូលទៅក្នុងមាត់បាវហើយ រមែងសប់ខ្យល់ចូលទៅតាមកាលដ៏សមគួរ, រមែងយកទឹកប្រោះតាមកាល ដ៏សមគួរ, រមែងដាក់ឱ្យស្ងៀមក្នុងកាលដ៏សមគួរ។ ម្នាលភិក្ខុទាំងឡាយ បើជាងមាស ឬកូនគូលីរបស់ជាងមាស គប្បីផ្លុំខ្យល់ចូលទៅដោយចំណែកតែមួយនោះសោត ឋាននោះ មាសក៏នឹងគប្បីត្រជាក់ទៅ។ ម្នាលភិក្ខុទាំងឡាយ បើជាងមាស ឬកូនគូលីរបស់ជាងមាស គប្បីយកទឹកប្រោះដោយចំណែកតែមួយនោះសោត, ឋាននោះ មាសក៏នឹងត្រូវត្រជាក់ទៅ។ ម្នាលភិក្ខុទាំងឡាយ បើជាងមាស ឬកូនគូលីរបស់ជាងមាស គប្បីមើលមាសនោះព្រងើយៗ យ៉ាងនោះតែម្យ៉ាងសោត, ឋាននោះ មាសក៏មិនគប្បីឆ្អិនល្អ។ ម្នាលភិក្ខុទាំងឡាយ ឯកាលណាជាងមាស ឬកូនគូលីរបស់ជាងមាស រមែងផ្លុំខ្យល់ចូលទៅដោយកាលដ៏សមគួរ រមែងយកទឹកមក

ព្រោះដោយកាលដ៏សមគួរ, មើលព្រងើយៗ តាមកាលដ៏សមគួរ, មាសនោះរមែងជាធម្មជាតទន់ គួរដល់ការងារ ឆ្អិនល្អ, មិនស្រួយ, រមែងប្រើការបានល្អ។ នាយជាងមាស ឬកូនគូលីរបស់ជាងមាស ចង់ធ្វើឱ្យទៅជាគ្រឿងប្រដាប់ប្រភេទណាៗ បើថានឹងធ្វើម្កុលខ្ចាស់ នឹងធ្វើក្រវិលត្រចៀក ធ្វើខ្សែក ធ្វើកម្រងផ្កាមាស កាលចាក់មាសនោះ រមែងសម្រេចប្រយោជន៍ដល់គេ យ៉ាងណា; ម្នាលភិក្ខុទាំងឡាយ ភិក្ខុអ្នកប្រកបរឿយៗ នូវអធិចិត្ត ។ល។ រមែងតាំងមាំដោយប្រពៃ ដើម្បីការអស់ទៅនៃអាសវៈទាំងឡាយ។ ភិក្ខុនោះ រមែងបង្អោនចិត្តទៅដើម្បីធម៌ ដែលគួរធ្វើឱ្យជាក់ច្បាស់ ដោយអភិញ្ញាណាៗ, កាលសតិ អាយតនៈមាន លោករមែងដល់ភាពជាអ្នកអាចដើម្បីធ្វើឱ្យជាក់ច្បាស់ដោយអភិញ្ញាក្នុងធម៌នោះៗ ឯងដូច្នេះ[១០០], គប្បីជ្រាបថាឈ្មោះថា **អធិចិត្តសូត្រ** ៕

## សីតិភាវសូត្រ

ព្រះសូត្រនេះថា "ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ ៦ ជាអ្នកគួរដើម្បីធ្វើឱ្យជាក់ច្បាស់នូវសីតិភាវៈ (ភាពជាអ្នកស្ងប់) ដ៏កំពូល, ធម៌ ៦ តើដូចម្តេច? ម្នាលភិក្ខុទាំងឡាយ ភិក្ខុក្នុងធម្មវិន័យនេះ ៖

១. រមែងគ្របសង្កត់ចិត្ត ក្នុងសម័យដែលគួរគ្របសង្កត់

២. រមែងផ្គងចិត្ត ក្នុងសម័យដែលគួរផ្គង

---

[១០០] អំ. តិក.។

[១០១] អំ. ឆក្ក.។

៣. រមែងរីករាយចិត្ត ក្នុងសម័យដែលគួររីករាយ

៤. រមែងដាក់ចិត្តព្រងើយៗ ក្នុងសម័យដែលគួរដាក់ចិត្តព្រងើយៗ

៥. រមែងជាអ្នកបង្អោនចិត្តទៅក្នុងធម៌ដែលប្រណីត

៦. រមែងជាអ្នកត្រេកអរក្រៃលែងក្នុងព្រះនិព្វាន ។

ម្នាលភិក្ខុទាំងឡាយ ភិក្ខុប្រកបដោយធម៌ទាំង ៦ នេះ ជាអ្នកគួរដើម្បីធ្វើឱ្យជាក់ច្បាស់នូវសីតិភាវៈដ៏កំពូល”[១០១] ។ គប្បីជ្រាបថា ឈ្មោះថា **សីតិភាវសូត្រ** ៕

## ពោជ្ឈង្គកោសល្លសូត្រ

ក៏ពោជ្ឈង្គកោសល្លសូត្រ មកហើយក្នុងពោជ្ឈង្គសំយុត្តនោះឯង ត្រង់ **សំយុត្តនិកាយមហាវគ្គ**ថា “ម្នាលភិក្ខុទាំងឡាយ យ៉ាងនោះឯង ក្នុងសម័យណា ចិត្តរួញរា ក្នុងសម័យនោះ មិនមែនជាកាល ដើម្បីចម្រើនបស្សទ្ធិសម្ពោជ្ឈង្គ”[១០២] ជាដើម ។ ព្រះយោគាវចរនោះ កាលធ្វើការរៀនឧគ្គហកោសល្យយ៉ាងនេះបានល្អហើយ និងកំណត់មនសិការកោសល្យ ១០ យ៉ាងនេះឱ្យល្អហើយ គប្បីរៀនកម្មដ្ឋានដោយអំណាចនៃកោសល្យទាំង ២ ឱ្យស្ទាត់ ។ បើសិនលោកមានសេចក្តីសប្បាយនៅក្នុងវិហារតែមួយជាមួយនឹងអាចារ្យនុ៎ះសោត, ក៏មិនចាំបាច់ត្រូវឱ្យអាចារ្យប្រាប់កម្មដ្ឋានដោយពិស្តារយ៉ាងនោះទេ គប្បីប្រកបរឿយៗ នូវកម្មដ្ឋាននេះទៅចុះ កាលមិនបានគុណវិសេសហើយ ទើបឱ្យលោកប្រាប់ឱ្យក្រៃលែងឡើងទៅ ។ ព្រះយោគា-វចរអ្នកប្រាថ្នានឹងទៅកាន់ទីដទៃ គប្បីឱ្យអាចារ្យប្រាប់ដោយសេចក្តីពិស្តារដោយវិធី

---

[១០២] សំ. ម. ។

តាមដែលពោលហើយ រឭករឿយៗ ទម្លាយបទដែលជាទីតាំងនៃសេចក្ដីសង្ស័យទាំងពួង លះសេនាសនៈដែលមិនសមគួរដល់ការចម្រើនកម្មដ្ឋានចេញ នៅក្នុងវិហារដែលសមគួរ វៀរចាកវិហារដែលជាទោស ១៨ ប្រការ មានសភាពជាអាវាសធំជាដើម កាត់បលិពោធតូចៗ ភិក្ខុណាជាអ្នកមានរាគចរិតច្រើន ត្រូវលះរាគៈជាមុន, ព្រោះហេតុដូច្នោះ គប្បីធ្វើបរិកម្មក្នុងបដិកូលមនសិការ ។ ក៏កាលនឹងធ្វើត្រូវកាន់យកនិមិត្តក្នុងសក់ទាំងឡាយសិន, គឺគប្បីដកសក់មួយសរសៃ ឬពីរសរសៃ ដាក់ទៅលើបាតដៃហើយ គប្បីកំណត់ពណ៌ជាមុន; និងមើលសក់ទាំងឡាយ សូម្បីក្នុងទីដែលកោរសក់ក៏បាន, និងមើលសក់ក្នុងបាត្រដាក់ទឹក ឬបាត្រដាក់បបរក៏បានដូចគ្នា។ ឃើញក្នុងវេលាដែលសក់មានពណ៌ខ្មៅ គប្បីមនសិការថា **"ខ្មៅ"**, ឃើញក្នុងវេលាដែលសក់មានពណ៌ស ក៏មនសិការថា **"ស"** ; តែក្នុងវេលាដែលសក់មានពណ៌លាយគ្នា ដូចផ្កាព្រាយៗ គប្បីមនសិការដោយអំណាចនៃពណ៌ច្រើន ។ ក្នុងសក់ទាំងឡាយយ៉ាងណា, ក្នុងតចបញ្ចកៈសូម្បីទាំងអស់ ក៏យ៉ាងនោះដែរ ឃើញហើយ ក៏គប្បីកាន់យកនិមិត្តតែម្ដង ។ កាលកាន់យកនិមិត្តយ៉ាងនេះហើយ គប្បីកំណត់ក្នុងកោដ្ឋាសៈ ដោយអំណាចនៃ **ពណ៌ សណ្ឋាន ទិស ឱកាស និងបរិច្ឆេទ** ហើយគប្បីកំណត់ភាពជា របស់បដិកូល ៥ យ៉ាង ដោយអំណាចនៃពណ៌ **សណ្ឋាន ក្លិន ទីនៅ និងឱកាស** ។ តទៅនេះ ជាអនុបុព្វីកថា (ការពោលតាមលំដាប់) ក្នុងកោដ្ឋាសៈទាំងពួងនោះ ៖

## ១. កេសា = សក់ទាំងឡាយ

ពោលនូវសក់ជាមុនសិន ៖

**ពោលដោយពណ៌** តាមប្រក្រតីមានពណ៌ខ្មៅ ដូចពណ៌ផ្លែផ្គាំ ។

**ពោលដោយសណ្ឋាន** មានសណ្ឋានវែងមូល ដូចដងជញ្ជីង ។

**ពោលដោយទិស** កើតក្នុងទិសខាងលើ ។

**ពោលដោយឱកាស** ត្រង់ខាងទាំងពីរ កំណត់ដោយត្រចៀក, ខាងមុខ កំណត់ដោយថ្ងាស, ខាងក្រោយ កំណត់ដោយកញ្ចឹងក, ស្បែកស្រស់ដែលដណ្ដប់លលាដ៏ក្បាល ជាឱកាស (គឺទីតាំង) នៃសក់ទាំងឡាយ ។ **ពោលដោយបរិច្ឆេទ** សក់ទាំងឡាយ ខាងក្រោម កំណត់ដោយផ្ទៃឫសរបស់សក់ទាំងឡាយ ដែលចាក់ចុះជ្រៅទៅក្នុងស្បែកដណ្ដប់លើក្បាល ប្រមាណមួយចុងគ្រាប់ស្រូវ, ខាងលើ កំណត់ដោយអាកាស (ដែលទទេ), ខាងជុំវិញ កំណត់ដោយសរសៃសក់ផងគ្នា។ **ការកំណត់ថា** "សក់ពីរសរសៃ មិនបានរួមនៅជាមួយគ្នា" នេះ ឈ្មោះថា សភាគ-បរិច្ឆេទ ។ ការកំណត់ថា សក់មិនលាយច្រឡំគ្នា ដោយកោដ្ឋាសៈ ៣១ ដែលនៅសល់ យ៉ាងនេះថា "សក់មិនមែនរោម, រោមមិនមែនសក់, ធម្មតាថា សក់រមែងជាកោដ្ឋាសៈមួយផ្នែក" នេះឈ្មោះថា វិសភាគបរិច្ឆេទ។ នេះជាការកំណត់សក់ទាំង-ឡាយ ដោយពណ៌ជាដើម។ គប្បីជ្រាបការកំណត់សក់ទាំងនោះ ដោយភាពជារបស់បដិកូល ៥ យ៉ាង ដោយអំណាចនៃពណ៌ជាដើមដូចតទៅនេះ ៖ ពិតមែនហើយ ឈ្មោះថា សក់ទាំងឡាយនេះ **សូម្បីដោយពណ៌** ក៏ជារបស់បដិកូល, **សូម្បីដោយសណ្ឋាន**, **សូម្បីដោយក្លិន**, **សូម្បីដោយអាសយៈ** (ទីអាស្រ័យ) និង**សូម្បីដោយឱកាស** ក៏ជារបស់បដិកូល; ព្រោះថា ជនទាំងឡាយឃើញអ្វីៗ ដែលមានពណ៌ដូច

សក់ក្នុងភាជន៍ដែលដាក់បបរ ឬភាជន៍ដាក់បាយសូម្បីដែលជាទីពេញចិត្ត ក៏រមែងខ្ពើមដោយពោលថា **“របស់នេះ វាលាយដោយសក់ ចូរនាំវាចេញទៅ”**។ សក់ជារបស់បដិកូល **ដោយពណ៌** យ៉ាងនេះ។ សូម្បីជនទាំងឡាយបរិភោគអាហារ ក្នុងវេលាយប់ប៉ះសរសៃធ្មៃ ឬសរសៃព្រាល ដែលមានសណ្ឋានដូចសក់ទាំងឡាយ ក៏ខ្ពើមដូច្នោះនុ៎ះឯង។ សក់ជារបស់បដិកូល **ដោយសណ្ឋាន** យ៉ាងនេះ។ មួយទៀតក្លិនរបស់សក់ វៀរចាកការតាក់តែងដោយរបស់ផ្សេងៗ មានការលាបដោយប្រេង និងអប់ដោយផ្កាឈើជាដើមចេញ រមែងជាក្លិនគួរខ្ពើមយ៉ាងក្រៃលែង, ក្លិនរបស់សក់ដែលដាក់ចូលទៅក្នុងភ្លើង រមែងមានក្លិនគួរខ្ពើមក្រៃលែងជាងនោះ។ ពិតមែន **កាលពោលដោយពណ៌ និងសណ្ឋាន** សក់ទាំងឡាយ មិនជារបស់បដិកូលបាន; **តែកាលពោលដោយក្លិនហើយ** រមែងជារបស់បដិកូលតែម្តង ។ ប្រៀបដូចដុំឧច្ចារៈ (អាចម៍) របស់ក្មេងតូចៗ **កាលពោលដោយពណ៌** មានពណ៌ដូចល្មៀត, **សូម្បីដោយសណ្ឋាន** ក៏មានសណ្ឋានដូចខ្ទែងល្មៀត និងសាកសពឆ្កែខ្មៅដែលប៉ោងឡើងដែលគេចោលទុកក្នុងទីចោលសម្រាម; **ពោលដោយពណ៌** ក៏មានពណ៌ដូចផ្លែត្នោតទុំ, **ពោលដោយសណ្ឋាន** មានសណ្ឋានដូចស្គរដែលគេបណ្តែតចោលទៅ សូម្បីចង្កូមរបស់វា ក៏ដូចជាផ្កាម្លិះ ព្រោះហេតុនោះ សូម្បីឧច្ចារៈក្មេងតូច និងសាកសពឆ្កែខ្មៅទាំងពីរ **កាលពោលដោយពណ៌** និងសណ្ឋាន មិនគប្បីជារបស់បដិកូលបាន, **តែកាលពោលដោយក្លិនហើយ** រមែងជារបស់បដិកូលនោះឯង យ៉ាងណា, សូម្បីសក់ ក៏យ៉ាងនោះដែរ **កាលពោលដោយពណ៌ និងសណ្ឋាន** មិនគប្បីជារបស់បដិកូលបាន, តែកាលពោលដោយក្លិនហើយ រមែងជារបស់បដិកូលពិតៗ ។

ក៏បន្លែសម្រាប់ ស្លដែលដុះឡើងក្នុងទីមិនស្អាត ដោយការហូរទៅនៃទឹកជ្រាំ មកអំពីភូមិដែលជារបស់គួរខ្ពើម មិនគួរបរិភោគសម្រាប់ជនអ្នកនគរ (អ្នកក្រុង) ទាំងឡាយយ៉ាងណា, សូម្បីសក់ទាំងឡាយក៏ដូច្នោះដែរ ឈ្មោះថា ខ្ពើមណាស់ ព្រោះដុះឡើងដោយទឹកដែលហូរចេញមកពីទឹក**ខ្ទុះ ឈាម ទឹកឧច្ចារៈ ទឹកបស្សាវៈ ទឹកប្រមាត់ និងទឹកស្លេស្មជាដើម** ។ នេះជាបដិកូលនៃសក់ទាំងនោះ **ដោយអាសយៈ** (ទីអាស្រ័យ) ។ មួយទៀត សក់ទាំងនេះកើតឡើងក្នុងគំនរនៃកោដ្ឋាសៈ ៣១ (ដែលមិនស្អាត) ដូចបន្លែកើតឡើង ត្រង់គំនរនៃលាមក, សក់ទាំងឡាយ ឈ្មោះថា គួររង្កៀសយ៉ាងក្រៃលែង ព្រោះដុះក្នុងទីដែលមិនស្អាត, ដូចបន្លែដែលដុះឡើងក្នុងព្រៃខ្មោច និងគំនរ សម្រាមជាដើម និងដូចផ្កាឈើ មានឈូកធំ និងព្រលិតជាដើម ដែលដុះឡើងក្នុងទីមិនស្អាត មានស្នាមភ្លោះជាដើម នេះជាភាពបដិកូលនៃសក់ទាំងនោះដោយឱកាស (គឺទីតាំងនៅ) ក៏ភាពបដិកូលនៃសក់ទាំងឡាយយ៉ាងណា, គប្បីកំណត់ភាពបដិកូលនៃកោដ្ឋាសៈទាំង ៥ យ៉ាង ដោយអំណាចនៃភាពបដិកូល **ដោយពណ៌ សណ្ឋាន ក្លិន អាសយៈ និងឱកាសយ៉ាងនោះចុះ** ។ តែថា ការពោលដោយពណ៌ សណ្ឋាន ទិស ឱកាស និងបរិច្ឆេទ សូម្បីក្នុងកោដ្ឋាសៈទាំងពួង គប្បីកំណត់តែមួយផ្នែកៗ ៕

## ២. លោមា = រោមទាំងឡាយ

បណ្ដាកោដ្ឋាសៈទាំងនោះ គប្បីកំណត់រោមទាំងឡាយ ដូចតទៅនេះ ៖

**ពោលដោយពណ៌** តាមប្រក្រតី មិនខ្មៅដូចសក់ពេកទេ, តែជាពណ៌ខ្មៅ

លាយលឿង ។

**ពោលដោយសណ្ឋាន** មានសណ្ឋានកោងចុង ដូចឫសត្នោត ។

**ពោលដោយទិស** កើតក្នុងទិសទាំងពីរ ។

**ពោលដោយឱកាស** វៀរឱកាសដែលសក់ទាំងឡាយតាំងនៅ និងផ្ទៃបាតដៃ បាតជើង ហើយដោយច្រើនកើតតាមស្បែកដណ្តប់សរីរៈដែលនៅសល់ ។

**ពោលដោយបរិច្ឆេទ** ខាងក្រោម កំណត់ដោយផ្ទៃឫសរបស់រោមដែលចាក់ចុះជ្រៅចូលទៅក្នុងស្បែកដណ្តប់សរីរៈប្រមាណ ១ លិក្ខា [១០៣], ខាងលើ កំណត់ដោយអាកាស, ជុំវិញ កំណត់ដោយរោមផងគ្នា។ ការកំណត់រោម ២ សរសៃ មិនបានរួមគ្នាជាចំណែកតែមួយ; នេះជាសភាគបរិច្ឆេទនៃរោមទាំងនោះ, ចំណែកវិសភាគបរិច្ឆេទ ដូចនឹងសរសៃសក់នោះឯង ៕

## ៣. នខា = ក្រចកទាំងឡាយ

ពាក្យថា **នខា** ជាឈ្មោះនៃក្រចក ២០, ក្រចកទាំងនោះ ៖

**ពោលដោយពណ៌** មានពណ៌ស ។

**ពោលដោយសណ្ឋាន** មានសណ្ឋានដូចស្រកាត្រី ។

---

[១០៣] ពាក្យថា លិក្ខា នេះ ជាឈ្មោះនៃមាត្រាវាស់រយៈបណ្តោយ ក្នុងអភិធានប្បទីបិកាពោលដូច្នេះ ៖

៣៦ បរិមាណូ = ១ អណូ, ៣៦ អណូ = ១ តជ្ជារី,

៣៦ តជ្ជារី = ១ រថរេណូ, ៣៦ រថរេណូ = ១ លិក្ខា,

៧ លិក្ខា = ១ ឩកា, ៧ ឩកា = ១ធញ្ញមាស ។ល ។

**ពោលដោយទិស** ដុះក្នុងទីទាំង ២ គឺក្រចកជើង ដុះក្នុងទិសខាងក្រោម, ក្រចកដៃ ដុះក្នុងទិសខាងលើ ។

**ពោលដោយឱកាស** តាំងនៅត្រង់ខ្នង ខាងផ្នែកចុងម្រាមទាំងឡាយ ។

**ពោលដោយបរិច្ឆេទ** ក្នុងទិសទាំង ២ កំណត់ដោយសាច់ចុងម្រាម, ខាងក្នុង កំណត់ដោយសាច់ខ្នងម្រាម, ខាងក្រៅ និងចុង កំណត់ដោយអាកាស, ខាងទទឹង កំណត់ដោយក្រចកផងគ្នា។ ការកំណត់ថា ក្រចក ២ ផ្ទាំង មិនរួមជាផ្ទាំងតែមួយជាមួយគ្នាទេ, នេះជាសភាគបរិច្ឆេទ; ឯវិសភាគបរិច្ឆេទ ដូចសរសៃសក់នោះឯង ៕

## ៤. ទន្តា = ធ្មេញទាំងឡាយ

ពាក្យថា **ទន្តា** គឺធ្មេញ ៣២ សម្រាប់អ្នកមានធ្មេញបរិបូណ៌។ សូម្បីធ្មេញទាំងនោះ ÷

**ពោលដោយពណ៌** ក៏មានពណ៌ស ។

**ពោលដោយសណ្ឋាន** មានសណ្ឋានមិនមែនមួយ, ពិតមែនហើយ បណ្តាធ្មេញទាំងឡាយនោះ ធ្មេញ ៤ ត្រង់កណ្តាលជួរធ្មេញខាងក្រោម មានសណ្ឋានដូចគ្រាប់ឃ្លោកដែលគេដោតរៀងគ្នាទុកត្រង់ដុំដីស្អិត។ ធ្មេញ ២ អមសងខាង នៃធ្មេញកណ្តាល ៤ នោះ, ធ្មេញម្ខាងៗ មានឫសតែមួយ មានចុងតែមួយ មានសណ្ឋានដូចផ្កាម្លិះក្រពុំ។ បន្ទាប់ពីនោះ ធ្មេញខាងនីមួយៗ មានឫស ២ មានចុង ២ មានសណ្ឋានដូចឈើទល់យានតូច (រទេះ)។ បន្ទាប់ទៅ ធ្មេញខាងពីរៗ មានឫស ៣ មានចុង ៣ ។ បន្ទាប់ទៅខាងពីរៗ មានឫស ៤ មានចុង ៤។ សូម្បីធ្មេញជួរលើ ក៏

ន័យនេះដែរ ។

**-ពោលដោយទិស** កើតក្នុងទិសខាងលើ ។

**-ពោលដោយឱកាស** តាំងនៅត្រង់ឆ្អឹងថ្គាមទាំង ២ ។

**-ពោលដោយបរិច្ឆេទ** ខាងក្រោម កំណត់ដោយផ្ទៃឫសរបស់ធ្មេញ ដែលតាំងនៅត្រង់ឆ្អឹងថ្គាម, ខាងលើ កំណត់ដោយអាកាស, ខាងទទឹង កំណត់ដោយធ្មេញផងគ្នា, ការកំណត់ថា ធ្មេញ ២ មិនបានរួមនៅជាមួយគ្នា នេះជាសភាគបរិច្ឆេទនៃធ្មេញទាំងឡាយនោះ, ចំណែកវិសភាគបរិច្ឆេទ ដូចនឹងសរសៃសក់នោះឯង ៕

## ៥. តចោ = ស្បែក

ពាក្យថា **តចោ** គឺស្បែកដណ្ដប់សរីរាង្គទាំងអស់, ស្បែកនោះមានពណ៌សម្បុរខ្មៅស្រគំ (ខ្មៅសណ្ដែកបាយ) លឿងជាដើម សម្បុរស្បែកនោះ កាលច្បូតចេញអំពីសរីរៈទាំងអស់ ក៏នឹងមានប្រមាណប៉ុនគ្រាប់ពុទ្រា ។

ស្បែកនោះ **ពោលដោយពណ៌** មានពណ៌សប៉ុណ្ណោះ, ក៏សេចក្ដីដែលស្បែកមានពណ៌សនោះ រមែងប្រាកដក្នុងកាលស្បែកសម្បុរផ្ទៃរលាត់ចេញទៅ ព្រោះរលាកអណ្ដាតភ្លើង ឬត្រូវរលាត់ដោយគ្រឿងប្រហារជាដើម ។

**-សណ្ឋានតោ** ពោលដោយសណ្ឋាន មានសណ្ឋានដូចរាងកាយនោះឯង, នេះជាសេចក្ដីសង្ខេបក្នុងខថា "ពោលដោយសណ្ឋាន" ។

ក៏ឯពោលដោយសេចក្ដីពិស្ដារ ស្បែកម្រាមជើងមានសណ្ឋានដូចសំបុកដង្កូវ

នាង [១០៤], ស្បែកខ្នងជើង មានសណ្ឋានដូចស្បែកជើងក្រវ៉ាត់កែង, ស្បែកស្មងជើង មានសណ្ឋានដូចស្លឹកត្នោតខ្ចប់បាយ, ស្បែកភ្លៅ មានសណ្ឋានដូចថង់វែងច្រកអង្ករ, ស្បែកត្រចៀក មានសណ្ឋានដូចផ្ទាំងសំពត់តម្រងទឹកដែលពេញដោយទឹក, ស្បែកខ្នង មានសណ្ឋានដូចស្បែកស្រោបខែល, ស្បែកពោះ មានសណ្ឋានដូចស្បែកស្រោបស្នូកពិណ, ស្បែកទ្រូងដោយច្រើនមានសណ្ឋាន ៤ ជ្រុង, ស្បែកដៃទាំង ២ មានសណ្ឋានដូចស្បែកស្រោបបំពង់កូនធ្នូ(សរ), ស្បែកខ្នងដៃ មានសណ្ឋានដូចស្រោមកាំបិតកោរ ឬដូចថង់ខែល, ស្បែកម្រាមដៃ មានសណ្ឋានដូចស្រោមកូនសោ, ស្បែក-ក មានសណ្ឋានដូចអាវបិទក, ស្បែកមុខដែលមានប្រហោងតូច ប្រហោងធំ មានសណ្ឋានដូចសំបុកកណ្តូប, ស្បែកក្បាល មានសណ្ឋានដូចស្លោក (គឺស្រោម) បាត្រ ៕

## វិធីកំណត់ស្បែក

ព្រះយោគាវចរអ្នកកំណត់ស្បែកជាអារម្មណ៍ គប្បីបញ្ជូនញាណទៅខាងមុខតាំងអំពីរិមបបូរមាត់ខាងលើឡើងទៅ ហើយកំណត់ស្បែកដណ្តប់មុខមុន; តអំពីនោះ គប្បីកំណត់ស្បែកថ្ងាស; បន្ទាប់ពីនោះមក ក៏គប្បីបញ្ជូនញាណទៅចន្លោះលលាដ៏ក្បាល និងស្បែកក្បាល ដូចស៊កដៃទៅក្នុងចន្លោះបាត្រ និងស្លោកបាត្រដែលពាក់ទុកដូច្នោះ ដោយញែកស្បែកដែលជាប់គ្នានឹងលលាដ៏ក្បាលចេញ កំណត់តែស្បែកក្បាល, តទៅក៏កំណត់ស្បែកក; តទៅទៀត កំណត់ស្បែកដៃខាងស្តាំ ទាំង

[១០៤] បាលីថា កោសការកកោសោ ។

ដោយអនុលោម (អំពីស្មាចុះទៅកំភួនដៃ) ទាំងដោយបដិលោម (អំពីកដៃឡើងទៅដល់ស្មា); បន្ទាប់ពីនោះមកទៀត គប្បីកំណត់ស្បែកដៃឆ្វេងដោយន័យមុននុ៎ះឯង, តពីនោះ គប្បីកំណត់ស្បែកខ្នង។ គ្រាកំណត់ស្បែកនោះៗ ហើយ គប្បីកំណត់ស្បែកជើងស្តាំ ទាំងដោយអនុលោម និងបដិលោម, ក្រោយពីនោះមក គប្បីកំណត់ស្បែកជើងឆ្វេង ដោយន័យមុននុ៎ះឯង, បន្ទាប់ពីនោះ គប្បីកំណត់ស្បែកពោះតូច, ស្បែកផ្ទៃពោះមុខ ស្បែកទ្រូងស្បែកក ដោយលំដាប់តែមួយ; បន្ទាប់មក គប្បីកំណត់ស្បែកក្រោមថ្គាម បន្ទាប់អំពីស្បែកកឡើងទៅ ដរាបដល់រឹមបបូរមាត់ខាងក្រោមជាទីបំផុត ទើបសម្រេច។ កាលព្រះយោគាវចរកំណត់ស្បែកធំៗ យ៉ាងនេះ សូម្បីស្បែកតូចៗ ក៏រមែងប្រាកដ ។

**ទិសតោ** ពោលដោយទិស កើតក្នុងទិសទាំង ២ ។

**ឱកាសតោ** ពោលដោយឱកាស តាំងនៅដណ្តប់សរីរៈទាំងអស់ ។

**បរិច្ឆេទតោ** ពោលដោយបរិច្ឆេទ ខាងក្រោម កំណត់ដោយផ្ទៃដែលតាំងនៅ, ខាងលើកំណត់ដោយអាកាស; នេះជាសភាគបរិច្ឆេទ, ចំណែកវិសភាគបរិច្ឆេទ ដូចនឹងសរសៃសក់នុ៎ះឯង ៕

## ៦. មំសំ = សាច់

ពាក្យថា **មំសំ** គឺដុំសាច់ ៩០០ ដុំ; ដុំសាច់សូម្បីទាំងពួងនោះ ៖

**វណ្ណតោ** ពោលដោយពណ៌ មានពណ៌ក្រហមដូចផ្កាចារ ។

**សណ្ឋានតោ** ពោលដោយសណ្ឋាន សាច់ត្រយួងចេក (កំភួនជើង) មានសណ្ឋានដូចបាយខ្ចប់ដោយស្លឹកត្នោត, សាច់ភ្លៅ មានសណ្ឋានដូចអង្រែថ្ម

(និសទបោតកៈ), សាច់ត្រគាកមានសណ្ឋាន ដូចដុំជើងក្រាន, **សាច់ខ្នង មានសណ្ឋានដូចផែនស្ករត្នោត, សាច់ជំនីទាំង ២ ខាង មានសណ្ឋានដូចការបូកលាបដោយដីស្អិតស្តើងៗ ក្នុងជង្រុកស្រូវ, សាច់ដោះទាំង ២ មានសណ្ឋានដូចដុំដីស្អិត** ដែលគេលុញហើយបោះចុះក្រោមទុក, សាច់ដើមដៃទាំង ២ មានសណ្ឋានដូចកណ្តុរធំ ដែលគេបកស្បែកធ្វើទុកជា ២ ចំណែក, **កាលព្រះយោគាវចរកំណត់ដុំសាច់ធំៗ យ៉ាងនេះ សូម្បីសាច់ដុំតូចៗ ក៏រមែងប្រាកដ ។**

**ទិសតោ** ពោលដោយទិស កើតក្នុងទិសទាំង ២ ។

**ឱកាសតោ** ពោលដោយឱកាស តាំងនៅជាប់នឹងឆ្អឹង ៣០០ [១០៥] កំណាត់។

**បរិច្ឆេទតោ** ពោលដោយបរិច្ឆេទ ខាងក្រោម កំណត់ដោយផ្ទៃដែលតាំងនៅត្រង់គ្រោងឆ្អឹង, ខាងលើ កំណត់ដោយស្បែក, ខាងទទឹង កំណត់ដោយសាច់ផងគ្នា, នេះជាសភាគបរិច្ឆេទ; ចំណែកវិសភាគបរិច្ឆេទ ដូចនឹងសក់នុ៎ះដែរ ៕

## ៧. នហារូ = សរសៃទាំងឡាយ

ពាក្យថា **នហារូ** គឺសរសៃ ៩០០; **ពោលដោយពណ៌** សរសៃសូម្បីទាំងអស់ មានពណ៌ស; **ពោលដោយសណ្ឋាន** មានសណ្ឋានផ្សេងៗ; ពិតណាស់ សរសៃទាំងនោះ សរសៃធំដែលរុំព័ទ្ធសរីរៈតាំងអំពីខាងលើនៃក ចុះទៅខាងមុខបេះដូង ៥ សរសៃ, ខាងក្រោយ ៥ សរសៃ, ខាងស្តាំ ៥ សរសៃ, ខាងឆ្វេង ៥ សរសៃ, សូម្បីរុំព័ទ្ធដៃស្តាំ ខាងមុខដៃ ក៏ ៥ សរសៃ, ខាងក្រោយដៃ ក៏ ៥ សរសៃ; សូម្បីរុំពទ្ធដៃ

---

[១០៥] ភូមា = ៣០០ កំណាត់ដ៏សេស ។

ឆ្វេង ក៏យ៉ាងនោះដែរ;សូម្បីរុំព័ទ្ធជើងស្តាំ ខាងមុខជើង ក៏ ៥ សរសៃ, ខាងក្រោយ ក៏ ៥ សរសៃ; សូម្បីរុំព័ទ្ធជើងឆ្វេង ក៏យ៉ាងនោះដែរ; សរសៃធំ ៦០ រុំព័ទ្ធចុះទៅរហូតដល់កាយយ៉ាងនេះ ដោយប្រការដូច្នេះ ទើបឈ្មោះថា **សរីរធារកា** = ទ្រទ្រង់ទុកនូវសរីរៈ, លោកហៅថា **"កណ្ឌរា"** ដូច្នេះខ្លះ។ សរសៃទាំងនោះ សូម្បីទាំងអស់មានសណ្ឋាន ដូចដើមគុណ្ឌលមកុលខ្ចី។ ចំណែកសរសៃពួកដទៃ រុំព័ទ្ធចំណែកនោះ។ ហើយតាំងនៅ;គឺដែលតូចជាង (សរីរធារកា) នោះ មានសណ្ឋានដូចខ្សែអំបោះ, សរសៃពួកដទៃដែលតូចជាងនោះ មានសណ្ឋានដូចវល្លិផោម (វល្លិដែលមានក្លិនស្អុយ) សរសៃពួកដទៃដែលតូចជាងនោះទៀត មានសណ្ឋានដូចខ្សែពិណធំ, សរសៃពួកដទៃទៀត មានសណ្ឋានដូចសរសៃអំបោះធំ, សរសៃត្រង់ខ្នងដៃ និងជើង មានសណ្ឋានដូចជើងបក្សា, សរសៃត្រង់ក្បាល មានសណ្ឋានដូចសំណាញ់គ្របក្បាលកូនក្មេង, សរសៃត្រង់ខ្នង មានសណ្ឋានដូចអួនទទឹក ដែលគេសន្ធឹងកណ្តាលថ្ងៃ, សរសៃដ៏សេសដែលទៅតាមអវយវៈតូចធំនោះ។ មានសណ្ឋានដូចអាវសំណាញ់ដែលដណ្តប់សរីរៈ ។

**ទិសតោ** ពោលដោយទិស សរសៃកើតក្នុងទិសទាំង ២ ។

**ឱកាសតោ** ពោលដោយឱកាស តាំងនៅតោងឆ្អឹងទាំងឡាយ ក្នុងសរីរៈទាំងអស់ ។

**បរិច្ឆេទតោ** ពោលដោយបរិច្ឆេទ ខាងក្រោម កំណត់ដោយផ្ទៃដែលតាំងនៅលើឆ្អឹង ៣០០ កំណាត់, ខាងលើ កំណត់ដោយប្រទេសដែលតាំងនៅទល់សាច់

និងស្បែក, ខាងទទឹង កំណត់នូវគ្នានឹងគ្នា; នេះជាសភាគបរិច្ឆេទរបស់សរសៃទាំងនោះ, ចំណែកវិសភាគបរិច្ឆេទ ដូចនឹងសរសៃសក់នុ៎ះឯង ៕

## ៨. អដ្ឋិ = ឆ្អឹងទាំងឡាយ

ពាក្យថា **អដ្ឋិ** សេចក្តីថា វៀរឆ្អឹងធ្មេញ ៣២ ចេញ, ឆ្អឹងដែលនៅសល់មានប្រមាណ ៣០០ កំណាត់ គឺ

-ឆ្អឹងដៃ ៦៤ កំណាត់

-ឆ្អឹងជើង ៦៤ កំណាត់

-ឆ្អឹងខ្ចីជាប់សាច់៦៤ កំណាត់

-ឆ្អឹងកែងជើង ២ កំណាត់

-ឆ្អឹងភ្នែកគោរ ពីរខាង ៤ កំណាត់

-ឆ្អឹងស្មងជើង ២ ខាង ៤ កំណាត់

-ឆ្អឹងជង្គង់ ( គ្រាប់អង្គុញ) ២ កំណាត់

-ឆ្អឹងភ្លៅ ២ កំណាត់

-ឆ្អឹងចង្កេះ ២ កំណាត់

-ឆ្អឹងខ្នង ១៨ កំណាត់

-ឆ្អឹងជំនី ២៤ កំណាត់

-ឆ្អឹងទ្រូង ១៤ កំណាត់

-ឆ្អឹងជិតបេះដូង១ កំណាត់

-ឆ្អឹងដងកាំបិត ២ កំណាត់

-ឆ្អឹងស្លាបប្រចៀវ ២ កំណាត់

-ឆ្អឹងដើមដៃ ២ កំណាត់

-ឆ្អឹងចុង (កំភួន) ដៃ ៤ កំណាត់

-ឆ្អឹងក ៧ កំណាត់

-ឆ្អឹងចង្កា ២ កំណាត់

-ឆ្អឹងច្រមុះ ១ កំណាត់

-ឆ្អឹងប្រឡង់ភ្នែកពីរ២ កំណាត់

-ឆ្អឹងត្រចៀក ២ កំណាត់

-ឆ្អឹងថ្ងាស ១ កំណាត់

-ឆ្អឹងអំបែងក្បាល(ក្នុងក្បាល)១ កំណាត់

-ឆ្អឹង (លលាដ៏) ក្បាល ៩ កំណាត់ ។

**សូម្បីឆ្អឹងទាំងអស់នោះ ពោលដោយពណ៌ មានពណ៌ស; ពោលដោយសណ្ឋាន មានសណ្ឋានផ្សេង១; ពិតណាស់ បណ្តាឆ្អឹងទាំងនោះ ÷**

-ឆ្អឹងម្រាមជើងផ្នែកខាងចុង មានសណ្ឋានដូចគ្រាប់ផ្លែដីប្លី

-ឆ្អឹងផ្នែកកណ្តាលបន្ទាប់ពីចុង មានសណ្ឋានដូចគ្រាប់ផ្លែខ្នុរ

-ឆ្អឹងផ្នែកខាងគល់ មានសណ្ឋានដូចគ្រាប់កណ្តាប់ស្គរ (អង្កាំស្គរ)

-ឆ្អឹងខ្នងជើង មានសណ្ឋានដូចគំនរនៃវល្លិដើមសរសៃធំ ដែលត្រូវគេដំហើយ[១០៦]

[១០៦] កោដ្ឋិតកណ្ឌលកណ្ឌរាសិ ។

-ឆ្អឹងកែងជើង មានសណ្ឋានដូចកំពឹងត្នោត ១ ដុំ

-ឆ្អឹងភ្នែកគោ មានសណ្ឋានដូចគ្រាប់អង្គុញមួយគូ

-ឆ្អឹងស្មងជើងពីលើភ្នែកគោ មានសណ្ឋានដូចពន្លកឈើខ្ចី ដែលគេបកសម្បកចេញ ។

-ឆ្អឹងស្មងកំណាត់តូច មានសណ្ឋានដូចធ្នូ

-ឆ្អឹងស្មងកំណាត់ធំ មានសណ្ឋានដូចខ្នងពស់ដែលស្ងួតហើយ

-ឆ្អឹងជង្គង់ មានសណ្ឋានដូចក្រពេញទឹកដែលរេកទៅម្ខាង

-ឆ្អឹងស្មងដែលទល់នឹងជង្គង់ មានសណ្ឋានដូចស្នែងគោមានចុងទាល

-ឆ្អឹងភ្លៅខ្ចីមានសណ្ឋានដូចដងកាំបិតព្រា ឬដងពូថៅដែលគគ្រាត១

-ឆ្អឹងភ្លៅខ្ចីដែលទល់នឹងឆ្អឹងចង្កេះនោះ មានសណ្ឋានដូចគ្រាប់អង្គុញលេង

-ឆ្អឹងចង្កេះដែលទល់នឹងឆ្អឹងភ្លៅនោះ មានសណ្ឋានដូចផ្លែបុស្សនាគធំស្ពួចចុង

-ឆ្អឹងចង្កេះទាំង ២ កំណាត់ មានសណ្ឋានដូចជើងក្រានរបស់ជាងឆ្នាំង បើញែកចេញមួយ១ មានសណ្ឋានដូចដង្កាប់របស់ជាងមាស ។

-ឆ្អឹងត្រគាកផ្នែកខាងចុង មានសណ្ឋានដូចពពាររពស់ដែលគេចាប់ផ្កាប់មុខ មានប្រហោងតូច-ធំ ៧ កន្លែង ។

-ឆ្អឹងខ្នងខាងក្នុង មានសណ្ឋានដូចក្រវិលសំណដែលដាក់តម្រួតគ្នាទុក

-ឆ្អឹងខ្នងខាងក្រៅ មានសណ្ឋានដូចផ្លែផ្គាំ ។ ក្នុងចន្លោះនៃឆ្អឹងនោះ១ មានបន្លួញពីរ-បី ដែលដូចធ្មេញរណារ ។

**បណ្តាឆ្អឹងជំនីទាំង ២៤ កំណាត់ កំណាត់ដែលមិនពេញ មានសណ្ឋាន**

ដូចកណ្ដៀវដែលមិនពេញមុខ កំណាត់ដែលពេញ មានសណ្ឋានដូចកណ្ដៀវដែលពេញមុខ ។

-សូម្បីឆ្អឹងជំនីទាំងអស់ មានសណ្ឋានដូចស្លាបមាន់សំឡីដែលកាងឡើង

-ឆ្អឹងទ្រូង ១៤ កំណាត់ មានសណ្ឋានដូចរបាំគ្រែស្នែងចាស់

-ឆ្អឹងជិតបេះដូង មានសណ្ឋានដូចវែក

-ឆ្អឹងដងកាំបិត មានសណ្ឋានដូចដងកាំបិតលោហៈតូច

-ឆ្អឹងស្លាបប្រចៀវ មានសណ្ឋានដូចចបអ្នកស្រុកសីហឡៈដែលរិលទៅម្ខាង

-ឆ្អឹងដើមដៃ មានសណ្ឋានដូចដងវែនតា កំណាត់ខាងចុង មានសណ្ឋានដូចឫសត្នោតពីរ ។

-ឆ្អឹងថ្នាំងដៃ មានសណ្ឋានដូចវង់ផែនសំណដែលគេភ្ជាប់គ្នាហើយតាំងទុក

-ឆ្អឹងខ្នងដៃ មានសណ្ឋានដូចគំនរនៃដើមវល្លិសរសៃធំដែលគេដំហើយ

-ឆ្អឹងម្រាមដៃត្រង់គល់ មានសណ្ឋានដូចបណ្ឌវៈ

-ឆ្អឹងម្រាមកំណាត់កណ្ដាល មានសណ្ឋានដូចគ្រាប់ខ្នុរមិនពេញគ្រាប់

-ឆ្អឹងម្រាមកំណាត់ខាងចុង មានសណ្ឋានដូចគ្រាប់ផ្លែជីប្លី

-ឆ្អឹងក ៧ កំណាត់ មានសណ្ឋានដូចកង់ទំពាំង ដែលគេប្រើឈើដោតទុកដោយលំដាប់ ។

-ឆ្អឹងថ្គាមក្រោម មានសណ្ឋានដូចដង្កាប់ដែករបស់ជាងលោហៈ

-ឆ្អឹងកំណាត់លើ មានសណ្ឋានដូចដែកខ្ចោះ

-ឆ្អឹងរន្ធភ្នែក និងឆ្អឹងរន្ធច្រមុះ មានសណ្ឋានដូចពន្លកគ្រាប់ត្នោតខ្ចី ដែលគេ

ខ្វេះសាច់ចេញ ។

-ឆ្អឹងថ្ពាស មានសណ្ឋានដូចសម្បកសង្ខដែលផ្កាប់មុខ

-ឆ្អឹងត្រចៀក មានសណ្ឋានដូចស្រោមកាំបិតកោររបស់ជាងកោរកាត់

-ឆ្អឹងដែលតាំងនៅជាប់គ្នាជាផ្ទាំងផ្នែកលើរបស់ឆ្អឹងថ្ពាស និងឆ្អឹងត្រចៀក មានសណ្ឋានដូចផ្ទាំងសំពត់ពេញឆ្អាំងដែលក្រញ៉ីក្រញូក់ ។

-ឆ្អឹងក្នុងក្បាល មានសណ្ឋានដូចត្រឡោកដូងដែលបែកហើយត្រង់សន្ទះមុខ

-ឆ្អឹងក្បាល មានសណ្ឋានដូចត្រឡោកឃ្លោកចាស់ ដែលគេដេរភ្ជាប់គ្នាហើយតាំងទុក ។

**ទិសតោ** ពោលដោយទិស កើតក្នុងទិសទាំងពីរ ។

**ឱកាសតោ** ពោលដោយឱកាស តាំងនៅក្នុងសរីរៈទាំងអស់ ដោយមិនប្លែកគ្នា។ **តែកាលពោលដោយប្លែកគ្នាក្នុងទីនេះ** ឆ្អឹងក្បាលតាំងនៅខាងលើឆ្អឹងក, ឆ្អឹងកតាំងនៅលើឆ្អឹងខ្នង, ឆ្អឹងខ្នងតាំងនៅលើឆ្អឹងចង្កេះ, ឆ្អឹងចង្កេះតាំងនៅលើឆ្អឹងភ្លៅខ្ចី, ឆ្អឹងភ្លៅខ្ចី តាំងនៅលើឆ្អឹងជង្គង់, ឆ្អឹងជង្គង់ តាំងនៅលើឆ្អឹងស្មង, ឆ្អឹងស្មង តាំងនៅលើឆ្អឹងភ្នែកគោរ, ឆ្អឹងភ្នែកគោរ តាំងនៅលើឆ្អឹងខ្នងជើង ។

**បរិច្ឆេទតោ** ពោលដោយបរិច្ឆេទ ខាងក្នុងកំណត់ដោយខួរក្នុងឆ្អឹង, ខាងក្រៅ កំណត់ដោយសាច់, ត្រង់ចុង និងគល់ កំណត់ដោយឆ្អឹងផងគ្នា ។

នេះជាសភាគបរិច្ឆេទនៃឆ្អឹងនោះ, ឯវិសភាគបរិច្ឆេទដូចនឹងសក់នោះដែរ ៕

## ៩. អដ្ឋិមិញ្ជំ = ខួរក្នុងឆ្អឹង

ពាក្យថា **អដ្ឋិមិញ្ជំ** គឺខួរដែលនៅខាងក្នុងឆ្អឹងនោះៗ;ខួរក្នុងឆ្អឹងនោះ **ពោល**

**ដោយពណ៌** មានពណ៌ស ។ **ពោលដោយសណ្ឋាន** ខួរដែលតាំងនៅខាងក្នុងនៃឆ្អឹងកំណាត់ធំៗ មានសណ្ឋានដូចចុងផ្តៅធំ ដែលគេរោលភ្លើងញាត់ទុកក្នុងបំពង់ឫស្សី, ខួរដែលតាំងនៅខាងក្នុងឆ្អឹងកំណាត់តូចៗ មានសណ្ឋានដូចចុងផ្តៅតូចដែលគេរោលភ្លើងញាត់ទុកក្នុងបំពង់ឫស្សីនៃថ្នាំងឫស្សី[១០៧] (ខ្លះពោលថាក្នុងបំពង់បបុស) ។ **ពោលដោយទិស** កើតក្នុងទិសទាំង ២ ។ **ពោលដោយឱកាស** តាំងនៅក្នុងឆ្អឹងទាំង-ឡាយ ។ **ពោលដោយបរិច្ឆេទ** កំណត់ដោយផ្ទៃខាងក្នុងនៃឆ្អឹងទាំងឡាយ ។ នេះជាសភាគបរិច្ឆេទរបស់ខួរក្នុងឆ្អឹងនោះ, ចំណែកវិសភាគបរិច្ឆេទដូចនឹងសក់នោះឯង ៕

## ១០. **វក្កំ = តម្រងបស្សាវៈ** (តម្រងនោម)

ពាក្យថា **វក្កំ** គឺតម្រងបស្សាវៈ ជាដុំសាច់ ២ ដុំ មានទងជាមួយគ្នា; តម្រងបស្សាវៈនោះ **ពោលដោយពណ៌** មានពណ៌ក្រហមព្រឿង ដូចពណ៌គ្រាប់រលួសបាយ ។ **ពោលដោយសណ្ឋាន** មានសណ្ឋានដូចគ្រាប់អង្គុញពីរសម្រាប់លេងរបស់ក្មេងៗ ឬមានសណ្ឋាន ដូចផ្លែស្វាយពីរមានទងជាមួយគ្នា ។ **ពោលដោយទិស** កើតក្នុងទិសខាងលើ ។ **ពោលដោយឱកាស** តាំងនៅដោយទងសរសៃធំមានឫសជាមួយគ្នា ចេញពីបំពង់កទៅបន្តិចហើយ ក៏បែកចេញជាពីរសរសៃពទ្ធជុំវិញសាច់បេះដូង ។ **ពោលដោយបរិច្ឆេទ** តម្រងបស្សាវៈកំណត់បានដោយចំណែកដែលជាតម្រងបស្សាវៈ ។ នេះជាសភាគបរិច្ឆេទ របស់ទាចនោះ; ចំណែកវិសភាគបរិច្ឆេទដូចនឹងសក់នោះឯង ៕

---

[១០៧] វេឡុយដ្ឋិបព្វេសុ ។

## ១១. **ហទយំ** = **សាច់បេះដូង**

ពាក្យថា **ហទយំ** គឺសាច់បេះដូង;សាច់បេះដូងនោះ **ពោលដោយពណ៌** មានពណ៌ក្រហម ដូចពណ៌ខាងខ្នងត្របកផ្កាឈូក ។ **ពោលដោយសណ្ឋាន** មានសណ្ឋានដូចផ្កាបទុមក្រពុំ ដែលគេប្រឡេះត្របកខាងក្រៅចេញ ហើយតាំងផ្កាប់ចុះ; ខាងក្រៅរាបស្មើរលោង, តែខាងក្នុងដូចជាខាងក្នុងនៃផ្លែននោងល្វីង(ននោងព្រៃ); សាច់បេះដូងរបស់មនុស្សមានបញ្ញា រីកបន្តិច;របស់មនុស្សគ្មានបញ្ញា ដូចជាផ្កាឈូកក្រពុំនោះឯង; ក៏ខាងក្នុងរបស់សាច់បេះដូងនោះ ជារណ្ដៅមានប្រមាណអាចបញ្ចុះគ្រាប់ផ្កាបុស្សនាគបាន; ក្នុងទីណា លោហិតមានប្រមាណកន្លះបាតដៃ កកនៅ; មនោធាតុ និងមនោវិញ្ញាណធាតុ អាស្រ័យទីណាហើយប្រព្រឹត្តទៅ; ឯលោហិតនោះៗ ក្នុងទីនោះៗ របស់មនុស្សរាគចរិត ជាពណ៌ក្រហម;របស់មនុស្សទោសចរិតជាពណ៌ខ្មៅ, របស់មនុស្សមោហចរិត មានពណ៌ដូចទឹកលាងសាច់; របស់មនុស្សវិតក្កចរិត មានពណ៌ដូចនឹងទឹកបបរសណ្ដែក...; របស់មនុស្សសទ្ធាចរិត មានពណ៌ដូចផ្កាកណិការ; របស់មនុស្សបញ្ញាចរិត ជាពណ៌ថ្លា ផូរផង់ មិនមួហ្មង សបរិសុទ្ធរមែងប្រាកដរុងរឿងដូចកែវមណីសុទ្ធដែលគេឆ្នៃហើយ ។ **ពោលដោយទិស** កើតក្នុងទិសខាងលើ ។ **ពោលដោយឱកាស** តាំងនៅត្រង់កណ្ដាលនៃដោះទាំងពីរខាងក្នុងសរីរៈ ។ **ពោលដោយបរិច្ឆេទ** កំណត់ដោយចំណែកដែលជាសាច់បេះដូង ។ នេះជាសភាគបរិច្ឆេទរបស់បេះដូងនោះ; ចំណែកវិសភាគបរិច្ឆេទ ដូចនឹងសក់នោះដែរ ៕

## ១២. យកនំ = ថ្លើម

ពាក្យថា **យកនំ** គឺជាដុំសាច់មួយគូ; ថ្លើមនោះ **ពោលដោយពណ៌** មានពណ៌ក្រហមលាយលឿង; មិនក្រហមច្បាស់ដូចពណ៌ត្របកកុមុទ (ផ្កាឈូកក្រហម) ។ **ពោលដោយសណ្ឋាន** ត្រង់គល់មានដុំជាមួយគ្នា; ត្រង់ចុងផ្នែកជា ២ មានសណ្ឋានដូចស្លឹករលួសផ្អុង ។ មួយទៀត ថ្លើមនោះ សម្រាប់អ្នកមានបញ្ញាខ្សោយ ជាដុំធំមួយដុំប៉ុណ្ណោះ; របស់អ្នកមានបញ្ញាខ្លាំង ជាដុំតូចៗ ២ ឬ ៣ ដុំ ។ **ពោលដោយទិស** កើតក្នុងទិសខាងលើ ។ **ពោលដោយឱកាស** អាស្រ័យនៅខាងស្តាំត្រង់ចន្លោះដោះទាំងពីរ ។ **ពោលដោយបរិច្ឆេទ** កំណត់ដោយចំណែកដែលជាថ្លើម ។ នេះជាសភាគបរិច្ឆេទនៃថ្លើមនោះ; ចំណែកវិសភាគបរិច្ឆេទ ដូចនឹងសក់នោះឯង ៕

## ១៣. កិលោមកំ = វាវ

ពាក្យថា **កិលោមកំ** គឺវាវ ជាសាច់សម្រាប់ដណ្តប់មាន ២ ប្រភេទ ដោយជាវាវប្រភេទបិទបាំង និងវាវប្រភេទមិនបិទបាំង;សូម្បីវាវទាំងពីរនោះ **ពោលដោយពណ៌** មានពណ៌សដូចពណ៌សំពត់ទុកូល (សំពត់ធ្វើដោយសម្បកឈើ)ចាស់។ **ពោលដោយសណ្ឋាន** មានសណ្ឋានតាមដែលតាំងនៅរបស់ខ្លួន ។ **ពោលដោយទិស** វាវប្រភេទបិទបាំង (ប្រក្រតី) កើតក្នុងទិសខាងលើ;វាវក្រៅនេះ កើតក្នុងទិសទាំងពីរ;**ពោលដោយឱកាស** វាវប្រភេទដែលបិទបាំង (ប្រក្រតី) តាំងនៅដណ្តប់បេះដូង និងទាច;វាវប្រភេទមិនបិទបាំង (មិនប្រក្រតី) តាំងនៅតោងសាច់

ក្រោមស្បែកក្នុងសរីរៈទាំងអស់ ។ **ពោលដោយបរិច្ឆេទ** ខាងក្រោម កំណត់ដោយសាច់; ខាងលើ កំណត់ដោយស្បែក; និងជុំវិញ កំណត់ដោយចំណែកដែលជាវ៉ាវ ។ នេះជាសភាគបរិច្ឆេទរបស់វ៉ាវនោះ; ចំណែកវិសភាគបរិច្ឆេទ ដូចនឹងសក់នោះឯង ៕

## ១៤. **បិហកំ** = **ក្រពះ**

ពាក្យថា **បិហកំ** គឺសាច់ ដូចជាអណ្តាតនៅក្នុងពោះ; ក្រពះនោះ **ពោលដោយពណ៌** មានពណ៌ខៀវ (គឺពណ៌ទឹកប្រាក់ចាស់) ដូចផ្កាគុន្ទីស ។ **ពោលដោយសណ្ឋាន** ដូចអណ្តាតកូនគោខ្មៅ លានចេញទៅប្រមាណ ៧ ធ្នាប់ ។ **ពោលដោយទិស** កើតក្នុងទិសខាងលើ ។ **ពោលដោយឱកាស** អាស្រ័យតាំងនៅលើផ្ទៃពោះ ចំហៀងខាងឆ្វេងរបស់បេះដូង; កាលវាចេញមកខាងក្រៅ ព្រោះត្រូវគេប្រហារដោយគ្រឿងប្រហារ សត្វទាំងឡាយក៏នឹងអស់ជីវិត ។ **ពោលដោយបរិច្ឆេទ** កំណត់ដោយចំណែកដែលជាក្រពះ ។ នេះជាសភាគបរិច្ឆេទរបស់ក្រពះនោះ; ចំណែកវិសភាគបរិច្ឆេទ ដូចនឹងសក់នោះឯង ៕

## ១៥. **បប្ផាសំ** = **សួត**

ពាក្យថា **បប្ផាសំ** គឺសួត ចែកចេញជាដុំសាច់ ៣២ ដុំ; សួតនោះ **ពោលដោយពណ៌** មានពណ៌ក្រហម ដូចផ្លែល្វាមិនទុំណាស់ ។ **ពោលដោយសណ្ឋាន** ដូចនំដុំក្រាស់ៗ ដែលកាត់មិនស្មើគ្នា; ចំណែកខាងក្នុងវាស្លេកស្លាំង ព្រោះត្រូវកំដៅក្តៅដែលកើតអំពីកម្មដុតបំផ្លាញដោយមិនមានវត្ថុដែលស៊ី និងផឹកចូលទៅ ដូចដុំស្លឹកឈើ

ដែលគេទំពាស៊ីហើយ (នៅសល់តែកាក) រករស និងឱជះមិនបាន ។ **ពោលដោយទិស** កើតក្នុងទិសខាងលើ ។ **ពោលដោយឱកាស** តាំងនៅព្យួរគ្របលើបេះដូង និងថ្លើមនោះ ត្រង់ចន្លោះដោះទាំង ២ ខាងក្នុងសរីរៈ។ **ពោលដោយបរិច្ឆេទ** កំណត់ចំណែកដែលជាស្បូត ។ នេះជាសភាគបរិច្ឆេទរបស់ស្បូតនោះ; ចំណែកវិសភាគបរិច្ឆេទ ដូចនឹងសក់នោះឯង ៕

## ១៦. អន្តំ = ពោះវៀនធំ

ពាក្យថា **អន្តំ** បានដល់ ពោះវៀនធំ; សម្រាប់មនុស្សប្រុសប្រវែង ៣២ ហត្ថ;មនុស្សស្រីប្រវែង ២៨ ហត្ថ ជាពោះវៀនបត់ ព្រោះបត់ទៅមកក្នុងទី ២១ កន្លែង;ពោះវៀនធំនោះ **ពោលដោយពណ៌** មានពណ៌ស ដូចពណ៌ដុំក្រួសស។ **ពោលដោយសណ្ឋាន** មានសណ្ឋានដូចពស់ (អន្ទង់ស) ដែលគេកាត់ក្បាលឆ្វាយទុកក្នុងស្នូកឈាម ។ **ពោលដោយទិស** កើតក្នុងទិសទាំង ២ ។ **ពោលដោយឱកាស** តាំងនៅក្នុងសរីរៈ មានក និងទ្វារធំជាខេត្តដែន ។ ដោយជាប់ជាមួយគ្នាគឺខាងលើ តាំងនៅត្រង់ប្រហោងបំពង់ក; ខាងក្រោមតាំងនៅត្រង់ទ្វារធំ ។ **ពោលដោយបរិច្ឆេទ** កំណត់ដោយចំណែកដែលជាពោះវៀនធំ ។ នេះជាសភាគបរិច្ឆេទរបស់ពោះវៀនធំនោះ; ចំណែកវិសភាគបរិច្ឆេទ ដូចនឹងសក់នោះដែរ ៕

## ១៧. អន្តគុណំ = ពោះវៀនតូច

ពាក្យថា **អន្តគុណំ** គឺពោះវៀនដែលជាខ្សែព័ន្ធនៅក្នុងទីរមូរពោះវៀនធំ ។ ពោះវៀនតូចនោះ **ពោលដោយពណ៌** មានពណ៌សដូចឫសចង្កុលនី ។ **ពោលដោយសណ្ឋាន** មានសណ្ឋានដូចឫសចង្កុលនីនុ៎ះឯង ។ **ពោលដោយទិស** កើតក្នុងទិសទាំងពីរ ។ **ពោលដោយឱកាស** ពោះវៀនតូចនោះ តាំងនៅតោងផ្ទត់ពោះវៀនធំទុកជាចំណងជាមួយគ្នា ដូចខ្សែគ្រឿងយន្តដែលកាន់តោងទ្រាប់យន្តទុក ក្នុងវេលាដែលគ្រឿងយន្តទាញ របស់នាយជាងអ្នកធ្វើការងារទាំងឡាយ មានការចោះ និងការចាំងជាដើម ដែលតាំងនៅក្នុងចន្លោះផ្ទត់ពោះវៀនធំ ក្នុងទី ២១ កន្លែង ដូចខ្សែដែលដេរដោតក្រង ក្នុងចន្លោះមណ្ឌលខ្សែសម្រាប់ជូតជើងដូច្នោះ ។ **ពោលដោយបរិច្ឆេទ** កំណត់ដោយចំណែកដែលជាពោះវៀនតូច ។ នេះជាសភាគបរិច្ឆេទរបស់ពោះវៀនតូចនោះ; ចំណែកវិសភាគបរិច្ឆេទ ដូចនឹងសក់នោះដែរ ៕

## ១៨. ឧទរិយំ = អាហារថ្មី

ពាក្យថា **ឧទរិយំ** បានដល់ របស់ដែលបរិភោគ (បាយ) ដែលលេប (ទឹក) ដែលទំពាស៊ី (ផ្លែឈើជាដើម) ដែលលិទ្ធភ្លក់ (ទឹកឃ្មុំជាដើម) ចូលទៅក្នុងពោះ ។ អាហារថ្មីនោះ **ពោលដោយពណ៌** មានពណ៌ដូចអាហារដែលលេបចូលទៅ ។ **ពោលដោយសណ្ឋាន** មានសណ្ឋានដូចថង់ស្តើង១ ដែលបញ្ចុះបាយ ។ **ពោលដោយទិស** កើតក្នុងទិសខាងលើ ។ **ពោលដោយឱកាស** តាំងនៅក្នុងពោះ (ក្រពះអាហារ)

អវយវៈក្រពេញពោះវៀន ដូចការបោងសំពត់ដែលកើតឡើងត្រង់កណ្តាលនៃសំពត់សើមដែលគេរួបជាយទុក ហៅថា ពោះ;ពោះនោះខាងក្រៅ រលីងរាបស្មើ; ខាងក្នុងដូចនឹងសំពត់ដែលខ្ចប់សាច់សំណល់ ឬសំពត់ដណ្តប់ប្រចាំខែដែលប្រឡាក់ហើយ; សូម្បីនឹងពោលថា ដូចនឹងខាងក្នុងនៃកូនខ្នុរ ល្អុតក៏គួរ ។ ក្នុងពោះទទេ ក៏មានពួកដង្កូវទាំងឡាយចែកចេញបានដល់ទៅ ៣២ ត្រកូល គឺ ៖

មានព្រូនរាងមូល ( ធម្មតា) ព្រូនខ្លួនមូល ព្រូនបន្លាត្នោត ព្រូនមាត់ម្ជុល ព្រូនខ្លួនសំប៉ែត ព្រូនសរសៃអំបោះជាដើម ជាត្រកូលផ្សេងៗ ពាសពេញដេរដាសអាស្រ័យនៅគ្រាច់ទៅជាពួកៗ; គ្រាកាលទឹក និងបាយជាដើមមិនមាន វាក៏នឹងផ្លែផ្លាពពាក់ពពូនខាំស៊ីសាច់ដែលវាអាស្រ័យនៅ; ក្នុងវេលាដែលលេបអាហារមានទឹក និងបាយជាដើមចូលទៅ វាក៏នឹងនាំគ្នាងើយមាត់ឡើងទទួលប្រញាប់ប្រញាល់ដណ្តើមពំនូតបាយដែលលេបចូលទៅគ្រាដំបូង ២-៣ ពំនូត ។ ត្រង់ពោះនោះឯងដូចជាផ្ទះកើត; វច្ចកុដិ ( បន្ទប់អនាម័យ) ; រោងព្យាបាល និងស្មសាន ( ព្រៃខ្មោច) របស់ពួកដង្កូវនោះ ។ អាហារទាំងឡាយមានទឹក និងបាយជាដើម មានប្រការផ្សេងៗ ដែលល្អិតដោយអង្រែ គឺធ្មេញ កៀសត្រឡប់ទៅមកដោយដៃ គឺអណ្តាតច្របូកច្របល់ដោយទឹកមាត់; ខណៈនោះឯង ក៏នឹងជាវត្ថុដែលប្រាសចាកគុណសម្បត្តិរបស់ពណ៌ ក្លិន និងរសជាដើម ដូចជាបាយជ្រលក់អំបោះរបស់នាយជាងតម្បាញ ឬដូចជាសុនខ និងស្នួកសុនខ គ្រាធ្លាក់ចុះទៅក្នុងក ក៏នឹងច្របូកច្របល់លាយទឹកប្រមាត់ទឹកស្លេស្ម ឈាមឡើងហើយ ដោយកម្លាំងនៃការដុតរោលរបស់ភ្លើងក្នុងពោះ ( ធាតុភ្លើងរំលាយអាហារ) ច្របូកច្របល់ទៅដោយពួកដង្កូវងើបឡើងមកលើដោយ

លំដាប់ ដល់នូវភាពជាវត្ថុស្មោកគ្រោក មានក្លិនអាក្រក់ក្រៃលែងណាស់ តាំងនៅក្នុងពោះនោះ ប្រៀបដូចកាលភ្លៀងគ្រាប់ក្រាស់ (ភ្លៀងធំ) ធ្លាក់ចុះមកក្នុងរដូវប្រាំង សាកសពសត្វផ្សេងៗ តាំងពីមូត្រ លាមក កំណាត់ស្បែក ឆ្អឹង សរសៃ ទឹកមាត់ ទឹកសំបោរ និងឈាមជាដើម ដែលទឹកនាំទៅធ្លាក់ចុះត្រង់ក្រអេងទឹកស្មោកគ្រោក ជិតទ្វារផ្ទះ របស់អ្នកចណ្ឌាល ផ្សំចូលនឹងភក់ ២-៣ ថ្ងៃ ក៏មានពួកដង្កូវកើតឡើង; ក្រអេងទឹកនោះក្តៅឡើងហើយ ដោយភាពក្តៅនៃកម្លាំងកំដៅថ្ងៃ អណ្តែតប៉ោងឡើងខាងលើពព្រយៗ ជារបស់មានពណ៌ខៀវល្អិត ជាវត្ថុគួររង្កៀស ដោយក្លិនស្អុយយ៉ាងក្រៃលែង; ដល់នូវសភាពជារូបមិនគួរចូលទៅជិត មិនគួរឃើញ; នឹងចាំបាច់ពោលទៅថ្វី ដល់វត្ថុគួរហិត គួរលិទ្ធសោត យ៉ាងណាមិញ; ទឹក និងបាយជាដើម មានប្រការផ្សេងៗ ក៏ដូច្នោះដែរ ដែលអង្រែ គឺធ្មេញបុកល្អិតហើយ ដែលដៃ គឺអណ្តាតផាត់កៀសទៅមកហើយ ច្របូកច្របល់ដោយទឹកមាត់ ប្រាសចាកសេចក្តីដល់ព្រមដោយពណ៌ក្លិន និងរសជាដើមភ្លាមៗ ដូចកំអួតសុនខក្នុងស្នូក រួមគ្នាច្របូកច្របល់ដោយទឹកប្រមាត់ និងស្លេស្ម ក្តៅដោយអណ្តាតភ្លើង និងភាពក្តៅក្នុងផ្ទៃ ដង្កូវត្រកូលធំតូចអណ្តែតប៉ោងឡើងខាងលើ ដល់ភាពជាគំនរសម្រាម មានក្លិនស្អុយគួរខ្ពើមយ៉ាងក្រៃលែង ហើយតាំងនៅ; សូម្បីព្រោះស្តាប់រឿងពោះណាសោត សេចក្តីមិនពេញចិត្ត ក្នុងទឹក និងបាយជាដើម ក៏កើតឡើងបាន; នឹងពោលថ្វី ដល់សេចក្តីមិនពេញចិត្ត ក្នុងទឹក និងបាយជាដើម ព្រោះការក្រឡេកមើលដោយបញ្ញាចក្ខុសោត ។

មួយទៀត ក្នុងពោះនោះ ដែលមានរបស់ស៊ីមានទឹក និងបាយជាដើមធ្លាក់ចូលទៅហើយ រមែងដល់នូវការចែកជាចំណែកៗ ៥ ចំណែក គឺសត្វ (ពួន) ទាំង-

ឡាយ រមែងទំពាស៊ីមួយចំណែក; ភ្លើងធាតុរមែងដុតបំផ្លាញមួយចំណែក; មួយចំណែក ក៏ជាមូត្រ, មួយចំណែក ក៏ជាលាមក; និងមួយចំណែកដល់នូវសេភាព ជាអាហារទៅបំពេញកោដ្ឋាសៈមានឈាម និងសាច់ជាដើមឱ្យចម្រើន។ **ពោលដោយបរិច្ឆេទ** កំណត់ដោយក្រពេញពោះ និងចំណែកឧទរិយៈ (គឺអាហារថ្មី) ។ នេះជាសភាគបរិច្ឆេទរបស់អាហារថ្មីនោះ; ចំណែកវិសភាគបរិច្ឆេទ ដូចនឹងសក់នោះឯង ៕

## ១៩. ករីសំ = អាហារចាស់

ពាក្យថា **ករីសំ** គឺឧច្ចារៈ; ឧច្ចារៈនោះ **ពោលដោយពណ៌** មានពណ៌ស្រដៀងអាហារដែលលេបចូលទៅនោះឯងដោយច្រើន។ **ពោលដោយសណ្ឋាន** មានសណ្ឋានតាមដែលតាំងនៅ។ **ពោលដោយទិស** កើតក្នុងទិសខាងក្រោម។ **ពោលដោយឱកាស** តាំងនៅត្រង់ក្រពះឧច្ចារៈ (បក្កាសយេ ទីផ្ទុកអាហារឆ្អិន) ។ ឈ្មោះថា ក្រពះឧច្ចារៈ ដូចជាបំពង់ឫស្សីខ្ពស់ប្រមាណ ៨ ធ្នាប់ នៅផ្នែកខាងចុងរបស់ពោះវៀនធំ ក្នុងចន្លោះផ្ចិត ផ្នែកខាងក្រោម និងឆ្អឹងជំនីខាងខ្នង; អាហារយ៉ាងណាមួយ មានទឹក និងបាយជាដើម ធ្លាក់ទៅហើយក្នុងក្រពះអាហារ (អាមាសយេ ទីផ្ទុកអាហារឆៅ) ក្តៅពុះដោយភ្លើង ក្នុងពោះ (ភ្លើងធាតុ) ឆ្អិនទៅៗ កម្ទេចឱ្យល្អិតដូចបុកដោយត្បាល់បុកហើយឃ្លាតទៅៗ តាមប្រហោងនៃពោះវៀនធំ ធ្លាក់ទៅខ្ទប់គ្នាដូចដីពណ៌លឿង ដែលគេញាត់ដាក់ទុកក្នុងបំពង់ឫស្សី ប្រៀបដូចភ្លៀងធ្លាក់ចុះខាងលើៗ ហូរចុះមកធ្វើឱ្យភាគផ្ទៃខាងទាបឃាំងនៅពេញដូច្នោះ ។

**ពោលដោយបរិច្ឆេទ** កំណត់ដោយក្រពេញក្រពះឧច្ចារៈ និងដោយចំណែក

ដែលជាឧច្ចារៈ ។ នេះជាសភាគបរិច្ឆេទរបស់ករីសៈ (អាហារចាស់) នោះ; ចំណែក វិសភាគបរិច្ឆេទ ដូចនឹងសក់នោះដែរ ៕

## ២០. មត្ថលុង្គំ = ខួរក្បាល[១០៨]

ពាក្យថា **មត្ថលុង្គំ** គឺកញ្ចុំខួរដែលតាំងនៅខាងក្នុងលលាដ៍ក្បាល ។ ខួរក្បាលនោះ **ពោលដោយពណ៌** មានពណ៌សដូចផ្កាផ្សិត, សូម្បីនឹងពោលថា មានពណ៌ដូចទឹកដោះដែលនៅមិនជូរ ជាទឹកដោះស្រស់ក៏គួរ។ **ពោលដោយសណ្ឋាន** មាន សណ្ឋានតាមដែលវាតាំងនៅ ។ **ពោលដោយទិស** កើតក្នុងទិសខាងលើ។ **ពោលដោយឱកាស** អាស្រ័យនៅតាមជួរថ្មេរ ៤ កន្លែង តាំងនៅរួមគ្នាក្នុងលលាដ៍ក្បាល ដូចដុំម្សៅ ៤ ដុំ ដែលគេតាំងទុករួមគ្នា។ **ពោលដោយបរិច្ឆេទ** កំណត់ដោយផ្ទៃខាងក្រោមលលាដ៍ក្បាល និងដោយចំណែកដែលជាខួរក្នុងក្បាល។ នេះជាសភាគបរិច្ឆេទរបស់មត្ថលុង្គំនោះ, ចំណែកវិសភាគបរិច្ឆេទ ដូចនឹងសក់នោះដែរ ៕

## ២១. បិត្តំ = ទឹកប្រមាត់

ពាក្យថា **បិត្តំ** បានដល់ ទឹកប្រមាត់ ២ យ៉ាង គឺ ទឹកប្រមាត់ដែលនៅក្នុងថង់ (ពទ្ធបិត្តំ) និងទឹកប្រមាត់មិននៅក្នុងថង់ (អពទ្ធបិត្តំ)។ ក្នុងទឹកប្រមាត់ទាំង ២ នោះ ទឹកប្រមាត់ដែលនៅក្នុងថង់ **ពោលដោយពណ៌** មានពណ៌ ដូចប្រេងស្រគំខាប់ៗ, ទឹកប្រមាត់ដែលមិននៅក្នុងថង់ មានពណ៌ដូចផ្កាពិកុលស្ងួត។ **ពោលដោយ**

---

[១០៨] បាលីពោលរួមទុកក្នុងអដ្ឋិមិញ្ជំ (ខួរក្នុងឆ្អឹង) ។

**សណ្ឋាន** ទឹកប្រមាត់សូម្បីទាំង ២ មានសណ្ឋានតាមដែលវាតាំងនៅ។ **ពោលដោយទិស** ទឹកប្រមាត់ក្នុងថង់កើតក្នុងទិសខាងលើ, ទឹកប្រមាត់ក្រៅនេះ កើតក្នុងទិសទាំង ២។ **ពោលដោយឱកាស** វៀរសក់ ក្រចក រោម ធ្មេញ និងស្បែកដែលស្ងួត ហើយតាំងនៅផ្សព្វផ្សាយពាសពេញក្នុងសរីរៈដែលនៅសល់ ដូចការបន្តក់ប្រេងក្នុងទឹកផ្សាយទៅពាសពេញដូច្នោះ, កាលទឹកប្រមាត់នេះកម្រើក ភ្នែករបស់សត្វទាំងឡាយលឿង រមែងចេញទឹក, រាងកាយរមែងញ័រ រមែងរមាស់។ ទឹកប្រមាត់ដែលឃាំងនៅក្នុងថង់ទឹកប្រមាត់ គឺតាំងនៅក្នុងស្រោម (ថង់) របស់ទឹកប្រមាត់ ដូចស្រោមននោងធំ; វាជាប់នៅត្រង់សាច់ថ្លើមក្នុងចន្លោះបេះដូង និងសួត, **កាលទឹកប្រមាត់នេះកម្រើក សត្វទាំងឡាយរមែងជាអ្នកឆ្កួត, មានចិត្តវិបល្លាស, លះចោលហិរិ និងឱត្តប្បៈ, រមែងធ្វើវត្ថុដែលមិនគួរធ្វើ, រមែងពោលវត្ថុ ដែលមិនគួរពោល និងរមែងគិតក្នុងវត្ថុដែលមិនគួរគិត ។ ពោលដោយបរិច្ឆេទ** កំណត់ដោយចំណែកជាទឹកប្រមាត់ ។ នេះជាសភាគបរិច្ឆេទរបស់ទឹកប្រមាត់នោះ;ចំណែកវិសភាគបរិច្ឆេទ ដូចនឹងសក់នោះដែរ ៕

## ២២. សេម្ហំ = ស្លេស្ម

ពាក្យថា **សេម្ហំ** គឺស្លេស្ម មានប្រមាណពេញមួយក្បង់ នៅខាងក្នុងរាងកាយ។ ស្លេស្មនោះ **ពោលដោយពណ៌** មានពណ៌ស ដូចពណ៌ទឹកត្រសក់។ **ពោលដោយសណ្ឋាន** មានសណ្ឋានតាមដែលវាតាំងនៅ ។ **ពោលដោយទិស** កើតក្នុង

ទិសខាងលើ ។ **ពោលដោយឱកាស** តាំងនៅត្រង់ក្រពេញពោះក្នុងវេលា ដែលលេបទឹក និងបាយជាដើម។ ក៏ទឹក និងបាយធ្លាក់ចុះទៅ វា (ស្លេស្ម) ក៏នឹងញែកចេញពីគ្នា ហើយហ៊ុមបិទតាមដើម ប្រៀបដូចចកក្នុងទឹក កាលបើឈើ ឬក្បឿងធ្លាក់ចុះទៅ វាក៏ញែកចេញពីគ្នា ហើយត្រឡប់ចូលដូចដើមវិញ; មួយទៀត កាលស្លេស្មមានតិចទៅ ពោះនឹងបញ្ចេញក្លិនស្អុយរបស់សាកសពសត្វ ដែលគួររង្កៀសយ៉ាងក្រៃលែង ដូចក្បាលខ្មោច ឬជម្ងឺដំបៅស្អុយដែលបែកដូច្នោះ, និងព្រោះក្លិនដែលផ្សាយឡើងពីពោះនោះ ខ្យល់គ្រើក្តី មាត់ក្តី រមែងមានក្លិនគួរខ្ពើម ដូចសាកសពសត្វដែលស្អុយ ទាំងអ្នកនោះ រមែងត្រូវគេបណ្តេញថា ចេញទៅ ខ្លួនឯងមានក្លិនគួរខ្ពើម។ មួយវិញទៀត ស្លេស្មនោះ កាលមានច្រើនហើយ វាក៏នឹងបិទក្លិនសត្វទុកខាងក្នុងអវយវៈពោះនោះឯង ដូចផែនក្តារដែលបិទវច្ចកុដិដូច្នោះ។ **ពោលដោយបរិច្ឆេទ** កំណត់ដោយចំណែកដែលជាស្លេស្ម។ នេះជាសភាគបរិច្ឆេទរបស់ស្លេស្មនោះ, ចំណែកវិសភាគបរិច្ឆេទ ដូចនឹងសក់នោះឯង ៕

## ២៣. បុព្វោ = ខ្ទុះ

ពាក្យថា **បុព្វោ ពោលដោយពណ៌** មានពណ៌ដូចស្លឹកឈើលឿង។ តែក្នុងរាងកាយរបស់អ្នកស្លាប់ មានពណ៌ដូចទឹកបាយខាប់ដែលផ្អូម។ **ពោលដោយសណ្ឋាន** មានសណ្ឋានតាមដែលវាតាំងនៅ ។ **ពោលដោយទិស** កើតក្នុងទិសទាំង ២ ។ **ពោលដោយឱកាស** ឈ្មោះថា ឱកាសរបស់បុព្វោមិនបានឃាំងនៅជា

និច្ចទេ, ប៉ុន្តែថា ចំណែកនៃរាងកាយណា ត្រូវប៉ះទង្គិចដោយកំណាត់ឈើ មុតបន្លាស្រួច ឬគ្រឿងប្រហារ និងអណ្តាតភ្លើងជាដើម លោហិតក៏កកឡើង, ឬពកមានបូសជាដើម កើតឡើងក្នុងទីណាៗ, **បុព្វោនោះ** ក៏គប្បីបង្កខ្លួនឡើងក្នុងទីនោះៗ ។ **ពោលដោយបរិច្ឆេទ** កំណត់ដោយចំណែកជាបុព្វោ ។ នេះជាសភាគបរិច្ឆេទរបស់បុព្វោនោះ; ចំណែកវិសភាគបរិច្ឆេទ ដូចនឹងសក់នោះឯង ៕

## ២៤. លោហិតំ = ឈាម

ពាក្យថា **លោហិតំ** បានដល់ លោហិតពីរយ៉ាង គឺសន្និចិតលោហិត (ឈាមដែលកក) និងសំសរណលោហិត (ឈាមដែលរាវ); ក្នុងពីរយ៉ាងនោះ សន្និចិត-លោហិត **ពោលដោយពណ៌** មានពណ៌ដូចទឹកលក្ខខាប់ ដែលដល់ (ចាស់) ភ្លើង, សំសរណលោហិត មានពណ៌ដូចទឹកលក្ខថ្លា; **ពោលដោយសណ្ឋាន** សូម្បីទាំងពីរមានសណ្ឋានតាមដែលវាតាំងនៅ ។ **ពោលដោយទិស** សន្និចិតលោហិតកើតក្នុងទិសខាងលើ, លោហិតក្រៅនេះ កើតក្នុងទិសទាំង ២; **ពោលដោយឱកាស** សំសរណលោហិត តាំងនៅផ្សាយទៅកាន់ឧបាទិន្នកសរីរៈទាំងអស់ តាមសរសៃលោហិត សក់ រោម ក្រចក ធ្មេញ និងស្បែកដែលស្ងួតរឹង ។

សន្និចិតលោហិត មានប្រមាណមួយបាត្រ (ខ្នាតតូច) តាំងនៅពេញ ចំណែកខាងក្រោមដែលជាទីតាំងរបស់ថ្លើមសន្សើមៗ ហូរទៅលើតម្រងឈាម បេះដូង ថ្លើម សួត ធ្វើឱ្យតម្រងឈាម បេះដូង ថ្លើម និងសួតសើមជោកជានិច្ច ព្រោះថា កាលបើលោហិតមិនធ្វើឱ្យតម្រងឈាម និងបេះដូងជាដើមសើមជោកទេ សត្វទាំងឡាយ

រមែងក្តៅក្រហាយ ។ **ពោលដោយបរិច្ឆេទ** កំណត់ដោយចំណែកដែលជាលោហិត ។ នេះជាសភាគបរិច្ឆេទរបស់លោហិតនោះ, ចំណែកវិសភាគបរិច្ឆេទ ដូចនឹងសក់នោះឯង ៕

## ២៥. **សេទោ** = ញើស

ពាក្យថា **សេទោ** គឺអាបោធាតុដែលហូរចេញតាមរន្ធរោមជាដើម ។ ញើសនោះ **ពោលដោយពណ៌** មានពណ៌ដូចទឹកប្រេងល្ងថ្លា ។ **ពោលដោយសណ្ឋាន** មានសណ្ឋានតាមដែលវាតាំងនៅ ។ **ពោលដោយទិស** កើតក្នុងទិសទាំង ២; **ពោលដោយឱកាស** ឈ្មោះថា ឱកាសរបស់ញើស មិនបានមានជានិច្ចដូចលោហិតទេ, តែកាលណា រាងកាយរមែងក្តៅដោយការក្តៅរបស់ភ្លើង របស់កំដៅថ្ងៃ និងការផ្លាស់ប្តូររបស់ឧតុជាដើម កាលនោះ ញើសនឹងហូរចេញចាករន្ធសក់ និងរោមទាំងពួង ដូចកណ្តាប់ឈូកគ្រាន់តែដក់ឡើងផុតពីទឹកដែលមានឫសពន្លកដាច់មិនស្មើគ្នា ទឹកក៏នឹងហូរចេញទៅដូច្នោះ, ព្រោះហេតុនោះ សណ្ឋានសេទោនោះ ក៏គប្បីជ្រាបដោយអំណាចនៃចន្លោះរន្ធសក់ និងរោមនោះឯង ។ ព្រោះព្រះយោគីអ្នកកំណត់សេទោជាអារម្មណ៍ គប្បីមនសិការសេទោ តាមដែលវាដក់នៅពេញក្នុងចន្លោះរន្ធសក់ និងរោមនោះឯង ។

**ពោលដោយបរិច្ឆេទ** កំណត់ដោយចំណែកដែលជាសេទោ ។ នេះជាសភាគបរិច្ឆេទរបស់សេទោនោះ; ចំណែកវិសភាគបរិច្ឆេទ ដូចនឹងសក់នោះឯង ៕

## ២៦. មេទោ = ខ្លាញ់ខាប់

ពាក្យថា **មេទោ** គឺខ្លាញ់ខាប់ ។ ខ្លាញ់ខាប់នោះ **ពោលដោយពណ៌** មានពណ៌ដូចល្មៀតដែលពុះចេញហើយ ។ **ពោលដោយសណ្ឋាន** សម្រាប់បុគ្គលអ្នកមានរាងកាយធាត់ មានសណ្ឋានដូចសំពត់ទុកូលចាស់ មានពណ៌ល្មៀតតាំងនៅក្នុងចន្លោះស្បែក និងសាច់ ។ ចំណែកបុគ្គលមានរាងកាយស្គម មានសណ្ឋានដូចសំពត់បង្សុកូលចាស់មានពណ៌ល្មៀតដែលកាត់ជា ២-៣ ចំណិត អាស្រ័យទីកពួកនេះ គឺសាច់ស្មង សាច់ភ្លៅ សាច់ខ្នងជាប់នឹងឆ្អឹងខ្នង និងសាច់ពោះបន្ទិច ។ **ពោលដោយទិស** កើតក្នុងទិសទាំងពីរ; **ពោលដោយឱកាស** សម្រាប់មនុស្សធាត់វាផ្សាយទៅកាន់សរីរៈទាំងអស់ សម្រាប់មនុស្សស្គមអាស្រ័យសាច់ស្មងជាដើម ហើយតាំងនៅ, ខ្លាញ់ខាប់នេះ សូម្បីដល់ការរាប់ថា ជាប្រេងបាន តែព្រោះជារបស់គួររង្កៀសយ៉ាងក្រៃលែង ទើបជនទាំងឡាយមិនបានកាន់យកដើម្បីប្រើលាបសរីរៈ និងប្រើជាប្រេងបន្តក់ច្រមុះជាដើម ។ **ពោលដោយបរិច្ឆេទ** ខាងក្រោម កំណត់ដោយសាច់, ខាងលើ កំណត់ដោយស្បែក, ខាងជុំវិញ កំណត់ដោយចំណែកជាខ្លាញ់ខាប់ ។ នេះជាសភាគបរិច្ឆេទរបស់ខ្លាញ់ខាប់នោះ, ចំណែកវិសភាគបរិច្ឆេទ ដូចនឹងសក់នោះដែរ ៕

## ២៧. អស្សុ = ទឹកភ្នែក

ពាក្យថា **អស្សុ** គឺអាបោធាតុដែលហូរចេញពីភ្នែកនោះ ។ ទឹកភ្នែកនោះ **ពោលដោយពណ៌** មានពណ៌ដូចប្រេងល្ងថ្លា ។ **ពោលដោយសណ្ឋាន** មានសណ្ឋានតាមដែលវាតាំងនៅ ។ **ពោលដោយទិស** កើតក្នុងទិសខាងលើ; **ពោលដោយឱកាស** តាំងនៅត្រង់រន្ធភ្នែក; តែថាទឹកភ្នែកនោះ មិនបានដក់នៅក្នុងភ្នែកគ្រប់កាល ដូចទឹកប្រមាត់ក្នុងថង់ប្រមាត់ទេ; ក៏កាលណា សត្វទាំងឡាយកើតសោមនស្សសើចខ្លាំង, កើតទោមនស្សយំស្រែកខ្សឹកខ្សួល, ស៊ីអាហារដែលជាវិសភាគមានសភាពយ៉ាងនោះ; (សម្គាល់សេចក្តីថា ស៊ីអាហារប្រភេទដែលធ្វើឱ្យទឹកភ្នែកហូរបាន) និងកាលណា កែវភ្នែករបស់សត្វទាំងឡាយខ្ទប់នឹងផ្សែង និងល្អងធូលីជាដើម វា (ទឹកភ្នែក) មកតាំងនៅត្រង់រន្ធភ្នែក ឬហូរចេញ ព្រោះការកើតឡើងដោយសោមនស្ស, ទោមនស្ស, អាហារដែលជាសវិភាគ និងឧតុទាំងនោះ ។

ក៏ព្រះយោគីអ្នកកំណត់ទឹកភ្នែកជាអារម្មណ៍ គប្បីកំណត់ដោយអំណាចនៃទឹកភ្នែកដែលតាំងនៅពេញរន្ធភ្នែកនោះឯង ។ **ពោលដោយបរិច្ឆេទ** កំណត់ដោយចំណែកដែលជាទឹកភ្នែក; នេះជាសភាគបរិច្ឆេទរបស់ទឹកភ្នែកនោះ, ចំណែកវិសភាគបរិច្ឆេទ ដូចនឹងសក់នោះឯង ៕

## ២៨. ទសា = ខ្លាញ់រាវ

ពាក្យថា **ទសា** គឺខ្លាញ់រាវ ។ ខ្លាញ់រាវនោះ **ពោលដោយពណ៌** មានពណ៌ដូចប្រេងដូង សូម្បីនឹងពោលថា "មានពណ៌ដូចប្រេងដែលដាក់ចុះលើបាយក្តាំង" ក៏គួរ ។ **ពោលដោយសណ្ឋាន** មានសណ្ឋានផ្សាយទៅដូចតំណក់ប្រេង ដែលអណ្តែតពេញនៅលើទឹកថ្លា ក្នុងវេលាដែលធ្វើការងូត (លាងជម្រះ) ។ **ពោលដោយទិស** កើតក្នុងទិសទាំងពីរ; **ពោលដោយឱកាស** ដោយច្រើនតាំងនៅត្រង់បាតដៃ ខ្នងដៃ បាតជើង ខ្នងជើង ចុងច្រមុះ ថ្ងាស និងចង្កូយស្មា, ក៏ប៉ុន្តែថា ខ្លាញ់រាវនោះ មិនបានរលាយនៅក្នុងទីនោះគ្រប់កាលទេ; តែកាលណា ចំណែករបស់រាងកាយនោះ កើតសេចក្តីក្តៅឡើងដោយភ្លើង គឺកំដៅថ្ងៃ ឧតុវិសភាគ និងធាតុវិសភាគ, កាលនោះ ទើបផ្សាយទៅខាងណោះ ខាងណេះ ដូចការផ្សាយទៅរបស់តំណក់ទឹក ប្រេងលើទឹកថ្លា ក្នុងវេលាធ្វើការងូតនោះដូច្នោះ ។ **ពោលដោយបរិច្ឆេទ** កំណត់ដោយចំណែកដែលជាខ្លាញ់រាវ ។ នេះជាសភាគបរិច្ឆេទរបស់ខ្លាញ់រាវនោះ; ចំណែកវិសភាគបរិច្ឆេទ ដូចនឹងសក់នោះឯង ៕

## ២៩. ខេឡោ = ទឹកមាត់

ពាក្យថា **ខេឡោ** គឺអាបោធាតុដែលផ្សំឡើង ជាពងខាងក្នុងមាត់ ។ **ខេ-ឡោ**នោះ **ពោលដោយពណ៌** មានពណ៌ដូចពងទឹក ។ **ពោលដោយសណ្ឋាន**

មានសណ្ឋានតាមដែលវាតាំងនៅ; សូម្បីនឹងពោលថា "មានសណ្ឋានដូចពពុះទឹក" ក៏គួរ ។ **ពោលដោយទិស** កើតក្នុងទិសខាងលើ, **ពោលដោយឱកាស** ចេញពីក្រពេញថ្ពាល់ទាំង ២ មកតាំងនៅត្រង់អណ្ដាត; តែមិនបានដក់នៅទីនោះគ្រប់កាលទេ; តែកាលណា សត្វទាំងឡាយឃើញ ឬនឹកដល់អាហារប្រាកដដូច្នោះ (សំដៅដល់អាហារដែលធ្វើឱ្យទឹកមាត់ចេញបាន); ឬថា ដាក់វត្ថុអ្វី១ មានរសក្ដៅ ល្វីង ហិល ប្រៃ និងជូរ ចុះទៅក្នុងមាត់, ឬកាលណា បេះដូងរបស់សត្វទាំងឡាយខ្សោយចុះ, ឬថា កើតសេចក្ដីស្រេកឃ្លាន ក្នុងអ្វី១ ឡើង, កាលនោះ ទឹកមាត់កើតឡើងហើយក៏ជ្រាបចេញពីក្រពេញថ្ពាល់ទាំង ២ ខាង មកដក់នៅត្រង់អណ្ដាត ។ មួយទៀតទឹកមាត់នោះ ត្រង់ចុងអណ្ដាតមានតិច, ត្រង់គល់អណ្ដាតមានច្រើន; មិនដល់ការអស់ទៅ ទាំងអាចញ៉ាំងអ្វី១ មានអំបុក ឬអង្ករ ឬថារបស់គួរទំពាស៊ីដែលដាក់ចូលទៅក្នុងមាត់ ឱ្យសើម ដូចអណ្ដូងទឹកដែលគេជីកទុកជិតឆ្នេរខ្សាច់ដូច្នោះ ។ **ពោលដោយបរិច្ឆេទ** កំណត់ដោយចំណែកដែលជាទឹកមាត់ ។ នេះជាសភាគបរិច្ឆេទ, ចំណែកវិសភាគបរិច្ឆេទ ដូចនឹងសក់នោះឯង ៕

## ៣០. សិង្ឃាណិកា = ទឹកសំបោរ

ពាក្យថា **សិង្ឃាណិកា** បានដល់ ទឹកមិនស្អាត ដែលហូរចេញពីខួរក្នុងឆ្អឹង; ទឹកសំបោរនោះ **ពោលដោយពណ៌** មានពណ៌ដូចក្រពេញក្នុងកំពឹងត្នោតខ្ចី; **ពោល**

**ដោយសណ្ឋាន** មានសណ្ឋានតាមដែលវាតាំងនៅ ។ **ពោលដោយទិស** កើតក្នុងទិសខាងលើ ។ **ពោលដោយពណ៌** តាំងនៅពេញប្រហោងច្រមុះ, តែទឹកសំបោរនោះ មិនបានដក់នៅក្នុងទីនោះគ្រប់កាលទេ, ក៏ឯកាលណា សត្វទាំងឡាយស្រែកយំ ឬជាអ្នកមានធាតុកម្រើកឡើងដោយអាហារដែលទាស់ ឬរដូវផ្លាស់ប្តូរ, កាលនោះខួរដែលដល់សេចក្តីជាស្លេស្មហើយ ទើបឃ្លាតធ្លាក់ចុះតាមប្រហោងពិតានខាងលើមកតាំងនៅពេញក្តៅងច្រមុះ ឬរមែងហូរចេញទៅប្រៀបដូចអ្នកខ្ចប់ទឹកដោះជូរដោយស្លឹកឈូកហើយយកបន្លាចាក់ខាងក្រោម, ពេលនោះទឹករាវរបស់ទឹកដោះជូរក៏ហូរចេញតាមប្រហោងនោះ ហើយគប្បីធ្លាក់ទៅខាងក្រៅដូច្នោះ ។

ក៏ព្រះយោគីកំណត់ទឹកសំបោរជាអារម្មណ៍ គប្បីកំណត់ដោយអំណាចនៃទឹកសំបោរដែលតាំងនៅពេញច្រមុះនោះឯង ។ **ពោលដោយបរិច្ឆេទ** កំណត់ដោយចំណែកដែលជាទឹកសំបោរ; នេះជាសភាគបរិច្ឆេទរបស់សំបោរ, ចំណែកវិសភាគ-បរិច្ឆេទ ដូចនឹងសក់នុ៎ះឯង ៕

## ៣១. លសិកា = ទឹករំអិល

ពាក្យថា **លសិកា** បានដល់ ទឹករំអិលជាប្រេង ដែលមានក្លិនស្អុយខាងក្នុងសន្លាក់របស់រាងកាយ ។ ទឹករំអិលនោះ **ពោលដោយពណ៌** មានពណ៌ដូចជ័រផ្កាកណិការ ។ **ពោលដោយសណ្ឋាន** មានសណ្ឋានតាមដែលវាតាំងនៅ ។ **ពោល**

**ដោយទិស** កើតក្នុងទិសទាំងពីរ; **ពោលដោយឱកាស** តាំងនៅត្រង់សន្លាក់ ១០៨ កន្លែងដែលធ្វើកិច្ច គឺការបន្តក់លាបថ្នាំងតឆ្អឹងទាំងឡាយឱ្យសម្រេច; ក៏រំអិលសន្លាក់នោះ របស់អ្នកណាមានតិចទៅ, កាលអ្នកនោះក្រោកឡើង អង្គុយចុះ ឈានទៅខាងមុខ ថយមកខាងក្រោយ បត់ចូល លាចេញ ឆ្អឹងទាំងឡាយ នឹងលាន់ព្នកដះកដះ, ដូចមនុស្សដែលត្រាច់ទៅផ្ទាត់ម្រាមដៃ, កាលដើរផ្លូវឆ្ងាយសូម្បីប្រមាណ ១ យោជន៍ ឬ ២ យោជន៍ វាយោធាតុក៏កម្រើក, រាងកាយរមែងជាទុក្ខ; តែទឹក (រំអិល) របស់អ្នកណាមានច្រើន, ឆ្អឹងទាំងឡាយរមែងមិនបញ្ចេញសំឡេង ព្នកដះកដះ ក្នុងវេលាក្រោកឡើង និងអង្គុយចុះជាដើមទេ, កាលដើរផ្លូវឆ្ងាយ វាយោធាតុក៏មិនកម្រើក រាងកាយក៏មិនជាទុក្ខ ។

**ពោលដោយបរិច្ឆេទ** កំណត់ដោយចំណែកដែលជារំអិល ។ នេះជាសភាគបរិច្ឆេទរបស់រំអិលនោះ, ចំណែកវិសភាគបរិច្ឆេទ ដូចនឹងសក់នុ៎ះឯង ៕

## ៣២. មុត្តំ = ទឹកមូត្រ

ពាក្យថា **មុត្តំ** បានដល់ ទឹកមូត្រ, **ពោលដោយពណ៌** មានពណ៌ដូចទឹកក្បុងសណ្តែកសៀង* ។ **ពោលដោយសណ្ឋាន** មានសណ្ឋានដូចទឹកនៅក្នុងឆ្នាំងទឹកដែលគេបិទមាត់ ។ **ពោលដោយទិស** កើតក្នុងទិសខាងក្រោម ។ **ពោលដោយ**

---

* តាមពុទ្ធសាសនា និយមហៅថា សណ្តែករាជមាស ។

**ឱកាស** តាំងនៅខាងក្នុងតម្រងបស្សាវៈ; ប្លោកនៃតម្រងបស្សាវៈ លោកហៅថា តម្រងនោម ។ ក្នុងតម្រងបស្សាវៈនោះសោត ទឹកនោមរមែងហូរចេញពីសរីរៈ តែផ្លូវដែលចូលទៅរបស់ទឹកនោមមិនបានប្រាកដ, ចំណែកផ្លូវដែលចេញទៅប្រាកដ, ប្រៀបដូចទឹកជ្រាំ ដែលជ្រៀមចូលទៅក្នុងឆ្នាំងទឹករំអិល (ឆ្នាំងសាច់គ្រោតគ្រាត) ដែលបិទមាត់ ដែលគេចោលទុកក្នុងក្រអេងទឹកជ្រាំ ផ្លូវចូលរបស់វាមិនប្រាកដដូច្នោះទេ ។ មួយទៀត ក្នុងពេលណាតម្រងបស្សាវៈដែលពេញហើយដោយទឹកមូត្រ សេចក្តីខ្វល់ខ្វាយរបស់សត្វទាំងឡាយតែងកើតថា "យើងនឹងបន្ទោបង់បស្សាវៈ" ពេលនោះ មានជាធម្មតា ។

**ពោលដោយបរិច្ឆេទ** កំណត់ដោយខាងក្នុងនៃតម្រង និងដោយវត្ថុដែលជាទឹកមូត្រ ។ នេះជាសភាគបរិច្ឆេទរបស់ទឹកមូត្រ, ចំណែកវិសភាគបរិច្ឆេទ ដូចនឹងសក់នោះឯង ។ ក៏ឯព្រះយោគាវចរ គ្រាកំណត់កោដ្ឋាសៈទាំងឡាយមានសក់ជាដើម **ដោយពណ៌ សណ្ឋាន ទិស ឱកាស និងបរិច្ឆេទ** យ៉ាងនេះហើយ កាលនឹងមនសិការដោយអំណាចនៃការឈានកន្លងបញ្ញត្តិ ដោយដាក់ចិត្តថា **បដិកូល បដិកូល ៥ យ៉ាង** ដោយពណ៌ សណ្ឋាន ក្លិន អាសយៈ និងឱកាស តាមន័យ**អនុបុព្វតោ** = ដោយលំដាប់, **នាតិសីឃតោ** = ដោយមិនរហ័សពេក, **នាតិសណិកតោ** = ដោយមិនយឺតពេកជាដើម, ដោយពិចារណាកាយនេះថា "**អត្ថិ ឥមស្មឹ កាយេ កេសា** = ក្នុងកាយនេះមានសក់" ជាដើម ធម៌ទាំងពួងនោះ (កោដ្ឋាសៈទាំងអស់) ក៏រមែង

ប្រាកដហាក់ដូចជាមិនមុន មិនក្រោយគ្នា ប្រៀបដូចបុគ្គលមានភ្នែកល្អក្រឡេកមើលកម្រងផ្កាឈើ ៣២ ពណ៌ ដែលគេដោតក្រងទុកដោយអំបោះមួយសរសៃ ផ្កាឈើទាំងឡាយ រមែងប្រាកដដូចជាមិនមុន មិនក្រោយដូច្នោះ ។ ដោយហេតុនោះ ទើបខ្ញុំពោលទុកក្នុងកថានៃមនសិការកោសល្យថា **“ក៏កាលព្រះយោគាវចរជាអាទិកម្មិកៈ មនសិការថា ‘កេសា’ មនសិការទៅដរាប ដល់កំណត់កោដ្ឋាសៈចុងបំផុតថា ‘មុត្តំ”** នេះនោះឯង ។ ក៏បើថា ចិត្តនឹងពិចារណាមនសិការទៅខាងក្រៅខ្លះសោត, កាលកោដ្ឋាសៈទាំងពួងប្រាកដហើយ ក្នុងលំដាប់នោះ មនុស្សនិងសត្វទាំងឡាយ អ្នកដើរផ្លូវទៅមក ក៏នឹងលះអាការថា ជាសត្វ ប្រាកដដល់ព្រះយោគាវចរនោះ ដោយជាគំនរនៃកោដ្ឋាសៈប៉ុណ្ណោះ; ឯអាហារមានទឹក និងបាយជាដើមដែលសត្វទាំងនោះ បរិភោគលេបចូលទៅ ក៏រមែងប្រាកដដូចជារបស់ដែលគេដាក់ចូលទៅក្នុងគំនរនៃកោដ្ឋាសៈ ។ លំដាប់នោះ កាលព្រះយោគាវចរមនសិការរឿយៗ ថា **“បដិកូល បដិកូល”** ដោយមនសិការកោសល្យ **តាមអនុបុព្វ-មុញ្ចនតោ** (កាលបណ្ដោយតាមលំដាប់) ជាដើម អប្បនាក៏រមែងកើតឡើងដោយលំដាប់ ។ ក្នុងការកើតឡើងនៃអប្បនានោះ កាលប្រាកដដោយអំណាចនៃពណ៌ សណ្ឋាន ទិស ឱកាស និងបរិច្ឆេទ **ជាឧគ្គហនិមិត្ត** កាលប្រាកដនៃកោដ្ឋាសៈដោយអំណាចនៃបដិកូល តាមអាការទាំងពួង **ជាបដិភាគនិមិត្ត** ។ កាលព្រះយោ-គាវចរទទួលអារម្មណ៍បដិភាគនិមិត្តនោះមកមនសិការត្រិះរិះរឿយៗ នាមខន្ធ ៤ ក៏

នឹងមានបដិកូលជាអារម្មណ៍; អប្បនាក៏នឹងតាំងនៅដោយអំណាចនៃបឋមជ្ឈាន ។ ក្នុងបុព្វភាគចិត្ត មានបរិកម្ម និងឧបចារប្រព្រឹត្តទៅជាមួយវិតក្កៈ វិចារៈ មានបីតិ សហគតៈដោយសោមនស្ស មានបដិកូល ជានិមិត្តារម្មណ៍, សូម្បីអប្បនា ក៏មាន វិតក្កៈ វិចារៈ បីតិ សហគតៈដោយសោមនស្សនោះឯង ។ ប៉ុន្តែថា ដោយលំដាប់នៃ ភូមិ អប្បនានោះ ជាមហគ្គតៈ ជារូបាវចរ ។ ក៏សោមនស្ស រមែងកើតឡើង ព្រោះ ភាពជាអ្នកមានប្រក្រតីឃើញអានិសង្សក្នុងអារម្មណ៍សូម្បីជាបដិកូលនោះ ។ ម្យ៉ាង ទៀត សោមនស្សនោះ រមែងកើតឡើងដោយកម្លាំងនៃអារម្មណ៍តែមួយជាមួយគ្នា, ចំណែកទុតិយជ្ឈានជាដើម មិនបានកើតឡើងក្នុងអារម្មណ៍បដិកូលនោះឡើយ ។ **សួរថា** ព្រោះហេតុអ្វី ? ឆ្លើយថា ព្រោះភាពជាអារម្មណ៍យ៉ាងគ្រោតគ្រាត; ពិត មែន បដិកូលនេះ ជាអារម្មណ៍គ្រោតគ្រាត, ទុតិយជ្ឈានជាដើម ទើបមិនបានកើត ឡើង ។ ក្នុងអធិការនេះ ភាពជាឯកគ្គតានៃចិត្ត រមែងកើតបានដោយកម្លាំងនៃ វិតក្កៈប៉ុណ្ណោះ, មិនបានកើតឡើងដោយការកន្លងវិតក្កៈឡើយ ។ នេះជាកម្មដ្ឋាន កថា ដោយអំណាចនៃសមថៈជាមុនសិន ៕

# កម្មដ្ឋានកថា

## សម្តែងដោយអំណាចនៃសាធារណ៍

ក៏គប្បីជ្រាបកម្មដ្ឋាន ដូចពណ៌នាមកនេះ ដោយអំណាចនៃសាធារណ៍ដែលមិនប្លែកគ្នា ៖

ពិតមែន ព្រះយោគាវចរ អ្នកប្រាថ្នានឹងចម្រើនកម្មដ្ឋាននេះ ត្រូវរៀនយកកម្មដ្ឋានហើយ គប្បីស្វាធ្យាយរឿយៗ **នូវនិមិត្តនៃពណ៌ និងនិមិត្តនៃសណ្ឋាន និមិត្តនៃទិស និមិត្តនៃឱកាស និងនិមិត្តនៃបរិច្ឆេទ** របស់កោដ្ឋាសៈទាំងឡាយមានសក់ជាដើម ដោយវាចាក្នុងវេលាដែលស្វាធ្យាយនោះឯង ហើយមនសិការក្នុងកោដ្ឋាសៈមួយៗ ថា "កោដ្ឋាសៈនេះ ដូចនឹងវត្ថុនោះ" ដូច្នេះហើយធ្វើការស្វាធ្យាយ ៣ វិធី ។ **សួរថា** គប្បីធ្វើការស្វាធ្យាយយ៉ាងណា ? ឆ្លើយថា ក្នុងតចបញ្ចកៈជាមុនសិន, គប្បីធ្វើការស្វាធ្យាយកោដ្ឋាសៈទាំងនេះ រហូតដល់កន្លះខែមែនពិត គឺដោយអនុលោម រហូតដល់ ៥ ថ្ងៃ ដោយន័យដែលពោលហើយក្នុងកាលមុននោះឯង, ដោយបដិលោម រហូតដល់ ៥ ថ្ងៃ, ទាំងអនុលោម ទាំងបដិលោម រហូតដល់ ៥ ថ្ងៃទៀត ។ តពីនោះ គប្បីទៅកាន់សំណាក់របស់អាចារ្យរៀនយក**វក្កបញ្ចកៈ**ហើយក៏គប្បីធ្វើការស្វាធ្យាយ រហូតដល់អស់កន្លះខែ ដោយទំនងនោះៗ ឯង, តពីនោះ គប្បីធ្វើការស្វាធ្យាយដោយកោដ្ឋាសៈសូម្បីទាំង ១០ នោះ រួមជាមួយគ្នា រហូតដល់កន្លះខែ, គប្បីរៀនយកកោដ្ឋាសៈមួយ និងមួយ សូម្បីក្នុង**បប្ផាសបញ្ចកៈ**ជាដើម

ទៀត ហើយធ្វើការស្វាធ្យាយរហូតដល់កន្លះខែ, តពីនោះ គប្បីធ្វើការស្វាធ្យាយកោដ្ឋាសៈសូម្បីទាំង ១៥ នោះ រហូតដល់កន្លះខែ, គប្បីធ្វើការស្វាធ្យាយ **មត្ថលុង្គបញ្ចកៈ** រហូតដល់កន្លះខែ, តពីនោះ គប្បីធ្វើការស្វាធ្យាយកោដ្ឋាសៈសូម្បីទាំង ២០ នោះ រហូតដល់កន្លះខែ, គប្បីធ្វើការស្វាធ្យាយ**មេទឆក្កបញ្ចកៈ** រហូតដល់កន្លះខែ, តពីនោះ គប្បីធ្វើការស្វាធ្យាយកោដ្ឋាសៈសូម្បីទាំង ២៦ នោះរួមគ្នារហូតដល់កន្លះខែ, គប្បីធ្វើការស្វាធ្យាយ**មុត្តឆក្កៈ**រហូតដល់កន្លះខែ, តពីនោះគប្បីធ្វើការស្វាធ្យាយកោដ្ឋាសៈ ៣២ សូម្បីទាំងអស់រួមគ្នារហូតដល់កន្លះខែ, គប្បីធ្វើការស្វាធ្យាយ ៦ ខែ យ៉ាងនេះ ដោយប្រការដូច្នេះ ។

ក្នុងកម្មដ្ឋាននោះ ភិក្ខុអ្នកមានឧបនិស្ស័យដែលដល់ព្រមហើយ អ្នកមានបញ្ញារៀនយកកម្មដ្ឋាននោះឯង កោដ្ឋាសៈទាំងឡាយរមែងប្រាកដ, រមែងមិនប្រាកដដល់ភិក្ខុរូបខ្លះ, ដោយហេតុនោះ ភិក្ខុទាំងនោះ ក៏មិនគប្បីលះបង់សេចក្ដីព្យាយាម ដោយគិតថា **"កោដ្ឋាសៈទាំងឡាយ មិនប្រាកដដល់យើង"** ។ កោដ្ឋាសៈទាំង-ឡាយ មានប្រមាណប៉ុណ្ណោះបានប្រាកដ, គប្បីកាន់យកកោដ្ឋាសៈ មានប្រមាណប៉ុណ្ណោះ ធ្វើការស្វាធ្យាយទៅចុះ ។

ម្យ៉ាងទៀត អាចារ្យអ្នកប្រាប់ ក៏មិនគប្បីប្រាប់កម្មដ្ឋានយ៉ាងនេះដល់អ្នកមានបញ្ញាច្រើន និងមានបញ្ញាតិចឡើយ, គួរប្រាប់ដល់អ្នកមាន**បញ្ញាកណ្ដាល**; ព្រោះថា អាចារ្យទាំងឡាយកំណត់ដាក់បែបផែនទុក ៦ ខែ សម្រាប់អ្នកមាន**បញ្ញាកណ្ដាល** ។ ចំណែកកោដ្ឋាសៈទាំងឡាយរបស់ភិក្ខុណា សូម្បីមានប្រមាណប៉ុណ្ណោះនៅមិនបានប្រាកដ, ភិក្ខុនោះក៏គប្បីកំណត់ការស្វាធ្យាយតទៅទៀត; នឹងមិនកំណត់

តពីនោះទៅ មិនគួរទេ, គប្បីកំណត់រហូតគ្រប់ៗ ៦ ខែ ។ **កាលលោកធ្វើការស្វាធ្យាយ មិនគប្បីពិចារណាពណ៌, មិនគប្បីមនសិការលក្ខណៈ**; គប្បីធ្វើការស្វាធ្យាយ ដោយអំណាចនៃកោដ្ឋាសៈប៉ុណ្ណោះ ។ សូម្បីអាចារ្យសោត ក៏មិនគប្បីប្រាប់កំណត់ទៅថា **“លោកចូរធ្វើការស្វាធ្យាយដោយអំណាចនៃពណ៌”** ទេ ៕

## ប្រាប់ការកំណត់នឹងជាទោសដូចម្ដេច?

កាលប្រាប់កំណត់ ការខុសភ្លាត់ដោយការសម្គាល់ខុស (នឹងគប្បីមាន) សូម្បីក្នុងវត្ថុដែលគេនឹងគប្បីដល់ព្រម, ព្រោះបើអាចារ្យប្រាប់ថា “លោកចូរធ្វើការស្វាធ្យាយដោយអំណាចនៃពណ៌” សោត, កាលភិក្ខុនេះធ្វើយ៉ាងនោះ កម្មដ្ឋានមិនប្រាកដដោយពណ៌, ឬដោយអំណាចនៃបដិកូល, ឬថា ដោយអំណាចនៃធាតុ; ពេលនោះភិក្ខុនោះក៏សម្គាល់ថា “នេះមិនមែនលក្ខណៈកម្មដ្ឋាន, ទាំងមិនមែនជាកម្មដ្ឋាន” , លោកនឹងកំណត់កាន់យកចំពោះពាក្យដែលអាចារ្យប្រាប់ហើយប៉ុណ្ណោះ ។ បើសូម្បីពាក្យអាចារ្យប្រាប់ថា “លោកចូរធ្វើការស្វាធ្យាយកម្មដ្ឋាននេះ ដោយអំណាចនៃបដិកូល” ដូច្នេះសោត, កាលភិក្ខុនោះធ្វើយ៉ាងនោះ កម្មដ្ឋានមិនប្រាកដ ដោយបដិកូល, ឬដោយអំណាចនៃពណ៌, ឬក៏ដោយអំណាចនៃធាតុ; ភ្លាមនោះ លោកក៏នឹងសម្គាល់ថា “នេះមិនមែនលក្ខណៈរបស់កម្មដ្ឋាន, ទាំងមិនមែនជាកម្មដ្ឋាន” , នឹងកំណត់យកចំពោះពាក្យដែលអាចារ្យប្រាប់ហើយប៉ុណ្ណោះ ។ បើអាចារ្យប្រាប់ថា

“លោកចូរធ្វើការស្វាធ្យាយដោយអំណាចនៃធាតុ” ដូច្នេះសោត, កាលភិក្ខុនោះធ្វើយ៉ាងនោះ កម្មដ្ឋានមិនប្រាកដដោយធាតុ, ឬដោយអំណាចនៃពណ៌, ឬក៏ដោយអំណាចនៃបដិកូល; ភ្លាមនោះ ភិក្ខុទាំងនោះរមែងនឹងសម្គាល់ថា “នេះមិនមែនលក្ខណៈ ទាំងមិនមែនជាកម្មដ្ឋាន” , នឹងកំណត់កាន់យកចំពោះពាក្យដែលអាចារ្យប្រាប់ហើយប៉ុណ្ណោះ ។ នេះជាទោសក្នុងពាក្យដែលអាចារ្យពោលកំណត់ទុក

## តើអាចារ្យគប្បីប្រាប់ដូចម្តេច ?

អាចារ្យអ្នកប្រាប់កម្មដ្ឋាន គប្បីប្រាប់ថា “លោកចូរធ្វើការស្វាធ្យាយដោយអំណាចនៃកោដ្ឋាសៈ” ។ គឺយ៉ាងណា ? គឺគប្បីប្រាប់ថា “លោកចូរធ្វើការស្វាធ្យាយកោដ្ឋាសៈថា “**កេសា លោមា**” ជាដើម, ក៏បើភិក្ខុនោះ ធ្វើការស្វាធ្យាយ ដោយអំណាចនៃកោដ្ឋាសៈយ៉ាងនេះ កម្មដ្ឋានប្រាកដដោយពណ៌, ភ្លាមនោះ ភិក្ខុនោះ ក៏នឹងគប្បីប្រាប់អាចារ្យអ្នកឱ្យឱវាទថា “ខ្ញុំធ្វើការស្វាធ្យាយអាការ ៣២ ដោយអំណាចនៃកោដ្ឋាសៈ, តែកម្មដ្ឋាននោះ (កោដ្ឋាសៈ) ប្រាកដដល់ខ្ញុំដោយពណ៌” ; អាចារ្យមិនគប្បីពោលជំទាស់ថា “នុ៎ះមិនមែនលក្ខណៈ (របស់កម្មដ្ឋាន) មិនមែនកម្មដ្ឋានដូចជាកម្មដ្ឋាន” ដូច្នេះទេ ។ តែគប្បីពោលថា “សប្បុរសល្អហើយ ក្នុងកាលមុនលោកនឹងធ្លាប់ធ្វើបរិកម្មក្នុងវណ្ណកសិណមក; កម្មដ្ឋាននោះនុ៎ះឯង ជាសប្បាយរបស់លោក, លោកចូរធ្វើការស្វាធ្យាយដោយអំណាចនៃពណ៌ចុះ” សូម្បីភិក្ខុនោះ ក៏គួរធ្វើការស្វាធ្យាយដោយអំណាចនៃពណ៌នោះឯង ៕

## ការប្រាកដនៃកោដ្ឋាសៈ

កាលភិក្ខុនោះ ធ្វើយ៉ាងនេះ រមែងនឹងបានវណ្ណកសិណ ៤ គឺលីនកសិណ (កសិណពណ៌ខៀវ), បីតកសិណ (កសិណពណ៌លឿង), លោហិតកសិណ (កសិណពណ៌ក្រហម), ឱទាតកសិណ (កសិណពណ៌ស); គឺយ៉ាងណា ? គឺកាលភិក្ខុនោះមនសិការពណ៌ត្រង់សក់ រោម ទឹកប្រមាត់ និងក្នុងពណ៌នៃគ្រាប់ភ្នែកថា **"នីលំ នីលំ** = ខៀវៗ" ដូច្នេះ, ឈានដែលជាចតុក្កន័យ ឬបញ្ចកន័យ រមែងកើតឡើង, ភិក្ខុនោះធ្វើឈានឱ្យជាបាទ ផ្ដើមតាំងវិបស្សនាទុកហើយ រមែងសម្រេចព្រះអរហត្ត ។ ក៏កាលភិក្ខុនោះមនសិការពណ៌ខ្លាញ់ខាប់ និងក្នុងទីមានពណ៌លឿងនៃគ្រាប់ភ្នែកថា **"បីតកំ បីតកំ** = លឿងៗ" ដូច្នេះ, ឈានជាចតុក្កន័យ ឬបញ្ចកន័យរមែងកើតឡើង, ភិក្ខុនោះធ្វើឈានឱ្យជាបាទ ផ្ដើមតាំងវិបស្សនាទុកហើយ រមែងសម្រេចអរហត្ត ។ ក៏កាលភិក្ខុនោះមនសិការពណ៌សាច់ ឈាម និងត្រង់ពណ៌នៃគ្រាប់ភ្នែកថា **"លោហិតំ លោហិតំ** = ក្រហមៗ" ដូច្នេះ, ឈានដែលជាចតុក្កន័យ ឬបញ្ចកន័យរមែងកើតឡើង, ភិក្ខុនោះធ្វើឈានឱ្យជាបាទ ផ្ដើមតាំងវិបស្សនាទុកហើយ រមែងសម្រេចអរហត្ត ។ ក៏កាលភិក្ខុនោះមនសិការពណ៌ក្រចក ធ្មេញ ស្បែក ឆ្អឹង និងក្នុងទីមានពណ៌សនៃគ្រាប់ភ្នែកថា **"ឱទាតំ ឱទាតំ** = សៗ" ដូច្នេះ, ឈានដែលជាចតុក្កន័យ ឬបញ្ចកន័យ រមែងកើតឡើង, ភិក្ខុនោះធ្វើឈានឱ្យជាបាទ ផ្ដើមតាំងវិបស្សនាឱ្យកើតឡើងហើយ រមែងសម្រេចអរហត្ត ។ សេចក្ដីនេះ ជាការចេញ

ទៅរបស់ភិក្ខុអ្នកមានសេចក្ដីតាំងមាំហើយ ដោយអំណាចនៃពណ៌ រហូតដល់ព្រះ-អរហត្ត ។

ភិក្ខុដទៃទៀត កាលធ្វើការស្វាធ្យាយដោយអំណាចនៃកោដ្ឋាសៈ កម្មដ្ឋានរមែងប្រាកដដោយបដិកូល, ភ្លាមនោះ ភិក្ខុនោះគប្បីប្រាប់ដល់អាចារ្យអ្នកឱ្យឱវាទ អាចារ្យក៏មិនគប្បីពោលជំទាស់ថា “នុ៎ះមិនមែនលក្ខណៈ (របស់កម្មដ្ឋាន), មិនមែនកម្មដ្ឋាន, ដូចជាកម្មដ្ឋាន” ដូច្នេះទេ, តែគប្បីប្រាប់ថា “សប្បុរសល្អហើយ ក្នុងកាលមុន លោកនឹងធ្លាប់ប្រកបសេចក្ដីព្យាយាម ក្នុងបដិកូលមនសិការកម្មដ្ឋាននេះនោះឯង ជាសប្បាយរបស់លោក, លោកចូរធ្វើការស្វាធ្យាយដោយអំណាចនៃបដិកូលនោះឯង” ។ សូម្បីភិក្ខុនោះ ក៏គួរធ្វើការស្វាធ្យាយដោយអំណាចនៃបដិកូល កាលភិក្ខុនោះ ធ្វើការស្វាធ្យាយដោយអំណាចនៃបដិកូលយ៉ាងនេះថា **“ក៏ឈ្មោះថាសក់ទាំងឡាយ ជារបស់មិនល្អ មិនគួរពេញចិត្ត មានក្លិនស្អុយ គួររង្កៀសជារបស់បដិកូល” បឋមជ្ឈានរមែងកើតឡើងក្នុងអារម្មណ៍បដិកូលបាន**; ភិក្ខុនោះធ្វើឈានឱ្យជាបាទ ផ្ដើមតាំងវិបស្សនាបានហើយ រមែងបានសម្រេចអរហត្ត; សេចក្ដីនេះជាការចេញទៅរបស់ភិក្ខុអ្នកមានចិត្តតាំងមាំហើយ ដោយអំណាចនៃបដិកូល ដរាបដល់ព្រះអរហត្ត ។

ភិក្ខុដទៃទៀត ធ្វើការស្វាធ្យាយដោយអំណាចនៃកោដ្ឋាសៈ កម្មដ្ឋានរមែងប្រាកដដោយធាតុ ។ **សួរថា** កម្មដ្ឋានកាលប្រាកដដោយធាតុ រមែងប្រាកដដូចម្ដេចទៅ ? សូមឆ្លើយ **សក់ទាំងឡាយជាមុន**, សក់កាលប្រាកដ រមែងប្រាកដដូចជាដើមស្មៅដុះដណ្ដប់លើដំបូក, រោមទាំងឡាយ រមែងប្រាកដដូចជាស្មៅព្រេចទាំង-

ឡាយកើតក្នុងទីរបស់ស្រុកចាស់, ក្រចកទាំងឡាយ រមែងប្រាកដដូចជាស្រោមគ្រាប់ផ្លែស្រគំ ដែលគេភ្ជាប់ទុកត្រង់ចុងកំណាត់ឈើ, ធ្មេញទាំងឡាយ រមែងប្រាកដដូចជាគ្រាប់ឃ្លោកដែលគេដោតទុកលើដុំដីស្អិត, ស្បែករមែងប្រាកដដូចស្បែកគោស្រស់ស្រោបពិណ, សាច់រមែងប្រាកដដូចជាដីស្អិត ដែលគេលាបទុកខាងក្នុងជញ្ជាំងផ្ទះ, សរសៃទាំងឡាយ រមែងប្រាកដដូចជាវល្លិពន្ធពទ្ធទព្វសម្ភារៈ, ឆ្អឹងរមែងប្រាដកដូចជាទព្វសម្ភារៈរបស់ផ្ទះ ដែលលើកឡើងតាំងទុក, ខួរក្នុងក្បាលរមែងប្រាកដដូចជាចុងផ្តៅរោលភ្លើងដែលដាក់ទុកក្នុងបំពង់ឫស្សីធំ, កោដ្ឋាសៈទាំង ៦ គឺ តម្រងនោម, បេះដូង, ថ្លើម, វាវ, ក្រពះ និងសួតរមែងប្រាកដ ដូចជារោងសម្លាប់សត្វ; ពោះវៀនធំវែង ៣២ ហត្ថ រមែងប្រាកដដូចជាពស់ផ្ទះ ដែលគេសម្លាប់ហើយដាក់ទុកក្នុងស្នូកឈាម, **ពោះវៀនតូច** រមែងប្រាដកដូចជាសរសៃខ្សែតូច ដែលគេដេរទុកក្នុងសំពត់សម្រាប់ជូតជើង, **អាហារថ្មី** រមែងប្រាដកដូចជាអង្ករក្នុងថង់សំពត់ស្តើងធូរៗ, **អាហារចាស់** (ឧច្ចារៈ) រមែងប្រាដកដូចជាដុំដីលឿង ដែលគេញាត់ទុកក្នុងបំពង់ឫស្សី, **ខួរក្នុងក្បាល** រមែងប្រាដកដូចជាដុំម្សៅអង្ករ ៤ ដុំ ដែលគេពូតហើយតាំងទុក, **អាបោធាតុ ១២ យ៉ាង** រមែងប្រាដកដូចជាកែវទឹកពេញ ១២ កែវ ដែលគេតាំងទុករៀងគ្នា ។

ភ្លាមនោះ ភិក្ខុនោះ គប្បីប្រាប់ដល់អាចារ្យអ្នកឱ្យឱវាទ; អាចារ្យក៏មិនគប្បីពោលជំទាស់ថា "នុ៎ះមិនមែនជាលក្ខណៈ (របស់កម្មដ្ឋាន), មិនមែនជាកម្មដ្ឋាន,

ដូចជាកម្មដ្ឋាន” ដូច្នេះទេ តែគប្បីពោលថា “សប្បុរសល្អហើយ ក្នុងកាលមុន លោកធ្លាប់ធ្វើសេចក្ដីព្យាយាមក្នុងធាតុមនសិការមក, កម្មដ្ឋាននុ៎ះឯង ជាសប្បាយរបស់លោក, លោកចូរធ្វើការស្វាធ្យាយដោយអំណាចនៃធាតុចុះ” ។ សូម្បីភិក្ខុនោះក៏គួរធ្វើការស្វាធ្យាយដោយអំណាចនៃធាតុនោះឯង ។

**ក្នុងខនោះ គប្បីជ្រាបវិធីការស្វាធ្យាយដោយគោលមនសិការដូច្នេះ៖**

ភិក្ខុក្នុងធម្មវិន័យនេះ រមែងមនសិការ (គឺធ្វើទុកក្នុងចិត្ត) ថា **“សក់ទាំងឡាយ កើតត្រង់ស្បែកដណ្ដប់ក្បាល, សក់ទាំងនោះ រមែងមិនដឹងខ្លួនឯងថា “យើងកើតត្រង់ស្បែកដណ្ដប់ក្បាលទេ”**, សូម្បីស្បែកដណ្ដប់សិរីរៈនោះ ក៏**រមែងមិនដឹងថា “សក់ទាំងឡាយកើតក្នុងយើង, វត្ថុទាំងនេះ មិនមានការគិតជាអព្យាកតៈ ជារបស់ទទេ ជាសភាពរឹង រឹងកំព្រឹស” នេះជាបឋវីធាតុ ។** រមែងមនសិការថា “រោមទាំងឡាយកើតត្រង់ស្បែកដណ្ដប់សិរីរៈ, រោមទាំងនោះរមែងមិនដឹងថា ‘ **យើងកើតលើស្បែកដណ្ដប់សិរីរៈ**”, សូម្បីស្បែកដណ្ដប់សិរីរៈនោះ ក៏មិនដឹងថា **រោមទាំងឡាយកើតក្នុងយើង**, សូម្បីវត្ថុទាំងនេះ ក៏មិនមានការគិត ។ ក្រចកទាំងឡាយកើតត្រង់ចុងម្រាមទាំងឡាយ, ក្រចកនោះ រមែងមិនដឹងថា “យើងកើតត្រង់ចុងម្រាមទាំងឡាយ”, សូម្បីចុងម្រាមទាំងនោះ ក៏មិនដឹងថា “ក្រចកទាំងឡាយកើតក្នុងយើង” សូម្បីវត្ថុពួកនេះ ក៏មិនមានការគិត ។ ធ្មេញទាំងឡាយកើតត្រង់ឆ្អឹងចង្កា, ធ្មេញទាំងនោះរមែងមិនដឹងថា “យើងកើតត្រង់ឆ្អឹងចង្កា”, សូម្បីឆ្អឹងចង្កានោះ ក៏មិនដឹងថា “ធ្មេញទាំងឡាយកើតក្នុងយើង”, សូម្បីវត្ថុនោះ ក៏មិនមានការគិត ។ ស្បែករមែងមិនដឹងថា “យើងដណ្ដប់សិរីរៈ”, សូម្បី

សរីរៈនោះ ក៏មិនដឹងថា “យើងត្រូវស្បែកដណ្តប់ទុក” , សូម្បីវត្ថុនេះ ក៏មិនមានការគិត ។ សាច់រមែងមិនដឹងថា “យើងបូកលាបសរីរៈ” , សូម្បីសរីរៈនោះ ក៏មិនដឹងថា “យើងត្រូវសាច់បូកលាបទុក, សូម្បីវត្ថុនេះ ក៏មិនមានការគិត” ។ សរសៃរមែងមិនដឹងថា “យើងចងពន្ធគំនរឆ្អឹងទុក” , សូម្បីគំនរឆ្អឹងនោះ ក៏មិនដឹងថា “យើងត្រូវក្រឡាសំណាញ់នៃសរសៃចងទុក” សូម្បីវត្ថុនេះ ក៏មិនមានការគិត ។ ឆ្អឹងសរីរៈរមែងមិនដឹងថា “យើងតាំងនៅត្រង់ឆ្អឹងក, សូម្បីឆ្អឹងកនោះ” ក៏មិនដឹងថា “ឆ្អឹងសរីរៈតាំងនៅក្នុងយើង” , ឆ្អឹងក ក៏មិនដឹងថា “យើងតាំងនៅលើឆ្អឹងខ្នង ឆ្អឹងខ្នង ឆ្អឹងចង្កេះ ឆ្អឹងភ្លៅ និងឆ្អឹងស្មង” ឆ្អឹងភ្នែកគោរមែងមិនដឹងថា “យើងតាំងលើឆ្អឹងកែងជើង” , សូម្បីឆ្អឹងកែងជើងនោះ ក៏មិនដឹងថា “យើងលើកឆ្អឹងកជើងតាំងទុក ។ ល ។” ឆ្អឹងកជើងរមែងមិនដឹងថា “យើងលើកឆ្អឹងសរីរៈតាំងទុក” ។ ឆ្អឹងទាំងឡាយ តាំងនៅដោយទីបំផុតគ្នាតាមលំដាប់ តពីនេះទៅ ក្នុងទីមិនមែនតិចសរសៃអ្វីៗ មិនបានចងទុក ។ គំនរឆ្អឹងនេះ ក៏មិនមានការគិតដូចជាកំណាត់ឈើ ជាសភាវៈដែលជរាដាស់តឿនហើយ សូម្បីខួរក្នុងក្បាលនេះ ក៏មិនមានការគិត ។ តម្រងនោម ។ ល ។ ខួរក្នុងក្បាល ក៏មិនមានការគិត ជាអព្យាកតៈ ជារបស់ទទេ រឹងកំព្រឹស ជាបឋវីធាតុ” ។ រមែងធ្វើទុកក្នុងថា “ទឹកប្រមាត់ ស្លេស ។ ល ។ ទឹកមូត្រមិនមានការគិត ជាអព្យាកតៈ ជារបស់ទទេ ជាគ្រឿងតោងជាប់ ជាអាបោធាតុផ្សព្វផ្សាយចេញទៅ ។ កាលព្រះយោគាវចរកំណត់មហាភូតរូប ២ ទាំងនោះ

តែដោធាតុដ៏ច្រើន រមែងប្រាកដត្រង់ពោះ ។ វាយោធាតុដ៏ច្រើន រមែងប្រាកដត្រង់ច្រមុះ ។ កាលកំណត់មហាភូតរូប ៤ នេះ ឧបាទាយរូបរមែងប្រាកដ ។ ឈ្មោះថាមហាភូតរូបរមែងកំណត់បានដោយឧបាទាយរូប, ឧបាទាយរូប ក៏កំណត់បានដោយមហាភូតរូប ។ ប្រៀបដូចឈ្មោះថា កំដៅថ្ងៃកំណត់បានដោយស្រមោល, ស្រមោលក៏កំណត់បានដោយកំដៅថ្ងៃ យ៉ាងណា, មហាភូតរូបក៏ដូច្នោះដែរ កំណត់បានដោយឧបាទាយរូប, ឧបាទាយរូបកំណត់បាន ដោយមហាភូតរូប ។ កាលសេចក្ដីជាយ៉ាងនោះ ភិក្ខុនោះកំណត់រូបក្ខន្ធថា **“មហាភូតរូប ៤ ឧបាទាយរូប ២៣ ជារូបក្ខន្ធ”** យ៉ាងនេះ អរូបក្ខន្ធ ក៏រមែងប្រាកដដោយអំណាចនៃអាយតនៈ និងទ្វារ ។ ការកំណត់រូប និងអរូបក្ខន្ធ គឺខន្ធ ៥ រមែងប្រាកដដោយប្រការដូច្នេះ ។ ខន្ធ ៥ គឺអាយតនៈ ១២, ឯអាយតនៈ ១២ ក៏គឺធាតុ ១៨, ព្រោះហេតុនោះ ភិក្ខុគប្បីកំណត់ **នាម និងរូប** ធ្វើឱ្យជាចំណែក ២ ដោយអំណាចនៃខន្ធ អាយតនៈ និងធាតុ ឱ្យដូចជាពុះនូវឫសត្នោតជាគូរដូច្នោះ ។

ភិក្ខុនោះត្រិះរិះថា **“នាមរូបនេះកើតឡើង ព្រោះមិនមានហេតុ មិនមានបច្ច័យមិនបានឡើយ, កើតឡើងព្រោះមានហេតុ មានបច្ច័យ; ក៏អ្វីទៅជាហេតុ ជាបច្ច័យរបស់នាមរូបនោះ”** ទើបកំណត់បច្ច័យនៃនាមរូបនោះថា **“នាមរូបកើតឡើង ព្រោះអវិជ្ជាជាបច្ច័យ, ព្រោះតណ្ហាជាបច្ច័យ, ព្រោះកម្មជាបច្ច័យ, ព្រោះអាហារជាបច្ច័យ”** ហើយរមែងឈានកន្លងសេចក្ដីសង្ស័យក្នុងកាលទាំង ៣ ថា **“ក្នុងអតីតកាលក្ដី ក្នុងអនាគតកាលក្ដី ក្នុងបច្ចុប្បន្នកាលក្ដី បច្ច័យទាំងឡាយ និងធម៌ដែលកើតឡើង ព្រោះបច្ច័យទាំងឡាយ រមែងកើត**

ឡើង, ក្រៅពីនេះហើយ មិនមានសត្វ ឬបុគ្គលទេ, មានតែកងសង្ខារសុទ្ធៗប៉ុណ្ណោះ” ។ **ក៏វិបស្សនានេះ** មានសង្ខារជាគ្រឿងកំណត់ ទើបឈ្មោះថា **ញាតបរិញ្ញា** ។ កាលភិក្ខុកំណត់សង្ខារហើយតាំងនៅយ៉ាងនេះ ឫសឋាន (មូលដ្ឋាន) ក្នុងព្រះពុទ្ធសាសនានៃព្រះទសពលរបស់លោក ឈ្មោះថា ចាក់ធ្លុះហើយ (ឆ្លងហើយ) ឈ្មោះថា បានទីពឹងហើយ; ភិក្ខុនោះជាអ្នកឈ្មោះថា ព្រះចុល្លសោតាបន្នអ្នកមានគតិទៀង។

ក៏ភិក្ខុនោះបានឧតុសប្បាយ បុគ្គលសប្បាយ ភោជនសប្បាយ និងធម្ម-សប្បាយដូច្នេះហើយ អាស្រ័យនៅដោយឯកបល្លង្កដែលប្រសើរក្នុងអាសនៈតែមួយ ពិចារណាសង្ខារទាំងឡាយ លើកឡើងកាន់ព្រះត្រៃលក្ខណ៍ដោយលំដាប់នៃវិបស្សនា រមែងកាន់យកនូវអរហត្តបានពិតៗ ។ សេចក្តីនេះជាការចេញទៅរបស់ភិក្ខុអ្នកមានចិត្តតាំងមាំដោយអំណាចនៃធាតុ ។

ចំណែកភិក្ខុណា កម្មដ្ឋានមិនប្រាកដដោយពណ៌ ដោយបដិកូល ដោយសុ-ញ្ញតៈ, ភិក្ខុនោះ ក៏មិនគប្បីអង្គុយលះបង់កម្មដ្ឋានចេញដោយគិតថា “**កម្មដ្ឋានមិនប្រាកដដល់យើង**” , តែតាមពិត ភិក្ខុគប្បីធ្វើសេចក្តីព្យាយាមមនសិការក្នុងកោដ្ឋាសៈតទៅទៀត ។ បានឮថា ព្រះថេរៈក្នុងកាលមុនពោលថា “ភិក្ខុមនសិការកោដ្ឋាសៈនុ៎ះឯងជាប្រមាណ” ។ កាលភិក្ខុធ្វើការស្វាធ្យាយ ដោយអំណាចនៃកោដ្ឋាស : រឿយៗ យ៉ាងនេះ កោដ្ឋាសៈទាំងឡាយរមែងស្ទាត់ជំនាញ ។ ក៏ក្នុងកាលណា កោ-

ដ្ឋាសៈទាំងឡាយទើបនឹងឈ្មោះថា ស្ទាត់ជំនាញ ? កាលណាគ្រាន់តែលោករំពឹងទៅថា **“កេសា”** មនសិការទៅដរាបតាំងនៅត្រង់កោដ្ឋាសៈចុងបំផុត គឺ **មត្ថលុង្គំ** និងគ្រាន់តែរំពឹងថា **“មត្ថលុង្គំ”** មនសិការមកដរាបដល់ត្រង់កោដ្ឋាសៈខាងដើម គឺ **កេសា**, ពេលនោះកោដ្ឋាសៈ ៣២ រមែងប្រាកដដល់ភិក្ខុនោះ ប្រៀបដូចបុរសអ្នកមានចក្ខុមើលផ្កាឈើ ៣២ ពណ៌ ដែលដោតទុកដោយអំបោះមួយសរសៃ ឬថាក្រឡេកមើលបង្គោលរបង ៣២ ដើម ដែលកប់ទុកដោយលំដាប់ផ្កាឈើ ៣២ ពណ៌ ឬសសរបង្គោល ៣២ ដើម រមែងមិនប្រាកដតាមលំដាប់ដូច្នោះ ។ សត្វតិរច្ឆានទាំងឡាយក្តី មនុស្សទាំងឡាយក្តី ដែលត្រាច់ទៅ រមែងប្រាកដ (ដល់ព្រះយោគាវចរនោះ) ថាជាសត្វ, រមែងប្រាកដជាកោដ្ឋាសៈទាំងឡាយ; ខាទនីយៈ ភោជនីយៈ ក៏រមែងប្រាកដដូចជាពណ៌វត្ថុដែលគេដាក់ចូលទៅក្នុងចន្លោះកោដ្ឋាសៈ ។ ចាប់ផ្តើមពីកោដ្ឋាសៈទាំងឡាយស្ទាត់ជំនាញហើយ ភិក្ខុនោះនឹងរួចផុតបាន ដោយគោលមួយក្នុងគោលទាំង ៣ (គឺដោយពណ៌ បដិកូល និងសុញ្ញតៈ) ។ កម្មដ្ឋាន រមែងប្រាកដដោយពណ៌ ឬដោយបដិកូល ឬក៏ដោយសុញ្ញតៈ ចាប់ផ្តើមពីកោដ្ឋាសៈទាំងឡាយស្ទាត់ជំនាញហើយ ក៏នឹងរួចផុតដោយគោល ១ ក្នុងគោលទាំង ៣, ប្រៀបដូចស្ត្រីដែលត្រូវការចៀននំ ប្រាថ្នានូវនំដុំណា។ ក៏រមែងនឹងចៀននំដុំនោះ។ បាន ពីម្សៅដែលខ្លួនច្របាច់តាំងទុកហើយ ឬថា ប្រៀបដូចបុគ្គលបង្ហិលឆ្នាំងពេញដោយទឹកដែលគេតាំងទុកក្នុងភូមិប្រទេសស្មើគ្នាទៅ ពីទីណា។ ទឹកក៏នឹងហូរទៅពីទីនោះ។ ឯងដូច្នោះ, កាលភិក្ខុប្រាថ្នាដោយពណ៌, ប្រាថ្នាដោយបដិកូល, ប្រាថ្នាដោយសុញ្ញត

កម្មដ្ឋានក៏នឹងប្រាកដបានដោយពិត ។ នេះឈ្មោះថា **ឧគ្គហសន្ធិ** មានប្រមាណប៉ុណ្ណេះ ។ ភិក្ខុអ្នកតាំងនៅក្នុងឧគ្គហសន្ធិហើយ សម្រេចអរហត្តមានប្រមាណច្រើន ។

មួយទៀត កម្មដ្ឋានរបស់ភិក្ខុណា មិនប្រាកដក្នុងឧគ្គហសន្ធិ, ភិក្ខុនោះរៀនយកកម្មដ្ឋានហើយ បើអាចារ្យនៅក្នុងអាវាសណា, អាវាសនោះសប្បាយដល់លោកនោះ, នុ៎ះជាការល្អ; តែបើមិនបានដូច្នោះទេ, គប្បីនៅក្នុងទីសប្បាយ; កាលអាស្រ័យ គប្បីវៀរវិហារដែលជាទោស ១៨ កន្លែង [១១០] ហើយនៅក្នុងសេនាសនៈដែលប្រកបដោយអង្គ ៥ [១១១] ។

សូម្បីភិក្ខុនោះឯង ក៏គប្បីប្រកបដោយអង្គ ៥ ។ តពីនោះ ភិក្ខុនោះត្រឡប់ពីបិណ្ឌបាត ក្រោយពីឆាន់ភត្តហើយ ក៏គប្បីទៅកាន់ទីសម្រាកក្នុងវេលាថ្ងៃ ឬទីសម្រាកក្នុងវេលារាត្រី ហើយមនសិការកម្មដ្ឋាន ។ គប្បីមនសិការយ៉ាងណា ? គឺគប្បីមនសិការកម្មដ្ឋានដោយលំដាប់ពីដើម តាមន័យដែលពោលហើយ ក្នុងកាលមុន ។ មិនគប្បីមនសិការ ដោយវៀរកម្មដ្ឋានទុកមួយក្នុងចន្លោះ ។ ក៏កាលលោកមនសិការកម្មដ្ឋានដោយលំដាប់ រមែងមិនសាបសូន្យចាកកម្មដ្ឋាន និងសោយលោកុត្តរធម៌ ៩ ប្រការ ដែលដូចនឹងអានិសង្សនៃប្រាសាទ, ប្រៀបដូចបុរសអ្នក

---

[១១០] វិសុទ្ធិ. ១ (បឋវីកសិណនិទ្ទេស) ។

[១១១] វិសុទ្ធិ. ១ (បឋវីកសិណនិទ្ទេស) ។

ឈានឡើងកាន់ជណ្តើរ ៣២ ថ្នាក់ (កាំ) ដោយលំដាប់ថ្នាក់ឡើងកាន់ប្រាសាទ និងសោយអានិសង្សនៃប្រាសាទដូច្នោះ ។

កាលមនសិការដោយលំដាប់ មិនគប្បីមនសិការដោយរហ័សពេកផង មិនគប្បីមនសិការដោយយឺតពេកផង ។ ព្រោះថា កាលមនសិការរហ័សពេក កម្មដ្ឋានរមែងស្ទាត់ជំនាញ ក៏ពិតមែនហើយ, តែកម្មដ្ឋាន ក៏មិនច្បាស់ ។ ក្នុងខនេះ គប្បីជ្រាបសេចក្តីឧបមាដោយន័យដែលពោលហើយក្នុងកាលមុននោះចុះ ។ កាលមនសិការយឺតពេកទៅ កម្មដ្ឋានរមែងមិនដល់ទីបំផុត, រមែងសាបសូន្យក្នុងចន្លោះមែនពិត ។ ប្រៀបដូចអ្នកដើរផ្លូវ ៣ យោជន៍ ព្រោះចាប់ចិត្តក្នុងម្លប់ដែលត្រជាក់ ចាប់ផ្តើមពីទីជាទីទៅហើយ ជួបម្លប់ដ៏ត្រជាក់សប្បាយ ក៏សម្រាក, ជួបផ្ទៃខ្សាច់ដែលជាទីមនោរម្យ ក៏ដាក់ខ្នងដេក, ជួបស្រះបោក្ខរណីក្នុងព្រៃ រមែងផឹក រមែងងូត, ឃើញភ្នំ ក៏ឡើងទៅមើលទេសភាព ដែលជាទីមនោរម្យនៃភ្នំ, សីហៈ ឬខ្លាដំបង ឬក៏ខ្លាធំ រមែងសម្លាប់គេក្នុងចន្លោះនោះឯង, ឬថា ពួកចោររមែងប្លន់ រមែងសម្លាប់យ៉ាងណា, កាលមនសិការយូរទៅ ក៏ដូច្នោះដែរ កម្មដ្ឋានរមែងមិនដល់ទីបំផុត, រមែងសាបសូន្យទៅក្នុងចន្លោះមែនពិត; ព្រោះហេតុនោះ **ក្នុងថ្ងៃមួយ ភិក្ខុគប្បីមនសិការអស់ ៣០ ដង ដោយមិនរហ័សពេក មិនយឺតពេកនោះឯង ។**

**ក្នុងវេលាព្រឹកគប្បីធ្វើការស្វាធ្យាយ ១០ ដង, វេលាថ្ងៃ ១០ ដង, ល្ងាច ១០ ដង,** ការមិនធ្វើ រមែងមិនគួរ; ដូចការភ្ញាក់ពីដេកពេលព្រឹក ការមិនលាងមុខ ក៏មិនគួរ, ការមិនទំពាស៊ីខាទនីយៈ និងភោជនីយៈ ក៏មិនគួរ; គួរញ៉ាំងកិច្ចនេះ ឱ្យប្រព្រឹត្តទៅ, កិច្ចនេះឯង មិនធ្វើត្រឹមតែចំណែកមួយ មិនគួរទេ, កាលធ្វើ

ទើបនឹងកាន់យកប្រយោជន៏ដ៏ធំហើយតាំងនៅបាន; ប្រៀបដូចបុគ្គលមានស្រែ ៣ ថ្នាល, ស្រែថ្នាលមួយឱ្យស្រូវ ៨ កុម្ភៈ (៤00 ថាំង) ស្រែថ្នាលមួយទៀត ឱ្យផល ស្រូវ ១៦ កុម្ភៈ (៨00 ថាំង) និងស្រែថ្នាលមួយផ្សេងទៀត ឱ្យផល ៣២ កុម្ភៈ (១៦00 ថាំង); បុគ្គលនោះ មិនអាចជម្រះ (ធ្វើ) ស្រែសូម្បីទាំង ៣ ថ្នាលបាន គប្បីចោល ២ ថ្នាល ហើយធ្វើស្រែមួយថ្នាល ដែលឱ្យ (ផល) ស្រូវ ៣២ កុម្ភៈ ប៉ុណ្ណោះ; គឺគប្បីធ្វើការភ្ជួរ ការព្រោះ ការច្រូតជាដើម ក្នុងស្រែថ្នាលទី ៣ នោះឯង; ស្រែថ្នាលទី ៣ នេះនុ៎ះឯង រមែងសម្ដែងការឱ្យកើតឧស្សាហ៍ដល់គេក្នុងស្រែ ២ ថ្នាល ក្រៅនេះ យ៉ាងណា, សេចក្ដីនេះ ក៏ដូច្នោះដែរ; ភិក្ខុសូម្បីលះបង់ការងារដែលនៅសល់ មានការងារលាងមុខជាដើមហើយ **គប្បីធ្វើកម្មដ្ឋានក្នុងទីនេះដោយពិត, ការមិនធ្វើ មិនគួរ, ការធ្វើទើបកាន់យកប្រយោជន៍ដ៏ធំ ហើយតាំងនៅបាន ។**

ឈ្មោះថា **មជ្ឈិមាបដិបទា** លោកពោលទុកដោយពាក្យ មានប្រមាណប៉ុណ្ណោះឯង ។

ភិក្ខុអ្នកបដិបត្តិយ៉ាងនេះ គប្បីការពារសេចក្ដីរវើរវាយបាន ។ ព្រោះថា ការលះកម្មដ្ឋាន ចិត្តដល់សេចក្ដីរវើរវាយទៅខាងក្រៅ, រមែងសាបសូន្យចាកកម្មដ្ឋាន, រមែងមិនអាចឈានកន្លងវដ្តភ័យ; ប្រៀបដូចបុរស (ឈ្មួញ) ម្នាក់ ញ៉ាំងបុគ្គលឱ្យជម្រះបំណុលផុតមួយ បានចំណេញហើយដើរផ្លូវមក ក្នុងចន្លោះផ្លូវ ឈានឡើងស្ពាន

កំណាត់ឈើដែលដើរបានម្នាក់ ដែលទើបឆ្លងជ្រលងញកភ្នំដ៏ជ្រៅ មានក្រពើ មង្ករ និងរក្ខៈ (អារក្សទឹក) គេដើរបណ្តោយជើងឈានទៅ ព្រោះក្រឡេកទៅឯណេះឯណោះ ហួសភ្លាត់ធ្លាក់ចុះទៅ ជាអាហាររបស់ក្រពើជាដើម យ៉ាងណា, សូម្បីភិក្ខុនោះក៏ដូចគ្នាដែរ, គ្រាកាលចិត្តរបស់ខ្លួនលះបង់កម្មដ្ឋាន ដល់សេចក្តីរវើរវាយទៅខាងក្រៅ រមែងសាបសូន្យចាកកម្មដ្ឋាន រមែងមិនអាចឈានកន្លងវដ្តភ័យបានឡើយ ៕

## សេចក្តីនេះគប្បីជ្រាបការឧបមាដូច្នេះ ៖

ក៏ការដែលភិក្ខុនេះរៀនកម្មដ្ឋានក្នុងសំណាក់របស់អាចារ្យ ប្រៀបដូចបុរសញុំាងបុគ្គលឱ្យជម្រះបំណុលមួយពាន់ បានចំណេញហើយ ។ សង្សារវដ្ត ប្រៀបដូចជ្រលងញកភ្នំដ៏ជ្រៅក្នុងចន្លោះផ្លូវ ។ ទុក្ខធំ មានវដ្តៈជាមូល ប្រៀបដូចកាលដែលបុរសនោះ ត្រូវក្រពើជាដើមឃើញហើយ ។ វីថិនៃការស្វាធ្យាយរបស់ភិក្ខុនេះ ប្រៀបដូចស្ពានកំណាត់ឈើដើរបានម្នាក់ ។ គប្បីជ្រាបថា ភាវៈនៃភិក្ខុនេះ ជាអ្នកលះបង់កម្មដ្ឋាន មានចិត្តរវើរវាយខ្លាំងទៅខាងក្រៅ សាបសូន្យចាកកម្មដ្ឋាន មិនអាចឈានកន្លងវដ្តភ័យបាន, ប្រៀបដូចកាលដែលបុរសនោះ ឈានកាន់ស្ពានកំណាត់ឈើ ដើរបានតែម្នាក់ ហើយព្រលែងឈើសម្រាប់ជាន់ រវល់តែក្រឡេកមើលខាងឯណេះឯណោះ ភ្លាត់ធ្លាក់ចុះទៅដល់ភាពជាអាហាររបស់ក្រពើជាដើម ព្រោះហេតុនោះព្រះយោគាវចរគប្បីមនសិការ **កេសា** = សក់ទាំងឡាយ, គ្រាមនសិការ **កេសា** ទាំងឡាយហើយ ក៏នឹងហាមមិនឱ្យចិត្តុប្បាទរវើរវាយទៅខាងក្រៅ ដោយចិត្តដែល

បរិសុទ្ធនោះឯង ។ គប្បីជ្រាបមនសិការតទៅថា **"លោមា នខា ទន្តា តចោ"** ; កាលមនសិការយ៉ាងនេះ រមែងមិនសាបសូន្យចាកកម្មដ្ឋាន, រមែងឈានកន្លងវដ្ត-ភ័យបាន ៕

## សេចក្តីនេះគប្បីជ្រាបការឧបមានោះឯង ឱ្យប្រព្រឹត្តទៅដោយសព្វគ្រប់យ៉ាងនេះថា ៖

គប្បីជ្រាបថា ការដែលភិក្ខុឆ្លាត មនសិការសក់ទាំងឡាយ ហាមមិនឱ្យចិត្ត-ប្បាទអណ្តែតទៅខាងក្រៅហើយដោយចិត្តហ្មត់ចត់នោះឯង គប្បីមនសិការនូវពាក្យថា **"លោមា នខា ទន្តា តចោ"** មិនឱ្យសាបសូន្យចាកកម្មដ្ឋាន ទើបឈានកន្លងវដ្តភ័យបាន, ប្រៀបដូចការដែលបុរសឆ្លាត ញុំាងបុគ្គលឱ្យជម្រះបំណុលមួយពាន់បានចំណេញហើយ ឈានឡើងកាន់ស្ពានកំណាត់ឈើ រវាំងប្រយ័ត្ន គ្រឿងស្បៀកដណ្តប់ ធ្វើធាតុ គឺកាយ ឱ្យរួសរាន់ទៅដរាបដល់ត្រើយឯណោះ ដោយសិរីសួស្តី ។ សូម្បីកាលលោកហាមសេចក្តីអណ្តែតអណ្តូងទៅខាងក្រៅ យ៉ាងនេះហើយ គប្បីមនសិការដោយការឈានកន្លងបញ្ញត្តិ ដោយន័យដែលពោលហើយក្នុងគ្រាមុននោះឯង, គឺគប្បីពន្លែងបញ្ញត្តិថា **"កេសា លោមា"** ចេញហើយ តាំងសតិថា **"បដិកូល បដិកូល"** ។ កម្មដ្ឋានដំបូងនោះឯង នៅមិនបានប្រាកដ ដោយភាពជាបដិកូល; ដរាបណា កម្មដ្ឋាននៅមិនទាន់ប្រាកដដោយភាពជាបដិកូល, ដរាបនោះ មិនគប្បី

លះបង់បញ្ញត្តិទេ; កាលណាកម្មដ្ឋានប្រាកដដោយភាពជាបដិកូល, កាលនោះ គប្បីលះបង់បញ្ញត្តិហើយមនសិការនូវពាក្យថា **“បដិកូល”** ។ ក៏កាលភិក្ខុធ្វើ គប្បីមនសិការកម្មដ្ឋានដោយភាពជាបដិកូល ដោយអាការ ៥ យ៉ាង តាមន័យដែលពោលហើយក្នុងកាលមុននោះឯង; ព្រោះថា ក្នុងតចបញ្ចកៈ រមែងបានភាពជាបដិកូលសូម្បីទាំង ៥ យ៉ាង ដោយអំណាចនៃពណ៌ សណ្ឋាន ក្លិន អាសយៈ (ទីអាស្រ័យ) និងឱកាស (ទីតាំង) នោះឯង ។ សូម្បីកម្មដ្ឋានដែលនៅសល់ ភិក្ខុបានបដិកូលណាៗ, ក៏គប្បីឱ្យមនសិការប្រព្រឹត្តទៅ ដោយអំណាចនៃចំណែក នោះៗ ។

បណ្ដាកោដ្ឋាសៈទាំងនោះ កោដ្ឋាសៈ ៥ មានសក់ជាដើម ដល់ការរាប់ថា **ជាសុភនិមិត្ត ជាទីតាំងនៃរាគៈ ជាឥដ្ឋារម្មណ៍; ក៏ឈ្មោះថា សត្វណាមួយជាអ្នកត្រេកអរ, សត្វទាំងអស់នោះរមែងត្រេកអរក្នុងកោដ្ឋាសៈ ៥ នេះ** ។ ប៉ុន្តែថា ភិក្ខុនេះ រមែងសម្រេចអប្បនា ក្នុងកោដ្ឋាសៈដែលជាទីតាំងនៃសេចក្ដីត្រេកអររបស់មហាជនថា ជារបស់បដិកូលបាន; ចាប់ផ្ដើមពីសម្រេចអប្បនាក្នុងកោដ្ឋាសៈទាំង ៥ នោះ តពីកោដ្ឋាសៈនោះទៅ លោកជាអ្នកមិនលំបាកទេ ដែលនឹងសម្រេចអប្បនាពិតប្រាកដ ។ ក្នុងសេចក្ដីនោះ គប្បីជ្រាបសេចក្ដីឧបមាដូច្នេះ ៖

ប្រៀបដូចនាយខ្មាន់ធ្នូដែលឆ្លាត ឱ្យព្រះរាជាប្រោសប្រាណហើយ បានស្រុកភូមិសួយដែលមានតម្លៃ ១ សែន បង្កប់លាក់អាវុធ ៥ យ៉ាងទុកក្នុងភូមិនោះ ក្នុងចន្លោះផ្លូវបានជួបចោរ ៣២ នាក់, បណ្ដាចោរទាំងនោះ គេគប្បីសម្លាប់ប្រធានចោរទាំង ៥ នាក់, ចាប់ផ្ដើមពីចោរទាំងនោះ ត្រូវបានសម្លាប់ហើយ ចោរពីរនាក់ ឈ្មោះថា ដើរទៅផ្លូវជាមួយគ្នា រមែងមិនមាន យ៉ាងណា, ឧបមេយ្យនេះជាគ្រឿងញ៉ាំង

ឧបមាឱ្យដល់ព្រម អ្នកសិក្សាគប្បីជ្រាបដូច្នោះចុះ ។ កាលដែលភិក្ខុនេះ រៀនកម្មដ្ឋានក្នុងសំណាក់អាចារ្យហើយតាំងនៅ ប្រៀបដូចកាលដែលនាយខ្មាន់ធ្នូ ឱ្យព្រះរាជាប្រោសប្រាណហើយបានស្រុកភូមិសួយ ។

កោដ្ឋាសៈ ៣២ ប្រៀបដូចចោរ ៣២ នាក់, កោដ្ឋាសៈ ៥ មានកេសាជាដើម ប្រៀបដូចប្រធានចោរ ៥ នាក់, កាលភិក្ខុនេះ **សម្រេចអប្បនាក្នុងតចបញ្ចកៈ** ដែលជាទីតាំងនៃសេចក្ដីត្រេកអររបស់សត្វទាំងឡាយថា "ជារបស់បដិកូល" ។ ប្រៀបដូចកាលដែលប្រធានចោរទាំង ៥ ត្រូវសម្លាប់ស្លាប់ហើយ គប្បីជ្រាបថា **ការសម្រេចអប្បនារបស់ភិក្ខុអ្នកមិនលំបាក** ក្នុងកោដ្ឋាសៈដែលនៅសល់នោះឯង ប្រៀបដូចកាលដែលពួកចោរនៅសល់ចៀសទៅ ដោយត្រឹមតែការទះដៃរបស់នាយខ្មាន់ធ្នូប៉ុណ្ណោះ ។

ភិក្ខុឈានកន្លងបញ្ញត្តិយ៉ាងនេះ គប្បីឱ្យមនសិការប្រព្រឹត្តទៅ ដោយការបណ្ដោយតាមលំដាប់ **គឺកាលមនសិការសក់ទាំងឡាយដដែលៗ នុ៎ះឯង** គ្រាជាប់ចិត្តក្នុងសក់ទាំងឡាយហើយ គប្បីបញ្ជូនទៅក្នុងលោមាទាំងឡាយ; ដរាបណាលោមានៅមិនប្រាកដ, ក៏គប្បីមនសិការថា **"កេសា កេសា"** សិន; តែកាលណា**លោមា**ទាំងឡាយប្រាកដ, ក្នុងកាលនោះ គប្បីវៀរ**កេសា**ទាំងឡាយហើយ ឱ្យសតិចូលទៅតាំងទុកក្នុងលោមាទាំងឡាយ ។

ក្នុងកោដ្ឋាសៈទាំងឡាយ សូម្បី**នខា**ជាដើម ក៏គប្បីឱ្យមនសិការប្រព្រឹត្តទៅ

យ៉ាងនេះ ។ ក្នុងខនេះ គប្បីជ្រាបសេចក្ដីឧបមាដូចតទៅ ៖

ដូចយ៉ាងថា ឈ្លើងកាលនឹងទៅ នៅមិនបានទីពឹង (ទីតោង) ខាងមុខ, ក៏នៅមិនពន្លែងទីដែលកន្ទុយទាមទុកខាងក្រោយ; តែកាលណា បានទីពឹងខាងមុខ វេលានោះ ក៏នឹងលើកកន្ទុយឡើងទៅទាមក្នុងទីជិតមាត់ដែលចាប់ទុក យ៉ាងណា; សេចក្ដីនេះ ក៏ដូច្នោះដែរ, កាលមនសិការ**កេសា**ដដែល១ នុំះឯង ផ្ដោតចិត្តជាប់ក្នុងកេសាហើយ ក៏គប្បីបញ្ជូនសតិទៅក្នុង**លោមា** ដរាបណា **លោមា**នៅមិនបានប្រាកដ, ក៏គប្បីមនសិការថា **"កេសា កេសា"** សិន, វេលាណា **លោមា**ប្រាកដ វេលានោះគប្បីពន្លែង**កេសា** ហើយទើបឱ្យសតិតាំងទុកក្នុងលោមា ។ សូម្បីក្នុង**នខា** (ក្រចក) ជាដើម ក៏គប្បីឱ្យមនសិការប្រព្រឹត្តទៅយ៉ាងនេះ អប្បនារមែងកើតដោយន័យដែលប្រព្រឹត្តទៅហើយយ៉ាងនេះ, ព្រោះហេតុនោះ គប្បីញ៉ាំងមនសិការកោសល្ល តាមដែលពោលហើយឱ្យដល់ព្រម ។ **គឺយ៉ាងណា ? គឺថា** កាលមនសិការអប្បនាកម្មដ្ឋាននេះ ក៏រមែងសម្រេចអប្បនាបាន; គ្រាមុនដំដូងបង្អស់ អប្បនានៅមិនប្រាកដទេ; ពិតមែន ចិត្តដែលធ្លាប់ចម្រើនកម្មដ្ឋានមកហើយក្នុងសង្សារវដ្ដរកទីបំផុតមិនបាន ដែលប្រព្រឹត្តទៅក្នុងអារម្មណ៍ផ្សេង១ មានពេលលោករំពឹងថា **"កេសា"** ដោយទំនងនៃក្រសែការស្វាធ្យាយដំណើរទៅតាំងនៅថា **"មត្ថលុង្គំ"** ; និងត្រឹមតែរំពឹងថា **"មត្ថលុង្គំ"** ដោយក្រសែនៃការស្វាធ្យាយដំណើរទៅតាំងនៅត្រង់**កេសា** ។ ក៏កាលមនសិការដដែល១ កោដ្ឋាសៈនោះ១ រមែងប្រាកដ, សតិក៏តាំងមាំ តាំងនៅហើយប្រព្រឹត្តទៅ ។ ដោយហេតុនោះ កោដ្ឋាសៈណា១ ប្រាកដក្រៃលែងជាង, គប្បីធ្វើសេចក្ដីព្យាយាមក្នុងកោដ្ឋាសៈនោះ១ ដោយទ្វេគុណហើយ នឹង

សម្រេចអប្បនា ។ ចាប់ផ្ដើមពីកាលដែលសម្រេចអប្បនាហើយយ៉ាងនេះ លោកក៏រមែងសម្រេចអប្បនាក្នុងកោដ្ឋាសៈដែលនៅសល់បាន ដោយមិនលំបាកឡើយ ។ ក្នុងសេចក្ដីនេះ គប្បីជ្រាបសេចក្ដីឧបមាដូចស្វាក្នុងព្រៃត្នោត ។

**ម្យ៉ាងទៀត** សេចក្ដីនេះ គប្បីជ្រាបការប្រកបសេចក្ដីសូម្បីយ៉ាងនេះថា៖

ស្វាអាស្រ័យនៅព្រៃត្នោត ៣២ ដើម ។ កាលព្រានត្រូវការនឹងចាប់ស្វានោះ ទើបឈរនៅជិតដើមត្នោតនោះ ។ល។ ក្នុងទីបំផុតបានធ្វើសំឡេងដេញ ។ ស្វាជាសត្វ **មានជាតិ** (មានជាតិនៃសត្វមានមានះ គឺការប្រកាន់ខ្លួន) លោតទៅកាន់ដើមត្នោតនោះៗ ហើយឈប់នៅត្រង់ដើមត្នោតចុងបំផុត ។ នាយព្រានទៅកាន់ទីសូម្បីនោះ ហើយបានធ្វើសំឡេងដេញ ។ ស្វាទើបទៅឈប់នៅត្រង់ដើមដំបូងនោះឯង ។ ស្វានោះ ត្រូវនាយព្រានដេញជាប់តាម ដេញជាប់ញយៗ នឿយហត់ ក៏ឈប់នៅត្រង់ដើមត្នោតនោះឯង ក្នុងកាលនាយព្រានធ្វើសំឡេងដេញញយៗ ទើបវានឹងក្រោកឡើងទៅ ។ កាលវានឿយហត់ ក៏នឹងតោងកាន់ចុងស្លឹកត្នោតនៃដើមត្នោតមួយទុកយ៉ាងមាំ, សូម្បីត្រូវនាយព្រានបាញ់ដោយធ្នូចាប់មក ក៏មិនជៀសចេញទៅ ។ **ក្នុងខនោះ កោដ្ឋាសៈ ៣២ ប្រៀបដូចត្នោត ៣២ ដើម ។ ចិត្ត (របស់ព្រះយោគាវចរ) ប្រៀបដូចស្វា; ព្រះយោគាវចរប្រៀបដូចនាយព្រាន** ។ កាលដែលព្រះយោគាវចរមានចិត្តធ្លាប់អប់រំហើយក្នុងសង្សារវដ្ដ ដែលរកទីបំផុតមិនបាន និងអារម្មណ៍ផ្សេងៗ គ្រាន់តែលោករំពឹងថា **"កេសា"** ដោយទំនងនៃ

ក្រសៃ ការស្វាធ្យាយទៅតាំងនៅត្រង់ **មត្ថលុង្គំ** ប្រៀបដូចកាលដែលស្វាជាសត្វមានជាតិក្នុងការដែលត្រូវនាយព្រានឈរនៅជិតដើមត្នោត ធ្វើសំឡេងដេញ ទើបជៀសទៅឈប់នៅត្រង់ដើមត្នោតចុងបំផុត ។

ការដែលព្រះយោគាវចរគ្រាន់តែរំពឹងថា **“មត្ថលុង្គំ”** ដោយទំនងនៃក្រសៃការស្វាធ្យាយមកឈប់នៅត្រង់ **កេសា** ប្រៀបដូចកាលដែលស្វានៅលើដើមត្នោតចុងបំផុត, កាលត្រូវនាយព្រានធ្វើសំឡេងដេញ ក៏ត្រឡប់មកក្នុងទីបំផុតនៃត្នោតខាងនេះ ។ ការដែលព្រះយោគាវចរមនសិការដដែល១ កោដ្ឋាសៈនោះ១ ប្រាកដសតិក៏តាំងមាំ តាំងនៅហើយប្រព្រឹត្តទៅ ប្រៀបដូចកាលដែលស្វានោះត្រូវនាយព្រានដេញតាមញយ១ នឿយហត់ ទើបក្រោកឡើងទៅក្នុងខណៈដែលត្រូវព្រានដេញ១ ហើយ ។ ការដែលកោដ្ឋាសៈណាប្រាកដក្រៃលែងជាង (ច្បាស់ជាង) ហើយទើបធ្វើមនសិការក្នុងកោដ្ឋាសៈនោះ១ ឱ្យទ្វេគុណទៅដរាបដល់សម្រេចអប្បនា, ប្រៀបដូចកាលដែលស្វាសូម្បីត្រូវនាយព្រានបាញ់ដោយធ្នូ ចាប់ខ្លួនមក ក៏មិនជៀសចេញទៅដូច្នោះ ។ ក្នុងកោដ្ឋាសៈទាំងនោះ ចាប់ផ្ដើមពីសម្រេចអប្បនាហើយ នឹងសម្រេចអប្បនាក្នុងកោដ្ឋាសៈដែលនៅសល់បានដោយមិនលំបាកឡើយ; ព្រោះហេតុនោះ ព្រះយោគាវចរគប្បីរំពឹងថា **“បដិកូល បដិកូល”** ដូច្នេះញយ១ គប្បីនាំបដិកូលមកត្រិះរិះញយ១; កាលធ្វើយ៉ាងនេះ នាមខន្ធ ៤ រមែងមានអារម្មណ៍បដិកូល ក៏នឹងសម្រេចអប្បនាបាន ។ ពាក្យទាំងពួងដែលថា បុព្វភាគចិត្តទាំងឡាយមានវិតក្កៈ វិចារៈ ពោលគឺបរិកម្ម និងឧបចារៈ (ជាដើម) ដូចនឹងពាក្យដែលពោលទុកហើយក្នុងកាលមុននុ៎ះឯង ។ តែថា កាលមនសិការកោដ្ឋាសៈមួយ បឋមជ្ឈាន

មួយប៉ុណ្ណោះ រមែងកើតឡើង, កាលមនសិការដោយចំពោះតែកោដ្ឋាសៈមួយៗ បឋមជ្ឈាន ៣២ រមែងកើតឡើង ។ បញ្ហាវត្ថុដែលកាន់យកហើយក្នុងដៃជារឿងធម្មតាទេ ។

ពាក្យថា **សោតំ និមិត្តំ** បានដល់ ភិក្ខុនោះ... នូវនិមិត្តនៃកម្មដ្ឋាននោះ ។

ពាក្យថា **អាសេវតិ** គឺរមែងសេព រមែងគប់ ។ ពាក្យថា **ភាវេតិ** គឺរមែងចម្រើន (អប់រំ) ។ ពាក្យថា **ពហុលីករោតិ** គឺធ្វើញយៗ ។ ពាក្យថា **ស្វាវត្ថិតំ វវដ្ឋបេតិ** គឺធ្វើការកំណត់ឱ្យល្អ ។ ខថា **"ពហិទ្ធាកាយេ ចិត្តំ ឧបសំហរតិ** = រមែងបង្អោនចិត្តទៅក្នុងកាយខាងក្រៅ" អធិប្បាយថា គ្រាធ្វើយ៉ាងនេះហើយ រមែងបង្អោន គឺរមែងឱ្យចិត្តតាំងនៅ រមែងបញ្ជូនចិត្តរបស់ខ្លួនទៅក្នុងកាយរបស់អ្នកដទៃ ដែលប្រព្រឹត្តទៅខាងក្រៅ ។

ពាក្យថា **អត្ថិស្ស កាយេ** គឺមាននៅក្នុងកាយរបស់អ្នកនោះ, ខថា **"អជ្ឈត្តពហិទ្ធា កាយេ ចិត្តំ ឧបសំហរតិ** = រមែងបង្អោនចិត្តទៅក្នុងកាយទាំងខាងក្នុង និងខាងក្រៅ" អធិប្បាយថា រមែងបង្អោនចិត្តទៅក្នុងកាយរបស់ខ្លួន តាមកាលដែលសមគួរ បង្អោនចិត្តទៅក្នុងកាយអ្នកដទៃ តាមកាលដែលសមគួរ ។

ពាក្យថា **"អត្ថិ កាយេ** = មាននៅក្នុងកាយ" នេះ លោកមិនប្រាថ្នាយកកាយរបស់ខ្លួន និងកាយរបស់អ្នកដទៃដោយចំណែកមួយ ព្រោះហេតុនោះ ព្រះមានព្រះភាគជាម្ចាស់ទើបត្រាស់ថា **មាននៅក្នុងកាយនេះ** ។ ក៏ក្នុងខនេះ កាលព្រះ

យោគាវចរធ្វើបរិកម្មថា **"បដិកូល"** ក្នុងសរីរៈដែលមាននៅក្នុងខ្លួន អប្បនាក្តី ឧបចារៈក្តី រមែងកើតឡើង កាលដែលបរិកម្មថា **"បដិកូល"** ក្នុងសរីរៈដែលមាននៅក្នុងអ្នកដទៃ អប្បនារមែងមិនកើត, ឧបចារៈក៏មិនកើត ។ **សួរថា** ក៏បដិកូលទាំង ២ រមែងកើតក្នុងអសុភមិនមែនឬ ? ឆ្លើយថា មែន រមែងកើតក្នុងអសុភ; ព្រោះអសុភទាំង ១០ នោះ តាំងនៅក្នុងផ្នែកអនុបាទិន្នកសង្ខារ (គ្មានវិញ្ញាណ), ព្រោះហេតុនោះ អប្បនាក្តី ឧបចារៈក្តី ទើបកើតឡើងបានក្នុងអសុភទាំង ១០ នោះ ចំណែកបដិកូលក្នុងសរីរៈរបស់អ្នកដទៃនេះ តាំងនៅក្នុងផ្នែកឧបាទិន្នកសង្ខារ, ព្រោះហេតុនោះឯង សូម្បីអប្បនា និងឧបចារៈទាំង ២ ទើបមិនកើតក្នុងទីនោះ; **ក៏វិបស្សនា** ពោលគឺការតាមឃើញអសុភ គប្បីជ្រាបថា **ជាភាវនា** ។ **សួរថា** ក្នុងសេចក្តីនេះ លោកហៅថាអ្វី ? ឆ្លើយថា លោកហៅថា **សមថវិបស្សនា** ។

ឥឡូវនេះ គប្បីជ្រាបបកិណ្ណកៈដែលទូទៅដល់ការមនសិការទាំងពួង ក្នុងទីនេះតទៅ ៖

## សម្តែងអំពីនិមិត្តជាដើម

ពិតមែន ការវិនិច្ឆ័យសក់ជាដើមនោះ គប្បីជ្រាបដោយនិមិត្ត ដោយលក្ខណៈ ដោយធាតុ ដោយសុញ្ញតៈ និងដោយខន្ធជាដើម ។ ក្នុងខទាំងនេះ ខថា **ដោយនិមិត្ត** គឺព្រះយោគាវចររមែងកំណត់អាការ ៣២ ដោយកោដ្ឋាសៈ តាមអំណាចនៃនិមិត្ត ១៦០ និមិត្ត មាននៅក្នុងអាការ ៣២; តើដូចម្តេច ? គឺសក់មាននិមិត្ត ៥ បានដល់ វណ្ណនិមិត្ត, សណ្ឋាននិមិត្ត, ទិសានិមិត្ត, ឱកាសនិមិត្ត និងបរិច្ឆេទនិមិត្ត; សូម្បីក្នុងរោមជាដើម ក៏ន័យនេះដែរ (៣២ x ៥ = ១៦០) ។

ខថា **ដោយលក្ខណៈ** គឺព្រះយោគាវចរ រមែងមនសិការអាការ ៣២ ដោយលក្ខណៈ តាមអំណាចនៃលក្ខណៈ ១២៨ ក្នុងអាការ ៣២; តើដូចម្តេច ? គឺដោយលក្ខណៈ តាមអំណាចនៃលក្ខណៈ ១២៨ ក្នុងអាការ ៣២ គឺសក់មានលក្ខណៈ ៤ បានដល់ ៖

**ថទ្ធត្តលក្ខណំ** មានសេចក្តីរឹងជាលក្ខណៈ

**អាពន្ធនលក្ខណំ** មានការតោងទុំស្អិតជាលក្ខណៈ

**ឧណ្ហត្តលក្ខណំ** មានសេចក្តីក្តៅជាលក្ខណៈ

**វិត្ថម្ភនលក្ខណំ** មានការពង្រីកខ្លួនជាលក្ខណៈ ។

សូម្បីក្នុងរោមជាដើម ក៏ន័យនេះដែរ (៣២ x ៤ = ១២៨) ។

ខថា **ដោយធាតុ** គឺព្រះយោគាវចររមែងកំណត់អាការ ៣២ ដោយធាតុ ដោយអំណាចនៃធាតុ ១២៨ ក្នុងអាការ ៣២ ដែលព្រះមានព្រះភាគទ្រង់ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ បុរសនេះ មានធាតុ ៤" សក់មានធាតុ ៤ គឺភាពរឹង ជាបឋវីធាតុ, ភាពតោងស្អិត ជាអាបោធាតុ, ភាពក្តៅ ជាតេជោធាតុ, ភាពពង្រីក ខ្លួនជាវាយោធាតុ ។ សូម្បីក្នុងរោមជាដើម ក៏ន័យនេះដែរ (៣២ x ៤ = ១២៨) ។

ខថា **ដោយសុញ្ញតៈ** គឺព្រះយោគាវចររមែងពិចារណាឃើញអាការ ៣២ ដោយអំណាចនៃសុញ្ញតៈ ៩៦ ក្នុងអាការ ៣២ តើដូចម្តេច ? គឺសក់មានសុញ្ញតៈ ៣ មុនសិន គឺ**អត្តសុញ្ញតា** (ទទេចាកខ្លួន) **អត្តនិយសុញ្ញតា** (ទទេចាកវត្ថុរបស់

ខ្លួន) **និច្ចភាវសុញ្ញតា** (ទទេចាកភាពជារបស់ទៀង) ព្រោះអត្ថថា សក់ទាំងឡាយទទេចាកខ្លួន ឬចាកវត្ថុជារបស់ខ្លួន... ចាកភាពពិតប្រាកដ... ចាកភាពមាំទាំ... ចាកភាពទៀង... ចាកធម៌ដែលមិនប្រែប្រួល...។ សូម្បីក្នុងរោមជាដើម ក៏ន័យនេះដែរ (៣២ x ៣ = ៩៦) ។

ខថា **ដោយខន្ធ** ជាដើម គប្បីជ្រាបវិនិច្ឆ័យក្នុងខនេះ ដោយន័យថា កាលព្រះយោគាវចរកំណត់អាការ ៣២ ដោយអំណាចនៃខន្ធជាដើម ក្នុងកោដ្ឋាសៈទាំងឡាយ មានសក់ជាដើម គឺថា សក់ទាំងឡាយជាខន្ធប៉ុន្មាន ? ជាអាយតនៈប៉ុន្មាន ? ជាធាតុប៉ុន្មាន ?; ជាសច្ចៈប៉ុន្មាន ? និងជាសតិប្បដ្ឋានប៉ុន្មាន ? ជាដើម ។

ព្រះមានព្រះភាគជាម្ចាស់ គ្រាទ្រង់សម្ដែងកាយានុបស្សនាដោយពិស្ដារ ៣ យ៉ាង ដោយចែកជាកាយខាងក្នុងជាដើមយ៉ាងនេះហើយ ឥឡូវនេះ ទ្រង់ប្រារព្ធពាក្យថា **អនុបស្សី** ជាដើម ដើម្បីនឹងចែកជាបទថា **“កាយានុបស្សី វិហរតិ អាតាបី សម្បជានោ”** ជាដើមចេញទៅ ។ ក្នុងខនោះដើម្បីសម្ដែងអនុបស្សនាដែលឈ្មោះថា កាយានុបស្សីនោះ ទើបត្រាស់ថា “ក្នុងបទទាំងនោះការពិចារណារឿយៗ (អនុបស្សនា) តើដូចម្ដេច ? **គឺបញ្ញាណា បជាននាណា**” ជាដើម; សូម្បីក្នុងពាក្យទាំងឡាយ មានពាក្យថា **អាតាបី** ជាដើម ក៏ន័យនេះដែរ ។ ពាក្យថា **បញ្ញា បជាននា** ជាដើម គប្បីជ្រាបដោយន័យដែលពោលទុកក្នុងអដ្ឋកថានៃចិត្តុប្បាទកណ្ឌនោះចុះ ។ ពាក្យទាំងពួងថា **“ឧបេតោ** = អ្នកចូលទៅដល់ហើយ” ជាដើម ជាវេវចនៈរបស់គ្នានឹងគ្នា ។ ម្យ៉ាងទៀត ឈ្មោះថា **ឧបេតោ** ដោយអំណាចនៃអាសេវនៈ (ការសេពគប់) ឈ្មោះថា **សមុបេតោ** (ចូលទៅដល់ហើយដោយ

ល្អ) ព្រោះចូលដល់ដោយល្អ ដោយអំណាចនៃភាវនា ។ សូម្បីពាក្យជាគូៗ គ្នាថា **ឧបាគតោ** = អ្នកចូលដល់ហើយ, **សមុបាគតោ** = អ្នកចូលមកដល់ហើយដោយល្អ; **ឧបបន្នោ** = អ្នកចូលដល់ហើយ, **សម្បន្នោ** = អ្នកចូលដល់ហើយដោយល្អ; ក៏ន័យនេះដែរ ។ តែក្នុងទីនេះ គប្បីជ្រាបការភ្ជាប់សេចក្តី (សម្ពន្ធ) យ៉ាងនេះថា ក៏ឈ្មោះថា អ្នកប្រកបហើយ ព្រោះអាចធ្វើឱ្យច្រើន ។ សូម្បីពាក្យថា ភិក្ខុជាអ្នកចូលទៅដល់ហើយ ដោយសេចក្តីព្យាយាមនេះជាដើម ក៏ន័យនេះដែរ ។

ក្នុងបទថា **"វិហរតិ** = នៅ" ព្រះមានព្រះភាគជាម្ចាស់ កាលសម្តែងដោយទេសនាបុគ្គលាធិដ្ឋាន ទើបត្រាស់ពាក្យថា **"ឥរិយតិ** = ប្រព្រឹត្តទៅរស់នៅ" ជាដើម ដោយមិនធ្វើពាក្យសួរថា "បណ្តាពាក្យទាំងនោះ **វិហារ** តើដូចម្តេច" ? ។ សេចក្តីនៃពាក្យនោះ ៖

ឈ្មោះថា **ឥរិយតិ** ព្រោះជាអ្នកព្រមព្រៀងដោយឥរិយាបថយ៉ាងណាមួយក្នុងឥរិយាបថទាំង ៤ ។ ឈ្មោះថា **វត្តតិ** (ប្រព្រឹត្តទៅ) ព្រោះប្រព្រឹត្តទៅដោយរទេះ **ពោលគឺកាយ** ដែលប្រព្រឹត្តទៅដោយឥរិយាបថ ៤ នោះ ។ ឈ្មោះថា **បាលេតិ** (រក្សា) ព្រោះការកម្ចាត់ឥរិយាបថមួយដែលជាទុក្ខ ដោយឥរិយាបថដទៃហើយ រក្សាសរីរៈទុកដោយភាពជាអ្នកតាំងនៅយឺនយូរ ។ ឈ្មោះថា **យាបេតិ** (ឱ្យប្រព្រឹត្តទៅ) ព្រោះមិនតាំងនៅក្នុងឥរិយាបថតែមួយ គឺប្រព្រឹត្តទៅដោយឥរិ-យាបថទាំងពួង ។ ម្យ៉ាងទៀត ឈ្មោះថា **យាបេតិ** ព្រោះញ៉ាំងកាយឱ្យប្រព្រឹត្តទៅ

ដោយឥរិយាបទនោះៗ ។ ឈ្មោះថា **ចរតិ** (ត្រាច់ទៅ) ព្រោះឱ្យកាយប្រព្រឹត្តទៅបានរហូតអស់កាលយូរ ។ ឈ្មោះថា **វិហរតិ** (នៅ) ព្រោះផ្លាស់ឥរិយាបថ ដោយឥរិយាបថហើយនាំជីវិតទៅ ។

ខថា **កាយនោះឯង** ឈ្មោះថា **លោក** សេចក្ដីថា ភិក្ខុមានប្រក្រតីតាមពិចារណាឃើញកាយ ក្នុងកាយណា, កាយនោះៗ ឯង ឈ្មោះថា **លោក** ព្រោះអត្ថថា សាបសូន្យរលាយទៅ = **លុជ្ជនបលុជ្ជនដ្ឋេន**; តែព្រោះអភិជ្ឈា និងទោមនស្ស ដែលបុគ្គលណាលះបានក្នុងកាយ បុគ្គលនោះ ឈ្មោះថា រមែងលះបានសូម្បីក្នុងវេទនាជាដើមនោះដែរ, ព្រោះហេតុនោះ សូម្បីឧបាទានក្ខន្ធ ៥ ក៏ឈ្មោះថា **លោក** ។

គប្បីជ្រាបវិនិច្ឆ័យក្នុងពាក្យថា **“សន្តា”** ជាដើម (អភិជ្ឈា ទោមនស្សដូចពោលនេះ) ឈ្មោះថា **សន្តា** (ស្ងប់) ព្រោះស្ងប់ហើយ ដោយអំណាចនៃនិរោធ, ឈ្មោះថា **សមិតា** (រម្ងាប់) ព្រោះរម្ងាប់ហើយដោយភាវនា ។ ឈ្មោះថា **វូបសន្តា** (ចូលទៅស្ងប់) ព្រោះភាពស្ងប់ដោយការមិនមានតទៅនៃការកំណត់ដឹងនូវវត្ថុ (វត្ថុសច្ចៈ) ។ ឈ្មោះថា **អត្ថង្គតា** (រលត់ទៅ) ព្រោះដល់ហើយនូវការតាំងនៅមិនបាន ពោលគឺនិរោធ ។ ឈ្មោះថា **អព្ភត្ថង្គតា** (រលត់ទៅយ៉ាងរលីង) ព្រោះដល់ការរលត់យ៉ាងក្រៃលែងបំផុត ព្រោះហេតុដែលកម្ចាត់ការកើតញយៗ បាន ។ ពាក្យថា **អប្បិតា** គឺត្រូវធ្វើឱ្យវិនាសទៅ, គឺមិនឱ្យមានតទៅ ។ ពាក្យថា **ព្យប្បិតា** គឺត្រូវធ្វើឱ្យវិនាសទៅដោយល្អ, គឺមិនមានឡើយ ។ ឈ្មោះថា **សោសិតា** (ត្រូវធ្វើឱ្យហួតហែង) ព្រោះឱ្យហួតហែងហើយយ៉ាងនេះ គឺមិនឱ្យមានអាសវៈកើតឡើង ខាង

ក្រោយទៀត ។ ឈ្មោះថា **វិសោសិតា** (ត្រូវធ្វើឱ្យហួតហែងដោយល្អ) ព្រោះហួតហែងដោយល្អ គឺត្រូវធ្វើឱ្យស្ងួតហើយ ។ ឈ្មោះថា **ព្យន្តិកតា** (ត្រូវធ្វើឱ្យមានទីបំផុតទៅប្រាសហើយ) ព្រោះធ្វើឱ្យប្រាសចាកទៅ ។ មួយទៀត ក្នុងអធិការនេះ ការបរិហារកាយរបស់អ្នកបដិបត្តិកម្មដ្ឋាន ដោយការនៅក្នុងកម្មដ្ឋាន គប្បីជ្រាបដោយអនុបស្សនា ។ សម្មប្បធាន គប្បីជ្រាបដោយអាតបៈ (សេចក្តីព្យាយាមដុតកិលេស), ឧបាយជាគ្រឿងរក្សាកម្មដ្ឋាន គប្បីជ្រាបដោយសតិសម្បជញ្ញៈ, អ្នកមានសមថៈដែលបានហើយ គប្បីជ្រាបដោយសតិ ឬដោយអំណាចនៃកាយានុបស្សនា; **វិបស្សនា** គប្បីជ្រាបដោយសម្បជញ្ញៈ ។ ម្យ៉ាងទៀត គប្បីជ្រាបថា ផលនៃភាវនាព្រះមានព្រះភាគត្រាស់ទុក ដោយការកម្ចាត់អភិជ្ឈា និងទោមនស្សដូច្នេះឯង ៕

**ចប់អដ្ឋកថាកាយានុបស្សនានិទ្ទេស**

# អដ្ឋកថាវេទនានុបស្សនានិទ្ទេស

សូម្បីក្នុងវេទនានុបស្សនានិទ្ទេស គប្បីជ្រាបដូចនឹងពាក្យដែលពោលហើយក្នុងកាលមុន ដោយន័យដែលពោលហើយនោះឯង ។

ក៏ក្នុងពាក្យថា “**សុខំ វេទនំ វេទយមានោ**” ជាដើម ពាក្យថា “**សុខំ វេទនំ**” អធិប្បាយថា កាលសោយសុខវេទនាដែលប្រព្រឹត្តទៅផ្លូវកាយ ឬផ្លូវចិត្ត ក៏ដឹងច្បាស់ថា “យើងសោយសុខវេទនា”។ ក្នុងសេចក្ដីនេះប្រៀបដូចទារកទាំង-ឡាយ សូម្បីនៅដេកផ្ងារក្នុងវេលាបៅដោះជាដើម កាលសោយសុខវេទនា ក៏រមែងដឹងថា “យើងសោយសុខវេទនា” ក៏ពិតមែន, តែព្រះមានព្រះភាគជាម្ចាស់ ក៏មិនបានត្រាស់សំដៅយកសេចក្ដីដឹងដូច្នោះទេ; ព្រោះថា សេចក្ដីដឹងដូច្នោះ រមែងមិនលះបង់សត្តូបលទ្ធិ (គឺការឃើញថាជាសត្វ), រមែងមិនដកសត្តសញ្ញា (គឺការសម្គាល់ថាជាសត្វ), ទាំងមិនមែនកម្មដ្ឋាន ឬមិនមែនការចម្រើនសតិបដ្ឋាន។ តែសេចក្ដីដឹងរបស់ភិក្ខុនេះ រមែងលះសត្តូបលទ្ធិ, រមែងដកសត្តសញ្ញា, ទាំងជាកម្មដ្ឋានផង ជាការចម្រើនសតិបដ្ឋានផង។ ព្រោះថា សេចក្ដីនេះលោកពោលសំដៅយកការសោយ គឺសេចក្ដីដឹងច្បាស់យ៉ាងនេះថា “អ្នកណាសោយវេទនា, វេទនារបស់អ្នកណា, វេទនាមានអ្វីជាហេតុ” ។

ក្នុងបញ្ហាទាំងនោះ បទថា **អ្នកណាសោយវេទនា** សេចក្ដីថា អ្នកណាៗ គឺសត្វ ឬបុគ្គលរមែងសោយវេទនាមិនមាន ។ បទថា **វេទនារបស់អ្នកណា** សេចក្ដីថា មិនមែនវេទនារបស់អ្នកណា មិនថាជាសត្វ ឬបុគ្គល។ បទថា **វេទនាមានអ្វីជាហេតុ** សេចក្ដីថា ក៏វេទនានោះឯង មានវត្ថុជាអារម្មណ៍; ព្រោះហេតុនោះ បុគ្គលនោះ ជ្រាបច្បាស់យ៉ាងនេះថា “វេទនានោះឯងដែលគេសោយ ព្រោះធ្វើវត្ថុនៃសុខ

ជាដើមនោះៗ ឱ្យជាអារម្មណ៍, តែព្រោះកាន់យកការប្រព្រឹត្តិទៅនៃវេទនានោះ ក៏ត្រឹមតែជាវោហារថា ‘យើងសោយវេទនា’ ដូច្នេះ គ្រាធ្វើវត្ថុឱ្យជាអារម្មណ៍ យ៉ាងនេះហើយ កាលកំណត់ថា ‘យើងសោយវេទនា’ ដូច្នេះ គប្បីជ្រាបថា អ្នកនោះរមែងជ្រាបច្បាស់ថា ‘យើងសោយសុខវេទនា” ។ ដូចព្រះថេរៈមួយរូប ក្នុងចិត្តលបព៌ត ៖

បានឮថា ព្រះថេរៈក្នុងវេលាដែលលោកមិនសប្បាយ ដេកស្រែកត្អូញត្អែរ ព្រោះវេទនាក្លៀវក្លាត្រឡប់ (ផ្លាស់ប្តូរ) ទៅមក ភិក្ខុកំលោះមួយរូបមកសួរលោកថា “លោកម្ចាស់ លោកឈឺចាប់កន្លែងណា”។ ព្រះថេរៈឆ្លើយយ៉ាងនេះថា **“អ្នកមានអាយុ ក៏ឈ្មោះថា ទីជាទីឈឺចាប់ដែលជាចំណែកត្រង់ណាមិនមានទេ, យើងសោយវេទនា ព្រោះធ្វើវត្ថុឱ្យជាអារម្មណ៍”** ។ ទើបភិក្ខុកំលោះទូលលោកថា **“ចាប់ តាំងពីកាលដែលលោកជ្រាបយ៉ាងនេះ ការអត់ធន់មិនគួរឬ លោកម្ចាស់”** ។ ព្រះថេរៈពោលថា **“យើងនឹងអត់ធន់”** ។ ទើបភិក្ខុកំលោះពោលថា **“ការអត់ធន់ ជាការល្អ”** ។ ព្រះថេរៈអត់ធន់ហើយ; ខ្យល់ផ្សាយទៅដរាបដល់បេះដូង; បានធ្វើពោះវៀនធំរបស់លោកឱ្យធ្លាយចេញមក ជាគំនរនៅលើគ្រែដេក; ព្រះថេរៈឱ្យភិក្ខុកំលោះមើល ហើយពោលថា “អ្នកមានអាយុ អត់ធន់ប៉ុណ្ណេះគួរឬនៅ”។ ភិក្ខុកំលោះក៏នៅស្ងៀម; ព្រះថេរៈប្រកបវីរិយសមាធិ ហើយសម្រេចអរហត្ត ព្រមទាំងបដិសម្ភិទា **ជាព្រះអរហន្តសមសីសី** (អ្នកមានទីបំផុតស្មើគ្នា គឺការអស់ជីវិតព្រម នឹងការសម្រេចព្រះអរហត្ត) បរិនិព្វានហើយ ។

ក៏សុខវេទនា យ៉ាងណា; ទុក្ខវេទនា ។ល។ កាលសោយអទុក្ខមសុខ-

វេទនា មិនមានអាមិស ក៏ដឹងច្បាស់ថា “យើងសោយអទុក្ខមសុខវេទនា មិនមានអាមិស”; ព្រះមានព្រះភាគជាម្ចាស់ គ្រាត្រាស់រូបកម្មដ្ឋានហើយ កាលត្រាស់អរូបកម្មដ្ឋានយ៉ាងនេះ ទើបត្រាស់ដោយអំណាចនៃវេទនា ។

ពិតមែន កម្មដ្ឋានមាន ២ គឺ ***រូបកម្មដ្ឋាន*** និង ***អរូបកម្មដ្ឋាន*** ។ កម្មដ្ឋាននោះនុ៎ះឯង ត្រាស់ថា **រូបបរិគ្គហោ** (គឺការកំណត់រូប) ខ្លះ, **អរូបបរិគ្គហោ** (គឺការកំណត់អរូប) ខ្លះ ។ ក្នុងកម្មដ្ឋាន ២ នោះ ព្រះមានព្រះភាគជាម្ចាស់កាលត្រាស់រូបកម្មដ្ឋាន ទើបត្រាស់ការកំណត់ធាតុ ៤ ដោយអំណាចនៃមនសិការ ដោយសង្ខេបខ្លះ ដោយពិស្តារខ្លះ ។ ការមនសិការសូម្បីទាំង ២ នោះ ខ្ញុំក៏សម្តែងទុកដោយប្រការទាំងពួង ក្នុងវិសុទ្ធិមគ្គនោះឯង ព្រះមានព្រះភាគជាម្ចាស់ កាលត្រាស់អរូបកម្មដ្ឋាន រមែងត្រាស់ដោយអំណាចនៃវេទនាដោយច្រើន ។

ម្យ៉ាងទៀត សេចក្តីប្រកាន់មាំក្នុងអរូបកម្មដ្ឋាន មាន ៣ យ៉ាង គឺ **ដោយអំណាចនៃផស្សៈ ១ ដោយអំណាចនៃវេទនា ១ និងដោយអំណាចនៃចិត្ត ១**; គឺយ៉ាងណា ? គឺថា ក៏កាលព្រះយោគាវចរកំណត់អរូបកម្មដ្ឋានដោយសង្ខេប ឬដោយពិស្តារ ជាការដែលចិត្ត និងចេតសិកធ្លាក់ទៅក្នុងអារម្មណ៍គ្រាដំបូងនោះ ផស្សៈដែលខ្ទប់នូវអារម្មណ៍នោះ ក៏កើតឡើង ប្រាកដដល់ព្រះយោគាវចររូបខ្លះ; ព្រះយោគាវចរទាំងឡាយ រមែងសោយអារម្មណ៍នោះ វេទនាកាលកើតឡើង ក៏រមែងប្រាកដ ដល់ព្រះយោគាវចររូបខ្លះ ។ វិញ្ញាណដែលកើតឡើង កំណត់ដឹងអារម្មណ៍នោះ ក៏រមែងប្រាកដដល់ព្រះយោគាវចររូបខ្លះ ។

ក្នុងសេចក្តីប្រកាន់មាំ ៣ យ៉ាងនោះ **ផស្សៈរមែងប្រាកដដល់ភិក្ខុណា,**

សូម្បីភិក្ខុនោះរមែងកំណត់ធម៌ពួក ៥ មានផស្សៈជាដើមតែម្តងថា “មិនមែនផស្សៈតែម្យ៉ាងយ៉ាងប៉ុណ្ណោះទេ ដែលកើតឡើង សូម្បីវេទនាដែលសោយនូវអារម្មណ៍នោះក៏កើតឡើងព្រមទាំងផស្សៈនោះ, សូម្បីសញ្ញាដែលចាំនូវអារម្មណ៍នោះ, សូម្បីចេតនាដែលគិតនូវអារម្មណ៍នោះ, សូម្បីវិញ្ញាណដែលដឹងនូវអារម្មណ៍នោះ ក៏រមែងកើតឡើងដោយផស្សៈនោះ”; **វេទនារមែងប្រាកដដល់ភិក្ខុណា**, សូម្បីភិក្ខុនោះក៏រមែងកំណត់ធម៌ពួក ៥ មានផស្សៈជាដើមនោះឯងថា “មិនមែនវេទនាតែម្យ៉ាងប៉ុណ្ណោះទេ ដែលកើតឡើង; សូម្បីផស្សៈដែលប៉ះខ្ទប់នូវអារម្មណ៍នោះឯង ក៏កើតឡើងជាមួយនឹងវេទនានោះដែរ, សូម្បីសញ្ញាដែលចាំនូវអារម្មណ៍នោះ,សូម្បីចេតនាដែលគិតនូវអារម្មណ៍នោះ, សូម្បីវិញ្ញាណដែលដឹងច្បាស់នូវអារម្មណ៍នោះ ក៏រមែងកើតឡើងជាមួយនឹងវេទនានោះដែរ”។ វិញ្ញាណរមែងប្រាកដដល់ភិក្ខុណា, សូម្បីភិក្ខុនោះក៏រមែងកំណត់ធម៌ពួក ៥ មានផស្សៈជាដើមនោះនុ៎ះឯងថា “មិនមែនវិញ្ញាណតែម្យ៉ាងប៉ុណ្ណោះទេ ដែលកើតឡើង, សូម្បីផស្សៈដែលប៉ះខ្ទប់នូវអារម្មណ៍នោះឯង ក៏កើតឡើងជាមួយនឹងវិញ្ញាណនោះដែរ, សូម្បីវេទនាដែលសោយនូវអា-រម្មណ៍នោះ, សូម្បីសញ្ញាដែលចាំនូវអារម្មណ៍នោះ, សូម្បីចេតនាដែលគិតនូវអា-រម្មណ៍នោះ ក៏រមែងកើតឡើងជាមួយនឹងវិញ្ញាណនោះដែរ” ។

កាលភិក្ខុនោះត្រិះរិះថា “ធម៌ពួក ៥ មានផស្សៈជាដើមនេះ អាស្រ័យអ្វី” ដូច្នេះ លោកក៏ដឹងច្បាស់ថា “អាស្រ័យវត្ថុ” ; ក៏ឈ្មោះថា វត្ថុ ក៏គឺករជកាយ,លោក

ពោលសំដៅយកវត្ថុ គឺករជកាយ ក្នុងទីនេះទុកថា “ក៏ឯវិញ្ញាណរបស់យើងនេះ អាស្រ័យក្នុងករជកាយនេះ ជាប់ទាក់ទងក្នុងករជកាយនេះ”[១១២] កាលពោលដោយ អត្ថ ករជកាយនោះ គឺមហាភូតរូប និងឧបាទាយរូបទាំងឡាយ ។ ក្នុងសេចក្តីនេះ ព្រះយោគាវចររមែងឃើញនាមរូបនោះឯង យ៉ាងនេះថា “វត្ថុជារូប ធម៌ពួក ៥ មានផស្សៈជាដើម ជានាម” ។ រូបក្នុងទីនេះ ក៏គឺរូបក្ខន្ធ, នាម ក៏គឺអរូបក្ខន្ធ ៤ ព្រោះ ហេតុនោះ នាមរូបទើបមានត្រឹមតែខន្ធ ៥; ព្រោះថា ខន្ធ ៥ ក្រៅពីនាមរូប ឬថា នាមរូប ក្រៅពីខន្ធ ៥ រមែងមិនមាន ។ ភិក្ខុនោះត្រិះរិះថា “ខន្ធទាំងឡាយ ៥ នោះ មានអ្វីជាហេតុ” រមែងឃើញថា មានអវិជ្ជាជាដើម ជាហេតុ; លំដាប់នោះ ទើប លើកឡើងកាន់ត្រៃលក្ខណ៍ ដោយអំណាចនៃនាមរូប ព្រមទាំងបច្ច័យថា “នេះជា បច្ច័យ, នេះជាបច្ចយុប្បន្ន (គឺធម៌ដែលកើតឡើងព្រោះអាស្រ័យបច្ច័យ), សត្វ ឬ បុគ្គលដទៃមិនមាន, មានត្រឹមតែគំនរនៃសង្ខារសុទ្ធៗ ប៉ុណ្ណោះ” ពិចារណាឃើញ **អនិច្ចំ ទុក្ខំ អនត្តា** ដោយលំដាប់នៃវិបស្សនាហើយត្រាច់ទៅ ។ ប្រាថ្នានូវការចាក់ ធ្លុះថា “ក្នុងថ្ងៃនេះ ក្នុងថ្ងៃនេះ” ឬថា លោកបានឧតុសប្បាយ បុគ្គលសប្បាយ ភោជនសប្បាយ និងធម្មស្សវនសប្បាយ ក្នុងថ្ងៃដូច្នោះហើយ អង្គុយដោយបល្លង្ក (ភ្នែន) តែមួយនោះឯង ញុំាងវិបស្សនាឱ្យដល់ទីបំផុត ហើយតាំងនៅក្នុងព្រះអរហត្ត ព្រះមានព្រះភាគជាម្ចាស់ត្រាស់កម្មដ្ឋានដល់ជនសូម្បីទាំង ៣ ពួកនេះ ដរាបដល់ អរហត្ត ដោយប្រការដូច្នេះឯង ។

---

[១១២] ទី. សី. ។

ក៏ឯក្នុងទីនេះ ព្រះមានព្រះភាគជាម្ចាស់កាលត្រាស់អរូបកម្មដ្ឋាន ក៏ត្រាស់ទុកដោយអំណាចនៃវេទនា។ ពិតមែន អរូបកម្មដ្ឋានដែលព្រះមានព្រះភាគជាម្ចាស់ត្រាស់ដោយអំណាចនៃផស្សៈ ឬដោយអំណាចនៃវិញ្ញាណរមែងមិនប្រាកដ, ប្រាកដដូចនឹងភាពងងឹត; ព្រោះកម្មដ្ឋាននោះ រមែងប្រាកដដោយអំណាចនៃវេទនា។ **សួរថា** ព្រោះហេតុអ្វី ? ឆ្លើយថា ព្រោះការកើតឡើងនៃវេទនាទាំងឡាយ រមែងប្រាកដ; ព្រោះថា ការកើតឡើងនៃសុខវេទនា និងទុក្ខវេទនាទាំងឡាយប្រាកដ; គឺក្នុងកាលណា សុខវេទនាកើតឡើង, ធ្វើសរីរៈទាំងអស់ ឱ្យញាប់ញ័រ ឱ្យផ្សព្វផ្សាយទៅ, ដូចជាឱ្យផឹកទឹកដោះថ្លា ដែលជម្រះទាំងរយដង ដូចឱ្យរំលត់នូវភាពក្តៅក្រហាយ ដោយទឹកទាំងពាន់ឆ្នាំង រមែងឱ្យថ្លែងវាចាថា “សុខហ៎ សុខហ៎” ដូច្នេះ។ ក្នុងកាលណាទុក្ខវេទនាកើតឡើង, ក៏ធ្វើឱ្យសរីរៈទាំងអស់ឱ្យរសាប់រសល់ កម្រើកញ័រ ផ្សព្វផ្សាយទៅ, ដូចជាចូលទៅកាន់គ្បឿងដែលក្តៅ, ដូចចាក់ស្រោចដោយទឹក ទង់ដែងដែលរលាយហើយ, ដូចក្តាប់គុបភ្លើងឈើដែលដាក់ចូលទៅក្នុងស្មៅ និងដើមឈើធំដែលស្ងួតក្នុងព្រៃ ធ្វើឱ្យស្រែកត្អូញត្អែរថា “ទុក្ខពិត ទុក្ខពិត” ។ ការកើតឡើងនៃសុខវេទនា និងទុក្ខវេទនារមែងប្រាកដដូចពណ៌នាមកដូច្នេះ ។

ចំណែកអទុក្ខមសុខវេទនា ពន្យល់ឱ្យឃើញបានដោយលំបាក មិនច្បាស់ ដូចសេចក្តីងងឹត ។ តែរមែងប្រាកដដល់អ្នកប្រកាន់យកដោយន័យថា “អទុក្ខមសុខ-វេទនានោះ ជាអាការកណ្តាល ដោយអំណាចនៃការបដិសេធសេចក្តីត្រេកអរ និងការប្រទូសរ៉ាយ ព្រោះសេចក្តីសុខ និងសេចក្តីទុក្ខប្រាសទៅ”។ ប្រៀបដូចនាយព្រានម្រឹគ តាមស្នាមជើងម្រឹគដែលឡើងទៅលើចន្លោះផ្ទាំងថ្ម ក្នុងវេលាដងទៃ ជួប

ស្នាមជើងម្រឹគត្រង់ចំណែកនេះ លើផ្ទាំងថ្ម សូម្បីមិនឃើញស្នាមជើងត្រង់កណ្ដាល ក៏នឹងដឹងបានដោយន័យថា "ម្រឹគនេះឡើងទៅពីទីត្រង់នេះ, ចុះមកពីត្រង់ទីឯណោះ ត្រង់កណ្ដាល វានឹងទៅលើផ្ទាំងថ្ម ដោយប្រទេសត្រង់នេះ" យ៉ាងណា, សេចក្ដីនេះក៏ដូច្នោះដែរ; ព្រោះថា ការកើតឡើងនៃសុខវេទនា រមែងប្រាកដដូចជាស្នាមជើងក្នុងទីជាទីឡើងទៅ, ការកើតឡើងនៃទុក្ខវេទនា រមែងប្រាកដដូចជាស្នាមជើងក្នុងទីឈានចុះ អទុក្ខមសុខវេទនារមែងប្រាកដដល់អ្នកកាន់យកដោយន័យថា "**អទុ-ក្ខមសុខវេទនា** ជាអាការកណ្ដាលដោយអំណាចនៃការបដិសេធ សេចក្ដីត្រេកអរ និងការប្រទូសរ៉ាយព្រោះការប្រាសចាកសុខ និងទុក្ខវេទនា ដូចការកាន់យកដោយន័យថា 'ម្រឹគនេះឡើងទៅលើផ្ទាំងថ្មត្រង់នេះ ចុះទៅត្រង់ទីឯណោះ ត្រង់កណ្ដាល វានឹងដើរទៅត្រង់នេះ" ។

ព្រះមានព្រះភាគជាម្ចាស់ត្រាស់រូបកម្មដ្ឋានជាមុនហើយ កាលនឹងត្រាស់អរូបកម្មដ្ឋានខាងក្រោយយ៉ាងនេះ ទើបទ្រង់ប្ដូរផ្លាស់ទៅសម្ដែងដោយអំណាចនៃវេទនា។ ក៏ព្រះអង្គទ្រង់សម្ដែងយ៉ាងនេះក្នុងសតិបដ្ឋានវិភង្គនេះ តែម្យ៉ាងប៉ុណ្ណោះក៏ទេ, ទ្រង់សម្ដែងរូបកម្មដ្ឋានជាមុនហើយ ទ្រង់សម្ដែងអរូបកម្មដ្ឋាន ប្ដូរផ្លាស់ទៅដោយអំណាចនៃវេទនាខាងក្រោយ ក្នុងព្រះសូត្រទាំងឡាយជាច្រើន គឺ **ក្នុងទីឃ-និកាយ** មានមហានិទានសូត្រ, សក្កបញ្ហាសូត្រ និងមហាសតិបដ្ឋានសូត្រ; **ក្នុងមជ្ឈិមនិកាយ** មានសតិបដ្ឋានសូត្រ, ចុល្លតណ្ហាសង្ខយសូត្រ, មហាតណ្ហាសង្ខយសូត្រ, ចុល្លវេទល្លសូត្រ, មហាវេទល្លសូត្រ, រដ្ឋបាលសូត្រ, មាគន្ទិយសូត្រ, ធាតុវិភង្គ និងអនេញ្ជសប្បាយសូត្រ; **ក្នុងសំយុត្តនិកាយ** មានចុល្ល

**និទានសូត្រ, រុក្ខោបមសូត្រ, បរិវិមំសនសូត្រ និងសកលវេទនាសំយុត្តសូត្រ ទាំងឡាយ** ។ ក៏សូម្បីក្នុងសតិបដ្ឋានវិភង្គនេះ ព្រះមានជោគត្រាស់រូបកម្មដ្ឋានជាមុន ហើយទ្រង់ផ្លាស់មកសម្ដែងអរូបកម្មដ្ឋាន ដោយអំណាចនៃវេទនាខាងក្រោយ ដូចក្នុងសូត្រទាំងនោះឯង ។

ក្នុងពាក្យថា "**កាលសោយសុខវេទនា**" ជាដើមនោះ គប្បីជ្រាបបរិយាយនៃការដឹងម្យ៉ាងទៀត ដូចតទៅនេះ ពាក្យថា "**ក៏ដឹងច្បាស់ថា យើងសោយសុខវេទនា**" អធិប្បាយថា ភិក្ខុនោះ សោយនូវសុខវេទនា រមែងដឹងច្បាស់ថា "យើងសោយនូវសុខវេទនា" ព្រោះការមិនមានទុក្ខវេទនា ក្នុងខណៈនៃសុខវេទនា, ដោយហេតុនោះ ក្នុងសេចក្ដីនោះ អ្នកនោះរមែងជ្រាបក្នុងទីនេះថា "ព្រោះទុក្ខវេទនាយ៉ាងណា ធ្លាប់មានមកក្នុងកាលមុន, ឥឡូវនេះ ទុក្ខវេទនាយ៉ាងនោះ មិនបានមាន និងព្រោះមិនមានវេទនាដទៃពីសុខវេទនានេះ ក៏ឈ្មោះថា វេទនា ទើបជាវត្ថុមិនទៀង មិនឃឹនយូរ មានការប្រែប្រួលទៅជាធម្មតាដូច្នេះ។ សមពិតដូចដែលព្រះមានព្រះភាគត្រាស់ទុកថា "ម្នាលអគ្គិវេសនៈ ក្នុងសម័យណា សោយសុខ-វេទនា, សម័យនោះ មិនសោយទុក្ខវេទនា, មិនសោយអទុក្ខមសុខវេទនា, សម័យនោះ រមែងសោយតែសុខវេទនាប៉ុណ្ណោះ, ម្នាលអគ្គិវេសនៈ ក្នុងសម័យណា សោយទុក្ខវេទនា ។ ល ។ សោយអទុក្ខមសុខវេទនា សម័យនោះ មិនសោយសុខវេទនា មិនសោយទុក្ខវេទនា, សម័យនោះ រមែងសោយអទុក្ខមសុខវេទនាប៉ុណ្ណោះ, ម្នាលអគ្គិវេសនៈ សូម្បីសុខវេទនា ក៏មិនទៀង ដែលបច្ច័យតាក់តែងហើយ អាស្រ័យគ្នាហើយកើតឡើង មានការអស់ទៅជាធម្មតា មានការវិនាសទៅជាធម្មតា មានការ

ប្រែប្រួលទៅជាធម្មតា មានការរលត់ទៅជាធម្មតា ។ សូម្បីទុក្ខវេទនានោះឯង ។ល ។ ម្នាលអគ្គិវេសនៈ សូម្បីអទុក្ខមសុខវេទនា ក៏មិនទៀង មានបច្ច័យតាក់តែងហើយ ។ល ។ មានការរលត់ទៅជាធម្មតា, ម្នាលអគ្គិវេសនៈ អរិយសាវ័កស្តាប់ហើយឃើញយ៉ាងនេះ រមែងនឿយណាយក្នុងវេទនាដែលជាសុខខ្លះ, រមែងនឿយណាយក្នុងវេទនាដែលជាទុក្ខខ្លះ, រមែងនឿយណាយក្នុងវេទនា ដែលជាអទុក្ខមសុខខ្លះ, កាលនឿយណាយ រមែងប្រាសចាកតម្រេក, ព្រោះប្រាសចាកតម្រេក រមែងរួចផុត, កាលរួចផុតហើយ រមែងដឹងច្បាស់ថា យើងរួចផុតហើយ' , លោករមែងជ្រាបច្បាស់ថា 'ជាតិអស់ហើយ, ព្រហ្មចរិយៈនៅចប់ហើយ, កិច្ចដែលគប្បីធ្វើ បានធ្វើស្រេចហើយ, កិច្ចដទៃដើម្បីយ៉ាងនេះ មិនបានមានទៀតឡើយ "[១១៣] ។

ក្នុងពាក្យថា **"ឬកាលសោយសុខវេទនាមានអាមិស"** ជាដើម គប្បីជ្រាបថា គេហសិតសោមនស្សវេទនា ៦ ដែលអាស្រ័យអាមិស គឺកាមគុណ ៥ ឈ្មោះថា សុខវេទនាមានអាមិស ។ នេក្ខម្មសិតសោមនស្ស ៦ ឈ្មោះថា **សុខវេទនាមិនមានអាមិស** ។ គេហសិតទោមនស្សវេទនា ៦ ឈ្មោះថា **ទុក្ខវេទនាមានអាមិស** ។ នេក្ខម្មសិតទោមនស្សវេទនា ៦ ឈ្មោះថា **ទុក្ខវេទនាមិនមានអាមិស** ។ គេហសិតឧបេក្ខាវេទនា ៦ ឈ្មោះថា **អទុក្ខមសុខវេទនាមានអាមិស** ។ នេក្ខម្មសិតឧបេក្ខាវេទនា ៦ ឈ្មោះថា **អទុក្ខមសុខវេទនាមិនមានអាមិស** ។ ការចែកវេទនាទាំងនោះ មានមកហើយក្នុងបាលីឧបរិបណ្ណាសកៈនោះឯង ។

---

[១១៣] ម. ម. ។

ពាក្យថា **“សោ តំ និមិត្តំ”** បានដល់ ភិក្ខុនោះ... នូវនិមិត្តនៃវេទនានោះ ។

ពាក្យថា **“ពហិទ្ធា វេទនាសុ** = ក្នុងវេទនាខាងក្រៅ” គឺក្នុងវេទនាទាំងឡាយរបស់បុគ្គលដទៃ ។

ពាក្យថា **“សុខំ វេទនំ វេទយមានំ”** គឺដឹងបុគ្គលដទៃដែលកំពុងសោយនូវសុខវេទនា ។

ពាក្យថា **“អជ្ឈត្តពហិទ្ធា** = ទាំងខាងក្នុង ទាំងខាងក្រៅ” គឺរមែងបង្អោនចិត្តចូលទៅក្នុងវេទនាទាំងឡាយ របស់ខ្លួនតាមកាលដ៏សមគួរ, របស់អ្នកដទៃតាមកាលដ៏សមគួរ; ព្រោះក្នុងវារៈនេះ មិនបានកំណត់ខ្លួន, មិនបានកំណត់អ្នកដទៃ, ព្រោះហេតុនោះ ដើម្បីទ្រង់សម្ដែងត្រឹមតែការកំណត់វេទនាប៉ុណ្ណោះ ទើបព្រះមានព្រះភាគត្រាស់ថា **“ភិក្ខុក្នុងសាសនានេះ កាលសោយសុខវេទនា ។ ល ។”** សេចក្ដីដែលនៅសល់ក្នុងទីនេះ ងាយស្រួលទាំងអស់ ។ ក្នុងសេចក្ដីនេះ លោកពោលវិបស្សនាទុកសុទ្ធៗ ប៉ុណ្ណោះ ៕

**ចប់អដ្ឋកថាវេទនានុបស្សនានិទ្ទេស**

## អដ្ឋកថាចិត្តានុបស្សនានិទ្ទេស

សូម្បីក្នុងចិត្តានុបស្សនានិទ្ទេស គប្បីជ្រាបដូចនឹងពាក្យដែលពោលហើយ ក្នុងកាលមុន ដោយន័យដែលពោលហើយនោះឯង ។

ក៏ក្នុងពាក្យថា **“សរាគំ វា ចិត្តំ”** ជាដើម បទថា ***សរាគំ*** គឺចិត្តសហគតៈដោយលោភៈ ៨ យ៉ាង។ បទថា **“វីតរាគំ”** គឺចិត្តជាកុសល និងអព្យាកតៈ ផ្នែក

ខាងលោកិយ ។ តែព្រោះការពិចារណានេះ មិនមែនជាធម្មសមោធាន, ព្រោះហេតុនោះ ទើបមិនបានលោកុត្តរចិត្ត សូម្បីត្រឹមតែបទមួយក្នុងទីនេះ ។ អកុសលចិត្តណាប្រព្រឹត្តទៅព្រមទាំងរាគៈជាដើម ដែលព្រះយោគាវចររមែងលះបានដោយអំណាចនៃអត្ថតែមួយ **គឺបហានៈ**, អកុសលចិត្តនេះ លោកក៏មិនកាន់យក ព្រោះមិនបានក្នុងបទទាំងពីរនេះដោយត្រង់ (និប្បរិយាយ) ។ អកុសលចិត្ត ៤ ដែលនៅសល់ មិនជាប់ទាក់ទងនឹងបទមុន និងបទក្រោយ ។

បទថា **"សទោសំ"** គឺចិត្តដែលសហគតៈដោយទោមនស្ស ២ យ៉ាង ។ បទថា **"វីតទោសំ"** គឺចិត្តដែលជាកុសល និងជាអព្យាកតៈផ្នែកខាងលោកិយ ។ អកុសលចិត្ត ១០ ដែលនៅសល់ មិនជាប់ទាក់ទងបទមុន និងបទក្រោយ ។

បទថា **"សមោហំ"** បានដល់ ចិត្ត ២ យ៉ាង គឺចិត្តដែលសហគតៈដោយវិចិកិច្ឆា និងចិត្តដែលសហគតៈដោយឧទ្ធច្ចៈ ។ តែព្រោះមោហៈរមែងកើតឡើងក្នុងអកុសលចិត្តទាំងពួង, ព្រោះហេតុនោះ **អកុសលចិត្ត** សូម្បីដែលនៅសល់ រមែងប្រព្រឹត្តទៅក្នុងទីនេះទាំងអស់; ព្រោះថា អកុសលចិត្ត ១២ លោកកាន់យកហើយក្នុងទុកៈនេះដូចគ្នា ។ បទថា **"វីតមោហំ"** គឺចិត្តដែលជាកុសល និងអព្យាកតៈផ្នែកខាងលោកិយ ។

បទថា **"សង្ខិត្តំ"** គឺចិត្តដែលធ្លាក់ទៅក្នុងថិនមិទ្ធៈ (គឺការរួញរា) ។ ពិតមែនចិត្តនោះ ឈ្មោះថា រួញរា ។ បទថា **"វិក្ខិត្តំ"** គឺចិត្តដែលសហគតៈដោយឧទ្ធច្ចៈ ។ ពិតមែន ចិត្តនោះ ឈ្មោះថា ចិត្តរវើរវាយទៅហើយ ។

បទថា **"មហគ្គតំ"** គឺរូបាវចរចិត្ត និងអរូបាវចរចិត្ត ។ បទថា **"អមហគ្គតំ"**

គឺកាមាវចរចិត្ត ។

បទថា **“សឧត្តរំ”** គឺកាមាវចរចិត្ត ។ បទថា **“អនុត្តរំ”** គឺរូបាវចរចិត្ត និងអរូបាវចរចិត្ត។ ម្យ៉ាងទៀត ក្នុងចិត្តទាំង ២ នេះ **សឧត្តរចិត្ត** បានដល់ រូបាវចរចិត្ត, ឯ **អនុត្តរចិត្ត** បានដល់ អរូបាវចរចិត្តនោះឯង ។

បទថា **“សមាហិតំ”** បានដល់ ចិត្តរបស់អ្នកមានអប្បនាសមាធិ ឬឧបចារសមាធិ។ បទថា **“អសមាហិតំ”** គឺចិត្តដែលវៀរចាកសមាធិទាំងពីរ ។

បទថា **“វិមុត្តំ”** គឺចិត្តដែលផុតហើយដោយតទង្គវិមុត្តិ និងវិក្ខម្ភនវិមុត្តិ ។

បទថា **“អវិមុត្តំ”** គឺចិត្តដែលវៀរចាកវិមុត្តិទាំងពីរ; ចំណែកសមុច្ឆេទវិមុត្តិ បដិបស្សទ្ធិវិមុត្តិ និងនិស្សរណវិមុត្តិ មិនមានឱកាសក្នុងទីនេះ ។

ពាក្យថា **“សរាគមស្ស ចិត្តំ”** បានដល់ ចិត្តរបស់អ្នកនោះមានរាគៈ ។

ពាក្យដែលនៅសល់ មានអត្ថងាយទាំងអស់ ព្រោះមានន័យតាមដែលពោលទុកហើយក្នុងកាលមុន; សូម្បីក្នុងសេចក្តីនេះ លោកក៏ពោលវិបស្សនាសុទ្ធៗ ទុកដោយប្រការដូច្នេះឯង ៕

**ចប់អដ្ឋកថាចិត្តានុបស្សនានិទ្ទេស**

## អដ្ឋកថាធម្មានុបស្សនានិទ្ទេស

ព្រះមានព្រះភាគត្រាស់ការកំណត់រូបក្ខន្ធ ដោយកាយានុបស្សនា, ត្រាស់ការកំណត់វេទនាខន្ធ ដោយវេទនានុបស្សនា និងត្រាស់ការកំណត់វិញ្ញាណក្ខន្ធ ដោយចិត្តានុបស្សនានោះឯង ដោយពាក្យមានប្រមាណប៉ុណ្ណោះ; ព្រោះហេតុនោះ ឥឡូវ

នេះ ដើម្បីនឹងត្រាស់ការកំណត់សញ្ញាខន្ធ និងសង្ខារក្ខន្ធ ដោយកាន់យកគោលប្រធាន នៃសម្បយុត្តធម៌សម្តែងធម្មានុបស្សនា ទើបត្រាស់ថា **"កថញ្ច ភិក្ខុ"** ជាដើម ៕

## អដ្ឋកថានីវរណបព្វៈ

បណ្តាបទទាំងនោះ បទថា **"សន្តំ"** គឺ (កាលកាមច្ឆន្ទៈខាងក្នុងចិត្ត) មាន ដោយអំណាចនៃការប្រាកដរឿយៗ ។ បទថា **"អសន្តំ"** គឺមិនមានដោយអំណាច នៃការមិនប្រាកដ ឬថា ព្រោះលះបានហើយ ។ ពាក្យថា **"យថា ច"** គឺកាមច្ឆន្ទៈ នឹងកើតឡើងដោយហេតុណា ។ ពាក្យថា **"តញ្ច បជានាតិ"** បានដល់ រមែង ជាក់ច្បាស់នូវហេតុនោះ ។ គប្បីជ្រាបសេចក្តីក្នុងបទទាំងពួង ដោយន័យនេះឯង ។

ក្នុងបទទាំងនោះ កាមច្ឆន្ទៈកើតឡើង **ព្រោះអយោនិសោមនសិការក្នុង សុភនិមិត្ត**។ ក៏ឈ្មោះថា **សុភនិមិត្ត** សូម្បីវត្ថុដែលល្អ ក៏ជាសុភនិមិត្ត, សូម្បីអា- រម្មណ៍ក្នុងវត្ថុដែលល្អ ក៏ជាសុភនិមិត្ត។ ឈ្មោះថា **អយោនិសោមនសិការ** គឺមិន មនសិការក្នុងឧបាយ (វិធីដែលគួរ) មនសិការខុសផ្លូវ គឺមនសិការក្នុងវត្ថុដែលមិន ទៀងថា "ទៀង" ឬក្នុងវត្ថុដែលជាទុក្ខថា "ជាសុខ" ឬក៏ក្នុងវត្ថុដែលមិនមែនតួ ខ្លួនថា "ជាតួខ្លួន" ឬថាក្នុងវត្ថុដែលមិនល្អថា "ល្អ"។ កាលញុំាងមនសិការនោះ ឱ្យប្រព្រឹត្តទៅក្នុងធម៌ទាំង ៤ នោះ កាមច្ឆន្ទៈរមែងកើតឡើង។ ដោយហេតុនោះ ទើបព្រះមានព្រះភាគជាម្ចាស់ត្រាស់ថា **"ម្នាលភិក្ខុទាំងឡាយ សុភនិមិត្តមាន, ការធ្វើឱ្យច្រើននូវអយោនិសោមនសិការ ក្នុងសុភនិមិត្តនោះ, នេះជាអាហារ ដើម្បីឱ្យកាមច្ឆន្ទៈដែលនៅមិនកើត បានកើតឡើង ឬថា ដើម្បីឱ្យកាមច្ឆន្ទៈ**

ដែលកើតហើយ ឱ្យបរិបូណ៌ក្រៃលែងឡើងទៅ"[១១៤] ។

ម្យ៉ាងទៀត កាមច្ឆន្ទៈនោះ **លះបានដោយយោនិសោមនសិការក្នុង អសុភនិមិត្ត** ។ ក៏ឈ្មោះថា **អសុភនិមិត្ត** សូម្បីវត្ថុដែលមិនល្អ ក៏ជាអសុភនិមិត្ត, សូម្បីអារម្មណ៍ក្នុងវត្ថុដែលមិនល្អ **ក៏ជាអសុភនិមិត្ត** ។ ឈ្មោះថា **យោនិសោមន សិការ** គឺមនសិការក្នុងឧបាយត្រូវផ្លូវ គឺមនសិការក្នុងវត្ថុមិនទៀងថា "មិនទៀង" ឬក្នុងវត្ថុ ដែលជាទុក្ខថា "ជាទុក្ខ" ឬក៏ក្នុងវត្ថុមិនមែនអត្តាថា "ជាអនត្តា" ឬថា ក្នុងវត្ថុដែលមិនល្អថា "មិនល្អ" ។ កាលញ៉ាំងមនសិការនោះ ប្រព្រឹត្តទៅឱ្យច្រើន ក្នុងធម៌ ៤ នោះ រមែងលះកាមច្ឆន្ទៈបាន; ដោយហេតុនោះ ទើបព្រះមានព្រះភាគ ត្រាស់ថា "ម្នាលភិក្ខុទាំងឡាយ អសុភនិមិត្តមាន, ការធ្វើឱ្យច្រើននូវយោនិ សោមនសិការ ក្នុងអសុភនិមិត្តនោះ, នេះជាអាហារ ដើម្បីឱ្យកាមច្ឆន្ទៈដែល នៅមិនកើតឡើង មិនឱ្យកើតឡើង ឬថា ដើម្បីការលះកាមច្ឆន្ទៈដែលកើត ឡើងហើយ"[១១៥] ។

ម្យ៉ាងទៀត ធម៌ ៦ ប្រការ រមែងប្រព្រឹត្តទៅដើម្បីលះកាមច្ឆន្ទៈ គឺ

**១. អសុភនិមិត្តស្ស ឧគ្គហោ** រៀនយកនូវអសុភនិមិត្ត

**២. អសុភភាវនានុយោគោ** ប្រកបរឿយៗ ក្នុងអសុភភាវនា

**៣. ឥន្ទ្រិយេសុ គុត្តទ្វារតា** មានទ្វារឃុំគ្រងហើយក្នុងឥន្ទ្រិយទាំងឡាយ

---

[១១៤] ស. ម. ។

[១១៥] ស. ម. ។

**៤. ភោជនេ មត្តញ្ញុតា** ស្គាល់ប្រមាណក្នុងភោជន

**៥. កល្យាណមិត្តតា** មានកល្យាណមិត្ត

**៦. សប្បាយកថា** និយាយពាក្យដែលជាទីសប្បាយ ។

ពិតមែន កាលព្រះយោគាវចររៀនយកនូវអសុភនិមិត្ត ១០ យ៉ាងក្តី រមែងលះកាមច្ឆន្ទៈបាន, ការចម្រើននូវអសុភនិមិត្តក្តី, ការមានទ្វារដែលបិទហើយ ក្នុងឥន្ទ្រិយទាំងឡាយក្តី, ភាពជាអ្នកស្គាល់ប្រមាណក្នុងការបរិភោគអាហារ ព្រោះកាលឱកាសនៃពំនូតបាយ ៤-៥ ពំនូតមាន ក៏ផឹកទឹកជំនួស ហើយឱ្យជីវិតប្រព្រឹត្តទៅដោយប្រក្រតីក្តី រមែងលះកាមច្ឆន្ទៈបាន ។ ដោយហេតុនោះ ទើបលោកពោលទុកថា ៖

**“មិនបរិភោគអាហារ ៤-៥ ពំនូតទៀត ហើយគប្បីផឹកទឹកជំនួស ជាការឆ្អែតល្មម ដើម្បីនៅជាសុខរបស់ភិក្ខុអ្នកមានសេចក្តីព្យាយាម”**[១១៦] ។

សូម្បីកាលសេពគប់កល្យាណមិត្ត អ្នកត្រេកអរក្នុងអសុភភាវនា ដូចនឹងព្រះតិស្សត្ថេរអ្នកចម្រើនអសុភកម្មដ្ឋាន ក៏រមែងលះកាមច្ឆន្ទៈបាន ។ រមែងលះកាមច្ឆន្ទៈបាន សូម្បីដោយសប្បាយកថា ដែលអាស្រ័យអសុភ ១០ ក្នុងឥរិយាបថទាំងឡាយ មានការឈរ និងការអង្គុយជាដើម ។ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា “ធម៌ទាំង ៦ ប្រការ រមែងប្រព្រឹត្តទៅដើម្បីលះកាមច្ឆន្ទៈ” ។ ភិក្ខុនោះរមែងដឹងច្បាស់ថា “កាមច្ឆន្ទៈដែលលះហើយ ដោយធម៌ទាំង ៦ ប្រការ

---

[១១៦] ខុ. ថេរ. ។

នេះ មិនកើតតទៅទៀត ដោយអរហត្តមគ្គ” ។

ក៏ព្យាបាទកើតឡើង ព្រោះអយោនិសោមនសិការក្នុងបដិឃនិមិត្ត។ ក្នុងពាក្យទាំងនោះ សូម្បីបដិឃៈក៏ឈ្មោះថា បដិឃនិមិត្ត។ សូម្បីអារម្មណ៍ក្នុងបដិឃៈក៏ឈ្មោះថា បដិឃនិមិត្ត។ អយោនិសោមនសិការមានលក្ខណៈតែមួយ ក្នុងទីទាំងពួងនោះឯង។ កាលញ៉ាំងមនសិការនិមិត្តនោះ ឱ្យប្រព្រឹត្តទៅច្រើនក្នុងនិមិត្ត ព្យាបាទរមែងកើតឡើង ។ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា **“ម្នាលភិក្ខុទាំងឡាយ បដិឃនិមិត្តមាន, ការធ្វើឱ្យច្រើននូវអយោនិសោមនសិការក្នុងបដិឃនិមិត្តនោះ, នេះជាអាហារ ដើម្បីឱ្យព្យាបាទដែលនៅមិនកើត បានកើតឡើង ឬថា ដើម្បីឱ្យព្យាបាទដែលកើតឡើងហើយ ឱ្យចម្រើនបរិបូណ៌ច្រើនឡើងទៀត”**[១១៧] ។

ម្យ៉ាងទៀត ព្យាបាទនោះលះបានដោយមេត្តាចេតោវិមុត្តិ។ ក្នុងពាក្យទាំងនោះ អប្បនាក្តី ឧបចារៈក្តី រមែងគួរក្នុងពាក្យដែលលោកពោលថា **“មេត្តា”**។ តែពាក្យថា **“ចេតោវិមុត្តិ”** បានដល់ អប្បនាប៉ុណ្ណោះ។ យោនិសោមនសិការមានលក្ខណៈតាមដែលពោលហើយនោះឯង។ កាលញ៉ាំងមនសិការឱ្យប្រព្រឹត្តទៅច្រើនក្នុងមេត្តាចេតោវិមុត្តិនោះ រមែងលះព្យាបាទបាន។ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា **“ម្នាលភិក្ខុទាំងឡាយ មេត្តាចេតោវិមុត្តិមាន, ការធ្វើឱ្យច្រើននូវយោនិសោមនសិការក្នុងមេត្តាចេតោវិមុត្តិនោះ, នេះជាអាហារ**

---

[១១៧-១១៨] ស. ម.។

ដើម្បីឱ្យព្យាបាទដែលនៅមិនទាន់កើត មិនឱ្យកើតឡើង ឬថា ដើម្បីការលះព្យាបាទដែលកើតឡើងហើយ” [១១៨] ។

ម្យ៉ាងវិញទៀត ធម៌ ៦ ប្រការ ប្រព្រឹត្តទៅដើម្បីការលះព្យាបាទ គឺ

**១. មេត្តានិមិត្តស្ស ឧគ្គហោ** រៀនយកនូវមេត្តានិមិត្ត

**២. មេត្តាភាវនានុយោគោ** ប្រកបរឿយៗ ក្នុងមេត្តាភាវនា

**៣. កម្មស្សកតាបច្ចវេក្ខណា** ពិចារណានូវកម្មជារបស់ខ្លួន

**៤. បដិសង្ខានពហុលីកតា** ធ្វើការត្រិះរិះពិចារណាឱ្យច្រើន

**៥. កល្យាណមិត្តតា** មានកល្យាណមិត្ត

**៦. សប្បាយកថា** និយាយពាក្យដែលជាទីសប្បាយ ។

ពិតមែន **សូម្បីកាលរៀនយកនូវមេត្តា** ដោយអំណាចនៃការផ្សាយទៅកាន់ទិស ដោយចំពោះ និងមិនចំពោះយ៉ាងណាមួយ រមែងលះព្យាបាទបាន។ **សូម្បីកាលចម្រើនមេត្តា** ដោយអំណាចនៃការផ្សាយទៅកាន់ទិស ដោយចំពោះ និងមិនចំពោះ ក៏រមែងលះព្យាបាទបាន។ **សូម្បីកាលពិចារណានូវកម្មជារបស់ខ្លួន និងរបស់អ្នកដទៃ** យ៉ាងនេះថា “**លោកក្រោធគេហើយ នឹងធ្វើអ្វី,** នឹងអាចដើម្បីញ៉ាំងគុណមានសីលជាដើមរបស់គេឱ្យវិនាសទៅបានឬ, លោកមកដោយកម្មរបស់ខ្លួន ក៏នឹងទៅដោយកម្មរបស់ខ្លួននោះឯងមិនមែនឬ, ក៏ឈ្មោះថា សេចក្តីក្រោធដល់អ្នកដទៃ រមែងដូចជាអ្នកត្រូវការចាប់រងើកភ្លើង ដែលប្រាសចាកអណ្តាត ចាប់ដុំដែកដែលក្តៅ និងលាមកជាដើម ហើយប្រហារអ្នកដទៃ សូម្បីសេចក្តីក្រោធរបស់លោកនេះ នឹងធ្វើអ្វី នឹងអាចដើម្បីញ៉ាំងគុណមានសីលជាដើមរបស់គេឱ្យវិនាស

ទៅបានឬ, យើងមកដោយកម្មរបស់ខ្លួនហើយ ក៏នឹងទៅដោយកម្មរបស់ខ្លួនប៉ុណ្ណោះ, សេចក្តីក្រោធនេះ នឹងធ្លាក់ទៅលើគេពិតប្រាកដ ដូចអំណោយ**ដែលបុគ្គលមិនព្រមទទួល និងដូចក្តាប់ធូលីបាចបញ្ច្រាស់ខ្យល់"** ក៏រមែងលះសេចក្តីក្រោធបាន ។ កាលតាំងនៅក្នុងសេចក្តីត្រិះរិះពិចារណានូវកម្មជារបស់ខ្លួន និងរបស់អ្នកដទៃយ៉ាងនេះ គ្រាត្រិះរិះពិចារណានូវកម្មស្សកតាទាំងពីរ ហើយតាំងនៅក្នុងការត្រិះរិះពិចារណាក្តី, កាលសេពគប់កល្យាណមិត្ត អ្នកត្រេកអរក្នុងមេត្តាភាវនា ដូចនឹងព្រះអស្សគុត្តត្ថេរក្តី រមែងលះព្យាបាទបាន ។ រមែងលះព្យាបាទបាន សូម្បីដោយសប្បាយកថាដែលអាស្រ័យនូវមេត្តា ក្នុងឥរិយាបថទាំងឡាយ មានការឈរ និងអង្គុយជាដើម ។ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា "ធម៌ ៦ ប្រការរមែងប្រព្រឹត្តទៅដើម្បីការលះព្យាបាទ" ។ ភិក្ខុនោះ រមែងដឹងច្បាស់ថា "ព្យាបាទដែលលះដោយធម៌ទាំង ៦ ប្រការនេះ មិនកើតតទៅទៀត ដោយអនាគាមិមគ្គ" ។

ការកើតឡើងនៃថីនមិទ្ធៈក្នុងធម៌ទាំងឡាយ **មានអរតិជាដើម** រមែងមានដោយអយោនិសោមនសិការ ។ ការមិនពេញចិត្តឈ្មោះថា **អរតិ** ។ សេចក្តីខ្ជិលច្រអូសផ្លូវកាយ (ឬភាពទំរន់ផ្លូវកាយ) ឈ្មោះថា **តន្ទី** ។ ការពត់កាយ (ឬការខ្ជិលច្រអូស) ឈ្មោះថា **វិជម្ភិតា** ។ ការងប់ងុលព្រោះភត្ត សេចក្តីខ្វល់ខ្វាយ ព្រោះភត្ត (ស្រវឹងបាយ) ឈ្មោះថា **ភត្តសម្មទៈ ។** អាការរួញរានៃចិត្ត ឈ្មោះថា **ចេតសោលីនត្តំ**។ កាលឱ្យអយោនិសោមនសិការប្រព្រឹត្តទៅ ច្រើនក្នុងធម៌ទាំងឡាយ មាន**អរតិ**ជាដើមនេះ ថីនមិទ្ធៈរមែងកើតឡើង។ ដោយហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា **"ម្នាលភិក្ខុទាំងឡាយ អរតិ (ការមិនពេញចិត្ត) តន្ទី (ការខ្ជិលច្រ-**

អួសផ្លូវកាយ) **ថិនមិទ្ធៈ** (ការបង្អោនកាយ ឬពត់កាយ) **ឥត្តសម្មទៈ** (ការស្រវឹងបាយ) និងភាពនៃចិត្តរួញរាមាន, ការធ្វើឱ្យច្រើននូវអយោនិសោមនសិការក្នុងធម៌ទាំងនោះ, នេះជាអាហារដើម្បីឱ្យថីនមិទ្ធៈដែលនៅមិនកើតឡើង ឬដើម្បីសេចក្ដីបរិបូណ៌ក្រៃលែងឡើង របស់ថីនមិទ្ធៈដែលកើតឡើងហើយ”[១១៩] ។

ម្យ៉ាងទៀត ការលះថីនមិទ្ធៈ រមែងមានដោយយោនិសោមនសិការក្នុងអារម្ភធាតុជាដើម ។ សេចក្ដីព្យាយាម ដែលតាំងឡើងដំបូង ឈ្មោះថា **អារម្ភធាតុ**។ សេចក្ដីព្យាយាមដែលមានកម្លាំងច្រើន ជាងអារម្ភធាតុនោះ ព្រោះកម្ចាត់សេចក្ដីខ្ជិលច្រអូសបានហើយ ឈ្មោះថា **និក្កមធាតុ**។ សេចក្ដីព្យាយាមមានកម្លាំងខ្លាំងជាងនិក្កមធាតុនោះ ព្រោះញ៉ាំញីឋានៈដទៃៗ ឈ្មោះថា **បរក្កមធាតុ**។ កាលញ៉ាំងមនសិការក្នុងសេចក្ដីព្យាយាម ៣ ប្រភេទនេះ ឱ្យប្រព្រឹត្តទៅ ឱ្យច្រើន រមែងលះថីនមិទ្ធៈបាន។ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា “ម្នាលភិក្ខុទាំងឡាយ អារព្ភធាតុ និក្កមធាតុ និងបរក្កមធាតុមាន, ការធ្វើឱ្យច្រើននូវយោនិសោមនសិការក្នុងធាតុទាំងនោះ, នេះជាអាហារដើម្បីមិនឱ្យថីនមិទ្ធៈ ដែលនៅមិនទាន់កើតឡើង មិនឱ្យកើតឡើង ឬថា ដើម្បីការលះថីនមិទ្ធៈដែលកើតឡើងហើយ”[១២០] ។

ម្យ៉ាងទៀត ធម៌ ៦ ប្រការ រមែងប្រព្រឹត្តទៅដើម្បីការលះថីនមិទ្ធៈ គឺ

---

[១១៩] ស.ម.។

[១២០] ស. ម.។

**១. អតិភោជនេ និមិត្តគ្គាហោ** កាន់យកនិមិត្តក្នុងអតិភោជន ( បរិភោគច្រើនហួសពេក) ។

**២. ឥរិយាបថសម្បរិវត្តនតា** ផ្លាស់ប្តូរឥរិយាបថឱ្យស្មើ

**៣. អាលោកសញ្ញាមនសិការោ** មនសិការក្នុងអាលោកសញ្ញា

**៤. អព្ភោកាសវាសោ** នៅកណ្តាលវាល

**៥. កល្យាណមិត្តតា** មានកល្យាណមិត្ត

**៦. សប្បាយកថា** និយាយតែពាក្យដែលជាទីសប្បាយ ។

ពិតមែន កាលបរិភោគអាហារ ដែលគួរដល់ការនាំមកនូវប្រយោជន៍ត្រឹមតែល្មមដល់សេចក្តីត្រូវការហើយ ស្លៀកដណ្តប់សំពត់សាដកដែលមានតម្លៃតិច អង្គុយនៅក្នុងទីសម្រាកវេលាថ្ងៃ ឬវេលាយប់ ធ្វើសមណធម៌ ថីនមិទ្ធៈ រមែងមកខ្ទាំងខ្ទប់ដូចជាត្រូវដំរីធំខ្ទប់ ។ កាន់យកនិមិត្តក្នុងភោជនដែលលើសថា “ក៏ភោជនដែលលើសនេះ រមែងមិនមានដល់ភិក្ខុអ្នកវៀរឱកាស (ទំនេរ) នៃពំនូតបាយ ៤-៥ ពំនូតទៀត ហើយផឹកទឹក ញុំាងអត្តភាពឱ្យប្រព្រឹត្តទៅតាមប្រក្រតី” រមែងលះថីនមិទ្ធៈបាន ។ ថីនមិទ្ធៈរមែងគ្របសង្កត់ឥរិយាបថណា កាលផ្លាស់ប្តូរឥរិយាបថដទៃពីនោះក្តី, មនសិការពន្លឺនៃព្រះចន្ទ ពន្លឺនៃប្រទីប ពន្លឺនៃភ្លើងក្នុងវេលារាត្រី និងពន្លឺនៃព្រះអាទិត្យក្នុងវេលាថ្ងៃក្តី, កាលនៅកណ្តាលវាលក្តី, កាលសេពគប់កល្យាណមិត្ត អ្នកលះថីនមិទ្ធៈដូចនឹងព្រះមហាកស្សបត្ថេរក្តី រមែងលះថីនមិទ្ធៈបាន ។ រមែងលះថីនមិទ្ធៈបាន សូម្បីដោយសប្បាយកថាដែលអាស្រ័យនូវធុតង្គក្នុងឥរិយាបថទាំងឡាយ មានការឈរ និងការអង្គុយជាដើម ។ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា **“ធម៌ទាំង ៦**

ប្រការ រមែងប្រព្រឹត្តទៅ ដើម្បីការលះថីនមិទ្ធៈ”។ ភិក្ខុនោះរមែងជ្រាបច្បាស់ថា “ក៏ថីនមិទ្ធៈដែលលះហើយ ដោយធម៌ទាំង ៦ ប្រការនេះ មិនកើតឡើងតទៅទៀតដោយអរហត្តមគ្គ” ។

ឧទ្ធច្ចកុក្កុច្ចៈកើតឡើង ព្រោះអយោនិសោមនសិការ ព្រោះសេចក្ដីមិនចូលទៅស្ងប់នៃចិត្ត ។ អាការនៃចិត្តដែលមិនចូលទៅស្ងប់ ឈ្មោះថា **អវូបសមៈ**; តែកាលពោលដោយអត្ថ ពាក្យថា **អវូបសមៈ** នេះ ក៏គឺឧទ្ធច្ចកុក្កុច្ចៈនោះឯង។ កាលញុំាងអយោនិសោមនសិការ ក្នុងឧទ្ធច្ចកុក្កុច្ចៈនោះឱ្យប្រព្រឹត្តទៅច្រើន ឧទ្ធច្ចកុក្កុច្ចៈរមែងកើតឡើង ។ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា “**ម្នាលភិក្ខុទាំងឡាយ ការមិនចូលទៅស្ងប់នៃចិត្តមាន, ការធ្វើឱ្យច្រើននូវអយោនិសោ-មនសិការក្នុងធម៌នោះ, នេះជាអាហារដើម្បីឱ្យឧទ្ធច្ចកុក្កុច្ចៈ ដែលនៅមិនទាន់កើត ឱ្យកើតឡើង ឬថា ដើម្បីសេចក្ដីបរិបូណ៌ច្រើនឡើងនៃឧទ្ធច្ចកុក្កុច្ចៈដែល កើតឡើងហើយ**” [១២១] ។

ម្យ៉ាងទៀត ការលះឧទ្ធច្ចកុក្កុច្ចៈរមែងមានដោយយោនិសោមនសិការ ព្រោះសេចក្ដីស្ងប់នៃចិត្ត **ពោលគឺសមាធិ** ។ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា “**ម្នាលភិក្ខុទាំងឡាយ ការចូលទៅស្ងប់នៃចិត្តមាន, ការធ្វើឱ្យច្រើននូវយោនិសោមនសិការក្នុងធម៌នោះ, នេះជាអាហារដើម្បីមិនឱ្យឧទ្ធច្ចកុក្កុច្ចៈដែលនៅមិនកើត ឱ្យកើតឡើង ឬថា ដើម្បីការលះឧទ្ធច្ចកុក្កុច្ចៈ ដែលកើត**

---

[១២១-១២២] ស. ម.។

ឡើងហើយ”[១២២] ។

ម្យ៉ាងទៀត ធម៌ ៦ ប្រការ រមែងប្រព្រឹត្តទៅដើម្បីលះឧទ្ធច្ចកុក្កុច្ចៈ គឺ

**១. ពហុស្សុតតា** ភាពជាពហូសូត ( បានស្តាប់ធម៌ច្រើន)

**២. បរិបុច្ឆកតា** ការសាកសួរ

**៣. វិនយេ បកតញ្ញុតា** ជំនាញក្នុងព្រះវិន័យ

**៤. វុឌ្ឍសេវិតា** សេពគប់បុគ្គលអ្នកចម្រើន

**៥. កល្យាណមិត្តតា** មានកល្យាណមិត្ត

**៦. សប្បាយកថា** និយាយតែពាក្យដែលជាទីសប្បាយ ។

ពិតមែន សូម្បីកាលរៀននូវពុទ្ធវចនៈ និងអត្ថៈ ១ និកាយ ឬថា ២-៣-៤-៥ និកាយ សូម្បីដោយការស្តាប់ច្រើន ក៏រមែងលះឧទ្ធច្ចកុក្កុច្ចៈបាន ។ ភាពជាអ្នកច្រើនដោយការសាកសួរដល់វត្ថុដែលគួរ និងមិនគួរក្តី, ភាពជាអ្នកជំនាញ ក្នុងវិនយប្បញ្ញត្តិ ព្រោះជាអ្នកមានប្រក្រតីជំនាញហើយក្តី, កាលចូលទៅរកព្រះថេរៈដែលធំ អ្នកចម្រើន ដូចព្រះឧបាលីក្តី រមែងលះឧទ្ធច្ចកុក្កុច្ចៈបាន ។ រមែងលះឧទ្ធច្ចកុក្កុច្ចៈបាន សូម្បីដោយសប្បាយកថា ដែលអាស្រ័យវត្ថុគួរ និងមិនគួរ ។ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា “ធម៌ ៦ ប្រការ រមែងប្រព្រឹត្តទៅដើម្បីការលះឧទ្ធច្ចកុក្កុច្ចៈ” ។ ភិក្ខុនោះរមែងដឹងច្បាស់ថា “ក៏ឧទ្ធច្ចៈដែលលះដោយធម៌ទាំង ៦ ប្រការនេះ មិនកើតឡើងតទៅទៀត ដោយអរហត្តមគ្គ និងកុក្កុច្ចៈដែលលះបានដោយធម៌ ៦ ប្រការនេះ មិនកើតឡើងតទៅទៀត ដោយអនាគាមិមគ្គ” ។

វិចិកិច្ឆាកើតឡើង ព្រោះអយោនិសោមនសិការ ក្នុងធម៌ទាំងឡាយដែលជាទីតាំងនៃសេចក្ដីសង្ស័យ។ វិចិកិច្ឆានោះឯង ឈ្មោះថា **ធម៌ជាទីតាំងនៃសេចក្ដីសង្ស័យ** ព្រោះជាហេតុនៃការសង្ស័យរឿយៗ។ កាលឱ្យអយោនិសោមនសិការក្នុងធម៌ដែលជាទីតាំងនៃសេចក្ដីសង្ស័យនោះប្រព្រឹត្តទៅច្រើន វិចិកិច្ឆារមែងកើតឡើង។ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា **"ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយ ដែលជាទីតាំងនៃសេចក្ដីសង្ស័យមាន, ការធ្វើឱ្យច្រើននូវអយោនិសោមនសិការក្នុងធម៌ទាំងនោះ, នេះជាអាហារដើម្បីឱ្យវិចិកិច្ឆាដែលនៅមិនកើតឡើង ឱ្យកើតឡើង ឬថា ដើម្បីសេចក្ដីបរិបូណ៌ក្រៃលែងឡើងរបស់វិចិកិច្ឆាដែលកើតឡើងហើយ"** [១២៣] ។

ម្យ៉ាងទៀត វិចិកិច្ឆានោះ លះបានដោយយោនិសោមនសិការក្នុងកុសលធម៌ជាដើម។ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា **"ម្នាលភិក្ខុទាំង-ឡាយ ធម៌ទាំងឡាយដែលជាកុសល និងអកុសល ដែលជាអទោសៈ និងទោសៈដែលគួរសេព និងមិនគួរសេព អាក្រក់ និងប្រណីត ប្រៀបដោយធម៌ខ្មៅ និងធម៌សមាន, ការធ្វើឱ្យច្រើននូវយោនិសោមនសិការក្នុងធម៌នោះ, នេះ ជាអាហារដើម្បីមិនឱ្យវិចិកិច្ឆា ដែលនៅមិនទាន់កើត មិនឱ្យកើតឡើង ឬថា ដើម្បីការលះវិចិកិច្ឆាដែលកើតហើយ"** [១២៤] ។

**ម្យ៉ាងទៀត ធម៌ ៦ ប្រការ រមែងប្រព្រឹត្តទៅដើម្បីលះវិចិកិច្ឆា គឺ**

**១. ពហុស្សុតតា** ភាពជាពហូសូត

---

[១២៣-១២៤] ស. ម. ។

**២. បរិបុច្ឆកតា** ភាពជាអ្នកសាកសួរ

**៣. វិនយេ បកតញ្ញុតា** ភាពជាអ្នកជំនាញក្នុងព្រះវិន័យ

**៤. អធិមោក្ខពហុលតា** ភាពជាអ្នកច្រើនដោយអធិមោក្ខ

**៥. កល្យាណមិត្តតា** ភាពជាអ្នកមានកល្យាណមិត្ត

**៦. សប្បាយកថា** និយាយពាក្យដែលជាទីសប្បាយ ។

ពិតមែន សូម្បីកាលរៀននូវពុទ្ធវចនៈ និងអត្ថ ១ និកាយ ឬថា ២-៣-៤-៥ និកាយ សូម្បីជាអ្នកស្តាប់ច្រើន ក៏រមែងលះវិចិកិច្ឆាបាន។ កាលប្រារព្ធព្រះរតនត្រ័យ ហើយធ្វើការសាកសួរច្រើនក្តី, ជាអ្នកជំនាញក្នុងការប្រព្រឹត្តិវិន័យក្តី, ការច្រើនដោយអធិមោក្ខ ពោលគឺសេចក្តីជឿមាំក្នុងព្រះរតនត្រ័យក្តី, ការសេពគប់កល្យាណមិត្ត ដូចព្រះថេរៈឈ្មោះ **វក្កលិ** អ្នកបង្អោនទៅដោយសទ្ធាក្តី រមែងលះវិចិកិច្ឆាបាន។ រមែងលះវិចិកិច្ឆាបាន សូម្បីដោយសប្បាយកថា ដែលអាស្រ័យគុណរបស់ព្រះរតនត្រ័យ ក្នុងតិរិយាបថទាំងឡាយ មានការឈរ និងអង្គុយជាដើម។ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា "ធម៌ ៦ ប្រការ **រមែងប្រព្រឹត្តទៅដើម្បីលះវិចិកិច្ឆា**" ។ ភិក្ខុនោះរមែងដឹងច្បាស់ថា "ក៏វិចិកិច្ឆាដែលលះបានដោយធម៌ ៦ ប្រការនេះ មិនកើតឡើងតទៅទៀត ដោយសោតាបត្តិមគ្គ" ៕

**ចប់អដ្ឋកថានីវរណបព្វៈ**

## អដ្ឋកថាពោជ្ឈង្គបព្វ
## សតិសម្ពោជ្ឈង្គ

ក្នុងពោជ្ឈង្គបព្វ ពាក្យថា **“សន្តំ”** បានដល់ មានដោយអំណាចនៃការបានចំពោះ។ ពាក្យថា **“អសន្តំ”** បានដល់ មិនមានដោយអំណាចនៃការមិនបាន។ ក៏ក្នុងពាក្យថា **“យថា ច អនុប្បន្នស្ស”** ជាដើម គប្បីជ្រាបសេចក្តីកើតឡើងនៃសតិសម្ពោជ្ឈង្គជាមុន យ៉ាងនេះថា **“ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយដែលជាទីតាំងនៃសតិសម្ពោជ្ឈង្គមាន, ការធ្វើឱ្យច្រើននូវយោនិសោមនសិការក្នុងធម៌ទាំងនោះ, នេះជាអាហារដើម្បីការកើតឡើងនៃសតិសម្ពោជ្ឈង្គដែលនៅមិនទាន់កើតឡើង ឱ្យកើតឡើង ឬថា រមែងប្រព្រឹត្តទៅដើម្បីសេចក្តីលូតលាស់ បរិបូណ៌ក្រៃលែងឡើង របស់សតិសម្ពោជ្ឈង្គ ដែលកើតឡើងហើយ”**[១២៥] ។

បណ្តាពាក្យទាំងនោះ សតិនោះឯង ឈ្មោះថា **ធម៌ដែលជាទីតាំងនៃសតិសម្ពោជ្ឈង្គ**។ យោនិសោមនសិការមានលក្ខណៈ ដូចដែលពោលហើយនោះឯង។ កាលញុំាងមនសិការឱ្យប្រព្រឹត្តទៅច្រើន ក្នុងធម៌ដែលជាទីតាំងនាំឱ្យកើតឡើង នៃសតិសម្ពោជ្ឈង្គនោះ សតិសម្ពោជ្ឈង្គរមែងកើតឡើង ។

ម្យ៉ាងទៀត **ធម៌ ៤ ប្រការ រមែងប្រព្រឹត្តទៅដើម្បីការកើតឡើងនៃសតិសម្ពោជ្ឈង្គ គឺ**

---

[១២៥] ស. ម.។

**១. សតិសម្បជញ្ញំ** សតិសម្បជញ្ញៈ

**២. មុដ្ឋស្សតិបុគ្គលបរិវជ្ជនតា** វៀរចាកបុគ្គលអ្នកវង្វេងភ្លេចសតិ

**៣. ឧបដ្ឋិតស្សតិបុគ្គលសេវនតា** សេពគប់បុគ្គលអ្នកមានសតិតាំងមាំ

**៤. តទធិមុត្តតា** បង្អោនចិត្តទៅក្នុងសតិសម្ពោជ្ឈង្គនោះ ។

ពិតមែន សតិសម្ពោជ្ឈង្គ រមែងកើតឡើងដោយសតិសម្បជញ្ញៈ ក្នុងឋាន ទាំង ៧ មានការឈានទៅខាងមុខជាដើម, ដោយវៀរបុគ្គលអ្នកភ្លេចសតិ ដូចក្នុង រឿងភ្នាក់ងារចាំឃ្លាំងបាយ, ដោយការសេពគប់បុគ្គលអ្នកមានសតិតាំងមាំ ដូចនឹង ព្រះតិស្សទត្តត្ថេរ និងព្រះអភយត្ថេរ, និងដោយភាពជាអ្នកមានចិត្តបង្អោនទៅ ឱន ទៅ ទេរទៅ ដើម្បីឱ្យសតិកើតឡើងក្នុងឥរិយាបថទាំងឡាយ មានការឈរ និង អង្គុយជាដើម។ ភិក្ខុនោះរមែងដឹងច្បាស់ថា “ក៏ភាវនារបស់លោកដែលកើតឡើង ដោយហេតុ ៤ យ៉ាងនេះ រមែងបរិបូណ៌ដោយអរហត្តមគ្គ” ៕

## ធម្មវិចយសម្ពោជ្ឈង្គ

ក៏ធម្មវិចយសម្ពោជ្ឈង្គ កើតឡើងយ៉ាងនេះថា “ម្នាលភិក្ខុទាំងឡាយ ធម៌ ទាំងឡាយដែលជាកុសល និងអកុសល ។ល ។ ដែលប្រៀបដោយធម៌ខ្មៅ និងធម៌ សមាន, ការធ្វើឱ្យច្រើននូវយោនិសោមនសិការក្នុងធម៌នោះ, នេះជាអាហារដើម្បី ការកើតឡើងនៃធម្មវិចយសម្ពោជ្ឈង្គដែលនៅមិនកើតឡើង ឱ្យកើតឡើង ឬថា រមែងប្រព្រឹត្តទៅព្រមដើម្បីការចម្រើនលូតលាស់ បរិបូណ៌ក្រៃលែងឡើង នៃធម្ម-

វិចយសម្ពោជ្ឈង្គដែលកើតឡើងហើយ”[១២៦] ។

ម្យ៉ាងទៀត ធម៌ ៧ ប្រការ រមែងប្រព្រឹត្តទៅដើម្បីសេចក្តីកើតឡើងនៃធម្មវិចយសម្ពោជ្ឈង្គ គឺ

| | |
|---|---|
| **១. បរិបុច្ឆកតា** | ការសាកសួរ |
| **២. វត្ថុវិសទកិរិយា** | ការធ្វើវត្ថុឱ្យស្អាត |
| **៣. ឥន្ទ្រិយសម្មត្តបដិបាទនា** | ការធ្វើឥន្ទ្រិយឱ្យស្មើគ្នា |
| **៤. ទុប្បញ្ញបុគ្គលបរិវជ្ជនា** | ការវៀរចាកបុគ្គលមានបញ្ញាអន់ |
| **៥. បញ្ញវន្តបុគ្គលសេវនា** | ការសេពគប់បុគ្គលអ្នកមានបញ្ញា |
| **៦. គម្ភីរញ្ញាណចរិយបច្ចវេក្ខណា** | ពិចារណាទៅដោយញាណដ៏ជ្រាលជ្រៅ |
| **៧. តទធិមុត្តតា** | បង្អោនចិត្តទៅក្នុងធម្មវិចយៈនោះ ។ |

បណ្តាធម៌ទាំងនោះ បទថា **“ការសាកសួរ”** បានដល់ ភាពជាអ្នកច្រើនដោយការសាកសួរដែលអាស្រ័យអត្ថនៃខន្ធ ធាតុ អាយតនៈ ឥន្ទ្រិយ ពលៈ ពោជ្ឈង្គ អង្គមគ្គ ឈាន សមថៈ និងវិបស្សនា ។

បទថា **“ការធ្វើវត្ថុឱ្យស្អាត”** បានដល់ ការធ្វើវត្ថុទាំងខាងក្នុង និងខាងក្រៅឱ្យស្អាត ។ ព្រោះថា កាលណា សក់ ក្រចក និងរោមទាំងឡាយ របស់លោកវែង, ឬថា រាងកាយរបស់លោកមានទោសច្រើន ប្រឡាក់ដោយក្អែល, កាលនោះ ឈ្មោះថា វត្ថុខាងក្នុង មិនស្អាត មិនបរិសុទ្ធ ។ ក៏កាលណា ចីវររបស់លោកចាស់

[១២៦] ស. ម. ។

គ្រាំគ្រា មានក្លិនស្អុយ, ឬថា សេនាសនៈរបស់លោកស្មោកគ្រោកប្រឡាក់ប្រឡូស, កាលនោះ ឈ្មោះថា វត្ថុខាងក្រៅមិនស្អាត មិនបរិសុទ្ធ ។ ព្រោះហេតុនោះ លោកគប្បីធ្វើវត្ថុខាងក្នុងឱ្យស្អាត ដោយការកោរសក់ជាដើមផង ដោយការធ្វើសរីរៈឱ្យស្រាល ដោយការជម្រះខាងលើ (សិរសៈ) ជម្រះខាងក្រោម (ការបន្ទោបង់លាមកជាដើម) ផង ដោយការងូតទឹកដុសលាងរាងកាយផង ។ គប្បីធ្វើវត្ថុខាងក្រៅមានការដេរ បោកគក់ និងការជ្រលក់របស់ប្រើប្រាស់ឱ្យស្អាត, ព្រោះថា វត្ថុខាងក្នុង និងខាងក្រៅយ៉ាងណាមួយមិនស្អាត សូម្បីញាណល្អក្នុងចិត្ត និងចេតសិកដែលល្អ ក៏មិនជាក់ច្បាស់ មិនបរិសុទ្ធ ប្រៀបដូចពន្លឺរបស់អណ្តាតភ្លើងដែលកើតឡើង ព្រោះអាស្រ័យប្រឆេះ និងប្រេងនៃចង្កៀងដូច្នោះ ។ តែកាលវត្ថុខាងក្នុង និងខាងក្រៅស្អាត ញាណល្អក្នុងចិត្ត និងចេតសិកដែលល្អ ក៏ជាក់ច្បាស់ បរិសុទ្ធ ប្រៀបដូចពន្លឺនៃអណ្តាតភ្លើងដែលកើតឡើង ព្រោះអាស្រ័យប្រឆេះ និងប្រេងក្នុងចង្កៀងដូច្នោះ ។ ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា **“ការធ្វើវត្ថុឱ្យស្អាត រមែងប្រព្រឹត្តទៅព្រមដើម្បីការកើតឡើងនៃធម្មវិចយសម្ពោជ្ឈង្គ”** ។

ការធ្វើឥន្ទ្រិយទាំងឡាយ មានសទ្ធិន្ទ្រិយជាដើមឱ្យស្មើគ្នា ឈ្មោះថា **ការធ្វើឥន្ទ្រិយឱ្យស្មើគ្នា** ។ ក៏បើថា សទ្ធិន្ទ្រិយរបស់លោកក្លៀវក្លា, **ឥន្ទ្រិយក្រៅនេះខ្សោយសោត,** ពេលនោះវីរិយិន្ទ្រិយមិនអាចធ្វើនាទី គឺការផ្គងព្យាយាម = **បគ្គហកិច្ច**, សតិន្ទ្រិយ ក៏មិនអាចធ្វើនាទី គឺការតាំងមាំ = **ឧបដ្ឋានកិច្ច**, សមាធិន្ទ្រិយក៏មិនអាចធ្វើនាទី គឺការមិនរវើរវាយ = **អវិក្ខេបនកិច្ច**, បញ្ញិន្ទ្រិយក៏មិនអាចធ្វើនាទី គឺការឃើញ = **ទស្សនកិច្ច**, ព្រោះហេតុនោះ **សទ្ធិន្ទ្រិយមានកម្លាំងខ្លាំង**

**ក៏គប្បីធ្វើឱ្យថយចុះ ដោយការពិចារណាសភាវធម៌**, ឬថា កាលមនសិការដោយប្រការណា សទ្ធិន្ទ្រិយមានកម្លាំង, ក៏គប្បីឱ្យថយចុះដោយមិនមនសិការដោយប្រការនោះ ។ ក្នុងសេចក្តីនេះ មានរឿងព្រះវក្កលិត្ថេរជាឧទាហរណ៍ ។ ក៏បើថា វីរិយិន្ទ្រិយមានកម្លាំងនោះ, ពេលនោះ សទ្ធិន្ទ្រិយក៏មិនធ្វើនាទី គឺបង្អោនចិត្តជឿ = **អធិមោក្ខកិច្ច**, ឥន្ទ្រិយ ក្រៅពីនោះ ក៏មិនអាចធ្វើនាទីដែលផ្សេងដោយនាទីក្រៅពីនេះ (គឺមិនធ្វើនាទីរបស់ខ្លួនៗ), ព្រោះហេតុនោះ គប្បីឱ្យវីរិយិន្ទ្រិយនោះថយចុះ ដោយការចម្រើនបស្សទ្ធិសម្ពោជ្ឈង្គជាដើម ។ សូម្បីក្នុងសេចក្តីនេះ គប្បីសម្តែងរឿងរបស់ព្រះសោណត្ថេរជានិទស្សន៍ ។ សូម្បីឥន្ទ្រិយដែលនៅសល់ ក៏ដូច្នោះដែរ គឺកាលឥន្ទ្រិយណាមួយមានកម្លាំង ក៏គប្បីជ្រាបថា ឥន្ទ្រិយក្រៅពីនេះ មិនអាចធ្វើនាទីដែលគួរធ្វើរបស់ខ្លួនបានឡើយ ។

ក៏ពោលដោយពិសេសក្នុងទីនេះ បណ្ឌិតទាំងឡាយសរសើរសេចក្តីស្មើគ្នានៃសទ្ធាជាមួយនឹងបញ្ញា និងសមាធិជាមួយនឹងវីរិយៈ; ព្រោះថា បុគ្គលមានសទ្ធាក្លៀវក្លា តែបញ្ញាខ្សោយ រមែងជាអ្នកជ្រះថ្លាក្នុងវត្ថុដែលមិនមែនវត្ថុ (វត្ថុ គឺព្រះរតនត្រ័យ) ។ បុគ្គលមានបញ្ញាក្លៀវក្លា តែសទ្ធាខ្សោយ រមែងសេពគប់ពួកមនុស្សកោង រមែងជាអ្នកកែខៃមិនបាន ដូចជារោគដ៏ខ្លាំង ដែលកើតពីថ្នាំរក្សាមិនបានល្អដូច្នោះ; គឺមានត្រឹមតែថាចិត្តុប្បាទនោះឯង ត្រាច់ទៅជាកុសល តែមិនធ្វើបុណ្យទាំងឡាយមានទានជាដើម រមែងកើតក្នុងនរក ។ តែព្រោះសេចក្តីដែលឥន្ទ្រិយទាំងពីរស្មើគ្នា ទើបគេជ្រះថ្លាក្នុងវត្ថុ (គឺព្រះរតនត្រ័យ) មែនពិត ។ម្យ៉ាងទៀត កោសជ្ជៈរមែងគ្របសង្កត់បុគ្គលអ្នកមានសមាធិខ្លាំង វីរិយៈខ្សោយ ព្រោះសេចក្តីដែលសមាធិ

ជាបក្សពួកនៃកោសជ្ជៈ ។ ឧទ្ធច្ចៈរមែងគ្របសង្កត់បុគ្គលអ្នកមានវីរិយៈ ខ្លាំងមានសមាធិខ្សោយ ព្រោះសេចក្តីដែលវីរិយៈជាផ្នែក (បក្សពួក) នៃឧទ្ធច្ចៈ ។ តែសមាធិដែលវីរិយៈប្រកបល្អហើយ រមែងមិនបានដើម្បីធ្លាក់ទៅក្នុងកោសជ្ជៈ, វីរិយៈដែលសមាធិប្រកបល្អហើយ រមែងមិនបានដើម្បីធ្លាក់ទៅក្នុងឧទ្ធច្ចៈ; ព្រោះហេតុនោះព្រះយោគាវចរគប្បីធ្វើឥន្ទ្រិយ សូម្បីទាំងពីរនោះ ឱ្យស្មើគ្នា ព្រោះថាអប្បនារមែងកើតឡើង ព្រោះភាពស្មើគ្នានៃឥន្ទ្រិយនោះ ។

ម្យ៉ាងទៀត សូម្បីសទ្ធាមានកម្លាំង ក៏គួរសម្រាប់សមាធិកម្មិកបុគ្គល (អ្នកបំពេញសមាធិ) គឺកាលបុគ្គលនោះ ជឿមាំយ៉ាងនោះ នឹងសម្រេចអប្បនាបាន ។ តែក្នុងសមាធិ និងបញ្ញា ឯកគ្គតាមានកម្លាំង ទើបគួរដល់សមាធិកម្មិកបុគ្គល; ព្រោះគេនឹងសម្រេចអប្បនាបាន ដោយអាការយ៉ាងនោះ ។ ក៏សម្រាប់វិបស្សនាកម្មិកបុគ្គល (អ្នកបំពេញវិបស្សនា) បញ្ញាមានកម្លាំងទើបគួរ; ព្រោះគេនឹងដល់ការចាក់ធ្លុះលក្ខណៈបានដោយអាការយ៉ាងនោះ ។ តែព្រោះសមាធិ និងបញ្ញាទាំងពីរស្មើគ្នា ទើបអប្បនាមានបានដោយពិត ។ ចំណែកសតិមានកម្លាំងក្នុងទីទាំងពួង ទើបគួរ; ព្រោះថា សតិរមែងរក្សាចិត្តមិនឱ្យធ្លាក់ទៅកាន់ឧទ្ធច្ចៈ ព្រោះអំណាចនៃសទ្ធា វីរិយៈ និងបញ្ញា ជាពួកនៃឧទ្ធច្ចៈ និងរក្សាចិត្តមិនឱ្យធ្លាក់ទៅក្នុងកោសជ្ជៈ ព្រោះសមាធិជាពួកនៃកោសជ្ជៈ ។ ព្រោះហេតុនោះ សតិនោះព្រះយោគាវចរគប្បីប្រាថ្នាក្នុងទីទាំងពួង, ដូចការផ្សំរសជាតិ ដោយអំបិលក្នុងម្ហូបទាំងពួង និងដូចអាមាត្យអ្នកធ្វើការងារក្នុងរាជកិច្ចទាំងពួង ។ ព្រោះហេតុនោះ ទើបពោលថា “ក៏សតិនោះឯង ព្រះមានព្រះភាគត្រាស់ថា **ជាគុណធម៌ត្រូវប្រាថ្នាក្នុងទីទាំងពួង**” ។ ព្រោះហេតុអ្វី ?

ព្រោះចិត្តមានសតិជាទីពឹង និងមានសតិជាគ្រឿងថែរក្សា; វៀរចាកសតិហើយ ការលើក និងការសង្កត់ចិត្ត ក៏មិនមានឡើយ" ។

ការវៀរចាកបុគ្គលអ្នកមានបញ្ញាមិនល្អ គឺមិនមានបញ្ញាដែលចាក់ធ្លុះ (ឈានចុះ) ក្នុងប្រភេទនៃខន្ធជាដើម ឈ្មោះថា **វៀរចាកបុគ្គលអ្នកមានបញ្ញាខ្សោយ**។ ការសេពគប់បុគ្គលអ្នកប្រកបដោយឧទយព្វយប្បញ្ញា ដែលកំណត់យកនូវលក្ខណៈនៃបញ្ញាល្អ ឈ្មោះថា **សេពគប់បុគ្គលអ្នកមានបញ្ញា**។ ការពិចារណាប្រភេទនៃធម៌ដ៏ជ្រាលជ្រៅ ប្រព្រឹត្តទៅក្នុងខន្ធជាដើម ដោយបញ្ញាដ៏ជ្រាលជ្រៅ ឈ្មោះថា ការពិចារណាដំណើរទៅដោយញាណដ៏ជ្រាលជ្រៅ ។ ភាពជាអ្នកមានចិត្តបង្អោនទៅ ឱនទៅ ទោរទៅ ដើម្បីញ៉ាំងធម្មវិចយសម្ពោជ្ឈង្គ ឱ្យកើតឡើងក្នុងឥរិយាបថទាំងឡាយ មានការឈរ និងអង្គុយជាដើម ឈ្មោះថា បង្អោនចិត្តទៅក្នុងធម្មវិចយសម្ពោជ្ឈង្គនោះ ។ ភិក្ខុនោះរមែងដឹងច្បាស់ថា "ក៏ភាវនារបស់លោកដែលកើតឡើងដោយអាការយ៉ាងនេះ រមែងបរិបូរណ៏ដោយអរហត្តមគ្គ" ៕

## វីរិយសម្ពោជ្ឈង្គ

វីរិយសម្ពោជ្ឈង្គ រមែងកើតឡើងយ៉ាងនេះថា "ម្នាលភិក្ខុទាំងឡាយ **អារព្ភធាតុ និក្កមធាតុ បរក្កមធាតុមាន**, ការធ្វើឱ្យច្រើនឡើងនូវយោនិសោមនសិការ ក្នុងធាតុទាំងនេះ, នេះជាអាហារដើម្បីឱ្យវីរិយសម្ពោជ្ឈង្គ ដែលនៅមិនទាន់កើត ឱ្យកើតឡើង ឬថា រមែងប្រព្រឹត្តទៅព្រមដើម្បីការចម្រើនបរិបូណ៏ក្រៃលែង

ឡើង របស់វីរិយសម្ពោជ្ឈង្គដែលកើតឡើងហើយ”[១២៧] ។

ម្យ៉ាងទៀត ធម៌ ១១ ប្រការ រមែងប្រព្រឹត្តទៅដើម្បីការកើតឡើងនៃវីរិយសម្ពោជ្ឈង្គ គឺ

| | |
|---|---|
| **១. អបាយភយបច្ចវេក្ខណតា** | ពិចារណាភ័យក្នុងអបាយ |
| **២. អានិសំសទស្សាវិតា** | ឃើញអានិសង្សនៃសេចក្តីព្យាយាម |
| **៣. គមនវីថិបច្ចវេក្ខណតា** | ពិចារណាវីថិជាទីដំណើរទៅ |
| **៤. បិណ្ឌបាតាបចាយនតា** | ប្រព្រឹត្តអើពើចំពោះបិណ្ឌបាត |
| **៥. ទាយជ្ជមហត្តបច្ចវេក្ខណតា** | ពិចារណាភាពជាធំក្រៃលែងនៃទាយាទ |
| **៦. សត្ថុមហត្តបច្ចវេក្ខណតា** | ពិចារណាភាពជាធំក្រៃលែងនៃព្រះសាស្តា |
| **៧. ជាតិមហត្តបច្ចវេក្ខណតា** | ពិចាណាភាពជាធំក្រៃលែងនៃជាតិ |
| **៨. សព្រហ្មចារិមហត្តបច្ចវេក្ខណតា** | ពិចារណានូវភាពជាធំក្រៃលែងនៃសព្រហ្មចារី ។ |
| **៩. កុសីតបុគ្គលបរិវជ្ជនតា** | វៀរចាកបុគ្គលខ្ជិលច្រអូស |
| **១០. អារទ្ធវីរិយបុគ្គលសេវនតា** | សេពគប់ជាមួយនឹងបុគ្គលដែលជាអ្នកមានព្យាយាមផ្តើមហើយ ។ |
| **១១. តទធិមុត្តតា** | បង្អោនចិត្តទៅក្នុងវីរិយៈនោះ ។ |

ក្នុងសេចក្តីនេះ វីរិយសម្ពោជ្ឈង្គរមែងកើតឡើង សូម្បីដល់អ្នកពិចារណានូវ

[១២៧] សំ. ម.។

ភ័យក្នុងអបាយយ៉ាងនេះថា “ក្នុងគ្រាដែលសោយទុក្ខធំ ចាប់ផ្តើមអំពីទារុណកម្ម ដោយគ្រឿងចង ៥ យ៉ាង ក្នុងនរកក៏ដោយ, ក្នុងគ្រាដែលចាប់ដោយសំណាញ់គ្រឿង បោះទៅ និងទ្រុងទ្រូជាដើម ក្នុងកំណើតតិរច្ឆានក៏ដោយ, ក្នុងគ្រាជាសត្វនាំរទេះទៅ ត្រូវគេទីមចាក់ដោយគ្រឿងប្រហារមានភ្នាក់ និងបន្លាស្រួចជាដើម ក៏ដោយ, ក្នុង គ្រាដែលជាអ្នកគួរអាណិតដោយសេចក្តីស្រេកឃ្លាន រហូតដល់រាប់ពាន់ឆ្នាំជាអនេក ខ្លះ រហូតដល់ ១ ពុទ្ធន្តរខ្លះ ក៏ដោយ, ក្នុងគ្រាដែលសោយទុក្ខ មានខ្យល់កំដៅថ្ងៃ ជាដើម ដោយអត្តភាពមានត្រឹមតែឆ្អឹង និងស្បែក មានអត្តភាពធំប្រមាណ ១០ ហត្ថ ៨០ ហត្ថ ក្នុងពួកអសុរឈ្មោះកាឡកញ្ជិកាក៏ដោយ មិនអាចដើម្បីឱ្យវីរិយ-សម្ពោជ្ឈង្គកើតបាន, ម្នាលភិក្ខុ កាលនេះឯង ជាកាលសមគួររបស់អ្នកដើម្បីធ្វើ សេចក្តីព្យាយាម” ។

វីរិយសម្ពោជ្ឈង្គរមែងកើតឡើង សូម្បីដល់អ្នកពិចារណាឃើញអានិសង្ស យ៉ាងនេះថា “អ្នកខ្ជិលច្រអូសមិនអាចបានលោកុត្តរធម៌ ៩,អ្នកមានសេចក្តីព្យាយាម ប្រារព្ធហើយប៉ុណ្ណោះ អាចដើម្បីបាន, នេះជាអានិសង្សរបស់សេចក្តីព្យាយាម” ។

វីរិយសម្ពោជ្ឈង្គ រមែងកើតឡើងសូម្បីដល់អ្នកពិចារណា វីថិនៃដំណើរទៅ យ៉ាងនេះថា “ព្រះយោគាវចរនោះ គប្បីដើរទៅតាមផ្លូវដែលព្រះពុទ្ធ ព្រះបច្ចេក-ពុទ្ធ និងព្រះមហាសាវកទាំងឡាយ របស់ព្រះពុទ្ធដើរទៅហើយនុ៎ះឯង, ព្រោះផ្លូវ នេះ អ្នកខ្ជិលមិនអាចធ្វើដំណើរទៅបានទេ” ។

វីរិយសម្ពោជ្ឈង្គ រមែងកើតឡើង សូម្បីដល់អ្នកពិចារណា ប្រព្រឹត្តអើពើ ចំពោះបិណ្ឌបាត យ៉ាងនេះថា “ជនពួកណា រមែងទំនុកបម្រុងលោកដោយបិណ្ឌ-

បាតជាដើម, មនុស្សទាំងនោះ មិនមែនញាតិ, មិនមែនទាសកម្មកររបស់លោក, ទាំងមិនបានឱ្យបិណ្ឌបាតជាដើម ដែលប្រណីតដល់លោក ដោយគិតថា “ពួកយើងអាស្រ័យលោកហើយរស់នៅ” , តាមពិត គេប្រាថ្នានូវផលដ៏ធំនៃការធ្វើរបស់ខ្លួនទើបឱ្យ; សូម្បីព្រះសាស្តាក៏មិនទ្រង់អនុញ្ញាតបច្ច័យទាំងឡាយដល់លោក ព្រោះពិចារណាឃើញយ៉ាងនេះថា “ភិក្ខុនេះបរិភោគបច្ច័យទាំងនេះហើយ ជាអ្នកមានរាងកាយរឹងមាំនៅជាសុខ” , តាមពិត ទ្រង់អនុញ្ញាតបច្ច័យទាំងឡាយដល់លោក ដោយទ្រង់ប្រាថ្នាថា “ភិក្ខុនេះបរិភោគបច្ច័យទាំងនេះហើយ ធ្វើសមណធម៌នឹងរួចផុតពីវដ្តទុក្ខ” ; ឥឡូវនេះ លោកឯងខ្ជិល មិនប្រព្រឹត្តអើពើចំពោះបិណ្ឌបាតនោះ; ព្រោះភិក្ខុអ្នកមានសេចក្តីព្យាយាមផ្តើមហើយប៉ុណ្ណោះ ឈ្មោះថា មានការប្រព្រឹត្តអើពើចំពោះបិណ្ឌបាត”; ក្នុងសេចក្តីនេះ មានរឿងព្រះថេរៈឈ្មោះថា **មហាមិត្ត** ជានិទស្សន៍ ៖

បានឮថា ព្រះថេរៈអាស្រ័យនៅក្នុងល្អាង (ទីកំបាំង) របស់អ្នកស្រែ; ក៏ក្នុងភូមិជាទីគោចររបស់លោក មានមហាឧបាសិកាម្នាក់ បដិបត្តិទំនុកបម្រុងព្រះថេរៈដូចជាបុត្រ; ថ្ងៃមួយ ឧបាសិកានោះ កាលនឹងទៅព្រៃ ទើបបញ្ជាធីតាថា “កូនម៉ែ អង្ករចាស់នៅក្នុងទីឯណោះ ទឹកដោះជូរ, ទឹកដោះថ្លា, ស្ករអំពៅនៅត្រង់ទីឯណោះ, កូនចូរដាំបាយព្រមទាំងទឹកដោះជូរ ទឹកដោះថ្លា និងស្ករអំពៅ ថ្វាយក្នុងវេលាដែលលោកម្ចាស់មហាមិត្តបងប្រុសរបស់កូនមកហើយកូនចូរបរិភោគចុះ” , ធីតាពោលថា “ចុះម៉ែវិញ នឹងបរិភោគអ្វី” ឧបាសិកាពោលថា “ម្សិលមិញនេះ បារិវាសិកភត្ត (គឺបាយដែលដាំសម្រាប់ភិក្ខុអ្នកនៅបរិវាស) នៅសល់ ម៉ែនឹងបរិភោគបាយ

នោះជាមួយនឹងទឹកជ្រក់” ធីតាពោលថា “ពេលថ្ងៃ ម៉ែនឹងបរិភោគអ្វី” មាតាពោលថា “កូនចូរយកស្លឹកបន្លែដាក់ចូលទៅ ហើយដាំបបរមានរសជូរដោយកញ្ចុំងអង្ករ ហើយតាំងទុកឱ្យម៉ែចុះ”។ ព្រះថេរៈដណ្តប់ចីវរនាំបាត្រចេញមក បានឮសំឡេងនោះ ទើបទូន្មានខ្លួនឯងថា “បានឮថា មហាឧបាសិកានឹងបរិភោគបារិវាសិកភត្តដោយទឹកជ្រក់ សូម្បីថ្ងៃត្រង់ ក៏នឹងបរិភោគបបរមានរសជូរដោយស្លឹកបន្លែ, តែថា ឧបាសិកាប្រាប់អង្ករចាស់ជាដើម ដើម្បីប្រយោជន៍ដល់អាត្មាអញ; ក៏មហាឧបាសិកានេះឯង មិនបានប្រាថ្នាស្រែ សួន អង្ករ និងវត្ថុ ព្រោះអាស្រ័យអាត្មាអញទេ តែគាត់ប្រាថ្នានូវសម្បត្តិ ៣ (គឺមនុស្សសម្បត្តិ សួគ៌សម្បត្តិ និងនិព្វានសម្បត្តិ) ទើបឱ្យ; អាត្មាអញអាចដើម្បីឱ្យសម្បត្តិទាំងនោះដល់គាត់ឬទេ; ក៏ឯបិណ្ឌបាតនេះអាត្មាអញនៅមានរាគៈ ទោសៈ និងមោហៈ មិនគួរឆាន់ទេ”, គ្រាទូន្មានហើយក៏ទុកបាត្រក្នុងថង់យាម ដោះក្ដុំចីវរ ត្រឡប់ចូលកាន់ល្អាងអ្នកស្រែនោះឯង ហើយដាក់បាត្រក្រោមគ្រែ ពាក់ចីវរទុកត្រង់ស្នូចីវរ ហើយអង្គុយអធិដ្ឋានសេចក្ដីព្យាយាមថា “យើងនៅមិនសម្រេចអរហត្តហើយ នឹងមិនចេញទៅ”; ជាអ្នកមិនប្រមាទរហូតអស់កាលយូរ ជាភិក្ខុមាំទាំ ហើយចម្រើនវិបស្សនា សម្រេចអរហត្តក្នុងវេលាមុនភត្តមែនពិត ជាខីណាស្រព អង្គុយញញឹម ដូចផ្កាបទុមរីកដូច្នោះ។ ទេវតាអ្នកឋិតនៅត្រង់ដើមឈើ ជិតទ្វារល្អាងអ្នកស្រែថ្លែងឧទានថា៖

**“បពិត្របុរសអាជានេយ្យ ខ្ញុំម្ចាស់សូមនមស្ការលោក, បពិត្របុរសឧត្តមបំផុត ខ្ញុំសូមនមស្ការលោក បពិត្រលោកអ្នកនិរទុក្ខ អ្នកណាអស់អាសវៈហើយ អ្នកនោះ ជាទក្ខិណេយ្យបុគ្គល”** ។

ហើយពោលថា "បពិត្រលោកម្ចាស់ដ៏ចម្រើន ស្ត្រីចាស់ថ្វាយភិក្ខាដល់ព្រះអរហន្ត ដូចលោកដែលចូលទៅដើម្បីបិណ្ឌបាតនឹងផុតចាកទុក្ខ"។ ព្រះថេរៈក្រោកឡើងហើយបើកទ្វារចេញទៅ មើលវេលាដឹងថា នៅព្រឹក ទើបកាន់បាត្រ និងចីវរចូលទៅកាន់ភូមិ។ សូម្បីទារិកាត្រៀមអាហារស្រេចហើយ ក៏បើកទ្វារអង្គុយចាំមើល ដោយគិតថា "ឥឡូវនេះ បងប្រុសយើងនឹងមក១" កាលព្រះថេរៈមកដល់ទ្វារផ្ទះ ទើបទារិកានោះទទួលបាត្រហើយ ដាក់ឱ្យពេញដោយបាយលាយដោយទឹកដោះជូរ ផ្សំជាមួយទឹកដោះថ្លា និងស្ករអំពៅ ហើយទើបដាក់ទុកលើដៃរបស់ព្រះថេរៈ; ព្រះថេរៈធ្វើអនុមោទនាថា "ចូររស់នៅជាសុខចុះ" ហើយជៀសចេញទៅ សូម្បីទារិការនោះ ក៏ឈរក្រឡេកមើលព្រះថេរៈនោះ; ក្នុងវេលានោះ ពណ៌សម្បុររបស់ព្រះថេរៈបរិសុទ្ធល្អក្រៃលែងណាស់, ឥន្ទ្រិយទាំងឡាយ ផូរផង់រុងរឿងក្រៃលែង, ដូចជាផ្លែត្នោតទុំដែលជ្រុះពីទងដូច្នោះ ។ មហាឧបាសិកាត្រឡប់មកពីព្រៃវិញ ទើបសួរថា "កូនម៉ែ បងប្រុសរបស់ឯង មកហើយឬ" ធីតានោះ បានប្រាប់ការប្រព្រឹត្តទៅទាំងឡាយនោះ; មហាឧបាសិកាដឹងថា ថ្ងៃនេះ កិច្ចបព្វជិតនៃបុត្តរបស់យើងដល់ទីបំផុតហើយ ទើបពោលថា "កូនម៉ែ បងប្រុសរបស់កូន នឹងមិនអផ្សុករសាប់-រសល់ ក្នុងព្រះពុទ្ធសាសនាទេ" ។

វីរិយសម្ពោជ្ឈង្គរមែងកើតឡើង សូម្បីដល់អ្នកពិចារណានូវភាពជាធំក្រៃ-លែងនៃអ្នកជាទាយាទ (គឺអ្នកទទួលមរតក) ថា ឈ្មោះថា **មរតករបស់ព្រះសាស្តាគឺអរិយទ្រព្យនោះ ធំក្រៃលែងណាស់**, មរតកនោះដែលអ្នកខ្ជិលមិនអាចដើម្បីបាន ដូចយ៉ាងថា មាតាបិតាធ្វើបុត្រដែលបដិបត្តិខុស ឱ្យមានខាងក្រៅ (កាត់ការ

ចោល) ថា **"អ្នកនេះ មិនមែនបុត្ររបស់យើង"** ដូច្នេះ បុត្រនោះរមែងមិនបាន មរតកដោយកាលដែលកន្លង (ស្លាប់) ទៅនៃមាតាបិតា យ៉ាងណា, សូម្បីអ្នកខ្ជិល ក៏ដូច្នោះដែរ រមែងមិនបានមរតក គឺអរិយទ្រព្យនេះ, អ្នកមានសេចក្ដីព្យាយាម ដែលប្រារព្ធហើយនោះឯង ទើបបាន" ។

វីរិយសម្ពោជ្ឈង្គរមែងកើតឡើង **សូម្បីដល់អ្នកពិចារណាភាពជាធំក្រៃ-លែងរបស់ព្រះសាស្ដា** យ៉ាងនេះ ក៏ព្រះសាស្ដារបស់លោកធំក្រៃលែងណាស់ សូម្បីហ្មឺនលោកធាតុ ក៏ញាប់ញ័រ ក្នុងវេលាដែលព្រះសាស្ដារបស់លោក ទ្រង់ចាប់បដិសន្ធិក្នុងគភ៌ព្រះមាតា សូម្បីក្នុងវេលាទ្រង់ចេញព្រះផ្នួស សូម្បីក្នុងវេលាត្រាស់ដឹង ក្នុងវេលាទ្រង់សម្ដែងធម្មចក្ក ក្នុងវេលាធ្វើយមកប្បាដិហារិយ៍ ក្នុងកាលយាងចុះចាកទេវលោក ក្នុងកាលដាក់ព្រះជន្មាយុសង្ខារ សូម្បីក្នុងកាលបរិនិព្វាននោះ ហ្មឺនលោកធាតុក៏ញាប់ញ័រ, ការដែលលោកបួសក្នុងសាសនារបស់ព្រះសាស្ដា ប្រាកដដូច្នេះហើយ ជាអ្នកខ្ជិលច្រអូស គួរឬ" ។

វីរិយសម្ពោជ្ឈង្គរមែងកើត សូម្បីដល់អ្នកពិចារណា **ភាពជាធំក្រៃលែងនៃជាតិ** យ៉ាងនេះថា "សូម្បីពោលអំពីជាតិ ឥឡូវនេះ លោកមិនជាអ្នកមានជាតិលាមក គឺប្រសូត្រក្នុងវង្សរបស់ព្រះបាទឱក្កាករាជ ដែលមានមកដោយមហាសម្មតិវង្ស ដែលមិនបែកញែកគ្នា (ខ្លួនលោក ក៏រាប់ថា) ជារាជនត្តារបស់ព្រះបាទសិរីសុទ្ធោ-ទនមហារាជ និងព្រះមហាមាយាទេវី ជាប្អូនរបស់ព្រះរាហុលដ៏ចម្រើន, ការដែលលោកជាជិនបុត្រប្រាកដដូច្នោះ ហើយជាអ្នកខ្ជិលច្រអូសសមគួរឬ" ។

វីរិយសម្ពោជ្ឈង្គរមែងកើតឡើង សូម្បីដល់អ្នកពិចារណា **ភាពជាធំក្រៃ-**

**លែងនៃសព្រហ្មចារី** (អ្នកប្រព្រឹត្តព្រហ្មចរិយធម៌ដូចគ្នា) យ៉ាងនេះថា "ព្រះសារីបុត្រ ព្រះមោគ្គលាន និងព្រះអសីតិមហាសាវ័កទាំងឡាយ សម្រេចលោកុត្តរធម៌បានដោយសេចក្ដីព្យាយាមប៉ុណ្ណោះ; ខ្លួនលោកនឹងដើរទៅតាមផ្លូវរបស់សព្រហ្មចារីទាំងនោះឬទេ" ។

កាលវៀរបុគ្គលអ្នកខ្ជិលច្រអូស គឺលះបង់សេចក្ដីព្យាយាមផ្លូវកាយ និងចិត្តដូចពស់ថ្លាន់ ស៊ីហើយដេកក្ដី, កាលសេពគប់បុគ្គលអ្នកមានសេចក្ដីព្យាយាម ដែលប្រារព្ធហើយ មានខ្លួនបញ្ជូនទៅក្ដី, មានចិត្តបង្អោនទៅ ឱនទៅ ទោរទៅ ដើម្បីឱ្យវីរិយៈកើតឡើងក្នុងឥរិយាបថទាំងឡាយ មានការឈរ និងការអង្គុយជាដើមក្ដី វីរិយសម្ពោជ្ឈង្គរមែងកើតឡើង។ ភិក្ខុនោះ រមែងដឹងច្បាស់ថា "ក៏ភាវនារបស់លោកដែលកើតឡើងហើយយ៉ាងនេះ រមែងបរិបូណ៌ដោយអរហត្តមគ្គ" ៕

## បីតិសម្ពោជ្ឈង្គ

បីតិសម្ពោជ្ឈង្គកើតឡើងយ៉ាងនេះថា **"ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយដែលជាទីតាំងនៃបីតិសម្ពោជ្ឈង្គមាន, ការធ្វើឱ្យច្រើននូវយោនិសោ-មនសិការក្នុងធម៌ទាំងនោះ, នេះជាអាហារដើម្បីឱ្យបីតិសម្ពោជ្ឈង្គ ដែលនៅមិនទាន់កើត ឱ្យកើតឡើង ឬថា រមែងប្រព្រឹត្តទៅដើម្បីការចម្រើនបរិបូណ៌ក្រៃលែងឡើង របស់បីតិសម្ពោជ្ឈង្គដែលកើតឡើងហើយ"** [១២៨] ។

---

[១២៨] សំ. ម. ។

ក្នុងសេចក្ដីនេះ បីតិនោះឯង ឈ្មោះថា ធម៌ជាទីតាំងនៃបីតិសម្ពោជ្ឈង្គ; ការធ្វើទុកក្នុងចិត្តដើម្បីឱ្យបីតិកើតឡើង ឈ្មោះថា យោនិសោមនសិការ ។

**ម្យ៉ាងទៀត ធម៌ ១១ ប្រការ រមែងប្រព្រឹត្តទៅដើម្បីការកើតឡើងនៃបីតិសម្ពោជ្ឈង្គ គឺ**

**១. ពុទ្ធានុស្សតិ** រឭករឿយៗ ដល់គុណព្រះពុទ្ធ

**២. ធម្មានុស្សតិ** រឭករឿយៗ ដល់គុណព្រះធម៌

**៣. សង្ឃានុស្សតិ** រឭករឿយៗ ដល់គុណព្រះសង្ឃ

**៤. សីលានុស្សតិ** រឭករឿយៗ ដល់គុណនៃសីល

**៥. ចាគានុស្សតិ** រឭករឿយៗ ដល់ការបរិច្ចាគទាន

**៦. ទេវតានុស្សតិ** រឭករឿយៗ ដល់ធម៌ដែលនាំឱ្យទៅកើតជាទេវតា

**៧. ឧបសមានុស្សតិ** រឭករឿយៗ ដល់សេចក្ដីស្ងប់

**៨. លូខបុគ្គលបរិវជ្ជនតា** វៀរបុគ្គលអ្នកមានចិត្តសៅហ្មង

**៩. សិនិទ្ធបុគ្គលសេវនតា** សេពគប់បុគ្គលអ្នកមានចិត្តផូរផង់

**១០. បសាទនីយសុត្តន្តបច្ចវេក្ខណតា** ពិចារណានូវព្រះសូត្រដែលជាទីតាំងនៃសេចក្ដីជ្រះថ្លា ។

**១១. តទធិមុត្តតា** បង្អោនចិត្តទៅក្នុងបីតិនោះ ។

ពិតមែន សូម្បីការរឭកដល់គុណព្រះពុទ្ធជាម្ចាស់ បីតិសម្ពោជ្ឈង្គក៏នឹងកើតឡើង ផ្សាយទៅរហូតដល់សរីរៈទាំងអស់ ដរាបដល់ឧបចារសមាធិ ។ សូម្បីការរឭកដល់គុណរបស់ព្រះធម៌ និងព្រះសង្ឃក៏ដូចគ្នា ។ កាលបព្វជិតពិចារណាចតុប្បារិ-

សុទ្ធិសីល ដែលរក្សាទុកមិនឱ្យដាច់ មិនឱ្យសៅហ្មងអស់កាលយូរក្តី, កាលគ្រហស្ថពិចារណាសីល ៥ សីល ១០ ក្តី, បីតិសម្ពោជ្ឈង្គរមែងកើតឡើង ។ កាលបព្វជិតពិចារណាដល់ចាគៈថា “យើងបានឱ្យភោជនដ៏ប្រណីត ដល់សព្រហ្មចារីយ៍” , សូម្បីគ្រហស្ថពិចារណាដល់ទានដែលថ្វាយហើយ ដល់អ្នកមានសីល ក្នុងកាលប្រាកដដូច្នោះក្តី, បីតិសម្ពោជ្ឈង្គ រមែងកើតឡើង។ ទេវតាប្រកបដោយគុណឯណា រមែងដល់ភាពជាទេវតា, សូម្បីក្នុងកាលពិចារណានូវគុណទាំងឡាយ ប្រាកដដូច្នោះ ដែលមាននៅក្នុងខ្លួន, បីតិសម្ពោជ្ឈង្គក៏កើតឡើង។ កាលកិលេសដែលគ្របសង្កត់ទុកដោយសមាបត្តិមាន សូម្បីក្នុងកាលពិចារណាថា “កិលេសទាំងឡាយមិនកើតឡើងរហូតដល់ ៦០ ឆ្នាំខ្លះ ៧០ ឆ្នាំខ្លះ” , បីតិសម្ពោជ្ឈង្គរមែងកើតឡើង ។ កាលវៀរបុគ្គលអ្នកមានចិត្តសៅហ្មង គឺមានសេចក្តីសៅហ្មងដែលសន្សំទុកហើយ ដោយមិនធ្វើសេចក្តីគោរពក្នុងការមើលចេតិយ មើលដើមពោធិ និងមើលព្រះថេរៈ ព្រោះមិនមានសេចក្តីជ្រះថ្លា ស្នេហា (ជាប់ចិត្ត) ក្នុងព្រះពុទ្ធជាដើម ដូចធូលីលើខ្នងលាក្តី, កាលសេពគប់បុគ្គលអ្នកផូរផង់ មានចិត្តទន់ ច្រើនទៅដោយសេចក្តីជ្រះថ្លាក្នុងព្រះពុទ្ធជាដើមក្តី, បីតិសម្ពោជ្ឈង្គក៏កើតឡើងបាន ។ កាលពិចារណាព្រះសូត្រដែលជាទីតាំងនៃសេចក្តីជ្រះថ្លា ដែលសម្តែងដល់គុណព្រះរតនត្រ័យក្តី, កាលមានចិត្តបង្អោនទៅ ឱនទៅ ទោរទៅ ដើម្បីឱ្យបីតិដែលកើតឡើងក្នុងឥរិយាបថទាំងឡាយ មានការឈរ និងការអង្គុយជាដើមក្តី, បីតិសម្ពោជ្ឈង្គក៏កើតឡើង ។ ភិក្ខុនោះ រមែងដឹងច្បាស់ថា “ភាវនារបស់លោកដែលកើតឡើងដោយអាការយ៉ាងនេះ រមែងបរិបូណ៌ដោយអរហត្តមគ្គ” ៕

## បស្សទ្ធិសម្ពោជ្ឈង្គ

បស្សទ្ធិសម្ពោជ្ឈង្គកើតឡើង យ៉ាងនេះថា “ម្នាលភិក្ខុទាំងឡាយ កាយបស្សទ្ធិ ចិត្តបស្សទ្ធិមាន, ការធ្វើឱ្យច្រើននូវយោនិសោមនសិការក្នុងធម៌នោះ, នេះជាអាហារដើម្បីឱ្យបស្សទ្ធិសម្ពោជ្ឈង្គ ដែលនៅមិនទាន់កើត ឱ្យកើតឡើង ឬថា រមែងប្រព្រឹត្តទៅព្រមដើម្បីការចម្រើនបរិបូណ៌ក្រៃលែងរបស់បស្សទ្ធិដែលកើតឡើងហើយ”[១២៩] ។

ម្យ៉ាងទៀត ធម៌ ៧ ប្រការ រមែងប្រព្រឹត្តទៅដើម្បីការកើតឡើងនៃបស្សទ្ធិសម្ពោជ្ឈង្គ គឺ

**១. បណីតភោជនសេវនតា** សេពភោជនដែលប្រណីត

**២. ឧតុសុខសេវនតា** សេពឧតុដែលសប្បាយ

**៣. ឥរិយាបថសុខសេវនតា** សេពឥរិយាបថដែលសប្បាយ

**៤. មជ្ឈត្តបយោគតា** ប្រកបព្យាយាមយ៉ាងកណ្ដាល

**៥. សារទ្ធកាយបុគ្គលបរិវជ្ជនតា** វៀរបុគ្គលដែលមានកាយរសាប់រសល់

**៦. បស្សទ្ធិកាយបុគ្គលសេវនតា** សេពគប់បុគ្គលអ្នកមានកាយស្ងប់

**៧. តទធិមុត្តតា** បង្អោនចិត្តទៅក្នុងបស្សទ្ធិនោះ ។

ពិតមែន ការបរិភោគភោជនដ៏ប្រណីតដែលជាទីសប្បាយ ដែលជាទីពេញចិត្តក្ដី, សេពឧតុដែលសប្បាយក្នុងរដូវទាំងឡាយ ដែលត្រជាក់ និងក្ដៅ និងសេព

---

[១២៩] សំ. ម. ។

តិរិយាបថទាំងឡាយ ដែលជាទីសប្បាយក្នុងតិរិយាបថទាំងឡាយ មានការឈរ និងអង្គុយជាដើមក្តី, បស្សទ្ធិសម្ពោជ្ឈង្គរមែងកើតឡើង។ តែថា បុគ្គលណាជាតិជាមហាបុរស រមែងជាអ្នកអត់ធន់ក្នុងឧតុ និងតិរិយាបថទាំងពួងបាន, លោកមិនបានពោលសំដៅយកបុគ្គល អ្នកជាមហាបុរសជាតិនោះ។ ភាវៈនៃបុគ្គលណា ជាអ្នកសភាគ និងវិសភាគមាន, កាលបុគ្គលនោះឯង វៀរឧតុ និងតិរិយាបថដែលជាវិសភាគ ហើយសេពនូវសភាគ បស្សទ្ធិសម្ពោជ្ឈង្គរមែងកើតឡើង។ ការពិចារណាកម្មស្សកតាទាំងរបស់ខ្លួនឯង និងរបស់អ្នកដទៃ លោកហៅថា ការប្រកបសេចក្តីព្យាយាមយ៉ាងកណ្តាល, បស្សទ្ធិសម្ពោជ្ឈង្គរមែងកើតដោយសេចក្តីព្យាយាម យ៉ាងកណ្តាលនោះឯង។ បុគ្គលណា ត្រាច់ទៅបៀតបៀនអ្នកដទៃដោយដុំដី និងកំណាត់ឈើជាដើម, សូម្បីវៀរបុគ្គលអ្នកមានកាយរសាប់រសល់ដូច្នោះ, បស្សទ្ធិសម្ពោជ្ឈង្គក៏កើតឡើង។ សូម្បីសេពគប់បុគ្គលអ្នកមានកាយស្ងប់ហើយ អ្នកមានដៃ និងជើងសង្រួមហើយ បស្សទ្ធិសម្ពោជ្ឈង្គ ក៏កើតឡើង សូម្បីដល់អ្នកមានចិត្តបង្អោនទៅឱនទៅ ទោរទៅ ដើម្បីឱ្យបស្សទ្ធិកើតក្នុងតិរិយាបថទាំងឡាយ មានការឈរ និងអង្គុយជាដើម។ ភិក្ខុនោះរមែងដឹងច្បាស់ថា "ភាវនារបស់ លោកដែលកើតឡើងហើយយ៉ាងនេះ រមែងបរិបូណ៌ដោយអរហត្តមគ្គ" ៕

## សមាធិសម្ពោជ្ឈង្គ

សមាធិសម្ពោជ្ឈង្គកើតឡើងយ៉ាងនេះថា “ម្នាលភិក្ខុទាំងឡាយ សមថ-និមិត្ត អព្យគ្គនិមិត្តមាន, ការធ្វើឱ្យច្រើននូវយោនិសោមនសិការក្នុងនិមិត្តនោះ, នេះជាអាហារដើម្បីឱ្យសមាធិសម្ពោជ្ឈង្គ ដែលនៅមិនទាន់កើតឡើង ឱ្យកើតឡើង ឬថា រមែងប្រព្រឹត្តទៅដើម្បីការចម្រើនបរិបូណ៌ក្រៃលែងឡើងរបស់សមាធិសម្ពោជ្ឈង្គដែលកើតឡើងហើយ” ។ ក្នុងសេចក្តីនេះ សមថៈនោះឯង ឈ្មោះថា សមថនិមិត្ត, និងឈ្មោះថា អព្យគ្គនិមិត្ត ព្រោះអត្ថថា មិនរវើរវាយ ។

ម្យ៉ាងទៀត ធម៌ ១១ ប្រការ រមែងប្រព្រឹត្តទៅដើម្បីការកើតឡើងនៃសមាធិសម្ពោជ្ឈង្គ គឺ

**១. វត្ថុវិសទកិរិយតា** ការធ្វើវត្ថុឱ្យស្អាត

**២. ឥន្ទ្រិយសម្មត្តបដិបាទនតា** តម្រូវឥន្ទ្រិយឱ្យស្មើគ្នា

**៣. និមិត្តកុសលតា** ភាពជាអ្នកឆ្លាតក្នុងនិមិត្ត

**៤. សមយេ ចិត្តស្ស បគ្គហណតា** ការលើកចិត្តក្នុងសម័យ

**៥. សមយេ ចិត្តស្ស និគ្គហណតា** ការគ្របសង្កត់ចិត្តក្នុងសម័យ

**៦. សមយេ សម្បហំសនតា** ការឱ្យចិត្តរីករាយក្នុងសម័យ

**៧. សមយេ អជ្ឈុបេក្ខនតា** ការដាក់ចិត្តព្រងើយៗ ក្នុងសម័យ

**៨. អសមាហិតបុគ្គលបរិវជ្ជនតា** វៀរបុគ្គលអ្នកមានចិត្តមិនតាំងមាំ

**៩. សមាហិតបុគ្គលសេវនតា** សេពគប់បុគ្គលអ្នកមានចិត្តតាំងមាំ

**១០. ឈានវិមោក្ខបច្ចវេក្ខណតា** ពិចារណាឈានវិមោក្ខ

**១១. តទធិមុត្តតា** បង្អោនចិត្តទៅក្នុងសមាធិនោះ ។

ក្នុងធម៌ទាំងនោះ ពាក្យថា **"ការធ្វើវត្ថុឱ្យស្អាត និងក្នុងការតម្រូវឥន្ទ្រិយឱ្យស្មើគ្នា** គប្បីជ្រាបដោយន័យដូចពោលហើយនោះឯង ។ ភាពជាអ្នកឆ្លាតក្នុងការរៀនយកនូវកសិណនិមិត្ត ឈ្មោះថា **ភាពជាអ្នកឆ្លាតក្នុងនិមិត្ត** ។ ពាក្យថា **"ការលើកចិត្តក្នុងសម័យ"** បានដល់ **ក្នុងសម័យណា** ចិត្តរួញរាដោយសេចក្តីព្យាយាមដែលធូររលុងពេកទៅជាដើម, សម័យនោះ ត្រូវលើកចិត្តនោះ ឱ្យតាំងឡើងដោយធម្មវិចយៈ វិរិយៈ និងបីតិសម្ពោជ្ឈង្គ ។ ពាក្យថា **"ការគ្របសង្កត់ចិត្តក្នុងសម័យ"** គឺក្នុងសម័យណា ចិត្តរវើរវាយ ដោយការប្រារព្ធសេចក្តីព្យាយាមពេកទៅជាដើម, សម័យនោះ ត្រូវគ្របសង្កត់ចិត្តនោះ ឱ្យតាំងឡើងដោយបស្សទ្ធិសម្ពោជ្ឈង្គ និងឧបេក្ខាសម្ពោជ្ឈង្គ ។ បទថា **"ការឱ្យចិត្តរីករាយក្នុងសម័យ"** គឺក្នុងសម័យណា មិនមានអស្សាទៈ (គឺមិនមានសេចក្តីពេញចិត្ត) ព្រោះភាពជាអ្នកប្រកបដោយបញ្ញាទន់ខ្សោយ ឬព្រោះមិនសម្រេចសេចក្តីសុខ ដែលកើតអំពីការចូលទៅស្ងប់, សម័យនោះ ត្រូវឱ្យចិត្តសង្វេគដោយការពិចារណាសង្វេគវត្ថុ ៨ ប្រការ ។ **ឈ្មោះថា សង្វេគវត្ថុ ៨ ប្រការ** គឺ ជាតិ ជរា ព្យាធិ និងមរណៈរួមជា ៤, អបាយទុក្ខជាទី ៥, វដ្តមូលកទុក្ខក្នុងអតីតៈជាទី ៦, វដ្តមូលកទុក្ខក្នុងអនាគតជាទី ៧, អាហារបរិយេដ្ឋិមូលកទុក្ខក្នុងបច្ចុប្បន្នជាទី ៨ ។ ឯការញុំាងសេចក្តីជ្រះថ្លាឱ្យកើតឡើង ដោយការរឭកដល់ព្រះរតនត្រ័យ, នេះលោកហៅថា ការញុំាងចិត្តឱ្យរីករាយក្នុងសម័យ ។ ឈ្មោះថា ការដាក់ចិត្តព្រងើយៗ ក្នុងសម័យ គឺក្នុងសម័យណា ចិត្តមិនរួញរា មិនរវើរវាយ មានអស្សាទៈដំណើរទៅក្នុងសមថវីថិប្រព្រឹត្តទៅដោយ

សេចក្តីពេញចិត្តក្នុងអារម្មណ៍ ព្រោះអាស្រ័យការបដិបត្តិដោយប្រពៃ, សម័យនោះ មិនត្រូវខ្វល់ខ្វាយ ក្នុងការលើក ការគ្របសង្កត់ និងក្នុងការញ៉ាំងចិត្តឱ្យរីករាយ ប្រៀបដូចសារថីមិនត្រូវខ្វល់ខ្វាយក្នុងសេះទាំងឡាយ ដែលត្រាច់ទៅល្អហើយ; ព្រោះហេតុនោះ ទើបលោកហៅថា ការដាក់ចិត្តព្រងើយៗ ក្នុងសម័យ។ ឈ្មោះថា **ការវៀរ បុគ្គលអ្នកមានចិត្តមិនតាំងមាំ** គឺវៀរឆ្ងាយចាកបុគ្គលមានចិត្តរវើរវាយ គឺមិនសម្រេចឧបចារៈ ឬអប្បនា។ ឈ្មោះថា **ការសេពបុគ្គលមានចិត្តតាំងមាំ គឺការសេព ការគប់ ការចូលទៅសេពបុគ្គលមានចិត្តតាំងមាំ ដោយឧបចារៈ និងអប្បនា**; ឈ្មោះថា **ការបង្អោនចិត្តទៅក្នុងសមាធិនោះ** គឺភាពជាអ្នកមានចិត្តបង្អោនទៅ ទោរទៅ ដើម្បីឱ្យសមាធិកើតឡើង ក្នុងឥរិយាបថទាំងឡាយ មានការឈរ និងការអង្គុយជាដើម ។ ព្រោះសមាធិសម្ពោជ្ឈង្គនោះ រមែងកើតឡើងដល់អ្នកបដិបត្តិហើយយ៉ាងនេះ ទើបភិក្ខុនោះដឹងច្បាស់ថា "ភាវនារបស់លោកដែលកើតឡើងហើយយ៉ាងនេះ រមែងបរិបូណ៌បានដោយអរហត្តមគ្គ" ៕

## ឧបេក្ខាសម្ពោជ្ឈង្គ

ឧបេក្ខាសម្ពោជ្ឈង្គ កើតឡើងយ៉ាងនេះថា **"ម្នាលភិក្ខុទាំងឡាយ ធម៌ទាំងឡាយ ដែលជាទីតាំងនៃឧបេក្ខាសម្ពោជ្ឈង្គ, ការធ្វើឱ្យច្រើននូវយោនិសោមនសិការក្នុងធម៌នោះ, នេះជាអាហារ ដើម្បីឱ្យកើតឧបេក្ខាសម្ពោជ្ឈង្គ ដែលនៅមិនកើត ឱ្យកើតឡើង ឬថា រមែងប្រព្រឹត្តទៅដើម្បីសេចក្តីចម្រើន**

បរិបូណ៌ក្រៃលែង នៃឧបេក្ខាសម្ពោជ្ឈង្គដែលកើតឡើងហើយ ក៏កើតឡើង” [១៣០] ។ ក្នុងសេចក្ដីនេះ ឧបេក្ខានោះឯង ឈ្មោះថា ធម៌ជាទីតាំងនៃឧបេក្ខាសម្ពោជ្ឈង្គ ។

ម្យ៉ាងទៀត ធម៌ ៥ ប្រការ រមែងប្រព្រឹត្តទៅដើម្បីការកើតឡើងនៃឧបេក្ខាសម្ពោជ្ឈង្គ គឺ

**១. សត្តមជ្ឈត្តតា** ការព្រងើយក្នុងសត្វ

**២. សង្ខារមជ្ឈត្តតា** ការព្រងើយក្នុងសង្ខារ

**៣. សត្តសង្ខារកេលាយនបុគ្គលបរិវជ្ជនតា** វៀរអ្នកប្រកាន់នូវសត្វ និងសង្ខារ

**៤.សត្តសង្ខារមជ្ឈត្តបុគ្គលសេវនតា** ការសេពគប់បុគ្គលអ្នកមានចិត្ត ព្រងើយក្នុងសត្វ និងសង្ខារ ។

**៥. តទធិមុត្តតា** បង្អោនចិត្តទៅក្នុងឧបេក្ខានោះ ។

បណ្ដាធម៌ទាំងនោះ **ការព្រងើយក្នុងសត្វ** រមែងតាំងឡើងដោយអាការ ២ យ៉ាង គឺដោយការពិចារណាកម្មស្សកតា យ៉ាងនេះថា “ខ្លួនលោកមកដោយកម្មរបស់ខ្លួនហើយ នឹងទៅដោយកម្មរបស់ខ្លួននោះឯង, សូម្បីបុគ្គលដទៃនោះ ក៏មកដោយកម្មរបស់ខ្លួន ហើយនឹងទៅដោយកម្មរបស់ខ្លួនដូចគ្នា, លោកស្រឡាញ់គ្នាដូចម្ដេចទៅ” និងដោយការពិចារណានិស្សត្តយ៉ាងនេះថា “ពោលដោយបរមត្ថ សត្វមិនមានទេ, លោកឯងស្រឡាញ់អ្នកណាទៅ” ។

**ការព្រងើយក្នុងសង្ខារ** រមែងតាំងឡើងដោយអាការ ២ យ៉ាង គឺដោយ

---

[១៣០] ក៏រមែងកើតឡើង ។

ការពិចារណាដោយភាពជាវត្ថុដែលមិនមានម្ចាស់របស់ យ៉ាងនេះថា “ចីវរនេះចូលដល់ការប្រែប្រួលទៅនៃពណ៌ដោយលំដាប់ នឹងចូលដល់ភាពជារបស់គ្រាំគ្រាហើយ នឹងជាកំណាត់សំពត់សម្រាប់ជូតជើងហើយ ក៏នឹងជារបស់ដែលគេត្រូវយកចុងឈើច្រត់ផ្ដិះចោលទៅ; ក៏បើថា ម្ចាស់របស់ចីវរគប្បីមាននោះ, ម្ចាស់របស់នោះ ក៏នឹងមិនគប្បីឱ្យចីវរនោះវិនាសទៅយ៉ាងនេះ” និងដោយការពិចារណា ដោយសេចក្ដីជារបស់ម្ដងម្កាល (របស់ខ្ចីគេ) យ៉ាងនេះថា “ចីវរនេះ ជារបស់មិនយឺនយូរ ជារបស់ម្ដងម្កាល”។ មា្យ៉ងទៀត ក្នុងចីវរ យ៉ាងណា, គប្បីធ្វើការប្រកប (យោជនា) សូម្បីក្នុងបរិក្ខារទាំងឡាយ មានបាត្រជាដើម យ៉ាងនោះចុះ ។

ក្នុងបទថា “**ការវៀរបុគ្គលអ្នកប្រកាន់សត្វ និងសង្ខារ**” នេះ អធិប្បាយថា បុគ្គលណាជាគ្រហស្ថ រមែងប្រកាន់បុត្រធីតាជាដើម របស់ខ្លួននោះឯងថា ជារបស់យើង, ឬថាជាបព្វជិតរមែងប្រកាន់អន្តេវាសិក និងឧបជ្ឈាយ៍ជាដើមថា “ជារបស់យើង” បុគ្គលនោះរមែងធ្វើការទាំងឡាយ មានការកោរសក់ ដេរចីវរ បោកគក់ ជ្រលក់ និងការដុតបាត្រជាដើម ឱ្យដល់អ្នកនោះ, កាលមិនឃើញជនជាទីស្រឡាញ់នោះ សូម្បីត្រឹមតែមួយភ្លែត ក៏គិតថា សាមណេររូបឯណោះទៅណា, ភិក្ខុកំលោះរូបឯណោះទៅណា” និងក្រឡេកមើលខាងឯណេះ ខាងឯណោះដូចជាម្រឹគស្ទុន (ថ្លាង) បែរទៅខាងណេះ ខាងណោះ ក្រឡេកមើល (ប្រយ័ត្នភ័យ) សូម្បីត្រូវអ្នកដទៃសួរថា “សូមលោកបញ្ជូនអ្នកនេះទៅ ដើម្បីប្រយោជន៍ជួយក្នុងការកាត់សក់ជាដើមមួយភ្លែត” ក៏រមែងមិនឱ្យដោយពោលថា “ពួកយើងនៅមិនឱ្យគេធ្វើការងារ សូម្បីរបស់ពួកយើងដើម្បីខ្លួន, លោកនាំគេទៅនឹងឱ្យគេលំបាក”, នេះ

ឈ្មោះថា **ការប្រកាន់សត្វ** ។

ចំណែកបុគ្គលណា រមែងប្រកាន់វត្ថុទាំងឡាយមានចីវរ បាត្រ ថង់បាត្រ (ស្លោក) និងឈើច្រត់ (របស់) មនុស្សចាស់ជាដើមថា "ជារបស់យើង", បុគ្គលនោះ រមែងមិនឱ្យបុគ្គលដទៃពាល់ត្រូវសូម្បីដោយដៃ, សូម្បីកាលមនុស្សដទៃ សូមខ្ចីម្តង ក៏ពោលថា "សូម្បីយើងក៏ថ្នមវត្ថុនេះ មិនប្រើប្រាស់, យើងនឹងឱ្យលោក ដូចម្តេចបាន" ; នេះឈ្មោះថា **ការប្រកាន់សង្ខារ** ។

តែថាបុគ្គលណាដាក់ខ្លួនជាកណ្តាល គឺព្រងើយក្នុងវត្ថុសូម្បីទាំងពីរ (គឺសត្វ និងសង្ខារ) នោះ, នេះឈ្មោះថា **ការព្រងើយក្នុងសត្វ និងសង្ខារ** ។ ឧបេក្ខាសម្ពោជ្ឈង្គរមែងកើតឡើងដល់បុគ្គលអ្នកវៀរឆ្ងាយចាកបុគ្គលអ្នកប្រកាន់សត្វ និងសង្ខារដូច្នេះខ្លះ, រមែងកើតឡើងដល់អ្នកសេពគប់បុគ្គល ដែលព្រងើយក្នុងសត្វ និងសង្ខារខ្លះ, រមែងកើតដល់អ្នកមានចិត្តបង្អោនទៅ ទោរទន់ទៅ ឱនទៅ ទេរទៅ ដើម្បីឱ្យឧបេក្ខានោះកើតឡើង ក្នុងឥរិយាបថទាំងឡាយ មានការឈរ និងការអង្គុយជាដើមខ្លះ ដូចពណ៌នាមកដូច្នេះ។ ភិក្ខុនោះរមែងដឹងច្បាស់ថា "ភាវនារបស់លោកដែលកើតឡើងហើយយ៉ាងនេះ រមែងបរិបូណ៌ដោយអរហត្តមគ្គ"។ ពាក្យដ៏សេសក្នុងទីទាំងពួង មានអត្ថងាយទាំងអស់នោះឯង ៕

## ចប់អដ្ឋកថាពោជ្ឈង្គបព្វ

សូម្បីក្នុងបព្វទាំងពីរ (គឺនីវរណបព្វ និងពោជ្ឈង្គបព្វ) នេះ លោកក៏ពោលថា ជាវិបស្សនាសុទ្ធៗ ដែរ ។ ដោយប្រការដែលពណ៌នាមក **សតិបដ្ឋាន ៤** នេះ

រមែងបានក្នុងចិត្តផ្សេងៗ ក្នុងចំណែកខាងដើម; ព្រោះថា ព្រះយោគាវចរកំណត់កាយដោយចិត្តម្យ៉ាង, កំណត់វេទនាដោយចិត្តម្យ៉ាង, កំណត់ចិត្តដោយចិត្តម្យ៉ាង, កំណត់ធម៌ទាំងឡាយដោយចិត្តម្យ៉ាង, តែក្នុងខណៈនៃលោកុត្តរមគ្គ រមែងបានចិត្តតែម្យ៉ាងដូចគ្នាមែនពិត ។ ពិតមែន សតិសម្បយុត្តដោយវិបស្សនារបស់ព្រះយោគាវចរ អ្នកកំណត់កាយមកតាំងពីដើម ឈ្មោះថា **កាយានុបស្សនា**, បុគ្គលអ្នកប្រកបដោយសតិនោះ ឈ្មោះថា **កាយានុបស្សី** ។ សតិដែលសម្បយុត្តដោយមគ្គ ក្នុងខណៈនៃមគ្គរបស់ព្រះយោគាវចរ ដែលខ្វល់ខ្វាយវិបស្សនា ហើយសម្រេចអរិយមគ្គ ឈ្មោះថា **កាយានុបស្សនា**, បុគ្គលដែលប្រកបដោយសតិនោះ ឈ្មោះថា **កាយានុបស្សី** ។ សតិដែលសម្បយុត្តដោយវិបស្សនា របស់ព្រះយោគាវចរដែលកំណត់វេទនា, កំណត់ចិត្ត និងកំណត់ធម៌ទាំងឡាយមកហើយ ឈ្មោះថា **វេទនានុបស្សនា, ចិត្តានុបស្សនា, ធម្មានុបស្សនា**, បុគ្គលដែលប្រកបដោយសតិនោះ ឈ្មោះថា **វេទនានុបស្សី, ចិត្តានុបស្សី, ធម្មានុបស្សី** ។ សតិដែលសម្បយុត្តដោយមគ្គ ក្នុងខណៈនៃមគ្គ របស់ព្រះយោគាវចរដែលខ្វល់ខ្វាយ ក្នុងវិបស្សនា ហើយសម្រេចអរិយមគ្គ ឈ្មោះថា **វេទនានុបស្សនា, ចិត្តានុបស្សនា, ធម្មានុបស្សនា** ។ បុគ្គលដែលប្រកបដោយសតិនោះ ឈ្មោះថា **វេទនានុបស្សី, ចិត្តានុបស្សី, ធម្មានុបស្សី** ៕

## ចប់ទេសនាបុគ្គលាធិដ្ឋានត្រឹមតែប៉ុណ្ណេះ

ក៏សតិដែលកំណត់កាយ លះវិបល្លាសក្នុងកាយថា “ជារបស់ល្អ” រមែង

សម្រេចដោយមគ្គ ព្រោះហេតុនោះ ទើបសតិនោះ ឈ្មោះថា **កាយានុបស្សនា**។ សតិកំណត់វេទនា លះវិបល្លាសក្នុងវេទនាថា "ជាសុខ" រមែងសម្រេចដោយមគ្គ ព្រោះហេតុនោះ សតិនោះ ទើបឈ្មោះថា **វេទនានុបស្សនា**។ សតិកំណត់ចិត្ត លះវិបល្លាសក្នុងចិត្តថា "ជាសភាពទៀង" រមែងសម្រេចដោយមគ្គ ព្រោះហេតុនោះ ទើបសតិនោះ ឈ្មោះថា **ចិត្តានុបស្សនា**។ សតិកំណត់ធម៌ លះវិបល្លាសក្នុងធម៌ទាំងឡាយថា "ជាអត្តា" រមែងសម្រេចដោយមគ្គ ព្រោះហេតុនោះ ទើបសតិនោះ ឈ្មោះថា **ធម្មានុបស្សនា**។ ដោយប្រការដូច្នេះ សតិដែលសម្បយុត្តដោយមគ្គតែម្យ៉ាងប៉ុណ្ណោះ រមែងបានឈ្មោះ ៤ យ៉ាង ព្រោះអត្ថថា ញុំាងកិច្ច ៤ ឱ្យសម្រេច, ព្រោះហេតុនោះ ទើបព្រះមានព្រះភាគត្រាស់ថា "ក៏ក្នុងខណៈនៃមគ្គសតិបដ្ឋាន ៤ រមែងបានក្នុងចិត្តតែម្យ៉ាងប៉ុណ្ណោះ" ៕

ចប់ការពណ៌នាអំពីសុត្តន្តភាជនិយ

## ពណ៌នាអំពីអភិធម្មភាជនិយ

សូម្បីសតិបដ្ឋានទាំងអស់ មានកាយានុបស្សនាសតិបដ្ឋានជាដើម ព្រះមានព្រះភាគទ្រង់សម្តែងត្រឹមតែគោលន័យរបស់ទេសនា ដែលចែកហើយក្នុងធម្មសង្គណី, តែទ្រង់មិនបានតាំងទុកជាបែបផែន ដូចក្នុងលោកិយសតិបដ្ឋានទាំងឡាយមានកាយជាដើម ជាអារម្មណ៍ទេ ព្រោះអភិធម្មភាជនិយ ទ្រង់ប្រារព្ធទេសនាដោយអំណាចនៃលោកុត្តរសតិបដ្ឋាន ។ គប្បីជ្រាបប្រភេទន័យក្នុងអភិធម្មភាជនិយ ។ **គឺយ៉ាងណា ?** គឺក្នុងការតាំងមាំ ដោយឈានក្នុងសោតាបត្តិមគ្គនៃកាយានុបស្សនា

ជាមុន មាន ១០ ន័យ ដោយអំណាចនៃចតុក្កៈ និងបញ្ចកៈយ៉ាងនីមួយៗ ២ ក្នុងឋាន ៥ នេះ គឺ សុទ្ធិកបដិបទា, សុទ្ធិកសុញ្ញតា, សុញ្ញតបដិបទា, សុទ្ធិកអប្បណិហិតៈ និងអប្បណិហិតបដិបទា (រួមជាចតុក្កៈ ៥ ន័យ និងបញ្ចកៈ ៥ ន័យ)។ សូម្បីក្នុងន័យទាំងឡាយដែលនៅសល់ ក៏ដូច្នោះដែរ គឺក្នុងការតាំងមាំ ២០ មាន ២០០ ន័យ ។ ២០០ ន័យ នោះ គុណដោយអធិបតី ៤ ក៏ត្រូវជា ៨០០ ន័យ ។ សូម្បីន័យទាំងអស់ ទើបមាន ១.០០០ ន័យ គឺ សុទ្ធិកៈ ២០០ ន័យ និងអធិបតី ៨០០ ន័យ ដោយប្រការដូច្នេះឯង ។ ក៏ក្នុងសុទ្ធិកសតិបដ្ឋាន ក្នុងវេទនានុបស្សនា-សតិបដ្ឋានជាដើម ក៏ដូចគ្នា គឺក្នុងសោតាបត្តិមគ្គមាន ៥.០០០ ន័យ ។ ម្យ៉ាងទៀត ក្នុងសោតាបត្តិមគ្គយ៉ាងណា, សូម្បីក្នុងមគ្គដ៏សេស ក៏ដូច្នោះដែរ គឺក្នុងកុសលមាន ២០.០០០ ន័យ។ តែពោលដោយប្រភេទនៃសុញ្ញតៈ និងអប្បណិហិតនិមិត្ត ក្នុងវិបាកជាត្រីគុណ អំពីន័យនៃកុសលនោះ ទើបជា ៦០.០០០ ន័យ, និទ្ទេសនៃអភិធម្មភាជនិយមាន ២ យ៉ាង ដោយអំណាចនៃសតិបដ្ឋាននិទ្ទេស ដែលជាកុសល និងវិបាក គឺជាការញ៉ាំងខ្លួនឱ្យសម្រេចម្យ៉ាង, ជាកិច្ចដែលសម្រេចដោយល្អម្យ៉ាង មាន ១០ ប្រភេទ ដោយអំណាចនៃនិទ្ទេសវារៈ ១០ គឺខាងកុសល ៥ និងខាងវិបាក ៥ ដោយអំណាចនៃកាយានុបស្សនាជាដើម និងដោយអំណាចនៃសុទ្ធិកៈ ដែលប្រដាប់ហើយដោយន័យ ៨០.០០០ ន័យ យ៉ាងនេះ ដោយប្រការដូច្នេះ ៕

**ពណ៌នាអំពីអភិធម្មភាជនិយចប់**

## ពណ៌នាអំពីបញ្ហាបុច្ឆកៈ

ក្នុងបញ្ហាបុច្ឆកៈ គប្បីជ្រាបសេចក្តីដែលសតិបដ្ឋានជាកុសលជាដើម ដោយទំនងនៃព្រះបាលីនោះឯង ។ ក៏ក្នុងអារម្មណត្តិកៈ សូម្បីសតិបដ្ឋានទាំងអស់នោះ ជាអប្បមាណារម្មណ៍ប៉ុណ្ណោះ ព្រោះប្រារព្ធព្រះនិព្វានដែលជាអប្បមាណធម៌ ហើយប្រព្រឹត្តទៅ, មិនជាមគ្គារម្មណ៍; តែជាមគ្គហេតុកៈដោយអំណាចនៃសហជាតហេតុ ។ ជាមគ្គាធិបតីក្នុងការចម្រើនមគ្គ ព្រោះធ្វើវីរិយៈ ឬវីមំសា ឱ្យជាប្រធាន, មិនគប្បីពោលថា ជាមគ្គាធិបតី ព្រោះចម្រើនមគ្គដែលធ្វើឆន្ទៈ ឬចិត្តឱ្យជាប្រធាន សូម្បីក្នុងកាលនៃផល ក៏មិនគប្បីពោលដូចគ្នា។ ក្នុងអតីតៈជាដើម ក៏មិនគប្បីពោលដោយភាពជាឯការម្មណ៍ ។ តែព្រោះសភាវៈនៃព្រះនិព្វាន ជាពហិទ្ធធម៌ ទើបឈ្មោះថាពហិទ្ធារម្មណ៍ ។ សតិបដ្ឋានព្រះមានព្រះភាគត្រាស់ថា ជាលោកុត្តរ ដែលសម្រេចហើយ ក្នុងបញ្ហាបុច្ឆកៈនេះឯង ដោយប្រការដូច្នេះ ។ ពិតមែន ព្រះសម្មាសម្ពុទ្ធត្រាស់សតិបដ្ឋានដែលជាលោកិយ និងលោកុត្តរ លាយគ្នាទុកក្នុងសុត្តន្តភាជនិយនោះឯង, តែក្នុងអភិធម្មភាជនិយ និងបញ្ហាបុច្ឆកៈនេះ ព្រះមានព្រះភាគត្រាស់ថាជាលោកុត្តរតែម្យ៉ាង ។ សូម្បីសតិបដ្ឋានវិភង្គនេះ ព្រះមានព្រះភាគក៏នាំចេញមកចែកសម្តែងហើយ ៣ បរិវដ្ដ (៣ ផ្នែក គឺសុត្តន្តភាជនិយ អភិធម្មភាជនិយ និងបញ្ហាបុច្ឆកៈ) ដូចបានពណ៌នាមកដូច្នេះឯង ។

**ចប់ពណ៌នាអំពីបញ្ហាបុច្ឆកៈ**

**ចប់អដ្ឋកថាសតិបដ្ឋានវិភង្គ**

**សម្មោហវិនោទនី អដ្ឋកថាព្រះអភិធម្មបិដក**

**ទុតិយភាគ ៦ ចប់**

បោះពុម្ពលើកទី ២
រក្សាសិទ្ធិ (ហាមថតចម្លង)